INSTITUT
DE CIVILISATION
INDIENNE
N° D 2116

ព្រះរាជបណ្ណាល័យកម្ពុជា

# CAMPUCHÉA SAURIYA

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់បួន

ខ្សែ ៧ ដល់ខ្សែ ១២ រួមគ្នា

កុម្ស៊ីយសេនាបតីបានអនុញ្ញាតហើយ

PER
933

ក្រុងភ្នំពេញ
រោងពុម្ពអាល់បែរពរទៃ
គ្រិ. ឆ្នាំ ១៩៣២
ពុ. ស. ២៤៧៤

ÉCOLE FRANÇAISE
BIBLIOTHÈQUE
D'EXTRÊME ORIENT

អ្នកទទួលខុសត្រូវ : ជុំ-មៅ

# បញ្ជីរឿង


ទំព័រ

១ រឿងមិលិន្ទបញ្ហា ព្រះឧត្តមមុនី អ៊ុម-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យកម្ពុជា ប្រែចេញពីបាឡីមកជាភាសាខ្មែរ (ត) . . . . . . . . . . . . . . . ៣

២ អំពីសេះពលាហ គាថាសំអាងរបស់លោក វិកទ័រកោលូបេហ្វ សមាជិកសាលាបារាំងសែសនៅចុងបូព៌ាប្រទេស ក្រម្ការអ៊ុំ-ម៉ៅ ជាអ្នកតែងសេចក្ដីក្នុងព្រះរាជបណ្ណាល័យប្រែជាភាសាខ្មែរ (ត-ចប់) . . . . . . . . . . . . . . ១១៣

៣ ឧប្បត្តិកថា, វិតក្កបញ្ហា និងមលគរបញ្ហា ព្រះស្រីសម្មតិវង្ស (ឯម) ជាងហ្វាងសាលាបាឡីជាន់ខ្ពស់ ប្រែចេញពីបាឡីគម្ពីរលោកនេយ្យជាតកជាភាសាខ្មែរ . . ១២៤

៤ បាយាសិរាជញ្ញសូត្រ ព្រះមហា ននូ វត្តប្រាង្គណ៌ (ឧត្តុង្គ-កំពង់ស្ពឺ) ប្រែពីបាឡីមកជាភាសាខ្មែរ . . . . . . . . . . . . . . . . . . . . ២១៤

៥ សុគន្ធជាតក ព្រះញាណវិរិយ ឡុង អាចារ្យសាលាបាឡីជាន់ខ្ពស់ ប្រែពីបាឡីគម្ពីរបញ្ញាសជាតកមកជាភាសាខ្មែរ . . . . . . . . . . . . . . ២៨២

៦ រតនបជោតជាតក, ព្រះឧត្តមមុនី (អ៊ុម-ស៊ូរ) អាចារ្យព្រះរាជបណ្ណាល័យកម្ពុជា ប្រែចេញពីបាឡីគម្ពីរបញ្ញាសជាតកមកជាភាសាខ្មែរ . . . . . . . ៣៦១

៧ ខេមាខេមសរណាគមនកថា, លោកឈិម-សុំ សិស្សឆ្នាំទី ៥ នៅសាលាបាឡីជាន់ខ្ពស់រៀបរៀង, ព្រះស្រីសម្មតិវង្ស (ឯម) ជាងហ្វាងសាលានេះបានពិនិត្យផ្ទៀងផ្ទាត់ . . . . . . . . . . . . . . . . . . . . . . ៣៩៨

៨ មួយរយហាសិបមួយថ្ងៃ នៅមាត់ឈូងសមុទ្រសៀម ពាក្យកាព្យរបស់ជីតិមហាក់ ធ្វើពក្ការនៅទីប្រែស្ដី ប៉ុស្ដិ៍មេមត់ (កំពង់ចាម) . . . . . . . ៤១៩

៩ រឿងមហាភារតយុទ្ធ ព្រះមហាពិទូរក្រសេមកន្ទរបនបណ្ឌិត នៅព្រះរាជបណ្ណាល័យ ប្រែពីភាសាសៀមមកជាភាសាខ្មែរ (ត-ចប់) . . . . . . . . . ៤៣០


# រូបប្រតិពម្ព


រូបសេះឡាលភ្ញាំនៅទីព្រះលានប្រាសាទអង្គរធំ . . . . . . . . . . . . ១១៤

រឿងសេះពលាហនៅស្រុកមង្គល (សព្វថ្ងៃនៅសារមន្ទីរក្រុងកាល់គុត្តា) . . . ១១៨

រឿងសេះពលាហនៅស្រុកអជណ្ដា . . . . . . . . . . . . . . . . ១១៩

រឿងសេះពលាហនៅព្រះវិហារអានន្ទស្រុកភូមា . . . . . . . . . . . . ១២២

# TABLE DES MATIÈRES

Pages

1° Les questions du Roi Milinda, traduites du Pâli en Cambodgien par le Vénérable Préas Uttama Munî (Oum-Sou), Achar à la Bibliothèque Royale (suite).. 3

2° Le Cheval Balâha par Victor Goloubew, Membre de l'École Française d'Extrême-Orient, traduit en Cambodgien par le Kromokar Chou m-Mau, Rédacteur de la Bibliothèque Royale (suite et fin)............ 113

3° Uppattikathâ, Vitaka pañhâ et Malatara pañhâ, extraits de Lokanaya Jâtaka et traduits du Pâli en Cambodgien par le Vénérable Préas Srey Samuttivong Em, Directeur de l'École Supérieure de Pâli............ 124

4° Pâyâsirâjañña Sûtra, traduit du Pâli en Cambodgien par feu Mahâ Nanda de Vat Prang (Oudong-Kg.-Speu). 214

5° Sutadhanu Jâtaka (Paññâsa Jâtaka) traduit du Pâli en Cambodgien par feu Préas Nhéan Viriya Long...... 282

6° Ratanapajota Jâtaka (Paññâsa Jâtaka) traduit du Pâli en Cambodgien par le Vénérable Préas Uttama Munî (Oum Sou), Achar à la Bibliothèque Royale......... 361

7° Khemâkhema Saranagamana Kathâ, par le bonze Chhim Sou, étudiant en 5e année de l'École Supérieure de Pâli, revu et corrigé par le Vénérable Préas Srey Samuttivong Em, Directeur de ladite École......... 398

8° Cent cinquante et un jours au bord de golfe de Siam, poème rédigé par M. Kim-Hak, Secrétaire des Postes et Télégraphes à Mémot (Kompong-Cham)......... 419

9° Mahâbhârata, traduit du Siamois en Cambodgien par Préas Maha Pitou Krasém, pandit à la Bibliothèque Royale (suite et fin)......................... 430

## ILLUSTRATIONS :

Cheval à cinq têtes de la Terrasse Royale, Angkor Thom (H. 2 m 50)............................ 114

Légende du cheval Balâha-Mathmâ (Musée de Calcutta). 118

Légende du Cheval Balâha-Ajantâ..................... 119

Légende du Chaval Balâha-Tampie d'Ananda, Pagan.. 122

# រឿងមិលិន្ទបញ្ហា

ព្រះឧត្តមមុនី អ៊ុំ-ស៊ូរ អាចារ្យនៅព្រះរាជបណ្ណាល័យកម្ពុជា

## ប្រែពីភាសាបាលីមកជាភាសាខ្មែរ

( គ )

ម. ឧបមំករោហិ សូមលោកម្ចាស់ឧបមានូវឧបសម្បទ-កម្មរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នេះជាសេចក្ដីឲ្យទូលាយងាយស្ដាប់បន្តិចទៅមើល ។

ន. យថាឯវមហារាជ បពិត្រមហារាជ ឯព្រះសម្មា-សម្ពុទ្ធដែលព្រះអង្គទ្រង់បាននូវឧបសម្បទយ៉ាងនេះ គឺថាព្រះ-អង្គស្ដេចដល់នូវទីជាទីបំផុតខាងលើទី ១ ហើយនឹតអ្នកឯណានឹងអាចឡើងទៅខាងលើទីដែលព្រះអង្គបានដល់នោះឡើយ ប្រៀបដូចព្រះរាជសម្ភារដែលទ្រង់ឡើងគង់លើកនែដំរីហើយ ៗ មានមនុស្សដទៃទៀតមកឡើងជិះលើព្រះសុរងព្រះអង្គនោះតើជាទ្រង់ព្រមឲ្យជិះឬ ៗ ទ្រង់នឹងធ្វើដូចម្ដេច ។

៥. នហិភគ្គេ  បពិត្រព្រះនាគសេនដ៏ចំរើន  បើខ្ញុំម្ចាស់បានឡើងជិះលើកដីរបស់ខ្ញុំហើយ  មិនមានអ្នកឯណានឹងហានមកជិះលើកខ្ញុំទៀតទេ  បើបែទៅជាមានមនុស្សដទៃណាមួយហ៊ានឡើងមកជិះលើកខ្ញុំ ៗ នឹងមិនអត់ទេ  មុខជានឹងកាត់ក្បាលមនុស្សនោះ ដោយព្រះខាន់រាជ ១ រំពេចមិនយូរឡើយ  សូមលោកម្ចាស់ជ្រាប ។

៦. ឯវមេវខោ  មហារាជ  បពិត្រសម្តេចមហារាជ  មហាបពិត្រដែលទ្រង់មានផ្នូវព្រះរាជតេជានុភាពយ៉ាងណា  ក៏អង្គសម្តេចព្រះដ៏មានព្រះភាគព្រះអង្គទ្រង់បានឧបសម្បទដោយព្រះ-អង្គឯងឥតមានអ្នកឯណា ១  ហើយនឹងអាចឲ្យឧបសម្បទនោះដល់ព្រះអង្គបានឡើយ  បើបែទៅជាមានអ្នកឯណា ១ ហើយអាចឲ្យនូវឧបសម្បទនោះដល់ព្រះអង្គ  អ្នកនោះឯងនឹងបែកក្បាលទៅជា ៧ ភាគ  ដោយអំណាចពុទ្ធានុភាពនោះមិនខានទេ  មានឧបមានុមេយ្យដូចជាព្រះរាជានុភាពនោះឯង  ម្យ៉ាងទៀតបពិត្រសម្តេចមហារាជ  កាលពីជាន់មុនព្រះអង្គស្តេច

បានមានព្រះរាជឱង្ការសួរអាត្មាភាពថា ក្រុមជុំនុំសង្ឃប៉ុន្មាន អង្គអាចឲ្យនូវឧបសម្បទដល់ព្រះដ៏មានព្រះភាគមែនឬ ។

ម. វិទាមិភន្តេ បពិត្រព្រះនាគសេនដ៏បំរើន ពាក្យនេះ ខ្ញុំបានពោលមែន ។

ន. នសង្ឃេនខោមហារាជ បពិត្រសម្តេចមហារាជ ឯឧបសម្បទរបស់ព្រះដ៏មានព្រះភាគនោះ ឥតមានភិក្ខុសង្ឃ ឯណាដ៏ទៃនឹងអាចឲ្យបានឡើយ មានតែសង្ឃ ៣ ពួកទើបឲ្យ បានគឺបារមីសង្ឃ ១ កុសលសង្ឃ ១ ផលសង្ឃ ១ សេចក្តី នេះត្រូវដូចពុទ្ធភាសិតដែលទ្រង់សម្តែងទុកមកថា:

បត្តាពោបបដីបន្នា បត្តាពោចផលេដ្ឋិតា

ឯសសង្ឃោឧជុភូតោ បញ្ញាសីលសមាហិតោ

សេចក្តីថា បុគ្គលឯណា ១ មានចិត្តត្រង់ ប្រកបដោយ សីល សមាធិ បញ្ញា បានប្រតិបត្តិក្នុងមគ្គ ៤ ហើយតាំងនៅ ក្នុងផល ៤ បុគ្គលនោះឯងលោកហៅថាជាសង្ឃប្រាកដបាន ។ មួយាំងទៀតបពិត្រសម្តេចមហារាជ ឧបសម្បទឯណា ១ គឺសង្ឃ

ទាំង ៣ ពុកមានបារមីសង្ឃជាដើមនេះអាចឲ្យនូវឧបសម្បទ បានឥតមានទាស់ឡើយ ។

ម. អប្បរិបាំភន្តេ បពិត្រព្រះនាគសេនដ៏ចំរើន សេចក្ដីនេះក៏ជាអស្ចារ្យពេកណាស់ អព្ភូតំ ភន្តេ បពិត្រព្រះនាគសេនដ៏ចំរើន ហេតុនេះក៏ជាហេតុមិនធ្លាប់កើតហើយកើត ឯប្រស្នាដែលលោកម្ចាស់វិសជ្ជនាមកនេះក៏ជាប្រស្នាយ៉ាងវិចិត្រ នឹងរកប្រស្នាឯណា ១ មកប្រៀបផ្ទឹមឲ្យប្រហែលនោះមិនមានឡើយ ។

ន. អាមមហារាជ បពិត្រមហារាជ ឯឧបសម្បទរបស់ព្រះដ៏មានព្រះភាគនេះល្អពេកណាស់ សូមមហាបពិត្រស្ដេចជ្រាប ។

ម. អត្ថិបនភន្តេ បពិត្រព្រះនាគសេនដ៏ចំរើន ចុះឧបសម្បទរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះប្រាកដជាមានឬមិនមានទេ ។

ន. ឧបសម្បន្នោមហាភជ បពិត្រសម្ដេចមហារាជ ឯព្រះសម្មាសម្ពុទ្ធប្រាកដជាព្រះអង្គបានដល់នូវឧបសម្បទដោយពិតមួយអន្លើនឹងព្រះសព្វញ្ញុតញ្ញាណក្រោមម្លប់ពោធិព្រឹក្ស នឹង

មានអ្នកឯណា ១ អាចឡើងនូវឧបសម្បទនោះដល់ព្រះអង្គនោះគ្មានឡើយ ដូចជាព្រះអង្គបញ្ញត្តិនូវសិក្ខាបទដល់សាវកទាំងឡាយមិនឲ្យប្រព្រឹត្តកន្លងជរាបដល់អស់ជីវិតនោះឯង ។

ម.កល្លោសិកន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់ឆ្លើយពូកែណាស់ ចេះវិសជ្ជនាគួរឲ្យចូលចិត្តដោយងាយ ។

អស្សុបញ្ហា ទី ៦

ព្រះបរមក្សត្រាធិរាជស្ដេចទ្រង់ព្រះរាជបុច្ឆាចំពោះទៅព្រះ-នាគសេនថេរថា បពិត្រព្រះថេរដ៏ចំរើន បុរសពីរពួកឬជនពីរពួកជនពួក ១ មានសេចក្ដីក្ដៅក្រហាយសម្រក់ទឹកភ្នែក ព្រោះមាតាបិតាធ្វើកាលកិរិយាស្លាប់បង់ទៅ ជនពួក ១ ទៀតសម្រក់ទឹកភ្នែកព្រោះបានស្ដាប់ធម៌ឬពេញធម៌ដែលពីរោះត្រូវចិត្ត ហើយកើតសេចក្ដីក្ដៅក្រហាយហូរហៀរទឹកភ្នែក ទឹកភ្នែករបស់ជនទាំងពីរពួកនេះ តើទឹកភ្នែករបស់ជនពួកណានឹងបានជាភេសជ្ជគឺថ្នាំសម្រាប់រំងាប់រោគ ទឹកភ្នែករបស់ជនពួកណាដែលមិនបានជាភេសជ្ជ លោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរទៅវិញថា បពិត្រមហារាជ ទឹកភ្នែកនៃជនពួក ១ មានសម្ផស្សដ៏ក្តៅ ព្រោះអំណាចនៃរាគ ទោស មោហ ដុតកំដៅទ្រូងខាងក្នុងហើយហូរហៀរស្រក់ស្រោបចេញមក ទឹកភ្នែកនៃជនពួក ១ ទៀតមានសម្ផស្សដ៏ត្រជាក់យ៉ាងឧត្តម ព្រោះបានស្តាប់ធម៌ទេសនាដោយកំឡាំងនៃបីតិនឹងសោមនស្សក្លាហានហើយហូរហៀរចេញមក មហារាជបពិត្រសម្តេចមហារាជ អាត្មាភាពសូមថ្វាយព្រះពរ សម្រេចសេចក្តីនេះថា ទឹកភ្នែកឯណាដែលត្រជាក់ ទឹកភ្នែកនោះនឹងទៅជាថ្នាំភេសជ្ជយ៉ាងវិសេស ទឹកភ្នែកឯណាដែល ក្តៅទឹកភ្នែកនោះឯងមិនមែនជាថ្នាំភេសជ្ជទេ សូមទ្រង់ជ្រាប ។

ម. កល្លោសិភន្តេ បពិត្រព្រះនាគសេនដ៏ចំរើន លោកម្ចាស់ប៉ុនប្រសប់ពេកណាស់ក្នុងការវិសជ្ជនានេះ ។

### រសបដិសំវេទិបញ្ហា ។ ទី ៣

ព្រះបាទមិលិន្ទនរិន្ទរាជស្តេចទ្រង់បុច្ឆាទៅព្រះនាគសេនថេរថា បពិត្រព្រះនាគសេនថេរដ៏ចំរើន ជនមានពីរបំពួក ជន

បំពួក ១ ជាវីតរាគបុគ្គល ជនបំពួក ១ ទៀតជាអវីតរាគបុគ្គល ជនទាំងពីរបំពួកនេះតើនឹងមានហេតុផ្សេង ៗ គ្នាដូចម្ដេចទៅ លោកម្ចាស់ ។

ព្រះនាគសេនបើរ ថ្វាយព្រះពរថាបពិត្រមហារាជ ជនដែលជាវីតរាគគឺមានរាគទៅប្រាសហើយចាកសន្ដានតោះ ជាអនជ្ឈោសិត ជនដែលជាអវីតរាគ គឺមានរាគមិនទាន់ទៅប្រាសចាកសន្ដានតោះ ជាអជ្ឈោសិត សូមមហាបពិត្រស្ដេចជ្រាប ។

ម. ក៏ឯវិភង្គេ បពិត្រព្រះនាគសេនដ៏ចំរើន បុះជនដែលជាអជ្ឈោសិតនោះមានសេចក្ដីអធិប្បាយដូចម្ដេច ជនដែលជាអនជ្ឈោសិតនោះ មានសេចក្ដីអធិប្បាយដូចម្ដេច សូមលោកម្ចាស់វិសជ្ជនាមកមើល ។

ន. ឯកោខោមហារាជ បពិត្រមហារាជ ឯជនពួក១ដែលជាអជ្ឈោសិតនោះ គឺជននោះឯងនៅមានប្រយោជន៍ ឬនៅប្រកបកិច្ចការក្នុងលោកនេះនៅឡើយ ឯជនដែលជាអនជ្ឈោសិតនោះ គឺជននោះឯងមិនមានប្រយោជន៍ឬមិនត្រូវការក្នុងលោកនេះតទៅទៀត សូមមហារាជស្ដេចជ្រាប ។

ម. ឯវិរូបំភន្តេ បពិត្រព្រះនាគសេនដ៏ចំរើន សេចក្តីដែលលោកម្ចាស់វិសជ្ជនាមកយ៉ាងនេះ ខ្ញុំក៏ចូលចិត្តបានហើយ ថាអ្នកដែលមានរាគរម្ងាប់ផុតចាកសន្តានគេនោះ តែងមិនមានប្រយោជន៍ត្រេកអរឡើយ ឯអ្នកដែលនៅប្រកបដោយរាគនោះ តែងមានប្រយោជន៍ត្រេកអរតទៅ ក៏បំណែកខាងខ្ញុំឃើញថា មនុស្សទាំងពីរបំពួកនេះ នៅមានសេចក្តីប្រាថ្នាបរិភោគនូវភោជនាហារដែលជាទីគាប់ចិត្តនៅឡើយ មិនមានអ្នកឯណា ១ នឹងប្រាថ្នានូវភោជនដែលមិនពេញចិត្តនោះទេ បើយ៉ាងនឹងហើយចុះហេតុអ្វី ក៏បុគ្គលទាំងនោះមិនដូចគ្នាលោកម្ចាស់ សូមនិមន្តវិសជ្ជនាឲ្យច្បាស់លាស់មកមើល ។

ន. វីតរាគោខោមហារាជ បពិត្រមហារាជបុគ្គលទាំង ២ បំពួកនោះ ក៏សុទ្ធតែជាអ្នកនៅបរិភោគអាហារដូចគ្នាមែន តែមានអារម្មណ៍ផ្សេងគ្នា អ្នកដែលជាវីតរាគនោះ មានអារម្មណ៍មិនបានជាប់ជំពាក់ក្នុងរសនៃអាហារអាក្រក់ល្អនោះឡើយ គឺឆាន់បង្ហាន់នោះគ្រាន់តែនឹងដឹកលំខ្លួនឲ្យបានតាំងនៅក្នុងព្រហ្ម-ចារិយធម៌ប៉ុណ្ណោះទេ ឯអ្នកដែលប្រកបដោយរាគនោះ នៅ

មានចិត្តត្រេកអរជាប់ជំពាក់ក្នុងរសនៃអាហារ ដែលធ្លាប់នឹងមិនធ្លាប់នៅឡើយ សូមមហាបពិត្រស្ដេចជ្រាប ។

ម. កល្លោសិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់ឆ្លៀវឆ្លាសពេកណាស់បេះវិសជ្ជនាស្រួលបួល ខ្ញុំអស់សង្ស័យហើយ ។

បញ្ហាយបដិដ្ឋានបញ្ហា ១ ទី ៨

ព្រះមហាក្សត្រស្ដេចទ្រង់បុច្ឆាសួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៨ នេះថា បពិត្រព្រះនាគសេនដ៏ចំរើន បញ្ញាកុំហឹវសតិ បញ្ញានេះតែងស្ថិតនៅត្រង់ទីណា លោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រមហារាជ ឯបញ្ញានេះមិនមានទីកន្លែងនឹងស្ថិតនៅទេ សូមជ្រាប ។

ម. នត្ថិបញ្ញា បពិត្រព្រះនាគសេនដ៏ចំរើន បើលោកម្ចាស់មានថេរវាចាថាដូច្នោះនោះ ប្រហែលជាបញ្ញានោះមិនមានទេឬ ។

ន. វាតោមហារាជ បពិត្រមហារាជ អាត្មាភាពសូមថ្វាយព្រះពរថា ចុះខ្យល់តែងស្ថិតនៅក្នុងទីណាមហាបពិត្រ ។

ម. នកិញ្ចិភន្តេ បពិត្រព្រះថេរដ៏ចំរើន ខ្យល់មិនមាន ទីកន្លែងស្ថិតនៅទេ លោកម្ចាស់ ។

ន· នត្ថិវាតោ បពិត្រមហារាជ បើខ្យល់នោះមិនមាន ទីស្ថិតនៅមានតែខ្យល់នោះមិនមានដែរឬ ។

ម· កល្លោសិ ព្រះថេរលោកឆ្លៀវឆ្លាសល្អ ចេះវិសជ្ជ-នាតបប្រស្នាស្រួលពេកណាស់ ។

### សំសារបញ្ហា ។ ទី ៩ .

ព្រះមហាក្សត្រស្តេចទ្រង់បុច្ឆាចំពោះទៅព្រះនាគសេនថេរ ថា បពិត្រព្រះនាគសេនដ៏ចំរើន លោកម្ចាស់បានពោលថា សំសារោ ៗ ដូច្នេះ សំសារសព្ទនេះតើមានសេចក្តីអធិប្បាយ ដូចម្តេច សូមលោកម្ចាស់វិសជ្ជនាមកមើល ។

ព្រះនាគសេនថ្វាយព្រះពរថា បពិត្រមហារាជ ឯសំសារ សព្ទនេះប្រែថា ប្រទេសជាទីអន្ទោលទៅនឹងត្រឡប់មកនៃសត្វ នីករ គឺសត្វដែលកើតក្នុងលោកនេះ វេលាដល់ស្លាប់ក៏ស្លាប់ ក្នុងលោកនេះ សត្វដែលស្លាប់ក្នុងលោកនេះហើយទៅបដិសន្ធិ

កើតទៀតក្នុងលោកដទៃ សត្វដែលកើតក្នុងលោកនោះរើឈឺ ដល់ស្លាប់ក៏ស្លាប់ក្នុងលោកនោះ សត្វដែលស្លាប់ក្នុងលោកនោះ ទៅកើតក្នុងលោកឯទៀត ឯវិទោមហារាជ តាំសោពោ បពិត្រ សម្ដេចមហារាជ ឯសំសារនេះមានសេចក្ដីដូចអាត្មាភាពវិសជ្ជ-នាមកនេះ សូមទ្រង់ជ្រាប ។

ម. ឧបមំករោហិ សូមលោកម្ចាស់ប្រៀបឧបមាជាសេចក្ដីបន្តិចមកមើល ។

ន. យថាមហារាជ បពិត្រសម្ដេចមហារាជ សេចក្ដីនេះប្រៀបឧបមាដូចបុរសណា ១ បានបរិភោគនូវផ្លែស្វាយទុំរួចយកគ្រាប់ស្វាយនោះទៅដាក់ដាំចុះលើផែនដី ស្វាយនោះក៏ដុះបំរើនធំឡើងដោយលំដាប់មានផ្កាផ្លែបរិបូណ៌ បំណែកខាងបុរសជាម្ចាស់នោះក៏ទៅបេះយកផ្លែនោះមកបរិភោគ រួចយកគ្រាប់ស្វាយនោះទៅដាំអង្គទៀត ស្វាយនោះក៏ដុះឡើងមានផ្លែផ្កាត ៗ ទៅ ឯផ្លែស្វាយជាដំបូងដែលបុរសយកទៅដាំមុនក៏ដុះចេញជាដើមជាមែកស្លឹកផ្កាផ្លែ ដើមចាស់ក៏រលំរលាយបាត់សូន្យទៅ នៅតែពូជគឺផ្លែ ៗ នោះក៏ដុះដាលជាដើមជា

មែកស្លឹកផ្កាផ្លែទៀត ត ៗ គ្នាទៅគឺតមានទីបំផុត ឯទីរាំផុត ខាងដើមនៃដើមស្វាយនោះនឹងរកប្រាកដមិនមានយ៉ាងណាមិញ បពិត្រមហារាជ ឯកំណើតសត្វក្នុងសំសារដែលកើតហើយ ស្លាប់ ៗ ហើយកើតត ៗ ទៅនោះ ក៏រកទីបំផុតពុំមានដូចពូជ ឈើនោះឯង សូមទ្រង់ជ្រាប ។

ម. កល្លោសិ លោកម្ចាស់បុនណាស់ប្រែសប់ប្រៀបគួរឲ្យ ចូលចិត្តបានហើយ ។

ចិរកតសរណបញ្ហា ។ ទី ១០

ព្រះបរមក្សត្រាធិរាជ ស្ដេចទ្រង់បុច្ឆាចំពោះទៅព្រះនាគ សេនថេរថា បពិត្រព្រះថេរដ៏ចំរើន បុគ្គលរលឹកនូវអំពើរការអ្វី និមួយដែលខ្ញុំធ្វើទុកយូរហើយ កន្លងទៅហើយនោះ តើរលឹក ដោយធម្មជាតិអ្វី លោកម្ចាស់ ។

ព្រះនាគសេនថេរ ថ្វាយព្រះពរថា សតិយាមហារាជ ប-ពិត្រសម្ដេចមហារាជ ឯបុគ្គលដែលនឹងរលឹកនូវអំពើកម្មទាំង ពួងនោះគឺរលឹកដោយស្មារតី សូមមហាគជជ្រាប ។

ម. បរិត្តេនស្សរិយតិ បពិត្រព្រះនាគសេនដ៏ចំរើន លោកម្ចាស់សំដែងថារលឹកដោយស្មារតី ឯខ្ញុំចូលចិត្តថាបុគ្គលនឹងរលឹកនូវអំពើការនោះគឺរលឹកដោយចិត្តជាប្រាកដ មិនមែនរលឹកដោយស្មារតីទេ ។

ន. អភិជានាសិ មហារាជ បពិត្រមហារាជ បំណែកមហាបពិត្រ ស្តេចពេញព្រះឫហទ័យថា ឯការដែលនឹងនឹករលឹកនោះ គឺរលឹកដោយចិត្តចំពោះ បើដូច្នេះអាត្មាភាពសូមថ្វាយព្រះពរសួរថា ចុះមហាបពិត្រកាលដែលនឹងធ្វើការអ្វីនិមួយ ហើយភ្លេចភ្លាំងបាត់ទៅនឹករកពុំឃើញជាមានឬពុំមាន ។

ម. អាមភន្តេ បពិត្រព្រះនាគសេនដ៏ចំរើន ឯការដែលធ្វើហើយវង្វេងភ្លេចបាត់ទៅគង់មាន លោកម្ចាស់ ។

ន. កិន្នុខោ មហារាជ បពិត្រមហារាជ ចុះសម័យដែលព្រះអង្គធ្វើការនោះប្រហែលជាទ្រង់ធ្វើដោយគ្មានចិត្តឬដូចម្តេចក៏បានជាភ្លេចបាន ។

ម. នហិ ភន្តេ បពិត្រព្រះនាគសេនដ៏ចំរើន ឯសម័យដែលធ្វើការនោះមិនមែនធ្វើដោយគ្មានចិត្តទេ គឺចិត្តនោះនៅមាន

ប្រាកដ តែវាគ្មានស្មារតីនឹងរលឹក បានជាវាភ្លេចបាត់ទៅវិញ លោកម្ចាស់ ។

ន. មហាបពិត្រស្តេចទ្រង់ជ្រាបយ៉ាងនេះត្រូវ ពកណាស់ក៏ការដែលរលឹកនោះគឺរលឹកដោយស្មារតី ៗ នេះជាភ្នាក់ងារសម្រាប់ខាងនឹករលឹកតែម្យ៉ាង ឯបិត្តនោះមានកិច្ចត្រូវគិតត្រូវសន្សំ បិត្តនេះជាភ្នាក់ងារខាងរិះគិតតែម្យ៉ាងប៉ុណ្ណោះ មិនមែនជាអ្នកនឹករលឹកទេ សូមមហាបពិត្រស្តេចជ្រាប ។

ម. ក្រល្មោសិ ព្រះបេរម្ចាស់លោកឆ្លាសពេកណាស់បេះវិសជ្ជនាដោះស្រាយប្រស្នាពីរោះល្អ ខ្ញុំអស់មានសេចក្តីសង្ស័យហើយ ។

សតិអភិជាននបញ្ហា ។ ទី ១១

ព្រះបរមក្សត្រាធិរាជ ស្តេចទ្រង់បុច្ឆាបំពោះទៅព្រះនាគសេនបេរក្នុងប្រស្នាទី ១១ នេះថា បពិត្រព្រះនាគសេនដ៏បំរើនសតិបេតសិកដែលជាធម្មជាតិសម្រាប់រលឹកនូវវត្ថុទាំងពួងនោះតែងមានដល់តែអ្នកដែលបេះដឹងម្យ៉ាងទេឬ ៗ នឹងមាននូវទៅដល់ជនជាកុដុម្ពិកដែរ ។

ម. ឯវិហិតោភន្តេ បពិត្រព្រះនាគសេនដ៏ចំរើន ខ្ញុំមិនយល់ដូច្នោះទេ ខ្ញុំយល់ថាឯសតិចេតសិកនោះមានចំពោះតែមនុស្សដែលចេះដឹង ឯជនដែលជាកុដុម្ពិកនោះមិនមានឡើយ

ន. មហារាជ បពិត្រសម្តេចមហារាជ ឯស្មារតីនេះបើមិនមានដល់ជនជាកុដុម្ពិកហើយ បំណែកខាងកិច្ចដែលបុគ្គលត្រូវប្រកបក្នុងសិល្បសាស្ត្រក្តី ក្នុងព្រះកម្មដ្ឋានក្តី ក្នុងវិជ្ជាការផ្សេងៗក្តី អំពីសំណាក់នៃគ្រូបាអាចារ្យទាំងឡាយ ក៏មិនមានប្រយោជន៍ឡើយ បពិត្រមហារាជ ឯស្មារតីនេះប្រាកដជាមានដល់ជនជាកុដុម្ពិកនោះឯង ទើបបានជាមានកិច្ចត្រូវប្រកបក្នុងការសិក្សាសិល្បសាស្ត្រ នឹងព្រះកម្មដ្ឋានហើយនឹងវិជ្ជាការទាំងពួងអំពីសំណាក់នៃអាចារ្យទាំងឡាយ ដើម្បីនឹងបំពេញស្មារតីនោះឲ្យចំរើនបរិបូណ៌ឡើងដោយគុណទាំងនោះ សូមមហារាជស្តេចជ្រាប ។

ម. កល្លោសិ លោកម្ចាស់ប៉ិនប្រសប់ណាស់ហើយ ចេះដោះស្រាយសេចក្តីស្រួលស្តាប់ ខ្ញុំអស់សង្ស័យហើយ ។

## សត្តមវគ្គមានប្រស្នា ១៩ ប្រការ

### សតិអាការបញ្ហា ៗ ទី ១

ព្រះបរមក្សត្រាធិរាជស្តេចទ្រង់សួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ១ ក្នុងវគ្គទី ៧ នេះថា បពិត្រព្រះនាគសេនដ៏ចំរើន ចុះសតិចេតសិកដែលនឹងកើតឡើងដល់បុគ្គលទាំងពួងនោះតើដោយអាការប៉ុន្មានយ៉ាងលោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្តេចមហារាជឯសតិចេតសិកនោះវេលាដែលនឹងកើតឡើង គឺកើតដោយអាការ ១៧ ស្ថាន ។

ឯអាការ ១៧ ស្ថាននោះគឺ

១.— អភិជានតោបិសតិ

២.— កុដុម្ពិកាយបិសតិ

៣.— ឱឡារិកវិញ្ញាណតោបិសតិ

៤.— ហិតវិញ្ញាណតោបិសតិ

៥.— អហិតវិញ្ញាណតោបិសតិ

៦.– សភាគនិមិត្តតោបិសតិ

៧.– វិសភាគនិមិត្តតោបិសតិ

៨.– កថាភិញ្ញាណតោបិសតិ

៩.– លក្ខណតោបិសតិ

១០.– សរណតោបិសតិ

១១.– មុទ្ទតោបិសតិ

១២.– គណនាតោបិសតិ

១៣.– ធារណតោបិសតិ

១៤.– ភាវនាតោបិសតិ

១៥.– បោត្ថកនិពន្ធតោបិសតិ

១៦.– ឧបនិក្ខេបនតោបិសតិ

១៧.– អនុភូតតោបិសតិ

ក៏អាការរបស់ស្មារតីទាំង ១៧ ស្ថាន ដូចឈ្មោះដែលរាប់មកនេះ សូមមហាបពិត្រស្តេចជ្រាប ។

ម. កបិភន្តេ អភិជានតោសតិ បពិត្រព្រះនាគសេន

ដ៏ចំរើន បុះអភិជានតោសតិ គឺសតិទី ១ នោះតើមានសេចក្ដីប្រែនិងអធិប្បាយដូចម្ដេចទៅ ។

ន. មហារាជ បពិត្រមហារាជ ឯអភិជានតោសតិ នោះប្រែជាសេចក្ដីថា ស្មារតីឯណាដែលកើតឡើងដល់បុគ្គលដែលជាអ្នកបេះដឹងអាចរលឹកជាតិបាន និងស្មារតីរបស់ព្រះមហាអានន្ទដែលជាអ្នកស្ដាប់នូវព្រះសូត្រតែ ១ គ្រាក៏អាចចងចាំបាន និងស្មារតីនៃនាងខុជ្ជុត្តរាឧបាសិកា ដែលបានស្ដាប់នូវព្រះសទ្ធម្មទេសនាតែម្ដងក៏អាចចាំបាន នាំយកមកសំដែងប្រាប់ជនទាំងឡាយឲ្យស្ដាប់បានផង ស្មារតីនោះឈ្មោះថា អភិជានតោសតិ សូមមហាបពិត្រស្ដេចជ្រាប ។

ម. កបិភន្តេ កុដុម្ពិកាយសតិ បពិត្រព្រះនាគសេនដ៏ចំរើន បុះកុដុម្ពិកាយសតិ ៗ ទី ២ នោះតើ មានសេចក្ដីអធិប្បាយយ៉ាងណាលោកម្ចាស់ ។

ន. មហារាជ បពិត្រព្រះរាជសម្ភារ ឯកុដុម្ពិកាយសតិនោះ ប្រែជាសេចក្ដីថា ស្មារតីឯណា ១ ដែលកើតឡើងដល់ជនដែលមានទ្រព្យសម្បត្តិច្រើនហើយ លាក់ទុកឬកប់ទុក

ហើយភ្លេចនឹក ភ្លេចគិតអំពីរបស់ទាំងនោះ លុះមានជនដទៃគេមករកខ្ញុំបងការ ទើបមានស្មារតីនឹករលឹកដល់ទ្រព្យដែលខ្លួនកប់ទុកនោះ ស្មារតីយ៉ាងនេះបានឈ្មោះថា កុដុម្ពិកាយសតិ សូមមហារាជស្ដេចជ្រាប ។

ម. កបិឌ្ឍឡារិកវិញ្ញាណតោសតិ បពិត្រព្រះថេរដ៏បំរើនបុះស្មារតីដែលឈ្មោះថាឱឡារិកវិញ្ញាណតោសតិ ៗ ទី ៣ នោះតើអធិប្បាយយ៉ាងដូចម្ដេច ។

ន. មហារាជ បពិត្រសម្ដេចមហារាជ ឯឱឡារិកវិញ្ញាណតោសតិនោះ ប្រែជាសេចក្ដីថា ស្មារតីឯណា ១ ដែលកើតឡើងដល់ជនដែលមានវិញ្ញាណគ្រោតគ្រាតនៅឡើយ បានខាងស្មារតីរបស់ព្រះបរមក្សត្រាធិរាជដែលទើបនឹងបានរាជាភិសេកថ្មី ៗ នឹងស្មារតីរបស់ព្រះអរិយបុគ្គលដែលទើបនឹងបានដល់សោតាបត្តិផលថ្មី ៗ តែងមានព្រះហឫទ័យរីករាយសប្បាយនៅឡើយ ស្មារតីយ៉ាងនេះ ហៅថា ឱឡារិកវិញ្ញាណតោសតិ សូមទ្រង់ជ្រាប ។

ម. កបិហិតក្ដេ ហិតវិញ្ញាណតោសតិ បពិត្រព្រះថេរ

ដ៏ចំរើន ហេតុវិញ្ញាណគោសតិ ៗ ទី ៤ នោះតើមានសេចក្ដីអធិប្បាយដូចម្ដេចលោកម្ចាស់ ៗ

ន. មហារាជ បពិត្រសម្ដេចមហារាជ ឯហេតុវិញ្ញាណគោសតិនោះ ប្រែចេញជាសេចក្ដីថា ស្មារតីឯណា ១ ដែលកើតឡើងដល់បុគ្គលដែលមានវិញ្ញាណប្រកបទៅដោយគុណបានខាងបុគ្គលដែលធ្លាប់សោយនូវសេចក្ដីសុខអំពីកាលមុន ៗ មក ហើយនឹករលឹកដល់សេចក្ដីសុខនោះថា អាត្មាអញបានភប់ប្រសប់ប្រទះនឹងសេចក្ដីសុខសប្បាយយ៉ាងនោះៗ ក្នុងពេលមុនស្មារតីយ៉ាងនេះ បានឈ្មោះថាហេតុវិញ្ញាណគោសតិ សូមមហាបពិត្រជ្រាប ៗ

ម. កបិអហេតុវិញ្ញាណគោសតិ បពិត្រព្រះថេរដ៏ចំរើន ចុះអហេតុវិញ្ញាណគោសតិ ៗ ទី ៥ នោះតើដូចម្ដេច ។

ន. មហារាជ បពិត្រមហារាជ ឯអហេតុវិញ្ញាណគោ-សតិនោះមានសេចក្ដីថា ស្មារតីឯណា ១ ដែលកើតឡើងដល់បុគ្គលដែលធ្លាប់បានទទួលរងទុក្ខវេទនាក្នុងកាលគ្រាមុន ៗ មក ហើយរលឹកនឹកដល់សេចក្ដីទុក្ខទោស ដែលខ្លួនធ្លាប់សោយ

នោះ ៗ ស្មារតីយ៉ាងនេះបានឈ្មោះថា អកេិតវិញ្ញាណគោសតិ សូមស្ដេចជ្រាប ។

ម. កបិសភាគនិមិត្តគោសតិ បពិត្រព្រះនាគសេនបវរដ៏បំពើន ចុះសភាគនិមិត្តគោសតិ ៗ ទី ៦ នោះតើមានសេចក្ដីអធិប្បាយដូចម្ដេចទៅ លោកម្ចាស់ ។

ន. មហារាជ បពិត្រសម្ដេចមហារាជ ឯសភាគនិមិត្ត-គោសតិនោះ មានសេចក្ដីថា ស្មារតីឯណាដែលកើតឡើងដល់ជនដែលមានទិមិត្តឬភេទមានបំណែកស្មើ បានខាងឯជនដែលបានឃើញអ្នកដ៏ទៃមានរូបរាង សណ្ឋានទ្រង់ទ្រាយប្រ-ហែលដូចមាតាបិតា បងប្រុស ប្អូនស្រី របស់ខ្លួនដែលបែកបាត់ទៅហើយមានស្មារតីរលឹកដល់ញាតិទាំងនោះ ឬបានឃើញនូវឱដ្ឋ, គោ, និងលាររបស់អ្នកដ៏ទៃហើយ មានស្មារតីនឹករលឹកដល់ទ្រព្យរបស់ខ្លួនទាំងនោះមានឱដ្ឋជាដើម ស្មារតីយ៉ាងនេះបានឈ្មោះថា សភាគនិមិត្តគោសតិ សូមទ្រង់ជ្រាប ។

ម. កបិវិសភាគនិមិត្តគោសតិ បពិត្រព្រះបវរដ៏បំពើន ចុះ

វិសភាគនិមិត្តតោសតិ ។ ទី ៧ នោះតើមានសេចក្ដីអធិប្បាយដូចម្ដេច ។

ន. មហារាជ បពិត្រមហារាជ ឯវិសភាគនិមិត្តតោសតិនោះ មានសេចក្ដីថា ស្មារតីឯណាដែលកើតឡើងដល់ជនដែលមាននិមិត្តឬភេទមានចំណែកមិនស្មើ បានដល់ជនដែលបានរលឹកដល់ ពណ៌សម្បុរ ក្លិន, រស, និងផោដ្ឋព្វារម្មណ៍ ដែលខ្លួនធ្លាប់ឃើញ ធ្លាប់ធុម ធ្លាប់ភ្លក់ ធ្លាប់ពាល់ត្រូវហើយ ស្មារតីយ៉ាងនេះបានឈ្មោះថា វិសភាគនិមិត្តតោសតិ សូមស្ដេចជ្រាប ។

ម. កបិកថាភិញ្ញាណតោសតិ បពិត្រព្រះថេរដ៏ចំរើនបុះស្មារតិ ទី ៨ ដែលហៅថា កថាភិញ្ញាណតោសតិ នោះតើមានសេចក្ដីអធិប្បាយដូចម្ដេចលោកម្ចាស់ ។

ន. មហារាជ បពិត្រមហារាជ ឯកថាភិញ្ញាណតោសតិនោះ មានសេចក្ដីថា ស្មារតីឯណា ១ ដែលកើតឡើងដល់បុគ្គលដែលភ្លេចស្មារតីឬភ្លាត់ស្មារតី លុះបុគ្គលដទៃគេប្រាប់គេរំលឹកឡើង ក៏បានដឹងចំពោះវិញ ស្មារតីយ៉ាងនេះបានឈ្មោះ

ថា កថាភិញ្ញាណតោសតិ សូមមហាបពិត្រស្ដេចជ្រាប ។

ម. កបិលក្ខណតោសតិ បពិត្រព្រះបេរដ៏បំរើនចុះលក្ខណតោសតិ ៗ ទី ៩ នោះតើមានសេចក្ដីអធិប្បាយដូចម្ដេច ។

ន. មហារាជ បពិត្រសម្ដេចមហារាជ ឯលក្ខណតោសតិនោះ មានសេចក្ដីថា ស្មារតីឯណា ១ ដែលកើតឡើងដល់បុគ្គលជាអ្នកដឹងនូវលក្ខណនៃសត្វទាំងពួង បានដល់ជនជាម្ចាស់នៃគោ បានឃើញនូវអរិយវជាគ្រឿងប្រដាប់របស់គោ ហើយអាចរលឹកដឹងស្គាល់បាន ស្មារតីយ៉ាងនោះបានឈ្មោះថា លក្ខណតោសតិ សូមស្ដេចជ្រាប ។

ម. កបិសរណតោសតិ បពិត្រព្រះបេរដ៏បំរើន ចុះសរណតោសតិ ៗ ទី ១០ នោះតើមានសេចក្ដីអធិប្បាយដូចម្ដេច ។

ន. មហារាជ បពិត្រមហារាជ ឯសរណតោសតិនោះ មានសេចក្ដីថា ស្មារតីឯណា ១ ដែលកើតឡើងដល់បុគ្គលដែលភ្លេចខ្លួន ហើយអ្នកដទៃគេមកនិយាយដះតឿនរំលឹកថា នែអ្នក ៗ ចូរនឹកនូវហេតុនេះមើល ទើបបុគ្គលនោះអាចរលឹក

បាន ស្មារតីយ៉ាងនេះបានឈ្មោះថា សរណតោសតិ សូមស្ដេចជ្រាប ។

ម. កបិមុទ្ធតោសតិ បពិត្រព្រះថេរដ៏ចំរើន ចុះមុទ្ធតោសតិ ៗ ទី ១១ នោះតើមានសេចក្ដីសំដែងចេញដូចម្ដេចទៅ ។

ន. មហារាជ បពិត្រមហារាជ ឯមុទ្ធតោសតិនោះមានសេចក្ដីសំដែងថា សតិណា ១ ដែលកើតឡើងដល់បុគ្គលណាដែលបានសរសេរសំបុត្រកំណត់កត់ទុកហើយភ្លេចទៅ លុះគ្រាក្រោយបានឃើញសំបុត្រនោះហើយ ទើបមានស្មារតីរលឹកឃើញថា អក្សរសំបុត្រនេះអាត្មាបានសរសេរទុកជាលំដាប់នៃសំបុត្រនេះ, ស្មារតីយ៉ាងនេះបា ឈ្មោះថា មុទ្ធតោសតិ សូមមហាបពិត្រស្ដេចជ្រាប ។,

ម. កបិគណនាតោសតិ បពិត្រព្រះថេរដ៏ចំរើន ចុះគណនាតោសតិ ៗ ទី ១២ នោះតើមានសេចក្ដីសំដែងដូចម្ដេចលោកម្ចាស់ ។

ន. មហារាជ បពិត្រមហារាជ ឯគណនាតោសតិនោះមានសេចក្ដីសំដែងថា សតិណា ១ ដែលតែងកើតឡើងដល់

បុគ្គលដែលជាអ្នករាប់គណនានូវវត្ថុទាំងពួង មានប្រមាណច្រើនដោយគំនូសកំណាប់ទើបរាប់បាន សតិយ៉ាងនេះបានឈ្មោះថា មុទ្ទតោសតិ សូមស្ដេចជ្រាប ។

ម. កបិ ធារណតោ សតិ បពិត្រព្រះនាគសេនដ៏ចំរើន បុះ ធារណតោសតិ ៗ ទី ១៣ នោះតើមានប្រការដូចម្ដេច ។

ន. មហារាជ បពិត្រមហារាជ ឯធារណតោសតិនោះមានអធិប្បាយជាសេចក្ដីសំខេបថា សតិណា ១ ដែលតែងកើតឡើងដល់បុគ្គលដែលជាអ្នកទ្រទ្រង់ទុកនូវសេចក្ដីទាំងពួងបានច្រើន សតិនេះឯងបានឈ្មោះថា ធារណតោសតិ សូមទ្រង់ជ្រាប ។

- ម. កបិភាវនាតោសតិ បពិត្រព្រះថេរដ៏ចំរើន បុះភាវនាតោសតិ ៗ ទី ១៤ នោះតើមានប្រការដូចម្ដេច ។

ន. មហារាជ បពិត្រមហារាជ ឯភាវនាតោសតិនោះមានសេចក្ដីថា សតិណា ១ ដែលកើតឡើងដល់ភិក្ខុណា ១ ដែលបានសំរេចនូវបុព្វេនិវាសានុស្សតិញាណ . គឺសេចក្ដីដឹងនឹងរលឹកបាន នូវខន្ធសន្ដានដែលកើតហើយក្នុងកាលមុន ៗ

គឺរលឹកជាតិបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ដរាបដល់ច្រើនជាតិទៅ សតិនោះឯង បានឈ្មោះថា ភាវនាគោសតិ សូមមហាបពិត្រស្តេចជ្រាប ។

ម. កថំ បោដ្ឋកនិពន្ធនគោសតិ បពិត្រព្រះថេរដ៏ចំរើន ចុះសតិទី ១៥ នោះតើនឹងមានសេចក្តីអធិប្បាយដូចម្តេចលោកម្ចាស់ ។

ន. មហារាជ បពិត្រមហារាជ ឯសតិទី ១៥ ដែលហៅថា បោដ្ឋកនិពន្ធនគោសតិនេះ មានសេចក្តីថា សតិណា ១ ដែលតែងកើតឡើងដល់បុរសជាខុរាជការ ដែលរលឹកដល់ព្រះរាជអនុសាសនិកថាដែលបានកត់ត្រាព្រះរាជដីកាទុកក្នុងស្លឹករឹតហើយជាស្រេច លុះដល់ត្រូវការវេលាណាហើយ ក៏នាំយកមកមើលនូវព្រះរាជដីកានោះទើបរលឹកចាំបានគ្រប់កន្លែងឡើង បពិត្រមហារាជ សតិយ៉ាងនេះបានឈ្មោះថា បោដ្ឋកនិពន្ធនគោសតិ សូមស្តេចជ្រាប ។

ម. កថំ ឧបនិក្ខេបនគោសតិ បពិត្រព្រះថេរដ៏ចំរើន ចុះសតិទី ១៦ នោះតើដូចម្តេច ។

ន. មហារាជ បពិត្រព្រះបរមរាជាធិរាជ ឯសតិទី ១៦ ដែលហៅថា ឧបនិក្ខេបនតោនោះ មានសេចក្ដីថា សតិណា ១ ដែលតែងកើតឡើងដល់ជនដែលបានឃើញនូវទ្រព្យដែលខ្លួនតាំងទុកហើយរលឹកនឹកឃើញសព្វគ្រប់បំពួក សតិយ៉ាងនេះបានឈ្មោះថា ឧបនិក្ខេបនតោសតិ សូមស្ដេចជ្រាប ។

ម. កបិំ អនុភូតតោហោតិ បពិត្រព្រះថេរដ៏ចំរើន ចុះសតិទី ១៧ នោះតើដូចម្ដេច លោកម្ចាស់ ។

ន. មហារាជ បពិត្រមហារាជ ឯសតិទី ១៧ ដែលហៅថា អនុភូតតោ នោះមានសេចក្ដីថា សតិណា ១ ដែលកើតឡើងដល់បុគ្គលដែលជាអ្នករលឹកដល់រូបដែលខ្លួនធ្លាប់បានឃើញ រលឹកដល់សំឡេង រលឹកដល់ក្លិន រលឹកដល់រស រលឹកដល់ផោដ្ឋព្វារម្មណ៍ ដែលខ្លួនធ្លាប់បានស្ដាប់ បានធុំ បានភ្លក់ នឹងធ្លាប់បានពាល់ត្រូវហើយក្នុងកាលមុន សតិយ៉ាងនេះបានឈ្មោះថា អនុភូតោសតិ បពិត្រសម្ដេចមហារាជ ឯសតិដែលនឹងកើតឡើងដោយអាការ ១៧ ស្ថាននេះ សូមមហាបពិត្រស្ដេចទ្រង់ជ្រាប ។

ម. កល្លោសិភន្តេ បពិត្រព្រះនាគសេនដ៏បំរើន លោកម្ចាស់ក៏ជាអ្នកប្រាជ្ញប្រាកដពិតហើយ ព្រោះមានប្រាជ្ញាវាងវៃណាស់ បេះដោះប្រស្នាស្រួលឥតមានទាស់ ខ្ញុំក៏អស់សង្ស័យហើយ ។

វិសេសតបញ្ហា ។ ទី ២

ព្រះបរមក្សត្រាធិរាជ ស្តេចទ្រង់ត្រាស់សួរទៅ ព្រះនាគ-សេនថេរក្នុងប្រស្នាទី ២ ក្នុងវគ្គទី ៧ ថា បពិត្រព្រះនាគសេនថេរដ៏បំរើន លោកម្ចាស់បានពោលថា អ្នកឯណា ១ ប្រព្រឹត្តធ្វើអំពើបាបកម្មកយ្ហរយាណាស់ហើយដរាបដល់អាយុ ១០០ ឆ្នាំ វេលាដល់ជិតមរណាសន្នកាលជិតនឹងស្លាប់ ក៏បានតាំងដឹកល់ស្មារតីល្អ រលឹកខ្ជាប់ទៅក្នុងពុទ្ធគុណតែមួយពេលប៉ុណ្ណោះ ថាអ្នកនោះឯងគង់នឹងបានទៅកើតឯស្ថានទេវលោកជាប្រាកដមិនខាន ពាក្យយ៉ាងនេះខ្ញុំម្ចាស់រកតាំងចិត្តជឿមិនកើត ១ ។ ម្យ៉ាងទៀតលោកម្ចាស់បានពោលថា អ្នកឯណា ១ តែផ្តិលខ្លួនបានប្រព្រឹត្តធ្វើអំពើបាណាតិបាតហើយកុំថាឡើយច្រើនផង

សូម្បីធ្មើតែម្តងអ្នកនោះឯងក៏គង់នឹងច្បុតទៅកើតក្នុងស្ថាននរក មិនខាន ពាក្យនេះខ្ញុំមិនជឿ ។ សូមលោកម្ចាស់ប្រែស្រាយ អធិប្បាយសេចក្តីនេះ ឲ្យខ្ញុំស្តាប់បាទបួលចិត្តផងមើល ។

ព្រះនាគសេនបេរ ថ្វាយព្រះពរទៅវិញថា តំកឹមញ្ញសិ មហារាជ បពិត្រសម្តេចមហារាជ ចុះសេចក្តីនេះព្រះអង្គទ្រង់ព្រះ-ដំរិះដូចម្តេចទៅ អាត្មាភាពសូមថ្វាយព្រះពរសួរថា ដុំថ្មនោះតូច តិចទេប្រមាណជាប៉ុនគ្រាប់ពោតឬគ្រាប់ម្រេច បុគ្គលយកទៅ ដាក់ដំកល់ផ្ទាល់លើខ្នងទឹកដោយឥតមានទូកឬវត្ថុអ្វី សម្រាប់ ទ្រាប់ទ្រអំពីខាងក្រោមនៃដុំថ្មនោះទេ បំណែកថ្មនោះនឹងអាច អណ្តែតទៅលើខ្នងទឹកបានឬមិនបានទេ មហាបពិត្រ ។

ម. នហិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ឯដុំថ្មនោះមិន-អាចនឹងអណ្តែតលើខ្នងទឹកផ្ទាល់ដោយឥតមានវត្ថុដំកល់នោះ បានឡើយលោកម្ចាស់ ។

ន. កិន្នុ រាហសតំបិបាសាណំ បពិត្រមហារាជ ហេតុ អ្វីក៏មិនអាចអណ្តែតបាន ប្រសិនបើថ្មមានប្រមាណច្រើនដំ នួន ១០០រទេះ តែគេបានលើកយកទៅដាក់ដំកល់លើទូកឬសំ-

ទៅ ហើយបណ្តែតបន្សាត់ទៅលើខ្នងទឹក តើថ្មនោះអាចនឹងអណ្តែតទៅបានឬទេមហាបពិត្រ ។

ម. អាមភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ថ្មនោះអាចអណ្តែតទៅបាន ព្រោះមានទូកឬសំពៅទ្រទ្រង់ពីខាងក្រោមលោកម្ចាស់ ។

ន. យថាមហារាជ បពិត្រមហារាជ សូមព្រះអង្គទ្រង់សណ្តាប់អាត្មាភាពនឹងប្រៀបថ្វាយ ឋាឯកុសលធម៌ទាំងពួងប្រៀបដូចជាទូកឬសំពៅមានសភាពតែងអណ្តែតទៅលើគង្គាបាន ឯអកុសលកម្មនោះសោតប្រៀបដូចជាដុំថ្មទាំងពួង មានសភាពតែងលង់លិចចុះទៅក្នុងគង្គា ក៏ធម្មតាដុំថ្មទាំងពួងតែងមានភារធ្ងន់ជាបំផុតជាងសភាវឯទៀត កុំថាឡើយថ្មនោះធំឬច្រើន សូម្បីដុំថ្មទាំងនោះតូចតាចបន្តិចបន្តួចក្តី តែគ្មានគ្រឿងទ្រពីក្រោមហើយ ថ្មនោះក៏មិនអាចនឹងអណ្តែតទឹកទៅបានប្រៀបដូចអំពើអកុសលទាំងពួងដែលបុគ្គលបានធ្វើហើយ កុំថាឡើយ បាំធ្វើច្រើនដង ទោះបីធ្វើតែបន្តិចឬតែម្តងហើយគ្មានបានធ្វើអំពើកុសលអ្វីដ៏ទៃជាឧបាយជាគ្រឿងគាំទ្រសោះ

បុគ្គលនោះនឹងអាចដោះខ្លួនចេញឲ្យផុតពីអបាយភូមិនោះមិនរួចឡើយ ព្រោះអកុសលកម្មនេះមានភាពជាគ្រឿងធ្ងន់តែងលង់តែងលិចចុះជាធម្មតា ។ ចំណែកខាងកុសលកម្មវិញប្រៀបដូចជាទូកឬសំពៅ ធម្មតាទូកទាំងពួងមានសភាពស្រាលតែងអណ្តែតទៅលើទឹកបាន កុំថាទូកនោះតូចស្រាលទោះបីទូកនោះធំធ្ងន់យ៉ាងណាក្តី ក៏គង់នឹងអណ្តែតទៅលើខ្នងគង្គាបាន ហើយមិនអណ្តែតទៅតែសម្បកទូកទទេឡើយ អាចទ្រទ្រង់ដឹកនាំនូវវត្ថុដែលគេផ្ទុកទៅជាមួយផងបាន ប្រៀបដូចកុសលទាំងពួងដែលបុគ្គលបានធ្វើហើយ កុំថាឡើយខ្លួនសត្វនោះបានប្រព្រឹត្តធ្វើតែអំពើកុសលកម្មមួយមុខដ៏បរិសុទ្ធស្អាតល្អ ប្រសិនបើខ្លួនសត្វនោះ កាលជាន់មុនភាន់ច្រឡំទៅប្រព្រឹត្តធ្វើអំពើអកុសលឲ្យជ្រុលហួសទៅហើយ ៗ ទើបបែរត្រឡប់មកប្រព្រឹត្តធ្វើអំពើសុចរិតជាខាងក្រោយវិញ កុសលផលសុចរិតនោះឯង ក៏គង់មិនលះបង់ចោលសត្វនោះឡើយ អាចទ្រទ្រង់នូវម្ចាស់បុណ្យនោះឲ្យអណ្តែតឡើងទៅកើតក្នុងសុគតិភពបាន ព្រោះកុសលកម្មនោះមានសភាពជាគ្រឿងអណ្តែតទៅខាងលើនោះឯង ។

សេចក្ដីនេះប្រហែលគ្នានឹងបទគាថាដែលលោកបានពោលទុក មកថាដូច្នេះ ។

ភត្តិកានំយថានាវា    អប្បមាណគរុភារា
អតិភារំសមាទាយេ    អណ្ណវេអវសីទតិ
ឯវមេវនរោបាបំ    ថោកំថោកម្បិអាចិនំ
អតិភារំសមាទាយ    និរយេវនិមុជ្ជតិ
តស្មាកិញ្ចិតមំនារិ    សិត្តាតេលហុមេស្សតិ
សុតិត្តុបរតោបាបំ    និព្វានស្សានុបាទិកន្ដិ ។

សេចក្ដីថា ទូកឬសំពៅតែងទ្រទ្រង់ឬផ្ទុកនូវភារជាទម្ងន់ហួសប្រមាណហើយ គង់នឹងលង់លិចចុះទៅកាន់បាទសមុទ្រមិនខាន ព្រោះតែផ្ទុកនូវទំនិញរបស់អ្នកឈ្មួញទាំងឡាយច្រើន សេចក្ដីនេះមានឧបមាដូចម្ដេចមិញ ថាមានឧបមេយ្យដូចនរជនទាំងពួង ដែលខំសន្សំធ្វើនូវអំពើបាបកម្មបន្តិច ៗ ក៏គង់នឹងលង់លិចចុះទៅកាន់ទីនរកមិនខាន ព្រោះតែផ្ទុកនូវបាបកម្មដ៏ធ្ងន់នោះឯង ហេតុដូច្នោះនរជាតិប្រុសស្រីគួរគប្បីស្ដារនូវទូកពោលគឺអត្តភាពដែលមានបន្តិចបន្តួចនោះចេញឲ្យស្រាល គឺ

បានដល់នូវត្រើយខាងនាយ ដែលមានកំពង់បតដ៏ល្អប្រពៃ ពោលគឺអមតមហានិព្វាន ដែលមិនមានសេសសល់នៃកិលេស តិចតួចឡើយ បពិត្រសម្តេចមហារាជ អាត្មាភាពអធិប្បាយ ថ្វាយសេចក្តីមកប៉ុណ្ណោះ សូមមហាបពិត្រស្តេចជ្រាប ។

ម. កល្លោសិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់ ពេញជាអ្នកឆ្លៀវឆ្លាសពេកណាស់ ខ្ញុំអស់សង្ស័យហើយ ។

អនាគតបញ្ហា ៗ ទី ៣

ព្រះបាទសម្តេចមិលិន្ទាធិបតិស្តេចទ្រង់សួរទៅ ព្រះនាគសេនថេរក្នុងប្រស្នាទី ៣ ក្នុងវគ្គទី ៧ នេះថា បពិត្រព្រះនាគសេនម្ចាស់ដ៏ចំរើន សព្វថ្ងៃនេះប្រហែលជាលោកម្ចាស់ខំព្យាយាមដើម្បីលះបង់នូវអនាគតទុក្ខ គឺទុក្ខដែលមិនទាន់មានមក នោះឬ ។

ន. នហិមហារាជ បពិត្រមហារាជអាត្មាភាពមិនមែន ព្យាយាម.ដើម្បីលះបង់នូវទុក្ខក្នុងអនាគតនោះទេ ។

ម. កឹបនភន្តេ បពិត្រព្រះថេរដ៏ចំរើន បើលោកម្ចាស់

មិនព្យាយាមដើម្បីរំលត់ទុក្ខក្នុងអតីតនឹងអនាគតនោះទេ ប្រហែលជាលោកម្ចាស់ព្យាយាមនឹងរំលត់នូវបច្ចុប្បន្នទុក្ខគឺទុក្ខក្នុងបច្ចុប្បន្ននេះឬអ្វី ។

ន. នហិមហារាជ បពិត្រមហារាជ អាត្មាភាពមិនមែនព្យាយាមបំរុងនឹងរំលត់ទុក្ខក្នុងបច្ចុប្បន្ននេះទេ ។

ម. យទិតុម្ហេភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ថាបើលោកម្ចាស់មិនព្យាយាមដើម្បីនឹងរំលត់នូវអតីតទុក្ខ អនាគតទុក្ខនឹងបច្ចុប្បន្នទុក្ខទេ ចុះសព្វថ្ងៃនេះព្រះថេរធ្វើសេចក្ដីព្យាយាមដើម្បីហេតុអ្វី ។

ន. កិន្តិមហារាជ បពិត្រព្រះរាជសម្ភារ ចុះហេតុដូចម្ដេចក៏មហាបពិត្រស្ដេចទ្រង់សួរដូច្នេះទៀត សេចក្ដីនេះអាត្មាភាពបានថ្វាយព្រះពររួចអំពីមុនមកហើយតើ ថាអាត្មាភាពបួសសព្វថ្ងៃនេះ ដើម្បីនឹងធ្វើសេចក្ដីព្យាយាមរំលត់នូវគឺនរទុក្ខនេះ នឹងមិនឲ្យទុក្ខដទៃកើតឡើងបាននោះឯង សូមមហាបពិត្រជ្រាប ។

ម. អត្ថិបនភន្តេ បពិត្រព្រះថេរដ៏ចំរើន បើដូច្នោះលោក

ម្ចាស់ធ្វើព្យាយាមសព្វថ្ងៃនេះ ដើម្បីនឹងរំលត់នូវទុក្ខដែលមិនទាន់មានមកនោះឯងឬ ។

៦. អាមមហារាជ បពិត្រសម្តេចមហារាជ អាត្មាភាពខំធ្វើព្យាយាមនឹងបន្ទោបង់នូវអនាគតទុក្ខ ដូចព្រះរាជឱង្ការនេះឯង សូមទ្រង់ជ្រាប ។

ម. តុម្ហេខោបនភន្តេ បពិត្រព្រះនាគសេនថេរដ៏ចំរើន លោកម្ចាស់ឆ្លៀវឆ្លាតពេកណាស់ ពេញទីជាបណ្ឌិតយ៉ាងឆើតយ៉ាងផ្តើមក្នុងលោកនេះ តែខ្ញុំមានសេចក្តីសង្ស័យពេកនឹងភាសិតរបស់លោកម្ចាស់សំដែងថា អង្គលោកម្ចាស់សព្វថ្ងៃនេះខំព្យាយាមដើម្បីនឹងរំលត់ឬបន្ទោបង់នូវទុក្ខទាំងឡាយដែលមិនទាន់មានមក ចុះបើទុក្ខទាំងនោះមិនទាន់កើតឡើងទេ លោកម្ចាស់ប្រឹងធ្វើព្យាយាមកំចាត់បង់នូវវត្ថុអ្វី សេចក្តីនេះគួរឲ្យសង្ស័យពេក សូមលោកម្ចាស់អធិប្បាយឲ្យងាយស្តាប់បន្តិចមកមើល ។

៦. អត្ថិបនអាមហារាជ បពិត្រសម្តេចមហារាជ ចុះក្នុងដែនគររបស់មហាបពិត្រ ប្រហែលជាមានមហាក្សត្រជា

សត្រូវឬជាបច្ចាមិត្រឯណានិមួយមានប្រាថ្នាចង់បានតែងលើកមកបៀតបៀនដណ្ដើមយកដែរឬ មហាបពិត្រ ។

ម. អាមភន្តេ បពិត្រព្រះបេរដ៍បំរើន ស្ដេចដែលជាសត្រូវនោះតែងមាន លោកម្ចាស់ ។

ន. កីន្នុខោមហារាជ បពិត្រមហាក្សត្រាធិរាជ បុះបើទ្រង់មានព្រះរាជឱង្ការត្រាស់ថា ស្រុកនគររបស់ព្រះអង្គតែងមានមហាបច្ចាមិត្រជាសត្រូវ មានបំណងចង់បានដោយពិត បុះព្រះអង្គនឹងអត់ទ្រាំចាំឲ្យសត្រូវទាំងនោះ លើកពួកពលសេនាទាហ៊ានចូលមកដល់ផ្ទាល់តួព្រះអង្គហើយ ទើបចាត់ចែងឲ្យជីកគូធ្វើកំពែង ធ្វើទ្វារស្រុក ធ្វើទ្វារនគរ លើកពួនភាគបន្ទាយនឹងនាំមកនូវស្រូវទាំងពួងបំរុងទុកធ្វើស្បៀងអាហារក្នុងវេលាជាមួយនឹងសត្រូវចូលមកនោះឬអ្វីព្រះអង្គ ។

ម. នហិភន្តេ បពិត្រព្រះបេរដ៍បំរើន ខ្ញុំមិនបណ្ដោយចាំឲ្យសត្រូវលុកលុយចូលមកដល់ហើយទើបចាត់ចែងការពារស្រុកដូច្នោះទេ ត្រូវចាត់ចែងរៀបចំបង្ការទុកជាមុនឲ្យស្រេបទើបបាន លោកម្ចាស់ ។

ន. កិត្តុម្ហមហារាជ បពិត្រមហារាជ បើមិនដូច្នោះ ព្រះអង្គនឹងបណ្តោយសត្រូវឲ្យចូលមកដល់ទីបំពោះព្រះភក្ត្រ ព្រះអង្គ ទើបទ្រង់ត្រាស់បង្គាប់ឲ្យបង្ហាត់ពលដំរី ពលសេះ ពលរទេះ ពលធ្នូ ពលសស្ត្រាវុធ មានដាវនឹងលំពែងជាដើមឬអ្វី មហាបពិត្រ ។

ម. នហិភន្តេ មិនមែនដូច្នោះទេលោកម្ចាស់ យើងត្រូវ បង្ហាត់បតុរង្គសេនានោះបំរុងទុកជាមុនឲ្យស្រេចទើបបាន ។

ន. កិស្សត្ថាយ ប្រយោជន៍ដើម្បីអ្វីក៏បង្ហាត់សេនាទាហានទុកជាមុន មហាបពិត្រ ។

ម. អនាគតានំភយានំបដិពាហនត្ថាយ បពិត្រព្រះបើរ ដ៏បំរើន បានជាប្រៀនប្រដៅពួកពលទាំងនោះទុកជាមុន ដើម្បីនឹងការពារនូវសេចក្តីភ័យអន្តរាយដែលមិនទាន់មានមក នោះ ឯងលោកម្ចាស់ ។

ន. អត្ថិបនមហារាជ បពិត្រមហារាជ. ចុះសេចក្តីភ័យ អន្តរាយទៅខាងមុខនោះមុខជានឹងមានមកឬអ្វីព្រះរាជសម្ភារ ។

ម. អត្ថិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ឯភ័យអន្តរាយនោះតែងមានមករឿយ ៗ មិនខាន ។

ន. តុម្ហេ ខោ មហារាជ បពិត្រមហារាជ ព្រះអង្គជាបុគ្គលប្រកបដោយបញ្ញាញាណដ៏ប្រពៃក្រៃពេក ទ្រង់បេះបាត់ការបំរុងទុកដើម្បីឃាត់ភ័យអន្តរាយដែលមិនទាន់មានមកជាមុននោះត្រូវល្អណាស់ សេចក្ដីនេះមានឧបមាដូចម្ដេចមិញ ថាមានឧបមេយ្យដូចជាអាត្មាភាពដែលតាំងការព្យាយាមបន្ទោបង់នូវទុក្ខនេះ ដើម្បីមិនឲ្យទុក្ខដ៏ទៃកើតឡើងបាននោះឯង ។

ម. ភិយ្យោ ឱបម្មំ សូមលោកម្ចាស់ឧបមាឲ្យច្រើនតទៅទៀតមើល ។

ន. តំ កឹ មញ្ញសិ មហារាជ បពិត្រសម្ដេចមហារាជ សេចក្ដីនេះព្រះអង្គនឹងទ្រង់ព្រះដំរិះដូចម្ដេចទៅ អាត្មាភាពនឹងថ្វាយព្រះពរសួរថា មហាបពិត្រស្ដេចតែងសោយនូវព្រះឧទការសជាធម្មតា បុះដែលព្រះអង្គនឹងសោយព្រះឧទកនោះទ្រង់បង្គង់ចាំស្រេកខ្លាំងហើយ ទើបបាត់ការឲ្យពួកពលជីកអណ្ដូងលើកស្រះបោក្ខរណីនឹងស្រះធំ ៗ ទាំង ៤ ហើយដងយកទឹកនោះមក

ទើបទ្រង់តាំងព្រះហឫទ័យថា អញនឹងផឹកនូវទឹកដូច្នេះឬអ្វី មហាបពិត្រ ។

ម. នហិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន មិនមែនដូច្នោះទេ ធម្មតាមនុស្សតែងផឹកទឹកតែរាល់ពេល គេត្រូវធ្វើនូវទីសម្រាប់ដម្កល់នូវទឹកគឺគេជីកអណ្តូងលើកស្រះទុកជាមុន វេលាណាត្រូវការផឹក គេដងមកផឹកភ្លាម មិនអាចទៅជីកឧទកស្ថាន-នោះទេ លោកម្ចាស់ ។

ន. កិស្សត្ថាយ ហេតុដូចម្តេចក៏បាធ្វើឧទកស្ថាននោះទុកជាមុន ។

ម. អនាគតានំភន្តេបិបាសានំ បពិត្រព្រះថេរដ៏ចំរើន បានជាធ្វើទីសម្រាប់ដម្កល់ទឹកទុកជាមុននោះ ដើម្បីនឹងការពារនូវសេចក្តីស្រេកទឹកដែលមិនទាន់មានមកនោះឯង ។

ន. អត្ថិមហារាជ បពិត្រមហារាជ កិច្ចដែលស្រេកទឹកនោះត្រូវមានមកខាងមុខមិនខានឬអ្វី ។

ម. អត្ថិភន្តេ កិច្ចដែលស្រេកទឹក ដែលមិនទាន់មានមកនោះ នឹងមានមកដល់ប្រាកដ លោកម្ចាស់ ។

ង. អតិបណ្ឌិតោ មហាបពិត្រស្ដេចមានព្រះបញ្ញាបារមីក្រៃពេកណាស់ ព្រោះទ្រង់បេះបាត់បែងនូវឧទកស្ពានទុកដើម្បីនឹងបន្ទោបង់នូវសេចក្ដីស្រេកទឹកដែលមិនទាន់មានមកនោះទុកជាមុន សេចក្ដីនេះមានគួរនាដូចម្ដេចមិញ ជាមានគួរនាដូចរូបអាត្មាភាពដែលបួសហើយ ទំព្យាយាមប្រហារនូវទុក្ខនេះ ដើម្បីមិនឲ្យទុក្ខដទៃកើតឡើងបាននោះឯង សូមស្ដេចជ្រាប ។

ន. អត្ថិបនមហារាជ បពិត្រមហារាជ ឯកិច្ចស្រេកឃ្លានត្រូវការបរិភោគដែលមិនទាន់មានមកនោះ នឹងមានមកជាខាងមុខមិនខានឬដូចម្ដេច ។

ម. អត្ថិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ឯការបរិភោគភោជនាហារទៅខាងមុខនោះនឹងមានមកមិនខានលោកម្ចាស់។

ង. អតិបណ្ឌិតោ បពិត្រសម្ដេចមហារាជ ព្រះអង្គជាបុគ្គលដ៏ឆ្លៀវឆ្លាស ជាបណ្ឌិតដ៏ក្រៃលែង ទ្រង់បេះបាត់បែងការងារទុកដើម្បីលះបង់នូវសេចក្ដីស្រេកឃ្លានដែលមិនទាន់មានមក សេចក្ដីនេះប្រៀបដូចការព្យាយាមរបស់អាត្មាភាពនោះឯង សូមទ្រង់ជ្រាប ។

ម. កល្លោសិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន លោកជាបុគ្គលឆ្លៀវឆ្លាសប្រពៃពេក បេះឧបមានុបមេយ្យគួរឲ្យចូលចិត្តស្តាប់បាន ខ្ញុំអស់សង្ស័យហើយក្នុងរឿងនេះ ។

ទូរព្រហ្មលោកបញ្ហា ៗ ទី ៤

ព្រះមហាក្សត្រស្តេចទ្រង់ត្រាស់បុច្ឆាទៅព្រះនាគសេនថេរក្នុងបញ្ហា ទី ៤ ក្នុងវគ្គទី ៧ តទៅទៀតថា បពិត្រព្រះថេរដ៏ចំរើន កីវទូរោឥតោព្រហ្មលោកោ ទីស្ថានព្រហ្មលោកនោះតើមានចំងាយប៉ុន្មានអំពីមនុស្សលោកនេះទៅ លោកម្ចាស់ ។

ន. ទូរោខោមហារាជ បពិត្រមហារាជ រីឯវិមានស្ថានព្រហ្មលោកនោះ ឆ្ងាយដាច់ស្រយាលក្រៃពេកណាស់ អំពីមនុស្សលោកនេះឡើងទៅ មានប្រមាណដល់ ៤៨,០០០ យោជន៍ ហើយមានពាក្យលោកប្រៀបទុកមកថា ដុំថ្មមួយដុំមានទំហំប្រមាណប៉ុនដំបូលផ្ទះ ដុំនោះធ្លាក់ចុះមកពីស្ថានព្រហ្មលោកនោះ មកដល់ផែនដីនេះអស់ពេលចំនួន ៤ ខែគត់ទើបដល់មក សូមមហារាជជ្រាប ។

ម. ភន្តេនាគសេន បពិត្រព្រះនាគសេនដ៏ចំរើន លោកម្ចាស់បានពោលពីជាន់មុនថា មានភិក្ខុដែលមានឫទ្ធានុភាពជាអ្នកមានចិត្តស្ទាត់ជំនាញដោយឈានសមាបត្តិ បានហោះឡើងអំពីមនុស្សលោកទៅកាន់ព្រហ្មលោកឆាយ តែមួយរំពេចបានដល់ទៅ ប្រហែលគ្នានឹងបុរសដែលមានកំឡាំងលាកដៃចេញទៅនឹងបត់ដៃចូលមកវិញប៉ុណ្ណោះឯង ពាក្យលោកម្ចាស់នេះខ្ញុំមិនអាចជឿបានទេ ព្រោះថាទីឆ្ងាយដល់ទៅមួយរយយោជន៍ ហេតុអ្វីក៏ទៅឆាប់ម្លេះ ។

ន. កុមារបនមហារាជ បពិត្រមហារាជ ជាតិភូមិដែលព្រះអង្គប្រសូតិនោះតើមាននៅក្នុងទីឯណា ។

ម. អត្ថិភន្តេ បពិត្រព្រះបេរដ៏ចំរើនឯទីកន្លែងដែលខ្ញុំកើតនោះមាន ទីនោះជាកោះឈ្មោះថាអលសណ្ឌទ្វីប សូមលោកម្ចាស់ជ្រាប ។

ន. កីវទូរេ មហារាជ បពិត្រមហារាជ អលសណ្ឌទ្វីបនោះមានចំងាយប៉ុន្មានយោជន៍អំពីទីនេះទៅ មហាបពិត្រ ។

ម. អត្ថិភន្តេ បពិត្រព្រះបេរដ៏ចំរើន ឯអលសណ្ឌទ្វីប

នោះមានចំងាយ ២០០ យោជន៍ អំពីទីនេះទៅ សូមលោកម្ចាស់ជ្រាប ។

ន. អភិជានាសិ បពិត្រព្រះរាជសម្ភារ ព្រះអង្គស្ដេចទ្រង់ចាំប្រាកដហើយទីនោះ ចុះព្រះអង្គនឹងអាចរលឹកដល់ការងារដែលទ្រង់បានធ្វើទុកនៅក្នុងទីនោះបានឬទេ ។

ម. អាមភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំអាចរលឹកបានដោយងាយ ។

ន. លហុំខោ មហារាជ បពិត្រព្រះរាជសម្ភារព្រះអង្គស្ដេចទ្រង់រលឹកទៅកាន់ទីឆ្ងាយចំងាយ ២០០ យោជន៍ បានក្នុងមួយរំពេចភ្នែក មហោបពិត្រ ។

ម. កល្លោសិភន្តេ បពិត្រព្រះថេរដ៏ចំរើន លោកម្ចាស់ជាអ្នកឆ្លៀវឆ្លាសប្រពៃពេក បេះប្រៀបពន្យល់ដោយស្រួលងាយស្ដាប់ណាស់ ។

ព្រហ្មលោកកស្មិនគរបញ្ហា ៦ ទី ៥

ព្រះបាទមិលិន្ទស្ដេចទ្រង់សួរទៅព្រះនាគសេនថេរក្នុងប្រ-

ស្ថានទី៥នេះថា បពិត្រព្រះនាគសេនដ៏បំរើន មនុស្សម្នាក់ធ្វើកាលកិរិយាស្លាប់អំពីទីនេះ ហើយទៅកើតឯស្ថានព្រហ្មលោក មនុស្សម្នាក់ទៀតធ្វើកាលកិរិយាអំពីទីនេះដែរ តែនៅកើតក្នុងស្ថានមនុស្ស ត្រឹមក្រុងកស្មិរនេះ បណ្ដាមនុស្សទាំងពីរពួកនេះ មនុស្សពួកណាទៅកើតមុន ពួកណាទៅកើតក្រោយ លោកម្ចាស់ ។

ព្រះនាគសេនថ្វាយព្រះពរថា សមកំមហារាជ បពិត្រមហារាជ ឯមនុស្សទាំងពីរក្រុមនេះទៅកើតស្មើគ្នាព្រមគ្នា សូមស្ដេចជ្រាប ។

ម. ឧបមំកពោហិ បុះហេតុអ្វីក៏បានជាទៅកើតស្មើគ្នា បើទីនោះមិនស្មើគ្នាទេ លោកម្ចាស់ សូមលោកម្ចាស់ឧបមាជាសេចក្ដីបន្ទិចមកមើល ។

ន. កុហិំបនមហារាជ បពិត្រសម្ដេចមហារាជ អាត្មាភាពសូមថ្វាយព្រះពរសួរមហាបពិត្រថា បុះជាតិភូមិគឺភូមិដែលព្រះអង្គទ្រង់ប្រសូតិនោះតើ នៅត្រង់ទីណាមានឈ្មោះថាអ្វី ។

ម. អត្ថិភន្តេ បពិត្រព្រះថេរដ៏បំរើន ឯស្រុកដែលខ្ញុំកើត

នោះមានឈ្មោះថា កាលសិរគ្រាមនៅក្នុងកោះឈ្មោះអលសណ្ឋ-ទ្វីបលោកម្ចាស់ ។

ន. កីរទូរោមហារាជ បពិត្រសម្ដេចមហារាជ ចុះស្រុកកាលសិរនោះមានចំងាយប៉ុន្មានយោជន៍អំពីទីនេះទៅ ។

ម. ទ្វិមត្តានិយោជនសតានិ បពិត្រលោកម្ចាស់ដ៏ចំរើនអំពីទីនេះទៅ ដល់កាលសិរគ្រាមនោះ មានចម្ងាយ ២០០ យោជន៍លោកម្ចាស់ ។

ន. កីវទូរំមហារាជ បពិត្រសម្ដេចមហារាជ ចុះអំពីទីនេះទៅក្រុងកស្មិរនោះតើមានចម្ងាយប៉ុន្មានយោជន៍ ។

ម. ទ្វាទសយោជនានិ បពិត្រលោកម្ចាស់ដ៏ចំរើន អំពីទីនេះទៅក្រុងកស្មិរនោះមានប្រមាណ ១២ យោជន៍ ។

ន. កាលសិរគាមំចិន្តេហិ សូមមហាបពិត្រស្ដេចទ្រង់ព្រះចិន្តានឹកអំពីទីនេះទៅកាន់ស្រុកកាលសិរដែលមានចម្ងាយ ២០០ យោជន៍នោះលមើលមើរ ។

ម. ចិន្តិតោភន្តេ ខ្ញុំបានរំពឹងនឹករួចហើយលោកម្ចាស់ ។

គ. កសិ្មរនគរំបិន្ទេហិ  សូមមហារាជស្ដេចនឹកទៅក្រុង កសិ្មរដែលមានចំងាយ ១២ យោជន៍នោះទៀតមើល ៕

ម. បិន្ទិតំភន្តេ  ខ្ញុំបាននឹករួចហើយលោកម្ចាស់ ៕

គ. កតមំនុខោមហារាជ  បពិត្រមហារាជ  បុះកាលដែល ព្រះអង្គទ្រង់ព្រះចិន្ដានឹកទៅកាន់ស្រុកទាំងពីរនោះតើ  នឹកទៅ ដល់ស្រុកណាយូរស្រុកណាឆាប់ ៕

ម. សមកំភន្តេ  ស្មើតែគ្នានេះឯងលោកម្ចាស់ ៕

គ. ឯវមេខោមហារាជ  បពិត្រសម្ដេចមហារាជ  សេចក្ដី នេះមានឧបមាដូចម្ដេចមិញ  ជាមានឧបមេយ្យដូចជាមនុស្ស ដែលស្លាប់អំពីទីនេះហើយឡើងទៅកើតឯស្ថានព្រហ្មលោក នឹងមនុស្សដែលស្លាប់អំពីទីនេះហើយនៅកើតក្នុងកសិ្មរនគរនេះ វិញ  មនុស្សទាំងពីរពួកនេះក៏អាចកើតព្រមគ្នាស្មើគ្នា  សូម ស្ដេចជ្រាប ៕

ម. ភិយ្យោឧបមំករោហិ  សូមលោកម្ចាស់ប្រៀបឧបមា ថែមមកទៀតមើល ៕

គ. យថាមហារាជ  បពិត្រមហារាជ  សេចក្ដីនេះប្រៀបដូច

សត្វបក្សីពីររូប បណ្ដាសត្វទាំងពីរនោះជាសត្វហើរទៅដោយអាកាសសំដៅទោះកទំទំលើចុងឈើ តែសត្វ ១ រូបទំនៅចុងឈើដ៏ទាប សត្វ ១ ទំនៅចុងឈើដ៏ខ្ពស់ វេលាដែលចាប់ទំនៅចុងឈើនោះក៏ទំព្រមគ្នាមិនមុនមិនក្រោយ ព្រះស្រមោលសត្វទាំងពីរនោះ ស្រមោលសត្វណាដល់មកផែនដីនេះមុនគេមហារាជ ។

ម. សមកំភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ឯស្រមោលសត្វទាំងពីរនោះ ដកដិតប្រាកដលើផែនដីនេះស្មើគ្នាទាំងអស់មិនមុនមិនក្រោយ ។

ន. ឯវមេវខោ មហារាជ បពិត្រមហារាជ សេចក្ដីនេះប្រៀបដូចមនុស្សសត្វដែលធ្វើកាលកិរិយាចាកទីនេះ ហើយឡើងទៅកើតឯស្ថានព្រហ្ម និងមនុស្សសត្វដែលធ្វើកាលកិរិយាចាកទីនេះ ហើយទៅកើតក្នុងក្រុងកស្មិរនេះ ឯអ្នកទាំងពីរនោះ គង់កើតព្រម ៗ គ្នាមិនមុនមិនក្រោយ ដូចជាស្រមោលសត្វទាំងពីររូបនោះឯង ។

ម. ភិយ្យោឧបមំករោហិ សូមលោកម្ចាស់ប្រៀបឧបមាឲ្យវិសេសជាងនេះតទៅទៀតមើល ។

ន. ឥមំមហារាជឱលោកហិ បពិត្រមហារាជ សូមព្រះអង្គស្ដេចទ្រង់ទស្សនាការទតមកខ្លួនអាត្មាភាពមើល ។

ម. ឱលោកិតោភន្តេ បពិត្រព្រះថេរដ៏ចំរើន ខ្ញុំបានមើលឃើញព្រះភក្ត្រលោកម្ចាស់ច្បាស់ហើយ ។

ន. ចន្ទិមសូរិយំឱលោកេហិ សូមព្រះរាជសម្ភារទ្រង់ទតព្រះនេត្រទៅត្រង់ចន្ទមណ្ឌលនឹងសូរិយមណ្ឌលឯអាកាសឯនោះមើល ។

ម. ឱលោកិតោភន្តេ ខ្ញុំបានមើលឃើញនូវមណ្ឌលនៃព្រះចន្ទនឹងព្រះអាទិត្យនោះហើយលោកម្ចាស់ ។

ន. តយាមហារាជ បពិត្រមហារាជ ចុះកាលដែលព្រះអង្គទ្រង់ទតព្រះនេត្រមកត្រង់អាត្មាភាពដែលនៅជិតបន្ទាប់ព្រះអង្គនេះហើយនឹងទ្រង់ទតព្រះនេត្រទៅឯព្រះចន្ទ នឹងព្រះអាទិត្យដែលមានចម្ងាយ ៤២.០០០ យោជន៍ឯនោះ តើឯណាឆាប់ឯណាយូរជាង ។

ម. សមសមកំសមាចិត្តំ លោកម្ចាស់ឯកិច្ចដែលក្រឡេក មើលត្រង់ទៅលោកម្ចាស់ ហើយនឹងមើលត្រង់ទៅព្រះចន្ទនឹង ព្រះអាទិត្យនោះ មិនមានយឺតមិនមានរហាស់ជាងគ្នាៈទគឺស្មើ ៗ គ្នា ទាំងសន្ទុសរបស់ចិត្តទៀតក៏ប្រហែល ៗ គ្នាដែរ ។

ន ឯវមេវមេខោមមហារាជ បពិត្រសម្តេចមហារាជ សេចក្តីនេះមានឧបមាដូចម្តេចមិញ ថាមានគួរនាដូចជាសត្វ ដែលធ្វើកាលកិរិយាចាកមនុស្សលោកនេះហើយ ឡើងទៅកើត ឯស្ថានព្រហ្មលោក នឹងសត្វដែលស្លាប់អំពីមនុស្សលោកនេះ ហើយទៅកើតក្នុងត្រឹមក្រុងកស្មិរនេះវិញ ក៏សត្វទាំងពីរពួកនេះ គង់កើតព្រម ៗ គ្នាដូច្នោះឯង ។

ម. កល្លោសិភន្តេ បពិត្រព្រះបេរដ៏ចំរើន លោកម្ចាស់ឆ្លៀវ ឆ្លាសវៀងវៃពេក ប្រសប់ឧបមានុបមេយ្យគួរឡប្ចូលចិត្តងាយ ៗ ខ្ញុំអស់សង្ស័យហើយ ។

ព្រហ្មលោកគតនីលបីតាទិវណ្ណគតបញ្ហា ១ ទី ៦

ព្រះបាទសម្តេចមិលិន្ទរាជទ្រង់ព្រះរាជបុច្ឆាចំពោះទៅព្រះ- នាគសេនបេរថា អហំភន្តេនាគសេន ឧត្តរិការណំ បុច្ឆិស្សាមិ

បពិត្រព្រះនាគសេនដ៏ចំរើន ខ្ញុំសូមសួរលោកម្ចាស់ចំពោះហេតុនេះឲ្យប្រាកដជាក់ស្តែងតទៅទៀត ដើម្បីនឹងអស់សេចក្តីសង្ស័យ ក្នុងចិត្តនៃខ្ញុំនឹងអ្នកឯទៀត បពិត្រព្រះនាគសេនដ៏ចំរើន សត្វលោកដែលធ្វើកាលកិរិយាស្លាប់ចាកមនុស្សលោកនេះទៅ ហើយនឹងទៅកើតក្នុងបរលោកគឺលោកខាងមុខទៀតនោះតើសត្វទាំងនោះនឹងមានពណ៌សម្បុរខៀវឬបៃតង ក្រហមសរ ហង្សបាត ឬមានពណ៌ឪភាសភ្លឺផ្លេក បណ្តាពណ៌ទាំង ៦ ប្រការនេះ តើសត្វលោកនឹងមានពណ៌យ៉ាងណា មានពណ៌ខៀវឬបៃតងជាដើម ក្នុងរវាងពាក់កណ្តាលផ្លូវដែលសត្វកំពុងលឿនទៅនោះ ពុំនោះសោតសត្វលោកនឹងចេញទៅនោះតើមានសណ្ឋានទ្រង់ទ្រាយ បែបផែនដូចជាអ្វី ដូចសត្វដីរឬដូចសេះដូចរទេះ លោកម្ចាស់ ។

ព្រះនាគសេនថ្វាយព្រះពរថា "អបញ្ញត្តំមហារាជ ភគវតាតេបិដកេពុទ្ធវចនេនត្ថិ" បពិត្រសម្តេចមហារាជ ឯសត្វលោកដែលធ្វើកាលកិរិយា អំពីមនុស្សលោកនេះទៅ នឹងទៅកើតទៀតក្នុងបរលោកនោះ ឥតមានពណ៌សម្បុរ ខៀវក្រហមបៃតង

សរ ហង្សព្យាត ឬមានឱភាសភ្លឺផ្លេកអ្វីនីមួយ ដូចព្រះរាជឱង្ការនោះទេ ម្យ៉ាងទៀតនឹងមានសណ្ឋានទ្រង់ទ្រាយ ដូចដីរឺដូចសេះ ដូចរទេះ នោះក៏ទេទាំងអស់ ព្រះសម្មាសម្ពុទ្ធនឹងបានសំដែងបញ្ញត្តទុកក្នុងព្រះត្រៃបិដកត្រង់កន្លែងណា ១ ក៏គ្មានគ្រប់អន្លើ សូមមហារាជជ្រាប ។

ម. យទិកន្តេនាគសេន បពិត្រព្រះនាគសេនដ៏ចំរើន បើព្រះសមណគោតមបរមគ្រូទ្រង់មិនបានសំដែងបញ្ញត្តទុកថាសត្វលោកដែលស្លាប់ទៅកាន់បរលោកនាយនោះ មិនបានប្រកដដោយពណ៌សម្បុរ ខៀវ សរ ជាដើម ឯណានីមួយទេបើដូច្នោះមានតែសត្វទាំងនោះមិនទៅកើតក្នុងបរលោកទៀត បើសត្វមិនទៅកាន់បរលោកហើយ ទាំងបរលោកនោះក៏គ្មានដែរកាលបើបរលោកគ្មានហើយ ទៅសមគ្នានឹងពាក្យរបស់មិច្ឆាទិដ្ឋិ ដែលឈ្មោះថាគុណាជីវកនោះឯង ឯគុណាជីវកនោះពួកជទៃគេបានលើកដំកើងថាជាគ្រូអាចារ្យបណ្ឌិតយ៉ាងធំ ជំពូកមួយខាងពួកឯទៀតដែរ ហើយគុណាជីវកនោះបានពោលទុកថា នត្ថិលោកោ នត្ថិបរលោកោ សត្តោបរលោកំនគច្ឆតិ

សេចក្ដីថា លោកនេះមិនមាន លោកខាងមុខក៏មិនមានដែរ សត្វលោកដែរស្លាប់ទៅ មិនទៅកាន់បរលោកឡើយ យ៉ាង នេះឬអ្វីលោកម្ចាស់ ។

ន. សុណោកើមហារាជមមរាក្សំ បពិត្រមហារាជសូម ព្រះរាជសម្ភារទ្រង់ព្រះសណ្ដាប់ពាក្យរបស់អាត្មាភាពឲ្យច្បាស់ សិន ។

ម. សុណោមិតរ៉ាក្សំ ខ្ញុំស្ដាប់ពាក្យរបស់លោកម្ចាស់បាន ច្បាស់ហើយ ។

ន. មមរាក្សំ បុះសួរសំដីរបស់អាត្មាភាពដែលចេញផុត អំពីមាត់អាត្មាភាពទៅ ៗ កាន់ព្រះសោតរបស់ព្រះអង្គនោះ តើទ្រង់នឹងទស្សនាការទតព្រះនេត្រទៅឃើញនូវពណ៌សម្បុរ របស់សំដីនោះ ជាមានពណ៌ខៀវបៃតង ឬសរក្នុងរាំងពាក់ កណ្ដាលផ្លូវ ដែលសំឡេងកំពុងចេញទៅនោះដែរឬ ។

ម. នបស្សាមិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំមើល នូវពណ៌សំដីនោះមិនឃើញទេ ។

ន. យទិមហារាជ បពិត្រមហាជ ជាបើមហាបពិត្រ

ទ្រង់ទតព្រះនេត្រទៅមិនឃើញពណ៌សម្បុរនៃសំដីនោះទេ បើដូច្នោះមានតែសំដីនោះ មិនបានចូលទៅកាន់ព្រះសោតនៃព្រះអង្គទេ កាលបើសំដីនោះមិនបានចូលទៅដល់ព្រះសោតទេ ចុះហេតុអ្វីក៏ព្រះអង្គមានព្រះរាជឱង្ការត្រាស់ថា ទ្រង់បានឮពាក្យរបស់អាត្មាភាពដែរ ប្រហែលជាព្រះអង្គទ្រង់មានព្រះរាជឱង្ការនោះ ជាពាក្យមុសាវាទទេដឹង ។

ម. នអលិកំភណាមិ ខ្ញុំមិនបានពោលពាក្យមុសាវាទទេលោកម្ចាស់ ឯសព្ទសំដីសូរសំឡេងលោកម្ចាស់នេះ ខ្ញុំបានឮច្បាស់ប្រាកដមែន តែត្រង់ពណ៌សម្បុរនៃសំដីនោះ ខ្ញុំមិនបានឃើញទេ ។

ន. ឯវមេវខោមហារាជ បពិត្រមហារាជ សេចក្ដីនេះមានឧបមាដូចម្ដេចមិញ ថាមានឧបមេយ្យដូចសត្វទាំងពួងដែលធ្វើកាលកិរិយាចាកស្ថានមនុស្សលោកនេះទៅ រមែងតែងទៅកើតក្នុងបរលោកនាយដោយពិត តែត្រង់រូបរាងសណ្ឋានទ្រង់ទ្រាយឬពណ៌សម្បុររបស់សត្វ ដែលកំពុងត្រេចឡើនទៅក្នុងរវាងពាក់កណ្ដាលផ្លូវនោះ មិនប្រាកដជារូបដីវឬរូបសេះពណ៌

ខ្មៅឬសរដូចម្ដេចនោះបានឡើយ ឯត្រង់តួសត្វទាំងឡាយទៀត តែទៅកើតទៀតប្រាកដមិនខាន ប្រៀបដូចជាសូរសំដីនៃអាត្មា ភាព ដែលចេញអំពីមាត់ហើយចូលទៅក្នុងព្រះសោតថ្លៃនៃ មហាបពិត្រនោះ នឹងបានមានរូបរាងសណ្ឋានទ្រង់ទ្រាយ ឬ ពណ៌សម្បុរខ្មៅសរដូច្នេះដូច្នោះក៏ទេ សូមថ្វាយព្រះពរ ។

ម. អច្ឆរិយំភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន សេចក្ដី វិសជ្ជនាដោះស្រាយអាថ៌ប្រស្នា របស់ព្រះករុណាម្ចាស់នេះ ជា ការអស្ចារ្យចំឡែកពេកណាស់ គួរឲ្យកោតឲ្យស្ញើចជាទីបំផុត លោកម្ចាស់ជាបុគ្គលមានបញ្ញាបារមី ឆ្លៀវឆ្លាសរឿងរ៉ៃយ៉ាង ផ្ដើមក្នុងលោក បើតាមអានុភាពរបស់លោកម្ចាស់ដែលមាន បញ្ញាញាណឈ្វេងយលមានប្រតិពលចេះដឹងយ៉ាងនេះនោះ គួរតែសោយនូវមហាសម្បត្តិដ៏ប្រសើរដែលមាននៅក្នុងសកល ជម្ពូទ្វីបទាំងមូលនេះទើបសម លុះព្រះបរមក្សត្រស្ដេចទ្រង់សរ សើរយ៉ាងនេះហើយទើបទ្រង់ត្រាស់សួរទៅព្រះនាគសេនបេរត ទៅទៀតថា ព្រះករុណាម្ចាស់ ញោមចូលចិត្តថាខន្ធទាំង ៥ ប្រការមានរូបក្ខន្ធជាដើម នេះជាធម្មជាតិមិនទៅកាន់បរលោក

តាយទេ កាលបើខន្ធទាំង ៥ ប្រការនេះមិនទៅកើតឯបរលោកទៀតទេ មានតែបញ្ញក្ខន្ធនេះផតមានកុសលាកុសលកម្មអ្វីនីមួយដែលសត្វធ្វើទុកនោះមកជួយតាក់តែងឡើយ វិលាត្រីវកើតក៏កើតឡើងឯង កាលបើបញ្ញក្ខន្ធនេះមិនមានកុសលនឹងអកុសលតាក់តែងទេ អាចកើតបានដោយខ្លួនឯងហើយ ពាក្យដែលថាសំសារគឺប្រទេសសម្រាប់សត្វវិលស្លាប់វិលកើតនោះក៏មិនមានដែរ នេះតាមញោមចូលចិត្តថាយ៉ាងនេះ ជាគួរឬមិនគួរទេ លោកម្ចាស់ ។

ឥ. ខេត្តការាបេយ្យាសិ បពិត្រមហារាជ អាត្មាភាពសូមសួរព្រះរាជសម្ភារថា ចុះមហាបពិត្រស្តេច ដែលបានបាត់បែងឲ្យពួកពលធ្វើស្រែព្រោះស្រូវដែរឬ ។

ម. អាមភន្តេ ខ្ញុំដែលឲ្យគេធ្វើដែរស្រែនោះលោកម្ចាស់ ។

ឥ. ឧទ្ទំសាលគ្គិគច្ចតិ បពិត្រព្រះរាជសម្ភារ ចុះស្រូវសាលីដែលគេដាំផ្លាស់ទៅនឹងផែនដីនោះ នឹងមានគ្រាប់ឡើងទៅកើតជាកួរឬជាផ្លែងចុងស្រូវខាងលើនោះដែរ ឬមិនមានធម្មជាតិអ្វីឡើងទៅកើតខាងលើនោះទេ ឯកួរស្រូវនៅចុងនោះ

គឺកើតឡើងឯង ឥតមានមនុស្សណាតាក់តែងព្រោះដាំទេ ឬ មហាបពិត្រ ។

ម. ភន្តេនាគសេន បពិត្រព្រះនាគសេនដ៏ចំរើន ឯគ្រាប់ស្រូវដែលជនដាំនៅផែនដីនោះមុខជានឹងប្រព្រឹត្តឡើងទៅឯចុងស្រូវខាងលើនោះមិនខានទេ បានជាមានផ្លែស្រូវឬកួរស្រូវនៅខាងវីបំផុតនោះ មិនមែនកួរស្រូវនៅចុងនោះកើតឡើងឯងឥតមានគេសាបព្រោះនោះទេ លោកម្ចាស់ ។

ន. យទិមហារាជ បពិត្រសម្តេចមហារាជ បុះបើស្រូវដែលបុគ្គលដាំនោះ កំពុងលូតលាស់ស្រួលដើម មិនទាន់មានផ្លែចេញមកខាងចុងទៅឡើយ នឹងថាជាស្រូវនោះមិនមានគេដាំទេ ឬទើបមិនឃើញមានផ្លែចេញមកប្រាកដ ឬនឹងថាស្រូវនោះមិនមែនជាស្រូវទេ មហាបពិត្រ ។

ម. នហិភន្តេ បពិត្រព្រះថេរដ៏ចំរើន ឯស្រូវដែលគេបានព្រោះដាំទុកហើយ ៗ មិនទាន់មានផ្លែចេញមកនោះនឹងថាជាស្រូវគឺមនុស្សមិនបានដាំមិនបានធ្វើនោះអិនមែនទេ គឺស្រូវនោះប្រាកដជាកើតដោយមនុស្សធ្វើ តែមិនទាន់ដល់ពេលដល់

វដ្តនោះឡើយ បានជាមិនទាន់មានផ្លែ ប្រការមួយទៀតឯស្រូវសាលីដែលបុគ្គលបានដាំផ្ទាល់ទៅនឹងផែនដីហើយ ទៅខាងមុខ ៗ ជានឹងមានកុំបរិបូណ៌មិនខាន ម្យ៉ាងទៀតថាបើស្រូវនោះកើតឡើង រកអ្នកធ្វើគ្មាន អ្នកដាំគ្មាន ឯបុគ្គលដែលប្រូតស្រូវមកគរជាគំនរទុក ធ្វើជាធ្មឹមនោះក៏គ្មានដែរ ទៅជាស្រូវនោះកើតឡើងឯង ៗ ទៅហើយលោកម្ចាស់ ។

៦. ឯវមេវខោមហារាជ បពិត្រសម្តេចមហារាជ សេចក្តីនេះគួរនាដូចម្តេចមិញ ថាមានគួរនាដូចបញ្ចក្ខន្ធនោះឯង បពិត្រមហារាជ ថាបើបញ្ចក្ខន្ធនេះអាចនឹងទៅកើតក្នុងលោកទៀតបាន, មនុស្សណាដែលធ្លាប់ខ្វាក់ភ្នែក ឬថ្លង់ត្រចៀកក្នុងជាតិនេះ វេលាដល់នឹងទៅកើតទៀតក្នុងបរលោកនាយ ក៏នឹងទៅជាមនុស្សខ្វាក់ភ្នែកឬថ្លង់ត្រចៀកដដែលវិញ ត្រង់កិច្ចដែលបុគ្គលបានធ្វើបុណ្យធ្វើបាបនោះ មិនមានជាប្រយោជន៍អ្វីដល់ខ្លួនឡើយ ។ ម្យ៉ាងទៀតថាបើបញ្ចក្ខន្ធនេះ អាចកើតឡើងឯងបាន គឺតមានកុសលាកុសលកម្មអ្វីជួយតាក់តែងទេ សេចក្តីដែលថាសត្វទៅកើតក្នុងស្ថាននរកសោយទុក្ខវេទនា

ព្រោះអកុសលកម្មនោះក៏ទៅជាមិនមែនមិនពិតទេ ៗ ទៅ សេចក្ដីនេះមិនមែនដូច្នោះទេមហាបពិត្រ ឯបញ្ញក្ខន្ធនោះមិនអាចនឹងទៅកើតក្នុងបរលោកទៀតទេ តែឯសត្វដែលស្លាប់ទៅនឹងទៅកើតទៀតក្នុងបរលោក ក៏គង់អាស្រ័យនូវបញ្ញក្ខន្ធនេះដែរទើបកើតបាន ។ ម្យ៉ាងទៀតបញ្ញក្ខន្ធនេះមិនមែនកើតឯងឥតមានកុសលាកុសលកម្មជួយតាក់តែងទេ គឺកើតព្រោះផលនៃកុសលកម្មជួយឧបត្ថម្ភទំនុកបំរុងទើបកើតបាន សូមស្ដេចជ្រាប ។

ម. ភិយ្យោឧបមំករោហិ សូមលោកម្ចាស់ឧបមាឲ្យប្លែកពីនេះទៅទៀតមើល ។

ន. សេយ្យថាបិមហារាជ បពិត្រសម្ដេចមហារាជ សេចក្ដីនេះប្រៀបដូចជាចង្កៀងដែលបុគ្គលអុចបន្តរពីគ្នា អាត្មាភាពសូមថ្វាយព្រះពរស្នួរព្រះរាជសម្ភារថា មានមនុស្សម្នាក់បានតាក់តែងអុចចង្កៀងទុកមានពន្លឺភ្លឺស្វាងរុងរឿងជារោចនជោតនាការ ហើយមានអ្នកឯទៀតយកចង្កៀងដទៃមកអុចបំ-ឡងពីគ្នាទៅ ឯអណ្ដាតភ្លើងនោះក៏អាចឆាបឆេះជាប់មកនឹងចង្កៀងឯទៀតនោះបាន បពិត្រមហារាជបុះអណ្ដាតភ្លើងដែល

ឆ្លងផុះមកបង្កៀងដទៃនោះជាឆ្លងមកឯងឥតមានបុគ្គលចាត់ចែងក្នុងការនោះឬទេ មហាបពិត្រ ។

ម. នហិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ក៏ប្តូនោះមិនមែនដូច្នោះទេ អណ្តាតភ្លើងដែលអាចឆ្លងពីបង្កៀងដើមទៅបង្កៀងដទៃបាននោះក៏ព្រោះអាស្រ័យមនុស្សចាត់ចែងដែរទើបឆ្លងទៅបាន បើឥតមានមនុស្សធ្វើទេមិនអាចនឹងឆ្លងទៅបានឡើយ ។

ន. ឯវមេវខោមហារាជ បពិត្រសម្តេចមហារាជ សេចក្តីនេះមានឧបមាដូចម្តេចមិញ ថាមានគួរនាដូចខន្ធទាំងឡាយ ៥ ប្រការ ឯខន្ធទាំង ៥ ប្រការនេះ មិនមែនទៅកើតក្នុងបរលោកទេ តែនឹងថាបញ្ចក្ខន្ធនេះកើតឡើងឯងឥតមានកុសលាកុសលកម្មជួយឧបត្ថម្ភគាំទ្រនោះមិនមែនទេ បំពោះថាមានកុសលនឹងអកុសលទំនុកបំរុងទើបកើតបាន ប្រៀបដូចជាប្រទីបដែលគេអុចចំឡងពីគ្នានោះឯង សូមមហារាជជ្រាប ។

ម. ភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំសូមសួរលោក

ម្ចាស់ពំពោះតែវេទនាក្នុងម្យ៉ាង ចុះវេទនាក្នុងនោះនឹងអាចទៅកើតក្នុងបរលោកទៀតដែរឬ ។

ន. យទិមហារាជ បពិត្រមហារាជ ថាបើវេទនាក្នុងនេះទៅកើតឯបរលោកនាយទៀតនោះ សត្វដែលធ្លាប់សោយទុក្ខសោយសុខក្នុងបញ្ចក្ខន្ធសព្វថ្ងៃនេះ វេលាដែលទៅកើតទៀតនឹងត្រូវសោយវេទនាដូចដើមវិញឬ មហារាជ ។

ម. នហិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន មិនមែនដូច្នោះទេ ។

ន. តំការណំមហារាជ បពិត្រមហារាជ សូមព្រះអង្គទ្រង់ជ្រាបសេចក្ដីនេះឲ្យប្រាកដចុះ ឯវេទនាក្នុងក្នុងអត្តភាពរបស់សត្វនេះ មិនបានទៅកាន់បរលោកទៀតទេ ។

ម. ភន្តេនាគសេន បពិត្រព្រះនាគសេនដ៏ចំរើន ចុះសញ្ញាក្នុងនឹងត្រូវទៅកាន់បរលោកទៀតដែរឬ ដូចម្ដេច ។

ន. យទិមហារាជ បពិត្រមហារាជ ថាបើសញ្ញាក្នុងទៅកើតក្នុងបរលោកទៀត មនុស្សដែលធ្លាប់កំបុតដៃកំបុតជើងក្នុងជាតិនេះ វេលាដល់ទៅកើតក្នុងបរលោកទៀតនឹងទៅជា

មនុស្សកំបុតដៃកំបុតជើងដដែលវិញ ព្រោះសញ្ញាគឺសេចក្តីសំគាល់ថាខ្លួនអញជាមនុស្សកំបុតដៃ កំបុតជើង នោះទៅកើតផង យ៉ាងនេះឬអ្វី ។

ម. នត្ថិភន្តេ បពិត្រលោកម្ចាស់ដ៏ចំរើន មិនមែនដូច្នោះទេ ។

ន. តិការណំមហារាជ បពិត្រមហារាជ បើដូច្នោះសូមព្រះរាជសន្ដារស្ដេចជ្រាបន្នូវហេតុនោះដោយប្រពៃចុះ ឯសញ្ញាក្នុងក្នុងអត្តភាពនេះមិនបានទៅកាន់បរលោកទៀតទេ ។

ម. ភិយ្យោ ខ បមំកពោហិ សូមលោកម្ចាស់ប្រៀបធៀបសេចក្ដីនេះឲ្យប្លែកតទៅទៀតមើល ។

ន. អត្ថិតេ មហារាជ បពិត្រសម្ដេចមហារាជ ចុះព្រះអង្គស្ដេចមានកញ្ចក់សម្រាប់ឆ្លុះព្រះភក្ត្រនៅជិតនេះដែរឬ ។

ម. មានដែរលោកម្ចាស់ ។

ន. សូមមហារាជ ស្ដេចឲ្យយកកញ្ចក់នោះមកដំកល់ទុកក្នុងទីនេះមើល ។

ម. នៃលោកម្ចាស់ កញ្ចក់នោះខ្ញុំបានឲ្យយកមកហើយនេះនែ ។

ន. សូមព្រះអង្គស្តេចទ្រង់ទតផ្ទះទៅត្រង់មណ្ឌលកញ្ចក់នោះមើលមើរ ទ្រង់នឹងបានឃើញព្រះនេត្រព្រះកាណ៌ព្រះនាសិកនឹងព្រះទន្តរបស់ព្រះអង្គប្រាកដទៅក្នុងផ្ទៃកញ្ចក់នោះដែរឬ ។

ម. លោកម្ចាស់ឯអាការទាំងឡាយមានភ្នែកជាដើមរបស់ខ្ញុំនោះ ខ្ញុំបានឃើញប្រាកដទៅក្នុងផ្ទៃកញ្ចក់ហើយ ។

ន. បុះបើព្រះនេត្រព្រះកាណ៌ព្រះនាសិកនឹងព្រះទន្តរបស់ព្រះអង្គនោះរបើកទៅនៅក្នុងមណ្ឌលកញ្ចក់ហើយព្រះអង្គមិនទៅជាមនុស្សខ្វាក់ព្រះនេត្រកំបុតព្រះកាណ៌ទៅហើយ ។

ម. មិនមែនដូច្នោះទេលោកម្ចាស់ ឯអាការទាំងឡាយមានភ្នែកជាដើមរបស់ខ្ញុំនោះមិនមែនរបើកចេញពីខ្លួនខ្ញុំចូលទៅតាំងនៅក្នុងផ្ទៃកញ្ចក់នោះទេ ឯភ្នែកត្របៀកច្រមោះជាដើមដែលនៅ ៗ ក្នុងកញ្ចក់នោះ គឺជាស្រមោលនៃភ្នែកត្របៀកដែលអាស្រ័យនៅនឹងកាយរបស់ខ្ញុំនេះឯង ។

ន. បពិត្រសម្តេចមហារាជ សេចក្តីនេះមានឧបមាដូច

ម្ដេចមិញ ថាមានឧបមេយ្យដូចបញ្ចក្ខន្ធនេះ ឯបញ្ចក្ខន្ធនេះមិនមែនទៅកាន់បរលោកទៀតទេ តែនឹងថាបញ្ចក្ខន្ធនេះកើតឡើងឥតមានកុសលាកុសលកម្មជួយឧបត្ថម្ភទំនុកបំរុងក៏ទេដែរ ពំពោះជាមានកុសលនឹងអកុសលទំនុកបំរុងទើបកើតបាន ប្រៀបដូចជាស្រមោលដែលអាស្រ័យនូវរូបកាយនេះហើយធ្លុះទៅក្នុងផ្ទៃកញ្ចក់នោះ បើប្រសិនជាឥតរូបឥតកាយនេះទេ ក៏មិនអាចនឹងមានស្រមោលធ្លុះចូលទៅក្នុងកញ្ចក់នោះបានឡើយ ឯសត្វដែលកាន់យកបដិសន្ធិក្នុងផ្ទៃនៃមាតាបាននោះ ក៏ដោយអំណាចនៃកុសលាកុសលកម្មដែលខ្លួនបានធ្វើហើយក្នុងបញ្ចក្ខន្ធនេះឯង ។

ម. ចូលចិត្តហើយលោកម្ចាស់ៗ ឆ្លៀវឆ្លាសពេកណាស់ ។

### មាតុកុច្ឆិបដិសន្ធិបញ្ហា ១ ទី ៣

ព្រះមហាក្សត្រស្ដេចទ្រង់សួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៣ នេះតទៅថា បពិត្រព្រះនាគសេនថេរដ៏ចំរើន មនុស្សសត្វដែលនឹងកាន់យកបដិសន្ធិក្នុងផ្ទៃនៃមាតានោះតើនឹងចូលទៅតាមទ្វារណា ទើបកាន់យកបដិសន្ធិបាន ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រមហារាជ ឯមនុស្សសត្វទាំងឡាយកាលចូលទៅកើតក្នុងផ្ទៃនៃមាតានោះឥតមានចូលទៅតាមទ្វារទេ មហាបពិត្រ ។

ម. បើមិនចូលទៅតាមទ្វារណាទេ ចុះហេតុដូចម្ដេចក៏មានសត្វកើតក្នុងផ្ទៃមាតា សូមលោកម្ចាស់ប្រៀបជាសេចក្ដីបន្តិចមកមើល ។

ន. ចុះមហាបពិត្រស្ដេចមានប្រអប់កែវនៅទៀបព្រះអង្គដែរឬ ។

ម. ប្រអប់កែវនោះខ្ញុំមានលោកម្ចាស់

ន. សូមព្រះរាជសម្ភារៈស្ដេចទ្រង់ព្រះចិន្តាត្រិះរិះនឹកទៅខាងក្នុងនៃប្រអប់កែវនោះមើល ។

ម. ខ្ញុំបានតាំងចិត្តនឹកបំពោះទៅខាងក្នុងនៃប្រអប់កែវនោះហើយលោកម្ចាស់ ។

ន. ចុះព្រះហឫទ័យរបស់ព្រះអង្គកាលដែលចូលទៅខាងក្នុងប្រអប់កែវនោះ តើចូលទៅតាមទ្វារដូចម្ដេច ។

ម. ឯចិត្តរបស់ខ្ញុំកាលដែលខ្ញុំតាំងនឹកដម្រង់ទៅខាងក្នុង

ប្រអប់កែវនោះ ឥតមានចូលទៅតាមទ្វារណាទេ លោកម្ចាស់
តែគង់ដឹងនូវវត្ថុក្នុងប្រអប់នោះបាន ។

ន. បពិត្រព្រះរាជសម្ភារ សេចក្ដីនេះមានគួរនាយ៉ាងណា
ថាមានគួរនាដូចមនុស្សសត្វ កាលដែលចូលទៅកើតក្នុងផ្ទៃនៃ
មាតានោះឯង ធម្មតាមនុស្សសត្វទាំងឡាយកាលដែលនឹង
ចូលទៅបដិសន្ធិក្នុងផ្ទៃនោះ ឥតមានចូលទៅតាមទ្វារណា ១
ទេ តែគង់អាចកើតបាន ព្រោះបឋមវិញ្ញាណឬបដិសន្ធិចិត្ត
នោះជាធម្មជាតមិនមានរូបរាងសណ្ឋានទ្រង់ទ្រាយទេ ប្រៀប
ដូចខ្សែព្រះចិន្តាឬសន្ទុះព្រះហឫទ័យរបស់ព្រះអង្គ ដែលស្ទុះចូល
ទៅក្នុងខាងក្នុងនៃប្រអប់កែវនោះឯង សូមទ្រង់ជ្រាប ។

ម. អច្ឆរិយំភន្តេនាគសេន បពិត្រព្រះនាគសេនដ៏ចំរើន
ហេតុនេះគួរជាទីអស្ចារ្យចំឡែកពេកណាស់ អព្ភុតំភន្តេនាគ
សេន បពិត្រព្រះនាគសេនដ៏ចំរើន សេចក្ដីនេះមិនធ្លាប់កើត
មានហើយមកមានប្រាកដ លោកម្ចាស់នេះពេញជាបុគ្គលឆ្លៀវ
ឆ្លាសក្នុងការវិសជ្ជនាដោះប្រស្នាដ៏វិចិត្រនេះ ឥតមានទើសទាល់
សល់ជំពាក់សោះ លោកម្ចាស់នេះប្រសិនបើជាព្រះសម្មាសម្ពុទ្ធ

ទ្រង់គង់ព្រះធរមាននៅ សមនឹងលើកនឹងសរសើរឲ្យសព្វសាធុការពរដោយច្រើនជាអានេកមិនខាន ។

សត្តពោជ្ឈង្គបញ្ហា ។ ទី ៨

ព្រះមហាក្សត្រស្ដេចទ្រង់បុច្ឆាចំពោះទៅព្រះនាគសេនថេរ ក្នុងប្រស្នាទី ៨ នេះថា បពិត្រព្រះនាគសេនដ៏ចំរើន សភាវធម៌ដែលជាហេតុសម្រាប់ត្រាស់ដឹង ដែលហៅថាពោជ្ឈង្គនោះ តើមានប៉ុន្មានយ៉ាង ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្ដេចមហារាជ ឯសភាវធម៌ដែលជាហេតុនាំឲ្យបេះដឹងនូវគុណទាំងពួងនោះមាន៧យ៉ាង មានសតិសម្ពោជ្ឈង្គជាដើម សូមទ្រង់ជ្រាប ។

ម. ចុះបុគ្គលដែលនឹងត្រាស់ដឹងនូវមគ្គនឹងផលនោះតើដោយពោជ្ឈង្គណាឬដោយពោជ្ឈង្គទាំង ៧ ប្រការនោះ លោកម្ចាស់ ។

ន. ឯបុគ្គលដែលនឹងត្រាស់ដឹងនូវមគ្គនឹងផលនោះបំពោះដោយពោជ្ឈង្គតែ ១ ទេ មហារាជ ។

ម. បុះពោជ្ឈង្គមួយនោះតើបានខាងពោជ្ឈង្គណា ក្នុងពោជ្ឈង្គទាំង ៧ ប្រការនោះ លោកម្ចាស់ ។

ន. ធម្មវិចយសម្ពោជ្ឈង្គ បពិត្រសម្តេចមហារាជ បណ្តាពោជ្ឈង្គទាំង ៧ ប្រការនោះ បានខាងឯធម្មវិចយសម្ពោជ្ឈង្គនោះឯង សូមទ្រង់ជ្រាប ។

ម. បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំមានសេចក្តីសង្ស័យនឹងចំឡើយរបស់លោកម្ចាស់នេះពេកណាស់ ព្រោះថាហេតុដែលជាទីត្រាស់ដឹងនោះមានដល់ទៅ ៧ យ៉ាង ហៅថាសត្តពោជ្ឈង្គ បុះហេតុដូចម្តេចក៏លោកម្ចាស់សំដែងថា ការដែលនឹងត្រាស់ដឹងនោះបំពោះតែត្រង់ធម្មវិចយសម្ពោជ្ឈង្គមួយ៉ាងវិញ ។

ន. បពិត្រមហារាជ បុះព្រះអង្គស្តេចទ្រង់ព្រះយោបល ក្នុងសេចក្តីនេះថាដូចម្តេចទៅ អាត្មាភាពសូមថ្វាយព្រះពរសួរមកបពិត្រវិញថា ផ្លែដាវដែលបុគ្គលប្រកបុះទៅក្នុងស្រោម មិនបានហូតបេញចាកស្រោមឡើយ បុះបើបុគ្គលត្រូវការនឹងកាត់នូវវត្ថុអ្វីទាំងពួងដោយផ្លែដាវព្រមទាំងស្រោម នោះតើនឹងដាច់ឬមិនដាច់ទេ មហារាជ ។

ម. គាត់មិនដាប់ទេ លោកម្ចាស់ ។

ន. សូមថ្វាយព្រះពរមហាបពិត្រ សេចក្ដីនេះមានឧបមាដូចម្ដេចមិញ ថាមានឧបមាដូចពោជ្ឈង្គទាំង ៦ ប្រការដែលតែងអាស្រ័យនូវធម្មវិចយសម្ពោជ្ឈង្គនោះឯង ឯពោជ្ឈង្គទាំង ៦ ប្រការមានសតិសម្ពោជ្ឈង្គជាដើមនេះ ថាបើវៀរចាកធម្មវិចយសម្ពោជ្ឈង្គហើយ មិនអាចនឹងត្រាស់ដឹងនូវមគ្គនឹងផលបានឡើយ ប្រៀបដូចស្រោមដាវដែលតែងអាស្រ័យនូវផ្លែដាវ ទើបអាចនឹងកាត់នូវវត្ថុទាំងពួងបាន បំណែកឯស្រោមបើវៀរចាកផ្លែហើយ មិនអាចនឹងកាត់វត្ថុទាំងពួងបានឡើយ ។

ម. លោកម្ចាស់មានប្រាជ្ញាឆ្លៀវឆ្លាសវៀងវៃពេកណាស់ ប្រសប់ក្នុងការវិសជ្ជនាដោះស្រាយអាថ៌ប្រស្នាដែលចង្អៀតឲ្យទៅជាទូលាយបាន ។

បាបបុញ្ញពហុតរបញ្ហា ។ ទី ៩

ព្រះបរមក្សត្រាធិរាជទ្រង់បុច្ឆាទៅព្រះនាគសេនថេរក្នុងប្រស្នាទី ៩ នេះតទៅថា បពិត្រព្រះនាគសេនដ៏ចំរើន បុញ្ញកម្ម

នឹងបាបកម្មទាំងពីរប្រការនេះ កម្មណាមានផលច្រើនដោយវិសេសជាងកម្មណា ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្តេចមហារាជ បណ្តាកម្មទាំងពីរប្រការនោះ បុញ្ញកម្មមានផលច្រើនដោយវិសេសជាងបាបកម្ម ឯបាបកម្មនោះជាកម្មមានផលតិចថយចុះមកជាងបុញ្ញកម្មសូមទ្រង់ជ្រាប ។

ម. ព្រោះហេតុអ្វីលោកម្ចាស់ បានជាបុណ្យមានផលច្រើនជាងបាប បាបវិបទៅជាមានផលតិចទៅវិញលោកម្ចាស់។

ន. បពិត្រព្រះរាជសម្ភារ ឯកម្មទាំងពីរប្រការបានជាមានផលខុសគ្នានោះព្រោះមានសេចក្តីអធិប្បាយផ្សេងគ្នាដូច្នេះ ថាបើជនណាផ្តិលខ្លួនទៅប្រព្រឹត្តធ្វើអំពើបាបកម្មជាអកុសលហើយ ជននោះឯងនឹងមានសេចក្តីក្តៅក្រហាយទោមនស្សត្អូញបិត្តនឹងខ្លួនជាខាងក្រោយថា អាត្មាអញបានធ្វើនូវអំពើអាក្រក់លាមកយ៉ាងនេះ បានជាមកប្រទះនូវសេចក្តីទុក្ខព្រួយដូច្នេះឯង ។ ព្រោះហេតុនេះហើយបានជាអាត្មាភាពថ្វាយព្រះពរថា បាបកម្មនោះមានផលតិចជាង មិនបំរើនផលល្អដល់អ្នកដែល

ធ្វើនោះ បពិត្រមហារាជ ម្យ៉ាងទៀត ថាបើជនណាដែលបាន ធ្វើបុណ្យរួចហើយ ជននោះឯងនឹងមិនបានសេចក្ដីតក់ស្លុត ឬក្ដៅក្រហាយជាខាងក្រោយទេ សឹងមានតែសេចក្ដីរីករាយ សេចក្ដីត្រេកអរ មានកាយដ៏ស្ងប់រម្ងាប់មិនបានក្រវល់ក្រវាយ បានសោយនូវសេចក្ដីសុខគ្រប់យ៉ាង ចិត្តនៃជននោះសោតក៏ អាចតាំងនៅមាំមួនខ្ជាប់ខ្ជួនដោយល្អទៅបាន ព្រោះហេតុនេះ ហើយបានជាអាត្មាភាពថ្វាយព្រះពរមហារាជថា បុណ្យមាន ផលច្រើនជាងបាបនោះឯង ម្យ៉ាងទៀត បពិត្រមហារាជ ប្រសិនបើជាបុរសណាមួយជាមនុស្សពិការ កំបុតដៃ កំបុតជើង មិនអាចនឹងធ្វើនូវការកុសលឲ្យបានមាំមួនទៅបាន គ្រាន់តែ បានថ្វាយនូវផ្កាឧប្បលចំនួន ១ ក្ដាប់ដល់ព្រះសម្ពុទ្ធជាម្ចាស់ ហើយ ខ្លួនបុរសនោះគង់នឹងបានទទួលសោយនូវផលបុណ្យ នោះយូរយាអស់ចំនួន ៩១ កប្ប.ជាយពិត ព្រោះហេតុនោះ បានជាអាត្មាភាពថ្វាយព្រះពរមហារាជថា បុណ្យមានផល ច្រើនជាងបាប ឯបាបនោះតែងមានផលតិចជាងបុណ្យ សូម ស្ដេចជ្រាប ។

ម. ខ្ញុំបួលចិត្តស្តាប់បានហើយលោកម្ចាស់ ៗ ជាបុគ្គលឆ្លៀវឆ្លាសល្អហើយ ។

ជានអជានបញ្ហា ១ ទី ១០

ព្រះបាទមិលិន្ទស្តេចទ្រង់សួរទៅព្រះនាគសេនថេរទៅក្នុងប្រស្នាទី ១០ នេះថា បពិត្រព្រះថេរដ៏ចំរើន ជនពីរនាក់ ជនម្នាក់ជានាក់ចេះដឹងស្គាល់បុណ្យបាប ហើយទៅប្រព្រឹត្តធ្វើអំពើបាប ជនម្នាក់ទៀតជាអ្នកមិនបានចេះដឹងមិនស្គាល់បុណ្យបាបទេ ហើយទៅប្រព្រឹត្តធ្វើបាបកម្មដូចគ្នា បណ្តាជនទាំងពីរនាក់នោះតើជនណាបានផលបាបច្រើនជាងជនណាលោកម្ចាស់ ។

ព្រះនាគសេនថ្វាយព្រះពរថា បពិត្រសម្តេចមហារាជជុំនុំជនទាំងពីរនោះ ជនណាដែលមិនចេះដឹង ជាអ្នកល្ងង់ខ្លៅហើយទៅធ្វើបាបកម្ម ជននោះបានផលបាបច្រើនជាងអ្នកដែលចេះដឹង សូមជ្រាប ។

ម. បពិត្រព្រះថេរដ៏ចំរើន បើដូច្នោះទោសនោះប្លែកគ្នានឹងទោសក្នុងបច្ចុប្បន្ននេះលោកម្ចាស់ ឯទោសក្នុងបច្ចុប្បន្ននេះ

ថាបើជនណាជារាជបុត្រឬ ជារាជមហាមាត្យ ជាអ្នកដឹងការខុសត្រូវធ្ងន់ស្រាល ហើយទៅប្រព្រឹត្តធ្វើអំពើអាក្រក់ផ្សេងៗ ឲ្យខុសបាករាជបញ្ញត្តិហើយ យើងខ្ញុំត្រូវធ្វើទោសដាក់ទណ្ឌកម្មដល់ជនទាំងនោះជាទ្វេគុណលោកម្ចាស់ ។

៦. បពិត្រសម្តេចមហារាជ ចុះព្រះអង្គទ្រង់ព្រះយោបលឈ្វេងយល់ក្នុងសេចក្តីនេះដូចម្តេចទៅ អាត្មាភាពនឹងប្រៀបជាសេចក្តីថ្វាយឲ្យជាក់ច្បាស់ថា ដូចជាជនពីរនាក់ ជនម្នាក់ជាអ្នកល្ងង់ខ្លៅ មិនដឹងមិនស្គាល់នូវដុំដែកដែលបុគ្គលដុតដោយភ្លើងកំពុងឆេះក្រហមរន្ទាលប្រាលឆ្អៅ គួរឲ្យញញើតស្ញើបជាពន្លឹកពេក ហើយជននោះយកដៃទៅចាប់កាន់ដោយសប់សួនបំពោះត្រង់ដុំដែកនោះ ដោយសេចក្តីយល់ខុសថាជាវត្ថុឯទៀតផ្សេង ឯជនម្នាក់ទៀតជាអ្នកដឹងប្រាកដថា ដុំក្រហមនោះបំពោះជាដុំដែកមានភ្លើងកំពុងឆេះក្រហមរន្ទាលប្រាលឆ្អៅ តែត្រូវការនឹងលូកទៅចាប់យកដុំដែកនោះដែរ ក៏បណ្តាជនទាំងពីរនាក់នោះ តើជនណានឹងត្រូវគ្រោះរលាករលួយដៃនោះច្រើនជាងជនណា មហាបពិត្រ ។

ម. បពិត្រលោកម្ចាស់ដ៏ចំរើន ជនណាដែលមិនដឹងមិនស្គាល់នូវដុំដែកដែលក្តៅហើយយកដៃទៅចាប់កាន់ដោយសប់សួន ជនោះនឹងត្រូវកំដៅយ៉ាងខ្លាំងដល់រលាករលួយដៃមិនខាន សូមលោកម្ចាស់ជ្រាប ។

ន. បពិត្រមហារាជ សេចក្តីនេះមានគួរនាដូចម្តេចមិញ ថាមានគួរនាដូចជាជនដែលជាអ្នកមិនដឹងការខុសត្រូវធ្ងន់ស្រាលហើយទៅប្រព្រឹត្តនូវអំពើអាក្រក់ ជនោះឯងនឹងបានផលបាបច្រើនជាងអ្នកដែលបេះដឹងនោះ សូមស្តេចជ្រាប ។

ម. លោកម្ចាស់ប្រសប់ប្រៀបប្រាយអធិប្បាយជាសេចក្តីងាយស្តាប់ពេក ។

ឧត្តរកុរុបញ្ហា ១ ទី ១១

ព្រះបាទមិលិន្ទស្តេចទ្រង់សួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ១១ នេះថា បពិត្រព្រះនាគសេនដ៏ចំរើន ជនឯណានីមួយអាចនឹងទៅកាន់ប្រទេសឧត្តរកុរុទ្វីបឬនឹងហោះទៅកាន់ស្ថានព្រហ្មលោកនឹងទ្វីបដ៏ទៃ ៗ ទៀតក្រៅពីទ្វីបនេះ ទៅដោយសរីរាងកាយនេះបានឬទេ លោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្ដេចមហារាជ ជនឯណាមានប្រាជ្ញានឹងទៅកាន់ឧត្តរកុរុទ្វីបក្ដី ទៅកាន់ស្ថានព្រហ្មលោកក្ដី ទៅកាន់ទ្វីបដ៏ទៃក្ដី ដោយរាងកាយដែលប្រកបដោយធាតុទាំង ៤ នេះបាន ឥតមានទាស់ទេ មហាបពិត្រ ។

ម. បពិត្រលោកម្ចាស់ដ៏ចំរើន ចុះហេតុដូចម្ដេចក៏ជនទាំងនោះអាចនឹងទៅកាន់ស្ថានទាំងនោះបានដោយរូបទាំងមូលនេះលោកម្ចាស់ ។

ន. បពិត្រសម្ដេចមហារាជ ចុះព្រះអង្គអាចនឹងលោតឲ្យផុតអំពីផែនដីនេះបំណូន ១ បំអាមឬ ១ ហត្ថទៅបានឬទេ មហារាជ ។

ម. លោកម្ចាស់ ខ្លួនខ្ញុំនេះអាចលោតឡើងបានកុំថាត្រឹម ១ បំអាមឬមួយហត្ថ ទោះបីទីខ្ពស់ដល់ទៅ ៨ ហត្ថក៏គង់ខ្ញុំលោតឡើងបាន ។

ន. ចុះហេតុដូចម្ដេចក៏ព្រះអង្គទ្រង់លោតឡើងដល់ទៅ ៨ ហត្ថបាន មហារាជ ។

ម. បពិត្រលោកម្ចាស់ដ៏ចំរើន ឯវិធីដែលនឹងលោតឡើងបានកំពស់ ៨ ហត្ថនោះគឺខ្ញុំបានតាំងចិត្តថានឹងលោតឡើងឲ្យបានកំពស់ត្រឹមនោះ ៗ ហើយក៏ខំប្រឹតប្រៀនរៀនហាត់រឿយ ៗ ទៅ កាយរបស់ខ្ញុំក៏ស្រាលអណ្តែតព្រមទៅដោយចិត្ត បានដូចប្រាថ្នា ។

ន. បពិត្រមហារាជ សេចក្តីនេះមានឧបមាដូចម្តេចមិញ ថាមានឧបមេយ្យដូចភិក្ខុដែលមានឫទ្ធិស្ទាត់ជំនាញទៅដោយឈានចិត្តហើយ លោកអាចនឹងទៅកាន់អាកាសវេហាបានដោយកំឡាំងឈាននោះឯង សូមស្តេចជ្រាប ។

ម. ខ្ញុំយល់ចិត្តហើយលោកម្ចាស់ ។

ទីឃអទ្ធិកបញ្ហា ៗ ទី ១២

ព្រះបាទក្រុងមិលិន្ទទ្រង់មានព្រះរាជឱង្ការ ត្រាស់សួរទៅព្រះនាគសេនថេរក្នុងប្រស្នាទី ១២ នេះថា បពិត្រព្រះថេរដ៏ចំរើន លោកម្ចាស់បានសំដែងថា មានឆ្អឹងអ្វីមួយវែងប្រមាណដល់១០០យោជន៍ ពាក្យនេះឃើញថាកើនហួសប្រមាណពេកណាស់ កុំថាតែឆ្អឹងសត្វទាំងពួង ទោះបីដើមឈើលើផែនដី

នេះទាំងប៉ុន្មាននឹងរកឈើឯណាឡើមានប្រវែងដល់ទៅ ១០០ យោជន៍នោះក៏គ្មានដែរ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្តេចមហារាជ ចុះព្រះអង្គទ្រង់យោបល់ឈ្វេងយល់នូវសេចក្តីនេះថាដូចម្តេចទៅ អាត្មាភាពសូមថ្វាយព្រះពរសួរព្រះអង្គវិញថា ចុះមហាបពិត្រ ទ្រង់ដែលបានឮពាក្យដែលគេតែងនិយាយថា មានមហាមច្ឆា គឺត្រី ១ ធំទំហំប្រមាណ ៥០០ យោជន៍នៅក្នុងមហាសមុទ្រ នោះដែរឬ ។

ម. បពិត្រលោកម្ចាស់ដ៏ចំរើន ពាក្យនេះខ្ញុំធ្លាប់បានឮមក ដែរ ថាមានត្រី ១ ធំប្រមាណ ៥០០ យោជន៍ក្នុងមហាសមុទ្រ នោះ ។

ន. ចុះមហាបពិត្រស្តេចនឹងទ្រង់ជ្រាបនូវហេតុនេះថាដូច ម្តេចទៅ បើខ្លួនត្រីដែលមានទំហំដល់ ៥០០ យោជន៍នោះ បំណែកខាងឆ្អឹងត្រីនោះតើមានប្រមាណប្រវែងណាទៅ ។

ម. លោកម្ចាស់ឆ្លាសពន្យល់ស្រួលពេកក្នុងការបុច្ឆាវិសជ្ជ-នានេះ ខ្ញុំចូលចិត្តហើយ ។

ព្រះបាទក្រុងមិលិន្ទទ្រង់មានព្រះរាជឱង្ការត្រាស់សួរបំពោះទៅព្រះនាគសេនបេរក្នុងប្រស្នាទី ១៣ នេះថា បពិត្រព្រះនាគសេនដ៏ចំរើន លោកម្ចាស់បានពោលថាខ្លួនលោកអាចនឹងអត់ដង្ហើមចេញចូលឬធ្វើដង្ហើមចេញចូលនោះមិនឲ្យប្រព្រឹត្តទៅបានហើយមិនឲ្យស្លាប់ផង ជាមែនឬទេ ។

ព្រះនាគសេនថ្វាយព្រះពរតបទៅវិញថា បពិត្រសម្ដេចមហារាជ អាត្មាភាពអាចនឹងញាំងអស្សាសបស្សាសនោះឲ្យរលត់ទៅបាន ។

ម. ចុះលោកម្ចាស់អាចញាំងអស្សាសបស្សាសឲ្យរលត់ទៅនោះដូចម្ដេច ។

ន. មហាបពិត្រស្ដេចទ្រង់ព្រះដំរិះនូវសេចក្ដីនេះថាដូចម្ដេចទៅ អាត្មាភាពសូមថ្វាយព្រះពរសួរព្រះរាជសម្ភារវិញថា បុគ្គលដែលដេកលក់ហើយស្រមុកនោះ តើមហាបពិត្រស្ដេចដែលបានឮស្នូរស្រមុកនោះដែរ ។

ម. ខ្ញុំធ្លាប់បានឮដែរលោកម្ចាស់ ។

ន. បពិត្រព្រះរាជសម្ភារសំឡេងដែលបុគ្គលស្រែមុកនោះ តើប្រហែលគ្នានឹងសំឡេងមនុស្សដែលជិតស្លាប់ហើយលាន់ឮក្រុក ៗ ឬឮដឹក ៗ នោះឬអ្វី ។

ម. យ៉ាងហ្នឹងហើយលោកម្ចាស់ ។

ន. បពិត្រព្រះរាជសម្ភារ ឯសំឡេងនៃបុគ្គលដែលជិតនឹងមរណៈហើយលាន់ឮដឹក ៗ នោះមិនមែនព្រោះហេតុអ្វីទេ ព្រោះតែបុគ្គលនោះឯងកាលដែលរស់នៅ មិនបានបង្ហាត់កាយឱ្យរក្សាសីលនឹងចំរើនសមាធិចិត្តឡើយ បានជាដល់វេលាជិតស្លាប់ក៏មានខ្យល់អស្សាសបស្សាសលាន់ឮដឹក ៗ នោះឯងចំណែកខាងលោកអ្នកសប្បុរសដែលបានទូន្មានកាយនឹងចិត្តឱ្យដឹកល់នៅក្នុងសីលាទិគុណហើយ វេលាដល់ជិតស្លាប់លោកក៏ចូលកាន់ចតុត្ថជ្ឈាន ហើយបានរម្ងាប់ខ្យល់អស្សាសបស្សាសនោះ មិនឱ្យប្រព្រឹត្តទៅបាន លុះចេញចាកឈានហើយទើបសម្រេចចុតិកិច្ច ។

ម. បពិត្រលោកម្ចាស់ដ៏ចំរើន សេចក្ដីចំឡើយរបស់លោកនោះសំគួរហើយ ។

សម្តេចព្រះមិលិន្ទស្តេចទ្រង់ត្រាសព្រះរាជឱង្ការសួរបំពោះទៅព្រះនាគសេនថេរក្នុងប្រស្នាទី ១៤ នេះថា បពិត្រព្រះថេរដ៏ចំរើន ខ្ញុំសូមសួរលោកម្ចាស់អំពីទឹកសមុទ្រ ថាទឹកដូចម្តេចដែលហៅថាទឹកសមុទ្រនោះ សូមលោកម្ចាស់អធិប្បាយមកមើល ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រសម្តេចមហារាជ ឯទឹកសមុទ្រនោះមានសេចក្តីអធិប្បាយថា ទឹកមានចំនួនប៉ុន្មាន រសប្រៃក៏មានចំនួនប៉ុណ្ណោះ រសប្រៃមានចំនួនប៉ុន្មាន ទឹកក៏មានចំនួនប៉ុណ្ណោះដែរ ព្រោះហេតុយ៉ាងនេះហើយបានជាលោកសន្មតិឲ្យឈ្មោះថាទឹកសមុទ្រ ៗ នោះឯង សូមស្តេចជ្រាប ។

ម. បពិត្រព្រះថេរដ៏ចំរើនចុះហេតុអ្វីក៏បានជាទឹកសមុទ្រនោះតែងមានរសជាតិប្រៃតែម្យ៉ាង លោកម្ចាស់ ។

ន. បពិត្រសម្តេចមហារាជ ឯទឹកសមុទ្រនោះបានជាមានរសប្រៃតែម្យ៉ាងព្រោះទឹកនោះត្រាំនៅក្នុងទី ១ អស់កាលយូរយា

មកហើយឥតមានផ្ទះផ្សិរទៅទីឯទៀតឡើយ សូមស្ដេចជ្រាប ។

ម. លោកម្ចាស់វិសជ្ជនាមកនេះសមគួរហើយ ។

សុខុមធេទទបញ្ហា ៗ ទី ១៥

ព្រះមហាក្សត្រស្ដេចទ្រង់ត្រាស់សួរទៅព្រះនាគសេនថេរ ក្នុងប្រស្នាទី ១៥ នេះថាបពិត្រព្រះថេរដ៏ចំរើន លោកម្ចាស់មានយោបលអាចនឹងកាត់នូវវត្ថុដ៏ល្អិតជាសុខុមជាងវត្ថុទាំងពួងនោះបានឬទេ ។

ព្រះថេរថ្វាយព្រះពរថា បពិត្រសម្ដេចមហារាជអាត្មាភាពអាចនឹកាត់ផ្ដេចនូវវត្ថុដ៏ល្អិតយ៉ាងសុខុមជាងវត្ថុទាំងពួងនោះបានឥតមានទាស់ទេ ។

ម. បពិត្រព្រះថេរដ៏ចំរើនបុះវត្ថុដូចម្ដេចដែលជារបស់សុខុមជាងវត្ថុទាំងពួងនោះលោកម្ចាស់ ។

ន. បពិត្រព្រះរាជសម្ភារ ឯសភាវដែលជាសុខុមជាងសភាវទាំងពួងនោះមិនគឺអ្វីទេគឺលោកុត្តរធម៌នោះឯង បើចំណែកខាងលោកិយធម៌វិញមិនមែនជាសភាវសុខុមសុទ្ធតែម្យ៉ាងដូច

លោកុត្តរធម៌ទេ ឯលោកិយធម៌ទាំងឡាយនោះ ជាសភាវស្ថិត ខ្លះ គ្រោតគ្រាតខ្លះ មិនសុទ្ធតែម្យ៉ាង មហាបពិត្រ បុគ្គលដែល នឹងកាត់នូវសុខុមធម៌ទាំងពួងបាននោះត្រូវកាត់ដោយលោកុត្តរ បញ្ញាតែម្យ៉ាង បើនឹងកាត់ដោយលោកិយបញ្ញាវិញមិនអាចនឹង កាត់បានទេ ។

ម. លោកម្ចាស់វិសជ្ជនាមកនោះសមគួរហើយ ។

បញ្ញាវិសេសបញ្ហា ១ ទី ១៦

ព្រះមហាក្សត្រស្តេចទ្រង់មានព្រះរាជឱង្ការត្រាស់សួរទៅ ព្រះនាគសេនថេរក្នុងប្រស្នាទី ១៦ នេះថា បពិត្រព្រះថេរដ៏ចំរើន ធម្មជាតិដែលហៅថាបញ្ញា ។ នោះស្ថិតនៅត្រង់ទីកន្លែងណា លោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រព្រះរាជសម្ភារ ឯធម្មជាតិដែលហៅថាបញ្ញានោះឥតមានស្ថិតនៅត្រង់កន្លែង ណានីមួយឡើយ មហាបពិត្រ ។

ម. បពិត្រព្រះថេរដ៏ចំរើន បើបញ្ញានេះឥតមានទីកន្លែង

សម្រាប់នៅទេ មានតែបញ្ហានោះក៏គ្មានដែរ លោកម្ចាស់ ។

ន. បពិត្រមហារាជបុះមហាបពិត្រស្ដេចទ្រង់ព្រះយោបល ឈ្វេងយល់ដូចម្ដេចទៅក្នុងរឿងនេះ អាត្មាភាពសូមថ្វាយព្រះពរ សួរព្រះរាជសម្ភារវិញថា បុះខ្យល់ដែលមាននៅសព្វថ្ងៃនេះតើ អាស្រ័យនៅកន្លែងណា មហាបពិត្រ ។

ម. បពិត្រព្រះបេរដ៍ចំរើន ខ្យល់មិនមានទីកន្លែងសម្រាប់ នៅទេ លោកម្ចាស់ ។

ន. បពិត្រព្រះរាជសម្ភារ បើទីកន្លែងសម្រាប់ខ្យល់នៅ នោះមិនមានហើយ ទាំងតួខ្យល់នេះក៏ប្រហែលជាមិនមានដែរ មហារាជ ។

លោកម្ចាស់ជាបុគ្គលឆ្លាសណាស់តើ ខ្ញុំចូលចិត្តបាន សព្វគ្រប់ហើយ ។

បញ្ហាទីទំនាទត្តភាវបញ្ហា ១ ទី ១៧

ព្រះបាទមិលិន្ទស្ដេចទ្រង់មានព្រះរាជឱង្ការត្រាស់សួរទៅ ព្រះនាគសេនបេរក្នុងប្រស្នាទី ១៧ នេះថា បពិត្រព្រះបេរដ៍ចំរើន

ធម៌ទាំងឡាយពីរប្រការគឺបញ្ញា ១ វិញ្ញាណ ១ ទាំងពីរនេះបាន ឈ្មោះថាជីវធម៌គឺជីវិតដែលអាស្រ័យក្នុងមហាភូតរូបយើងសព្វ ថ្ងៃនេះឬអ្វី ម្យ៉ាងទៀតធម៌ទាំងពីរប្រការគឺបញ្ញានឹងវិញ្ញាណនេះ មានអត្ថផ្សេង ៗ គ្នាមានព្យញ្ជនផ្សេង ៗ គ្នាឬ មានអត្ថតែម្យ៉ាង មានព្យញ្ជនផ្សេង ៗ គ្នាលោកម្ចាស់ ។

ព្រះនាគសេនថេរថ្វាយព្រះពរថា បពិត្រមហារាជ ឯធម៌ ទាំងពីរប្រការគឺបញ្ញានឹងវិញ្ញាណនោះ មិនបានកំណត់ហៅថា ជីវធម៌ទេ ហើយធម៌ទាំងពីរនេះសោតសឹងមានអត្ថផ្សេងគ្នា មិនបានដូចគ្នាទេ ដូចមានបទថា វិជាននលក្ខណំ វិញ្ញាណំ បជាននលក្ខណា បញ្ញា ប្រែថា វិញ្ញាណមានសេចក្ដីដឹងផ្សេង ៗ ជាលក្ខណ បញ្ញាមានកិរិយាដឹងច្បាស់ប្រាកដជាលក្ខណ សូមមហាបពិត្រជ្រាប ។

ម. បពិត្រលោកម្ចាស់ដ៏ចំរើន ថាបើបញ្ញានឹងវិញ្ញាណ ទាំងពីរនេះមិនបានហៅថាជីវធម៌ទេ ចុះសភាវដូចម្ដេចដែល ហៅថាជីវធម៌នោះ ក្រែងវិញ្ញាណដែលសម្រាប់ឃើញរូបដោយ ភ្នែក ស្ដាប់សំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ភ្លក់រស

ដោយអណ្ដាត ប៉ះពាល់នូវវត្ថុទាំងពួងដោយកាយ ដឹងធម៌ដោយចិត្តនោះឬអ្វីដែលហៅថាជីវធម៌ លោកម្ចាស់ ។

ន. បពិត្រមហារាជ ថាបើវិញ្ញាណនោះជាជីវធម៌ ជាធម្មជាតិសម្រាប់ឃើញរូបដោយភ្នែក ស្ដាប់សំឡេងដោយត្រចៀក ធុំក្លិនដោយច្រមុះ ភ្លក់រសដោយអណ្ដាត ប៉ះពាល់នូវវត្ថុទាំងពួងដោយកាយ ដឹងធម៌ដោយចិត្ត នោះមានតែជីវធម៌នោះ កាលដែលបុគ្គលបើកភ្នែកហើយ បែមុខទៅខាងក្រៅដើយមើលទៅខាងលើ បានឃើញនូវរូបផ្កាយប្រាកដ កាលប្រុងត្រចៀកបែទៅខាងក្រៅបានឮសំឡេងប្រាកដ ប្រុងច្រមុះបែទៅខាងក្រៅ បានធុំក្លិនប្រាកដ ប្រុងអណ្ដាតលៀនចេញទៅខាងក្រៅ បានភ្លក់រសប្រាកដ ប្រុងកាយដាកចេញទៅខាងក្រៅ បានប៉ះពាល់នូវសម្ផស្សប្រាកដ កាលដម្រង់ចិត្តបែទៅខាងក្រៅ បានដឹងធម៌ទាំងពួង យ៉ាងនេះឬអ្វី ដែលព្រះអង្គសំគាល់ថាជីវធម៌នោះ ។

ម. មិនមែនដូច្នោះទេ លោកម្ចាស់ ។

ន. បពិត្រសម្ដេចមហារាជ បើដូច្នោះវិញ្ញាណនឹងបញ្ញា

នោះ មិនមែនជាឈ្មោះនៃជីវិតធម៌ក្នុងភូតកាយនេះទេ គឺជាធម្មជាតិម្យ៉ាងសម្រាប់ដឹងផ្សេងៗ នឹងធម្មជាតិសម្រាប់ដឹងទូទៅនោះឯង ឯជីវិតធម៌នោះជាធម្មជាតិដ៏ទៃក្រៅពីវិញ្ញាណ នឹងបញ្ញានោះឯងសូមទ្រង់ជ្រាប ។

ម. បពិត្រព្រះនាគសេនដ៏ចំរើន លោកម្ចាស់ឆ្លៀវឆ្លាសពេកបេះដោះស្រាយ អាចប្រស្នាស្រួលបួលណាស់ខ្ញុំអស់សង្ស័យហើយ ។

អរូបវវត្ថានទុក្ខបញ្ហា ទី ១៨

ព្រះនាគសេនថេរលោកតាំងផ្ដើមថ្វាយព្រះពរទៅព្រះបាទមិលិន្ទថា បពិត្រសម្ដេចមហារាជ ព្រះអង្គបានជ្រាបដែរឬ ថាព្រះដ៏មានព្រះភាគ ស្ដេចបានធ្វើនូវអំពើដែលព្រះអង្គធ្វើបានដោយកម្រក្រៃពេកនោះ មហាបពិត្រ ។

ព្រះបាទមិលិន្ទស្ដេចទ្រង់សួរទៅព្រះនាគសេនវិញថា បពិត្រព្រះថេរដ៏ចំរើន បុះអំពើដែលព្រះសម្ពុទ្ធព្រះអង្គធ្វើដោយកម្រនោះតើដូចម្ដេច ។

ន. បពិត្រសម្តេចមហារាជ ឯអំពើដែលព្រះសម្ពុទ្ធទ្រង់ធ្វើ ហើយដោយកម្រនោះ គឺថាព្រះអង្គបានកំណត់នូវធម៌ទាំងឡាយ គឺចិត្តនិងចេតសិកដែលជាធម្មជាតិមិនមានរូបតែងប្រព្រឹត្តទៅក្នុងអារម្មណ៍ជាមួយគ្នាមិនមានភាន់ច្រឡំឡើយ ហើយទ្រង់អាចពោលកំណត់នូវធម៌ទាំងនោះថា សភាពយ៉ាងនេះហៅថាផស្ស ធម្មជាតិយ៉ាងនេះហៅថា វេទនា ធម្មជាតិយ៉ាងនេះហៅថា សញ្ញា ធម្មជាតិយ៉ាងនេះហៅថា ចេតនា ធម្មជាតិយ៉ាងនេះហៅថា ចិត្ត បពិត្រព្រះរាជសម្ភារ ព្រះបរមគ្រូព្រះអង្គទ្រង់កំណត់យ៉ាងនេះបាន ៗ ជាអាត្មាភាពថ្វាយព្រះពរថា ព្រះសម្ពុទ្ធទ្រង់ធ្វើនូវអំពើដែលព្រះអង្គធ្វើបានដោយកម្រនោះឯង សូមទ្រង់ជ្រាប ។

ម. សូមលោកម្ចាស់ឧបមាជាសេចក្តីយ៉ាងងាយបន្តិចមកនឹងបានស្តាប់ក្នុងកាលឥឡូវនេះមើល ។

ន. បពិត្រមហារាជ ឯព្រះសម្ពុទ្ធជាម្ចាស់នោះប្រៀបដូចជាបុរសម្នាក់ដែលជាអ្នកឆ្លាសអាចស្គាល់ច្បាស់នូវរសទឹកសមុទ្រ ហើយបានចុះសំពៅទៅតាមមហាសមុទ្រ បានយកដៃទៅក្បង់ទឹកសមុទ្រនោះយកមកភ្លក់ដោយអណ្តាត លុះបានភ្លក់រួចហើយ

បុរសនោះឯងអាចដឹងច្បាស់នូវរសនៃទឹកនោះថា ទឹកប៉ុណ្ណោះជាទឹកហូរមកអំពីស្ទឹងឈ្មោះ គង្គា ទឹកប៉ុណ្ណោះមកអំពីស្ទឹងឈ្មោះ យមុនា ទឹកប៉ុណ្ណោះមកអំពីស្ទឹងឈ្មោះ សរភូ ទឹកប៉ុណ្ណោះមកអំពីស្ទឹងឈ្មោះ អចិរវតី ទឹកប៉ុណ្ណោះមកអំពីស្ទឹងឈ្មោះ មហី បពិត្រសម្តេចមហារាជ ព្រះបរមគ្រូព្រះអង្គទ្រង់ត្រាស់ដឹងនូវចិត្តនិងចេតសិកទាំងឡាយបានឥតមានភាន់ប្រឡំសោះនោះ ដូចបុរសដែលជាអ្នកស្គាល់ច្បាស់នូវរសនៃទឹកសមុទ្រនោះឯងសូមទ្រង់ជ្រាប ។

ម. បពិត្រព្រះបវរដ៏ចំរើន ព្រះសម្ពុទ្ធទ្រង់ត្រាសដឹងនូវកិច្ចដែលព្រះអង្គធ្វើបានដោយកម្រនោះមែនហើយ ខ្ញុំបួលចិត្តអស់សង្ស័យលោកម្ចាស់ ។

ន. បពិត្រសម្តេចមហារាជ ព្រះបរមសាស្តានោះព្រះអង្គមិនមែនគ្រាន់តែត្រាស់ដឹងនូវធម៌ទាំងឡាយ គឺចិត្តនិងចេតសិកដែលជាអរូបធម៌ដែលតែងប្រព្រឹត្តទៅក្នុងអារម្មណ៍ តែមួយជាមួយគ្នាថា នេះជាផស្ស នេះជាវេទនា នេះជាសញ្ញា នេះ

ជាចេតនា នេះជាចិត្តប៉ុណ្ណោះទេ គឺព្រះអង្គអាចត្រាស់ដឹងនូវកិច្ចឯទៀតក្រៃលែងជាងនេះតទៅ ។

ម. បពិត្រព្រះថេរដ៏ចំរើន សេចក្តីត្រាស់ដឹងរបស់ព្រះដ៏-មានព្រះភាគនេះប្រពៃពេកណាស់ ខ្ញុំមានអំណរជាទីបំផុតក្នុងរឿងនេះលោកម្ចាស់ ។

ទុក្ករបញ្ហា ៗ ទី ១៩

ព្រះនាគសេនថេរ បានថ្វាយព្រះពរទៅព្រះបាទមិលិន្ទ្រាធិបតីថា បពិត្រសម្តេចមហារាជ សូមព្រះអង្គទ្រង់ជ្រាបនូវពេលវេលានេះចុះព្រោះពេលនេះជាពេលដ៏សមគួរហើយ ។

ព្រះបាទមិលិន្ទភូមិន្ទ្រាធិបតី ស្តេចទ្រង់មានព្រះរាជឱង្ការពិតទៅព្រះថេរវិញថា បពិត្រព្រះថេរដ៏ចំរើនមែនហើយ ញោមក៏បានដឹងច្បាស់ថាពេលនេះជាពេលដ៏សមគួរហើយ ព្រោះយាមថាដំបូងនោះកន្លងទៅហើយ ឥឡូវនេះដល់មកមជ្ឈិមយាមពាក់កណ្តាលអាធ្រាត្រមកហើយ ប្រទីបគោមទាំងឡាយក៏ភ្លឺស្វាងរុងរឿងនៅ ហើយរាជសេវកាមាត្យទាំងឡាយ ក៏នាំយក

សម្ពត់ទាំងឡាយ ៤ ផាប់ អំពីព្រះឃ្លាំងដែលស្តេចទ្រង់ត្រាស់បង្គាប់ឲ្យបើរុងទុកចាំប្រគេនដល់ព្រះមហាបេរក្នុងពេលនោះផង ។

បំណែកខាងយោនកាមាត្យទាំងឡាយ ក៏នាំគ្នាក្រាបបង្គំទូលមហាក្សត្រថា បពិត្រព្រះរាជសម្ភារព្រះអង្គក៏ជាបុគ្គលឆ្លៀវឆ្លាសណាស់ហើយ ទាំងភិក្ខុអង្គនេះសោតលោកក៏ជាបណ្ឌិតប្រាកដមែន ។

ព្រះបរមក្សត្រាធិរាជស្តេចទ្រង់ត្រាស់ព្រះរាជឱង្ការតបទៅពួកយោនកាមាត្យទាំងឡាយនោះថា មែនហើយយោនកាមាត្យធម្មតាមនុស្សយើងបើបានអាចារ្យមានប្រាជ្ញាប្រាកដយ៉ាងនេះហើយបានកូនសិស្សក៏ឆ្លៀវឆ្លាសយ៉ាងនេះដែរ គង់នឹងបានបេះដឹងធម៌អាថ៌អំពីសំណាក់អាចារ្យនោះដោយឥតមិនខាន ហើយអង្គព្រះមហាក្សត្រស្តេចក៏មានព្រះរាជចិន្តាសោមនស្សត្រេកអរចំពោះនឹងព្រះនាគសេនបេរ ដោយលោកបានវិសជ្ជនាដោះអាថ៌ប្រស្នាត្រូវកែគ្លែង ត្រូវព្រះហឫទ័យឥតមានឆ្គង ទើបទ្រង់ប្រគេនសម្ពត់កម្ពលយ៉ាងល្អចំនួនថ្លៃមួយសែនដំឡឹងទៀតដល់ព្រះបេរនោះហើយស្តេចបវារណាថា បពិត្រព្រះនាគសេនបេរដ៏ចំ-

ចើន ញោមសូមបរិវេណាប្រគេនភត្តាហារចំនួន ១០៨ សម្រាប់អំពីគេហស្ថានរបស់ខ្ញុំតាំងពីថ្ងៃនេះទៅ ហើយសូមប្រគេននូវវត្ថុអ្វីនីមួយដែលជារបស់គួរគប្បីដែលមាននៅខាងក្នុងបូរីនៃខ្ញុំនេះដល់លោកម្ចាស់ទៀតតាមលោកម្ចាស់ត្រូវការ សូមលោកម្ចាស់ទទួលដោយសេចក្ដីអនុគ្រោះដល់ញោម ។

ព្រះនាគសេនថេរថ្វាយព្រះពរទៅវិញថា បពិត្រព្រះរាជសម្ភារ អាត្មាភាពសព្វថ្ងៃនេះមានវត្ថុសម្រាប់ចិញ្ចឹមជីវិតល្មមសមគួរហើយ សូមព្រះមហាបពិត្រស្ដេចកុំព្រួយព្រះរាជហឫទ័យឡើយ ។

ព្រះមហាក្សត្រស្ដេចទ្រង់ត្រាសទៅវិញថា បពិត្រព្រះនាគសេនម្ចាស់ដ៏ចំរើន ញោមដឹងច្បាស់ហើយថាលោកម្ចាស់មានស្បៀងល្មមលៀងជីវិតបាន តែថាត្រូវលោកម្ចាស់រក្សានូវអង្គលោកផងរក្សានូវញោមផង ។

ព្រះនាគសេនថេរថ្វាយព្រះពរសួរទៅមហាក្សត្រវិញថា បពិត្រសម្ដេចមហារាជ ដែលទ្រង់មានព្រះរាជឱង្ការត្រាស់ថា

ឲ្យអាត្មាភាពរក្សានូវខ្លួនអាត្មានោះតើដូចម្តេច រក្សានូវអង្គរបស់មហាបពិត្រនោះដូចម្តេច ។

ព្រះបាទមិលិន្ទរាជស្តេចទ្រង់ពិតបើរភាចាទៅព្រះពេររិញថាលោកម្ចាស់ ពាក្យដែលញោមថា ឲ្យលោកម្ចាស់រក្សានូវអង្គលោកនោះគឺញោមយល់ថាពីនេះទៅមុខក្រែងនឹងមានពាក្យបរ-បវាទពោលបំពោះមកអង្គលោកម្ចាស់ថា ព្រះនាគសេនបើរជាអ្នកប្រាជ្ញប្រាកដ អាចញ៉ាំងស្តេចមិលិន្ទឲ្យមានព្រះរាជហឫទ័យជ្រះថ្លាបាន តែឥតមានបាននូវសក្ការបូជាអ្វីបន្តិចបន្តួចអំពីសំ-ណាក់នៃស្តេចនោះសោះឡើយ ពាក្យដំណេះដំនៀលយ៉ាងនេះគង់នឹងកើតមានដល់លោកម្ចាស់មិនខាន បានជាញោមថាសូមឲ្យលោកម្ចាស់ទទួលយកនូវភត្តាហាររបស់ញោមកុំខាន ដើម្បីនឹងរក្សានូវអង្គលោកម្ចាស់យ៉ាងនេះឯង ម្យ៉ាងទៀតពាក្យដែលញោមពិត្រលោកម្ចាស់ថា ឲ្យរក្សានូវញោមផងនោះ គឺថានឹងមានពាក្យបរបវាទថា ព្រះបាទមិលិន្ទ្រាធិរាជស្តេចមានព្រះហឫទ័យសោមនស្សជ្រះថ្លានឹងធម៌ទេសនារបស់ព្រះនាគ-សេនបើរនោះពិតមែនហើយ តែថាស្តេចឥតមានត្រិការធ្វើនូវ

សក្ការបូជារបន្តិចបន្តួចដល់ព្រះថេរនោះសោះទេ ហេតុនេះហើយបានជាញោមពិត្រលោកម្ចាស់ថា ឲ្យលោកទទួលនូវខាទនីយភោជនីយាហារ របស់ញោមដើម្បីនឹងរក្សានូវខ្លួនញោមនេះផង ។

ព្រះនាគសេនថេរថ្វាយព្រះពរទៅវិញថា បពិត្រសម្ដេចមហារាជ បើដូច្នោះអាត្មាភាពមិនហានប្រកែកទេ សូមទទួលតាមព្រះរាជអធ្យាស្រ័យ ។

លំដាប់នោះព្រះបាទមិលិន្ទ្រាធិបតីស្ដេចទ្រង់សំដែងព្រះ-រាជអធ្យាស្រ័យរបស់ព្រះអង្គ ពិត្រដល់ព្រះនាគសេនថេរឲ្យជ្រាប សេចក្ដីពិត្រនោះថាដូច្នេះ បពិត្រព្រះនាគសេនម្ចាស់ដ៏បំរើនខ្លួនញោមសព្វថ្ងៃនេះ ពិតមែនតែជាបុគ្គលនៅគ្រប់គ្រងរក្សារាំងដំណាក់នៅឡើយ តែត្រង់គំនិតរបស់ញោមជាបុគ្គលបែមុខចេញទៅខាងក្រៅជាដរាបរាល់ថ្ងៃឥតមានអាល័យត្រង់ទីលំនៅនេះទេ ប្រៀបដូចជាស្ដេចម្រឹគដែលហៅថាសីហរាជដែលជាប់នៅក្នុងទ្រុងមាសក៏ពិតមែនហើយ តែគំនិតរបស់សី-ហរាជនោះតែងបែមុខចេញទៅខាងក្រៅជានិច្ចដូច្នោះឯង ម្យ៉ាង

ទៀត បពិត្រព្រះនាគសេនម្ចាស់ដ៏ចំរើន បើប្រសិនណាជាញោមហើយបេញចាកគេហស្ថាន ទៅបួសក្នុងព្រះពុទ្ធសាសនា ប្រហែលជាញោមមិនបានរស់នៅយូរទេ ព្រោះហាមនុស្សទាំងឡាយដែលជាសត្រូវនឹងញោមនោះមានច្រើនពេកណាស់ ។

គ្រានោះព្រះនាគសេនថេរដ៏មានអាយុលោកបានវិសជ្ជនាដោះប្រស្នារបស់ព្រះបាទមិលិន្ទរាជស្រេចហើយវេលាណាក៏ថ្វាយព្រះពរលាស្ដេចក្រោកចាកទីនោះទៅកាន់សំឃារាមវិញក្នុងវេលានោះ កាលបើព្រះនាគសេនថេរត្រឡប់ទៅសំឃារាមនោះមិនជាយូរប៉ុន្មាន ព្រះចៅក្រុងមិលិន្ទស្ដេចមានព្រះរាជដំរិះថាដូច្នេះខ្លួនអញបានសួរប្រស្នាដូចម្ដេចខ្លះនឹងព្រះនាគសេនថេរ បំណែកព្រះនាគសេនដ៏ចំរើនលោកបានឆ្លើយប្រស្នាដូចម្ដេចខ្លះហ្ន៎ លុះស្ដេចទ្រង់ព្រះដំរិះដូច្នេះហើយទើបទ្រង់ជ្រាបថា បញ្ហាកម្មទាំងអស់ដែលអញបានសួរហើយនោះជាការប្រពៃពេក បំណែកឯព្រះនាគសេនសោតលោកក៏បានឆ្លើយនូវបញ្ហាកម្មទាំងអស់នោះដោយល្អពិត ។

ឯអង្គព្រះនាគសេនដ៏មានអាយុលោកបានទៅដល់ទីសំ-

យារាមហើយ ក៏មានសេចក្តីត្រិះរិះរំពឹងថាដូច្នេះ ព្រះបាទមិ-លិន្ទស្តេចទ្រង់សួរនូវប្រស្នាដូចម្តេចខ្លះ អាត្មាអញបានវិសជ្ជនាដោះប្រស្នានោះដូចម្តេចខ្លះ លុះរំពឹងរួចហើយទើបដឹងច្បាស់ថាបញ្ហាកម្មទាំងអស់ដែលស្តេចមិលិន្ទទ្រង់ព្រះរាជបុច្ឆានោះជាប្រ-ស្នាប្រពៃពេក បំណែកខាងអាត្មាអញទៀតក៏បានវិសជ្ជនាដោះប្រស្នានោះដោយល្អពិតឥតមានភាំងភាត់ឡើយ ។

លុះដល់វេលាព្រឹកឡើងព្រះនាគសេនថេរលោកក៏ស្លៀកស្បង់ឃ្លុំចីពររួចស្រេចបាប់យកនូវបាត្រហើយ ក៏និមន្តចូលទៅឯព្រះរាជនិវេសនស្ថានដែលស្តេចគង់នៅនោះ លុះដល់ហើយក៏ចូលទៅគង់នៅលើអាសនដែលស្តេចឲ្យតែងតាំងទុកប្រគេននោះ ។

សម័យនោះព្រះបាទមិលិន្ទបរមក្សត្រាធិរាជ ស្តេចទ្រង់ព្រះដំណើរចូលទៅកាន់ទីដែលព្រះនាគសេនគង់នៅនោះ លុះដល់ហើយក៏ក្រាបថ្វាយបង្គំបំពោះព្រះថេរ ហើយស្តេចទ្រង់គង់នៅក្នុងទីដ៏សមគួរមួយ លុះស្តេចទ្រង់ស្ថិតនៅស្រួលបួលហើយទើបទ្រង់ប្រារព្ធសន្ទនាការសួរទៅព្រះនាគសេនថេរថា បពិត្រ

ព្រះនាគសេនដ៏ចំរើនសូមលោកម្ចាស់កុំមានសេចក្តីត្រិះរិះថា ព្រះមហាក្សត្រស្តេចបានសួរប្រស្នារួចហើយ ម្យ៉ាងទៀតសូមលោកម្ចាស់កុំឈ្វេងយល់យ៉ាងនេះថា ព្រះមហាក្សត្រស្តេចបានផ្ទំស្កល់អស់មួយយប់ទាំងមូល ព្រោះសេចក្តីសោមនស្សត្រេកអរនឹងការសួរនូវប្រស្នានោះឡើយ បពិត្រព្រះនាគសេនដ៏ចំរើនសូមលោកម្ចាស់ជ្រាបដូច្នេះថា យោមមានសេចក្តីត្រិះរិះរំពឹងអស់មួយយប់ទាំងមូលថា បញ្ហាកម្មដូចម្តេចដែលយោមបានសួរចំពោះលោកម្ចាស់ហើយ បញ្ហាកម្មដូចម្តេចដែលលោកម្ចាស់បានឆ្លើយដោយល្អប្រាប់យោមហើយៗត្រូវជ្រាបឡើប្រាកដទៀតថា ប្រស្នាគ្រប់ចំពូកគឺយោមបានសួរលោកម្ចាស់រួចហើយ ប្រស្នាគ្រប់ចំពូកគឺលោកម្ចាស់បានឆ្លើយដោយល្អប្រាប់យោមហើយ ដូច្នេះវិញទើបសមគួរ ។

ព្រះនាគសេនថេរលោកបានថ្វាយព្រះពរទៅវិញ ថាបពិត្រសម្តេចមហារាជ សូមព្រះអង្គកុំមានព្រះរាជដំរិះត្រិះរិះដូច្នេះថា ខ្ញុំអាត្មាភាពបានឆ្លើយដោះប្រស្នារួចហើយ ម្យ៉ាងទៀតសូមទ្រង់កុំឈ្វេងយល់ដូច្នេះថា ព្រះថេរនេះបានសឹង្ហលក់

ជរាបដល់ព្រឹកព្រោះសេចក្ដីសោមនស្សត្រេកអរថាខ្លួនបានដោះប្រស្នារួចហើយ បពិត្រមហារាជសូមព្រះអង្គទ្រង់ព្រះដំរិះយ៉ាងនេះវិញថា បញ្ហាកម្មដូចម្ដេចដែលព្រះអង្គបានបុច្ឆារួចហើយ បញ្ហាកម្មដូចម្ដេចដែលអាត្មាភាពបានវិសជ្ជនារួចហើយ ៗ សូមទ្រង់ជ្រាបឲ្យប្រាកដដូច្នេះទៀតថា ព្រះអង្គស្ដេចបានទ្រង់បុច្ឆានូវប្រស្នាគ្រប់បំពូកហើយអាត្មាភាពបានវិសជ្ជនាដោះប្រស្នាដោយល្អគ្រប់បំពូកហើយ យ៉ាងនេះទើបសមគួរ ។

ឯអ្នកប្រាជ្ញទាំងពីរព្រះអង្គគឺព្រះបាទមិលិន្ទនឹងព្រះនាគសេនថេរលោកបានបុច្ឆាវិសជ្ជនា ពោលឆ្លើយអាថ៌ប្រស្នាគ្នាទៅវិញទៅមកដោយសុន្ទរវាចារួចហើយកបញ្ចប់សេចក្ដីបុណ្ណោះតាមសមគួរ ។

ទុក្ករបញ្ហាទី ១៩ ក្នុងសត្តមវគ្គបប់តែប៉ុណ្ណោះ

ចប់បុច្ឆាវិសជ្ជនាមិលិន្ទបញ្ហា

បានរួបរួមប្រស្នាក្នុងមិលិន្ទបញ្ហាតាំងអំពីបឋមវគ្គរហូតដល់មកសត្តមវគ្គនេះបាន ៨៨ ប្រស្នា យកវិសេសបញ្ហា ១ មកបញ្ចូលទៀតត្រូវជា ៨៩ ប្រស្នា នៅមានប្រស្នាតទៅទៀត

ច្រើន មានមេណ្ឌកបញ្ហាជាដើមក្នុងគម្ពីរមិលិន្ទបញ្ហានេះ ម្យ៉ាងទៀតក្នុងបាឡីស្លឹករឹតមានសេចក្ដីប្រាប់ថា ក្នុងមិលិន្ទបញ្ហានេះ មានប្រស្នា ១០៨ ដែលព្រះគន្ថរចនាចារ្យលោករៀបរៀងសម្រេចទុកក្នុងស្រុកលង្កាទ្វីបឯនោះ តែបានពិនិត្យរាប់មើលឃើញតែ ៨៨ ប្រស្នា បញ្ចូលវិសេសបញ្ហាមកផងទើបត្រូវជា ៨៩ នៅខ្វះ ១៩ ប្រស្នាទៀតទើបគ្រប់ ១០៨ ។

វិសេសបញ្ហា

ឬ

## គោតមីវត្ថទានបញ្ហា

ព្រះបរមក្សត្រាធិរាជស្ដេចទ្រង់ត្រាស់សួរទៅព្រះនាគសេនបើរក្នុងវិសេសបញ្ហានេះថា បពិត្រព្រះនាគសេនដ៏ចំរើន សម្ដេចព្រះភគវន្តមុនី ព្រះអង្គទ្រង់មានពុទ្ធដីការបំពោះទៅនឹងនាងមហាបជាបតិគោតមីជាព្រះមាតុច្ឆារបស់ព្រះអង្គ ក្នុងកាលដែលព្រះនាងបានយកសម្ពត់សាដកថ្មីមួយគូមកថ្វាយព្រះអង្គនោះថា បពិត្រព្រះមេព្រះមាតុច្ឆា សូមព្រះមេបូជានូវសម្ពត់សាដកនេះដល់សង្ឃទាំងពួងចុះ កាលបើទ្រង់បានបូជាសម្ពត់នោះដល់ព-

ពួកសង្ឃហើយ ក៏ឈ្មោះថាបានបូជាដល់តថាគតផង ដល់
សង្ឃផង បពិត្រព្រះនាគសេនដ៏ចំរើន ឯពុទ្ធភាសិតដូច្នេះ
ក៏ឃើញសេចក្ដីថា ព្រះតថាគតបរមគ្រូមិនជាបុគ្គលថ្លៃថ្លាជាង
ព្រះសង្ឃ មិនជាគ្រូអាចារ្យនៃព្រះសង្ឃ មិនជាបុគ្គលប្រសើរ
ជាងព្រះសង្ឃទេឬអ្វីលោកម្ចាស់ ។ ម្យ៉ាងទៀតគូនៃសម្ពត់សា-
ដកនោះសោតមិនមែនជាអ្នកដ៏ទៃធ្វើឡើយ គឺជាស្នាដៃរបស់
ព្រះគោតមីនាងធ្វើដោយព្រះអង្គឯង គឺទ្រង់បោះកប្បាស ថ្ពេប
អូរ រវៃ ការដាក់ខ្នារ ហើយទ្រង់ត្បាញដោយព្រះអង្គ រួចហើយ
ទើបនាំចូលមកថ្វាយចំពោះព្រះបរមគ្រូ តែបំណែកព្រះបរមគ្រូ
ទ្រង់មិនព្រមទទួលយក ទ្រង់បែរទៅជាបង្គាប់ឲ្យព្រះមាតុច្ឆាយក
សម្ពត់សាដកនោះបូជាដល់ព្រះសង្ឃវិញ បពិត្រព្រះនាគសេន
ម្ចាស់ ថាបើព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់មានគុណសម្បត្តិដ៏ឧ-
ត្តមក្រៃលែងដោយវិសេសជាងសង្ឃរតននោះ គួរតែព្រះអង្គទ-
ទួលយកនូវគូនៃសម្ពត់សាដកនោះអំពីព្រះមាតុច្ឆា ហើយសម
តែទ្រង់ត្រាស់ប្រាប់ទៅព្រះមាតុច្ឆានោះថា ទានដែលបុគ្គលបាន
បូជាដល់តថាគតហើយ ជាទានមានផលច្រើនដូច្នេះទើបសម

គួរ បុះហេតុអ្វីក៏ទ្រង់ដាក់បន្ទាបព្រះអង្គឲ្យទៅជាតូចទាបជាង ព្រះសង្ឃវិញៈទៅជាព្រះអង្គទ្រង់ត្រាស់ប្រាប់ទៅព្រះមាតុច្ឆា សូមឲ្យព្រះមេយកនូវសម្ពត់សាដកនោះបូជាដល់ព្រះសង្ឃវិញ បើយ៉ាងនេះព្រះសង្ឃមិនជាធំជាងព្រះពុទ្ធហើយ លោកម្ចាស់ ។

ព្រះនាគសេនបើរថ្វាយព្រះពរទៅវិញថា បពិត្រសម្តេចមហារាជ ឯពុទ្ធភាសិតដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ទៅនឹងនាងមហាបជាបតិគោតមីជាព្រះមាតុច្ឆា ក្នុងកាលដែលព្រះនាងនាំយកសម្ពត់សាដកមកថ្វាយព្រះអង្គនោះថា បពិត្រព្រះមេសូមព្រះនាងយកសម្ពត់នេះបូជាទៅសង្ឃវិញ កាលបើព្រះនាងបានបូជាដល់សង្ឃហើយក៏បានពោះ្ម៉ះថាបូជាដល់តថាគតផង ដល់សង្ឃផង ម្យ៉ាងទៀតឯកិច្ចដែលព្រះអង្គមិនបានទទួលនូវសម្ពត់ដោយព្រះអង្គឯង, ហើយទ្រង់បង្គាប់ព្រះមាតុច្ឆាឲ្យបូជាទៅសង្ឃវិញនោះនឹងថាព្រះអង្គមិនជាទីគោរពជាងព្រះសង្ឃ ឬថាអិនជាបុគ្គលប្រសើរជាងព្រះសង្ឃ ព្រោះតែព្រះអង្គបង្គាប់ព្រះមាតុច្ឆាឲ្យបូជាសម្ពត់សាដកដល់ព្រះសង្ឃប្រណ្ណោះនោះមិន

មែនទេ ម្យ៉ាងទៀតបពិត្រព្រះរាជសម្ភារ ពុទ្ធអធ្យាស្រ័យ ដែលទ្រង់មិនទទួលសម្ពត់សាដកដោយព្រះអង្គឯង ហើយ ទ្រង់បង្គាប់ឲ្យព្រះមាតុច្ឆាបូជាទៅព្រះសង្ឃនោះដោយទ្រង់ព្រះ ញាណយល់ច្បាស់ទៅក្នុងអនាគតកាលខាងមុខថា ដើម្បីនឹង សង្គ្រោះដល់ព្រះសង្ឃ ទ្រង់នឹងធ្វើឲ្យជាប្រយោជន៍ដល់ព្រះ សង្ឃ ព្រោះថាកាលបើអំណើសឥតពីព្រះអង្គទៅ គឺព្រះអង្គ ទ្រង់ចូលនិព្វានកន្លងហួសទៅហើយ នៅតែព្រះសង្ឃ ៗ នោះ នឹងជាទីគោរពរាប់អានដល់សាមញ្ញជនទាំងពួងខាងក្រោយ ហេតុនេះហើយបានជាព្រះអង្គទ្រង់លើកសរសើរគុណព្រះ-សង្ឃឲ្យព្រះមាតុច្ឆាទ្រង់បូជាសាដកដល់ព្រះសង្ឃ ដោយព្រះ-ពុទ្ធដីកាថា បពិត្រព្រះគោតមីព្រះមាតុច្ឆា សូមព្រះនាងបូជា សម្ពត់សាដកនេះដល់សង្ឃចុះ កាលបើព្រះនាងបានបូជាដល់ សង្ឃហើយ បានឈ្មោះថាបូជាដល់តថាគតផង ដល់ព្រះសង្ឃ ផង បពិត្រសម្ដេចមហារាជ សេចក្ដីនេះអាត្មាភាពនឹងប្រៀប ឧបមាថ្វាយ ថាដូចជាបិតា កាលដែលមានជីវិតរសនៅ ៗ

ឡើយ បើមានកូនឯណាដែលមានគុណសម្បត្តិច្រើនក្នុងខ្លួន គួរនឹងលើកនឹងសរសើរកូននោះ ក្នុងសំណាក់នៃបរមក្សត្រាធិរាជឬក្នុងទីប្រជុំនៃរាជមហាមាត្យ ពួកនាយទ្វារនឹងពួកសេនាយោធាទាំងពួងឲ្យបានដឹងឮផង ព្រោះថាសេចក្ដីបំណងរបស់បិតានោះ បង់ឲ្យមនុស្សទាំងឡាយ មានសេចក្ដីគោរពរាប់អាន ដល់កូនរបស់ខ្លួន ក្នុងកាលទៅខាងមុខ សេចក្ដីនេះមានគួរនាដូចម្ដេចអិញ ថាមានគួរនាដូចសម្ដេចព្រះបរមគ្រូទ្រង់ពិចារណាឃើញប្រយោជន៍ដល់សង្ឃក្នុងកាលទៅខាងមុខ ហើយ ទើបទ្រង់ប្រកាសសរសើរគុណរបស់ព្រះសង្ឃទុកឲ្យប្រាកដឡើង ដើម្បីជាប្រយោជន៍ដល់ជនជាខាងក្រោយ នឹងបានគោរពរាប់អានធ្វើសក្ការបូជាដល់ព្រះសង្ឃ ក្នុងកាលដែលព្រះអង្គទ្រង់បរិនិព្វានកន្លងទៅហើយនោះឯង មិនមែនថាសង្ឃរតននោះប្រសើរជាងព្រះមហាករុណា ព្រោះតែព្រះអង្គបង្គាប់ឲ្យព្រះមាតុបូជាបូជាសម្ពត់សាដកនោះប៉ុណ្ណោះទេ ម្យ៉ាងទៀតបពិត្រព្រះរាជសម្ភារ អាត្មាភាពនឹងថ្វាយសេចក្ដីឧបមា ១ ទៀត

ថាដូចជាមាតាបិតាទាំងឡាយដែលជាអ្នកងូត ប្រាប់ ជូតទឹក លាប ស្រះឡាប ប្រុសព្រឹនឹងសម្លៀកបំពាក់សម្ពត់ឱ្យកូនទាំងឡាយ បពិត្រព្រះរាជសម្ភារបើមាតាបិតាទំនុកបំរុងកូនយ៉ាងនឹងហើយកូននោះមិនទៅជាបុគ្គលធំជាងឬប្រសើរជាងមាតាបិ-តា ព្រោះតែមាតាបិតាទាំងនោះធ្វើកិច្ចទំនុកបំរុងប៉ុណ្ណោះទៅហើយ មហាបពិត្រ ។

ព្រះបាទមិលិន្ទស្តេចទ្រង់ពិត្រទៅព្រះថេរវិញថា មិនមែនដូច្នោះទេលោកម្ចាស់ ធម្មតាមាតាបិតាទាំងឡាយ តែងធ្វើនូវសេចក្តីទំនុកបំរុងដល់កូនទាំងឡាយនោះឯង ព្រោះកូនទាំងនោះកើតមកហើយអំពីខ្លួននឹងអាចលះបង់ចោលឯណាក៏បាន តែថាកូនទាំងនោះនឹងបានជាធំឬប្រសើរជាងមាតាបិតា ព្រោះតែមាតាបិតាទំនុកបំរុងប៉ុណ្ណោះក៏ទេ ។

ព្រះនាគសេនថេរថ្វាយព្រះពរទៅព្រះមហាក្សត្រទៀតថា បពិត្រសម្តេចមហារាជ សេចក្តីនេះមានឧបមាដូចម្តេចមិញ ថាឧបមេយ្យដូចសង្ឃរតន ឯសង្ឃរតននោះនឹងថាជាធំជាង

ឬប្រសើរជាងព្រះតថាគតបរមគ្រូ ព្រោះតែព្រះអង្គទ្រង់ប្រោសប្រទាននូវសម្ផត់សាជកដល់ព្រះសង្ឃប៉ុណ្ណោះនោះក៏ទេ ម្យ៉ាងទៀតមហាបពិត្រ ឯសម្តេចព្រះបរមសាស្តាចារ្យជាគ្រូ ដែលទ្រង់ត្រាស់ឲ្យព្រះមាតុច្ឆាយកសម្ផត់សាជកប្តូជាដល់ព្រះសង្ឃនោះ ព្រះអង្គនឹងមានធ្វើនូវសេចក្តីគោរពកោតខ្លាចអ្វីដល់ព្រះសង្ឃនោះក៏ទេ ព្រោះតែទ្រង់យល់ទៅក្នុងអនាគតកាលខាងមុខ ៗ ថាទុកព្រះសង្ឃនេះជាទីគោរពរាប់អានដល់ជនជាខាងក្រោយប៉ុណ្ណោះទេ បពិត្រព្រះរាជសម្ភារ សេចក្តីនេះអាត្មាភាពសូមប្រៀបឧបមាថ្វាយ ថាដូចជាបុគ្គលឯណា ១ បាននាំយកនូវស្លួយសារអាករចូលមកថ្វាយដល់ព្រះបរមក្សត្រាធិរាជ ៗ ក៏ទ្រង់ប្រោសប្រទាននូវរាជបណ្ណាការទាំងនោះដល់ជនដទៃទៀត គឺទ្រង់ប្រទានឲ្យពួកអ្នកឈ្នួលឬឲ្យទៅពួកពលសេនាទាហ៊ានឬឲ្យទៅបុរោហិត បពិត្រមហារាជអាត្មាភាពសូមថ្វាយព្រះពរសួរព្រះអង្គថា បើមហាក្សត្រស្តេចទ្រង់ប្រោសប្រទានរាជ-បណ្ណាការដល់ជនទាំងពួងមានបុរោហិតជាដើម នោះជនទាំង

នោះមិនជាធំប្រសើរជាងព្រះមហាក្សត្រព្រោះតែទ្រង់ព្រះរាជទាន បណ្ណាការនោះឲ្យឬអ្វី មហាបពិត្រ ។

ព្រះបាទមិលិន្ទស្តេចទ្រង់មានព្រះរាជឱង្ការត្រាស់តបទៅព្រះថេរវិញថា មិនមែនដូច្នោះទេលោកម្ចាស់ បពិត្រលោកម្ចាស់ដ៏ចំរើន ឯជនទាំងពួងមានបុរោហិតជាដើមនោះមិនបានប្រសើរជាងស្តេចទេ តែព្រះមហាក្សត្រដែលស្តេចទ្រង់ប្រោសប្រទាននូវរាជបណ្ណាការនោះដើម្បីនឹងឲ្យជនទាំងនោះមានកេរ្តិ៍ឈ្មោះថា ជាអ្នកបានទទួលរង្វាន់អំពីមហាក្សត្រទ្រង់ប្រទានឲ្យប៉ុណ្ណោះទេ ។

ព្រះនាគសេនថេរទើបថ្វាយព្រះពរទៅមហាក្សត្រវិញថា បពិត្រមហារាជ សេចក្តីនេះមាឧបមាដូចស្តេចមិញ ថាមានឧបមេយ្យដូចសង្ឃរតននោះដែរ ឯសង្ឃរតននេះ មិនមែនជាធំជាងឬប្រសើរជាងព្រះបរមសាស្តា ព្រោះតែព្រះសាស្តាស្តេចទ្រង់ត្រាស់ឲ្យព្រះមាតុច្ឆាបូជាសម្ពត់សាជកប៉ុណ្ណោះនោះទេ ប្រការ ១ ទៀតឯព្រះសង្ឃនោះតែងមានព្រះសម្មាសម្ពុទ្ធជាប្រធាន ព្រះ

សម្មាសម្ពុទ្ធព្រះអង្គទ្រង់លើកដំកើងព្រះសង្ឃនោះទុកក្នុងទីជាទីបូជារបស់ព្រះអង្គ ហើយទើបទ្រង់ត្រាស់បង្គាប់ទៅនាងមហាបជាបតិគោតមីឲ្យព្រះនាងយកសម្ពត់សាដក់នោះបូជាដល់ព្រះសង្ឃនោះ ។

ន័យ ១ វិញទៀត បពិត្រព្រះរាជសម្ភារ សម្តេចព្រះទសពលញាណស្តេចទ្រង់មានព្រះយោបលឃើញយល់ថា សង្ឃរតននេះជាវត្ថុគួរដល់ការបូជាដោយពិត្រ បានជាទ្រង់តាំងព្រះហឫទ័យថា តថាគតនឹងបូជាបំពោះនូវសង្ឃរតន ដោយវត្ថុជារបស់ព្រះអង្គ ហើយទើបទ្រង់ត្រាស់ បំពោះទៅព្រះមាតុច្ឆាឲ្យព្រះនាងយកសម្ពត់សាដកនោះទៅប្រគេនដល់ព្រះសង្ឃក្នុងកាលនោះឯង ។

ម្យ៉ាងទៀត ព្រះរាជសម្ភារ សម្តេចព្រះទសពលញាណព្រះអង្គមិនដែលលើកសរសើរព្រះអង្គឯង ថាជាបុគ្គលគួរដល់ការបូជាទេទ្រង់តែងពណ៌នាសរសើរនូវបុគ្គលណា ១ ដែលមានវត្តប្រតិបត្តិល្អគួរជាទីបូជា ទើបព្រះអង្គសរសើរបំពោះបុគ្គលនោះ

បពិត្រព្រះរាជសម្ភារ ឯព្រះបរមសាស្តាចារ្យព្រះអង្គជាវិសុទ្ធទេ-វាកន្លងលើសនូវទេវតាទាំងពួង ព្រះអង្គទ្រង់បានត្រាស់សំដែង លើកនូវភិក្ខុដែលមានវត្តប្រតិបត្តល្អជាអ្នកប្រាប្នតិប ដោយធម្ម-ទាយាទធម្មបរិយាយ ក្នុងគម្ពីរមជ្ឈិមនិកាយថា អសុយេរិបុ-រិមោភិក្ខុ ភិក្ខុឈ្មោះនោះហ្ន៎ដែលជាភិក្ខុនៅខាងមុខនៃតថាគត នោះ ជាបុគ្គលគួរដល់បូជាយ៉ាងវិសេស នឹងគួរជាទីសរសើរ យ៉ាងក្រៃលែង តែថានឹងប្រសើរជាងព្រះអង្គនោះមិនមានឡើយ បពិត្រព្រះរាជសម្ភារ បណ្តាសត្វនិកាយទាំងឡាយ ក្នុងភព ទាំងអស់នោះ នឹងរកសត្វណានិមួយឲ្យជាសត្វប្រពៃក្រៃលែង លើសព្រះអនាវរញ្ញាណនោះគ្មានទេ ឯសម្តេចព្រះអនាវរញ្ញាណ នោះព្រះអង្គជាបុគ្គលប្រសើរខ្ពង់ខ្ពស់ ដោយវិសេសជាងសត្វ ទាំងអស់ក្នុងត្រៃភព នឹងរកសត្វណាមកប្រៀបផ្ទឹមឲ្យត្រឹមស្មើ ពុំបានឡើយ បពិត្រសម្តេចមហារាជសេចក្តីនេះត្រូវគ្នានឹង ពាក្យសរសើរ របស់មាណវិគាមិកទេវបុត្រពោលទុកក្នុងទីចំ-ពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ ក្នុងកណ្តាលនៃពួកមនុស្ស

នឹងស្ដេចនៃមនុស្សទាំងពួង  ក្នុងគម្ពីរសំយុត្តនិកាយជាបទគា
ថា ថាដូច្នេះ ។

វិបុលោរាជគហានំ  គិរិសេដ្ឋោបវុច្ចតិ
សេតោហិមវន្តំសេដ្ឋោ  អាទិច្ចោអឃគាមិនំ
សមុទ្ទោនទីនំសេដ្ឋោ  នក្ខត្តានញ្ចចន្ទិមា
សទេវកស្សលោកស្ស  ពុទ្ធោអគ្គោបវុច្ចតិ ។

សេចក្ដីថា  ភ្នំវិបុលប្រសើរជាងភ្នំទាំងអស់ក្នុងប្រទេសរាជគ្រឹះ  ភ្នំកៃលាសប្រសើរជាងភ្នំទាំងអស់ក្នុងព្រៃហេមពាន្ត ព្រះអាទិត្យថ្លៃថ្លាជាងវត្ថុទាំងអស់ដែលមាននៅក្នុងអាកាសវិហារ មហាសមុទ្ររុងរឿងជាងស្ទឹងទាំងអស់ក្នុងលោកនេះ  ព្រះចន្ទថ្លៃថ្លាវិសេសជាងនក្ខត្តឫក្សទាំងឡាយ  ព្រះសព្វញ្ញុពុទ្ធព្រះអង្គមានគុណង៍ប្រសើរលើសលប់ជាងទេវតានឹងមនុស្សទាំងពួងក្នុងលោក បពិត្រសម្ដេចមហារាជ  ពាក្យនេះជាពាក្យរបស់មា-ណវគាមិកទេវបុត្រពោលទុកជាគាថានេះ ឯគាថានេះគឺទេវបុត្រនោះរៀបរៀងក្រងទុកដោយល្អហើយ  មិនបានរៀបរៀងដោយ

វិញទេ ជាគាថាសុភាសិតមិនមែនទុព្ភាសិតទេ ព្រោះព្រះសម្មា
សម្ពុទ្ធព្រះអង្គបានអនុមតិតាមថាត្រឹមត្រូវល្អហើយ បពិត្រព្រះ
រាជសម្ភារ ព្រះធម្មសេនាបតិសារិបុត្តត្ថេរ លោកបានពោល
ទុកថា បុគ្គល ១ ពួកបានដល់នូវត្រ័យសរណគមន៍ បានបង្អោន
នូវអញ្ជលីកម្មដោយសេចក្ដីជ្រះថ្លាក្នុងចិត្តថា ដើម្បីនឹងឆ្លង
ចាកសំសារទុក្ខដោយការព្យាយាមនោះ ឬមិនដូច្នោះទេមហា
បពិត្រ ។ ម្យ៉ាងទៀតសម្ដេចព្រះសព្វញ្ញុតញ្ញាណ ព្រះអង្គជា
ទេវតាវិសេសជាងទេវតាទាំងអស់ក្នុងត្រៃលោក ទ្រង់បានត្រាស់
ប្រកាសសេចក្ដីទុកមកថាដូច្នេះ ឯកបុគ្គលោ ភិក្ខវេ លោកេ
ឧប្បជ្ជមានោ ឧប្បជ្ជតិ នៃភិក្ខុទាំងឡាយ មានបុគ្គលម្នាក់កាល
ដែលកើត ៗ មកក្នុងមនុស្សលោក ហើយទំប្រព្រឹត្តធ្វើខ្លួនឲ្យជា
ប្រយោជន៍ដល់ជនច្រើន ឲ្យមានសេចក្ដីសុខដល់ជនច្រើន ជា
អ្នកអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចំរើន នឹងប្រយោជន៍
នឹងសេចក្ដីសុខ ដល់ទេវតានឹងមនុស្សទាំងឡាយ កតមោ
ឯកបុគ្គលោ បុគ្គលម្នាក់នោះតើគឺអ្នកណា តថាគតោអរហំ

សម្មាសម្ពុទ្ធោ អយំខោ ភិក្ខុវេឯកបុគ្គលោ ឯបុគ្គលម្នាក់នោះ មិនគឺអ្នកឯណាទេ គឺអង្គព្រះតថាគតដែលមាននាមថា អរហំ សម្មាសម្ពុទ្ធនេះឯង ព្រះអង្គនេះទ្រង់កើតឡើងក្នុងលោក ដើម្បីសេចក្តីចំរើន នឹងប្រយោជន៍ ហើយនឹងសេចក្តីសុខ ដល់ទេវតានឹងមនុស្សទាំងឡាយ សេចក្តីដូចអាត្មាភាពរាប់រៀបមកនេះ សូមមហាបពិត្រស្តេចជ្រាប ។

ព្រះបាទមិលិន្ទ្រាធិបតីស្តេចទ្រង់ត្រាស់ទទួលពាក្យព្រះនាគសេនថេរថា សាធុភន្តេនាគសេន បពិត្រព្រះនាគសេនដ៏ចំរើន សេចក្តីដែលលោកម្ចាស់អធិប្បាយ រាប់រៀបមកនេះក៏ប្រពៃណាស់ហើយ ញោមក៏ចូលចិត្តស៊ប់សួនអស់សង្ស័យហើយ ខ្ញុំព្រមទទួលតាមពាក្យរបស់លោកម្ចាស់ដោយសព្វគ្រប់ប៉ុណ្ណោះឯង ។

បប់គោតមីវត្ថុទានបញ្ហាប៉ុណ្ណោះ

គោតមីវត្ថុទានបញ្ហានេះ មិនប្រាកដជាមានមកក្នុងវគ្គណា ស្រាប់តែឃើញមានមកនៅត្រង់ទីបញ្ចប់នៃមិលិន្ទបញ្ហា

នេះ ហើយប្រាប់សេចក្ដីថាគោតមីវត្ថុទាននេះជាប្រស្នាទី ៣ តែម្ដង ឯត្រង់ប្រស្នាទី ១ ទី ២ ឬទី ៤ ទី ៥ តទៅមិនឃើញមាន ។

ក្នុងគម្ពីរមិលិន្ទបញ្ហានេះ បែកចេញជា ៦ ស្ពាន គឺ

បុព្វយោគ ១ មិលិន្ទបញ្ហា ១
មេណ្ឌកបញ្ហា ១ អនុមានបញ្ហា ១
លក្ខណបញ្ហា ១ ឧបមានកថាបញ្ហា ១
ត្រូវជា ៦ ស្ពាន ។

បណ្ដាស្ពានទាំង ៦ នោះ ស្ពានទី ១ គឺបុព្វយោគ ស្ពានទី ២ គឺមិលិន្ទបញ្ហានោះ បានប្រែរៀបរៀងចប់មកហើយ នៅសល់ ៤ ស្ពានទៀត នឹងមានទៅក្នុងសៀវភៅជាន់ក្រោយ ។

# អំពីសេះពលាហ៍

តាមសំអាងដោយលក្ខណ៍ជានរបស់លោក វិកទ័រគោលូបែហ៍
អគ្គលេខាធិការសាលាបារាំងសេស នៅចុងបូព៌ាប្រទេស ហាណូយ

## ក្រម្ការ ជុំ-មៅ ជាអ្នកតែងសេចក្ដីក្នុងព្រះរាជបណ្ណាល័យ

## ប្រែមកជាភាសាខ្មែរ

(ត – ចប់)

សេចក្ដីដែលគ្មានបរិកកាលសម័យជាសំគាល់ ដោយច្បាស់លាស់នោះមិនអាចនឹងជំរុំពេលសម័យ ឲ្យបានដោយជាក់ស្ដែងដល់ការនេះឡើយ តាមសភាពការដែលយើងស្រាវជ្រាវរកសព្វថ្ងៃនេះ គេគ្រាន់តែបញ្ជាក់បានយ៉ាងដូច្នេះ គឺជារូបសេះពលាហ ព្រមទាំងក្បាច់បំឡាក់នៅប្រាសាទនាគព័ន្ធទាំងប៉ុន្មាន មានក្បាច់បំឡាក់នៅក្នុងទីបោស្ថកណ្ដាល នឹងជើងកោសដែលធ្វើជាត្របកឈូកជាដើម នឹងក្បាច់រូបដំរីទឹកមួយអន្លើនឹងរូបនាគដែលព័ន្ធត្របាញ់បញ្ចូលផ្លូងគ្នានោះ មានភាពសណ្ឋានខាងបែបបំឡាក់នឹងបែបប៉ាន់រូប ដូចគ្នានឹងប្រាសាទ

បាយ័ន, ប្រាសាទព្រះខ័ន នឹងទ្វារអង្គរធំ, បើនឹងនិយាយជាសេចក្ដីម្យ៉ាងទៀតថា រូបសេះពលាហនេះចាប់សាងក្នុងគ្រាដែលព្រះពុទ្ធសាសនាកំពុងចំរើនល្អ នឹងកំពុងបែកប្រតិស្ឋការសួនប៉ាន់រូប ហើយដែលស្រុកខ្មែរទទួលបែបរបនាមកអំពីស្រុកឥណ្ឌៀប៉ែកខាងទិសអគ្នេយ៍ ទំនងជាមកអំពីស្រុកពោធគយានឹងនាលន្ទ, ប្រហែលជាទទួលជាដំណរមកពីស្រុកជ្វាស្មាជានៃព្រះពុទ្ធសាសនាប៉ែកខាងឧត្ដរនិកាយ ។

ក្នុងការសិក្សាស្រាវជ្រាវក្នុងគ្រាក្រោយនេះ លោកល្វ៉េ-ណូត៍បានបញ្ចូលរឿងប្រាសាទបាយ័នទៅក្នុងរឿងរ៉ាវនៃការសាសនាក្នុងសម័យអង្គរ គេបានជឿមកជាអង្វែងឆ្នាំ ថាវិហារស្ថាននេះកសាងឡើងដើម្បីដំកល់នូវលិង្គ ឥឡូវនេះយើងបានដឹងថាប្រាសាទនេះកាលជាន់ដំបូងបំផុតបានសាងឧទ្ទិស្សថ្វាយព្រះលោកេស្វរពោធិសត្វ, ហើយឯរូបពោធិសត្វដែលមានព្រះភក្ដ្រញញឹមនេះមានរបនាដេរដាសនៅលើសុំទ្វារ ។ គឺជាជោគល្អដោយឥតទន្ទឹងចាំដែលបានប្រទះនូវការជាទីនាំឲ្យបាន



រូបសេះក្បាល ៥ នៅទីព្រះលានប្រាសាទនគរធំ កំពស់ ២ម៉៥០

ឃើញវិធីថ្មីនឹងបានបញ្ជាក់នូវគោលចារិកដោយជាក់លាក់ឥត ស្រើស ។

លោកល្វីហ្វីណូត៍បានពោលថា៖ «គេដឹងថាផ្ទៃដែលទ្រនូវកំពូលកណ្តាលនោះតាមរាងវានឹងទំហំសព្វថ្ងៃ ជាការប្រែកែខុសអំពីបាត់ដោដើម ឯក្នុងបាត់ដោដើមគេបានកំណត់ទីផ្ទៃនោះ តូចជាងសព្វថ្ងៃ លុះពង្រីកឲ្យធំទូលាយដូច្នេះទៅផ្ទៃនេះក៏ប៉ះទៅនឹងស៊ុំទ្វារបែរនៃថ្នាក់ជាន់ក្រោម ហើយក៏បាំងនូវក្លោងទ្វារអស់ទៅ នៅកន្លែងខ្លះមានទាំងធ្វើឲ្យបាក់បែកខូចផង ។

" នូវវេលាដែលដកយកថ្មក្រាលចេញ ដើម្បីនឹងពិនិត្យនូវក្លោងទ្វារ ១ ក្នុងបណ្តាក្លោងទ្វារទាំងឡាយ លោកប៉ារម៉ងបេ ក៏បានឃើញនូវរូបមួយយ៉ាងច្បាស់ ស្ទើតែមិនមានអ្វីទៅប៉ះពាល់ឡើយ គឺជារូបលោកេស្វរនៅឈរលើផ្កាឈូក ១ មានទាំងរូបព្រះអមិតាភនៅលើផ្នួងព្រះកេសា ហើយព្រះហស្តកាន់សៀវភៅនឹងកុន្ទី ព្រមទាំងមានរូបអប្សរនឹងរូបហោះឯទៀតនៅជុំវិញ ឯក្លោងទ្វារឯទៀតដែលនៅសល់នោះ សំគាល់ឃើញមានរូបដូច ៗ គ្នា តែឯព្រះកេសនោះក៏កំបាំងនឹងផែន

សិលាដែលក្រាលផ្ទៃខាងលើពង្រីកឡើង ហើយបំណែកព្រះហស្តទាំង ២ ខាងលើក៏គេកាត់បេញត្រឹមក ប៉ុន្តែព្រះហស្តទាំងពីរខាងក្រោមកាន់នូវផ្កាឈូកនឹងដប ១ ជាទីតាំងឲ្យសំគាល់បានដោយងាយថាជារូបព្រះពោធិសត្វ ។

បំពោះនឹងរូបសំអាងយ៉ាងច្បាស់លាស់ មិនអាចនឹងទុកដាក់បានថាជាបែបរចនាតាមធម្មតា ដូច្នេះហើយ, យើងត្រូវដឹងនូវសេចក្តីថាប្រាសាទបាយ័នជាន់ដើមមិនមែនជាទេវស្ថានរបស់លិង្គដូចជាយើងធ្លាប់ជឿមកលុះដល់សម័យនេះទេ គឺជាទីវិហារស្ថាន ១ របស់ព្រះពុទ្ធសាសនាវិញ (១), នូវវេលាក្រោយដែលបានរកឃើញនេះ បានធ្វើការស្រាវជ្រាវរិះរកនៅប្រាសាទបាយ័នទៀត ហើយក៏បានឃើញជាក់ច្បាស់ថាក្លោងទ្វារទាំងឡាយដែលនៅជុំវិញភ្នំកណ្តាលនោះសុទ្ធតែមានរូបលោកេស្វរទាំងអស់ ប៉ុន្តែរូបទាំងនេះខ្លះឃើញកែឡើងឲ្យទៅជាលិង្គ

(១) មើលសៀវភៅដែលសម្តែងអំពីលោកេស្វរនៅប្រទេសឥណ្ឌូស៊ីន ដែលលោកល្វីហ្វីណូត៍អធិប្បាយក្នុងសេចក្តីស្រាវជ្រាវក្នុងស្រុកអាស៊ី បោះពុម្ពក្នុងឆ្នាំ ១៩២៥ ខ្សែ ១ ទំព័រ ២២៦ សៀវភៅនេះមានក្នុងព្រះរាជបណ្ណាល័យ ។

ទៅវិញដោយកាត់ព្រះកេសនឹងព្រះហស្ថបេញបង់ ហើយរូបខ្លះក៏ឃើញជុះរំលប់ដោយផ្ចិតផ្ចង់ គង់នៅតែស្នាមយាងស្រាលស្ទើមើលមិនច្បាស់ នៅលើក្លោងទ្វារដែលឆ្លាក់រឿងរ៉ាវនេះ ហើយដែលកាលពីដើមរូបទាំងនេះជាទីគោរពយ៉ាងប្រសើរក្នុងទីនោះឯង ក្នុងស្ថាននេះប្រហែលជាពួកសត្រូវនឹងព្រះដែលគេលែងរាប់អានក្នុងទីនោះ កើតនូវចិត្តដែលចង់បំផ្លាញរូបទាំងនេះឡើង លុះដល់ធ្វើបំបាត់រូបអំពីក្បាច់នៅជញ្ជាំងនឹងនៅសសរព្រមទាំងចំឡាក់អ្វីទាំងប៉ុន្មាន ដែលអាចនឹងសំគាល់បានបន្តិចបន្តួចថាជាចំឡាក់ក្នុងពុទ្ធសាសនា ។

លុះដល់មកក្នុងខែធ្នូសម ១៩២៦ បានពិនិត្យក្បាច់ចំឡាក់នៅជញ្ជាំងបន្ទប់ក្រៅខាងកើត បានឃើញក្បាច់ចំឡាក់ ២ បែបក្នុងក្រមរស្លែនឹងផ្សិតថ្មហ៉ាងក្រាសដែលបានដុសប្រាសចេញ គឺជារូបចំឡាក់រឿងសេះពលាហមិនមែនជារឿងអ្វីឡើយ ។

រូបចំឡាក់នេះមាននៅ ៗ លើចំហៀងក្លោងទ្វារទាំង ២

ដែលជាប់ទៅនឹងជ្រុងខាងក្រោមនៃបន្ទប់ក្រៅ ១ ជាខាងកើត ជណ្ដើរដែលឡើងទៅកាន់ផ្នែកកណ្ដាល ។

ឯក្បាច់ចំឡាក់ខាងផ្ទៃងនោះច្បាស់ជាយករឿងជាមួយគ្នា នឹងរឿងរបស់រូបដែលបានគាស់ឃើញនៅប្រាសាទនាគព័ន្ធ មកធ្វើ ប៉ុន្តែមិនយកគំរូតួយ៉ាងនោះមកធ្វើតាមឡើយ ក្បាច់ចំឡាក់នេះហាក់ដូចជាបន្ថយដកនូវសេចក្ដីលំអរបស់រឿងចេញ ដោយសេចក្ដីខ្ជិលរវល់មិនអើពើ និងដោយសេចក្ដីមិនស្ទូវប៉ុនប្រសប់របស់ជាងដែលប្រកបឆ្លាក់ គឺជាងនេះឯងរកគំនិតនឹងផ្ដើមរឿងរ៉ាវដោយរកទំនងខ្លួនឯងមិនកើត ហើយក៏យករឿងដែលគេធ្វើហើយមកជាគំរូ ម៉ាងកន្លែងខ្លះបានយកបែបដែលគេរបនាក្នុងគ្រា « ចេញទ្រង់ព្រះផ្នួស » ដែលព្រះសិទ្ធបិពោធិសត្វទ្រង់គង់លើអាជានេយ្យ ហើយទេវតាទាំងឡាយទ្រជើងនៃព្រះរាជយាននោះ ។

បំណែកខាងលើនៃក្លោងទ្វារនោះរបើកជ្រុសបាត់ ជាប់ដោយទាំងក្បាលសេះពលាហត្រឹមពាក់កណ្ដាលកនឹងក្បាលមនុស្ស ២ នាក់ដែលប្រគោងកៀកគ្នានៅលើខ្នងសេះ ដើម្បី



រឿងសេះពលាហ    នៅស្តូបបហ៊ុត

សព្វថ្ងៃនៅសារមន្ទីរ    ក្រុងក័លគុត្តា



រឿងសេះពលាហ នៅព្រហ្មបុត

សព្វថ្ងៃនៅសារមន្ទីរ ក្រុងកលគុត្តា

មិនឱ្យប្រេះធ្លាក់ទៅក្នុងពេលហៀវនោះផង ដែលគ្រឿងនៃរាងដួចផ្កាឈូក ទ្វារនោះ គ្រឿងពិធីបោសសំអាតបែរទឹកជុំវិញអាងទាក់ស្ទើរផ្ទៃ ទឹកលយឿង មានស្នើទឹកគ្រឿងពិធីដែលធ្វើពីធ្មេញ ៧ ។

ឆាវទឹកផ្កាដំ មានពិទ្ធក់ ២ ចែបទៀត ដែលគេយក មកបញ្ចូលក្នុងការ

កាលពីឆ្នាំ ... ហេត លោកយកទឹកមកក្នុង ... ៥ មួយ[១] ហើយ ... កក្កាយយកទឹកថ្មី ... ពេ ក្នុងទីផ្សារនោះ[២]

ដំរីទូក ... អស់



រឿងរសេះពាណហារទៅអដ្ឋា

ហើយលោះដើងលោកក្រុមទាំងអស់នេះ ... ហើយ ត្រឹមស្នើទីងជើង ក្នុងពេលក៏ដំណើរក្នុងបង់រឿងទាំងបង់ខាង

(១) ឬក្ខិតាំងសកលវាក់វិធីរបរទៅក្នុងសម្ពាធទៀតផ្ទើរ ៤ ភាគ ៥ ទំព័រ ១១១

(២) ឬក្ខិតាំងសកលវាក់វិធីរបរទៅក្នុងសម្ពាធទៀតផ្ទើរ ១៥ ភាគ ៤ ទំព័រ ៨៨

មិនឲ្យរបេះធ្លាក់ទៅក្នុងសមុទ្រនោះផង គែមក្រៅនៃរង្វង់ក្លោងទ្វារនោះ ក្រៅអំពីរូបសេះនឹងរូបមនុស្សឃើញមានឆ្លាក់ធ្វើជាផ្ទៃទឹកសមុទ្រ មានស្មៅទឹកក្រពើនឹងមច្ឆាជាតិផ្សេង ៗ ។

នៅទីអង្គរធំ មានបំឡាក់ ២ បែបទៀត ដែលគួរយកមកបញ្ចូលក្នុងការសិក្សានេះដែរ ។

កាលពីឆ្នាំ ១៩១៦ វេលាដែលកកាយឬសទីព្រះលានលោកហង់រីមារ្សាល់បានប្រទះឃើញបំឡាក់រូបសេះក្បាល ៥ មួយ[១] ហើយតពីនោះក្រោយមកក្នុងឆ្នាំ ១៩១៧ បានគាស់កកាយឃើញបំណែករូបសេះ១ទៀត ទំនងដូចជាមានក្បាល៧ក្នុងទីជិតគ្នានោះ[២] ។

ឯបំឡាក់រូបសេះក្បាល ៥ នោះនៅល្អស្មើតែទាំងអស់ហើយសេះធំដែលនៅជាកណ្ដាលនោះមានជើងទ្រង់មូលហើយត្រឹមស្មើនឹងជើង ក្បាលក៏ធំជាងក្បាលឯទៀតទាំងសងខាង

---

(១) ប៊ុល្លេតាំងសាលាបារាំងសែសនៅចុងបូព៌ាប្រទេសឆ្នាំ ១៦ ភាគទី ៥ ទំព័រ ១០១

(២) ប៊ុល្លេតាំងសាលាបារាំងសែសនៅចុងបូព៌ាប្រទេសឆ្នាំ ១៧ ភាគទី ៦ ទំព័រ ៥៧

រីគ្រឿងរចនាប្រដាប់កាយសេះទាំងប៉ុន្មាននោះមានសណ្ឋានដូចជាគ្រឿងអលង្ការសំរាប់ទេវតានឹងស្តេច គឺមានម្កុដស្រួច ៣ ជាន់ ១ ខ្សែកធំមានក្បាច់ប្រគោង ១ ហើយមានកងជើង ២ គូពាក់នូវជើងនីមួយ ៗ ផង ម្យ៉ាងវិញទៀតឯប្រដាប់ប៉ាំងមុខនោះនៅទន្ទិមគ្នានឹងភ្នែកធ្វើជាផ្កាមានក្លែប ៤ ក្នុងក្បាច់លំអទាំងនេះឃើញមានក្បាច់ម្យ៉ាងគួរឲ្យយើងពិនិត្យបន្តិច គឺនៅលើក្បាលសេះនីមួយ ៗ នោះមានសក់ស្វាយ ២ ដុំក្តួចត្របាញ់ជុំវិញត្រចៀក ហួលក្នុងក្រវិល ២ ដែលរចនាដោយកែវមុក្តា ហើយបេញឡើងស្រួចទៅលើបែបជាស្នែង ។

ឯទីព្រះលានេះនោះគេបានដឹងថាចាប់កសាងក្នុងពេលជាមួយគ្នានឹងប្រាសាទនាគព័ន្ធ លុះយកសេចក្តីត្រង់នេះមករិះគិតទៅ នាំឲ្យល្បងពិចារណាថា ប្រហែលជាមិនលែងមានសេចក្តីទាក់ទិនអ្វី អំពីរូបចំឡាក់ដែលយើងទើបនឹងពោលរៀបរាប់នេះនឹងបំណោមសេះហោះទាំងនោះឡើយ ។

ត្រង់នេះលោកល្វីហ្វីណូត៍បានអធិប្បាយថា “ ជាបំណោទ ១ ដែលត្រូវរកឲ្យឃើញថា តើរូបសេះក្បាល ៥ ដែល

មាននៅជញ្ជាំងទីព្រះលានៈនៅអង្គរធំ មានមនុស្សគោរពជុំវិញនោះ ជារូបព្រះលោកេស្វរនិមិត្តព្រះអង្គជាសេះទិព្យដែរឬអ្វី ,, សេចក្ដីសម្មតិណែនាំរបស់លោកល្វីហ្វីណូត់នោះ ក្រៅអំពីប្រយោជន៍ឯទៀតជាច្រើន នាំឲ្យពន្យល់ឲ្យបានច្បាស់លាស់បន្តិចថា បុះហេតុអ្វីបានជានៅទីព្រះលាននោះគេរចនាសេះពាលាហឲ្យមានក្បាលដល់ទៅ ៥ សេចក្ដីនេះបើតាមពិនិត្យគ្រប់រូបលោកេស្វរទៅ បើយ៉ាងតិចក៏មានរូប ១ ដែលមានមុខ ៥ ដែរ ដូច្នេះឃើញថាជាការគួរជឿដល់អ្នកដែលបានស្គាល់បែបភាពរូបផ្សេង ៗ របស់មហាយាន ថាជាងចំឡាក់បង់ធ្វើរូបទេវតាតែ ១ អង្គ តែបំបែកឲ្យមានបែបភាពទីទៃពីគ្នា ។

អំពីរូបសេះពលាហនេះ ត្រូវសារសព្វអំពីរូបខ្លះដែលមានក្នុងប្រាសាទផ្សេង ៗ ក្រៅអំពីប្រទេសឥណ្ឌាស៊ីនផង ។

រូបដែលចាស់ជាងគេបំផុត គឺរូបដែលនៅ។ សារមន្ទីរក្រុងក័លគុត្តាក្នុងស្រុកឥណ្ឌៀ រូបនេះមានបែបភាពជាការរចនាដែលចេញមកពីប្រទេសមថុរាក្នុងរវាង់គ្រិស្តសករាជពី ២០០ ទៅ ៣០០ ឆ្នាំ រូបនេះឆ្លាក់ផ្ចិតបែបជាប្រិបត់នៅលើសសរ

ជញ្ជាំងតឿ ដែលមានកាត់ជាខាន់ ៗ ចំនួន ៣ ផ្ទាំង ហើយក្នុង ១ ខាន់មានរឿង ១ កន្លែង ឯខាន់កណ្ដាលនោះបាប់យករឿងត្រង់ដែលជួយសង្គ្រោះដោយអស្ចារ្យ គឺសេះនោះហោះឆ្លងកាត់សមុទ្រនាំមនុស្សដែលលិចសំពៅយកទៅ ។

ឯរឿងនៅខាងក្រោមធ្វើឲ្យយើងឃើញពួករាក្សសី ដំបូងគឺឃើញរូបក្មេងជាស្រីមានរូបឆោមល្អបំព្រួន ហើយតមកទៀតឃើញជារូបយក្ខិណីយ៉ាងសំបើមគួរខ្លាច កំពុងទំពាសាច់មនុស្សស៊ី ហើយៈនៅខាន់ទី ៣ ខាងលើបំផុតនោះរូបនាយឈ្មួញកេត្រាឡើងលើចុងឈើ ដើម្បីនិយាយប្រាប់ហេតុដល់មនុស្សដែលត្រូវឃុំរបស់យក្ខិណីក្នុងគុកនោះ ។

នៅបន្ទាប់រូបនេះគឺរូបសេះពលាហនៅក្នុងគោហា អជណ្ដានៅជញ្ជាំងខាន់ល្វែងនៃល្វែងវិហារនេះ មានគំនូរ ១ បែបក្នុងរឿងដដែលនេះដែរ គឺជាគំនូរឋ្មាំដែលធ្វើនៅទីអជណ្ដា ក្នុងរវាងគ្រិស្តសករាជពី ៦០០ ទៅ ៧០០ ឆ្នាំ តែជាការឥតភ័ពណាស់ ដែលយើងមិនមានរូបថតត្រង់កន្លែងស្រោចស្រង់យ៉ាងអស្ចារ្យ ។

ឯក្បាច់ចំឡាក់ក្រៀកផ្កាមានឆ្លាក់រឿងនេះដែរ ដូចមាន

សំអាងនៅក្បាច់ផ្តាច់ក្រោលទម្រុបន្ទប្រោប់ ការដែលយក

រឿងសេះពលាហកទៅចាក្នុលក្នុងរឿងផ្សេង ២ ជារឿងបរិវត្តន៍

ព្រះអរិយមេត្រីយពោធិសត្វនៅថ្ងៃទី ៣ និងទី ៤ តាំងឡើង

ស្ពានបានក្នុងគំនិតថា គេយកព្រះអរិយមេត្រីយជាពោធិ

សត្វពោធិសត្វ



រឿងសេះពលាហៈនៅវិហារ អានន្ទ ស្រុកភូមា

ឯរូបក្រៅ … ក្បាច់

ផ្តាំងធំនៅប … បន្ទះ

ទ្វារដែលសាងក្នុង … ពល

និងពួកពល្លជា … នេះ

មានរឿងរាវចិត្តគ្នានឹង … ប៉ុន្តែ

ទាំង ២ ស្ពានទេះប្រហែលជាកាងបតាបានយករូប អភិនិក្ខម-

ណប្បញ្ញទៅជំនួសមកជាតំរូ ព្រោះរូបនេះជាងបតាដែលកាន

ព្រះពុទ្ធសាសនាក្នុងប្រឆាំងរូបសេះពលាហ ១៩៥—

ឯក្បាច់ចំឡាក់ស្រុកជ្វាមានធ្លាក់រឿងនេះដែរ ដូចមានសំអាងនៅក្បាច់ជញ្ជាំងប្រាសាទបូរបូឌុរស្រាប់ ការដែលយករឿងសេះពលាហទៅបញ្ចូលក្នុងរឿងផ្សេង ៗ ជារឿងបរិវត្តន៍ព្រះអរិយមេត្រិយពោធិសត្វនៅវែវទី ៣ និងទី ៤ នាំឲ្យយើងស្មានបានក្នុងគំនិតជ្វាថា គេយកព្រះអរិយមេត្រិយជាលោកេស្វរពោធិសត្វ ។

ឯរូបក្រោយបំផុតដែលយើងត្រូវនិយាយនោះ គឺក្បាច់ជញ្ជាំងអិដនៅវិហារស្ពាន អានន្ទនៅស្រុកភូមា ។ នៅបន្ទះទ្វារដែលសាងក្នុងរវាងឆ្នាំ ១១០០ នោះមានចារិកត្រង់សីហលនិងពួកឈ្មួញជាមិត្ររត់បេញពីពួកយក្ខិណី ក្បាច់ចំឡាក់នេះមានរឿងរ៉ាវដូចគ្នានឹងក្បាច់ចំឡាក់នៅប្រាសាទបាយ័ន ប៉ុន្តែទាំង ២ ស្ពាននេះប្រហែលជាជាងរបនាបានយករូប អភិនិស្ក្រម-ណាឬបេញទ្រង់ផ្នួសមកជាគំរូ ព្រោះរូបនេះជាងរបនាដែលកាន់ព្រះពុទ្ធសាសនាស្គាល់ច្បាស់ជាងរូបសេះពលាហ ។៚

ប្រស្នាធម៌

ព្រះស្រីសម្មតិវង្ស អែម ចាងហ្វាងសាលាបាឡីជាន់ខ្ពស់នៅក្រុងភ្នំពេញ

# រៀបរៀង

## ៥ អត្ថស្សទ្វារបញ្ហា ប្រស្នាសួរទ្វារដែលជាប្រធាននៃអត្ថ

រឿងនេះមានក្នុងគម្ពីរឯកនិបាតជាតកខ្សែ ១៣ សម្ដែងសេចក្ដីថាកាលអង្គសម្ដេចព្រះបរមគ្រូជាម្ចាស់ កាលព្រះអង្គគង់នៅក្នុងវិហារព្រះជេតពនសុគន្ធកុដី ទៀបក្រុងនគរសាវត្ថី ព្រះអង្គទ្រង់ប្រារព្ធនូវកុលបុត្រម្នាក់ជាអ្នកឆ្លាតក្នុងអត្ថ ហើយទ្រង់សម្ដែងនូវធម៌ទេសនានេះមានបទថា អរោគ្យបរមា លាភា ជាដើម ។

សេចក្ដីពិស្ដារថា កាលនោះមានកូនសេដ្ឋីមួយ មានសម្បត្តិច្រើននៅក្នុងនគរសាវត្ថី សេដ្ឋីបុត្តនោះទើបតែនឹងមានអាយុៈ ៧ ឆ្នាំអំពីជាតិ តែថាជាអ្នកមានប្រាជ្ញាវៀងវៃ ជាបុគ្គលឆ្លាតក្នុងអត្ថគឺសេចក្ដីជាប្រយោជន៍ និងសេចក្ដីចំរើនដោយច្រើន ។

ថ្ងៃមួយសេដ្ឋីបុត្តនោះ ក៏ចូលទៅជិតកាន់សំណាក់សេដ្ឋីជាបិតាហើយសួរនូវទ្វារបញ្ហា ដែលជាប្រធាននៃសេចក្តីចំរើននឹងបិតា ឯបិតានោះក៏ពុំបានដឹងនូវសេចក្តីអធិប្បាយនៃប្រស្នានោះឡើយ ឆ្លើយអធិប្បាយប្រាប់កូនពុំបាន ។

គ្រានោះសេដ្ឋីជាបិតា កើតមានសេចក្តីវិតក្កវិចាររំពឹងគិតថាប្រស្នានេះជាសុខុមល្អិតក្រៃពេក វៀរលែងតែព្រះសម្មាសម្ពុទ្ធជាអង្គសព្វញ្ញូចេញ បុគ្គលឯណាដទៃ ក្នុងលោកសន្និវាសនេះខាងក្រោមកំណត់តាំងតែអំពីស្ថាននរកឈ្មោះអវិចីមក ខាងលើតាំងអំពីទីបំផុតនៃអកនិដ្ឋភពចុះមក ឈ្មោះថាជាបុគ្គលអាចហើយដើម្បីសម្តែងនូវសេចក្តីអធិប្បាយនៃប្រស្នានេះពុំមានឡើយ ។

ឯសេដ្ឋីជាបិតានោះ កាន់យកនូវកូនហើយ ញ៉ាំងកូនឲ្យកាន់យកនូវផ្កាកម្រងនឹងគ្រឿងក្រអូបនឹងគ្រឿងលាបមានប្រ-មាណច្រើន ហើយចូលទៅកាន់វិហារព្រះជេតពន បូជានូវព្រះសាស្តា ថ្វាយបង្គំហើយអង្គុយនៅក្នុងទីដ៏សមគួរមួយ បានពោលនូវពាក្យនេះនឹងព្រះសាស្តាថា ភន្តេ បពិត្រព្រះអង្គដ៏ចំរើន

ទារកនេះមានប្រាជ្ញាឆ្លាតវៀងវៃនូវអត្ថ បានសួរនូវប្រស្នាដែលជាប្រធាននៃអត្ថនឹងខ្ញុំ ៗ កាលពុំបានដឹងនូវប្រស្នានោះ ហើយបានចូលកាន់សំណាក់ព្រះអង្គ បពិត្រព្រះអង្គដ៏ចំរើន សូមអារាធនាសូមព្រះដ៏មានព្រះភាគទ្រង់សម្តែងនូវប្រស្នានោះដល់ខ្ញុំ ។

អង្គសម្តេចព្រះសាស្តាចារ្យជាម្ចាស់ ទ្រង់បានស្តាប់ហើយពោលថា ម្នាលឧបាសក ព្រះតថាគតក្នុងកាលមុន គឺកុមារនេះបានសួរនូវប្រស្នានោះដែរ សេចក្តីអធិប្បាយនៃប្រស្នានោះគឺព្រះតថាគតបានសម្តែងហើយដល់កុមារនោះ ឯកុមារនេះក៏បានដឹងជាក់ច្បាស់ក្នុងកាលនោះ ដល់មកក្នុងកាលឥឡូវនេះកំណត់ពុំបានព្រោះភាវនៃខ្លួនគឺភពគ្របសង្កត់ហើយ បិទបាំងប្រាជ្ញាឲ្យវិនាសបាត់ទៅដោយពិត លុះដល់ព្រះអង្គបានពោលដូច្នេះហើយ សេដ្ឋីនោះក៏បានអារាធនានិមន្តព្រះអង្គ ៗ ក៏បានទាញអតីតនិទានមកសម្តែងថា ម្នាលឧបាសក នាកាលអតីតកន្លងរំលងទៅយូរណាស់ហើយ គ្រានោះមានព្រះបរមក្សត្រិយ៍មួយព្រះអង្គទ្រង់ព្រះនាមព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិ

ក្នុងនគរពារាណសី ឯព្រះបរមពោធិសត្វបានបង្កើតជាមហាសេដ្ឋីមានសម្បត្តិច្រើននៅអាស្រ័យក្នុងនគរនោះ ។

ក្នុងកាលជាខាងក្រោយ កូនមហាសេដ្ឋីនោះ មានអាយុ ៧ ឆ្នាំអំពីជាតិជាអ្នកមានប្រាជ្ញាឆ្លាតវៀងវៃក្នុងអត្ថ ថ្ងៃ ១ ចូលទៅជិតកាន់សំណាក់នៃបិតា ហើយសួរនូវអត្ថស្សទ្វារបញ្ហានឹងបិតាដូច្នេះថា តាត បពិតបិតា ធម្មជាតិឈ្មោះថាជាទ្វារនៃសេចក្តីចំរើន គឺធម្មជាតិអ្វី. ។

ឯបិតានៃកុមារនោះ កាលសម្តែងនូវប្រស្នានោះ ពោលជាបទព្រះគាថាដូច្នេះថា :

. អរោគ្យមិច្ឆេ បរមញ្ច លាភំ សីលញ្ច វុទ្ធានុមតំ សុតញ្ច
ធម្មានុវត្តិ ច អលីនតា ច អត្ថស្ស ទ្វារា បមុខា ឆឡេតេ

(ប្រែថា) ធម៌ទាំងឡាយ ៦ នេះគឺប្រាថ្នានូវលាភដ៏ឧត្តម គឺបណ្ឌិតពោលថាមិនមានរោគ ១ អាចារសីល ១ សេចក្តីអធិប្បាយតាមអ្នកប្រាជ្ញទាំងឡាយ ១ ស្តាប់អាស្រ័យហើយនូវហេតុ ១ កិរិយាប្រព្រឹត្តតាមនូវសុចរិតធម៌ ១ ភាពនៃចិត្តពុំបានបោកទាប ១ ធម៌ទាំង ៦ នេះឈ្មោះថាទ្វារជាប្រធាន

នៃអត្ថគឺសេចក្ដីចំរើនគ្រប់ចំពូក សេចក្ដីនេះប្រែត្រង់តាមបាឡី ពីនេះនឹងសម្ដែងតាមន័យអដ្ឋកថាឲ្យពិស្ដារតទៅទៀត ។

ប្រស្នាធម៌ទីមួយ អធិប្បាយថា ភាវៈដែលពុំមានរោគ គឺថាមិនបានឈឺចាប់មិនបានក្ដៀវក្លាដោយកិលេស នៃសរីរៈកាយផងនៃចិត្តផងបានឈ្មោះថាពុំមានរោគ កាលបើសរីរៈកាយក្ដៀវក្លាដោយរោគឈឺចាប់ហើយ លាភបាននូវភោគៈសម្បត្តិដែលខ្លួនពុំទាន់បាន ក៏ពុំអាចដើម្បីបរិភោគប្រើប្រាសនូវភោគសម្បត្តិទាំងអស់នោះបានឡើយ បុគ្គលដែលពុំបានក្ដៀវក្លាដោយរោគឈឺចាប់គឺថាពុំមានជម្ងឺ ទើបអាចដើម្បីញ៉ាំងលាភទាំងពីរនោះឲ្យចំរើនប្រយោជន៍បាន ។

កាលបើចិត្តនៃខ្លួនក្ដៀវក្លាហើយដោយកិលេសមកគ្របសង្កត់ហើយ លាភបាននូវគុណវិសេសមានប្រាជ្ញាដឹងខុសត្រូវជាដើមដែលខ្លួនពុំទាន់បានហើយ ក៏ពុំអាចដើម្បីនឹងញ៉ាំងលាភនោះឲ្យកើតឡើងបាន លាភបាននូវគុណវិសេសមានប្រាជ្ញាដឹងខុសត្រូវជាដើម ដែលខ្លួនបានហើយ ក៏ពុំអាចដើម្បីនឹងប្រើប្រាសដោយអំណាចនៃសមាបត្តិបាន នាកាលរោគនេះ

កាលបើមានហើយ លាភទាំងឡាយដែលបុគ្គលពុំបានហើយក្តី បានឈ្មោះថាលាភគឺបុគ្គលពុំបានដោយពិត ទោះលាភទាំងឡាយគឺបុគ្គលបានហើយក្តី គង់បានឈ្មោះថាលាភឥតប្រយោជន៍ ហៅថាមិនមានលាភវិញ ឯកាលរោគកាលបើមានហើយ លាភទាំងឡាយទុកជាគឺបុគ្គលមិនទាន់បានហើយ ក៏បានឈ្មោះថាលាភគឺបុគ្គលបានហើយ លាភទាំងឡាយដែលបុគ្គលបានហើយក្តី បានឈ្មោះថាលាភប្រកបដោយប្រយោជន៍ចំរើនយ៉ាងធំ ព្រោះហេតុដូច្នោះបានជាព្រះបរមគ្រូជាម្ចាស់ ទ្រង់សម្តែងថា អរោគ្យបរមោលាភោនាម ឈ្មោះថាបុគ្គលមានលាភធំ ព្រោះតែពុំមានរោគឈឺចាប់នេះជាឧត្តមដ៏ក្រៃលែង បើបុគ្គលមានរោគឈឺចាប់ហើយ ទុកជាមានលាភបានសម្បត្តិទ្រព្យច្រើនយ៉ាងណាក្តី ក៏គង់បានឈ្មោះថាបុគ្គលឥតលាភវិញដោយពិត្រ ការដែលពុំមានរោគនោះគឺបណ្ឌិតគប្បីប្រាជ្ញាមុនជាងប្រយោជន៍ទាំងពួង ពាក្យដែលបានពោលមកនេះជាប្រស្នាទីមួយ ឈ្មោះថាទ្វារគឺថាជាប្រធាននៃឧបាយនឹងកិរិយា

បានន្ចូវអត្ថគឺប្រយោជន៍នឹងសេចក្ដីចំរើនក្នុងលោកនេះនឹងលោកខាងមុខដោយពិត ។

ប្រស្នាទីពីរ អធិប្បាយថា សីលដែលបុគ្គលប្រព្រឹត្តិរក្សាទូទៅគឺសីល ៥ ជាចរិតក្នុងលោក ជនទាំងឡាយដែលបានយកជាតិជាមនុស្សបានព្រោះតែរក្សាសីល ៥ ជាប់ពីជាតិមុនមកទើបកើតជាមនុស្សបានមានឥន្ទ្រិយ៍ពេញបរិបូណ៌ បើពុំបានរក្សាចរិតសីលរបស់ខ្លួនឲ្យជាប់ ហើយធ្វើឲ្យដាច់សីលឯណានីមួយក៏ពុំអាចរក្សាជាតិខ្លួនឲ្យគង់នៅជាមនុស្សបានឡើយ នឹងភ្លាត់ជាតិទៅជាសត្វតិរច្ឆានដោយពិត បើទុកជាបានកើតជាមនុស្សក៏គង់ជាមនុស្សមានឥន្ទ្រិយ៍ខ្វះខាតពុំពេញបរិបូណ៌ឡើយ បើបានរក្សាសីល ៥ នេះជាប់បរិបូណ៌ហើយទៀងតែនឹងបានកើតជាមនុស្សពិត រំលៀងជាតិពីមនុស្សនឹងបានកើតទៅជាទេវតាសោយទិព្វសម្បត្តិក្នុងឆកាមាវចរសួគ៌ ក៏អាស្រ័យនឹងសីល ៥ ដោយពិត ព្រោះហេតុនោះសីលទាំង ៥ នេះបានឈ្មោះថាទ្វារជាប្រធាននៃឧបាយនឹងកិរិយាបានន្ចូវអត្ថ

គឺប្រយោជន៍នឹងសេចក្ដីចំរើនក្នុងលោកនេះនឹងលោកខាងមុខដោយពិត ។

ឯទោសដែលបុគ្គលប្រព្រឹត្តធ្វើនូវវេរាទាំងប្រាំនេះ គឺ ១ សម្លាប់សត្វមានទោស បើកើតជាមនុស្សមានអាយុខ្លីមានឥន្ទ្រិយ៍ពុំបានពេញបរិបូណ៌ឡើយ, ២ លួចទ្រព្យគេមានទោស បើកើតជាមនុស្សមានសម្បត្តិទ្រព្យតិចជាអ្នកទាល់ក្រ មានទ្រព្យបន្តិចបន្តួចចោរលួចយកទៅ ទុកពុំបេះគង់, ៣ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយមានទោស បើកើតជាមនុស្សរមែងព្រាត់ប្រាសកូនប្រពន្ធ ព្រាត់ប្រាសស្វាមី ឬប្រែប្រួលខូចសតិបាត់ស្មារតីជាមនុស្សវង្វេងទៅក៏មាន, ៤ ពោលពាក្យកុហកមានទោស បើកើតទៅជាមនុស្សនិយាយទៅគ្មានបុគ្គលឯណាគេជឿឡើយ បើគេនិយាយមកនឹងខ្លួនវិញមិនដែលទៀងមានតែកុហកជានិច្ច, ៥ ផឹកនូវទឹកស្រវឹងគឺសុរានឹងមេរ័យមានទោស បើកើតជាមនុស្សពុំមានប្រាជ្ញាល្ងង់ខ្លៅ ឬប្រែទៅជាមនុស្សឆ្កួតវង្វេងប្រើការពុំបានដោយពិត ។

ឯអានិសង្សនៃបុគ្គលដែលបានវៀរលែងវេរាប្រាំនេះគឺៈ

១ វៀរលែងសម្លាប់សត្វ មានអានិសង្សកើតជាមនុស្សមានអាយុវែងមានឥន្ទ្រិយ៍ពេញបរិបូណ៌ មានរូបល្អពុំបានវិកលវិការឡើយ. ២ វៀរលែងលួចទ្រព្យគេ មានអានិសង្សកើតជាមនុស្សមានទ្រព្យសម្បត្តិច្រើនមិនប្រកបដោយអន្តរាយ, ៣ វៀរលែងមិនលួចប្រពន្ធកូនប្ដីគេដទៃ មានអានិសង្សកើតជាមនុស្សមូលកូនចៅមូលប្ដីប្រពន្ធពុំបានព្រាត់ប្រាសគ្នាឡើយ. ៤ វៀរ-លែងមិនពោលពាក្យកុហក មានអានិសង្សកើតជាមនុស្ស ជាទីសំឡាញ់ពេញចិត្តអ្នកដទៃនិយាយទៅគេតែងស្ដាប់យកមាំ បើគេនិយាយមកនឹងខ្លួនវិញ ពាក្យនោះទៀងទាត់ប្រាកដមែនពុំបានភូតកុហកឡើយ. ៥ វៀរលែងផឹកសុរានឹងមេរយ មានអានិសង្សកើតជាមនុស្សមានប្រាជ្ញាវៀងវៃ មានស្មារតីខ្ជាប់ខ្ជួនជាមនុស្សពុំបានឆ្កួតវង្វេងឡើយ ។

ប្រស្នាទីបី អធិប្បាយថា បុគ្គលអ្នកប្រដៅងាយ ប្រព្រឹត្តប្រតិបត្តិតាមពាក្យឱវាទនៃអ្នកប្រាជ្ញទាំងឡាយ ពុំបានប្រព្រឹត្តកន្លងពាក្យប្រដៅអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម អ្នកប្រដៅឲ្យប្រព្រឹត្តតាមយ៉ាងណាប្រព្រឹត្តតាមយ៉ាងនោះ អ្នក

ប្រឹងប្រាមឃាត់យ៉ាងណា ពុំបានប្រព្រឹត្តកន្លងយ៉ាងនោះ បានឈ្មោះថា ទ្វារជាប្រធាននៃឧបាយនឹងកិរិយាបាននូវអត្ថ គឺប្រយោជន៍នឹងសេចក្ដីចំរើនក្នុងលោកនេះនឹងលោកខាងមុខ ដោយពិត ។

ប្រស្នាទីបួន អធិប្បាយថា សូត្រឯអាស្រ័យនូវហេតុ គឺការដែលរៀនសូត្រចេះដឹងជាពហូសូត្រ ជាបុគ្គលមាន ឧស្សាហ៍ព្យាយាមស្ដាប់ពាក្យប្រដៅជាច្រើន ខំសង្កេតយក ហេតុពិតនឹងពុំពិតខុសនឹងត្រូវ អំពើឯណាហេតុឯណាដែល ពិតដែលមែន ខំព្យាយាមបំពេញអំពើនោះហេតុនោះឲ្យពេញ បរិបូណ៌ បានឈ្មោះថាទ្វារជាប្រធាននៃឧបាយនឹងកិរិយាបាន នូវអត្ថគឺប្រយោជន៍នឹងសេចក្ដីចំរើន ក្នុងលោកនេះនឹងលោក ខាងមុខដោយពិត ។

ប្រស្នាទីប្រាំ អធិប្បាយថា បុគ្គលអ្នកប្រព្រឹត្តវៀរលែង ទុច្ចរិតធម៌ទាំង ៣ យ៉ាងដែលជាអរិយមង្គល ( គឺអពមង្គល ) គឺប្រព្រឹត្តអាក្រក់លាមកដោយកាយ ១ ប្រព្រឹត្តអាក្រក់លាមក ដោយពាក្យសំដី ១ ប្រព្រឹត្តអាក្រក់លាមកដោយចិត្ត ១ វៀរ

លែងទុច្ចរិតធម៌ទាំង ៣ នេះឲ្យស្រឡះចេញ ហើយប្រព្រឹត្ត តាមនូវសុចរិតធម៌ទាំង ៣ យ៉ាងដែលជាមង្គលល្អ គឺប្រព្រឹត្ត សំអាតកាយឲ្យស្អាតម៉ត់ចត់ល្អ ១ ប្រព្រឹត្តសំអាតពាក្យសំដីឲ្យ ស្អាតម៉ត់ចត់ល្អ ១ ប្រព្រឹត្តសំអាតចិត្តឲ្យស្អាតម៉ត់ចត់ល្អ ១ បាន ឈ្មោះថាទ្វារជាប្រធាននៃឧបាយនឹងកិរិយាបាននូវអត្ថគឺប្រ- យោជន៍នឹងសេចក្តីចំរើនក្នុងលោកនេះ នឹងលោកខាងមុខ ដោយពិត ។

ប្រស្នាទីប្រាំមួយ អធិប្បាយថា បុគ្គលធ្វើចិត្តនៃខ្លួនពុំ បានឲ្យហែកទាបពុំឲ្យលុះទៅក្នុងអកុសលដឹកនាំ ហើយធ្វើចិត្ត នៃខ្លួនឲ្យជាចិត្តដ៏ឧត្តមដ៏ល្អិត មិនឲ្យកម្រើកញាប់ញ័រដោយ អកុសលដឹកនាំឡើយ បានឈ្មោះថាទ្វារជាប្រធាននៃឧបាយ នឹងកិរិយាបាននូវអត្ថគឺប្រយោជន៍នឹងសេចក្តីចំរើនក្នុងលោកនេះ នឹងលោកខាងមុខដោយពិត ។

រួមប្រស្នាធម៌ទាំង ៦ យ៉ាងបានឈ្មោះថាទ្វារដ៏ឧត្តមជាប្រ- ធាននៃឧបាយនឹងកិរិយាបាននូវខ្លឹមធម៌ ជាលោកិយនឹងលោ-

កុត្តរ គឺបណ្ឌិតពោលថាសេចក្ដីចំរើនសុខក្នុងបច្ចុប្បន្ននេះនឹងបរលោកដោយពិត ។

ព្រះបរមពោធិសត្វបានសម្ដែងនូវអត្ថស្សទ្វារបញ្ហា ទាំង ៦ យ៉ាងនេះដល់កុមារជាបុត្តរបស់ខ្លួនយ៉ាងនេះចប់ហើយ កុមារជាបុត្តនោះក៏បានដឹងនូវសេចក្ដីអធិប្បាយនៃទ្វារបញ្ហានោះជាក់ច្បាស់ ហើយខំគោរពប្រដិបត្តិប្រព្រឹត្តទៅក្នុងព្រះសាស្ដាធម៌ទាំង ៦ យ៉ាងនោះពុំបានដាច់ឡើយ ចាប់ដើមតាំងតែអំពីថ្ងៃនោះតទៅ ។

បំណែកខាងព្រះបរមពោធិសត្វ ព្រះអង្គបានរក្សាសីល ៥ សីលឧបោសថ ធ្វើនូវបុណ្យទាំងឡាយមានទានជាដើមដរាបដល់អស់ព្រះជន្មទៅ បានទៅបង្កើតក្នុងស្ថានសួគ៌ទេវលោកតាយសោយនូវទិព្វសម្បត្តិជាសុខក្សេមក្សាន្តទៅហោង ។

សម្ដេចព្រះបរមគ្រូសាស្ដាចារ្យជាម្ចាស់ ព្រះអង្គនាំព្រះធម្មទេសនានេះមកសម្ដែងចប់ស្រេចហើយ ទ្រង់ប្រជុំនូវជាតកថា

តទា បុត្តោ បច្ចុប្បន្នបុត្តោ មហាសេដ្ឋី បន អហមេវ

អធិប្បាយថា ម្នាលឧបាសក កុមារជាកូននៃមហាសេដ្ឋី

ក្នុងកាលនោះ វិលមកក្នុងបច្ចុប្បន្ននេះគឺកុមារជាកូនផ្នែអ្នកនេះឯង បំណែកឯមហាសេដ្ឋីវិលមកក្នុងកាលឥឡូវនេះមិនគឺអ្នកឯណាគឺអង្គព្រះតថាគតនេះឯង ។

សម្តែងរឿងអត្ថស្សទ្វារបញ្ហាមានក្នុងអត្ថស្សទ្វារជាតកចប់សេចក្តីជាសង្ខេបតែប៉ុណ្ណោះ ។ល៚

---

ឧប្បត្តិកថាសម្តែងឧប្បត្តិហេតុកើតឡើងខាងដើម ។

រឿងនេះមានក្នុងគម្ពីរលោកនេយ្យជាតកខ្សែ ១ សម្តែងសេចក្តីជាសង្ខេបថា ខណៈនោះព្រះថេរឈ្មោះអានន្ទដ៏មានអាយុបានទូលសួរហើយសរសើរពីអច្ឆរិយគុណព្រះសម្មាសម្ពុទ្ធជាម្ចាស់ថា ភន្តេ បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន សេចក្តីអស្ចារ្យមិនដែលបង្កើតមានហើយបង្កើតមានជាអស្ចារ្យពេកណាស់ ព្រះសម្មាសម្ពុទ្ធព្រះអង្គអាចដើម្បីធ្វើនូវជនទាំងឡាយជាមិច្ឆាទិដ្ឋិឲ្យជាបុគ្គលមានពុតកំណាចពុំមាន អាចធ្វើបុគ្គលជាមិច្ឆាទិដ្ឋិឲ្យត្រឡប់ទៅជាសម្មាទិដ្ឋិវិញបានដោយងាយ ។

សម្តេចព្រះលោកនាថដ៏ទ្រង់នូវព្រះភាគព្រះអង្គបានស្តាប់ពាក្យព្រះថេរឈ្មោះអានន្ទក្រាបទូលដូច្នោះហើយ ព្រះអង្គបាន

ពោលទៅនឹងព្រះថេរឈ្មោះអានន្ទថា អានន្ទ ម្នាលភិក្ខុឈ្មោះអានន្ទ សេចក្តីអស្ចារ្យនេះមិនទាន់ជាអស្ចារ្យប៉ុន្មានទេ ព្រោះវិស័យនេះជាវិស័យនៃព្រះពុទ្ធដែលបានត្រាស់ដឹងរួចហើយ ម្នាលភិក្ខុឈ្មោះអានន្ទកាលពីដើមដែលព្រះតថាគតមានញាណពុំទាន់បានចាស់ទំបរិបូណ៌នៅឡើយនោះ ហើយព្រះតថាគតអាចដើម្បីធ្វើនូវកិរិយាទូន្មានយក្សដែលមានចិត្តរឹងរឹងរូសហើយធ្វើឲ្យជាយក្សមានចិត្តស្លូតត្រង់ មិនឲ្យមានពុតកំណាចខូចកាចឡើយ នេះទើបបានឈ្មោះថាជាអស្ចារ្យមែនពិត ។

លំដាប់នោះព្រះអានន្ទថេរ បានក្រាបទូលទៅព្រះដ៏មានព្រះភាគថា "ភន្តេ បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គអាចដើម្បីធ្វើនូវយក្សទាំងឡាយដែលមានចិត្តរឹងរឹងរូស ឲ្យជាយក្សមានពុតកំណាចពុំមាន ក្នុងកាលឯណាព្រះអង្គ ។

សម្តេចព្រះមុនិន្ទជិនស្រីជាម្ចាស់ ទ្រង់បានសណ្តាប់ហើយលើកឡើងនូវព្រះហស្តខាងស្តាំ ចង្អុលបង្ហាញនូវអង្គុលីមាលត្ថេរហើយសម្តែងថា "ម្នាលភិក្ខុទាំងឡាយ អង្គុលីមាលត្ថេរដ៏មានអាយុនេះ កាលដើមឡើយបានបង្កើតជាយក្សកាចអាក្រក់

អាស្រ័យនៅដើមជ្រៃមួយ ក្នុងព្រៃស្ងាត់តែងចាប់មនុស្សស៊ីជាអាហារ តែថាៈស្ដេចព្រះវេស្សវណ្ណរាជបើកអំណាចឲ្យចាប់បានតែមនុស្សមិនបេះមលគរធម៌ចូលមកជ្រកក្រោមម្លប់ជ្រៃទើបចាប់ស៊ីជាអាហារបាន ។

ម្នាលភិក្ខុទាំងឡាយ កាលនោះមានស្ដេចអង្គព្រះអង្គទ្រង់ព្រះនាមព្រះបាទធនញ្ជយ្យកោរព្យរាជ សោយរាជសម្បត្តិក្នុងនគរឥន្ទបថ ព្រះអគ្គមហេសីទ្រង់ព្រះនាមអតុលាទេវី ជាចំបងលើសស្ត្រីទាំងឡាយ ១ ហ្មឺន ៦ ពាន់ ។ មានព្រាហ្មណ៍ម្នាក់ឈ្មោះទុដ្ឋិព្រាហ្មណ៍ជាបរោហិត អ្នកទូន្មានប្រៀនប្រដៅនូវអត្ថនឹងធម៌ដល់ស្ដេចនោះ មានសេនាបតី ១ ឈ្មោះខុដ្ឋសេនាបតី ។ ស្ដេចនោះប្រកបព្រមដោយសេនាប្រកបដោយអង្គ ៤ មានពពួកពលមួយអក្ខោភិនី មានស្រុកសួយធំទាំងឡាយសម្រាប់ឡើង ៤ ស្រុក គឺបាចិណគ្រាមទ្វារខាងកើត ១ ទក្ខិណគ្រាមទ្វារខាងត្បូង ១ បច្ឆិមគ្រាមទ្វារខាងលិច ១ ឧត្តគ្រាមទ្វារខាងជើង ១ សម្រាប់ឡើងសួយដល់ស្ដេចនោះ ក្នុងទ្វារនៃនគរទាំង ៤ ។

នគរនោះមានសេដ្ឋីធំ ៤ គឺធនញ្ជ័យសេដ្ឋីស្ថិតនៅក្នុងបាចិណគ្រាមខាងកើត វិសាលសេដ្ឋីស្ថិតនៅក្នុងទក្ខិណគ្រាមខាងត្បូង សុបិសេដ្ឋីស្ថិតនៅក្នុងបច្ឆិមគ្រាមខាងលិច សុទស្សនសេដ្ឋីស្ថិតនៅក្នុងឧត្តរគ្រាមខាងជើង សេដ្ឋីធំទាំង ៤ នោះសេដ្ឋីធំមួយ ៗ មានសេដ្ឋីតូច ៥០០ ជាបរិវារ តែងចាត់ការគ្រប់ជំពូកបំរើសេដ្ឋីធំទាំង ៤ នោះ ។

ឯប្រពន្ធនៃធនញ្ជ័យសេដ្ឋី ដែលជាអគ្គភរិយាដ៏ប្រសើរឈ្មោះនាងសុខុមាលី ជាសត្រីប្រកបដោយលក្ខណាល្អ ក្នុងវេលាបែកបុស្សសម័យ ព្រះបរមពោធិសត្វព្រះអង្គទ្រង់ច្យុតិចុះបាកតាវតឹំសភព ហើយចាប់បដិសន្ធិក្នុងផ្ទៃនៃនាងសុខមាលីជាភរិយានៃធនញ្ជ័យសេដ្ឋីនោះឯង ។

បំណែកខាងទេវបុត្តទាំងឡាយដទៃ ៥០០ ក៏ច្យុតិចុះមកចាប់បដិសន្ធិក្នុងផ្ទៃនៃសេដ្ឋីទាំង ៥០០ ជាបរិវារនៃធនញ្ជ័យសេដ្ឋីនោះ ។

ឯព្រះបាទធនញ្ជ័យកោរព្យរាជ ព្រះអង្គស្តេចផ្ទំលើទីដំណេកដ៏មានសិរីសួស្តី ហើយទ្រង់បានឃើញសុបិននិមិត្តជា

អស្ចារ្យ ឯសុបិននិមិត្តនោះឃើញហាក់ដូចព្រះអង្គ គឺបរិសទ្យ មានប្រមាណច្រើនចោមរោមជាបរិវារ ហើយព្រះអង្គគង់ពែន លើភ្នែនសីហាសនដ៏ប្រសើរ ក្នុងកាលនោះមានគំនរភ្លើងធំ មានប្រមាណប៉ុនដើមត្នោតតាំងឡើងក្នុងមុខៗព្រះលាន មានផ្កាក្រមុទធំមួយប្រមាណប៉ុនកង់ចក្រ ផុសឡើងក្នុងកណ្តាលនៃគំនរភ្លើងនោះ ហើយប្រព្រឹត្តកន្លងនូវគំនរនៃភ្លើងប៉ុនដើមត្នោតនោះ តាំងឡើងដោយកំពស់ ឯផ្កាក្រមុទនោះទៀតឱនបុះទៅកាន់រោងមហាវិនិច្ឆ័យនៃស្តេច ហើយទទួលព្រមនូវស្តេច ៗ ឡើងគង់លើផ្ទៃនៃផ្កាក្រមុទនោះ ហើយទ្រង់ពែននូវព្រះភ្នែន ហើយអណ្តាតភ្លើងនោះក៏រលត់ទៅ លុះអណ្តាតភ្លើងរលត់ទៅហើយ បំណែកឯផ្កាក្រមុទក៏ញាំងពន្លឺឱ្យភ្លឺរុងរឿងផ្សាយទៅក្នុងជម្ពូទ្វីបទាំងអស់ ។

ព្រះបរមក្សត្រិយ៍ បានឃើញសុបិននិមិត្តនេះហើយតើនឡើងហើយទ្រង់នូវសរីរកិច្ចអំពីព្រឹក ស្រេចហើយស្តេចយាងទៅគង់លើរាជបល្លង្ក ក្នុងកណ្តាលនៃពពួកអាមាត្យក្នុងបុងព្រះរាជរោងហើយស្តេចហៅបរោហិតចូលមកដល់ហើយ ទ្រង់

ញុំាងបរោហិតនោះឲ្យទំនាយនូវសុបិននិមិត្តនោះ តាមទំនង
នៃសុបិននិមិត្តដែលព្រះអង្គបានឃើញនោះមែនពិត ។

ឯព្រាហ្មណ៍បរោហិត បានព្យាករណ៍ទំនាយសុបិននិមិត្ត
នោះថ្វាយព្រះបរមក្សត្រិយ៍នោះថា បពិត្រមហារាជ ឯគំនរភ្លើង
ធំប្រាកដស្មើដោយអ្នកប្រាជ្ញរបស់ព្រះអង្គនោះឯង ឯផ្កាក្រមុំ
ប្រាកដស្មើដោយអ្នកប្រាជ្ញកើតឡើងហើយ អ្នកប្រាជ្ញនោះដ៏-
អាចដើម្បីរើឡើងនូវព្រះអង្គឲ្យរួច អំពីទីដែលមានពៀរដោយ
ពិត ឯភ្លឺគឺប្រាជ្ញានៃអ្នកប្រាជ្ញនោះ ដ៏អាចដើម្បីរើធ្វើនូវព្រះអង្គ
ហើយភ្លឺរុងរឿងផ្សាយទៅក្នុងជម្ពូទ្វីបទាំងអស់ពុំមានសល់ ។

ព្រះបាទធនញ្ជ័យកោរព្យរាជ ទ្រង់បានសណ្ដាប់ទំ-
នាយនោះហើយមានព្រះរាជឱង្ការសួរថា " ម្នាលបរោហិត
អ្នកប្រាជ្ញនោះកើតក្នុងទីកន្លែងឯណា ។

បរោហិតក្រាបទូលថា បពិត្រព្រះសម្មតិទេព អ្នកប្រាជ្ញ
នោះបានមកចាប់បដិសន្ធិក្នុងផ្ទៃមាតាជាគំរប់ ១០ ខែហើយ
នឹងប្រសូតិចេញអំពីផ្ទៃនៃមាតាក្នុងថ្ងៃនេះឯង ។

កាលនោះនាងសុខុមាលី ជាភរិយានៃធនញ្ជ័យសេដ្ឋី

បានទ្រង់គភ៌គ្រប់ ១០ ខែបរិបូណ៌ហើយ នាងបានប្រសូតិនូវបុត្តប្រុសហើយ ក្នុងវេលាបច្ចុសសម័យរស្មីព្រះអាទិត្យរះឡើងពេញកំឡាំង ខែចេត្របែកបដោយនក្ខត្តឫក្សដ៏ប្រសើរ ។

គ្រានោះប្រពន្ធនៃសេដ្ឋីជាបរិវារទាំង ៥០០ នោះ ក៏បានប្រសូតិនូវកូនប្រុសទាំងឡាយ ៥០០ ព្រមគ្នាទាំងអស់ក្នុងថ្ងៃនោះ ។

ឯស្គរនន្ទភេរីជ័យ នៃស្ដេចនោះក៏លាន់ឮសន្ធឹកដោយខ្លួនឯង ឥតមានអ្នកឯណាវាយឡើយ ឮផ្សាយទៅក្នុងដែនកុរុទាំងអស់ជាអស្ចារ្យ ក្នុងកាលដែលព្រះបរមពោធិសត្វប្រសូតិចេញពីផ្ទៃនៃមាតានោះ ។ ញាតិទាំងឡាយមានសេដ្ឋីជាដើមបានឲ្យឈ្មោះដល់កុមារនោះហៅថា ធនញ្ជ័យកុមារក្នុងថ្ងៃដែលជាទីកាន់យកនូវនាម ។

ព្រះបាទធនញ្ជ័យកោរព្យរាជ ទ្រង់បានឮសំឡេងស្គរនន្ទភេរីជ័យ លាន់ឮសន្ធឹកដោយខ្លួនឯងដូច្នោះហើយក៏មានព្រះហឫទ័យតក់ស្លុតញាប់ញ័រ ត្រាស់បង្គាប់ឲ្យហៅបរោហិតមកដល់ហើយ ទ្រង់សួរថា ម្នាលព្រាហ្មណ៍ ស្គរនន្ទភេរី

ជ័យញុំងសំឡេងឲ្យលាន់ឮសន្ធឹកដោយខ្លួនឯងយ៉ាងនេះ តើព្រោះហេតុអ្វី ។

ព្រាហ្មណ៍បុរោហិតក្រាបទូលថា បពិត្រមហារាជ ព្រះ-អង្គកុំខ្លាចឡើយពុំមានអន្តរាយអ្វីទេ អ្នកប្រាជ្ញបានកើតហើយក្នុងថ្ងៃនេះ ។

ស្តេចបានស្តាប់ពាក្យបុរោហិតទូលដូច្នោះហើយ ទ្រង់បាត់អាមាត្យទាំងឡាយ ៤ នាក់ ឲ្យចេញទៅតាមទ្វារព្រះនគរទាំង ៤ ស៊ើបសួររកកូនទាំងឡាយដែលកើតក្នុងថ្ងៃនោះ គ្រប់ទិសទាំង ៤ ។

អាមាត្យម្នាក់ចេញតាមទ្វារខាងកើត បានដឹងដំណឹងថាកូននៃធនញ្ជយ្យសេដ្ឋីកើតហើយ មួយអន្លើដោយទារកទាំង ៥០០ ដែលជាបរិវារក្នុងផ្ទះនោះ ហើយត្រឡប់មកវិញយកសេចក្តីក្រាបទូលដល់ព្រះបរមក្សត្រិយ៍នោះ ។

ព្រះបាទធនញ្ជយ្យកោរព្យរាជ ទ្រង់បានស្តាប់ពណ៌ដំ-មាននោះហើយ មានព្រះរាជហឫទ័យពេញទៅដោយបីតិសោម-នស្សជ្រះថ្លា ហើយស្តេចព្រះរាជទានប្រាក់ ១ ពាន់កហាបណ

ឲ្យជាថ្លៃទឹកដោះ មួយអន្លើដោយស្រីមេនំ ៤ នឹងគ្រឿងសំរាប់ប្រដាប់នូវកុមារដល់ធនញ្ជយ្យសេដ្ឋី ស្តេចព្រះរាជទានប្រាក់ ៥០០ កហាបណាមួយអន្លើដោយស្រីមេនំមួយ ៗ សំរាប់បិញ្ជិមនូវកុមារទាំងឡាយដ៏សេស ហើយតាំងព្រះរាជហឫទ័យទុកថា កុមារទាំងឡាយតែបំរើនវ័យធំឡើងហើយ អញនឹងសួរប្រស្នាល្បងប្រាជ្ញាមើល ៗ

អបរភាគេ កាលជាបំណែកខាងក្រោយ ធនញ្ជយ្យកុមារក៏បានចំរើនវ័យធំឡើង មួយអន្លើដោយកុមារទាំងឡាយជាបរិវារដ៏មានរូបឆោមលោមពណ៌ ជាអស្ចារ្យ ៗ

ឯកុមារទាំង ៥០០ នោះ ក៏តាមហោមរោមជាបរិវារនៃព្រះបរមពោធិសត្វនោះ អស់កាលជានិច្ចមែនពិត តែងរត់លេងជាមួយនឹងព្រះបរមពោធិសត្វនោះ ដ៏ជានិច្ចពុំដែលដាច់ឡើយ ៗ

សំដែងរឿង ឧប្បត្តិហេតុកើតឡើងជាខាងដើម នៃព្រះបរមពោធិសត្វ ទ្រង់ព្រះនាមធនញ្ជយ្យកុមារ ក៏បប់សេចក្តីដោយសង្ខេបតែប៉ុណ្ណោះឯង ៗ

ទី ៦– វិតក្កបញ្ហាប្រស្នាសួរពីសេចក្តីត្រិះរិះ

រឿងនេះតគ្នាមកសម្តែងសេចក្តីថា នាកាលកុមារទាំងឡាយមានធនញ្ជ័យកុមារជាដើមនោះ បំរើនវ័យធំឡើងបាន អាយុ ៧ ឆ្នាំបរិបូណ៌ហើយ ព្រះបាទធនញ្ជ័យកោរព្យរាជព្រះ-អង្គមានប្រាថ្នាដើម្បីល្បងមើលនូវកុមារទាំងឡាយនោះហើយ ស្តេចសួរទៅបរោហិតថា អាចរិយ ម្នាលអាចារ្យ កុមារទាំង-ឡាយនោះគឺយើងគប្បីល្បងមើលដោយភាវៈនៃកុមារទាំងឡាយនោះជាអ្នកប្រាជ្ញនឹងមិនមែនជាអ្នកប្រាជ្ញ ក្នុងកាលឥឡូវនេះ ។

ឯព្រាហ្មណ៍បរោហិតនោះ ក្រាបទូលថា បពិត្រមហារាជ បើព្រះអង្គចង់ជ្រាបនូវកុមារទាំងឡាយនោះ ព្រះអង្គគប្បីល្បងមើលឥឡូវនេះ ។

សម្តេចព្រះជនាធិបតីស្តេចសួរថា ម្នាលបរោហិត កុមាទាំងឡាយនោះ គឺយើងគប្បីល្បងមើល យ៉ាងដូចម្តេច ។

បរោហិតក្រាបទូលថា បពិត្រមហារាជបើដូច្នោះកុមារទាំងឡាយនោះ គឺយើងទាំងឡាយគប្បីសួរដោយកិរិយាល្បងមើលនូវវិតកគឺសេចក្តីត្រិះរិះគិតក្នុងគំនិត ។

ស្ដេចទ្រង់បានសណ្ដាប់ហើយ ទ្រង់ទទួលព្រមថាសាធុ ៗ ហើយបង្គាប់ឲ្យហៅអាមាត្យជាបណ្ឌិតមួយមក ហើយស្ដេចត្រាស់បង្គាប់ថា អ្នកឯងត្រូវចូលទៅកាន់សំណាក់នៃធនញ្ជយ្យសេដ្ឋីហើយត្រូវប្រជុំនូវកុមារក្មេងទាំងអស់នោះ សួរថាសេចក្ដីរីតកគំនិតអ្នកត្រិះរិះដូចម្ដេច ហើយត្រូវសួរធនញ្ជយ្យកុមារជាខាងក្រោយជាងកុមារទាំងពួង សេចក្ដីរីតកឯណា ៗ គឺកុមារទាំងឡាយឯណាបានពោលហើយ អ្នកឯងត្រូវសរសេរកត់ត្រា នូវពាក្យទាំងឡាយនៃកុមារទាំងឡាយ នោះហើយត្រូវយកមកប្រាប់ដល់អញ ។

អាមាត្យនោះបានទទួលព្រះរាជឱង្ការត្រាស់បង្គាប់ដូច្នោះហើយ លើកនូវអញ្ជលីដាក់លើសិរីសីថ្វាយបង្គំលាចេញទៅធនញ្ជយ្យសេដ្ឋីនូវក្នុងទីណាក៏ចូលទៅក្នុងទីនោះ បានប្រាប់នូវអាជ្ញាស្ដេចដល់សេដ្ឋីនោះ ហើយប្រជុំនូវសេដ្ឋីទាំង ៥០០ មួយអន្លើដោយទារកទាំងនោះក្នុងសណ្ឋាគារស្ថានរោងសម្រាប់ទទួលភ្ញៀវ ហើយសួរនូវកុមារទាំងអស់នោះ សួរកុមារមួយម្ដង ៗ ថា សេចក្ដីរីតកដូចម្ដេច នាកាលពាក្យពោលគឺកុមារ

ទាំងនោះ មិនអង់អាចនឹងឆ្លើយបាន ហើយត្រឡប់ពោលតប វិញ ថាសេចក្តីវិតកអ្វី ហើយសួរនូវធនញ្ជយកុមារ ជាខាង ក្រោយជាងកុមារទាំងពួងដូច្នេះ តាត ម្នាលបា សេចក្តីត្រិះ រិះដូចម្តេច ។

ធនញ្ជយកុមារនោះ ស្តាប់ហើយពោលថា សេចក្តី វិតករបស់ខ្ញុំមាន ៤ គឺ រណ្តៅ ១ ផ្លែត្រឡាច ១ ស្រីមានគភ៌ ១ ពាមចិញ្ចឹម ១ ។

អាមាត្យបានស្តាប់ហើយសួរថា កបិក្ខប៉ សេចក្តីបរិវិតក នូវរណ្តៅដោយប្រការដូចម្តេច ។

ព្រះបរមពោធិសត្វស្តាប់ហើយពោលថា ភោ ម្នាលអ្នក ដ៏ចំរើន ជនទាំងឡាយជីកនូវផ្ទៃផែនដីដ៏ស្មើដោយចបជីក ហើយធ្វើជារណ្តៅដ៏មានជម្រៅ ធ្វើនូវអាចដីទាំងអស់ឲ្យជាគំនរ ហើយលើកឡើងនូវសសរមួយដាំទៅក្នុងរណ្តៅ ហើយលប់ នូវអាចដីទាំងអស់ក្នុងរណ្តៅនោះ ហើយបុកបង្ហាប់ដោយអង្រែ អាចដីបានជាពុំពេញរណ្តៅព្រោះហេតុអ្វី សេចក្តីបរិវិតករបស់ ខ្ញុំនោះជាបឋមមែនពិត ។

អាមាត្យនោះក៏បានសរសើរកត់ត្រាពាក្យនេះសព្វគ្រប់ ហើយ សួរតទៅទៀតថាសេចក្ដីបរិវិតកនូវផ្លែត្រឡាចនោះ ដោយប្រការដូចម្ដេច ។

ព្រះបរមពោធិសត្វ ស្ដាប់ហើយពោលថា ភោ ម្នាលគ្នា យើងដ៏ចំរើន ផ្លែត្រឡាចធំប្រមាណប៉ុនជើងដាក់ទឹក អាស្រ័យ នូវវល្លិ៍ដើមតូចតែមួយហើយស្ថិតនូវបាន វល្លិ៍នោះពុំបានដាច់ ទៅមែនពិត ឯវល្លិ៍ត្រឡាចនោះបើទុកជាធំណាស់ប្រមាណប៉ុន ខ្សែបងគោប៉ុណ្ណោះ ហើយវល្លិ៍នោះពុំបានដាច់ទៅព្រោះហេតុអ្វី សេចក្ដីវិតករបស់ខ្ញុំនេះជាគំរប់ ២ មែនពិត ។

អាមាត្យនោះបានសរសើរកត់ត្រា ពាក្យនេះសព្វគ្រប់ ហើយសួរតទៅទៀតថា សេចក្ដីវិតកនូវសត្រីមានគភ៌នោះ ដោយប្រការដូចម្ដេច ។

ធនញ្ជេយ្យកុមារ ស្ដាប់ហើយពោលថា ភោ ម្នាលអ្នក ដ៏ចំរើន ឈ្មោះថាសត្រីតែងបរិភោគនូវបាយបំនួនអង្ករ ២ នាឡិ ក្នុងមួយថ្ងៃដោយប្រក្រតី ចាប់ដើមមកតាំងតែអំពីមាន គភ៌ឡើងដរាបដល់ប្រសូតិចេញ នៅតែបរិភោគបាយអស់អង្ករ

២ នាឡិ ៗ ដ៏ដែល សត្រីនោះមានគភ៌ចាស់ហើយ រិតតែមាន សេចក្ដីស្រេកឃ្លានច្រើនឡើងរឿយ ៗ ស៊ីបំណាំអាហារក៏ស៊ី រឿយ ៗ រក្សានូវកូនរក្សានូវបាយពុំបង្អៀតតឹងពោះ ដោយប្រ- ការដូចម្ដេច សេចក្ដីបរិវិតក់របស់ខ្ញុំជាគំរប់ ៣ មែនពិត ។

អាមាត្យនោះក៏បានសរសេរកត់ត្រា ពាក្យនោះសព្វគ្រប់ ហើយ សួរតទៅទៀតថា សេចក្ដីវិតកនូវរោមបិញ្ចើមដូច ម្ដេចហ្ន៎ ។

ព្រះបរមពោធិសត្វ បានស្ដាប់ហើយពោលថា ភោ ម្នាល អ្នកដ៏ចំរើន បំណែកឯរោមបិញ្ចើមនៃបុរសទាំងឡាយ គឺបុរស ទាំងឡាយនោះពុំដែលដកសោះ បំណែកឯពុកចង្កាទាំងឡាយ ក៏ដុះលូតឡើងវែងរហ័សមែនពិត ឯរោមបិញ្ចើមពុំបានដក កាត់កោរសោះហើយពុំបានដុះឡើងវែង ឯពុកចង្កាដកកាត់ កោររឿយ ៗ បេះតែដុះលូតវែងឡើងរហ័សព្រោះហេតុអ្វី សេចក្ដី វិតករបស់ខ្ញុំ ជាគំរប់ ៤ មែនពិត ។

អាមាត្យនោះបានស្ដាប់ហើយក៏សរសេរកត់ត្រា ពាក្យ

នោះសព្វគ្រប់ហើយ ក៏ចូលទៅកាន់រាជនិវេសនស្ថាន បានយកលិខិតសញ្ញានោះថ្វាយដល់ព្រះបរមក្សត្រិយ៍នោះ ។

ព្រះបាទធនញ្ជយ្យកោរព្យរាជ បានអាននូវសេចក្ដីសំបុត្រនោះហើយទ្រង់រំពឹងពិចារណាមើល មិនអាចដើម្បីដឹងនូវសេចក្ដីអធិប្បាយនៃប្រស្នានោះសោះ សម័យនោះស្ដេចក៏បានឲ្យជុំនុំនូវមហាជនទាំងឡាយ មានស្ដេចបំណុះនិងឧបរាជមហាមាត្យ សេនាបតី ព្រាហ្មណ៍បរោហិត និងអ្នកប្រាជ្ញជាដើមមកជួបជុំហើយ ស្ដេចត្រាស់បង្គាប់ឲ្យពិចារណាមើលនូវសេចក្ដីអធិប្បាយនៃប្រស្នាទាំងឡាយនោះ ។

មហាជនទាំងឡាយទាំងអស់នោះ ខំត្រិះរិះរំពឹងពិចារណានូវសេចក្ដីអធិប្បាយនៃប្រស្នានោះ ទាល់គំនិតគិតដូចម្ដេចក៏ពុំអាចដើម្បីដឹងនូវសេចក្ដីអធិប្បាយនៃប្រស្នានោះឡើយ ។

ចំណែកខាងបរោហិត ក្រាបទូលថា បពិត្រមហារាជប្រស្នានេះជាប្រស្នារបស់បុគ្គលឯណា ។

ស្ដេចក៏មានព្រះរាជឱង្ការប្រាប់ថា ប្រស្នានេះជាប្រស្នារបស់ធនញ្ជយ្យកុមារជាបុត្រនៃធនញ្ជយ្យសេដ្ឋី ។

បរោហិតស្តាប់ហើយក្រាបទូលថា បពិត្រមហារាជបុគ្គលឯណានីមួយ ក៏គង់តែពុំអាចដើម្បីដឹងនូវសេចក្តីអធិប្បាយនៃប្រស្នាទាំងឡាយនេះឡើយ ។

សម្តេចព្រះភូមិន្ទ្រាធិបតី ស្តេចបានស្តាប់ពាក្យបរោហិតនោះហើយ គ៏សេចក្តីក្រោធពិរោធគ្របសង្កត់ព្រះអង្គ ស្តេចទ្រង់ខ្ញាល់ជាខ្លាំង ហើយមានព្រះបន្ទូលថា ភោភ្តោ ម្នាលអ្នកទាំងឡាយដ៏បំរើន សេចក្តីវិតកនេះជាសេចក្តីវិតកនៃទារកតូចហាបើសេចក្តីវិតកនេះ ជាសេចក្តីវិតកនៃបុគ្គលទាំងឡាយចាស់ជាអ្នកឆ្លាសវៀងវៃទៅវា៉ អញក៏មិនថាអ្វីដែរ បុគ្គលដូចម្តេចគប្បីអាចដើម្បីដឹងនូវសេចក្តីអធិប្បាយនៃប្រស្នានេះ ចាប់ដើមតាំងតែអំពីថ្ងៃនេះទៅកិច្ចទាំងឡាយទាំងពួងគឺអ្នកទាំងឡាយគប្បីធ្វើតែក្នុងវេលាថ្ងៃ ដល់វេលាយប់គឺអ្នកទាំងឡាយគប្បីរំពឹងពិចារណាមើល នូវសេចក្តីអធិប្បាយនៃប្រស្នាទាំងឡាយនេះឲ្យដឹងសព្វគ្រប់ ។

អាមាត្យទាំងឡាយទាំងពួង ក៏បានទទួលព្រមតាមព្រះរាជឱង្ការហើយបបួលគ្នាប្រជុំ ត្រិះរិះគិតរំពឹងពិចារណារកនូវ

សេចក្តីអធិប្បាយនៃប្រស្នាទាំងឡាយនោះដរាបដល់ថ្ងៃជាគំរប់៧ ក៏ពុំអាចដើម្បីដឹងនូវសេចក្តីអធិប្បាយនៃប្រស្នានោះឡើយ លុះដល់ថ្ងៃជាគំរព ៨ វេលាបុព្វណ្ហសម័យពេលព្រឹកព្រហាម ព្រាហ្មណ៍បរោហិត បានក្រាបទូលព្រះបរមក្សត្រិយ៍ជូច្នេះថា បពិត្រមហារាជ ធនញ្ជយ្យកុមារទើបអាចដើម្បីដឹងនូវសេចក្តីអធិប្បាយនៃប្រស្នាទាំងឡាយនេះបាន ភាវនៃធនញ្ជយ្យកុមារនេះជាបណ្ឌិតក៏គឺព្រះអង្គគប្បីល្បងមើលក្នុងកាលឥឡូវនេះ ។

ព្រះបាទធនញ្ជយ្យកោរព្យរាជ ទ្រង់បានសណ្តាប់ហើយក៏បានទទួលព្រមតាមពាក្យបរោហិតនោះ ថាសាធុ ៗ ហើយស្តេចចាត់សេរីកាមាត្យឲ្យសរសេរសំបុត្របុតហ្មាយ រួចស្រេចស្តេចត្រាស់បង្គាប់ប្រើបុរសម្នាក់មានជើងលឿន ឲ្យនាំបុតហ្មាយនោះទៅឲ្យដល់សេដ្ឋី ឯសេចក្តីបុតហ្មាយនោះថា ត្រូវឲ្យធនញ្ជយ្យសេដ្ឋីនឹងសេដ្ឋីទាំង៥០០ នាំយកទារកទាំង៥០០ នឹងធនញ្ជយ្យកុមារ ចូលមកកាន់សំណាក់យើងកុំខានឡើយ ។

ឯបុរសនោះបានទទួលស្តាប់បុតហ្មាយនោះហើយ ក៏នាំ

យកទៅឲ្យសេដ្ឋីទាំងឡាយមានធនញ្ជ័យសេដ្ឋីជាដើមនោះ ។

សេដ្ឋីទាំងឡាយមានធនញ្ជ័យជាដើម បានអានសេចក្ដីបុតហ្នាយនោះដឹងសេចក្ដីសព្វគ្រប់ហើយ បានប្រជុំព្រមនូវធនញ្ជ័យកុមារមួយអន្លើដោយទារកទាំង ៥០០ មកជួបជុំហើយ ក៏បានប្រាប់នូវពណ៌ដមាននេះដោយសព្វគ្រប់ ។

ឯធនញ្ជ័យកុមារ បានស្ដាប់នូវពណ៌ដមាននោះហើយ ពោលទៅនឹងបុរសនោះថា ខ្ញុំពុំអាចដើម្បីនឹងទៅក្នុងថ្ងៃនេះឡើយ ព្រោះហេតុដូច្នេះខ្ញុំនឹងទៅក្នុងថ្ងៃស្អែក ។

ឯបាទមូលិកបុរស មានជើងលឿននោះបានស្ដាប់ពាក្យនោះហើយ ក៏ត្រឡប់វិលវិញយកសេចក្ដីក្រាបបង្គំទូលដល់ស្ដេចតាមន័យនោះមែនពិត ។

ព្រះបាទធនញ្ជ័យកោរព្យរាជ ទ្រង់បានសណ្ដាប់ពាក្យនោះហើយ ស្ដេចឲ្យឃោស្នាប្រាប់ដល់សេនាបតី បរោហិតនឹងព្រាហ្មណ៍ជាអ្នកប្រាជ្ញទាំងឡាយថា ក្នុងថ្ងៃស្អែកនោះត្រូវអ្នកទាំងឡាយប្រជុំគ្នាព្រមក្នុងមហាតលស្ថានឲ្យមកព្រមព្រៀងគ្នា ខានពុំបានឡើយ ។

គ្រានោះសេដ្ឋីទាំងឡាយទាំងពួង ចាត់ចែងនូវគ្រឿងបណ្ណាការទាំងឡាយ សេដ្ឋីពួកខ្លះកាន់យកកែវវេទូរិយ៍ សេដ្ឋីពួកខ្លះកាន់យកកែវ ៧ ប្រការ សេដ្ឋីពួកខ្លះកាន់យកកែវមណីនឹងកែវមុក្តា សេដ្ឋីពួកខ្លះកាន់យកកែវឥន្ទនិល សេដ្ឋីពួកខ្លះកាន់យកកែវផលិក ធ្វើឲ្យជាគ្រឿងបណ្ណាការមានដំឡៃព្រើនបញ្ជូនឲ្យទៅធនញ្ជ័យសេដ្ឋី ។

បំណែកឯធនញ្ជ័យសេដ្ឋី ក៏បានសួរធនញ្ជ័យកុមារដូច្នេះថា តាត ម្នាលកូន គ្រឿងបណ្ណាការទាំងអស់នេះគ្រឿងបណ្ណាការដូចម្តេច ជាទីគាប់ចិត្តអ្នក ។

ឯធនញ្ជ័យកុមារ ក៏បានពោលទៅនឹងសេដ្ឋីវិញថា បពិត្រសេដ្ឋី កិរិយាធ្វើនូវកែវមណីជោតិមានប្រមាណប៉ុនផ្លែត្នោតឲ្យជាគ្រឿងបណ្ណាការដល់ខ្ញុំទើបគួរ ហើយបញ្ជូននូវគ្រឿងបណ្ណាការនោះត្រឡប់ទៅវិញ ពុំបានទទួលយកឡើយ ។

កាលនោះធនញ្ជ័យសេដ្ឋីមានសេដ្ឋីទាំងពួងជាបរិវារចូលទៅកាន់រាជនិវេសនស្ថាន ឡើងកាន់បុងព្រះរាជវាំងហើយដំ-

កល់នូវអញ្ចាលីលើសិរិសី ថ្វាយបង្គំសម្ដេចព្រះទីបទិន្នាធិបតីជាក្សត្រិយ៍ប្រសើរ ហើយអង្គុយនៅក្នុងទីដ៏សមគួរមួយ ។

ព្រះបរមក្សត្រិយ៍ បានឃើញគហបតីទាំងឡាយមកជួបជុំដូច្នោះហើយ ស្ដេចក៏ដល់នូវសេចក្ដីសោមនស្សជ្រះថ្លាក្នុងព្រះរាជហឫទ័យ សួរថាម្នាលគហបតីទាំងឡាយដ៏បំរើន ធនញ្ជយកុមារនឹងមកក្នុងកាលឯណា ។

ធនញ្ជយសេដ្ឋី បានស្ដាប់ព្រះរាជឱង្ការសួរដូច្នោះហើយក្រាបទូលថា បពិត្រមហារាជ ធនញ្ជយកុមារនឹងមកក្នុងកាលឥឡូវនេះពុំខានឡើយ ។

គ្រានោះធនញ្ជយកុមារគឺកូនសេដ្ឋីទាំង ៥០០ ចោមរោមជាបរិវារមានសម្ពត់មានពណ៌សបានស្លៀកដណ្ដប់ហើយដៃកាន់នូវប្រទីបមានដងជាវិការនៃមាស ប្រាថ្នាដើម្បីធ្វើឲ្យជាគ្រឿងបណ្ណាការនោះ ហើយបានទៅដល់ព្រះរាជត្រកូលឡើងកាន់មហាតលស្ថានដ៏ប្រដាប់ដោយប្រពៃ ហើយញ៉ាំងកុមារទាំងឡាយនោះឲ្យដំកល់ចុះនូវប្រទីបទាំងឡាយនោះដោយលំដាប់

នឹងលំដាប់ហើយថ្វាយបង្គំស្ដេចដោយគោរព ស្រេចហើយ អង្គុយព្រមគ្នាក្នុងទីសមគួរមួយតាមលំដាប់គ្នា ។

រាជបុរសទាំងឡាយទាំងអស់នោះ មានសេនាបតី ព្រាហ្មណ៍នឹងបរោហិតជាដើម បានឃើញនូវរូបសិរីនៃព្រះបរម-ពោធិសត្វនោះហើយ មានចិត្តភិរម្យរីករាយស្រួលស្រឡាញ់ស្ងើចសរសើរប្រាប់គ្នាទៅវិញទៅមក ។

ព្រះបាទធនញ្ជយ្យកោរព្យរាជ បានទតឃើញព្រះបរម-ពោធិសត្វនោះហើយ ស្ដេចដល់នូវសេចក្ដីសោមនស្សជ្រះថ្លា មានព្រះរាជឱង្ការសួរថា ធនញ្ជយ្យ ម្នាលកុមារឈ្មោះធ-នញ្ជយ្យប្រទីបដែលមានដងទាំងឡាយនេះ ដូចម្ដេចហ្ន៎ ។

ធនញ្ជយ្យកុមារនោះ បានបង្អោនទៅនូវអញ្ជលីហើយ ក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំកាន់យកនូវប្រទីបទាំងឡាយនេះដើម្បីឲ្យជាគ្រឿងបណ្ណាការដល់ព្រះអង្គ ដើម្បីប្រ-យោជន៍ដល់អណ្ដាតភ្លើង ។

មហាជនទាំងឡាយទាំងអស់នោះ ស្ដាប់ហើយអស់ សម្ដើបសើចបំអកឡុកឡឺយដោយសំឡេងអឺកធឹករឹករ ដោយ

គំនិតគិតថាប្រទីបមានដឹងទាំងឡាយនេះ មិនមានឧបការ ប៉ុន្មានទេ មិនជាថ្លៃថ្នូរប៉ុន្មានទេ ។

ស្ដេចក៏បានសួរតទៅទៀតថា ប្រយោជន៍អ្វីដោយប្រទីប។

ធនញ្ជ័យកុមារនោះ ក្រាបទូលថា បពិត្រព្រះសម្មតិទេព ឯអណ្ដាតភ្លើងប្រទីបនេះមានឧបការច្រើនណាស់ ។

ព្រះបាទធនញ្ជ័យកោរព្យរាជ សួរតទៅទៀតថា ម្នាល ធនញ្ជ័យកុមារ ពាក្យអ្នកពោលថាអណ្ដាតភ្លើងប្រទីបមាន ឧបការច្រើនណាស់ នោះតើមានឧបការដូចម្ដេច ។

ព្រះបរមពោធិសត្វ ក៏បានក្រាបទូលអធិប្បាយថា ទេវ បពិត្រព្រះសម្មតិទេព ធម្មតាឯភ្លើងទាំងអស់ ជាគ្រឿងសំរេច ប្រយោជន៍ទាំងពួង ដោយកិរិយាបំអិននូវបាយនឹងត្រីសាច់ខ្លះ ដោយកិរិយាបំអិននូវទឹកក្ដៅខ្លះ ដើម្បីប្រយោជន៍ដល់កិរិយា បន្ទោបង់នូវរោគបាក់ដោតដោយសេចក្ដីត្រជាក់រងាខ្លះ ម្យ៉ាង វិញទៀត អណ្ដាតភ្លើងប្រទីបនោះ មានប្រមាណតិចដោយ វិសេស ព្រោះហេតុដូច្នោះ បានជាមហាជនទាំងឡាយទាំង អស់នោះមើលងាយស្មើបបំអកក្រៃពេក បពិត្រព្រះសម្មតិទេព

ឈ្មោះថាភ្លើងនេះ តែងមានឧបការដល់កិច្ចទាំងឡាយមាន
កិរិយាចំអិននូវបាយជាដើម តែបើភ្លើងតិចតួចពេក ក៏បង្កើតជា
ទីមើលងាយដល់ជនទាំងឡាយនោះដោយពិត មានសេចក្ដី
ឧបមាយ៉ាងណា ចំណែកឯបុរសដែលដល់នូវសេចក្ដីទាល់ក្រ
តែងបង្កើតជាទីមើលងាយដល់មនុស្សទាំងឡាយនោះ មាន
សេចក្ដីឧបមាយ៉ាងនោះដែរ បពិត្រព្រះសម្មតិទេព ភ្លើងនេះ
កាលបើឆេះនូវផ្ទះក្ដីនូវព្រៃក្ដី ហើយធ្វើនូវសន្ធឹកនៃអណ្ដាតភ្លើង
នឹងផ្សែងភ្លើងហើយ ក៏អាចបង្កើតជាទីខ្លាចតក់ស្លុតដល់មនុស្ស
ទាំងឡាយនោះមានសេចក្ដីឧបមាយ៉ាងណា មនុស្សដែលមាន
ទ្រព្យមានសម្បត្តិច្រើន ដល់នូវយសសក្ដិនឹងកិត្តិសព្ទគេសរសើរ
ហើយ ក៏បង្កើតជាទីតក់ស្លុតដល់មនុស្សទាំងឡាយនោះក្រៃ
ពេក មានសេចក្ដីឧបមាយ៉ាងនោះដែរ ម្យ៉ាងវិញទៀត ឯ
អណ្ដាតភ្លើង តិចក្ដី ច្រើនក្ដី ក៏ទុកថាជាមានដោយចំណែកមួយ
ដោយប្រការឯណា ឯមនុស្សជាអ្នកកំសត់ក្ដី ជាអ្នកស្ដុកស្ដម្ភក្ដី
ជាអ្នកមានយសសក្ដិតូចក្ដី ជាអ្នកមានយសសក្ដិធំក្ដី ក៏ទុកថា
មានដោយចំណែកមួយ ដោយប្រការដូច្នោះដែរ ព្រះបរមពោ-

ធិសត្វអធិប្បាយដូច្នេះហើយ ក៏ពោលជាបទព្រះគាថាដូច្នេះថា

អសហាយោ សមត្ថោបិ តេជសីពីភវិស្សតិ
និវាតេជលិតោអគ្គិ សយមេវោបសមតិ

អធិប្បាយថា ៗ បើបុគ្គលពុំមានមិត្តសំឡាញ់ហើយ ទុកជាមានតេជះអង់អាចហើយ នឹងធ្វើនូវការអ្វីជាធំបាន ធម្មតាឯភ្លើងបើឆេះក្នុងទីពុំមានខ្យល់ហើយ នឹងរលត់សូន្យទៅវិញដោយខ្លួនឯង ឆេះកាត់ច្រើនឡើងពុំបានដោយពិត ព្រះគាថាដែលព្រះបរមពោធិសត្វទ្រង់សម្តែងនេះមានច្រើន តែពុំបានសម្តែងទេ ព្រោះសេចក្តីប្រហែល ៗ គ្នា លុះដល់ព្រះបរមពោធិសត្វអធិប្បាយរឿងប្រស្នាសួរអំពីអណ្តាតភ្លើង ជាសេចក្តីសង្ខេបប៉ុណ្ណោះ ។

សម្តេចព្រះនរិន្ទ្រាធិបតី ស្តេចបានស្តាប់នូវសេចក្តីអធិប្បាយនៃប្រស្នានេះហើយ ស្តេចក៏មានសេចក្តីសោមនស្សជ្រះថ្លា សួរទៅព្រះបរមពោធិសត្វនោះតទៅទៀតថា តាត ម្នាលបាធនញ្ជេយ្យកុមារ សេចក្តីវិតកទាំង ៤ យ៉ាងក៏សេចក្តីវិតក

ទាំង ៤ នោះដូចម្តេច អ្នកត្រូវសម្តែងធ្វើឲ្យជាក់ច្បាស់នូវសេចក្តីអធិប្បាយនៃវិតកទាំង ៤ យ៉ាងនោះមកមើល ។

ព្រះបរមពោធិសត្វ បានស្តាប់ហើយក្រាបទូលព្រះបរម-ក្សត្រិយ៍ថា ទេវ បពិត្រព្រះសម្មតិទេព ខ្ញុំជាទារកក្មេងនឹងអាចដឹងនូវសេចក្តីអធិប្បាយនៃប្រស្នាទាំងឡាយនេះ គឺសេវកា-មាត្យទាំងឡាយមានសេនាបតី បរោហិតនឹងរាជបណ្ឌិតជាដើមរបស់ព្រះអង្គគប្បីដឹង បំណែកខាងធុជបរោហិតនេះ ក៏ជាបុគ្គលចាស់ជាងខ្ញុំដ៏ឆ្លាតវៀងវៃគួរតែអធិប្បាយថ្វាយព្រះអង្គ បំណែកខាងខ្ញុំបានជាពោលយ៉ាងនេះព្រោះហេតុអ្វី ឯវិតកបញ្ហានេះជាការបន្តិចបន្តួច គឺទារកក្មេងបានពិចារណារំពឹងមើលហើយពុំទាន់មាន ម្យ៉ាងវិញទៀតពាក្យពោលដែលមានពីរោះក្នុងបទដើម នឹងបទកណ្តាលនឹងបទចុង គឺបុគ្គលអ្នកពោលនូវសេចក្តីអធិប្បាយត្រូវការដល់គ្រែនេះ ទើបសម្តែងដោយប្រពៃបាន ព្រោះហេតុដូច្នោះពាក្យនេះជាពាក្យគឺខ្ញុំគប្បីអង្វរនូវព្រះអង្គដោយពិត ។

បពិត្រព្រះសម្មតិទេព កិរិយាសម្តែងនូវសេចក្តីអធិប្បាយ

នៃប្រស្នាទាំងឡាយនេះក្នុងទីនេះដូចម្ដេចជាទីគាប់ចិត្តដល់ខ្ញុំ ទើបខ្ញុំនឹងសម្ដែងបានដោយពិត ។

ឯព្រះបាទធនញ្ជយ្យកោរព្យរាជ ទ្រង់ព្រះសណ្ដាប់ ហើយស្ដេចបង្គាប់អាមាត្យឲ្យរៀបចំក្រាលនូវធម្មាសន លើបល្លង្ក៍ប្រសើរមានស្វេត្រឆត្តគឺពុគ្គលពើកឡើងព្រមហើយ ៗ ស្ដេចញាំងព្រះបរមពោធិសត្វនោះ ឲ្យអង្គុយនៅលើគ្រែធម្មាសននោះ ។

ព្រះបរមពោធិសត្វនោះ ឡើងគង់ពែនភ្នែនលើធម្មាសន ហើយក្រាបទូលស្ដេចថា បពិត្រព្រះសម្មតិទេព បណ្ដាសេចក្ដីវិតកទាំងឡាយនោះ សេចក្ដីវិតកជាបឋមគឺព្រះអង្គគប្បីដឹងច្បាស់ដោយប្រពៃ ខ្ញុំនឹងសម្ដែងអធិប្បាយតាមលំដាប់នឹងលំដាប់ ។

ព្រះបរមក្សត្រិយ៍ ព្រះអង្គដល់នូវសេចក្ដីសោមនស្សហើយ ពោលថាអ្នកត្រូវសម្ដែងនូវកួបវិតកជាបឋមមែនពិត តាមលំដាប់នឹងលំដាប់រៀបរៀងគ្នាតទៅ ។

កាលនោះព្រះមហាសត្ត ព្រះអង្គពុំញាប់ញ័រដំកៀវក្លាបី-

ដូចជាកេសរសីហ៍ប្រសើរ ទ្រង់ប្រកាសសម្តែងនូវកូបរិតក បញ្ហាដូច្នេះថា ទេវ បពិត្រព្រះសម្មតិទេព ភូមិប្រទេសឯណា ដ៏មានផ្ទៃស្មើល្អ បុគ្គលជីកនូវភូមិប្រទេសនោះហើយរើឡើងនូវ អាច់ដីធ្វើឲ្យជាគំនរ ធ្វើឲ្យជារណ្ដៅឲ្យមានជម្រៅ ហើយដាក់បុះ នូវសសរក្នុងរណ្ដៅនោះ ហើយលប់នូវអាច់ដីទាំងអស់នោះរុក បង្ហាប់ដោយអង្រៃ បុគ្គលនោះប្រមូលមកនូវអាច់ដីទាំងអស់ នោះ ដើម្បីញុំាងរណ្ដៅឲ្យពេញស្មើ រណ្ដៅនោះក៏ពុំបានពេញ ដោយអាច់ដីទាំងឡាយនោះឡើយ បុគ្គលនោះទំប្រមូលមកនូវ អាច់ដីទាំងឡាយដ៏ទៃទៀត ដើម្បីញុំាងរណ្ដៅឲ្យពេញស្មើ ឯ បុគ្គលតែងបុកបង្ហាប់នូវរណ្ដៅដោយអង្រៃដោយច្រើន ព្រោះ ហេតុឯណាព្រោះហេតុនោះ បុគ្គលដែលនឹងញុំាងរណ្ដៅឲ្យ ពេញបានដោយអាច់ដីទាំងឡាយ ២ ចំណែកផង អាច់ដីទាំង ឡាយដទៃផង អាច់ដីទាំងឡាយដទៃផងឧបមាដូចជាពួកពល ៧ ពីរដង (គឺ ១៤ អ្នក) នៃនាយកងធំម្នាក់របស់ព្រះអង្គ ជាបើ សេនាបតិម្នាក់បែកនូវពួកពល ៧ ពីរដងនោះឲ្យបំរើនឡើង ហើយដឹកល់ទុកក្នុងសំណាក់នៃនាយកងធំ ៧ ពីរដង ក្នុងកាល

ឯណា នាយកងធំទាំងឡាយ ៣ ពីរដងមានប្រាកដក្នុងកាលនោះ តាំងពីកាលនោះមករាជកិច្ចទាំងឡាយគឺបុគ្គលធ្វើឲ្យច្រើនដោយភ័យនឹងពិន័យ ព្រោះហេតុដូច្នោះរាជកិច្ចទាំងឡាយមានប្រមាណតិចទេ តែបើដូចជាមានប្រមាណច្រើនណាស់ ថាបើសេនាទាំងឡាយបានទៅច្បាំងដណ្តើមយកផែនដីទៃបាន ហើយបានថ្វាយដល់ព្រះអង្គ ដើម្បីតែនឹងញាំងព្រះរាជហឫទ័យព្រះអង្គឲ្យពេញប៉ុណ្ណោះ បុគ្គលជីករណ្តៅយ៉ាងណាសេនាបតីកែណ្ឌនូវពួកនៃពល ៣ ពីរដងយ៉ាងនោះដែរ គឺនរអាប់ដីទាំងឡាយមានយ៉ាងណា ពួកពលទាំងឡាយមានយ៉ាងនោះដែរ បុគ្គលអ្នកបុកបង្ហាប់រណ្តៅមានយ៉ាងណា ពិន័យរបស់ស្តេចមានយ៉ាងនោះដែរ ព្រះបរមពោធិសត្វ សម្តែងអធិប្បាយ កូបវិតក្កបញ្ហាជាសេចក្តីសង្ខេបយ៉ាងនេះ ។

ព្រះបរមពោធិសត្វ ក្រាបទូលតទៅទៀតថា បពិត្រមហារាជ ឯផ្លែត្រឡាចយ៉ាងធំប្រមាណប៉ុនផើងអាស្រ័យនូវទងតែមួយស្ថិតទៅបាន ដ៏ជាប់ស្ថិតស្ថេរទៅពុំបានជាប់ធ្លាក់ចុះឡើយ ឯវល្លិ៍ដើមត្រឡាចបេញផ្លែទាំងឡាយនោះ ក៏វិនាស

អស់ទៅពុំមានសល់ឡើយ ផ្លែត្រឡាចឧបមាដូចជាគេរ ព្រិ-សីមាប្រាកដស្មើដោយសម្បកនៃត្រឡាចនោះ ពូជនៃត្រឡាចនោះប្រាកដស្មើដោយដែនទាំងអស់ ភោគសម្បត្តិទាំងឡាយមានសេចក្តីឧបមាប្រាកដស្មើដោយសាច់នៃត្រឡាច ស្រីរបាំទាំងឡាយប្រាកដស្មើដោយទងនៃត្រឡាច បំណែកឯវល្លិ៍ដើមត្រឡាច ប្រាកដស្មើដោយស្តេចគ្រងរាជសម្បត្តិមែនពិត ស្តេចដែលបានសោយរាជសម្បត្តិវិនាសអន្តរាយបាត់ទៅក្នុងកាលឯ-ណា ព្រិសីមានឹងដែននឹងភោគសម្បត្តិ នឹងអង្គនៃសេនាដ៏ក្លៀវក្លាទាំងឡាយ នឹងវិនាសអន្តរាយអស់ទៅក្នុងកាលនោះ ព្រះបរមពោធិសត្វ សម្តែងដូច្នេះហើយ ក៏ពោលដោយបទព្រះគាថាដូច្នេះថា ។

ធនវាសោតិយោរាជា នទីវេដ្ឋោតគ្គេរិច
បញ្ចាយត្ថនវិជ្ជន្តេ នតត្ថទិវិសំវិសេ

អធិប្បាយថា បុគ្គលទាំងឡាយ ៥ គឺបុគ្គលអ្នកមានសម្បត្តិទ្រព្យច្រើន ១ ព្រាហ្មណ៍ជាអ្នកប្រាជ្ញឬបុគ្គលអ្នកមានប្រាជ្ញាឆ្លៀវឆ្លាសវៀងវៃ ១ ស្តេចគ្រងរាជសម្បត្តិប្រកបដោយ

ទុសពិធរាជធម៌ ១ ស្ទឹងទន្លេមានផ្លូវបេញចូលទូកនាវាជានិច្ច ១ គ្រូពេទ្យអ្នកបេះថ្នាំបាំរក្សាជម្ងឺពូកែធុតឆាប់ ១ បុគ្គលទាំង ៥ នេះកើតមានក្នុងនគរនោះ ៗ នឹងប្តីមចម្រើនរុងរឿង បីដូចជាព្រះអាទិត្យនឹងព្រះចន្ទមានវង់ពេញមែនពិត ឯសភាវទាំង ៥ នេះបើពុំមានក្នុងនគរឯណាហើយ បុគ្គលមិនគប្បីនៅក្នុងនគរនោះ តែមួយថ្ងៃក៏មិនគប្បីនៅឡើយសេចក្តីអធិប្បាយនៃកុម្ភណ្ឌដលនៃវិតក្កបញ្ហាមានដោយប្រការយ៉ាងនេះឯង ។

បពិត្រមហារាជ សេចក្តីវិតកនូវស្ត្រីមានគភ៌នោះ គឺស្ត្រីតែងបរិភោគនូវបាយក្នុងមួយថ្ងៃ ៗ អស់អង្ករ ២ នាឡិជាប្រក្រតី ដល់ស្ត្រីនោះមានគភ៌ហើយ ក៏នៅតែបរិភោគពេញកំណត់ជាប្រក្រតីរាល់ ៗ ថ្ងៃក្នុងកាលឯណា ស្ត្រីនោះមានគភ៌កាន់តែធំបាស់ឡើង សេចក្តីស្រេកឃ្លានរាន់តែកើតច្រើនឡើង តែងបរិភោគអាហាររឿយ ៗ ក្នុងកាលនោះ នាកាលស្ត្រីនោះជិតនឹងប្រសូតិកូនហើយតេជោធាតុក៏រិតតែក្តៅខ្លាំងឡើងដុតនូវអាហារ ព្រោះហេតុឯណាហេតុនោះ អាហារដែល

សត្រីនោះបរិភោគហើយ អាចរព្ឋយឆាប់មួយរំពេច សេចក្ដីស្រែកឃ្លានក៏បំរើនឡើងដល់សត្រីនោះដោយពិត គភ៌មានសេចក្ដីឧបមាយ៉ាងណា ធាតុដែលកើតជាប្រក្រតីមានសេចក្ដីឧបមាយ៉ាងណា សួយទាំងឡាយដែលកើតឡើងជាប្រក្រតីក៏មានសេចក្ដីឧបមាយ៉ាងនោះដែរ គភ៌ដែលបំរើនធំឡើងមានសេចក្ដីឧបមាយ៉ាងណា សួយទាំងឡាយដែលបំរើនឡើងជាប្រក្រតីមានសេចក្ដីឧបមាយ៉ាងនោះដែរ ឯវិមេរិគព្ភិត្តិវិតក្កត្ថោ សេចក្ដីអធិប្បាយនៃសេចក្ដីវិតកនូវសត្រីមានគភ៌ដោយប្រការដូច្នេះមែនពិត ។

បពិត្រមហារាជ សេចក្ដីវិតកនូវរោមបិញ្ចើមនោះ អធិប្បាយថា បំណែកឯរោមបិញ្ចើមទាំងឡាយ ពុំបានបំរើនដុះឡើងវែងមែនពិត ទុកជាគឺបុគ្គលដកក្ដីក៏គង់ដុះឡើងតាមកំណត់ពុំបានវែងមែនពិត បំណែកឯពុកមាត់ ពុកចង្កាគឺបុគ្គលដកក្ដីកាត់ក្ដីក៏គង់ដុះឡើងទៀត ដុះឡើងឆាប់ក្រៃលែងមែនពិត រោមបិញ្ចើមទាំងឡាយមានសេចក្ដីឧបមាយ៉ាងណា ទំរាជការចាស់ក៏មានសេចក្ដីឧបមាយ៉ាងនោះដែរ មួយទៀតរោមបិញ្ចើម

ទាំងឡាយគឺបុគ្គលពុំបានកាត់ពុំបានដកមែនពិត ព្រោះហេតុឯណាហេតុនោះបានជាពោមបិញ្ចើមដុះឡើងតែឋាកំណត់ពុំបានដុះឡើងវែងមែនពិត ឯខ្ញុំរាជការទុកជាដល់នូវសេចក្ដីស្និទស្នាលនឹងស្ដេចដោយអំណាចនៃខ្លួនជាខ្ញុំរាជការចាស់ ក៏គង់ពុំមានសេចក្ដីមើលងាយនូវអ្នកដទៃឡើយ ពុំបានធ្វើនូវភ័យលុះក្នុងអំណាចនៃឆន្ទាគតិដល់អ្នកដទៃដោយពិត ម្យ៉ាងវិញទៀតខ្ញុំរាជការចាស់នោះសោយនូវផលបុណ្យតែដោយឧបនិស្ស័យនៃបុណ្យចាស់មុន ទុកជាមានលាភដ៏ប្រសើរនឹងយសសក្ដិ៍ដ៏ប្រសើរ ក៏គង់មិនបំរើនអ្នូតទៅទៀតដោយពិត បំណែកឯពុកមាត់ពុកចង្កាគឺបុគ្គលកាត់ដករឿយ ៗ ព្រោះហេតុឯណាហេតុនោះបានជាពុកមាត់ពុកចង្កាដុះលូតលាស់វែងឡើងមែនពិត ឯខ្ញុំរាជការថ្មីក្មេង ៗ ប្រកបដោយសេចក្ដីស្និទស្នាលដោយអំណាចនៃខ្លួនជាខ្ញុំរាជការថ្មីក្មេង អាចបង្កាប់នូវបុគ្គលឯណា ៗ ហើយធ្វើនូវភ័យលុះក្នុងអំណាចនៃឆន្ទាគតិដល់បុគ្គលនោះ ៗ មែនពិត ព្រោះហេតុឯណាហេតុនោះ ខ្ញុំរាជការថ្មីក្មេង ៗ តែងដុះលូតលាស់ឡើងដោយច្រើនមែនពិត ម្យ៉ាងវិញទៀតខ្ញុំ

រាជការក្មេងនោះសោយនូវផលបុណ្យដោយអំណាចនៃឧបទិ-ស្ស័យបុណ្យមុនអាចបាននូវលាភដ៏ប្រសើរនឹងយសដ៏ប្រសើរឆាប់មែនពិត មួយទៀតសេចក្ដីបំរើនទាំងឡាយគឺខ្ញុំរាជការទាំងឡាយគប្បីសេពគប់ដោយហេតុទាំងឡាយ ៩ យ៉ាងគឺ ម្ចាស់ទ្រព្យទាំងឡាយគឺខ្ញុំរាជការចាស់ក្ដីក្មេងក្ដីគប្បីឲ្យសម្រេចចូលទៅកាន់ច្បាប់តាមសភាពពិត ១ កិរិយាដឹងនូវអាមាត្យអ្នកបំរើខ្លួនផងនូវផៅពង្សផង នូវប្រពន្ធផង ហើយជួយទំនុកបំរុងឲ្យបានសេចក្ដីសុខសប្បាយក្នុងកាលដែលមានភ័យអន្តរាយនឹងកាលដែលអស់ទៅនៃទ្រព្យសម្បត្តិ ១ កិរិយាប្រព្រឹត្តទៅដោយពាក្យសច្ច ១ កិរិយាដឹងច្បាស់នូវមិត្តល្អអាក្រក់ដោយឧស្សាហព្យាយាមរបស់ខ្លួន ១ កិរិយាប្រកបដោយអំពើបុណ្យជាកុសល ១ ឯខ្ញុំរាជការត្រូវសេពគប់ដោយហេតុទាំង ៩ យ៉ាងនេះ ឯវិមេរិ-ភមុលោមវិតក្កតោ សេចក្ដីអធិប្បាយនៃសេចក្ដីវិតកនូវរោមបិញ្ចើមដោយប្រការដូច្នេះឯង ។

ព្រះបាទធនញ្ជយ្យកោរព្យរាជ ព្រះអង្គទ្រង់ព្រះសណ្ដាប់នូវសេចក្ដីអធិប្បាយនៃប្រស្នានេះហើយ ទ្រង់មានព្រះទៃសោ-

មនុស្សកើតឡើងហើយ ដោះនូវសម្ពត់នឹងគ្រឿងអម្ពរបស់ព្រះអង្គឲ្យនូវសព្ទសាធុការហើយពោលថា តាត ម្នាលបា ពាក្យពោលដ៏ពិរោះគឺអ្នកពោលហើយដោយប្រពៃ ព្រោះហេតុនោះយើងមានសេចក្ដីត្រេកអរឮជានូវធម៌នៃអ្នក ទារកក្មេងមានប្រាជ្ញាច្រើនប្រាកដស្មើដោយអ្នក គឺយើងមិនដែលឃើញហើយមិនដែលឮដោយពិត ។

លំដាប់នោះនាងខត្តិយកញ្ញាទាំងឡាយទាំងពួង មានព្រះព្រះអគ្គមហេសីជាប្រធាន ដោះនូវគ្រឿងអម្ពរទាំងឡាយទាំង-ពួងបូជានូវធម៌ដល់ព្រះបរមពោធិសត្វ ។

បំណែកឯជនទាំងឡាយដទៃ មានព្រាហ្មណ៍នឹងគហ-បតីបរោហិតនឹងបណ្ឌិតជាប្រធាន ក៏សឹងមានចិត្តជ្រះថ្លាហើយដោះនូវគ្រឿងអម្ពរទាំងឡាយបូជានូវធម៌ដល់ព្រះបរមពោធិសត្វនោះ ។

ព្រះមហាសត្វព្រះអង្គមានសក្ការគឺមហាជនទាំងឡាយបូ-ជាយ៉ាងនេះហើយ ក៏ចុះចាកទីអាសនហើយថ្វាយបង្គំលានូវស្ដេចត្រឡប់ទៅកាន់ទីលំនៅនៃខ្លួនវិញ ។

គ្រានោះព្រះមហាក្សត្រិយ៍ បានត្រាស់បង្គាប់អាមាត្យទាំងឡាយឲ្យនាំយកនូវគ្រឿងបូជាទាំងឡាយទាំងពួង យកទៅប្រគល់ឲ្យដល់ព្រះបរមពោធិសត្វនោះ ។

ឯព្រះបរមពោធិសត្វនោះ បានទទួលយកហើយព្រះអង្គចាត់ចែងឲ្យធ្វើនូវទានសាលាមួយ ទៀបទ្វារនៃស្រុកនោះហើយញាំងទានវត្តឲ្យប្រព្រឹត្តទៅអស់កាលជានិច្ចមែនពិត ។

សម្ដែងរឿងវិតក្កបញ្ហាជាបឋមក៏ចប់ដោយសេចក្ដីសង្ខេបតែប៉ុណ្ណោះឯង ។៚

៣– មលតរបញ្ហាប្រស្នាសួរអំពីមលតរធម៌ជាមន្ទិល

សម័យថ្ងៃមួយជាខាងក្រោយ សម្ដេចព្រះភូនាថធនញ្ជយ្យកោរព្យរាជ ព្រមទាំងពពួកពលសេនាប្រកបដោយអង្គ ៤ ស្ដេចយាងចេញទៅអំពីនគរ ចូលទៅកាន់ព្រៃដើម្បីសម្លាប់នូវម្រឹគ ហើយឲ្យពាត់នូវស្បាតនៃព្រៃធំមួយ ដោយជុំវិញវាយនូវកំបូតព្រៃនោះដោយដម្បង ។

កាលនោះមានសត្វម្រឹគទ្រាយមួយស្ទុះចេញទៅក្នុងទីចំពោះព្រះភក្ត្រនៃស្ដេច ហើយរត់ទៅដោយរហាស់ ។

ខណៈនោះស្ដេចឡើងកាន់ពាហនសេះមានកំឡាំងដ៏រហាស់បរដេញតាមបាញ់នូវសត្វទ្រាយនោះ ឯអាមាត្យទាំងឡាយទៅតាមពុំទាន់ឡើយ ស្ដេចជាប់តាមនូវសត្វទ្រាយអំពីក្រោយ ពុំអាចដើម្បីបាញ់បានឡើយ កាលរមិលមើលនូវសត្វទ្រាយពុំឃើញរត់ទៅឆ្ងាយពេក ហើយបានឃើញនូវដើមជ្រៃធំមួយ ដ៏មានម្លប់ត្រសុំត្រសាយសាខាល្អ ស្ដេចក៏ចូលទៅកាន់បរិមណ្ឌលនៃដើមជ្រៃនោះ ដើម្បីប្រយោជន៍ដំរំងាប់នូវសេចក្ដីក្ដៅក្រហាយកាយ ។

បរិមណ្ឌលនៃដើមជ្រៃនោះ គឺយក្ខមួយឈ្មោះនន្ទបានអំ-ពីសំណាក់នៃព្រះបាទវេស្សវណ្ណរាជ ប្រទានឲ្យជាដាច់ខាត ។

ឯព្រះបាទវេស្សវណ្ណរាជ បានពោលនូវយក្ខដូច្នេះ ថា-បើបុគ្គលឯណាបានចូលមកដល់កាន់បរិមណ្ឌលនៃដើមជ្រៃនេះ អ្នកត្រូវមានអំណាចទំពាស៊ីនូវបុគ្គលនោះបាន វៀរលែងតែតែបុគ្គលអ្នកចេះដឹងនូវមលតរធម៌ចេញ ថាបើបុគ្គលដទៃគេពុំបានចូលមកកាន់ម្លប់ជ្រៃនេះទេ អ្នកមិនត្រូវទំពាស៊ីនូវបុគ្គលនោះឡើយ ។

ចាប់ដើមអំពីកាលនោះមក នន្ទិយក្តនោះ កាលបើជន ឯណាវង្វេងដើរកន្លងចូលទៅ ក្រោមម្លប់ជ្រៃនោះហើយពុំបេះ ដឹងនូវមលតរធម៌ផង តែងចាប់នូវជននោះដោយកំលាំងខ្លាំង ហើយបរិភោគនូវសាច់និងឈាមជាប្រក្រតី ។

ក្នុងកាលនោះនន្ទិយក្ខស្ទុះចេញមកចាប់ព្រះហស្តនៃស្តេច កាលចូលទៅក្នុងម្លប់ជ្រៃនោះ ឲ្យមាំហើយសួរថា អ្នកជាបុគ្គល ដូចម្តេច ដើរចូលមកក្នុងទីនេះព្រមទាំងពាហននឹងគ្រឿង ប្រដាប់កាយ ។

ស្តេចបានស្តាប់ពាក្យនោះហើយពោលថា យើងជាស្តេច ឈ្មោះធនញ្ជ័យកោរព្យរាជ ។

នន្ទិយក្ខបានស្តាប់ហើយសួរថា មហារាជ បពិត្រស្តេច ដ៏ប្រសើរ ព្រះអង្គបានបេះដឹងនូវមលតរធម៌ដែរឬ ។

ស្តេចនោះបានស្តាប់ហើយ ពោលថា មលតរធម៌នេះ គឺអ្វី ។

នន្ទិយក្ខពោលថា មន្ទិលទាំងឡាយដូចម្តេចហ្ន៎ ឈ្មោះ ជាមន្ទិលសៅម៉ងដោយវិសេស មន្ទិលអ្វីឈ្មោះថាជាមន្ទិល

ក្រៃលែងមន្ទិល ព្រះអង្គត្រូវរំពឹងមើលក្នុងទីទាំងពួងដោយហេតុនេះបុះ ព្រះអង្គគឺខ្ញុំបានសួរហើយនូវមន្ទិលនោះត្រូវព្រះអង្គប្រាប់នូវមន្ទិលនោះមកដល់ខ្ញុំ ។

ព្រះបាទធនញ្ជ័យកោរព្យរាជ បានស្តាប់ហើយពោលថាយើងពុំបានបេះដឹងនូវមន្ទិលធម៌នោះទេ នាកាលពាក្យគឺនន្ទិយក្ខនោះពោលថាបើដូច្នោះព្រះអង្គជាគ្រឿងបរិភោគរបស់យើងហើយ យើងនឹងទំពាស៊ីព្រះអង្គឥឡូវនេះឯង ស្តេចបានស្តាប់នូវពាក្យនោះហើយ សួរទៅយក្ខវិញថា អ្នកឯងបានបេះដឹងនូវសេចក្តីអធិប្បាយនៃមលតរធម៌នេះដែរឬ ។

មន្ទិយក្ខបានស្តាប់ហើយ ពោលថា បពិត្រមហារាជខ្ញុំក៏ពុំបានបេះដឹង នូវមលតរធម៌នោះដែរ ។

ព្រះបាទធនញ្ជ័យកោរព្យរាជ ព្រះអង្គពោលទៅយក្ខនោះថា បើដូច្នោះយើងនឹងញ៉ាំងអ្នកប្រាជ្ញដទៃឲ្យសម្តែងនូវសេចក្តីអធិប្បាយនៃមលតរធម៌នេះ អ្នកឯងនឹងយល់ឃើញដូចម្តេច ។

នន្ទិយក្ខបានស្តាប់ហើយ ពោលថា បពិត្រមហារាជ

សេចក្តីអធិប្បាយឯណា នៃមលតរធម៌នេះមាន សេចក្តីអធិ-ប្បាយនោះ នៃមលតរធម៌នេះ ជាអស្ចារ្យមែនពិត ។

ព្រះបរមក្សត្រិយ៍ ទ្រង់ព្រះសណ្តាប់ហើយ ពោលទៅនឹងយក្ខនោះវិញថា ម្នាលយក្ខ ឈ្មោះថាមលតរធម៌នេះគឺយើងពុំដែលឮហើយមែនពិត ព្រោះហេតុដូច្នោះយើងទៅដើម្បីប្រយោជន៍ដល់កិរិយាសួរនូវសេចក្តីអធិប្បាយនៃមលតរធម៌នេះនឹងអ្នកប្រាជ្ញទាំងឡាយរបស់យើង នាកាលអ្នកប្រាជ្ញទាំងឡាយ កាលសម្តែងនូវសេចក្តីអធិប្បាយនៃមលតរធម៌នោះ ហើយយើងនឹងនាំនូវសេចក្តីអធិប្បាយនោះមក សម្តែងប្រាប់ដល់អ្នកមែនពិត ។

នន្ទិយក្ខបានស្តាប់ហើយ ពោលថា បពិត្រមហារាជ ធម្មតាឯស្តេចនៅក្នុងកណ្តាប់ដៃនៃយក្ខដ៏របឹងរឹងរូសប្រកបដោយសហាស្សិកកម្ម ដ៏របហាស់យ៉ាងនេះ តែបានរួចអំពីកណ្តាប់ដៃនោះហើយ ត្រឡប់មកវិញទៀតគឺខ្ញុំមិនដែលបានឃើញឡើយ

សម្តេចព្រះភូមិស្សរាធិបតី ស្តេចពោលបញ្ជាក់ទៅនឹងយក្ខនោះថា ម្នាលយក្ខ ធម្មតាឯស្តេចតែងប្រកបដោយអង្គប្រា

ពុំបានលះបង់នូវអង្គទាំងឡាយប្រាំនេះគឺ សូរោច ជាបុគ្គលក្លៀវក្លា ១ មហិទ្ធិកោច ជាបុគ្គលមានរិទ្ធិអានុភាពច្រើន ១ បរមទ្ធនោច ជាបុគ្គលញាំញីនូវសត្រូវដទៃ ១ វិបនសទ្ធហាភូតោច ដ៏ជាបុគ្គលមានពាក្យសំដីគឺជនគប្បីជឿ ១ វិបនមធុរោច ជាបុគ្គលមានពាក្យពោលដ៏ពីរោះ ១ យើងជាស្ដេចតែងប្រកបដោយអង្គទាំងប្រាំនេះ ហើយបរិបូណ៌ព្រមដោយផលនៃពាក្យសច្ចនោះ ឯយើងជាស្ដេចបានពោលពាក្យឯណាចេញពីមាត់ទៅហើយ ពាក្យនោះមិនអាចដើម្បីចូលមកក្នុងមាត់ទៀតទេ បីដូចជាសត្រីសំរាលនូវកូនចេញមកពីក្នុងផ្ទៃហើយ មិនដែលត្រឡប់បញ្ចូលកូនទៅក្នុងផ្ទៃវិញឡើយ យើងជាបុគ្គលនឹងនៅជាប្រក្រតីដោយសច្ចភាពនោះមែនពិត ព្រោះហេតុដូច្នោះយើងនឹងទៅសួរនូវសេចក្ដីអធិប្បាយនៃមលតរធម៌នេះ នឹងអ្នកប្រាជ្ញទាំងឡាយ ហើយត្រឡប់មកវិញនឹងសម្ដែងប្រាប់នូវសេចក្ដីអធិប្បាយនោះដល់អ្នកដោយពិត ។

នន្ទិយក្ខស្ដាប់ហើយពោលថា បពិត្រមហារាជ បុគ្គលជាអ្នកឆ្លាសវៀងវៃ ក្នុងសំណាក់នៃព្រះអង្គមានដែរឬ ។

ព្រះមហាក្សត្រិយ៍ ស្តាប់ហើយពោលថា ម្នាលនន្ទិយក្ខ អ្នកប្រាជ្ញឆ្លាសវៀងវៃក្នុងសំណាក់យើងមានដែរ ។

នន្ទិយក្ខស្តាប់ហើយពោលថា បពិត្រមហារាជ បើដូច្នោះ សន្យាប៉ុន្មានថ្ងៃ ព្រះអង្គនឹងត្រឡប់មកវិញ ។

ព្រះបរមក្សត្រិយ៍ ទ្រង់ព្រះសណ្តាប់ហើយ ពោលថា ម្នាលនន្ទិយក្ខ យើងសន្ទិយ៉ា ៧ ថ្ងៃ នឹងត្រឡប់មកវិញពុំខាន ឡើយ ។

នន្ទិយក្ខ ពោលថាបើដូច្នេះបុគ្គលឯណាជាអ្នកប្រាជ្ញបាន ប្រេះដឹងនូវសេចក្តីអធិប្បាយនៃប្រស្នានេះ ព្រះអង្គត្រូវបញ្ជូនតែ បុគ្គលនោះមកក៏បាគហើយ ព្រះអង្គមិនបាច់យាងមកទៀត ឡើយ ថាបើព្រះអង្គមិនបាននូវអ្នកប្រាជ្ញប្រេះដឹងទេ ហើយមក ដោយខ្លួនឯង យើងនឹងទំពាស៊ីតែព្រះអង្គមួយប៉ុណ្ណោះ បើ ព្រះអង្គមិនបាននូវអ្នកប្រាជ្ញប្រេះហើយ គេបវេះពុំបានមកដោយ ខ្លួនឯងឡើយ យើងនឹងទំពាស៊ីនូវព្រះអង្គព្រមទាំងមនុស្សអ្នក នៅក្នុងដែនទាំងអស់ពុំឲ្យមានសល់ឡើយ ។

ព្រះបាទធនញ្ជ័យ្យកោរព្យរាជ បានឲ្យនូវបតិញ្ញាដល់

យក្ខនោះហើយ ស្ដេចត្រឡប់មកវិញ បានដល់នូវសេនា គឺពពួកនៃពលបោមរោមហើយ ត្រឡប់ៈកកាន់ព្រះនគរវិញ ស្ដេចទ្រង់ឡើងកាន់ប្រាសាទ ។

លុះដល់ថ្ងៃព្រឹកទៀត ស្ដេចឲ្យប្រជុំនូវមហាជនទាំងឡាយ មានរាជមហាមាត្យនឹងឧបរាជ-សេនាបតី-ព្រាហ្មណ៍-បណ្ឌិត-បរោហិតជាប្រធាន ហើយទ្រង់សួរនូវសេចក្ដីអធិប្បាយនៃប្រស្នានោះ ។

មហាជនទាំងឡាយទាំងអស់នោះ បានស្ដាប់ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព យើងទាំងឡាយពុំបានបេះដឹងនូវសេចក្ដីអធិប្បាយនៃប្រស្នានោះឡើយ ។.

ព្រះបាទកោរព្យរាជ ទ្រង់ព្រះសណ្ដាប់នូវពាក្យនោះហើយ ព្រះអង្គមានព្រះរាជហ្ឫទ័យភិតភ័យតក់ស្លុតហើយ ពោលថា ជីវិតរបស់អញក្នុងកាលឥឡូវនេះមុខជាមិនមានដោយពិត ។

បរោហិត បានស្ដាប់នូវពាក្យនោះហើយ ក្រាបទូលសួរស្ដេចថា បពិត្រមហារាជ ព្រះអង្គពោលនូវហេតុនេះដូចម្ដេច ។

ព្រះបរមក្សត្រិយ៍ ស្ដេចបានប្រាប់បរោហិតតាមទំនងនោះ

ទៀត ហើយពោលថា បំណែកខាងអញ តែបុគ្គលនីមួយពុំបានបេះដឹងនូវសេចក្ដីអធិប្បាយនៃប្រស្នានេះហើយ នន្ទិយក្ដុវាញាំងអញនឹងអ្នកដែនទាំងអស់ឲ្យវិនាសទៅទាំងអស់ ។

បំណែកខាងសេនាបតី ស្ដាប់ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព បុគ្គលនីមួយដទៃវៀរលែងតែព្រះសម្មាសម្ពុទ្ធចេញ អាចនឹងបេះដឹងនូវសេចក្ដីអធិប្បាយនៃប្រស្នានេះពុំមានឡើយ ។

ព្រះបរមក្សត្រិយ៍ ទ្រង់ព្រះសណ្ដាប់ហើយ ពោលថា បើដូច្នោះ សេចក្ដីអធិប្បាយនៃប្រស្នានេះ គឺយើងទាំងឡាយគប្បីញាំងធនញ្ជ័យក្សុមារ ឲ្យពិចារណាមើលបានដែរឬ ។

អាមាត្យទាំងឡាយ ក្រាបទូលថា បពិត្រមហារាជ ឯធនញ្ជ័យក្សុមារនេះក្មេងណាស់ នៅមានក្លិនទឹកដោះផ្សាយនៅក្នុងមាត់នៅឡើយនឹងបេះដឹងដូចម្ដេចបាន ។

ឯព្រះបាទកោរព្យរាជ ទ្រង់ព្រះសណ្ដាប់ហើយ គឺសេចក្ដីក្រោធគ្របសង្កត់ហើយ ដ៏មានសរីរញាប់ញ័រ បីដូចជាភុជង្គ-នាគរាជមានកន្ទុយគឺបុគ្គលប្រហារហើយដោយដំបងដែក

ហើយស្ដេចពោលថា ភោន្ដោ ម្នាលអ្នកទាំងឡាយដ៏ចំរើន អស់៧ថ្ងៃហើយ ជនទាំងឡាយឯណា ពុំបានដឹងនូវសេចក្ដីអធិប្បាយនៃប្រស្នានេះ ជីវិតនៃជនទាំងឡាយនោះពុំមានឡើយ ។

ព្រះបាទធនញ្ជ័យកោរព្យរាជ ស្ដេចកាន់ព្រះទ័នគំរាមអាមាត្យទាំងឡាយ ឲ្យគិតពិចារណានូវសេចក្ដីអធិប្បាយនៃប្រស្នានោះ ទាំងយប់ទាំងថ្ងៃ ពួកអាមាត្យទាំងឡាយមានសេនាបតីជាដើម ខំរំពឹងគិតពិចារណាទាំងយប់ទាំងថ្ងៃ ភាវរកសេចក្ដីអធិប្បាយនោះពុំបានដឹងសោះ តាំងពីថ្ងៃទីមួយដរាបដល់ថ្ងៃជាគំរប់ ៥ កន្លងទៅ លុះដល់ថ្ងៃជាគំរប់ ៦ ដល់ព្រឹមហើយ ព្រះមហាក្សត្រិយ៍ស្ដេចគង់លើសីហាសនកែវ មានអាមាត្យសេនាបតី បរោហិត ព្រាហ្មណ៍ចោមរោមជាបរិវារ ហើយស្ដេចត្រាស់ប្រដៅថា ភោន្ដោ ម្នាលអ្នកទាំងឡាយដ៏ចំរើន អ្នកទាំងឡាយចូរកុំប្រមាទឡើយ ថាបើអញនឹងនៅក្នុងទីនេះ យក្ខនោះវានឹងញាំងដែនទាំងអស់ឲ្យវិនាសអន្ដរាយទៅពុំមានសល់ឡើយ ព្រោះហេតុដូច្នោះ ថ្ងៃស្អែកនេះអញតែម្នាក់ឯងនឹងចូលទៅកាន់សំណាក់យក្ខនោះ ។

មហាជនទាំងពួង បានស្តាប់នូវព្រះរាជឱង្ការនោះហើយ ក៏បញ្ចេញនូវទឹកភ្នែក ទ្រហោទ្រួញយំសោយសោកតែរាល់ៗ-គ្នា ហើយអង្គុយស្ងៀមនៅ ពុំដឹងបើគិតដូចម្តេចឡើយ ។

ព្រះបាទកោរព្យរាជ ព្រះអង្គបានឃើញនូវសេចក្តីរិបរិត យំសោកនៃមហាជនទាំងឡាយនោះហើយ ស្តេចក៏ទ្រង់យាង ចូលទៅកាន់ប្រាសាទវិញ ។

លុះដល់កន្លងរាត្រីជាគំរប់ ៦ នោះទៅ ដល់ថ្ងៃជាគំរប់ ៧ ហើយ នឹងមានបគ្គលឯណានិមួយ អាចដឹងនូវសេចក្តីអធិប្បាយ នៃប្រស្នានោះពុំមានឡើយ ។

កាលបុព្វណ្ហសម័យ ព្រះបាទកោរព្យរាជ ព្រះអង្គបាន ឃើញនូវសេចក្តីរិបរិតយំសោកនៃមហាជនទាំងឡាយនោះ ហើយស្តេចក៏ទ្រង់យាងចូលទៅកាន់ប្រាសាទវិញ ។

លុះដល់កន្លងរាត្រីជាគំរប់ ៦ នោះទៅ ដល់ថ្ងៃជាគំរប់ ៧ ហើយ នឹងមានបុគ្គលឯណានីមួយ អាចដឹងនូវសេចក្តីអធិ-ប្បាយនៃប្រស្នានោះពុំមានឡើយ ។

កាលបុព្វណ្ហសម័យ ក្សត្រិយ៍ថ្លៃប្រសើរព្រះអង្គស្ដេចទ្រង់នូវសំពត់មានពណ៌ខៀវ មានព្រះហស្ដទទេពុំបានកាន់គ្រឿងអ្វីឡើយ ទ្រង់យាងចេញទៅអំពីរាជត្រកូល ។

គ្រានោះសត្រីទាំងឡាយ ១ ម៉ឺន ៦ ពាន់មាននាងអតុលាទេវីជាប្រធាន រំសាយសក់ទ្រហោយំញ្ញាំទ្រហឹងអឺងកងដើរទៅតាមក្រោយស្ដេចនោះ ។

ធុជ្ជព្រាហ្មណបុរោហិតនឹងឧដុកសេនាបតី ក៏ដើរទៅតាមស្ដេចនោះមួយអន្លើដោយពួកអាមាត្យទាំងឡាយ ។

អ្នកនគរទាំងអស់ មានកោលាហលតែមួយ ដ៏គឹកកងខ្សឹកខ្សួលជ្រួលច្របល់ដើរតាមស្ដេចទៅ ដ៏មានសំឡេងយំសោកនោះលាន់ឮខ្ទាំងស្មើតែនឹងស្រុតទាំងផែនដី ។

ព្រះបរមក្សត្រិយ៍ កាលបើឮហាជនទ្រហោយំខ្សឹកខ្សួលគឹកកងដូច្នោះហើយ ស្ដេចក៏ទ្រង់យាងចេញទៅតាមទ្វារខាងកើត ។

គ្រានោះធនញ្ជយ្យកុមារព្រះបរមពោធិសត្វ ដ៏មានទារកទាំង ៥០០ ចោមរោមជាបរិវារ បានឮសំឡេងទ្រូញយំទ្រ

ហឹងអឹងកងដូច្នោះហើយ ក៏ស្ទុះចេញទៅអំពីផ្ទះម្ដីម្នាដើម្បីរមិល
មើល បានឃើញស្ដេចហើយចូលទៅ- ថ្វាយបង្គំមស្ស្ឫរថាបពិត្រ
ព្រះសម្មតិទេព ព្រះអង្គស្ដេចយាងទៅក្នុងទីឯណា ។

ព្រះបាទកោរព្យរាជ ស្ដេចប្រាប់ថា ម្នាលធនញ្ជ័យ
កុមារ យើងនឹងទៅកាន់សំណាក់ឪយក្ខ ឯព្រះបរមពោធិសត្វ
ទូលថាព្រះអង្គទៅកាន់សំណាក់យក្ខព្រោះហេតុអ្វី ស្ដេចក៏បាន
សម្ដែងប្រាប់ហេតុនោះសព្វគ្រប់ដោយពិស្ដារ ។

ព្រះបរមពោធិសត្វក្រាបទូលថា បពិត្រមហារាជ ខ្ញុំ
នឹងទៅកាន់សម្នាក់យក្ខនោះដោយខ្លួនឯងមែនពិត ។

ស្ដេចទ្រង់ព្រះសណ្ដាប់ហើយសួរថា តាត ម្នាលបា
អ្នកឯងបានចេះដឹងនូវមលតរធម៌ ឬ ។

ពោធិសត្វក្រាបទូលថា ទេវ បពិត្រព្រះសម្មតិទេព ខ្ញុំ
ពុំបានដឹងដែរ តែថាបុគ្គលដទៃក្នុងជម្ពូទ្វីបទាំងអស់វៀរលែងតែខ្ញុំ
ចេញហើយ អាចចេះដឹងនូវមលតរធម៌ពុំមានឡើយ ។

ស្ដេចទ្រង់ព្រះសណ្ដាប់ហើយ ពោលថា បើដូច្នេះអ្នកចូរ
សម្ដែងមកមើល ។

ពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព មលតរ-ធម៌នេះគឺព្រះសម្មាសម្ពុទ្ធសម្ដែងហើយ កិរិយាសម្ដែងក្នុងកាលឥឡូវនេះ មិនគាប់ចិត្តខ្ញុំមែនពិត ។

ស្ដេចទ្រង់ព្រះសណ្ដាប់ហើយពោលថា ម្នាលបា ពាក្យអ្នកពោលមកប្រពៃហើយ បើនឹងគាក់តែងនូវធម្មាសនជាហេតុនឹងឲ្យយូរដំណើរ ។

ដ្បិតថ្ងៃជាគំរប់ ៧ ដល់មកព្រមហើយក្នុងកាលឥឡូវនេះ ព្រោះហេតុដូច្នោះ យើងទាំងឡាយគឺអញផងគឺអ្នកផងនឹងទៅជាមួយគ្នា នាកាលពាក្យយ៉ាងនេះគឺព្រះបរមពោធិសត្វទទួលព្រមហើយ ស្ដេចក៏សួរតទៅទៀតថា ម្នាលបា អ្នកត្រូវការយករត្នអ្វីខ្លះ ។

ព្រះបរមពោធិសត្វក្រាបទូលថា ទេវ បពិត្រព្រះសម្មតិទេព ខ្ញុំគប្បីបាននូវសំពត់សំរាប់ស្លៀកសសុទ្ធនឹងសំពត់ដណ្ដប់សសុទ្ធ បំណែកខាងព្រះអង្គឡើងគង់លើកណ្ដាលនៃដំរីដ៏ប្រសើរ មានស្វេត្រឆត្តគឺបុគ្គលលើកឡើងបាំងហើយ យាង

ចេញទៅមួយអន្លើដោយពពួកពលប្រកបដោយអង្គ ៤ កាលខ្ញុំទៅហើយសូមព្រះអង្គនឹងយាងចេញជាប់តាមក្រោយខ្ញុំទៅ ។

ព្រះបរមក្សត្រិយ៍ ព្រះអង្គទ្រង់ព្រះសណ្ដាប់ហើយ ទទួលថាសាធុ ៗ ហើយទ្រង់បានចាត់ចែងការដោយប្រការដូច្នោះ ។

គ្រានោះធនញ្ជ័យសេដ្ឋីជាបិតានឹងនាងសុខុមាលីទេវីជា-មាតាព្រះបរពោធិសត្វ បានឮនូវពាក្យដ៏មាននោះហើយ ក៏ចូលទៅក្នុងទីនោះដោយឆាប់ ថ្វាយបង្គំព្រះមហាក្សត្រិយ៍ហើយក្រាបទូលថា បពិត្រមហារាជ កូនខ្ញុំនេះនៅក្មេងណាស់នៅមានក្លិនទឹកដោះផ្សាយទៅក្នុងមាត់នៅឡើយ នឹងអាចពោលបរបាមួយអន្លើដោយយក្ខដូចម្ដេចបាន ។

ព្រះនរិន្ទ្រាធិបតីកោរព្យរាជ ទ្រង់ព្រះសណ្ដាប់ហើយពោលថា ភោ ម្នាលអ្នកដ៏ចំរើន ធនញ្ជ័យកុមារនេះសុខចិត្តទៅដោយខ្លួនឯង យើងពុំបានប្រើទេ ។

ឯធនញ្ជ័យកុមារ បានពោលទៅនឹងមាតាបិតាថា អម្មតាត បពិត្រអ្នកជាមាតាជាបិតា អ្នកទាំងឡាយកុំឃាត់ខ្ញុំឡើយ ខ្ញុំនឹងទៅជាប្រាកដ ។

មាតាបានស្តាប់នូវពាក្យនោះហើយ ពោលជាបទព្រះ-គាថាដូច្នេះថា :

ហាតាតបិយបុត្តក ហាតាតហទយំមម
ជីវិតំមេសបុត្តេហិ មាមំធទ្ធេសិឯកកំ

អធិប្បាយថា ហៃបាជាបុត្រតូចសំឡាញ់ពេញចិត្តមាតាបាអើយ សាច់ហ្ឫទ័យរបស់មាតាក្តី ជីវិតរបស់មាតាក្តី ដែលគង់នៅអាស្រ័យនឹងកូន បើកូនអ្នកកាត់ចោលមាតាឲ្យនៅតែម្នាក់ឯងហើយ ជីវិតរបស់មាតានឹងមានមកពីណា ។

ឯសេដ្ឋីជាបិតា ក៏ពោលជាបទព្រះគាថាដូច្នេះថា :

យក្ខោបិពលវាឯតំ នសក្កោសិសល្លបិតុំ
គណ្ហាតិមានុស្សេសព្វេ និច្ចលោហិតបាណិនោ
អលមេតេនយុទ្ធេន យក្ខេនធិរុសេនប
មញ្ញាមិសោអហំតុយ្ហំ ជីវិតំអបិយំគតំ

អធិប្បាយថា អ្នកមិនអាចដើម្បីបរបាចនូវប្រស្នានេះបានឡើយ បំណែកខាងយក្ខមានកំឡាំងខ្លាំងណាស់ មានដៃប្រឡាក់ដោយឈាមជានិច្ច តែងចាប់នូវមនុស្សទាំងឡាយ

ទាំងពួងស៊ីជានិច្ច កិរិយាប្បាំងនឹងយក្ខកាចអាក្រក់យ៉ាងនេះ មិនគួរដល់អ្នកឡើយ អញសំគាល់នូវអ្នកថា ជីវិតរបស់អ្នក នឹងដល់នូវសេចក្ដីទុក្ខដ៏មិនជាទីសំឡាញ់ឡើយ ម្នាលកូនតូប ជាសំឡាញ់ឳពុក ខ្លួនអ្នកជាទារកក្មេង ព្រើនទៅដោយ សេចក្ដីសុខ បំណែកឯយក្ខប្រកបដោយសាហសិកម្ម ប្រព្រឹត្ត ទៅរហាស់ មានកំលាំងព្រើនមានរាងកាយធំ មានកំពស់ប្រ មាណដើមត្នោតលៃ មានភ្នែកក្រហមប្រាលដូចជាព្រះអាទិត្យ អ្នកនឹងអាចដើម្បីពោលបរចា មួយអន្លើដោយយក្ខនោះដូច ម្ដេចបាន ។

ព្រះបរមពោធិសត្ត បានស្ដាប់ពាក្យមាតាបិតាពោល ឃាត់ដូច្នោះហើយ ក៏សម្ដែងធម៌លួងលោមមាតាបិតាពុំឲ្យឃាត់ ព្រះអង្គ ដោយឧបមាខ្លួនព្រះអង្គប្រកបដោយមេត្តាធម៌ដ៏ធំ បីដូចជាសមុទ្រសាគរដ៏ជ្រៀលជ្រៅធំធ្លាយទូលាយ ទោះ បីមានខ្យល់ពាយុបក់បោកមកដូចម្ដេចក្ដីក៏ពុំអាចញ៉ាំងសមុទ្រ សាគរឲ្យរីងស្ងួតទៅបាន ពុំនោះសោតដូចជាព្រះអាទិត្យទុក ជារាហូអសុរិន្ទមកបៀតបៀនយ៉ាងណាក៏គង់ពុំឈប់ដំណើរ

គង់ដើរប្រទក្សិនលោកជាធម្មតា ឯខ្លួនព្រះអង្គប្រកបដោយមេ-ត្តាធម៌ក៏ប្រាកដដូច្នោះដែរ ។

ឯមាតានឹងបិតាទាំងឡាយ បានស្ដាប់ពាក្យនោះហើយ កាលមិនអាចដើម្បីឃាត់ឃាំងបាន ហើយឲ្យនូវពរដល់ព្រះ-ពោធិសត្តជាបុត្តអាត្មាថា៖

បិយបុត្តក សព្វសោត្ថិ សព្វសិទ្ធិ សព្វជយោ ភវតុតេ

(ប្រែថា) ម្នាលកូនស្ងួនត្បូងជាសំឡាញ់ សេចក្ដីសួស្ដីទាំងពួងក្ដី សេចក្ដីសិរីទ្ធិជោគទាំងពួងក្ដី សេចក្ដីជ័យជំនះជ្នះសត្រូវទាំងពួងក្ដី ចូរឲ្យកើតមានប្រាកដដល់អ្នកដោយពិត ។

ព្រះបរមពោធិសត្ត បានទទួលយកនូវពរហើយថ្វាយបង្គំលាមាតានឹងបិតាស្រេចហើយ ក្រាបទូលព្រះមហាក្សត្រិយ៍-ថា បពិត្រមហារាជ ព្រះអង្គចូរយាងទៅចុះ ចូរផ្ញើនូវធុរនេះដល់ខ្ញុំ ៗ ទទួលយកនូវធុរបស់ព្រះអង្គដោយពិត ។

ឯពួកអាមាត្យទាំងឡាយ មានខុដុកសេនាបតីនឹងធុជ្ជ-ព្រាហ្មណ៍ជាដើម ជជែកទាស់គ្នា ខ្លះថាគួរឲ្យស្ដេចយាងទៅ

ខ្លះថាមិនគួរឲ្យស្ដេចយាងទៅ ដោយសេចក្ដីតក់ស្លុតខ្លាចអំ-ណាចយក្សនោះឯង ៗ

ធនញ្ជយ្យកុមារមហាសត្វ បានស្ដាប់ពាក្យនោះហើយ ពោលថា បពិត្រមហារាជ ថាបើខ្ញុំនឹងខ្លាចយក្សនោះនឹងគេចទៅក្នុងទីដទៃហើយ នរណានឹងចេញទៅកាន់សំណាក់នៃយក្សនោះ ម្យ៉ាងវិញទៀត ថាបើយក្សរាបង្គាប់ទាយកថ្លៃនៃស្ដេច ខ្ញុំនឹងធ្វើនូវការឈ្នះលដល់យក្សនោះ ម្យ៉ាងទៀត អានុភាពនៃខ្ញុំនឹងប្រាកដដល់យក្ស ដើម្បីដឹងនូវសេចក្ដីអធិប្បាយនៃធម៌ ព្រោះហេតុដូច្នោះ ព្រះអង្គប្រូវពួននៅក្នុងទីដ៏ឆ្ងាយហើយរង់ចាំ-មើលចុះ ៗ

ឯពពួកមហាជនទាំងពួង មានមហាមាត្យជាដើម ក៏-មានសេចក្ដីប្រាថ្នាតែមួយព្រមព្រៀងគ្នាទាំងអស់ ហើយបាត់-បែងនូវដំណើរ ដើរតាមដង្ហែរស្ដេចទៅទាំងអស់ ៗ

សម្ដេចព្រះទីបទិន្នាធិបតីកោរព្យរាជ មានសេនាប្រកបដោយអង្គ ៤ ចោមរោមជាបរិវារ ព្រមទាំងរាជសត្រីទាំងឡាយ មាននាងអតុលាទេវីជាប្រធាននឹងសេដ្ឋីគហបតីទាំងអស់ ស្ដេច

យាងបេញទៅ ហើយទ្រង់ពធនញ្ជយ្យកុមារដោយបង្កេះឡើងគង់លើក្បូនៃដំរីដ៏ប្រសើរ ទ្រទ្រង់នូវស្វេត្រឆត្តមានពណ៌ ៥ ស្តេចបេញទៅតាមលំដាប់ លុះបានដល់នូវទីជិតនៃយក្ខនោះហើយ ក៏ចុះអំពីដំរីព្រមទាំងមហាជនទាំងអស់លាក់ព្រះអង្គពួននៅក្នុងព្រៃធំដ៏ឆ្ងាយអំពីទីស្ថាននៃយក្ខនោះឯង ។

គ្រានោះធនញ្ជយ្យកុមារមហាសត្វ ក៏ស្លៀកសំពត់សាដកសសុទ្ធ ពាត់ឈៀងសំពត់បង់កណ្តាសសុទ្ធស្នាម្ខាងហើយកាន់ផ្តិតវិជ្ជនីដោយដៃខាងស្តាំ អង់អាចបីដូចកេសរសីហះដ៏ក្លៀវក្លាចូលទៅកាន់ដើមជ្រៃ ញាំងមេត្តាចិត្តឲ្យតាំងព្រម ប្រកបដោយមេត្តាព្រហ្មវិហារ លីលាចូលទៅកាន់ទីជិតបរិមណ្ឌលនៃដើមជ្រៃឰដខាងក្រៅ ហើយស្រែកហៅយក្ខថាភោនន្ទិយក្ខ ម្នាលនន្ទិយក្ខដ៏បំរើន យើងមកដល់ហើយ ។

នន្ទិយក្ខនោះកាលឃើញព្រះបរមពោធិសត្វនោះមកអំពីចម្ងាយហើយក៏មានក្តីស្នេហាស្រឡាញ់បីដូចជាកូនបង្កើតរបស់ខ្លួន កើតឡើងព្រម មានកាយមិនប្រាកដស្ថិតនៅទៀប

គល់ជ្រៃ ស្តាប់សំដីនៃព្រះបរមពោធិសត្វនោះ ហើយមាន សេចក្តីស្រឡាញ់ដ៏វិសេសក្រៃពេកកើតឡើង ទើបសំដែងកាយ ឲ្យប្រាកដហើយពោលនូវពាក្យតបទៅពោធិសត្វថា ភោ មាណវ ម្នាលមាណពដ៏បំរើន អ្នកមានឈ្មោះដូចម្តេច ជា កូននៃបុគ្គលឈ្មោះអ្វី ។

ពោធិសត្វប្រាប់ថា យើងឈ្មោះធនញ្ជយ្យកុមារជាកូន នៃធនញ្ជយ្យសេដ្ឋី ។

នន្ទិយក្ខស្តាប់ហើយសួរថា អ្នកឯងមកប្រយោជន៍អ្វី អ្នក ឯណាបញ្ជូនអ្នកមក ។

ព្រះបរមពោធិសត្វប្រាប់ថា បំណែកខាងយើងនេះ ជាទាសបុត្រនៃព្រះបាទធនញ្ជយ្យកោរព្យរាជ ស្តេចនេះ បញ្ជូនយើងមក បានជាយើងមក ។

នន្ទិយក្ខសួរទៀតថា តាត ម្នាលបា អ្នកឯងបានបេះ ដឹងនូវមលតរធម៌ឬ បានជាស្តេចបញ្ជូនអ្នកឯងមក ។

ព្រះបរមពោធិសត្វពោលថា ម្នាលយក្ខដ៏បំរើន អ្នក ឯងគុង់តែនឹងដឹងនូវភាវនៃយើង បះដឹងនូវមលតរធម៌ ឯយើង

គឺស្តេចនោះបញ្ជូនមកហើយ ដើម្បីប្រយោជន៍ឲ្យអ្នកឯងបរិភោគជាចំណី ។

នន្ទិយក្ខស្តាប់ហើយពោលថា ម្នាលអ្នក សាច់និងឈាមរបស់អ្នកនេះ គ្រាន់តែញ៉ាំងជើងធ្មេញនៃយើងឲ្យទទឹកក៏មិនគ្រាន់ផង, ព្រោះហេតុនោះ យើងត្រូវបានស៊ីនូវអ្នកដោយពិត ល្មើយចុះបើដូច្នោះអ្នកឯងចូលមក ។

ព្រះបរមពោធិសត្តនោះ ក៏បានចូលទៅជិតគល់ជ្រៃនោះ ហើយឈរស្ងៀមនៅពុំបានពោលថាអ្វីឡើយ ។

នន្ទិយក្ខបានឃើញហើយពោលថា តាត ម្នាលអ្នក ព្រោះហេតុអ្វីបានជាអ្នកមិនចូលមកឲ្យដល់សំណាក់យើង ។

ព្រះបរមពោធិសត្ត បានស្តាប់ហើយពោលថា ម្នាលយក្ខយើងជាអ្នកប្រព្រឹត្តទៅតាមសុចរិតធម៌ ព្រោះហេតុដូច្នោះបានជាយើងពុំបានចូលទៅជិតកាន់សំណាក់នៃអ្នក ។

នន្ទិយក្ខបានស្តាប់ហើយសួរថា សភាវអ្វីឈ្មោះថាសុចរិតធម៌ សុចរិតធម៌នោះតើដូចម្តេចខ្លះ ។

ព្រះបរមពោធិសត្ត បានស្តាប់ហើយពោលថា បើដូច្នោះ

អ្នកឯងត្រូវធ្វើទុកក្នុងចិត្តឲ្យមាំមួន យើងនឹងសម្តែងប្រាប់ ពោធិសត្តបានពោលយ៉ាងនេះហើយ ក៏ពោលជាបទព្រះគាថាដូច្នេះថា៖

អនិមន្តិយរំគន្តា អបុច្ឆាបរិភាសតិ
អត្តានញ្ចបសំសិយោ តិវិធំហីនលក្ខណំ

អធិប្បាយថា សេចក្តីខាតលក្ខណ៍មាន ៣ យ៉ាង គឺគេពុំបានអញ្ជើញទៅកាន់ផ្ទះ ហើយទៅកាន់ផ្ទះគេ ១ គេពុំបានសាកសួរឲ្យនិយាយ ហើយនិយាយប្រាប់គេមុនសួរ ១ គេពុំបានសរសើរ ហើយសរសើរតែខ្លួនឯង ១ ម្នាលយក្ខបុគ្គលវៀរលៀងធម៌ខាតលក្ខណ៍ ៣ យ៉ាងនេះឲ្យស្រឡះ បានឈ្មោះថាបុគ្គលអ្នកប្រព្រឹត្តនៅសុចរិតធម៌ដោយពិត ។

នន្ទិយក្ខបានស្តាប់ហើយ កើតសេចក្តីស្រប់ស្រៀងនឹងពោធិសត្ត គិតថាបុរសនេះជាបុរសអាជានេយ្យដោយពិត គិតដូច្នេះហើយពោលថា តាត ម្នាលអ្នក ចូរអ្នកសំដែងនូវសេចក្តីអធិប្បាយនៃមលតរធម៌នោះមកមើល ។

ព្រះបរមពោធិសត្វស្ដាប់ហើយពោលថា យើងនឹងមិនសំដែងសេចក្ដីអធិប្បាយនៃមលតរធម៌នោះទេ ។

នន្ទិយក្ខ ពោលថាបើដូច្នោះអញនឹងទំពាស៊ីអ្នកឯងឥឡូវនេះ ។

ព្រះពោធិសត្វពោលថា អ្នកឯងនឹងអាចទំពាស៊ីយើងម្ដេចបាន យើងពោលយ៉ាងនេះព្រោះហេតុអ្វី អ្នកឯងទំពាស៊ីបុគ្គលដទៃដោយហេតុប៉ុន្មាន ។

នន្ទិយក្ខពោលថាយើងអាចដើម្បីទំពាស៊ីនូវបុគ្គលដទៃដោយហេតុទាំងឡាយ ២ យ៉ាងគឺ បុគ្គលចូលមកក្នុងម្លប់ដើមជ្រៃនេះ ១ បុគ្គលពុំរបេះដឹងនូវមលតរធម៌ ១ យើងត្រូវទំពាស៊ីបុគ្គលដទៃបាន ដោយហេតុ ២ យ៉ាងនេះដោយពិត ។

ព្រះបរមពោធិសត្វពោលថា ភោ ម្នាលយក្ខដ៏ចំរើនអ្នកឯងមិនអាចដើម្បីនឹងទំពាស៊ីយើង ដោយហេតុទាំងឡាយ ២ យ៉ាងនោះ គឺអ្នកហៅឲ្យយើងចូលមក យើងបានចូលមកដោយអំណាចអ្នកហៅ យើងពុំបានចូលមកដោយខ្លួនឯងម្យ៉ាងវិញទៀត យើងបានរបេះដឹងនូវមលតរធម៌ផង

ព្រោះហេតុឯណាហេតុនោះ អ្នកមិនត្រូវទំពាស៊ីយើងឡើយ ។

នន្ទិយក្ខ បានស្ដាប់ហើយ ពោលថា តាត ម្នាលបា បើអ្នកបេះដឹងនូវមលតរធម៌មែន ហេតុអ្វីក៏អ្នកមិនសម្ដែងមក ។

ព្រះបរមពោធិសត្វពោលថា ភោ ម្នាលយក្ខដ៏ចំរើន ទីស្នាក់ក្ដីបុគ្គលក្ដី ពុំបានគាប់ចិត្តយើង ព្រោះហេតុនោះបានជាយើងមិនសម្ដែង ។

នន្ទិយក្ខបានស្ដាប់ហើយពោលថា តាត ម្នាលបាយើងនឹងធ្វើប្រដាប់នូវទីស្នាក់ឲ្យល្អ តែថាបុគ្គលដែលមិនជាទីគាប់-ចិត្តនៃអ្នកដូចម្ដេច ។

ព្រះបរមពោធិសត្វពោលថា ភោ ម្នាលអ្នកដ៏ចំរើន ចំណែកខាងបុគ្គលមិនជាទីគាប់ចិត្តយើង គឺបុគ្គលទាំងឡាយឯណាមានចិត្តរឹងរឹងរូសកាចអាក្រក់ មានដៃប្រឡាក់ដោយឈាមជានិច្ច , ព្រោះហេតុឯណាហេតុនោះ មលតរធម៌នេះមិនគួរសមដល់បុគ្គលទាំងឡាយនោះឡើយ មលតរធម៌នេះគួរសម តែដល់បុគ្គលដែលមានចិត្តជាកុសលដោយពិត , ថាបើ

អ្នកនឹងប្រព្រឹត្តនូវធម៌ដែលជាកុសលនោះបាន យើងនឹងសម្តែងនូវមលតរធម៌នោះដល់អ្នក ។

នន្ទិយក្សស្តាប់ហើយពោលថា តាត ម្នាលបា យើងនឹងប្រព្រឹត្តតាមធម៌ជាកុសលនោះ អ្នកចូរសម្តែងមលតរធម៌នោះមកចុះ ។

ព្រះបរមពោធិសត្វពោលថា កិរិយាសម្តែងនូវមលតរធម៌ក្នុងទីយ៉ាងនេះ មិនគាប់ចិត្តយើង ។

នន្ទិយក្សបានស្តាប់ពាក្យនោះហើយ ក៏និមិត្តនូវទីអាសនដ៏ខ្ពស់ តាក់តែងដោយគ្រឿងប្រដាប់ទាំងឡាយមានទាំងស្វេត្រឆត្រលើកឡើងព្រម ហើយអារាធនាថា តាត ម្នាលបា អ្នកចូរអង្គុយលើអាសននេះចុះ ហើយចូលសម្តែងនូវធម៌ដល់យើង ៗ នឹងស្តាប់ក្នុងកាលឥឡូវនេះ ។

ព្រះបរមពោធិសត្វពោលថា ភោ ម្នាលយក្សដ៏ចំរើន សរីរនៃយើងមិនស្អាត ប្រឡាក់ដោយញើសក្អែលច្រើនណាស់ លុះតែយើងបានជំរះងូតស្រោបលាងនូវមន្ទិលញើសក្អែលឲ្យ

ស្អាតល្អដោយទឹកដ៏រងថ្លារួចស្រេចហើយ ទើបនឹងសម្តែងធម៌បាន ។

នន្ទិយក្ខបានស្តាប់នូវពាក្យនោះហើយ ក៏រួសរាន់ហោះចេញទៅកាន់ប្រទេសព្រៃហេមពាន្ត ដងទឹកអនោតត្តស្រះនាំមកដោយរហាស់ដោយកំលាំងនៃឫទ្ធិ ហើយអញ្ជើញព្រះពោធិសត្វ ឲ្យងូតសំអាតនូវញើសក្អែលមន្ទិលសៅហ្មងស្អាតហើយ យកនូវគ្រឿងក្រអូបដ៏កើតអំពីគន្ធរសមកលាបប្រស់ព្រំព្រះបរមពោធិសត្វ ស្រេចហើយអារាធនាឲ្យសម្តែងធម៌ ។

គ្រានោះព្រះបរមពោធិសត្វ ពែនព្រះភ្នែនគង់លើធម្មាសនដ៏ស្អិតស្អាងដោយគ្រឿងប្រដាប់ដ៏វិចិត្រ ហើយកាន់យកនូវវិជ្ជនីដ៏វិចិត្របិទបាំងព្រះភ័ក្ត្រ ហើយសម្តែងធម៌ ។

កាលនោះព្រះបាទធនញ្ជយ្យកោរព្យរាជ ស្តេចទតទៅឃើញព្រះបរមពោធិសត្វនោះ អង្គុយនៅលើធម្មាសនដ៏ខ្ពស់ គឺនន្ទិយក្ខប្រដាប់តាក់តែងឲ្យហ្នោះហើយ ស្តេចទ្រង់រំពឹងគិតថា ធនញ្ជយ្យកុមារនេះបានទូន្មាននន្ទិយក្ខ ធ្វើមិនឲ្យ

មានពុតកំណាច ហើយសម្តែងនូវមលតរធម៌ ស្តេចគិតដូច្នេះ ហើយ ព្រមទាំងបរិវារទាំងអស់ បោះនូវកងទ័ពឈប់ចាំស្តាប់ធម៌នៃព្រះបរមពោធិសត្វនោះអំពីចម្ងាយ ។

បំណែកឯព្រះបរមពោធិសត្វ បានពោលទៅនឹងយក្ខថា ភោយក្ខរាជ បពិត្រស្តេចនៃយក្ខដ៏បំរើន ព្រះអង្គត្រូវធ្វើទុកក្នុងចិត្តឲ្យល្អ ខ្ញុំនឹងសម្តែងនូវកល្យាណធម៌ឥឡូវនេះ ព្រះពោធិសត្វបានពោលយ៉ាងនេះហើយក៏ពោលជាបទព្រះគាថាដូច្នេះ

បាណាតិបាតាធនហារតាបិ បរស្សទាររិបធំអសច្ចំ
មជ្ជំបិវិយោតិធសោនរោច សមូលប្បេទោមុនិនាបវុត្តោ ។

អធិប្បាយថា ក៏រីនរជនឯណាក្នុងលោកនេះសម្លាប់នូវសត្វមានជីវិត ១ លួចយកនូវទ្រព្យនៃបុគ្គលដទៃ ១ គប់នូវប្រពន្ធកូននៃបុគ្គលដទៃ ១ ពោលនូវពាក្យកុហកមិនទៀង ១ ផឹកនូវទឹកស្រវឹងគឺសុរានឹងមេរ័យ ១ ហៅមន្ទិលធម៌ជាគ្រឿងសៅហ្មងដល់ចិត្តនឹងចេតសិកដោយពិត នរជនដែលប្រកបដោយមន្ទិលធម៌ទាំងប្រាំប្រការនោះ អ្នកប្រាជ្ញមានព្រះពុទ្ធជាដើម

ពោលឲ្យឈ្មោះថាជាបុគ្គលកាត់ផ្ដេចបង់នូវឫសគល់នៃខ្លួន ជាមនុស្ស ពុំបានលូតលាស់កើតជាមនុស្សទៀតឡើយ ។

អបាយបត្តោបិមនុស្សភូតោ. អប្បាយុកោព្យាធិកុលាតិភាសោ. ទុប្បញ្ញរូបោរិកសោរិយោគោ.បិយេហិយោសោបរបាណឃាតោ.

អធិប្បាយថា បុគ្គលឯណាប្រព្រឹត្តធ្វើនូវអំពើបាណាតិបាត សម្លាប់បំបាត់ជីវិតសត្វដទៃ បុគ្គលនោះឯង ស្លាប់ទៅទៀងតែនឹងទៅកើតក្នុងអបាយ ៤ គឺនរក ប្រេត អសុរកាយ តិរច្ឆាន សោយទុក្ខវេទនា ដល់សែសសល់ផលកម្មនោះត្រឡប់មកបង្កើតជាមនុស្សវិញ ជាបុគ្គលមានអាយុខ្លី ជាសំបុកនៅនៃរោគ មានប្រាជ្ញាខ្លៅ មានរូបអាក្រក់ ខ្វាស់ខាតឥន្ទ្រិយ៍ពុំពេញបរិបូណ៌ ព្រាត់ប្រាសមិត្តសំឡាញ់បងប្អូនកូនចៅដែលជាទីសំឡាញ់ពេញចិត្តទាំងឡាយដោយផលអំពើបាណាតិបាតនោះឯង ។

អបាយបត្តោបិមនុស្សភូតោ ទលិទ្ទភូតោបរទាសជាតោ បណ្ឌាលកុលេនិចនេចជាតោ ភោគស្សហានោឯនហារកោសោ

អធិប្បាយថា បុគ្គលឯណាជាអ្នកលួចយកនូវទ្រព្យរបស់នៃ

បុគ្គលដទៃ ដែលគេពុំបានឲ្យដោយកាយដោយវាចា បុគ្គលនោះស្លាប់ទៅកើតក្នុងអបាយទាំង៤សោយនូវសេចក្ដីទុក្ខវេទនា ដល់សែសសល់ផលកម្មនោះត្រឡប់មកកើតជាមនុស្សវិញ ជាអ្នកហីនហោបចាកភោគសម្បត្តិ កើតជាអ្នកកំសត់ទូរគតជាទាសាទាសីខំបំរើអ្នកដទៃផង កើតក្នុងត្រកូលនៃមនុស្សបណ្ដាលកាលកិណី ក្បត់ទ្រព្យសម្បត្តិផង ដោយផលអទិន្នាទាននោះឯង ។

អបាយបត្តោបិមនុស្សត្តោ នបុំសកោទុក្ខសយោអបិយោ
ឥត្ថិបបិយេហិជនេហិវិយោគោ បរស្សទារគមនោនរោសោ

អធិប្បាយថា នរជនឯណាជាអ្នកលេងសេពគប់នូវប្រពន្ធអ្នកដទៃ នរជននោះស្លាប់ទៅនឹងកើតក្នុងអបាយទាំង ៤ សោយនូវសេចក្ដីទុក្ខវេទនា ដល់សែសសល់ផលកម្មនោះត្រ-ឡប់មកកើតជាមនុស្សវិញ នឹងកើតជាមនុស្សខ្ទើយជាជែនកើតទុក្ខលំបាក មិនជាទីពេញចិត្តនៃអ្នកដទៃផង នឹងកើតជា-ស្រីរំយោគព្រាត់ប្រាសចាកជនទាំងឡាយ ដែលជាទីសំឡាញ់ពេញចិត្តផង ដោយផលកាមេសុមិច្ឆាចារកម្មនោះឯង ។

អបាយបត្តោបិមនុស្សភូតោ ទុគ្គន្ធវាតោវិឡបទត្តោ

អសទ្ធភាវោមុខរោវិសង្កោ ភាសាបិកោតុច្ចរហោនរោសោ

អធិប្បាយថា នរជនឯណាអ្នកពោលនូវពាក្យទទេ ពុំពិត កុហកបញ្ឆោតអ្នកដទៃឲ្យគេខូចប្រយោជន៍ នរជននោះស្លាប់ទៅកើតក្នុងអាបាយទាំង ៤ សោយនូវសេចក្ដីទុក្ខវេទនា ដល់សែសសល់ផលកម្មនោះ ត្រឡប់មកកើតជាមនុស្សវិញ ជាបុគ្គលមានក្លិនស្អុយផ្សាយចេញពីមាត់ មានធ្មេញធំរង្វើលពុំស្មើល្អ មានសំដីនិយាយគឺបុគ្គលមិនគប្បីជឿ មានមាត់រឹងរូសគឺបុគ្គលដទៃស្ទើទស្គាលនិយាយផងពុំបាន មានសំឡេងស្អកស្អាពុំពិរោះឡើយ ដោយផលមុសាវាទនោះឯង ។

អបាយបត្តោបិមនុស្សភូតោ ឧម្មត្តកោឯឡមូគោបិយក្ខោ

សម្ពប្បលាបោផរុសោទុសីលោ គារយ្ហយុត្តោទុរូបោនរោសោ

អធិប្បាយថា នរជនឯណាជាអ្នកផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ នរជននោះស្លាប់ទៅកើតក្នុងអបាយទាំង ៤ សោយនូវសេចក្ដីទុក្ខវេទនា ដល់សែសសល់ផលកម្មនោះ ត្រឡប់មកកើតជាមនុស្សវិញ ជាបុគ្គលឆ្កួតវង្វេង ជាបុគ្គល

ឆ្កួតជ្រិក ជាយក្ខភាពអាក្រក់ ជាបុគ្គលពោលនូវពាក្យឥតប្រយោជន៍ ជាបុគ្គលមានសំដីអាក្រក់ ជាបុគ្គលទ្រុសសីល ជាបុគ្គលមានរូបអាក្រក់ ប្រកបដោយកម្មគឺបណ្ឌិតគប្បីតេះដៀលជានិច្ច ដោយផលសេពសុរាមេរ័យនោះឯង ។

តស្មាកយិមិរិធិសរិត្វា វេរំជយិត្វានរម្មេយ្យសីលំ
អនន្តគុណញ្ចមហានិសំ សម្បត្តុបាទំជិនគោចរត្តំ

អធិប្បាយថា ព្រោះហេតុដូច្នោះ បុគ្គលជាសប្បុរសបើវៀករៀយ ៗ នូវភ័យមានប្រការផ្សេង ៗ ហើយៈគប្បីលះបង់នូវពៀរនេះចេញឲ្យស្រឡះ ហើយត្រេកអរនូវសីលទាំងប្រាំ ដែលជាសីលមានអានិសង្សច្រើនជាអនន្តគុណជាទីគោចរនៃព្រះជិនស្រី ជាទីញាំងសម្បត្តិទ្រព្យទាំងពួងឲ្យកើតឡើងស្ថិតស្ថេរដោយពិត ។

គណ្ហាតុបញ្ចសីលានិ បាលយន្តុសុនិមលំ
នោតុវភោគត្តម្បិប និព្វានត្តញ្ចវិមលំ

អធិប្បាយថា ដុំនុំយើងទាំងឡាយ អ្នកត្រូវកាន់យកនូវសីលទាំងឡាយ ៥ រក្សាឲ្យល្អកុំឲ្យមានមន្ទិលសៅហ្មងឡើយ

ដើម្បីបាននូវភោគផង ដើម្បីបាននូវព្រះនិព្វានមានមន្ទិលសៅហ្មងពុំមានផង ជាទីរំលត់នូវទុក្ខដោយពិត ។

ទេសនាវសានេ កាលចប់ព្រះធម៌ទេសនាហើយ នន្ទិយក្ខក៏លើកឡើងនូវអញ្ជលីប្រណម្យ ដោយសេចក្ដីជ្រះថ្លាក្នុងធម៌ហើយពោលជាបទព្រះគាថាដូច្នេះ

គណ្ហាមិ បញ្ចសីលានិ បាលេយ្យន្តិ សុនិម្មលំ
ឯវំ សង្គណ្ហិតុំ ធីរ សទ្ធំវិហារកន្តិមំ ។

អធិប្បាយថា បពិត្រព្រះអង្គអ្នកមានព្យាយាម ខ្ញុំសូមទទួលយកនូវសីលទាំងឡាយប្រាំ សូមព្រះអង្គសង្គ្រោះនូវខ្ញុំ ឋិតជាសទ្ធិវិហារិករក្សានូវសីលឲ្យល្អមិនឲ្យមានមន្ទិលសៅហ្មងយ៉ាងនេះដោយពិត ។

ព្រះបរមពោធិសត្វ ព្រះអង្គបានស្ដាប់ពាក្យនោះហើយ ពោលថា បើដូច្នោះអ្នកចូរអង្គុយប្រហោង ហើយទទួលយកនូវសីលទាំង ៥ នេះចុះ ។

នន្ទិយក្ខបានស្ដាប់ពាក្យនោះហើយ ក៏បង្អោនទៅ

នៅអញ្ជលីអង្គុយប្រះហោងពោលថា បណ្ឌិត សីលំយាចាមិ បពិត្របណ្ឌិត ខ្ញុំសូមនូវសីល ។

ព្រះបរមពោធិសត្វ ក៏បានសម្ដែងប្រកាសឲ្យនូវសីល មានបាណាតិបាតាវេរមណីជាដើម ហើយធ្វើនូវយក្ខនោះមិនឲ្យមានពុតកំណាច ញុំាងយក្ខនោះឲ្យទទួលកាន់យកនូវសីលទាំង ៥ ហើយគង់ស្ងៀមទៅ ។

គ្រានោះទេវតាទាំងឡាយដែលនៅក្នុងព្រៃទាំងអស់ មានកាយកាលមិនប្រាកដ ធ្វើនូវសំឡេងសាធុការឲ្យប្រាកដ ធ្វើនូវកោលាហលឲ្យមានសេចក្ដីគឹកកងតែមួយ ក្នុងព្រៃនោះឯង ។

បំណែកឯនន្ទិយក្ខបានទទួលយកនូវសីលហើយអារាធនាថ្លែងថា បពិត្របណ្ឌិត សូមព្រះអង្គសម្ដែងនូវមលតរធម៌ដល់ខ្ញុំ ។

ព្រះបរមពោធិសត្វបានស្ដាប់នូវពាក្យនោះហើយ បង្គាប់នន្ទិយក្ខនោះថា ម្នាលយក្ខដ៏ពិរេន បើដូច្នោះចូរអ្នកអញ្ជើញស្ដេចជាម្ចាស់នៃយើង ឲ្យចូលមកក្នុងទីនេះ ហើយចូរឃោសនានូវធម៌ ឃោសនានូវទេវតាទាំងឡាយឲ្យមកប្រជុំក្នុងទីនេះ ។

នន្ទិយក្ខបានស្ដាប់នូវពាក្យនោះហើយ ក្រោកឡើងចាកទីអាសនចូលទៅកាន់សំណាក់ព្រះបាទធនញ្ជយ្យកោរព្យរាជអញ្ជើញស្ដេចហាដូច្នេះ មហារាជ បពិត្រមហារាជ សូមព្រះអង្គយាងចូលទៅគង់នៅក្នុងទីជិតនៃធម្មាសន ទ្រង់ព្រះសណ្ដាប់សេចក្ដីអធិប្បាយនៃមលតរធម៌ ។

ព្រះបរមក្សត្រិយ៍ទ្រង់ព្រះសណ្ដាប់នូវពាក្យនោះហើយ ស្ដេចបានជ្រាបច្បាស់នូវការនៃយក្ខនោះជាបុគ្គលមានពុតក៍-ណាបពុំមានដោយពិត ហើយក្រោកចាកទីអាសនព្រមទាំងបរិវារ ស្ដេចយាងចូលទៅគង់លើអាសនដ៏សមគួរគឺយក្ខតាក់តែងហើយក្នុងទីជិតនៃធម្មាសន ។

បំណែកខាងឯនន្ទិយក្ខក៏បានស្រែកឃោសនាទេវតាទាំងឡាយដោយពាក្យពោលដូច្នេះថា ភោន្តោ ទេវសំឃោ បពិត្រពួកទេវតាទាំងឡាយដ៏ចំរើន ធនញ្ជយ្យកុមារនឹងសម្ដែងនូវមលតរធម៌ក្នុងកាលឥឡូវនេះ ចូរអ្នកទាំងឡាយចូលមកស្ដាប់មលតរធម៌នោះក្នុងទីនេះ ។

ក្នុងខណៈនោះ ទេវតាទាំងឡាយដែលនៅក្នុងព្រៃនោះ

ទាំងអស់ បានឮពាក្យឃោសនានោះហើយ ក៏គិតក្នុងចិត្តថា មលគរធម៌នេះប្លែកពេកណាស់យើងទាំងឡាយមិនដែលបាន ស្តាប់ហើយ អត្ថក្តី ព្យញ្ជនក្តី យើងទាំងឡាយមិនដែលបាន ស្តាប់ហើយ លុះទេវតាទាំងអស់នោះគិតដូច្នេះហើយ មាន រាងកាយកាលមិនប្រាកដចូលទៅប្រជុំគ្នាស្តាប់នូវធម៌ទេសនានៃ ព្រះបរមពោធិសត្វ ។

បំណែកឯនន្ទិយក្ខអង្គុយនៅក្នុងទីដ៏សមគួរមួយ ទើប បង្អោនទៅអញ្ជលីចំពោះព្រះបរមពោធិសត្វ ហើយអារាធនា ធម៌ថា ទេសេតុ បណ្ឌិត បពិត្របណ្ឌិតសូមព្រះអង្គសម្តែងនូវ សេចក្តីអធិប្បាយនៃមលគរធម៌នោះដល់យើងទាំងឡាយ ក្នុង កាលឥឡូវនេះ ។

គ្រានោះធនញ្ជយ្យកុមារមហាសត្វ បើកនូវព្រះនេត្រ ទាំងពីរមានប្រាសាទទាំងប្រាំដ៏ស្អាត រមិលមើលនូវបរិសទ្យ ដោយជុំវិញ ហើយបានឃើញនូវបរិសទ្យពុំបានរពឹសដៃជើង ផង ពុំមានសំឡេងក្អកកណ្តាសផង ដ៏សំងំស្ងប់ស្ងាត់ដោយ ប្រពៃ ហើយក៏សម្តែងនូវធម៌ដល់យក្ខដូច្នេះថា យក្ខរាជ

បរិត្រស្តេចយក្ខធម្មតាឯមលតរធម៌នេះ មិនមែនជាវិស័យនៃយក្ខនឹងគន្ធព្វ-នាគ-គ្រុឌ-តាបស-សមណ-ព្រាហ្មណ៍ទាំងឡាយដទៃឡើយ ជាវិស័យនៃព្រះសម្មាសម្ពុទ្ធនឹងព្រះបច្ចេកពុទ្ធសាវកនៃព្រះពុទ្ធទាំងឡាយដោយពិត ព្រោះហេតុដូច្នោះអ្នកត្រូវធ្វើទុកក្នុងចិត្តឲ្យល្អ យើងនឹងសម្តែងនូវមលតរធម៌ ព្រះពោធិសត្តពោលយ៉ាងនេះហើយ ក៏ពោលជាបទព្រះគាថាដូច្នេះ

ទិដ្ឋិដុទ្ធច្ចទោសន្ត កំខំបិតុនតិទស
លោកនាសយុត្តេនេត កិលេសាបិត្តកេសតោ ។

អធិប្បាយថា ធម៌ទាំងឡាយនេះមាន ១០ គឺមួយ ទិដ្ឋិ យើញខុសប្រកាន់ខុសបង្កើតជាគំនិតដទៃដោយអំណាចនៃសេចក្តីវិបរិតផ្សេង ៗ, ពីរស្វែងរកនូវទ្រព្យសម្បត្តិក្នុងសំសារវដ្តដោយអំណាចនៃសេចក្តីលោភខុសជម្រា, បី ឧទ្ធច្ចំ រក្សានូវធម៌សុចរិតពុំបានដោយអំណាចនៃចិត្តរាយមាយពុំទៀង, បួន ទោសោ អាឃាតព្យាបាទគំនុំគុំគួនចងពៀរនឹងអ្នកដទៃ ដោយអំណាចនៃសេចក្តីទោស, ប្រាំ អន្ទោ បៀសបៀនឯងនឹងញ៉ាំង

បុគ្គលដទៃឲ្យបៀសចេញចាកព្រះនិព្វាន ដោយអំណាចនៃមោ-
ហាដឹកនាំឲ្យវង្វឹតវង្វេង, ប្រាំមួយ កង្ខា ផាត់ទាត់ចោលចេញ
ពុំជឿនូវគុណព្រះរតនត្រ័យ ដោយអំណាចនៃសេចក្ដីសន្ទិះ
សង្ស័យ, ប្រាំពីរ ថីនំ ដល់នូវកិរិយាដេកពុំភ្ញាក់ក្នុងសំសារ
ភព ដោយអំណាចនៃសេចក្ដីខ្ជិលច្រអូសហើយមានអំនួតអួត
ខ្លួនផង, ប្រាំបី ឧទតិ ឡើងជំនោប្រកាន់អស្មិមានះរបឹងរឹងរូស
ដោយអំណាចនៃអហង្ការនិងមមង្ការ មួយអន្លើដោយអកុសល
ចេតសិកមួយគូទៀត, ប្រាំបួន អហិរិកំ សេចក្ដីមិនខ្មើមអៀន
ខ្មាសបាប អាចហ៊ានធ្វើនូវអំពើទុច្ចរិតទាំង ៣ ពេញទំនិត
មានកោតញញើត, ដប់ អនោត្តប្បំ សេចក្ដីមិនខ្លាចតក់ស្លុត
និងបាប អាចហ៊ានធ្វើនូវអំពើទុច្ចរិតទាំង៣ឥតមានខ្លាចឡើយ
ឯធម៌ទាំង ១០ នេះបានឈ្មោះថាកិលេស ព្រោះជាគ្រឿងញ៉ាំង
ចិត្តនិងចេតសិកឲ្យសៅហ្មង បានឈ្មោះថាមលតរធម៌ ព្រោះ
ជាគ្រឿងមន្ទិលសៅហ្មងដោយវិសេស អាចបើកនូវផ្លូវអបាយ
ឲ្យសត្វទៅហើយបិទបាំងនូវផ្លូវសួគ៌និងផ្លូវព្រះនិព្វានពុំឲ្យសត្វ

ទៅបានឡើយ បុគ្គលឯណាបានសម្លាប់ផ្ដេចបង់នូវមលតរៈធម៌នេះចេញឲ្យស្រឡះ បុគ្គលនោះទៀងតែនឹងបានត្រាស់ដឹងនូវព្រះនិព្វានដោយពិត ។

លុះព្រះបរមពោធិសត្វសម្ដែងធម៌ទេសនានេះចប់ហើយ សំឡេងសព្ទសាធុការនៃទេវតាទាំងឡាយ ដ៏លាន់ឮខ្លាំងផ្សាយឡើង បីដូចជានឹងបែកធ្លាយនៃផែនដីធំ ប្រាកដក្នុងកាលនោះឯង ។

- បំណែកឯនន្ទិយក្ខ ក៏ក្រាបចុះទៀបបាទមូលនៃព្រះមហាសត្វ ហើយពោលថា សុន្ទរធីរ បពិត្រព្រះអង្គទ្រង់នូវព្យាយាមល្អសូមព្រះអង្គជាទីអាង ជាទីជ្រកកោនជាពន្លឺជាទីពឹងជាទីរឭកនៃខ្ញុំ សូមកាន់យកនូវខ្ញុំជាកូនសិស្សមែនពិត សូមព្រះអង្គជាអាចារ្យនៃខ្ញុំដោយពិត ចាប់ដើមអំពីថ្ងៃនេះទៅ ខ្ញុំនឹងធ្វើឧបការដល់ព្រះអង្គ សូមព្រះអង្គអនុគ្រោះនូវខ្ញុំដោយពិត ពោលដូច្នេះហើយក៏ក្រោកឡើងចាកទីអាសន អង្គុយនៅក្នុងទីដ៏សមគួរមួយ ។

គ្រានោះពួកនៃទេវតាទាំងឡាយ ថ្វាយបង្គំនូវព្រះពោធិសត្វ ធ្វើបទក្សិណ ៣ ជុំហើយបាត់ទៅក្នុងទីនោះមែនពិត ។

ព្រះបាទធនញ្ជយ្យកោរព្យរាជ ស្តេចលើកនូវព្រះបរមពោធិសត្វចុះអំពីធម្មាសន ហើយឱបកៀកដោយបង្កេះជប់សិរសា ហើយពោលថា បុគ្គលឯណានីមួយ គឺអាមាត្យក្តី សេនាបតីក្តី បរោហិតក្តី កូននៃស្តេចឧបរាជក្តី អគ្គមហេសីក្តី បុគ្គលជាពួកជាសំឡាញ់នៃត្រកូលមាតាបិតាជាដើមក្តី សូម្បីតែបុគ្គលមួយនាក់ក៏ពុំអាចជាទីពឹងនៃអញបានឡើយ ស្តេចពោលដូច្នេះហើយ ក៏ពនូវពោធិសត្វដោយបង្កេះឡើងគង់លើខ្នងនៃដំរីដ៏ប្រសើរ មានទង់ជាយនឹងទង់ជ្រុងនឹងស្វេត្រឆត្ត គឺបុគ្គលលើកឡើងព្រមហើយ ស្តេចក៏យាងមកកាន់នគរឥន្ទបថវិញដោយលំដាប់ ។

បំណែកឯនន្ទិយក្ខ ក៏ដើរតាមក្រោយនៃជនទាំងពួង ។

បំណែកខាងព្រះបរមពោធិសត្វ បានឃើញនូវដើមមហាសាលព្រឹក្ស ដ៏មានមែកសន្លឹកសាខាល្អ ស្ថិតនូវក្នុងទី

ជិតនៃបាពិណគ្រាមជាខាងក្រៅ ហើយក្រាបទូលទៅព្រះមហាក្សត្រិយ៍ថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គបញ្ឈប់នូវដំរីក្នុងទីនេះសិន ។

ខណនោះនន្ទិយក្ខ បានបង្អោនទោះនៅអញ្ជលីហើយស្ថិតនៅក្នុងទីចំពោះមុខនៃព្រះបរមពោធិសត្វ ។

ឯព្រះបរមពោធិសត្វ បានពោលទៅនឹងយក្ខនោះដូច្នេះថា ម្នាលយក្ខ អ្នកចូរនៅ ៗ ដើមមហាសាលព្រឹក្សនេះចុះ យើងនឹងថែរក្សាឲ្យបំណាំអាហារដល់អ្នក ។

ឯនន្ទិយក្ខនោះក៏ចូលទៅនៅអាស្រ័យនឹងដើមមហាសាលព្រឹក្សនោះឯង ។

ព្រះនរិន្ទ្រាធិបតីកោរព្យរាជ ស្តេចចុះអំពីដំរីដ៏ប្រសើរ ហើយស្តេចយាងចូលទៅកាន់ទ្វារនៃព្រះបរមរាជវាំងតាមលំដាប់ ដល់ហើយស្តេចកៀកពនូវពោធិសត្វនោះឡើងកាន់ប្រាសាទ ឲ្យព្រះពោធិសត្វអង្គុយនៅលើសីហាសនដ៏ប្រសើរស្រេចហើយ ស្តេចគង់នៅលើបល្ល័ង្កកែវដ៏ប្រសើរដោយព្រះអង្គ

ឯង ញុំាងធនញ្ជ័យសេដ្ឋីនឹងនាងសុខុមាលីទេវី ឲ្យអង្គុយនូវក្នុងទីដ៏សមគួរមួយ ហើយឲ្យបរិភោគនូវភោជនដ៏ឧត្តម ស្រេចហើយពោលថា អ្នកទាំងឡាយចូរឲ្យធនញ្ជ័យកុមារដល់អញ ចាប់ដើមអំពីនេះទៅ ធនញ្ជ័យកុមារនេះជាបុត្ររបស់អញមែនពិត ។

ឯនាងសុខុមាលីនឹងធនញ្ជ័យសេដ្ឋីជាមាតាបិតានៃព្រះបរមពោធិសត្វនោះ ក៏ព្រមតាមព្រះរាជឱង្ការក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គធ្វើដោយសមគួរតាមសព្វព្រះរាជហឫទ័យចុះ ។

ស្ដេចទ្រង់ព្រះសណ្ដាប់ហើយ ក៏ទ្រង់ស្រោចទឹកអភិសេកធនញ្ជ័យកុមារធ្វើឲ្យជាព្រះរាជបុត្ររបស់ព្រះអង្គ ហើយញុំាងជាងទាំងឡាយឲ្យសាងប្រាសាទធំមួយ រៀបថ្កល់ក្នុងទីបំពោះមុខនៃបរិស្ថានមិនឆ្ងាយប៉ុន្មានអំពីរាជមណ្ឌីរ ហើយស្ដេចព្រះរាជទានឲ្យដល់ធនញ្ជ័យកុមារនោះអាស្រ័យនៅ ព្រះទានរង្វាន់ជាប្រាក់ក្នុងមួយថ្ងៃ ៗ មួយសែន ព្រះទានទាំងយស-

សក្តិពលពាហណាជាច្រើន ហើយស្តេចធ្វើនូវស្រុកនោះឱ្យជាស្រុកសំរាប់ឡើងសួយព្រះរាជទានដល់ធនញ្ជ័យសេដ្ឋីជាបិតា ។

ចាប់ដើមអំពីកាលនោះមក ព្រះបរមពោធិសត្វក៏បានចាត់ចែងឱ្យជនទាំងឡាយចំអិននូវបាយមធុបាយាសពុំមានទឹកលាយដោយគោរសប្បិ ឱ្យដល់នន្ទិយក្តុបរិភោគក្នុងមួយថ្ងៃពីរពេលសព្វ ៗ ថ្ងៃអស់កាលជានិច្ចពុំដែលដាច់ឡើយ ព្រះបរម-ពោធិសត្វនោះសោតព្រះអង្គដល់នូវលាភយសបរិវារដ៏ប្រសើរលើសដោយអានុភាពនៃបុណ្យល្បីលាន់ឮសព្វទៅក្នុងដែនកុរុរដ្ឋទាំងអស់ជាអស្ចារ្យ ។

តមត្ថុបកាសេន្តោសត្ថាអហ សម្តេចព្រះបរមគ្រូជាម្ចាស់កាលព្រះអង្គសម្តែងនូវសេចក្តីអធិប្បាយនោះហើយ ក៏ពោលជាបទព្រះគាថាដូច្នេះ

បញ្ញាបសង្ខាកុសលាវទន្តិ  ឥក្ខត្តរាជាវិតារកាតំ
ស៊ីលំសិរិញ្ចាបិសតញ្ចធម្មោ  អន្វាយិកាបញ្ញាវតោភវន្តិ

អធិប្បាយថា ព្រះចន្ទដែលជាស្តេចនៃផ្កាយនក្ខត្តឫក្សដ៏ប្រសើរដោយវិសេសជាងផ្កាយនក្ខត្តឫក្សទាំងឡាយមានឧបមាយ៉ាងណា អ្នកប្រាជ្ញទាំងឡាយដ៏ឆ្លាសតែងពោលថាបញ្ញាជាធម្មជាតិប្រសើរដោយវិសេសជាងធម៌ទាំងឡាយមានឧបមាយ៉ាងនោះដែរ ម្យ៉ាងវិញទៀតធម៌ទាំងឡាយ ៣ គឺសីល ១ សិរី ១ ធម៌នៃសប្បុរសទាំងឡាយ ១ រមែងប្រព្រឹត្តទៅតាមបុគ្គលអ្នកមានប្រាជ្ញាដោយពិត ។ ៚

សម្តែងអំពីរឿងខេលករបញ្ហាប្រស្នាសួរអំពីធម៌ជាមង្គលដ៏ក្រៃលែង
ជាអំរប់ពីរកំចប់សេចក្តីជាសង្ខេបតែប៉ុណ្ណោះឯង

# បាយាសិរាជញ្ញសូត្រ

លោក មហា ឆន្ទ នៅវត្តប្រាង្គណ៍ ឃុំភាំងចាស់ ( ឧដុង្គ ) ខេត្តកំពង់ស្ពឺ

## ប្រែនិងរៀបរៀង

### ឧទោឃាតកថា

" ពាក្យផ្តើម "

បាយាសិរាជញ្ញសូត្រនេះ លោកមហា ឆន្ទ បានប្រែចេញពីគម្ពីរទីឃនិកាយ មហាវគ្គ រៀបរៀងសេចក្តីជាភាសាខ្មែរ ចប់ស្រេចតាំងពីក្នុងព្រះពុទ្ធសករាជ ២៤៧១ តែនៅជាសំណៅពុំទាន់បានផ្ទៀងផ្ទាត់នឹងស្រង់ចម្លងចេញដោយត្រឹមត្រូវនៅឡើយ ដោយលោកមហា ឆន្ទ ធ្លាក់ខ្លួនជាប់នៅក្នុងអំណាចព្យាធិបច្ចាមិត្រ គឺ កាសរោគ ( រោគក្អក ) រោគនេះវាចូលមកជ្រកសំងំនៅសរីរកាយរបស់លោក វាមិនព្រមងាកថយចេញ ទោះបីខ្លួនលោកមហា ឆន្ទ ទំប្រឹងប្រហារដោយគ្រឿងសស្ត្រាវុធពោល គឺ ឱសថផ្សេង ៗ ដូចម្តេច វាក៏មិនព្រម

ងាកចិយចេញ ក្រាញឃ្លៀចនៅៗនោះ ហើយវាបៀតបៀនឈ្លេចឈ្លីស៊ីជញ្ជក់សាច់ឈាម ឲ្យថមថយកំលាំងព្រមទាំងសរីរាវយវៈ ចុះបន្តិចម្តងៗដោយលំដាប់ ។ ដល់មកក្នុងព្រះពុទ្ធសករាជ ២៤៧៣ នេះ រោគនោះក៏កាន់តែមានកំលាំងខ្លាំងឡើងៗ បានផ្តាច់បង់នូវជីវិតិន្ទ្រិយ៍របស់លោកមហា ឧន្ទ ក្នុងឆ្នាំមមីទោស័កនេះ ។

កាលក្នុងពេលដែលលោកមហា ឧន្ទ រៀបនឹងទំលាយបេសំខារចេញចាកលោកនេះទៅ បានប្រារព្ធដល់ការកុសលដែលលោកបានធ្វើទុកក្នុងព្រះពុទ្ធសាសនា ជាបុញ្ញនិធិរបស់លោក ក៏នឹកមកដល់ការ ១ ដែលលោកធ្វើពុំទាន់ស្រេច គឺការប្រែព្រះសូត្រនេះឯង ទើបលោកបាននិយាយផ្តាំនឹងខ្ញុំឲ្យជួយផ្ទៀងផ្ទាត់នឹងជួយចាត់ចែងឲ្យបានសំរេចជារបស់ត្រឹមត្រូវឲ្យផង នឹងបានជាសម្បត្តិឧត្តម នាំឲ្យមានប្រយោជន៍ក្នុងព្រះពុទ្ធសាសនាតទៅ ។

ខ្ញុំក៏បានទទួលភារក្នុងការនេះ ហើយបានចាត់ចែងផ្ទៀង

ផ្ទាត់ឲ្យសរសេរចម្លងដោយត្រឹមត្រូវស្រេចហើយ បានយកទៅដឹកល់ទុកជាសម្បត្តិក្នុងព្រះរាជបណ្ណាល័យ-កម្ពុជា ដើម្បីជាប្រយោជន៍ដល់ពុទ្ធសាសនិកជនទាំងឡាយតទៅ ។

ឯសេចក្ដីប្រែជាភាសាខ្មែរនេះមិនបានត្រឹមស្មើគ្នានឹងបាឡីដែលជាគោលដើមនោះទេ ព្រោះក្នុងបាឡីមានសេចក្ដីផ្ទួនសាំដដែល ៗ ជាច្រើនអន្លើ កាលបើប្រែជាភាសាខ្មែរឲ្យសាំដដែល ៗ ដូចគ្នានឹងបាឡី ជាហេតុនាំឲ្យអផ្សុកឬធុញទ្រាន់ដល់អ្នកដែលត្រូវការមើល ។ ព្រោះហេតុនោះ ទើបបានប្រែកាត់សេចក្ដីឲ្យខ្លីបុះច្រើនអន្លើ គឺត្រង់ណាដែលសាំដដែល ៗ កាត់ចោលចេញ ត្រង់ណាក្លីពេកស្ដាប់ពុំបាន ក៏បន្ថែមបំពេញសេចក្ដីឲ្យវែងបន្តិចឡើង ដើម្បីឲ្យងាយស្ដាប់តាមសេចក្ដីដែលមានក្នុងអដ្ឋកថា ។

សេចក្ដីក្នុងព្រះសូត្រនេះ មានអត្ថនៃប្រស្នាដ៏ឧត្តមពីរោះគួរចង់ស្ដាប់ណាស់ ខ្ញុំមានសង្ឃឹមថាព្រះសូត្រនេះ កាលបើអ្នកដែលជាសិក្ខាកាម បានមើល បានអាន ឬបានស្ដាប់

ដោយយកចិត្តទុកដាក់ប្រាកដ នឹងនាំឲ្យកើតមានប្រយោជន៍ច្រើនយ៉ាងដូច្នេះ ។

១. នឹងមានសេចក្ដីស្ងប់អស្ចារ្យក្នុងចិត្ត បំពោះត្រង់សេចក្ដីដែលយើងអ្នកមើលមិនដែលបានគិតដល់ ក៏ត្រឡប់ទៅជាមានទំនងមានផ្លូវឲ្យបេះគិតដល់ទៅបាន ។

២. នឹងនាំឲ្យមានគំនិតប្រាជ្ញាវាងវៃ ដោយបានសង្កេតសេចក្ដីក្នុងប្រស្នាទាំងនោះ ហើយស្រូបយកមកទុកដាក់ក្នុងចិត្តរបស់ខ្លួន ។

៣ នឹងនាំឲ្យគំនិតអ្នកដែលធ្លាប់យល់ឃើញខុសឆ្វេងពីផ្លូវត្រូវ. ត្រឡប់ប្រែជាយល់ឃើញត្រូវតាមសេចក្ដីពិតវិញ ។

៤. នឹងនាំឲ្យអ្នកដែលមានគំនិតយល់ត្រូវស្រាប់ មានសេចក្ដីពេញចិត្តនឹងជ្រះថ្លាជាភិយ្យោភាពឡើងទៀត ។

ទីបំផុតនេះ សូមឧទ្ទិស្សផលដែលកើតឡើងអំពីកុសលកម្ម គឺការបាត់បែងផ្ទៀងផ្ទាត់ព្រះសូត្រនេះឯវាបដល់ហើយស្រេប ឲ្យបានសំរេចដល់ទៅលោកមហា ឥន្ទ ជាអ្នកប្រែ

នឹងរៀបរៀងដំបូង ដែលនិមន្តទៅបរលោកហើយ សូមឲ្យលោកបានសេចក្ដីសុខ នឹងសេចក្ដីចំរើន អស់កាលយូរអង្វែងទៅហោង ។

ថ្ងៃ ៥ ៗ ៩ ១២ មមីទោស័ក ពុទ្ធសករាជ ២៤៧៣
ត្រូវនឹងថ្ងៃ ២១ ខែអាអ៊ូត ឆ្នាំ ១៩៣០

ព្រះគ្រូសំឃវិជ្ជា ហ. ពាត អាចារ្យបង្រៀននៅសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ

ឧដ្ឋបវត្តិ — សំខេប

លោកមហាឥន្ទ កើតនៅថ្ងៃអង្គារ ១០ កើតខែអាសាឍ ឆ្នាំរកក្នុងឃុំរាំងចាស់ (ឧដុង្គ) ខណ្ឌត្រាចទង ខេត្តកំពង់ស្ពឺ មាតាឈ្មោះខៀវ បិតាឈ្មោះស៊ីន ។ កាលនៅជាកុមារតូច អាយុប្រមាណជា ១៣ ឆ្នាំបានចូលទៅសិក្សារៀនបំណោះអក្សរខ្មែរ ក្នុងទីវត្តប្រាង្គណ៍ ក្នុងឃុំ-ខេត្តជាមួយគ្នា ។ ដល់អាយុ ១៧ ឆ្នាំបានបួសជាសាមណេរហើយបានសិក្សារៀនព្រះត្រៃបិដកតមក ។ ដល់អាយុគំរប់ ២០ ឆ្នាំ

គត់ បានបំពេញឧបសម្បទាជាភិក្ខុ នៅក្នុងទីវត្តប្រាង្គណ៍ លោកគ្រូព្រះធម្មឃោសា មាស ជាព្រះឧបជ្ឈាយ៍ លោកគ្រូសមុហធម្មឃោសា យិន និងលោកគ្រូអាចារ្យ ទ្បាំង ជាឧបសម្បទាចារ្យរបស់លោកមហា ឆន្ទ ព្រះឧបជ្ឈាយ៍បានឱ្យនាមបញ្ញត្តិក្នុងឆាយាជា " ឆន្ទបេរ " ( តាមឈ្មោះដើម ) ហើយលោកបានសិក្សារៀនព្រះត្រៃបិដកតមកទៀត ។ ដល់អាយុប្រមាណជា ២៥ ឬ ២៦ ឆ្នាំ បានធ្វើជាអាចារ្យបង្ហាត់បង្រៀនព្រះត្រៃបីដកដល់ភិក្ខុសាមណេតមក ។ ដល់អាយុ ២៩ ឆ្នាំបានចូលមកប្រឡងប្រយោគព្រះត្រៃបិដកក្នុងទីវិហារវត្តព្រះកែវមរកដក្រុងភ្នំពេញក្នុងរាជព្រះករុណាព្រះបាទសម្តេចព្រះសិរីសុវត្ថិ បានបានទីជាមហា ៣ ប្រយោគ ។ តាំងអំពីនោះមក លោកមហាឆន្ទ បានចាត់ចែងបង្ហាត់បង្រៀនធម៌វិន័យ ដល់ភិក្ខុសាមណេរនឹងគ្រហស្ថទាំងឡាយជាច្រើន ហើយលោកបានតែងធម៌អាថ៌ទុជាប្រយោជន៍ក្នុងព្រះពុទ្ធសាសនាក៏ក្រែលដែរ គឺបានប្រែព្រះធម្មចក្កប្បវត្តនសូត្រ បាឡីមកជាភាសាខ្មែរ ១ ចប់ (សូត្រនេះព្រះរាជបណ្ណាល័យ បានយកមកបោះពុម្ពក្នុងសៀវភៅ

កម្ពុជសុរិយា ឆ្នាំទី២រួចហើយ) បានប្រែបាយាសិរាជញ្ញសូត្រ បាឡី (នេះ) មកជាភាសាខ្មែរ ១ ចប់ បានប្រែរថវិនីតសូត្រ ប៉ាឡីមកជាភាសាខ្មែរ ១ ចប់ និងធម៌អាថិវាយរងក្រៅពីនេះក៏ ក្រៃល ។ លោកមហា ឧន្ទ នេះ គួររាប់បញ្ចូលថាជាភិក្ខុ អង្គ ១ ដែលជាពហុស្សូតជាអ្នកមានឧស្សាហក្នុងការដែលនាំ ឲ្យព្រះពុទ្ធសាសនាចំរើនឡើង ។ ដល់មកអាយុគំរប់៤៥ឆ្នាំ ក៏ មានព្យាធិរោគគឺរោគក្អកចូលមកចាប់ដាប់ក្នុងសរីរកាយ ហើយ បៀតបៀនឲ្យថមថយកំឡាំងព្រមទាំងសរីរវិយវចុះបន្តិចម្តង ៗ ដរាបដល់អាយុគំរប់ ៤៧ ឆ្នាំ រោគនោះឯងកាន់តែបំរើនខ្លាំង ឡើង ៗ បៀតបៀនបាក់ដោតរូបលោកមហា ឧន្ទ ឲ្យដល់នូវ សេចក្តីឈឺចាប់និងក្តៅក្រហាយជាទីបំផុត ឥតមានអ្វីនឹងជួយ ការពារបានឡើយ លោកមហា ឧន្ទ ក៏ទំលាយសំខារចេញ បាកលោកនេះទៅកាន់បរលោក នៅវេលារសៀលម៉ោង ១ ក្នុង ថ្ងៃពុធ ១៤ កើតខែអាសាធ ឆ្នាំមមីទោស័កពុទ្ធសករាជ២៤៧៣ ត្រូវនឹងថ្ងៃ៩ខែស្តូយេតឆ្នាំ១៩៣០ក្នុងទីវត្តប្រាង្គណ៍ (ឧដុង្គ)។

ព្រះគ្រូសំឃវិជ្ជា ហ. ៣គ ជាអ្នករៀបរៀង

# បាយាសិរាជញ្ញសូត្រ

ទីឃនិកាយ មហាវគ្គ

ឯវម្មេសុតំ សូត្រនេះឈ្មោះបាយាសិរាជញ្ញសូត្រ គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់ហើយ ដោយអាការយ៉ាងនេះថា ក្នុងសម័យ ១ ព្រះកុមារកស្សបថេរដ៏មានអាយុ លោកនិមន្តទៅក្នុងដែនកោសល ជាមួយនឹងភិក្ខុសំឃប្រមាណ ៥០០ អង្គ បានទៅដល់សេតព្យនគរក្នុងដែនកោសល ហើយក៏គង់សំរេចឥរិយាបថទាំង ៤ ក្នុងសីសបាវ័ន គឺព្រៃដ៏ដេរដាសដោយឈើធ្នង់ នៅជាខាងជើងសេតព្យនគរ ។ រីឯសេតព្យនគរនោះ ជាស្រុកបរិបូណ៌ដោយរាជបរិភោគ នឹងបរិបូណ៌ដោយធញ្ញាហារ ជាស្រុកកុសករដោយប្រជាជន នឹងសត្វគោក្របី ដ៏រីសេះជាច្រើន ព្រមទាំងសម្បូណ៌ដោយស្មៅ ដោយឧស ដោយទឹកជាច្រើន ។

ព្រះបាទបសេនទិកោសល ទ្រង់បានព្រះរាជទានសេតព្យនគរនោះ ដល់ក្សត្រ ១ អង្គទ្រង់ព្រះនាម “បាយាសិ” មិនទាន់បានរាជាភិសេកនៅឡើយទៀជាព្រហ្មទេយ្យសម្បត្តិ គឺព្រះ-

រាជទានឲ្យជារបស់ដាច់ខាតដល់ស្ដេចបាយាសិ ៗ ក៏នៅគ្រប
គ្រងសម្បត្តិក្នុងសេតព្យនគរនោះ ។

ក្នុងសម័យនោះ ស្ដេចបាយាសិ មានគំនិតវិបលាស
យល់ឃើញខុសជាមិច្ឆាទិដ្ឋិ ថា: « នត្ថិបរោលោកោ លោក
ដទៃ ( ក្រៅពីលោកនេះ ) មិនមាន នត្ថិសត្តាឱបបាតិកា
សត្វទាំងឡាយដែលកើតក្នុងលោកនេះ តែស្លាប់ទៅហើយក៏
សូន្យលែងកើតទៀត នឹងបានទៅកើតក្នុងស្ថាននរកឬក្នុងស្ថាន
សួគ៌ឯណានោះមិនមានឡើយ នត្ថិសុកតទុក្កតានំកម្មានំផល
វិបាកោ ផលវិបាករបស់កម្មដែលបុគ្គលធ្វើល្អនឹងធ្វើអាក្រក់
ក៏មិនមាន » ។

គ្រានោះ ព្រាហ្មណ៍នឹងគហបតីទាំងឡាយដែលអាស្រ័យ
នៅក្នុងសេតព្យនគរ បានឮដំណឹងថា ព្រះកុមារកស្សប
លោកជាសាវកនៃព្រះសមណគោតម និមន្តមកជាមួយនឹង
ព្រះភិក្ខុសង្ឃប្រមាណ ៥០០ អង្គ គង់នៅក្នុងសីសបាវ័ន
ដែលនៅជាខាងជើងនៃសេតព្យនគរ ។ ម្យ៉ាងទៀត កិត្តិសព្ទ
របស់លោកនោះ ផ្សាយខ្ចរខ្ចាយទៅថា លោកជាអ្នកប្រាជ្ញ

អ្នកផ្ទៀវឆ្លាស ជាពហុស្សូត មានសំដីដ៏វិចិត្រគួរបង់ស្តាប់ មានប្រាជ្ញាវៀងវៃ លោកជាអ្នកបេះដឹង ជាអង្គព្រះអរហន្ត កិរិយាដែលបានឃើញព្រះអរហន្ត ដូចជាព្រះកុមារកស្សប នោះជាគុណប្រសើរណាស់ ។ ទើបព្រាហ្មណ៍នឹងគហបតីទាំងឡាយក៏នាំគ្នាចេញពីសេតព្យនគរនោះ ទៅជាពួក ៗ ដំរង់ទៅកាន់សីសបាវ័ន ។

ក្នុងសម័យនោះ ស្តេចបាយាសិគង់ខាងលើប្រាសាទ ទ្រង់ទតព្រះនេត្រទៅ ក៏ឃើញព្រាហ្មណ៍នឹងគហបតីទាំង-ឡាយ កំពុងតែនាំគ្នាចេញពីសេតព្យនគរ មានមុខបែទៅខាងឧត្តរទិសាភាគជាពួក ៗ ទើបត្រាស់សួរមហាអាមាត្យ ក៏បានជ្រាបដោយសព្វគ្រប់ ហើយត្រាស់បង្គាប់មហាអាមាត្យឱ្យទៅប្រាប់ពួកព្រាហ្មណ៍នឹងគហបតីទាំងនោះឱ្យរង់ចាំព្រះអង្គផងស្តេចនឹងយាងទៅកាន់សំណាក់ព្រះកុមារកស្សបថេរនោះជាមួយដែរ ។

គ្រានោះ ស្តេចបាយាសិ មានពួកព្រាហ្មណ៍នឹងគហបតីទាំងនោះហោមរោមជាបរិវារ ទ្រង់គមនាការយាងទៅដល់

ក៏សំដែងនូវសេចក្តីរាពរាយគួរសម ជាមួយនឹងព្រះកុមារកស្សបថេរ ហើយពោលប្រាស្រ័យនូវពាក្យគួរជាទីរីករាយ ហើយគង់នៅក្នុងទី ១ ដ៏សមគួរ ។ បំណែកខាងពួកព្រាហ្មណ៍នឹងគហបតីទាំងនោះ ពួកខ្លះថ្វាយបង្គំព្រះកុមារកស្សបថេរ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះធ្វើនូវសេចក្តីរាក់ទាក់គួរសមជាមួយនឹងកុមារកស្សប ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះលើកដៃប្រណម្យបំពោះទៅកាន់ព្រះកុមារកស្សប ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះប្រកាសនាមនឹងគោត្ររបស់ខ្លួន ហើយក៏អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះក៏អង្គុយស្ងៀម ៗ តែម្តងទៅ ។ បំណែកស្តេចបាយាសិ បានគង់នៅក្នុងទី ១ ដ៏សមគួរហើយក៏មានព្រះបន្ទូលបំពោះទៅព្រះកុមារកស្សបថេរថា " បពិត្រព្រះកុមារកស្សបដ៏ចំរើន ខ្ញុំព្រះករុណាតែងនិយាយយ៉ាងនេះតែងឃើញយ៉ាងនេះថា " លោកដទៃមិនមាន សត្វដែលជាឱបបាតិកទាំងឡាយមិនមាន ផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអាក្រក់ក៏មិនមាន " ( សំដីនឹងគំនិតរបស់ខ្ញុំយ៉ាង

នេះលោកម្ចាស់ នឹងយល់ឃើញថាត្រូវថាល្អថាពិតដែរ ឬក៏លោកម្ចាស់ យល់ឃើញដូចម្ដេច ) ។

ព្រះកុមារកស្សបថេរ លោកមានថេរវាចាតបមកវិញថា ថ្វាយព្រះពរមហាបពិត្រ អាត្មាភាពធ្លាប់បានឃើញ ធ្លាប់បានឮដែរ អ្នកដែលនិយាយយ៉ាងនេះ អ្នកដែលមានសេចក្ដីយល់ឃើញយ៉ាងនេះ ហេតុដូចម្ដេច បានជាគេនិយាយ គេប៉ូលចិត្តថា " លោកដទៃមិនមាន សត្វដែលជាឱបបាតិកមិនមាន ផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអាក្រក់មិនមាន ។ មហាបពិត្រ បើដូច្នោះអាត្មាភាពត្រឡប់សួរចំពោះទៅព្រះអង្គវិញក្នុងរឿងនេះ ព្រះអង្គយល់ឃើញដូចម្ដេច សូមឆ្លើយដូច្នោះចុះ ។ មហាបពិត្រ ព្រះអង្គសំគាល់ឃើញដូចម្ដេចៈ ព្រះចន្ទនឹងព្រះអាទិត្យនេះ ជាទេវតា ឬជាមនុស្សនៅក្នុងលោកនេះ ឬនៅក្នុងលោកដទៃ ។

បា. បពិត្រព្រះកុមារកស្សបដ៏ចំរើន ព្រះចន្ទនឹងព្រះអាទិត្យនេះជាទេវតា មិនមែនជាមនុស្សទេ នៅក្នុងលោកដទៃ មិនមែននៅក្នុងលោកនេះទេ ។

ក. ថ្វាយព្រះពរមហាបពិត្រ តាមដោយនូវបរិយាយដែលព្រះអង្គឆ្លើយមកនេះ មានតែត្រូវចូលចិត្តថា "លោកដទៃមាន សត្វដែលជាឱបបាតិកមាន ផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអាក្រក់មាន ។

បា. បពិត្រព្រះកុមារកស្សបដ៏ចំរើន លោកម្ចាស់មានថេរវាចាដូច្នេះក៏ពិតមែនហើយ តែខ្ញុំនៅតែមានសេចក្ដីយល់ឃើញដូចមុន ។

បា. ថ្វាយព្រះពរមហាបពិត្រ ហេតុអ្វីក៏បានជាព្រះអង្គនៅតែមានសេចក្ដីយល់ឃើញដូចមុនដដែល ព្រះអង្គនៅមានសេចក្ដីបរិយាយដូម្ដេចទៀត

បា. បពិត្រព្រះកុមារកស្សបដ៏ចំរើន បានជាខ្ញុំនៅតែមានសេចក្ដីយល់ឃើញដូចមុនដដែល ព្រោះខ្ញុំនៅមានបរិយាយដូច្នេះទៀតថា មិត្រអាមាត្យនឹងញាតិសាលោហិតទាំងឡាយរបស់ខ្ញុំ កាលដែលរស់នៅក្នុងលោកនេះ បានធ្វើនូវអំពើអកុសលកម្មទាំងឡាយ គឺសម្លាប់សត្វ, លួចទ្រព្យគេ, ប្រព្រឹត្តខុសក្នុងផ្លូវកាម, និយាយពាក្យកុហក, និយាយពាក្យបាក់

ជោតគេ, និយាយពាក្យញុះញង់គេ, និយាយពាក្យឥតប្រ-
យោជន៍, លុះក្នុងអំណាចសេចក្ដីលោភ, មានចិត្តព្យាបាទគេ,
និងមានគំនិតយល់ឃើញខុស, លុះដល់កាលមកខាងក្រោយ
អ្នកទាំងនោះមានជម្ងឺឈឺជាទម្ងន់ ខ្ញុំបានដឹងថា អ្នកទាំងនោះ
មានជម្ងឺឈឺមិនអាចនឹងត្រឡប់ជាវិញទេ ទើបខ្ញុំបានទៅនិ-
យាយនឹងអ្នកជម្ងឺទាំងនោះថា "អ្នកដ៏ចំរើន មានសមណ
ព្រាហ្មណ៍ពួកខ្លះ គេនិយាយថា អ្នកណាប្រព្រឹត្តធ្វើនូវអំពើ
អកុសលមានសម្លាប់សត្វជាដើម អ្នកនោះតែទំលាយរាងកាយ
គឺស្លាប់ទៅ នឹងទៅកើតក្នុងអបាយភូមិមាននរកជាដើម ឥឡូវ
ខ្លួនអ្នកបានធ្វើនូវអំពើអកុសលទាំងឡាយមានសម្លាប់សត្វជា
ដើមនោះហើយ បើពាក្យរបស់សមណព្រាហ្មណ៍ទាំងនោះជា
ពាក្យពិតប្រាកដមែន អ្នកឯងតែទំលាយរាងកាយស្លាប់ទៅ
នឹងទៅកើតក្នុងអបាយភូមិដោយពិត បើអ្នកទៅកើតក្នុងអបាយ
ភូមិនោះមែន អ្នកចូរត្រឡប់មកប្រាប់យើងផង ថា លោកដទៃ
មានមែន, សត្វទាំងឡាយដែលជាឱបបាតិក មានមែន, ផល
វិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអាក្រក់មានមែន ។ អ្នក

ជម្ងឺទាំងនោះបានទទួលពាក្យបណ្ដាំរបស់ខ្ញុំ ហើយក៏ធ្វើកាលកិរិយាក្ស័យទៅ ពំទ្បូវបាត់មិនឃើញត្រឡប់មកប្រាប់ បើមិនមកប្រាប់ដោយខ្លួនឯងគួរតែប្រើបំរើឲ្យមកប្រាប់ បំរើក៏មិនឃើញ " ។ បពិត្រព្រះកុមារកស្សប សេចក្ដីបរិយាយរបស់ខ្ញុំ មានយ៉ាងនេះ បានជាខ្ញុំនៅតែមានគំនិតយល់ឃើញថា "លោកដទៃមិនមាន, សត្វទាំងឡាយជាឱបបាតិក មិនមាន, ផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអាក្រក់មិនមាន " ។

កុ. ថ្វាយព្រះពរមហាបពិត្រ បើដូច្នោះអាត្មាភាព នឹងសូមសួរព្រះអង្គក្នុងប្រស្នានេះវិញ ព្រះអង្គយល់ឃើញយ៉ាងណា សូមព្រះអង្គឆ្លើយយ៉ាងនោះចុះ ព្រះអង្គសំគាល់សេចក្ដីត្រង់នេះដូចម្ដេច សេចក្ដីថា រាជបុរសទាំងឡាយចាប់ចោរដែលប្រព្រឹត្តអាក្រក់ក្នុងព្រះនគរនេះបានមក ហើយថ្វាយដល់ព្រះអង្គ ៗ ក៏ត្រាស់បង្គាប់ឲ្យចងដើមដៃទាំងពីរមកខាងក្រោយ ហើយឲ្យនាំចោរទាំងនោះចេញទៅតាមទ្វារព្រះនគរខាងត្បូង ហើយឲ្យកាត់ក្បាល ក្នុងកន្លែងដែលសំរាប់សម្លាប់ចោរ ។ រាជបុរសទាំងឡាយ កាលបើទទួលព្រះរាជអាជ្ញារបស់ព្រះអង្គ

ហើយ ក៏ធ្វើតាមព្រះរាជឱង្ការសព្វគ្រប់ ហើយឲ្យចោរនោះអង្គុយក្នុងកន្លែងដែលសំរាប់សម្លាប់ចោរ រួចក៏ផ្ទរផ្គុងនឹងសម្លាប់ ។ ចោរនោះក៏និយាយអង្វរពួកពេជ្ឈឃាដកគឺបុរសដែលជាអ្នកសម្លាប់នោះថា « បពិត្រអស់លោកទាំងឡាយ សូមលោកមេត្តាឈប់បង្អង់បន្តិចសិន ព្រោះមិត្រសម្លាញ់នឹងញាតិសាលោហិតទាំងឡាយរបស់ខ្ញុំ នៅក្នុងស្រុកនឹងនិគមឯណោះ ៗ គេនឹងមកជួបនឹងខ្ញុំក្នុងពេលនេះ ។ រីឯពួកបុរសអ្នកសម្លាប់ កាលបើចោរទួញយំអង្វរដូច្នេះ តើនឹងបង្អង់ចាំតាមពាក្យអង្វររបស់ចោរ ឬនឹងកាត់ក្បាលចោរដែលកំពុងទួញយំនោះ ព្រះអង្គ ។

ប. បពិត្រព្រះកុមារកស្សប ពួកបុរសអ្នកសម្លាប់នឹងមិនព្រមឈប់បង្អង់តាមពាក្យអង្វររបស់ចោរនោះឡើយ នឹងកាត់ក្បាលចោរ ក្នុងពេលដែលចោរកំពុងតែយំសោកអង្វរនោះឯង លោកម្ចាស់ ។

ក. ថ្វាយព្រះពរមហាបពិត្រ ចោរនោះជាមនុស្សពិតសូមអង្វរពួកបុរសអ្នកសម្លាប់ដែលមានជាតិជាមនុស្សដូចគ្នា អង្វរ

មិនបាន បំណាច់បើមិត្រអាមាត្យនឹងញាតិសាលោហិតទាំងឡាយរបស់ព្រះអង្គ ដែលធ្វើអកុសលកម្មមានសម្លាប់សត្វជាដើមហើយស្លាប់ទៅកើតក្នុងអបាយភូមិមាននរកជាដើមនឹងអង្វរពួកនិរយបាល ឲ្យឈប់បង្អង់កុំអាលឲ្យធ្វើទុក្ខទោស នាំត្រឡប់មកថ្វាយដំណឹងដល់ព្រះអង្គសិន ធ្វើម្ដេចពួកនិរយបាលនឹងព្រមឈប់បង្អង់ចាំបាន នឹងមិនព្រមតាមពាក្យអង្វរនោះឡើយ ។ ហេតុដូច្នេះ សូមព្រះអង្គជ្រាបដោយសេចក្ដីអធិប្បាយនេះចុះថា "លោកដទៃមាន សត្វទាំងឡាយជាឱបបាតិកក៏មាន ផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអាក្រក់ ក៏មាន" ។

បា. បពិត្រព្រះកុមារកស្សប លោកម្ចាស់អធិប្បាយពន្យល់សេចក្ដីមកយ៉ាងនេះ ក៏ឃើញថាពិតមែនហើយ តែខ្ញុំនៅតែមានគំនិតយល់ឃើញដដែល ថា "លោកដទៃមិនមាន សត្វទាំងឡាយជាឱបបាតិកមិនមាន ផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអាក្រក់ មិនមាន" ។

កុ. ថ្វាយព្រះពរមហាបពិត្រ ព្រះអង្គនៅមានបរិយាយដូចម្ដេចទៀត បានជាព្រះអង្គនៅតែប្រកាន់ទិដ្ឋិដូចដែល ។

៣. លោកម្ចាស់ ខ្ញុំនៅមានបរិយាយដូច្នេះទៀត ថា មិត្រអាមាត្យនឹងញាតិសាលោហិតទាំងឡាយរបស់ខ្ញុំ កាលដែលរស់នៅក្នុងលោកនេះ បានវៀរចាកអំពើអកុសលទាំង-ឡាយ មានវៀរចាកកិរិយាសម្លាប់សត្វជាដើម លុះដល់កាលមកខាងក្រោយ អ្នកទាំងនោះមានជម្ងឺឈឺជាទម្ងន់ ខ្ញុំដឹងថាអ្នកទាំងនោះមានជម្ងឺឈឺមិនអាចនឹងត្រឡប់ជាវិញទេ ក៏បានចូលទៅនិយាយនឹងអ្នកទាំងអស់នោះថា " អ្នកដ៏ចំរើន មានសមណព្រាហ្មណ៍ពួកខ្លះ គេនិយាយថា អ្នកឯណាមួយបានធ្វើនូវអំពើកុសលកម្ម មានមិនសម្លាប់សត្វជាដើម អ្នកនោះលុះរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិភូមិគឺស្ថានសួគ៌ ត-ឡូវអ្នកទាំងឡាយ បានធ្វើនូវអំពើកុសលកម្ម មានមិនសម្លាប់សត្វជាដើមហើយ បើពាក្យសមណព្រាហ្មណ៍នោះ ជាពាក្យពិតប្រាកដមែន តែអ្នកស្លាប់ទៅនឹងទៅកើតក្នុងស្ថានសួគ៌ដោយពិត បើអ្នកបានទៅកើតក្នុងស្ថានសួគ៌ហើយ អ្នកគប្បីត្រឡប់មកប្រាប់យើងឲ្យដឹងផងថា "លោកដទៃមានមែន សត្វទាំងឡាយជាឧបបាតិកមានមែន ផលវិបាករបស់កម្មដែល

សត្វធ្វើល្អនឹងធ្វើអាក្រក់មានមែន, ក៏អ្នកទាំងនោះបានទទួលពាក្យបណ្ដាំរបស់ខ្ញុំ ហើយធ្វើកាលកិរិយាក្ស័យទៅ ឥឡូវមិនឃើញត្រឡប់មកប្រាប់ បើមិនមកដោយខ្លួនឯងក៏គួរតែប្រើបំរើឲ្យមកប្រាប់ បំរើក៏មិនឃើញមក ។ បពិត្រព្រះកុមារកស្សប ខ្ញុំមានរឿងបរិយាយយ៉ាងនេះ បានជាខ្ញុំនៅតែប្រកាន់ទិដ្ឋិដូចដែល ។

កុ. ថ្វាយព្រះពរមហាបពិត្រ បើដូច្នោះអាត្មាភាពសូមនាំសេចក្ដីឧបមាមួយមកថ្វាយព្រះអង្គទៀតថា "មានបុរសម្នាក់ធ្លាក់ទៅក្នុងរណ្ដៅគូថលាមក គ្រានោះព្រះអង្គបានទតព្រះនេត្រទៅឃើញហើយ ក៏បង្គាប់រាជបុរសទាំងឡាយ ឲ្យលើកបុរសនោះឡើងអំពីរណ្ដៅលាមកនោះ ហើយឲ្យយកបន្ទះឬស្សីកៀរគូថលាមកចេញអំពីខ្លួនបុរសនោះ ហើយឲ្យដុះលាងខ្លួនបុរសនោះដោយទឹក មួយអន្លើដោយដីសំរាប់កក់បាន ៣ ដង រួចឲ្យលាបស្រឡាបខ្លួនបុរសនោះ ដោយប្រេងសម្រាប់លាបដោយលំអិតគ្រឿងក្រអូបបីដងទៀត ហើយឲ្យយកកំរងផ្កានឹងលំអិតគ្រឿងលាបគ្រឿងផាត់ នឹងសំពត់យ៉ាងល្អយ៉ាងថ្លៃ មកឲ្យ

បុរសនោះប្រដាប់តាក់តែងកាយរូបស្រេចហើយ ឡើងបុរសនោះ ឡើងកាន់ប្រាសាទ ហើយឡើងបាត់បែងបំរើបុរសនោះដោយ កាមគុណទាំង ៥ យ៉ាង ។ រាជបុរសទាំងឡាយក៏ធ្វើតាមព្រះ-រាជឱង្ការទាំងអស់ ។ ថ្វាយព្រះពរមហាបពិត្រ ព្រះអង្គសំគាល់ សេចក្ដីនេះដូចម្ដេច បុរសនោះកាលបើរួចចេញអំពីរណ្ដៅ លាមក ហើយបានប្រដាប់តាក់តែងកាយរបស់ខ្លួនដោយគ្រឿង លំអ ហើយឡើងទៅអាស្រ័យនៅខាងលើប្រាសាទ កំពុង ត្រេកត្រអាលដោយកាមគុណទាំង ៥ យ៉ាងនេះហើយ បុរស នោះនឹងមានសេចក្ដីប្រាថ្នាចង់ចុះទៅក្នុងរណ្ដៅលាមកនោះម្ដង ទៀត ឬអ្វី ។

បា. ទេលោកម្ចាស់ បុរសនោះឥតមានប្រាថ្នានឹងចង់ចុះ ទៅក្នុងរណ្ដៅលាមកនោះវិញឡើយ ព្រោះរណ្ដៅលាមកនោះ ពេញទៅដោយវត្ថុមិនស្អាត មានក្លិនស្អុយអាក្រក់គួរខ្ពើមរអើម ក្រៃពេកណាស់ ។

កុ. ថ្វាយព្រះពរមហាបពិត្រ រណ្ដៅលាមកនោះជាទី ស្មោកគ្រោកមិនស្អាតគួរខ្ពើមរអើមដល់បុរសនោះយ៉ាងណា

មនុស្សលោកក៏ជាទីស្មោកគ្រោកមិនស្អាតមានក្លិនស្អុយ គួរជាទីខ្ពើមរអើមក្រៃពេក ដល់ទេវតាទាំងឡាយ យ៉ាងនោះដែរ ។ ម្យ៉ាងទៀត មនុស្សលោកនេះមានក្លិនស្អុយ ផ្សាយឡើងទៅលើ ចម្ងាយ ១០០ យោជន៍ ដោយហេតុនេះ បានជាមិត្រអាមាត្យ នឹងញាតិសាលោហិតរបស់ព្រះអង្គ ដែលធ្វើនូវអំពើកុសល កម្មមានកិរិយាវៀរលែងសម្លាប់សត្វជាដើម ហើយធ្វើកាលកិរិ-យាក្ស័យទៅ ៗ កើតក្នុងស្ថានសួគ៌ មិនអាចនឹងត្រឡប់មក ថ្វាយដំណឹងដល់ព្រះអង្គវិញបាន ។ ហេតុដូច្នេះ សូមព្រះអង្គ ជ្រាបដោយសេចក្ដីអធិប្បាយនេះចុះ ថា « លោកដទៃមាន សត្វទាំងឡាយជាឱបបាតិក មាន ផលវិបាករបស់កម្ម ដែល សត្វធ្វើល្អនឹងធ្វើអាក្រក់ មាន» ។

៣. បពិត្រព្រះកុមារកស្សប លោកម្ចាស់អធិប្បាយ ពន្យល់មកយ៉ាងនេះ ក៏ឃើញជាត្រូវមែនហើយ ប៉ុន្តែសេចក្ដីបរិយាយរបស់ខ្ញុំនៅមានទៀត មិត្រអាមាត្យនឹងញាតិសា លោហិតរបស់ខ្ញុំ បានវៀរចាកអំពើអកុសលកម្មទាំងឡាយ មានវៀរចាកកិរិយាសម្លាប់សត្វជាដើម ដល់មានជម្ងឺឈឺជា

ទម្ងន់ខ្ញុំបានចូលទៅនិយាយថា មានសមណព្រាហ្មណ៍ពួកខ្លះ គេនិយាយថា អ្នកឯណាបានវៀរចាកអំពើអកុសលកម្មមានវៀរចាកកិរិយាសម្លាប់សត្វជាដើម អ្នកនោះដល់ទំលាយរាងកាយស្លាប់ទៅនឹងទៅកើតក្នុងស្ថានសួគ៌ នៅរួមជាមួយគ្នានឹងពួកទេវតាទាំងឡាយក្នុងស្ថានតាវតឹង្ស បើពាក្យសមណព្រាហ្មណ៍នោះជាពាក្យពិតប្រាកដមែន ខ្លួនអ្នកនេះតែទំលាយរាងកាយស្លាប់ទៅនឹងទៅកើតក្នុងស្ថានសួគ៌ នៅរួមជាមួយគ្នានឹងពួកទេវតាទាំងឡាយក្នុងស្ថានតាវតឹង្សដោយពិត អ្នកគប្បីត្រឡប់មកឲ្យដំណឹងយើងផង ។ ក៏អ្នកទាំងនោះទទួលពាក្យបណ្ដាំរបស់ខ្ញុំហើយធ្វើកាលកិរិយាក្ស័យទៅ ឥឡូវបាត់មិនឃើញត្រ-ឡប់មកឲ្យដំណឹង បើមិនមកដោយខ្លួនឯង គួរតែឲ្យបំរើមកបំរើក៏មិនឃើញមក ។ សេចក្ដីបរិយាយរបស់ខ្ញុំ នៅមានយ៉ាងនេះ បានជាខ្ញុំនៅតែប្រកាន់ទិដ្ឋិដូចដែល ។

ក. ថ្វាយព្រះពរមហាបពិត្រ បើដូច្នោះអាត្មាភាពសូមសួរព្រះអង្គវិញក្នុងប្រស្នានេះថា ១ រយឆ្នាំរបស់មនុស្សលោកនេះត្រូវជាមួយរាត្រីរបស់ទេវតានៅក្នុងស្ថានតាវតឹង្ស ៣០ រាត្រី

ទិព្យនោះជា ១ ខែ ១២ ខែទិព្យនោះជា ១ ឆ្នាំ ១ ពាន់ឆ្នាំទិព្យនោះជាអាយុរបស់ទេវតានៅក្នុងស្ថានតាវតឹង្ស ។ រីឯមិត្រអាមាត្យនឹងញាតិសាលោហិតរបស់ព្រះអង្គ ដែលបានវៀរចាកអកុសលកម្មមានមិនសម្លាប់សត្វជាដើម ហើយធ្វើកាលកិរិយាក្ស័យទៅក៏ទៅកើតក្នុងស្ថានសួគ៌ នៅរួមជាមួយគ្នានឹងពួកទេវតាក្នុងស្ថានតាវតិង្ស; បើប្រសិនព្រះអង្គបានផ្តាំមែន តែពួកទេវតាទាំងនោះគិតថា យើងនៅត្រេកត្រអាលសប្បាយដោយកាមគុណទិព្យនេះ ពីរបីរាត្រីសិនសឹមបើងទៅឲ្យដំណឹងដល់ស្តេចបាយាសិ; បើជាទេវតាពួកនោះ នៅឈប់បង្អង់តែពីរបីថ្ងៃប៉ុណ្ណោះ ឆ្នាំក្នុងមនុស្សលោកនេះកន្លងទៅ ពីរបីរយឆ្នាំទៅហើយ ។ ហេតុដូច្នេះសូមព្រះអង្គជ្រាបដោយសេចក្តីអធិប្បាយនេះចុះ ថា "លោកដទៃមាន សត្វទាំងឡាយជាឱបបាតិកមាន ផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអាក្រក់មាន" ។

បា. បពិត្រព្រះកុមារកស្សប មិនមែនដូច្នោះទេ ប្រសិនបើពួកយើងធ្វើកាលកិរិយាក្ស័យទៅអស់កាលយូរអង្វែងយ៉ាង

នេះតើទេវតាណា នឹងមកឡើងណាងដល់លោកម្ចាស់ ថាទេវតាទាំងឡាយនៅក្នុងស្ថានតាវតិំង្ស មាន ថាទេវតាទាំងឡាយក្នុងស្ថានតាវតិំង្ស មានអាយុះវែងយឺនយូរយ៉ាងនេះ ខ្ញុំមិនជឿលោកម្ចាស់ទេ ។

ក. ថ្វាយព្រះពរមហាបពិត្រ បើដូច្នោះ បុរសដែលខ្វាក់អំពីកំណើត មិនដែលមើលឃើញរូបទាំងឡាយ ដែលមានពណ៌ខ្មៅ ពណ៌ស ពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម នឹងរូបដែលស្មើនឹងមិនស្មើ នឹងរូបផ្កាយ រូបព្រះបន្ទ្រ រូបព្រះអាទិត្យ ។ បុរសខ្វាក់អំពីកំណើតនោះ និយាយថា រូបទាំងឡាយ មានរូបដែលមានពណ៌ខ្មៅ ពណ៌សជាដើម មានរូបព្រះបន្ទ្រនឹងព្រះអាទិត្យជាទីបំផុតនោះមិនមានទេ អ្នកដែលមើលទៅឃើញរូបទាំងនោះក៏មិនមាន បើប្រសិនជារូបទាំងនោះមានមែន ឬអ្នកដែលមើលទៅឃើញរូបទាំងនោះមានមែនយើងក៏គង់ដឹង គង់ស្គាល់ គង់ឃើញ ។ ថ្វាយព្រះពរមហាបពិត្រ បើបុរសខ្វាក់អំពីកំណើត និយាយដូច្នេះតើឈ្មោះថានិយាយត្រូវ ឬនិយាយខុស ព្រះអង្គ ។

ឃ. បពិត្រព្រះកុមារកស្សប ពាក្យដែលបុរសខ្វាក់ពីកំណើតនិយាយដូច្នេះមិនត្រូវទេ ព្រោះថារូបទាំងឡាយមានរូបមានពណ៌ខ្មៅជាដើម ជារូបមានប្រាកដ តែបុរសខ្វាក់អំពីកំណើតមើលមិនឃើញ ហើយក៏និយាយតាមទំនើងចិត្តរបស់ខ្លួនថាមិនដឹង មិនដែលឃើញ ដូច្នេះទៅ ។

ក. ម្នាលព្រះពរមហាបពិត្រ ព្រះអង្គឧបមាដូចជាបុរសដែលខ្វាក់អំពីកំណើតនោះឯង ព្រះអង្គមានព្រះបន្ទូលតាមសេចក្តីសំគាល់ តាមសេចក្តីយល់ឃើញរបស់ព្រះអង្គ ថា " អ្នកណាមកឲ្យដំណឹងដល់ព្រះកុមារកស្សប ថា ទេវតានៅក្នុងស្ថានតាវតិំង្សមាន ថា ទេវតានៅក្នុងស្ថានតាវតិំង្សនោះមានអាយុវែង " ដូច្នេះ ។ ម្នាលព្រះពរមហាបពិត្រ លោកដទៃឥតមានអ្នកណានឹងមើលទៅឃើញបាន ដូចសេចក្តីដែលព្រះអង្គសំគាល់ថាមើលឃើញដោយមំសចក្ខុ គឺភ្នែកប្រក្រតីនោះឡើយ ។ សមណព្រាហ្មណ៍ទាំងឡាយឯណា ដែលលោកអាស្រ័យនូវទីសេនាសនដ៏ស្ងាត់នៅក្នុងព្រៃ សមណព្រាហ្មណ៍ទាំងឡាយនោះ លោកមិនប្រមាទ លោកមាន

សេចក្ដីព្យាយាម លោកមានចិត្តបញ្ជូនត្រង់ទៅកាន់ព្រះនិព្វាន លោកជំរះនូវចក្ខុទិព្យ គឺថាលោកបាននូវចក្ខុទិព្យ ។ សមណព្រាហ្មណ៍ទាំងនោះហើយ ដែលលោកមើលឃើញ នូវលោកនេះផង នូវលោកដទៃផង នូវសត្វទាំងឡាយជាឱបបាតិកផង ដោយចក្ខុទិព្យដ៏បរិសុទ្ធស្អាត កន្លងនូវចក្ខុរបស់មនុស្ស ( សាមញ្ញ ) ។ ហេតុដូច្នេះសូមព្រះអង្គជ្រាបតាមសេចក្ដីបរិយាយនេះចុះ ថា "លោកដទៃ មាន សត្វទាំងឡាយជាឱបបាតិក មាន ផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអាក្រក់ មាន" ។

៣. បពិត្រព្រះកុមារកស្សប លោកម្ចាស់អធិប្បាយពន្យល់មកយ៉ាងនេះ គួរតែឲ្យជឿណាស់ហើយ ប៉ុន្តែការត្រេះរិះគិតរបស់ខ្ញុំក្នុងរឿងនេះនៅមានទៀត ខ្ញុំគិតឃើញថា សមណព្រាហ្មណ៍ទាំងឡាយក្នុងលោកនេះ លោកមានសីលល្អ មានគុណធម៌ល្អ លោកប្រាថ្នាចង់តែរស់នៅ លោកមិនប្រាថ្នាចង់ស្លាប់ទេ លោកប្រាថ្នាសេចក្ដីសុខ លោកខ្ពើមសេចក្ដីទុក្ខ ។ ខ្ញុំត្រេះរិះគិតទៅឃើញថា សមណព្រាហ្មណ៍ទាំងឡាយ ដែល

លោកមានសីលបរិសុទ្ធិល្អ មានគុណធម៌ល្អ លោកក៏គង់ដឹងច្បាស់ថា "សេចក្ដីប្រសើរសេចក្ដីល្អ នឹងមានដល់លោកក្នុងកាលដែលលោកស្លាប់អំពីលោកនេះទៅ" ហេតុអ្វីក៏បានជាលោកមិនបរិភោគថ្នាំពិស មិនប្រហារជីវិតខ្លួនដោយគ្រឿងសស្ត្រាវុធ មិនចងក មិនលោតទៅក្នុងជ្រោះឲ្យស្លាប់ដោយខ្លួនឯង ពីក្នុងលោកនេះទៅ នឹងទៅយករបស់ប្រសើរក្នុងបរលោកឯណោះ ឬក៏សមណព្រាហ្មណ៍ទាំងឡាយនោះ លោកមិនដឹងជា សេចក្ដីប្រសើរ សេចក្ដីល្អ នឹងមានដល់ខ្លួនលោកក្នុងកាលដែលលោកស្លាប់អំពីលោកនេះទៅទេ បានជាលោកប្រាថ្នាចង់រស់នៅ លោកមិនប្រាថ្នាសេចក្ដីស្លាប់ ។ បពិត្រព្រះកុមារកស្សប សេចក្ដីយល់ឃើញរបស់ខ្ញុំយ៉ាងនេះ បានជាខ្ញុំនៅមានសេចក្ដីប្រកាន់ថា "លោកដទៃ មិនមាន សត្វទាំងឡាយជាឱបបាតិក មិនមាន ផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអាក្រក់ មិនមាន" ។

កុ. ថ្វាយព្រះពរមហាបពិត្រ បើដូច្នោះអាត្មាភាពនឹងធ្វើសេចក្ដីឧបមាមួយថ្វាយ ។ មហាបពិត្រ កាលព្រេង-

 241

ព្រឹសពីដើម មានព្រាហ្មណ៍ម្នាក់មានឈ្មោះមិនប្រាកដ ព្រាហ្មណ៍នោះមានប្រពន្ធពីរ ប្រពន្ធទីមួយមានកូនប្រុសម្នាក់ មានអាយុប្រមាណជា ១០ ឆ្នាំ ឬ ១២ ឆ្នាំ ប្រពន្ធទីពីរក៏មានគភ៌ឡើងទៀត ។ សម័យនោះព្រាហ្មណ៍ជាបិតាធ្វើកាលកិរិយាក្ស័យទៅ ទើបមាណពជាកូននោះ ទៅនិយាយនឹងស្រីដែលជាម្ដាយចុងថា បពិត្រអ្នកដ៏ចំរើន ទ្រព្យសម្បត្តិ ស្រូវអង្ករ មាសប្រាក់ទាំងអស់នេះ ជារបស់បិតាខ្ញុំទាំងអស់ ដែលជារបស់អ្នកនោះតែបន្តិចបន្តួចក៏មិនមានទេ អ្នកចូរប្រគល់ទ្រព្យមត៌កទាំងអស់នោះឲ្យមកខ្ញុំ ។ នាងព្រាហ្មណី (ម្ដាយចុង) នោះ ក៏និយាយអង្វរឃាត់មាណពនោះថា ម្នាលកូន ចូរបាឯងឈប់បង្អង់រង់ចាំម្ដាយប្រសូតកូនមកសិន បើកូននោះជាប្រុស នឹងត្រូវបានទ្រព្យសម្បត្តិនេះ ១ ចំណែកដែរ បើកូននោះជាស្រី ក៏នឹងបានជាបាទបរិចារិកា ជាភរិយានៃបាឯង ។ លុះបន្តិចមក មាណពនោះទៅនិយាយតឿនម្ដងទៀត ជាគំរប់ពីរដង ។ នាងព្រាហ្មណី ក៏និយាយឃាត់ដូចមុន ។ លុះបន្តិចមកទៀត មាណពនោះ ទៅនិយាយតឿនតាមព្រាហ្មណីម្ដងទៀត ជា

គំរប់បីដង ។ កាលបើមាណពនិយាយតៀនអស់វារបីដង ដូច្នោះហើយ នាងព្រាហ្មណីនោះក៏កាន់កំបិតចូលទៅក្នុងបន្ទប់ ហើយវះឧទររបស់ខ្លួន ដោយប្រាថ្នាចង់ដឹងថាកូនដែលនឹងប្រសូតមកនោះជាប្រុសឬជាស្រី ។ នាងព្រាហ្មណីនោះ ធ្វើខ្លួនផង ធ្វើជីវិតរបស់ខ្លួនផង ធ្វើគភ៌ផង ធ្វើសម្បត្តិដែលខ្លួនត្រូវបានផង ឲ្យវិនាសអន្តរាយអស់ទៅ នាងព្រាហ្មណីជាស្រីពាលមិនឆ្លាស បង់បានទ្រព្យមត៌កដោយមិនត្រូវទំនង ក៏ដល់នូវសេចក្ដីវិនាសធំ មានឧបមាយ៉ាងណា ក៏ឧបម័យដូចជាព្រះអង្គជាមនុស្សពាលមិនឆ្លាស ស្វែងរកបរលោកដោយមិនត្រូវទំនង ក៏គង់នឹងដល់នូវសេចក្ដីវិនាសធំមិនខាន ។ ឯសមណព្រាហ្មណ៍ទាំងឡាយលោកមានសីលបរិសុទ្ធិល្អ លោកមានគុណធម៌ល្អ លោកមានជីវិតរស់នៅអស់កាលយូរអង្វែងទៅនោះ ព្រោះលោកនៅសោយផលបុណ្យរបស់លោកផង លោកប្រតិបត្តិដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ប្រជុំជនច្រើនផង ដើម្បីអនុគ្រោះដល់សត្វលោកផង ។ មហាបពិត្រ សូមព្រះអង្គជ្រាបតាមសេចក្ដីបរិយាយនេះចុះ ថា «លោក

ជទៃមាន, សត្វទាំងឡាយជាឱបបាតិក មាន, ផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអាក្រក់ មាន" ។

៣. បពិត្រព្រះកុមារកស្សបដ៏បំរើន លោកម្ចាស់អធិប្បាយពន្យល់មកនេះ ក៏ឃើញថាល្អមចូលចិត្តណាស់ហើយ តែខ្ញុំនៅមានសេចក្ដីបរិយាយក្នុងរឿងនេះទៀត ។ លោកម្ចាស់ រាជបុរសទាំងឡាយ បានចាប់ចោរដែលប្រព្រឹត្តអាក្រក់ក្នុងព្រះនគរនេះ យកមកឲ្យខ្ញុំ ៗ ក៏បង្គាប់ថា ឲ្យយកចោរនោះទាំងរស់ដាក់ទៅក្នុងខ្ទះ បិទមាត់ខ្ទះដោយស្បែកស្រស់ ហើយបិទពរឲ្យជិតដោយដីស្អិត ហើយឲ្យលើកដាក់ទៅលើចង្ក្រាន រួចឲ្យដុតភ្លើងឡើង ។ រាជបុរសទាំងឡាយក៏ធ្វើតាមបង្គាប់ខ្ញុំគ្រប់ប្រការ ខ្ញុំកាលបើបានដឹងថាចោរដែលនៅក្នុងខ្ទះនោះស្លាប់ហើយ ក៏បង្គាប់ឲ្យដាក់ខ្ទះនោះមកវិញ ឲ្យទំលាយដីដែលបិទពរនោះចេញ ហើយឲ្យបង្ហើបស្បែកដែលបិទមាត់ខ្ទះនោះបន្តិចម្ដងៗ ដោយប្រាថ្នានឹងសង្កេតមើលជីវិតគឺសេចក្ដីរស់នៅ (ព្រលឹង) របស់ចោរនោះដែលចេញទៅ ក៏មិនឃើញព្រលឹងនោះចេញទៅឡើយ ហេតុដូច្នេះបានជាខ្ញុំនៅតែមានសេចក្ដី

យល់ឃើញថា "បរលោកមិនមាន សត្វទាំងឡាយជាឱប-
បាតិក មិនមាន ផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអា-
ក្រក់ មិនមាន" ។

ក. ថ្វាយព្រះពរ បើដូច្នោះអាត្មាភាពសូមសួរព្រះអង្គវិញ ព្រះអង្គដែរផ្ទំស្កល់ក្នុងវេលាថ្ងៃ ព្រះអង្គដែលទ្រង់សុបិននិមិត្ត ឃើញសួនច្បារ ព្រៃព្រឹក្ស ភូមិប្រទេស និងស្រះបោក្ខរណី ដែលជាទីគាប់ព្រះហឫទ័យខ្លះដែរឬទេ ។

ខ. ខ្ញុំដែរអាស្រ័យដំណេកក្នុងវេលាថ្ងៃ ធ្លាប់ដែលឃើញសុបិននិមិត្តយ៉ាងដូច្នោះដែរ លោកម្ចាស់ ។

ក. ថ្វាយព្រះពរ ចុះក្នុងពេលដែលព្រះអង្គកំពុងផ្ទំ ស្រីទាំងឡាយមានស្រីគម និងស្រីតឿជាដើម ដែលជាអ្នករក្សាព្រះអង្គមានដែរឬអ្វី ព្រះអង្គ ។

ខ. មានដែរ លោកម្ចាស់ ។

ក. ចុះក្នុងពេលដែលព្រះអង្គកំពុងតែទ្រង់សុបិននិមិត្ត ស្រីទាំងនោះបានឃើញព្រលឹងដែលចេញពីព្រះអង្គទៅ ឬចូលមកក្នុងព្រះអង្គវិញ ដែរឬអ្វី មហាបពិត្រ ។

បា. ឱ លោកម្ចាស់អ្នកណានឹងមើលព្រលឹងនោះឃើញ ។

កុ. ថ្វាយព្រះពរមហាបពិត្រ ស្រីទាំងនោះជាមនុស្សមានជីវិតដូចព្រះអង្គដែរ មើលព្រលឹងដែលចេញពីព្រះអង្គទៅ ឬដែលចូលមកក្នុងព្រះអង្គវិញ មិនឃើញហើយ បំណាច់បើព្រលឹងដែលចេញពីមនុស្សស្លាប់ ព្រះអង្គធ្វើម្ដេចនឹងទតទៅឃើញ ហេតុដូច្នេះសូមព្រះអង្គជ្រាបថា "បរលោកមាន សត្វទាំងឡាយជាឱបបាតិកមាន ផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអាក្រក់មាន" ។

បា. បពិត្រព្រះកុមារកស្សប លោកម្ចាស់អធិប្បាយពន្យល់មកយ៉ាងនេះ ក៏ពិតមែន ហើយ តែសេចក្ដីបរិយាយរបស់ខ្ញុំក្នុងរឿងនេះនៅមានទៀត ។ លោកម្ចាស់ រាជបុរសទាំងឡាយចាប់បានចោរដែលប្រព្រឹត្តអាក្រក់ក្នុងព្រះនគរនេះ នាំមកឲ្យខ្ញុំ ៗ បានបង្គាប់ឲ្យថ្លឹងចោរនោះទាំងរស់ដោយជញ្ជីង ហើយឲ្យបាញ់សម្លាប់ដោយធ្នូ (ព្រួញ) រួចឲ្យថ្លឹងចោរដែលស្លាប់ហើយនោះម្ដងទៀត ។ ចោរនោះកាលដែលមានជីវិតរស់នៅ មានរាងកាយស្រាលល្មមផង ទន់ស្រួលផង គួរដល់

ការងារគឺធ្វើអ្វី ៗ ធ្វើបានដោយស្រួលផង លុះដល់ចោរនោះស្លាប់ទៅកាលណា ក៏មានរាងកាយធ្ងន់ណាស់ផង រឹងណាស់ផង មិនគួរដល់ការងារគឺធ្វើអ្វី ៗ ធ្វើមិនកើតផង ។ បពិត្រព្រះកុមារកស្សបដ៏ចំរើន បរិយាយរបស់ខ្ញុំនៅមានយ៉ាងនេះឯង បានជាខ្ញុំនៅមានសេចក្ដីចូលចិត្តថា "បរលោកមិនមាន សត្វទាំងឡាយជាឱបបាតិកមិនមាន ផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអាក្រក់មិនមាន" ។

កុ. ថ្វាយព្រះពរមហាបពិត្រ បើដូច្នោះអាត្មាភាពនឹងធ្វើសេចក្ដីឧបមា ១ ថ្វាយ សេចក្ដីថា បុរសម្នាក់ថ្លឹងដុំដែកដែលកំពុងក្ដៅកំពុងឆេះដោយភ្លើង ដល់មកខាងក្រោយទៅថ្លឹងដុំដែកដដែលនោះទៀត តែជាដុំដែកត្រជាក់ស្ងួតឥតមានភ្លើងឆេះ, មហាបពិត្រ ក្នុងវេលាណាហ្ន៎ ដុំដែកនោះជារបស់ស្រាលល្មមផង ទន់ស្រួលផង គួរដល់ការងារគឺធ្វើអ្វី ៗ ធ្វើបានដោយស្រួលផង ក្នុងកាលដែលដុំដែកកំពុងក្ដៅកំពុងឆេះដោយភ្លើង ឬក៏ក្នុងកាលដែលដុំដែកត្រជាក់ស្ងួត ។

បា. បពិត្រព្រះកុមារកស្សប ដុំដែកដែលប្រកបដោយ

ក្រុមជំនុំ... ទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES



គេដោជាតុនឹងវាយោធាតុ ជាដុំដែកកំពុងក្ដៅកំពុងឆេះដោយភ្លើង ដុំដែកនោះជារបស់ស្រាលល្មមផង ទន់ស្រួលផង គួរដល់ការងារស្រួលផង ដុំដែកដែលមិនប្រកបដោយតេជោធាតុនឹងវាយោធាតុ ជាដុំដែកត្រជាក់ឥតមានឆេះដោយភ្លើង ដុំដែកនោះជារបស់ធ្ងន់ណាស់ផង រឹងណាស់ផង មិនគួរដល់ការងារផង ។

ក. ថ្វាយព្រះពរមហាបពិត្រ សេចក្ដីនេះក៏មានឧបមាដូច្នោះឯង រាងកាយនេះ កាលបើប្រកបដោយអាយុផង ប្រកបដោយចំហាយនៃភ្លើងធាតុផង ប្រកបដោយវិញ្ញាណផង ក្នុងកាលឯណា រាងកាយនោះក៏ជារបស់ស្រាលល្មមផង ទន់ស្រួលផង គួរដល់ការងារស្រួលផង ក្នុងកាលនោះឯង កាលបើរាងកាយនេះឥតមានប្រកបដោយអាយុ ដោយចំហាយនៃភ្លើងធាតុដោយវិញ្ញាណទេ រាងកាយនោះជារបស់ធ្ងន់ណាស់ផង រឹងណាស់ផង មិនគួរដល់ការងារផង ។ មហាបពិត្រ តាមដោយនូវសេចក្ដីបរិយាយយ៉ាងនេះ សូមព្រះអង្គជ្រាបថា "បុរ-

លោក មាន សត្វទាំងឡាយជាឱបបាតិក មាន ផលវិបាករបស់កម្មដែលសត្វធ្វើល្អនិងធ្វើអាក្រក់ មាន ។

៣. បពិត្រព្រះកុមារកស្សបដ៏ចំរើន លោកម្ចាស់នាំសេចក្ដីឧបមាមកពន្យល់យ៉ាងនេះ ក៏ឃើញថាពិតមែនហើយ ។ ប៉ុន្តែសេចក្ដីបរិយាយរបស់ខ្ញុំនៅមានទៀត លោកម្ចាស់ រាជបុរសទាំងឡាយបានចាប់ចោរដែលធ្វើអំពើអាក្រក់ក្នុងដែននេះនាំមកឲ្យខ្ញុំ ៗក៏បានបង្គាប់ឲ្យសម្លាប់ចោរនោះ តែហាមមិនឲ្យធ្វើ ឆវី ស្បែក សាច់ សរសៃ ឆ្អឹង និងខួរក្នុងឆ្អឹង ឲ្យវិនាសខូច ដោយគិតថា ចាំសង្កេតមើលព្រលឹងរបស់ចោរដែលចេញទៅ កាលដែររាជបុរសប្រាកដនឹងសម្លាប់ចោរនោះ ខ្ញុំបានបង្គាប់ពួកអ្នកសម្លាប់ឲ្យផ្ដេកចោរនោះផ្ងាឡើង ទើបឲ្យសម្លាប់។ ពួកអ្នកសម្លាប់ក៏ធ្វើតាមបង្គាប់ ខណខ្ញុំចាំសង្កេតមើលព្រលឹងរបស់ចោរដែលចេញទៅ មិនឃើញ រួចឲ្យផ្ដេកផ្កាប់មុខទៅវិញ ក៏មើលព្រលឹងមិនឃើញ ឲ្យផ្ដេកបែរទៅខាងស្ដាំ ខាងឆ្វេង ឲ្យលើកបញ្ឈរក្បាលឡើងលើ ឲ្យសំយុងក្បាលចុះក្រោមជើងឡើងលើ ហើយពិនិត្យមើលទៀតក៏មិនឃើញ . រួចឲ្យ

គោះដោយដុំដី ដោយកំណាត់ឈើ ដោយគ្រឿងសស្ត្រា ឲ្យប្រមៀលត្រឡប់ទៅត្រឡប់មកចុះឡើង ក៏មិនឃើញព្រលឹងរបស់ចោរចេញទៅ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយរបស់ចោរដែលស្លាប់ទៅនោះនៅមានទាំងអស់ អាយតនៈខាងក្រៅគឺរូប សំឡេង ក្លិន រស ផោដ្ឋព្វ ក៏មាន តែចោរដែលស្លាប់នោះមិនឃើញរូបនោះដោយភ្នែក មិនឮសំឡេងនោះដោយត្រចៀក មិនធុំក្លិននោះដោយច្រមុះ មិនទទួលឱជារសនោះដោយអណ្ដាត មិនទទួលគ្រឿងសម្ផស្សនោះដោយកាយ ។ បពិត្រលោកម្ចាស់ សេចក្ដីបរិយាយយ៉ាងនេះ នាំឲ្យខ្ញុំបួលចិត្តប្បាស់ថា "បរលោក មិនមាន សត្វទាំងឡាយជាឱបបាតិក មិនមាន ផលវិបាករបស់កម្មដែលសត្វធ្វើល្អទឹងធ្វើអាក្រក់ មិនមាន" ។

កុ. ឋាយព្រះពរ បើដូច្នោះអាត្មាភាពនឹងនាំរឿង ១ មកធ្វើជាសេចក្ដីឧបមាថ្វាយ :- មហាបពិត្រ កាលព្រេងព្រឹលពីដើមមានបុរសម្នាក់បេះផ្លុំស័ង្ខ កាន់ស័ង្ខដើរសំដៅទៅកាន់ជនបទ ១ ដែលនៅខាងចុងដែន ហើយចូលទៅក្នុងស្រុក ១

ដែលនៅក្នុងជនបទនោះ លុះចូលទៅដល់កណ្ដាលស្រុក ក៏ឈរផ្លុំស័ង្ខនោះបីបទ រួចដាក់ស័ង្ខទៅលើផែនដី ហើយអង្គុយក្នុងទីមួយដ៏សមគួរទៅ ។ គ្រានោះ មនុស្សទាំងឡាយដែលនៅក្នុងជនបទនោះ ក៏ផ្អើលឈូឆរឡើងនិយាយគ្នាថា "ម្នាលគ្នាយើងទាំងឡាយ សំឡេងអ្វីហ្ន៎ អម្បាញមិញនេះ ពីរោះជាប់ក្នុងចិត្ត គួរឲ្យស្រណោះ គួរឲ្យស្រង៉ូតស្រងាត់ គួរឲ្យលន្លង់លន្លោច" ហើយនាំគ្នាចូលទៅឯអ្នកផ្លុំស័ង្ខ សួរថា "អ្នកដ៏ចំរើន សំឡេងអម្បាញមិញនេះ ជាសំឡេងអ្វី ក៏ពីរោះជាប់ក្នុងចិត្តម្លេះ" ។ បុរសអ្នកផ្លុំស័ង្ខប្រាប់ថាសំឡេងស័ង្ខ ។ អ្នកស្រុកទាំងនោះក៏នាំគ្នាចូលទៅឯស័ង្ខ លើកស័ង្ខនោះផ្ងាឡើងហើយនិយាយអង្វរថា "ម្នាលស័ង្ខ ចូរអ្នកបន្លឺសំឡេងមកទៀតមើល" ។ ស័ង្ខក៏មិនបន្លឺសំឡេង ។ អ្នកស្រុកទាំងនោះនាំគ្នាផ្ដេកស័ង្ខផ្កាប់ទៅវិញផង ផ្ដេកទៅខាងស្ដាំផ្ដេកទៅខាងឆ្វេងផង គោះដោយដៃ ដោយដុំដី ដោយកំណាត់ឈើ ដោយគ្រឿងសស្ត្រាផង ដើម្បីឲ្យស័ង្ខបន្លឺសំឡេងឡើង ។ ស័ង្ខក៏មិនបន្លឺឡើងនូវសំឡេង ។ មហោបពិត្រ ក្នុងលំដាប់នោះ

អ្នកផ្លុំស័ង្ខក៏គិតថា "ឳ មនុស្សទាំងឡាយនៅក្នុងជនបទនេះជាមនុស្សល្ងង់មនុស្សឆោតណាស់ហ្ន៎ ហេតុដូចម្តេចក៏ទៅស្វែងរកសំឡេងស័ង្ខដោយមិនត្រូវទំនងដូច្នេះ" ទើបបុរសអ្នកផ្លុំស័ង្ខនោះ ក៏ចាប់ស័ង្ខលើកឡើងផ្លុំបីបទ ទៀត ហើយកាន់យកស័ង្ខនោះដើរចេញពីស្រុកនោះទៅ ។ គ្រានោះ ពួកមនុស្សដែលនៅក្នុងជនបទនោះក៏បានដឹងហើយនិយាយគ្នាថា "ស័ង្ខនេះ កាលបើបានប្រកបដោយបុរសអ្នកបេះផ្លុំផង ដោយព្យាយាមគឺបុរសនោះបានផ្លុំផង ដោយខ្យល់ផង ទើបចេញសំឡេងបាន កាលបើមិនបានប្រកបដោយរបស់ទាំង ៣ យ៉ាងនេះទេ ក៏នឹងចេញសំឡេងឮមិនបាន" ។

មហាបពិត្រ កាយនេះក៏ដូច្នោះដែរ កាយរបស់មនុស្សនេះ កាលបើបានប្រកបដោយអាយុ ប្រកបដោយបំហាយនៃភ្លើងធាតុ នឹងប្រកបដោយវិញ្ញាណ ទើបឈានទៅមុខបាន ថយមកក្រោយបាន ឈរបាន អង្គុយបាន ដេកបាន ឃើញរូបដោយភ្នែកបាន ស្តាប់សំឡេងដោយត្រចៀកបាន ធុំក្លិនដោយច្រមុះបាន ទទួលឱជារសដោយអណ្តាតបាន ទទួល

សម្ផស្សដោយកាយបាន ដឹងនូវធម៌ដោយចិត្តបាន រាងកាយនេះ កាលបើមិនបានប្រកបដោយធម្មជាតិទាំង ៣ យ៉ាងនោះទេ ក៏មិនអាចនឹងសំរេចនូវឥរិយាបថទាំង ៤ គឺដេកដើរ ឈរអង្គុយបានឡើយ ឬនឹងទទួលនូវអារម្មណ៍ទាំង៦មានរូបជាដើមដោយអាយតនទាំង៦ មានភ្នែកជាដើម ក៏ពុំបាន ។ ថ្វាយព្រះពរមហាបពិត្រ តាមសេចក្ដីបរិយាយយ៉ាងនេះ សូមព្រះអង្គជ្រាបថា "បរលោក មាន សត្វទាំងឡាយជាឱបបាតិក មានផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹង ធ្វើអាក្រក់ មាន " ។

៣. បពិត្រព្រះកុមារកស្សប លោកម្ចាស់អធិប្បាយពន្យល់មកនេះ ក៏ឃើញថាពិតមែនហើយ តែសេចក្ដីបរិយាយរបស់ខ្ញុំក្នុងរឿងនេះ ទៅមានទៀត ។ លោកម្ចាស់ រាជបុរសទាំងឡាយបានចាប់ចោរដែលប្រព្រឹត្តធ្វើអំពើអាក្រក់ នាំមកឲ្យខ្ញុំ ។ បានបង្គាប់ឲ្យកោសជរី គឺសម្បុរស្បែក ដើម្បីនឹងសង្កេតរកមើលព្រលឹង មិនឃើញ រូបឲ្យពន្លះស្បែក ឲ្យអារសាច់ កាត់សរសៃ ពុះឆ្អឹង ឆ្កិះឆ្កៀលខួរក្នុងឆ្អឹង ដើម្បីរកមើលព្រលឹង ក៏មិនឃើញទៀត ។ លោកម្ចាស់ សេចក្ដី

នេះឯងនាំឲ្យខ្ញុំព្រួលចិត្តថា "បរលោកមិនមាន សត្វទាំងឡាយជាឱបបាតិកមិនមាន ផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអាក្រក់មិនមាន" ។

ក. ថ្វាយព្រះពរ បើដូច្នោះ អាត្មាភាពនឹងធ្វើសេចក្ដីឧបមាមួយថ្វាយទៀត មហាបពិត្រ កាលព្រេងព្រឹលពីដើមមានជដិលម្នាក់ ជាអ្នកបំរើភ្លើង អាស្រ័យនៅក្នុងបណ្ណសាលាប្រៀបដងព្រៃធំ ១ ។ គ្រានោះមានពួកអ្នករទេះ នៅក្នុងជនបទឯទៀតមានដំណើរចេញពីស្រុករបស់ខ្លួនទៅដោយរទេះ ទៅដាក់រទេះអាស្រ័យដំណេកក្នុងទីជុំវិញអាស្រមរបស់ជដិលអ្នកបំរើភ្លើងនោះ អស់ ១ រាត្រីហើយបររទេះចេញទៅទៀត ។ លំដាប់នោះ ជដិលអ្នកបំរើភ្លើងគិតថា អ្នករទេះគង់នឹងមានភ្លេចរបស់អ្វីខ្លះមិនខាន គិតហើយក៏ទៅឯកន្លែងគេដាក់រទេះ បានឃើញក្មេងប្រុសតូចម្នាក់ក្បាលត្រងោលគេ ផ្ដួកបោលនៅទីនោះ ក៏រើសកូនតូចនោះយកមកចិញ្ចឹមថែរក្សា ដរាបដល់កូនតូចនោះបានចំរើនវ័យឡើង មានអាយុប្រមាណជា ១០ ឆ្នាំឬ ១២ ឆ្នាំ។ សម័យនោះ ជដិលអ្នកបំរើភ្លើង ត្រូវការនឹងទៅកាន់ជនបទ

ដោយមានកិច្ចរវល់ ក៏ហៅកុមារនោះមកផ្តាំថា "កូន បិតាត្រូវការនឹងទៅកាន់ជនបទ ចូរឯងប្រតិបត្តិថែទាំបំរើភ្លើងកុំឲ្យរលត់ បើប្រសិនជារលត់ទៅ កំបិត ឧស នឹងគូពំនួតភ្លើងមាននៅនេះស្រាប់ហើយ ចូរឯងបង្កាត់ភ្លើងឲ្យឆេះឡើងវិញ លុះផ្តាំទុកដាក់ស្រេចហើយ ក៏ចូលទៅកាន់ជនបទទៅ ។ ឯកុមារតូចដែលនៅចាំអាស្រម ក៏ខ្វល់ខ្វាយតែនឹងការលេងភ្លេចថែរក្សាភ្លើង ៗ ក៏រលត់អស់ទៅ កុមារនោះឃើញភ្លើងរលត់ដូច្នោះ ក៏នឹកដល់ពាក្យដដែលជាបិតាផ្តាំទុក ថាបើភ្លើងនេះរលត់ កំបិត ឧស នឹងគូពំនួតភ្លើងមាននៅនេះស្រាប់ ឲ្យបង្កាត់ឡើង ៗ លុះនឹកដូច្នោះហើយ ក៏យកកំបិតមកប្រាសពំនួតភ្លើង រកមើលភ្លើង មិនឃើញមានភ្លើង ទើបពុះពំនួតភ្លើងនោះជាពីរ ជាបី ជាបួនបំរៀក រហូតដល់ដប់បំរៀកក៏មិនឃើញភ្លើង ទំពុះពំនួតភ្លើងនោះខ្ទេចខ្ទីជាបំរៀកតូច-ធំ រកមើលភ្លើងក៏មិនឃើញ ។ រីឯជដិលអ្នកបំរើភ្លើងដែលទៅកាន់ជនបទ កាលបើរួចកិច្ចរវល់ហើយ ក៏ត្រឡប់មកកាន់អាស្រមវិញ ឃើញកុមារនោះកំពុងតែពុះពំនួតភ្លើងរកភ្លើង ក៏សួរថា

កូនឯងធ្វើអ្វី ។ កុមារតូចនោះក៏និយាយរៀបរាប់ប្រាប់ជដិល ជាបិតា តាមគំនិតដែលខ្លួនគិត ។ ជដិលអ្នកបំរើភ្លើងគិតថា ឱកុមារនេះល្ងង់ណាត ជាមនុស្សមិនឆ្លាសមិនប្រសប់ ទេតើ គិត ហើយក៏ចាប់យកគូពំនួតភ្លើងពីដៃកុមារនោះមកពួតដោយខ្លួន ឯងដរាប់ដល់បានបង្កាត់ភ្លើងនោះឆេះឡើងវិញហើយប្រាប់កុមារ នោះថា "ម្នាលកូន បាឯងជាមនុស្សល្ងង់ ណាត មិនឆ្លាស សោះ ទៅពុះឯពំនួតភ្លើង រកភ្លើង ឯងធ្វើមិនត្រូវទំនងយ៉ាង នេះ តើធ្វើម្ដេចនឹងឃើញភ្លើង ។

មហាបពិត្រ កុមារៈដែលល្ងង់ ណាត មិនឆ្លាស ទៅពុះ ពំនួតភ្លើងរកភ្លើង មិនឃើញភ្លើង យ៉ាងណាមិញ ព្រះអង្គក៏ យ៉ាងនោះដែរ ព្រះអង្គជាមនុស្សល្ងង់ណាតមិនឆ្លាសទៅស្វែង រកបរលោកដោយមិនត្រូវទំនង ធ្វើម្ដេចនឹងឃើញបរលោក នោះ ។ ហេតុដូច្នេះ សូមព្រះអង្គលះបង់នូវទិដ្ឋិដ៏លាមកអាក្រក់ នេះចោលចេញ ទិដ្ឋិដ៏លាមកនេះសូមកុំកើតមានដល់ព្រះអង្គ ឡើយ ព្រោះទិដ្ឋិនេះប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បី សេចក្ដីទុក្ខអស់កាលដ៏យូរ ។

ឮ. លោកម្ចាស់ អធិប្បាយពន្យល់មកយ៉ាងនេះក៏ពិតមែនហើយ តែខ្ញុំមិនអាចនឹងលះបង់នូវទិដ្ឋិដ៏លាមកនេះចោលចេញបានឡើយ ព្រោះព្រះបាទបសេនទិកោសល នឹងស្តេចទាំងឡាយដែលនៅខាងក្រៅលោកជ្រាបថា ខ្ញុំប្រកាន់ទិដ្ឋិយ៉ាងនេះទៅហើយ ប្រសិនបើខ្ញុំលះបង់ទិដ្ឋិនេះចោលចេញសមជនទាំងឡាយនោះនឹងពោលតេះដៀលថា "ខ្ញុំនេះជាមនុស្សល្ងង់ខ្លៅមិនឆ្លាស ទៅប្រកាន់យកសេចក្តីអាក្រក់ទុកក្នុងខ្លួន" កាលបើយ៉ាងនេះ ខ្ញុំនឹងរក្សាប្រកាន់នូវទិដ្ឋិនោះ ដោយសេចក្តីក្រោធផង ដោយសេចក្តីលុបគុណផង ដោយការប្រមាទមើលងាយផង ( ជាហេតុនាំមិនឱ្យសប្បាយកាយសប្បាយចិត្ត )

ក. មហាបពិត្រ បើដូច្នោះអាត្មាភាពនឹងនាំរឿង ១ មកឧបមាថ្វាយទៀត ។ កាលព្រេងព្រឹតពីដើម មានពួកឈ្មួញរទេះធំមួយ មានរទេះ១ពាន់ នាំគ្នាចេញអំពីជនបទដែលនៅក្នុងបុរត្ថិមទិស បំពោះទៅកាន់ជនបទដែលនៅក្នុងបច្ចិមទិស ។ ឯពួករទេះនោះតែចេញទៅកាន់ទីណា ស្មៅ ឧសទឹក នឹងស្លឹកឈើស្រស់ក្នុងទីនោះ ក៏អស់រលីងទៅដោយឆាប់

រហាស់ ៗ ក្នុងរទេះទាំង ១ ពាន់នោះ មានតាយឈ្មួញពីរនាក់ ជាធំ តាយឈ្មួញម្នាក់ ៗ មានរទេះប្រាំរយ ៗ ពួកឈ្មួញទាំង នោះគិតគ្នាថា រទេះពួកយើងនេះច្រើនណាស់ បើយើងចេញទៅ ព្រមគ្នាទាំងអស់បំពោះទៅកាន់ទីណា ៗ ស្មៅ, ឧស, ទឹក, នឹង ស្លឹកឈើស្រស់ ក្នុងទីនោះ ៗ នឹងអស់ទៅដោយឆាប់រហាស់ បើដូច្នេះមានតែយើងត្រូវបំបែករទេះជា ២ បំណែក ហើយនឹង ចេញទៅ ១ បំណែកម្ដង លុះគិតព្រមគ្នាហើយក៏បំបែករទេះ នោះចេញជាពីរបំណែក ក្នុងបំណែកមួយ ៗ មានរទេះ ប្រាំរយ ៗ ។ តាយឈ្មួញបំណែកមួយដែលត្រូវចេញទៅមុន បានចាត់ចែងឲ្យមនុស្សទាំងឡាយ ផ្ទុកស្មៅ, ឧស, ទឹក, នឹង ស្លឹកឈើស្រស់ ពេញរទេះហើយក៏បរចេញទៅ បានប្រមាណ ពីរបីថ្ងៃក៏បានឃើញបុរសម្នាក់ មានសម្បុរខ្មៅ,ភ្នែកក្រហម សៀតផ្កាកុម្មុទ មានសំពត់នឹងសក់ដ៏ទទឹក បររទេះមកពីខាង មុខ មានកង់រទេះប្រឡាក់ទៅដោយទឹកនឹងដីភក់សើម ៗ ទើបសួរថា " អ្នកមកពីណា ទៅណា បុរសនោះឆ្លើយប្រាប់ មកវិញថា ខ្ញុំមកពីជនបទឯណោះ ទៅកាន់ជនបទឯណោះ,

តាយឈ្មោញសួរទៀតថា តាមផ្លូវទៅមុខ ទៅ មានផ្កៀងមានទឹកដក់តាមដំណាក់ឬទេ បុរសនោះប្រាប់ថា តាមផ្លូវទៅខាងមុខ មានផ្កៀងច្រើន មានទឹកដក់តាមដំណាក់រៀងទៅ ស្មៅនឹងស្លឹកឈើក៏លូតលាស់ឡើងហើយ បើអ្នកចង់ឲ្យរទេះស្រាលនឹងបរទៅបានឆាប់របាស់ អ្នកចូរទំលាក់ស្មៅ, ឧស, នឹងទឹកដែលមានក្នុងរទេះទាំងអស់នេះចោលចេញទៅ ព្រោះទៅតាមផ្លូវមានស្មៅ ទឹក នឹងឧស បរិបូណ៌ណាស់ ។ តាយឈ្មោញជាមនុស្សល្ងង់ខ្លៅ បានឮគេប្រាប់ដូច្នោះក៏ជឿតាមហើយឲ្យបើស្មៅ ឧស នឹងទឹក ពីក្នុងរទេះទាំងនោះចោលចេញអស់ រួចបររទេះទទេទៅ លុះដល់ដំណាក់ទី ១ មិនឃើញមានស្មៅ មានឧស មានទឹក ក៏ប្រឹងបររទេះបង្ហួទៅទៀត ដល់ទៅដំណាក់ទី ២, ទី ៣, ទី ៤, ទី ៥, ទី ៦, នឹងដំណាក់ ទី ៧ ក៏មិនឃើញមានស្មៅ, មានឧស, មានទឹកដូចគ្នាគ្រប់ដំណាក់ ។ មនុស្សនឹងសត្វគោក្របី ក៏ដល់នូវសេចក្ដីវិនាសធំដោយមិនមានអាហារ ឯយក្ខដែលដំណែងខ្លួនជាបុរសបាំកុហកប្រាប់ផ្លូវ ក៏

តាមមកបរិភោគមនុស្សនឹងសត្វទាំងនោះអស់រលីង នៅសេស-សល់តែឆ្អឹងគរបោលក្នុងទីនោះ ។

បំណែកនាយឈ្មួញទី២បានបង្គាប់ឲ្យមនុស្សទាំងឡាយផ្ទុកស្មៅ, ឧស, និងទឹកពេញរទេះហើយ ក៏បររេចេញទៅជាខាងក្រោយ ទៅប្រទះនឹងបុរសសម្បុរខ្មៅ ភ្នែកក្រហមនោះទៀត ។ បុរសនោះបានក្លែងនិយាយកុហកប្រាប់ដល់នាយឈ្មួញទី ២ នោះ អំពីផ្លូវទៅខាងមុខ ដូចសេចក្ដីដែលបានក្លែងនិយាយប្រាប់ដល់នាយឈ្មួញមុននោះ ។ នាយឈ្មួញទី ២ ដែលទៅក្រោយនេះជាមនុស្សមានប្រាជ្ញាឆ្លាស ស្រែកប្រាប់មនុស្សទាំងអស់នោះថា "ម្នាលគ្នាយើងទាំងឡាយ, បុរសដែលនិយាយប្រាប់ផ្លូវនេះ មិនមែនជាមិត្រសំឡាញ់ មិនមែនជាញាតិសាលោហិតអ្វីនឹងយើងទេ យើងមិនត្រូវជឿតាមពាក្យបុរសនេះឡើយ" ហើយក៏នាំគ្នាបររទេះទៅមុខទៀត មិនបានរើរបស់អ្វីមួយពីក្នុងរទេះចោលចេញឡើយ ទៅដល់ដំណាក់ទី ១, ទី ២, ទី ៣, ទី ៤, ទី ៥, ទី ៦, ក៏មិនឃើញមានស្មៅ, មានឧស, មានទឹក, ដូចពាក្យបុរសនោះប្រាប់ឡើយ

លុះទៅដល់ដំណាក់ទី ៣ ក៏ឃើញរទេះនឹងទ្រព្យសម្បត្តិនៅក្នុងរទេះ ព្រមទាំងគំនរឆ្អឹងមនុស្សនឹងឆ្អឹងសត្វនៅក្នុងទីនោះ ទីបនាយឈ្មួញទី ២ នោះបញ្ឈប់រទេះ ហៅមនុស្សទាំងអស់មកប្រាប់ថានាយឈ្មួញដែលមកមុនជាមនុស្សល្ងង់ខ្លៅ មិនឆ្លាសជាប់កលឧបាយរបស់យក្ខរាបពោត ក៏បានដល់នូវសេចក្ដីវិនាសពំទាំងអស់គ្នា លុះប្រាប់រួចហើយក៏បង្គាប់ឲ្យមនុស្សទាំងឡាយពីយកទ្រព្យដែលមានដំម្លៃថ្លៃ ៗ អំពីរទេះទាំងនោះមកដាក់ក្នុងរទេះរបស់ខ្លួន ៗ ហើយបរចេញទៅទៀត បានឆ្លងផ្លូវដែលឆ្ងាយដាច់ស្រយាលនោះទៅបានដោយសេចក្ដីសុខសួស្ដី ។

មហាបពិត្រ នាយឈ្មួញទី ១ ដែលជាអ្នកនាំឈ្មួញទាំងឡាយ ដល់នូវសេចក្ដីវិនាសធំយ៉ាងនេះ ព្រោះខ្លួនជាមនុស្សពាលល្ងង់មិនឆ្លាស មានឧបមាដូចម្ដេចមិញ ឧបមេយ្យដូចជាព្រះអង្គដ៏ជាមនុស្សពាលល្ងង់ពុំឆ្លាស គិតស្វែងរកបរលោកដោយមិនត្រូវទំនង់មិនត្រូវបែប ក៏នឹងដល់នូវសេចក្ដីវិនាសធំមិនខាន ។ម្យ៉ាងទៀត មនុស្សទាំងឡាយដែលជឿស្ដាប់ពាក្យ

នាយឈ្មួញល្ងង់ហើយដល់នូវសេចក្ដីវិនាសធំនោះ ក៏ដូចគ្នានឹងមនុស្សទាំងឡាយដែលសំគាល់នូវពាក្យរបស់ព្រះអង្គ ថាជាពាក្យគួរជឿគួរស្ដាប់ហើយនាំគ្នាកាន់តាម មនុស្សទាំងនោះគង់តែនឹងដល់នូវសេចក្ដីវិនាសធំទៅខាងមុខមិនខាន ។

មហាបពិត្រ ព្រះអង្គចូរលះបង់នូវទិដ្ឋិដ៏លាមកបោលបេញទៅ ទិដ្ឋិលាមកអាក្រក់នេះកុំកើតមានដល់ព្រះអង្គឡើយ ព្រោះទិដ្ឋិនេះប្រព្រឹត្តទៅដើម្បីកម្មមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខលំបាកអស់កាលយូរ ។

បា· លោកម្ចាស់ សំដែងសេចក្ដីឧបមាពន្យល់មកយ៉ាងនេះឃើញថាពិតមែនហើយ ប៉ុន្តែខ្ញុំមិនអាចនឹងលះបង់ទិដ្ឋិនេះបោលបេញបានឡើយ ព្រោះព្រះបាទបសេនទិកោសលនឹងស្ដេចទាំងឡាយឯទៀត លោកជ្រាបថាខ្ញុំជាអ្នកប្រកាន់ទិដ្ឋិយ៉ាងនេះទៅហើយ បើខ្ញុំលះបង់បោលទៅ នឹងមានគេះដៀលថាខ្ញុំនេះជាមនុស្សពាល មនុស្សល្ងង់ខ្លៅ មិនឆ្លាស ។

កុ· មហាបពិត្រ បើដូច្នោះអាត្មាភាពនឹងនាំរឿងមួយមកឧបមាថ្វាយទៀត: កាលព្រេងព្រឹឝ្សពីដើម មានបុរស

ម្នាក់ជាអ្នកបិញ្ចិមជ្រូក មានកាល ១ ថ្ងៃ ចេញពីស្រុករបស់ខ្លួនទៅកាន់ស្រុកដទៃ បានឃើញលាមក ( គូថ ) ជាច្រើនដែលគេផុះចោលក្នុងទី ១ ជាលាមកស្ងួតក្រៀមរឹងដោយត្រូវកំដៅថ្ងៃឥតមានធុំក្លិនស្អុយ ។ បុរសអ្នកបិញ្ចិមជ្រូកនោះ ក៏គិតថាលាមកក្រៀមនេះ គួរអញយកទៅឲ្យជ្រូកវាស៊ី គិតហើយក៏ក្រាលសម្ពត់ទៅលើផែនដី ប្រមូលលាមកក្រៀម ៗ ដាក់លើសម្ពត់វេចជាបង្វេចមួយធំ ហើយលើកឡើងទូលលើក្បាលត្រឡប់មកវិញ. កាលដែលបុរសទូលលាមកនោះ • ត្រឡប់មកដល់ពាក់កណ្ដាលផ្លូវ ក៏ជួនមហាមេឃបង្អុរភ្លៀងធំធ្លាក់ចុះមក រីឯលាមកក្រៀមដែលនៅក្នុងបង្វេចនោះ កាលបើត្រូវទឹកភ្លៀងក៏រីករលាយហៀរហូរចុះមកប្រឡាក់ខ្លួនទាំងអស់គ្មានសេសសល់អ្វី ប្រឡាក់រហូតដល់ដើមក្របកដៃ-ជើង ធុំក្លិនស្អុយអាសោចអស់ទាំងខ្លួន មនុស្សទាំងឡាយឃើញហើយគេស្ដីគេតេះដៀលថា « បុរសនេះជាមនុស្សឆ្កួតលេលាទេ ឬអ្វីបានជាវេចលាមកទូលលើក្បាលឲ្យហៀរហូរប្រឡាក់អស់ទាំងខ្លួនយ៉ាងនេះ» បុរសដែលទូលលាមកបានឮគេស្ដីឲ្យដូច្នោះ

ឆ្លើយឈ្លោះតបទៅនឹងគេវិញថា "ក្រែងតែអ្នករាល់គ្នាទើបជាមនុស្សឆ្កួតលេលា ឯយើងនេះមិនមែនឆ្កួតលេលាដូចអ្នករាល់គ្នាថានោះទេ គឺយើងទូលបំណាំទៅឲ្យជ្រូកយើងវាស៊ី ។

មហាបពិត្រ ព្រះអង្គដែលប្រកាន់ទិដ្ឋិអាក្រក់មិនព្រមលះបង់ចោល ប្រៀបដូចជាមនុស្សអ្នកចិញ្ចឹមជ្រូក ដែលទូលលាមកលើក្បាលមិនព្រមទំលាក់ចោលនោះឯង ។ ហេតុនេះសូមព្រះអង្គលះបង់នូវទិដ្ឋិអាក្រក់នេះចោលទៅ ព្រោះទិដ្ឋិអាក្រក់នេះមិនមែនជាគុណប្រយោជន៍អ្វីទេ នាំតែសេចក្តីទុក្ខលំបាកអស់កាលយូរអង្វែងមកឲ្យព្រះអង្គតែម្យាងប៉ុណ្ណោះ ។

ឬ. បពិត្រព្រះកុមារកស្សបដ៏បំរើន រឿងដែលលោកម្ចាស់នាំមកឧបមាឲ្យខ្ញុំស្តាប់នេះ ឃើញថាពិតមែនណាស់ហើយ តែខ្ញុំមិនអាចនឹងលះបង់ទិដ្ឋិដែលធ្លាប់ប្រកាន់មកយូរហើយនោះឲ្យដាច់ស្រឡះចេញពីខ្លួនទៅបានទេ ព្រោះបានជាធ្លាប់ចិត្តធ្លាប់គំនិតទៅហើយ លោកម្ចាស់ ។ ម្យ៉ាងទៀតក្សត្រទាំងឡាយ មានព្រះបាទបសេនទិកោសលជាដើម លោកជ្រាបថាខ្ញុំជាអ្នកប្រកាន់ទិដ្ឋិយ៉ាងនេះ ៗ តែខ្ញុំលះបង់

ចោលទៅ នឹងមានគេតេះដៀលខ្ញុំថា ជាមនុស្សពាលល្ងង់ខ្លៅ មិនឆ្លាស ។

ក. ថ្វាយព្រះពរ. បើដូច្នោះ អាត្មាភាពសូមនាំរឿងមួយមកឧបមាថ្វាយទៀត: កាលព្រេងព្រឹលពីដើម មានបុរសពីរអ្នកជាសំឡាញ់នឹងគ្នា បានបបួលគ្នាទៅរកស៊ីឆ្ងាយក្នុងជនបទដទៃ លុះទៅដល់ស្រុកមួយដែលគេបោះបង់ចោលនៅក្នុងជនបទនោះ ក៏បានឃើញសម្បកធ្មៃច្រើន គេចោលនៅប្រិបស្រុកនោះ ទើបសំឡាញ់ទី ១ ដែលជាអ្នកបបួលមក និយាយនឹងសំឡាញ់ទី ២ ដែលតាមមកនោះថា "សំឡាញ់, យើងមកនេះប្រាថ្នាមកធ្វើការងាររកស៊ី តទ្បូវសម្បកធ្មៃគេចោលក្នុងទីនេះគរគោកគួរយើងរើសយកទៅប្រកបការងាររបស់យើង ហើយក៏នាំគ្នាចងសម្បកធ្មៃរៀបជាសម្ពាយស្ពាយដើរទៅទៀត ដើរបន្តិចទៅបានឃើញសរសៃធ្មៃដែលគេកូតគេគៀរស្រាប់ គេចោលក្នុងទីមួយនោះច្រើន ។ សំឡាញ់ទី ១ និយាយទៅនឹងសំឡាញ់ទី ២ ថា "សុំឡាញ់, សម្បកធ្មៃដែលយើងស្ពាយមកនេះមិនល្អទេ គួរយើងចោលសម្បកធ្មៃទៅ ហើយ

យើងនឹងរើសយកសរសៃធ្មៃដែលគេកូតគៀរស្រាប់នេះវិញល្អ ជាង" ។ សំឡាញ់ទី ២ ឆ្លើយតបមកវិញថា "សំឡាញ់ បើអ្នកចង់ចោលសម្បកធ្មៃក៏ចោលតែរបស់អ្នកទៅចុះ ឯរបស់ ខ្ញុំ ៗ បានជាស្ពាយជាប់មកយូរហើយ ខ្ញុំមិនចោលទេ ខ្ជិលរើរុះ សម្ពាយ ។ សំឡាញ់ទី ១ ក៏ចោលសម្បកធ្មៃនោះទៅ ហើយ រើសយកសរសៃធ្មៃដែលគេកូតគេគៀរស្រាប់ មកវេចជា សម្ពាយស្ពាយដើរទៅទៀត ។ សំឡាញ់ទាំងពីរនាក់នោះ នាំគ្នាដើរទៅ បានដល់ទៅស្រុកគេបោះបង់ចោល ១ ទៀត ឃើញសំពត់ដែលគេត្បាញដោយសរសៃធ្មៃជាច្រើន គេចោល ក្នុងទី ១ ទើបសំឡាញ់ទី ១ បបួលសំឡាញ់ទី ២ ឲ្យចោល សម្បកធ្មៃទៅ ឲ្យយកសំពត់ដែលត្បាញដោយសរសៃធ្មៃវិញ ។ សំឡាញ់ទី ២ ក៏មិនព្រមចោល ថាស្តាយ ដ្បិតស្ពាយយូរ ណាស់មកហើយផង ខ្ជិលរើរុះសម្ពាយផង ។ សំឡាញ់ទី ១ ក៏ចោលសរសៃធ្មៃទៅ រើសយកសំពត់ដែលគេធ្វើដោយសរសៃ ធ្មៃតែម្នាក់ឯងហើយនាំគ្នាដើរទៅទៀត ទៅដល់ស្រុកគេបោះ បង់ចោល ១ ទៀត បានឃើញសម្បកឈើ. ឃើញអម្បោះ

ដែលធ្វើដោយសម្បកឈើ, យើញសម្ពត់ដែលត្បាញដោយអម្បោះធ្វើពីសម្បកឈើ, យើញក្របាស, យើញអម្បោះដែលធ្វើពីក្របាស, យើញសម្ពត់ដែលត្បាញដោយអម្បោះធ្វើពីក្រ-បាស, យើញដែក, យើញសំណ, យើញសំរិត, យើញប្រាក់ យើញមាស ដែលគេបោលក្នុងទីមួយ ក៏បបួលសំឡាញ់ទី២ ឲ្យរើសសម្បកធ្មៃដែលស្ពាយជាប់មកនោះបោលចេញទៅ ឲ្យរើសយកមាសរើបស្ពាយទៅវិញ ។ សំឡាញ់ទី ២ ក៏មិនព្រមបោលសម្បកធ្មៃនោះ ថាបានជាស្ពាយជាប់ឆ្ងាយណាស់មកហើយ បោលទៅស្តាយ ។ ឯសំឡាញ់ទី ១ នោះក៏រើបោលរបស់ដែលរើសយកមកមុន ៗ នោះចេញ ហើយត្រឡប់រើសយកមាសរើបជាសម្ពាយស្ពាយទៅវិញ ។ សំឡាញ់ទាំងពីរនាក់នាំគ្នាត្រឡប់មកកាន់ស្រុកទេសរបស់ខ្លួន ៗ វិញ ។ បុរសជាសំឡាញ់ឯណា ដែលស្ពាយសម្បកធ្មៃមក, មាតាបិតា, បុត្រភរិយា, មិត្រសំឡាញ់ របស់បុរសនោះ ឥតមានសេចក្តីរីករាយសប្បាយ មានតែទុក្ខនឹងទោមនស្សមិនបាននូវសេចក្តីសុខកាយសុខចិត្តឡើយ បុរសជាសំឡាញ់ឯណាដែលបាន

ស្តាយមាសយកមក, បិតាមាតា, បុត្រភរិយា, មិត្រសំឡាញ់របស់បុរសនោះ ក៏មានសេចក្ដីរីករាយសប្បាយគ្រប់គ្នា បានសេចក្ដីសុខកាយសុខចិត្ត ។

មហាបពិត្រ ព្រះអង្គដែលមិនព្រមលះបោលនូវទិដ្ឋិអាក្រក់ ដូចគ្នានឹងបុរសដែលស្ពាយសម្បកធ្មៃ មិនព្រមបោលសម្បកធ្មៃនោះឯង ។ ហេតុដូច្នេះ សូមព្រះអង្គលះបង់បោលនូវទិដ្ឋិដ៏លាមកអាក្រក់នេះចេញ ទិដ្ឋិដ៏លាមកនេះកុំកើតមានដល់ព្រះអង្គឡើយ ព្រោះទិដ្ឋិនេះនឹងនាំឲ្យព្រះអង្គបាននូវសេចក្ដីវិនាស សេចក្ដីមិនចំរើន នឹងនាំឲ្យបាននូវសេចក្ដីទុក្ខលំបាកអស់កាលយូរ ។

ព្រះបាទបាយាសិ បានស្ដាប់ពេរវាចាព្រះកុមារកស្សបថេរលោកនាំរឿងមកអធិប្បាយប្រៀបធៀបណែនាំឲ្យល់សេចក្ដីសព្វគ្រប់ប្រការដូច្នោះហើយ ក៏មានព្រះបន្ទូលសរសើរបំពោះទៅព្រះកុមារកស្សបថេរថា បពិត្រព្រះកុមារកស្សបដ៏ចំរើន ខ្ញុំម្ចាស់មានសេចក្ដីពេញចិត្តនឹងសេចក្ដីជ្រះថ្លា តាំងពីបានស្ដាប់សេចក្ដីឧបមាប្រៀបធៀបរបស់លោកម្ចាស់ពីខាងដើមម្ល៉េះ ប៉ុន្តែ

ខ្ញុំម្ចាស់មានប្រាថ្នាបង់ស្លាប់នូវប្រស្នាដ៏វិចិត្រពីរោះតទៅទៀត បានជាបេះតែធ្វើជាពើឈ្លៀតឆ្លើយទទឹងទាស់នឹងលោកម្ចាស់ មិនព្រមបណ្តោយតាម ។ បពិត្រព្រះកុមារកស្សប ខ្ញុំករុណាបានកន្លងផុតនូវសេចក្តីសង្ស័យហើយ ។ បពិត្រព្រះកុមារកស្សប លោកម្ចាស់បានប្រកាសធម៌ទេសនាបំភ្លឺឲ្យខ្ញុំម្ចាស់បានភ្លឺស្វាងបាន់ឃើញជាក់ច្បាស់ ( ទៅក្នុងធម៌ពិតធម៌មែន ) ដោយអនេកបរិយាយ ប្រៀបដូចជាគេធ្វើអ្វីមួយដែលផ្កាប់ឲ្យផ្ងារឡើង ពុំនោះដូចជាគេបើកនូវអ្វីមួយដែលបិទបាំងឲ្យបំហរស្រឡះឡើង ឬក៏ដូចជាគេប្រាប់ផ្លូវដល់មនុស្សដែលវង្វេងផ្លូវឲ្យស្គាល់ផ្លូវច្បាស់ឡើង ពុំនោះសោតដូចជាកាន់ប្រទីបដែលមានពន្លឺស្វាងរុងរឿង ទ្រោលបំភ្លឺទៅក្នុងទីងងឹត ឲ្យមនុស្សដែលមានភ្នែកភ្លឺបានឃើញនូវរូបទាំងពួងដោយជាក់ច្បាស់បាន ។

ព្រះបាទបាយាសិ មានព្រះបន្ទូលសរសើរធម្មទេសនាដូច្នោះហើយ ក៏បញ្ចេញវាចីភេទប្រកាសខ្លួនជាឧបាសកក្នុងព្រះពុទ្ធសាសនាថា៖

"ឯសាហំ ភោកស្សប ភគវន្តំ គោតមំ សរណំគច្ឆាមិ ធម្មញ្ច ភិក្ខុសំឃញ្ច ឧបាសកំ មំ ភវំ កស្សបោ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ។

បពិត្រព្រះកស្សបដ៏ចំរើន ខ្ញុំព្រះករុណាម្ចាស់នេះ សូមដល់នូវព្រះដ៏មានព្រះភាគព្រះនាមគោតម ព្រមទាំងព្រះធម៌នឹងព្រះសង្ឃ ថាជាទីពឹងទីរឭក សូមព្រះកស្សបដ៏ចំរើន ប្ដូរចាំទុកចុះ ថាខ្ញុំព្រះករុណាម្ចាស់ជាឧបាសក ដល់នូវព្រះរតនត្រ័យជាទីពឹងស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះតរៀងទៅ" ។

ព្រះបាទបាយាសិ ប្រកាសខ្លួនជាឧបាសកក្នុងព្រះពុទ្ធសាសនាស្រេចហើយ ក៏សួរព្រះកុមារកស្សបថេរអំពីការបូជាមហាយញ្ញថា "បពិត្រព្រះកុមារកស្សប ខ្ញុំម្ចាស់មានប្រាថ្នានឹងធ្វើនូវមហាយញ្ញ (ការបូជាធំ) សូមលោកម្ចាស់ប្រាប់ពន្យល់ខ្ញុំផង មហាយញ្ញនោះត្រូវធ្វើដូចម្ដេច ដែលនឹងនាំឲ្យបានប្រយោជន៍ នឹងនាំឲ្យបានសេចក្ដីសុខអស់កាលយូរ ។

ព្រះកុមារកស្សបថេរ ថ្វាយព្រះពរថា "មហាបពិត្រ ក្នុងវិធីធ្វើការបូជាយញ្ញ (បើ) ជនទាំងឡាយសម្លាប់គោឬ

សម្លាប់សត្វទាំងឡាយមានពពែ ជៀមនឹងជ្រូក មាន់ជាដើម សត្វទាំងឡាយផ្សេង ៗ ក៏ដល់នូវសេចក្តីវិនាសជីវិតព្រោះតែការបូជាយញ្ញនោះ ។ ឯបុគ្គលជាបដិគ្គាហក (អ្នកទទួលនូវការបូជា) ជាអ្នកមានគំនិតយល់ឃើញខុស មានសេចក្តីត្រិះរិះខុស មានវាចាខុស មានការងារខុស មានការចិញ្ចឹមជីវិតខុស មានព្យាយាមខុស មានស្មារតីដំកល់ទុកខុស មានកិរិយាដំកល់ចិត្តឲ្យនឹងខុស ។ ការបូជាយញ្ញមានសភាពយ៉ាងនេះ មិនមានផលមិនមានអានិសង្សច្រើនឡើយ ឥតមានសេចក្តីរុងរឿងដ៏ធំទូលាយផ្សាយទៅឡើយ (ព្រោះអ្នកឲ្យក៏មិនបរិសុទ្ធ អ្នកទទួលក៏មិនបរិសុទ្ធ) ។

ថ្វាយព្រះពរមហាបពិត្រ អ្នកធ្វើស្រែនាំយកពូជស្រូវនឹងនង្គ័លនោះចូលទៅក្នុងព្រៃ ហើយព្រោះពូជទៅក្នុងទីស្រែដែលមិនល្អ គឺស្រែមានទីដីក្រហេងក្រហូងមិនរាបស្មើ មានដង្កត់គល់ឈើនឹងថ្មគ្រួសរៀនច្រើន ពូជដែលសាបព្រោះទៅនោះខ្ទេចខ្ទីស្អុយរលួយដោយត្រូវខ្យល់នឹងកំដៅថ្ងៃ ហើយថែមទាំងភ្លៀងមិនស្រួល គឺភ្លៀងធ្លាក់មិនត្រូវតាមកាលតាមរដូវផង

ទៀត ។ មហាបពិត្រ បើអ្នកស្រែធ្វើស្រែយ៉ាងនេះ តើពូជដែលសាបព្រោះទៅនោះនឹងចំរើនដុះលូតលាស់បែកគុម្ពបែកសន្ទូក មានផ្កាផ្លែឡើងបានឬទេ អ្នកម្ចាស់ស្រែនោះនឹងត្រូវបាននូវផលអំពីស្រែនោះបរិបូណ៌ ដោយសេចក្តីរីករាយសប្បាយដែរ ឬដូចម្តេច ។

បា. មិនមែនដូច្នោះទេ លោកម្ចាស់ ។

កុ. ថ្វាយព្រះពរ សេចក្តីនេះមានឧបមាដូចម្តេចមិញឯការបូជាយញ្ញ ក៏មានឧបមាដូច្នោះ (ព្រោះថា) បុគ្គលអ្នកធ្វើការបូជាយញ្ញ ទៅសម្លាប់សត្វទាំងឡាយមានគោនឹងពពែជាដើម ឬថាសត្វទាំងឡាយផ្សេងៗ ដល់នូវសេចក្តីស្លាប់ព្រោះតែការបូជាយញ្ញ ចំណែកអ្នកទទួលការបូជា ក៏ជាអ្នកប្រតិបត្តិខុស មានទិដ្ឋិយល់ឃើញខុះ ទំងមានសេចក្តីត្រិះរិះខុសជាដើម ការបូជាយញ្ញមានសភាពយ៉ាងនេះមិនមានផលមិនមានអានិសង្សច្រើនទេ មិនមានសេចក្តីរុងរឿងដ៏ធំទូលាយផ្សាយចំរើនទៅទេ ។

មហាបពិត្រម្យ៉ាងទៀត ក្នុងវិធីធ្វើការបូជាយញ្ញ ជន

ទាំងឡាយ មិនបានសម្លាប់សត្វទាំងឡាយមានគោនឹងពពែជាដើម ឬថាសត្វទាំងឡាយផ្សេងៗ ក៏មិនបានដល់នូវសេចក្ដីស្លាប់ ព្រោះតែការបូជាយញ្ញនោះទេ ។ បំណែកបដិគ្គាហ (អ្នកទទួលនូវការបូជា) ជាអ្នកមានគំនិតយល់ឃើញត្រូវ មានសេចក្ដីត្រិះរិះត្រូវ មានវាចាត្រូវ មានការងារត្រូវ មានការចិញ្ចឹមជីវិតត្រូវ មានព្យាយាមត្រូវ ដំកល់ស្មារតីត្រូវ ដំកល់ចិត្តឱ្យនឹងត្រូវ ការបូជាយញ្ញ មានសភាពយ៉ាងនេះ មានផលអានអានិសង្សច្រើន មានសេចក្ដីរុងរឿងដ៏ធំទូលាយផ្សាយទៅច្រើន (ព្រោះអ្នកឱ្យក៏បរិសុទ្ធ អ្នកទទួលក៏បរិសុទ្ធ) ។

មហាបពិត្រ អ្នកធ្វើស្រែ នាំយកពូជស្រូវនឹងនង្គ័លរនាស់ចូលទៅក្នុងព្រៃ ហើយភ្ជួររាស់ព្រោះពូជទៅក្នុងស្រែដ៏ល្អ គឺស្រែមានទីដីរាបស្មើល្អ គ្មានដង្គត់គល់ឈើឬសឈើនឹងគ្រួសរៀនឡើយ ពូជដែលសាបព្រោះទៅ មិនខូចខ្ទិស្អុយរលួយដោយត្រូវខ្យល់នឹងកំដៅថ្ងៃ ភ្លៀងក៏ធ្លាក់ស្រួលល្អ គឺភ្លៀងត្រូវតាមកាលតាមរដូវ ។ មហាបពិត្រ បើអ្នកស្រែធ្វើស្រែយ៉ាងនេះ តើពូជដែលសាបព្រោះនោះនឹងបំរើនលូតលាស់

បែកគុម្ពបែកសន្លឹក មានផ្កាផ្លែល្អឡើងទេ អ្នកម្ចាស់ស្រែនឹងត្រូវបានផលអំពីស្រែនោះបរិបូណ៌ ដោយសេចក្ដីរីករាយសប្បាយដែរ ឬដូចម្ដេច ។

ឃ. បើអ្នកម្ចាស់ស្រែ បានធ្វើស្រែដោយស្រួលបួលល្អដូច្នោះត្រូវបានផលអំពីស្រែនោះ ដោយសេចក្ដីរីករាយសប្បាយជាប្រាកដ ។

ក. ថ្វាយព្រះពរ, សេចក្ដីនេះមានឧបមាដូចម្ដេចមិញឯការបូជាយញ្ញ ក៏មានឧបមេយ្យដូច្នោះ (ព្រោះថា) បុគ្គលអ្នកធ្វើការបូជាយញ្ញ មិនបានសម្លាប់សត្វទាំងឡាយមានគោនឹងពពែជាដើម ឬជាសត្វទាំងឡាយផ្សេងៗ ក៏មិនបានដល់នូវសេចក្ដីស្លាប់ ព្រោះតែការបូជាយញ្ញនោះ ។ បំណែកខាងឯអ្នកទទួលនូវការបូជា ក៏ជាអ្នកមានសេចក្ដីប្រតិបត្តិត្រូវល្អមានគំនិតយល់ឃើញត្រូវ នឹងមានសេចក្ដីត្រិះរិះត្រូវជាដើម, ការបូជាយញ្ញមានសភាពយ៉ាងនេះ មានផលមានអានិសង្សច្រើន មានសេចក្ដីរុងរឿងដ៏ធំទូលាយផ្សាយទៅច្រើន ។

លំដាប់នោះព្រះបាទបាយាសិ បានស្ដាប់ធម្មទេសនា

ដែលព្រះកុមារកស្សបលោកសំដែងទូន្មានប្រដៅដូច្នោះហើយ ក៏មានសេចក្ដីជ្រះថ្លា បាននិមន្តព្រះមហាថេរមកកាន់ព្រះរាជដំណាក់ហើយបានធ្វើទានធំអស់ ៧ ថ្ងៃ ។ ចាប់ដើមអំពីថ្ងៃនោះទៅព្រះអង្គក៏ចាត់ចែងឲ្យទានដល់សមណព្រាហ្មណ៍ និងមនុស្សកំព្រា, មនុស្សដើរផ្លូវឆ្ងាយ និងអ្នកសូមទាំងឡាយ ។

ឯទានរបស់ស្ដេចបាយាសិនោះ បំណែកខាងភោជនដែលត្រូវឲ្យគឺបាយដែលដណ្ដាំដោយចុងអង្ករលាយប្រទាលដោយកន្ទក់ មានទឹកជ្រក់ជាគំរប់ពីរមុខ ឯបំណែកខាងសំពត់ដែលត្រូវឲ្យទានគឺសំពត់ដែលមានសាច់គគ្រើម មានជាយគ្រាស់គគ្រាំងគគ្រន់ មាណពដែលជាអ្នកខ្វល់ខ្វាយចាត់ចែងឲ្យទាននោះ ឈ្មោះឧត្តរមាណព ៗ នោះកាលបើឲ្យទានរួចហើយម្ដងៗ បាននិយាយឧទ្ទិសថា "ដោយផលានិសង្សនៃទាននេះ សូមឲ្យខ្ញុំបានជួបបានឃើញស្ដេចបាយាសិ តែក្នុងលោកនេះប៉ុះដល់ទៅក្នុងបរលោក សូមកុំឲ្យខ្ញុំបានជួបបានឃើញស្ដេចបាយាសិទៀតឡើយ ។

ព្រះបាទបាយាសិ បានជ្រាបដូច្នោះហើយ ក៏ឲ្យហៅ

ឧត្តរមាណពមកហើយត្រាស់សួរថា "ម្នាលឧត្តរមាណព ហេតុអ្វីក៏អ្នកប្រាថ្នាមិនឲ្យជួបនឹងយើងទៅក្នុងបរលោក" ។

ឧត្តរមាណពក្រាបបង្គំទូលថា បានជាទូលព្រះបង្គំជាខ្ញុំប្រាថ្នាមិនឲ្យជួបនឹងព្រះអង្គទៅក្នុងបរលោក ព្រោះព្រះអង្គបាត់បែងឲ្យៗទានដោយរបស់មិនល្អ បំណែកខាងភោជនាហារ គឺ បាយដែលដណ្តាំមដោយបុងអង្ករលាយច្រឡំដោយកន្ទក់ មានទឹកជ្រក់ជាគំរប់ពីរមុខ ភោជនយ៉ាងនេះ បើជាព្រះអង្គវិញ សូមបីតែព្រះបាទ ព្រះអង្គក៏មិនប្រាថ្នាឲ្យប៉ះពាល់ត្រូវ កុំថាឡើយដល់ទៅប្រាថ្នានឹងសោយ ៗ ឯណាកើត ។ បំណែកខាងឯសំពត់ដែលឲ្យទាននោះ គឺសំពត់ដែលមានសាច់គគ្រើម មានជាយក្រាស់គគ្រាំងគគ្រន់ សំពត់យ៉ាងនេះ បើជាព្រះអង្គវិញ សូម្បីតែព្រះបាទព្រះអង្គក៏មិនប្រាថ្នាឲ្យប៉ះពាល់ត្រូវ កុំថាឡើយដល់ទៅប្រាថ្នានឹងស្លៀកដណ្តប់ ៗ ឯណាកើត ។

ព្រះបាទបាយាសិ បានទ្រង់ព្រះសណ្តាប់ពាក្យឧត្តរមាណពដូច្នោះហើយ ក៏មានព្រះរាជឱង្ការបង្គាប់ថា "ម្នាលឧត្ត-

រមាណព បើដូច្នោះចាប់ដើមអំពីថ្ងៃនេះទៅ ភោជនាហារយ៉ាងណាដែលយើងតែងបរិភោគ អ្នកចូរឲ្យទានដោយភោជនាហារយ៉ាងនោះចុះ សំពត់យ៉ាងណាដែលយើងតែងប្រើប្រះស្លៀកដណ្ដប់អ្នកចូរឲ្យទានដោយសំពត់យ៉ាងនោះចុះ" ។

ឧត្តរមាណពបានទទួលព្រះរាជឱង្ការដូច្នោះហើយ ក៏ចាត់ចែងឲ្យទានដោយភោជនាហារនឹងសំពត់អារដ៏ល្អ ៗ តាមព្រះរាជឱង្ការ ចាប់ដើមតាំងអំពីថ្ងៃនោះតរៀងទៅ ។

ព្រះបាទបាយាសិ ទ្រង់បំណាយព្រះរាជទ្រព្យឲ្យទាននោះ ប្រកបដោយអសប្បុរិសទាន ៤ យ៉ាងគឺ

១. អសក្កច្ចំទានំ ឲ្យទានដោយមិនមានសេចក្ដីគោរពគឺឲ្យទានដោយមិនមានសទ្ធា ។

២. អសហត្ថាទានំ ឲ្យទានមិនបានឲ្យដោយដៃខ្លួនឯង ។

៣. អចិត្តីកតំទានំ ឲ្យទានដោយមិនមានចិត្តលំឱតលំឱន គឺធ្វើទានដោយមិនមានផ្ចិតផ្ចង់ ធ្វើតាមតែបាន ។

៤. អបវិទ្ធំទានំ ឲ្យទានដូចជាបោះបោល គឺធ្វើទានដោយបោះឲ្យ ទំលាក់ឲ្យ ឬប្រមៀលទៅឲ្យ ។

លុះដល់ព្រះអង្គសោយព្រះទិវង្គតទៅ ក៏បានទៅកើតនៅក្នុងចាតុមហារាជិកទេវលោក អាស្រ័យនៅក្នុងសេរីសកវិមាន គឺវិមានព្រាក់ មានដើមប្រើសជុះនៅប្រែបទ្វារ ជាវិមានស្ងួតស្ងាត់ទទេ ឥតមាននាងទេវកញ្ញាណាមួយជាបរិវារឡើយ ។

ឯឧត្តរមាណពដែលជាអ្នកចាត់ចែងទាន ថ្វាយស្ដេចបាយាសិ បានធ្វើទានដោះប្រកបដោយសប្បុរិសទាន ៤ យ៉ាង គឺៈ

១. សក្កច្ចំទានំ ឲ្យទានដោយមានសេចក្ដីគោរព

២. សហត្ថាទានំ ឲ្យទានដោយដៃខ្លួនឯង

៣. ចិត្តីកតំទានំ ឲ្យទានដោយមានសេចក្ដីលំឱតលំឱន

៤. អនបវិទ្ធំទានំ ឲ្យទាន មិនដូចជាគេបោះបោលឡើយ ។

លុះដល់ទំលាយខន្ធធ្វើកាលកិរិយាក្ស័យទៅ ក៏បានទៅកើតនៅក្នុងតាវតិំង្សទេវលោក ។

ក្នុងសម័យនោះ ព្រះគុម្មារកស្សបថេរដ៏មានអាយុ លោករមែង និមន្តទៅសំណាក់ក្នុងវេលាថ្ងៃ ៗ ក្នុងសេរីសកវិមាននោះ រឿយ ៗ ។

គ្រានោះ បាយាសិទេវបុត្រ ក៏ចូលទៅថ្វាយបង្គំព្រះគុម្មារកស្សបថេរដ៏មានអាយុ ហើយស្ថិតនៅក្នុងទីមួយដ៏សមគួរ ។

ព្រះគុម្មារកស្សបថេរ លោកមានវាចាសួរថា "ម្នាលអាវុសោ អ្នកជាអ្វី ។

បា. បពិត្រលោកដ៏ចំរើន ខ្ញុំម្ចាស់ជាស្តេចឈ្មោះបាយាសិ ។

គ. ម្នាលអាវុសោ អ្នកឯងនឹងហើយឬ ដែលប្រកាន់ទិដ្ឋិមានសេចក្តីយល់ឃើញថា "បរលោក មិនមាន សត្វទាំងឡាយដែលជាឱបបាតិក មិនមាន ផលវិបាករបស់កម្មដែលសត្វធ្វើល្អនឹងធ្វើអាក្រក់ មិនមាន ។

បា. បពិត្រលោកម្ចាស់ ខ្ញុំនឹងហើយដែលជាអ្នកប្រកាន់ទិដ្ឋិដ៏លាមកយ៉ាងនេះ ប៉ុន្តែកុមារកស្សបថេរជាម្ចាស់ លោក

បានកើបទាញខ្ញុំម្ចាស់នេះ ឡើងផុតចេញពីទីផ្អិលាមកនេះ ដោយធម៌ទេសនារបស់លោក ។

គ. ម្នាលអារុំសោ បុះឧត្តរមាណពដែលជាអ្នកបាត់ដែង ទ្បូទាននោះ ទៅកើតឯណា ។

ឃ. បពិត្រលោកម្ចាស់ ឧត្តរមាណពនោះ គេបានឡើ ទានប្រកបដោយសប្បុរិសទាន ៤ យ៉ាង លុះដល់ទំលាយខន្ធ ហើយគេបានទៅកើតក្នុងតាវត្តឹង្សទេវលោកទៅហើយ ឯខ្ញុំ ម្ចាស់នេះជាម្ចាស់ទាន បានឡើទានប្រកបដោយអសប្បុរិស ទាន៤យ៉ាង លុះធ្វើកាលកិរិយាក្ស័យហើយ ក៏បានមកកើត នៅក្នុងសេរីសកវិមាន ជាវិមានសូន្យទទេ នៅក្នុងស្ថានចាតុ មហារាជិកទេវលោកនេះ ។

ហេតុដូច្នោះ បពិត្រព្រះករុណាដ៏ចំរើន បើដល់លោក ម្ចាស់និមន្តត្រឡប់ទៅកាន់ស្ថានមនុស្សលោកវិញ សូមលោក ម្ចាស់ផ្សាយដំណឹងនេះប្រាប់មនុស្សផងថា "អ្នកទាំងឡាយចូរ ឡើទានឡើប្រកបដោយសប្បុរិសទាន ៤ យ៉ាង (ទាននោះទើប

នឹងមានផលានិសង្សច្រើន) ឯស្តេចបាយាសិ ជាម្ចាស់ទាន បានឲ្យទានប្រកបដោយអសប្បុរិសទាន៤យ៉ាង តទ្បូវទៅកើត នៅក្នុងស្ថានចាតុមហារាជិកទេវលោកទៅហើយ អាស្រ័យនៅ ក្នុងសេរីសកវិមាន ជាវិមានសូន្យទទេ គតមានបរិវារដល់ មួយឡើយ (ដោយអំណាចទានរបស់ស្តេចបាយាសិនោះមាន ផលតិចតួចស្តួចស្តើងណាស់) ។ ឯឧត្តរមាណពដែលជា អ្នកចាត់ចែងទានរបស់ស្តេចបាយាសិ គេបានឲ្យទានប្រកប ដោយសប្បុរិសទាន ៤ យ៉ាង តទ្បូវបានទៅកើតនៅក្នុងស្ថាន តាវតឹង្សទេវលោកទៅហើយ (ដោយអំណាចទានរបស់ឧត្តរ មាណពនោះមានផលច្រើន) ។

ក្នុងវេលានោះ ព្រះគវម្បតិថេរដ៏មានអាយុ លោកនិមន្ត ត្រឡប់មកកាន់ស្ថានមនុស្សលោកវិញ ក៏បានផ្សាយដំណឹង នោះដល់មនុស្សទាំងឡាយ ដូចពាក្យបាយាសិទេវបុត្របាន ផ្តាំមកនោះឯង ។

ពពួកមហាជន បានស្តាប់ថេរវាចារបស់ព្រះគវម្បតិថេរ

ដូច្នោះហើយ ក៏មានចិត្តជ្រះថ្លា បានបរិច្ចាគទ្រព្យធ្វើទាន ដោយសេចក្ដីគោរព លុះទំលាយខន្ធពីមនុស្សលោកនេះទៅ ក៏បានទៅបង្កើតក្នុងទេវលោកជាច្រើន ។

រីឯនាងបរិចារិកា (មហេសី) របស់ស្ដេចបាយាសិ នាងបានឲ្យទាន ប្រកបដោយសេចក្ដីគោរព លុះទំលាយខន្ធទៅ ដោយអំណាចដែលនាងមានសេចក្ដីប្រាថ្នាចង់ជួបនឹងស្ដេចបាយាសិ ក៏បានទៅកើតក្នុងសំណាក់ស្ដេចបាយាសិនោះឯង ។ ០៚—

បាយាសិរាជញ្ញសុត្តំ និដ្ឋិតំ

បាយាសិរាជញ្ញសូត្រ ចប់តែប៉ុណ្ណេះហោង់

# រឿងសុតធនុជាតក

ព្រះញាណវិរិយ ឡុង ប្រែពីបាឡីរត្តីបញ្ញាសជាតក

## រៀបរៀងជាភាសាខ្មែរ

ហាហាបុត្តនិវត្តស្សូតិតំទំសត្ថា

ជេតវនេវិហរន្តោមារពលទមនំអារព្ភកថេសិ

កាលព្រះពុទ្ធអង្គគង់នៅជេតវនវិហារ ទ្រង់ប្រារព្ធនោការ ទូន្មានមារព្រមទាំងពលហើយសម្តែងនោគាថាដូច្នេះជាដើមថា

ហាហាបុត្តនិវត្តសុ

ដ្បិតក្នុងកាលណោះភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភា-សាលាពោលសរសើរគុណព្រះសាស្តាថា ម្នាលអ្នកដ៏មានអា-យុ ព្រះតថាគតនៃយើងទាំងឡាយ ព្រះអង្គលះបង់នោសម្បត្តិស្តេចចក្រពត្តិដដល់ក្នុងកណ្តាប់ដៃ ស្ទុះយាងចេញទៅបព្វជាតែមួយអង្គឯង គង់លើរតនបាលង្កកែវដ៏រទៀបដើមពោធិព្រឹក្ស ផ្ចាញ់បង់នោមារពលមានបរិមណ្ឌល ៣០ យោជន៍មិនធ្វើនោការបញ្ចេញវាចាក៏ប្បាំងនឹងមារ ដែលនិមិត្តនូវដៃមួយពាន់គួរ

សម្បើមគួរខ្លាចពន្លឹក ដោយយកគ្រឿងអាវុធគ្រប់ដៃនឹងសម្លេងបន្លឺផ្សេង ៗ ព្រះអង្គដល់ព្រមនូវសេចក្ដីផ្ទះប្រសើរវិសេសព្រះសាស្ដាជាគ្រូយើងមានអានុភាពច្រើនណាស់ ។

## តំសុត្វាភគវាអាគត្វា

ព្រះដ៏មានព្រះភាគបានឮនៅហេតុភិក្ខុប្រជុំគ្នា ដោយទិព្វសោតហើយយាងមកដល់ ត្រាស់សួរភិក្ខុទាំងឡាយថាអ្នករាល់គ្នាប្រជុំពោលក្នុងវេលានេះ អំពីរឿងអ្វី ភិក្ខុក្រាបទូលនៅដំណើរសេចក្ដីគ្រប់ប្រការ ព្រះសាស្ដាតបទៅវិញថាព្រះតថាគតដែលបំពេញបារមី ៣០ គ្រប់គ្រាន់ហើយឋិតនៅក្នុងសភាពជាព្រះពុទ្ធដល់នូវសេចក្ដីផ្ទះធំក្នុងកាលឥឡូវនេះ មិនជាអស្ចារ្យទេ ភិក្ខុកើយក្នុងកាលមុនលើយ ព្រះតថាគតមានពោធិញាណពុំទាន់ទុំ តថាគតទូន្មានដោយខ្លួនយក្សក៏ដល់នៅសេចក្ដីផ្ទះជាអស្ចារ្យណាស់ មានព្រះពុទ្ធដីកាតែប៉ុណ្ណោះហើយគង់ស្ងៀមនៅ ភិក្ខុទាំងពួងចង់ដឹងក៏ក្រាបទូលអារាធនា ព្រះវិជិតមារ ព្រះអង្គនាំមកនៅអតីតនិទានរឿងដែលកន្លងឆ្ងាយមកសម្ដែងប្រាប់ ។

# អតីតេភិក្ខុវេពារាណសិយំ

ម្នាលភិក្ខុទាំងឡាយកាលកន្លងទៅដ៏ឆ្ងាយ មានស្តេចមួយអង្គព្រះនាមព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី គ្រានោះអគ្គមហេសីព្រះបាទព្រហ្មទត្ត ឈ្មោះនាងកេសនីជាប្រធាននៃស្រីបរិវារ ១ ហ្មឺន ៦ ពាន់ អគ្គមហេសីនិងស្រីបរិវារមិនដែលបានកូនប្រុសឬកូនស្រីដល់ម្នាក់ឡើយ ។ លំដាប់នោះពួកអ្នកនគរចូលទៅកាន់សំណាក់ព្រះរាជាក្រាបទូលដើម្បីប្រយោជន៍នឹងរាក្សាវង្សស្តេចតទៅ ខណៈនោះស្តេចបើកសីហបញ្ជរឃើញមហាជនមកច្រើនគ្នាទ្រង់សួរថា អ្នករាល់គ្នាមករកអ្វី ។ មហាជនទាំងអស់គ្នាលើកហត្ថប្រណំក្រាបទូលថា បពិត្រព្រះសម្មតិទេពកាលបើព្រះអង្គទិវង្គតទៅ យើងរាល់គ្នាកុំព្រាគ្មានទីពឹង ព្រះអង្គចូរប្រាថ្នាផ្សងរកព្រះរាជបុត្រអាចដើម្បីដំណាររាជវង្ស ព្រះបាទព្រហ្មទត្តស្តេចទទួលតាមពាក្យមហាជនស្រេចស្តេចប្រជុំនាងទេវី និងស្រីស្នំទាំងពួងមកជួបជុំហើយមានបន្ទូលថា នាងរាល់គ្នាចូលស្តាប់នូវពាក្យយើង នាងទាំងអស់ចូរប្រាថ្នាផ្សងកូនរាល់ ៗ គ្នា ថា

បើនាងណាបានបុត្រា អញនឹងឲ្យរាជសម្បត្តិទាំងអស់ដល់នាងនោះពិត ។ នាងទេវីនឹងស្រីស្នំបានឮព្រះរាជឱង្ការស្ដេចដូច្នោះ ក៏ខំបន់ស្រន់ទេវតានៃខ្លួនរៀង ៗ ធ្វើនូវពលិកម្មដល់ទេវតាសូមបុត្ររាល់ ៗ គ្នា ។ ស្រីស្នំទាំងឡាយធ្វើការបន់ស្រន់ដូច្នោះក៏មិនបាននៅកូនស្រីកូនប្រុះដល់ម្នាក់ឡើយ ។

## អបិកេសនីទេវីនមស្សមានមេរិកគ្នា

កាលនោះនាងកេសនីទេវីធ្វើនូវនមស្សការហើយគិតថា អញគង់នឹងបានព្រះរាជបុត្រា ដល់ថ្ងៃឧបោសថពេញបូណ៌មី នាងក្រោកអំពីព្រឹកសមាទានអដ្ឋឧបោសថ បំណាយនូវកហា-បណមួយសែនតាក់តែងមហាទានឲ្យដល់ស្មូមយាចក ស្រេចហើយនាងឡើងទៅគង់លើទីអាសនារបស់ខ្លួនក្នុងផ្ទៃប្រាសាទខាងលើ អង្គុយពិចារណានូវទានសីលនៃខ្លួនទើបធ្វើសេចក្ដីប្រាថ្នាថា សីលរបស់ខ្ញុំដែលរក្សាមិនដេបមិនសៅហ្មងមិនពព្រុសពពាលទេ បុត្រាសូមមកបង្កើតក្នុងឧទរខ្ញុំកុំខាន នាងអធិដ្ឋានហើយក៏ប្រាសផ្ទុំ នាងកេសនីទេវីដែរធ្វើប្លែកអំពីស្រីដទៃដូច្នេះនេះ ពីព្រោះខ្លួននាងជាស្រីមានប្រាជ្ញាឆ្លាសវៃ ។

ក្នុងខណៈនោះអាសនាទីអង្គុយរបស់ព្រះឥន្ទក៏សម្តែងអាការក្តៅ ដោយតេជះសីលនាងកេសនីទេវីនោះ ។

អមរិន្ទទេវរាជក៏ពិចារណានូវហេតុនោះជ្រាបថា នាងកេសនីទេវីនេះសមាទាននូវអដ្ឋង្គឧបោសថ ជាស្រីរក្សាសីលប្រាថ្នាចង់បានកូនប្រុស ចាំបើដូច្នោះអញនឹងឲ្យនូវកូនដ៏ប្រសើរដល់នាងទេវីនោះ ព្រះឥន្ទក៏ពិចារណាកនូវកូនមានសភាពសមគួរដល់នាងទេវី ទើបឃើញនូវពោធិសត្វ មានអាយុជិតនឹងអស់នឹងច្យុតទៅបង្កើតក្នុងទេវលោកខាងលើ . អមរិន្ទទេវរាជស្តេចយាងទៅកាន់សំណាក់ពោធិសត្វ ក៏អញ្ជើញដោយទេវបញ្ជាថា ម្នាលទេវបុត្តប្រាកដស្មើដោយយើង អ្នកគួរទៅកាន់មនុស្សលោក កាន់យកនូវបដិសន្ធិក្នុងផ្ទៃនាងកេសនីទេវី ។

សោពោធិសត្តស្សសម្បជិប្បន្នភាវំ

ព្រះឥន្ទបានដឹងនូវពោធិសត្វទទួលអារាធនា ក៏ចុះមកអំពីទេវលោកចូលទៅកាន់ល្វែងមានសិរីរបស់ទេវីក្នុងវេលាបច្ចូសសម័យ ឲ្យបទៀបត្រចៀកដោយពាក្យថា ម្នាលនាងទេវី

នាងក្រោកឡើងអំពីព្រឹកងូតទឹកប្រដាប់កាយ ឈនូវទៀបសីហបញ្ជរ មានមុខបំពោះទៅកាន់ទ្វារ វេលានោះមានសត្វខ្លែងមួយពាំនូវផ្លែពុទ្រាមកទំលាក់ក្នុងទីបំពោះមុខនាង នាងបួលរើសនូវផ្លែពុទ្រានោះសោយ ហើយបោលគ្រាប់ទៅលើផែនដីព្រះរាជបុត្តនឹងបង្កើតក្នុងផ្ទៃនាងដោយហេតុនេះ ព្រះឥន្ទ្រឡើងហើយក៏ហោះទៅកាន់ទេវលោកវិញ ។

នាងកេសនីទេវី បានស្ដាប់នូវពាក្យនោះហើយតើនឡើងក៏មានព្រះកាយញាប់ញ័រគិតក្នុងចិត្តថា អញឃើញនូវសុបិននិមិត្តយ៉ាងនេះ ។ លុះវេលាព្រឹកឡើងនាងទេវីស្រង់ទឹកប្រ-ដាប់កាយ បើកព្រះកៅរិតាមានភក្ត្រទៅកាន់ទ្វារធំឈនៅតាមនិយមដែលព្រះឥន្ទ្រប្រាប់សព្វគ្រប់នោះ ។ ខណៈនោះព្រះឥន្ទ្រនិមិត្តខ្លួនជាភេតសត្វខ្លែង ពាំផ្លែពុទ្រាដោយជុំពុះហើរមកទម្លាក់បុះក្នុងទីបំពោះមុខនាងទេវី នាងទេវីក៏រើសផ្លែពុទ្រានោះសោយហោលនូវគ្រាប់ទៅលើផែនដី ។ គ្រានោះមានមេសេះមួយដើរទៅខាងក្រោមប្រាសាទក៏ទំពាស៊ីនូវគ្រាប់ពុទ្រានោះ ពោធិសត្វក៏បង្កើតក្នុងផ្ទៃនាងទេវីក្នុងវេលាដែលសោយ

ផ្លែពុទ្រា នោះពិត ។ ចំណែកនាងទេវីក៏ជ្រាបព្រះអង្គថាទ្រង់គភ៌ក្នុងកាលដែលពោធិសត្វច្យុតចុះមកចសន្និតក្នុងផ្ទៃ នាងយាងទៅកាន់សំណាក់ព្រះស្វាមីដោយសេចក្តីសាទរថ្វាយបង្គំក្រាបទូលថា បពិត្រក្សត្រថ្លៃប្រសើរ គភ៌សន្និតក្នុងផ្ទៃនៃខ្ញុំម្ចាស់ហើយសូមទ្រង់ជ្រាប ។ ព្រះបាទព្រហ្មទត្តជាភស្តាបានស្តាប់ពាក្យនាងទេវីមានព្រះរាជហឫទ័យត្រេកអរ ព្រះរាជទានគ្រឿងក្សាគភ៌ដល់នាងទេវី ។ ចំណែកមេសេះដែរស៊ីគ្រាប់ពុទ្រាមានផ្ទៃពោះក៏សំរាលនូវកូនមុននាងទេវី កូនសេះនោះសោតមានភ្នែកប្រាកដស្មើដោយកុណ្ឌល ហេតុនោះជនទាំងឡាយឲ្យឈ្មោះកូនសេះនោះហៅថា (មណិកក្ខ) ឯនាងទេវីមានគភ៌បរិបូណ៌គ្រប់ទសមាសហើយ ប្រសូតនូវព្រះរាជបុត្រាមានឆវីវណ្ណបីដូចជាមាស ។

ជាតក្ខណោយេវស្ស

ក្នុងកាលដែលព្រះរាជបុត្រប្រសូត ស្តេចទាំងឡាយនៅក្នុងជម្ពូទ្វីបទាំងអស់ ក៏បញ្ជូននូវកែវ ៧ ប្រការផង នូវពានដៃគ្រឿងបុណ្ណាការដទៃផងមកថ្វាយព្រះបាទព្រហ្មទត្ត ដោយ

បុញ្ញានុភាពនៃព្រះពោធិសត្វ ។ លំដាប់នោះព្រះបាទព្រហ្មទត្ត ទ្រង់ឲ្យហៅនូវព្រាហ្មណ៍ដែលស្គាល់និមិត្តឲ្យមកទំនាយលក្ខណព្រះរាជបុត្ត ។ ព្រាហ្មណ៍ទាំងឡាយមកដល់ព្យាករណ៍លក្ខណថ្វាយថា បពិត្រមហារាជមនុស្សដែលនៅក្នុងទ្វីបធំទាំង ៤ មានទ្វីបតូច ២. ពាន់ជាបរិវារចូលលើកទុកសិន មនុស្សក្នុងជម្ពូទ្វីបតែមួយ នឹងមានមនុស្សណាមួយឲ្យចេះសិល្បសាស្ត្រធ្នូ ប្រាកដស្មើដោយព្រះរាជឱរសព្រះអង្គមិនមានឡើយ ។

ព្រះបាទព្រហ្មទត្តឮព្រាហ្មណ៍ព្យាករណ៍ដូច្នោះ ទ្រង់ថ្វាយព្រះនាមព្រះរាជបុត្តឈ្មោះ (សុធនុកុមារ) សុធនុកុមារចំរើនធំឡើងចេះសិល្បសាស្ត្រធ្នូមត់ចត់មិនមានអ្នកណាមួយស្មើបានឡើយ ។ ឪពុកធំពោធិសត្វមានកូនពីរនាក់ កូនប្រុសឈ្មោះសេតបកុមារ កូនស្រីឈ្មោះនាងករេណុវតី ជាប្អូនសេតបកុមារ ។

បំណែកឯនាងករេណុវតីនោះមានរូបល្អគួរទស្សនាជាទីជ្រះថ្លាមានពណ៌ដូចផ្កាឈូក ប្រកបដោយយសសមគួរដល់ពោធិសត្វ ក្នុងសម័យមួយពោធិសត្វលេងជាមួយនឹងសេតប

កុមារជាប្អូន ហើយគូនូវរូបស្រីមួយនិយាយបំអន់នឹងប្អូនថា ខ្លួនយើងមិនដែលឃើញប្អូនស្រីអ្នកឯង អ្នកមើលនូវរូបដែលយើងគូនេះដូចប្អូនស្រីអ្នកឬទេ សេតបកុមារជាប្អូនតបទៅកាន់ពោធិសត្វថា ប្អូនស្រីខ្ញុំព្រះអង្គធ្លាប់ឃើញបានជាគូដូច ប្អូនក៏ពោលនូវពាក្យដទៃផ្សេងៗ ជាមួយនឹងពោធិសត្វ ។

ជវិកៈគកាលេ

កាលកន្លងទៅជាយូរ ដោយប្រការដូច្នេះ ពោធិសត្វបានព្រះជន្ម ១៦ វស្សា ព្រះបាទព្រហ្មទត្តជាបិតាទ្រង់ទិវង្គតទៅ អ្នកនគរទាំងឡាយរៀបធ្វើនូវសរីរកិច្ចព្រះបាទព្រហ្មទត្តហើយ មានប្រាជ្ញាដើម្បីធ្វើការអភិសេកមហាសត្វបង្អោននៅសេះសិន្ធូរមានសម្បុណ៌សរប្រដាប់គ្រឿងប្រដាប់ស្រេចនាំមចូលទៅថ្វាយ ពោធិសត្វមិនទទួល ពោធិសត្វទ្រង់ឃើញនូវមណិកក្ខអស្ចារ្យ ត្រាស់បង្គាប់អាមាត្យដោយព្រះរាជឱង្ការថា អ្នកទាំងឡាយចូរប្រដាប់នូវសេះមណិកក្ខនេះនាំមមកឲ្យយើងវិញ ។ អាមាត្យក៏នាំមសេះមណិកក្ខចូលទៅថ្វាយ ពោធិសត្វឡើងគង់លើខ្នងមណិកក្ខ អាមាត្យប្រគំនូវ

តន្ត្រីទាំងពួងដ៏ច្រើន សម្លេងសាធុការជាមង្គលផ្សេង ៗ នឹង លើកឡើងនូវឆត្តនឹងទង់រាប់ពាន់ មណិកក្ខអស្សតរលោតស្ទុះ ឡើងកាន់អាកាសកំពស់បានមួយព្យាម អ្នកនគរបានឃើញ នូវសេចក្ដីអស្ចារ្យនោះក៏បន្លឺនូវសម្លេងកងរំពង ៗ សេះលោត ឡើងកាន់អាកាសដោយលំដាប់យ៉ាងនេះ បំនួនកំពស់ព្រៃដូរ- ដើមត្នោត មហាជនឃើញសេះហោះទៅកាន់អាកាសឆ្ងាយ ក៏ទៅក្រាបទូលនាងទេវីដែលកំពុងតែស្រង់ទឹកថា បពិត្រព្រះ នាងទេវី ចូរយាងមកឆាប់ ព្រះរាជបុត្រព្រះអង្គសេះនាំយកទៅ ឆ្ងាយហើយ ព្រះអង្គចូរឃាត់សេះកុំឲ្យធ្វើយើងរាល់គ្នាឲ្យទៅ ជាអ្នកខ្សត់ទីពឹងដូច្នោះឡើយ ៗ នាងទេវីមានព្រះកេសា ទើបសិតបានពាក់កណ្ដាល ព្រះពស្ត្រក៏មិនទាន់ទ្រង់ស្រប ស្ដួបយាងរួសរាន់ទៅដល់ធិតព្រះទ្វារទតទៅអាកាសឃើញ ពោធិសត្តទៅឆ្ងាយ ទ្រង់អត់នូវសេចក្ដីសោកមិនបានទ្រង់គក់ ព្រះឧរាខ្សឹកខ្សួលពោលនូវគាថា ៗ ម្នាលកូនសំឡាញ់ អ្នកចូរ ត្រឡប់វិញ កុំធ្វើមាតាឲ្យជាស្រីអនាថា ខ្ញុំនមាតាកាលមិន

ឃើញនូវអ្នកជាបុត្រ សមព្វទ័យនៃយើងនឹងបែកក្នុងថ្ងៃនេះ មិនខានឡើយ ។

## តំសុត្វាមហាសត្តេ

ព្រះមហាសត្វបានស្តាប់ពាក្យមាតាសារស័ព្ទ ក៏មានហឫទ័យហាក់ដូចជានឹងរលាយ ទ្រង់គិតថា អញនឹងកាប់ក្បាលសេះនេះឲ្យត្រឡប់វិញ ទើបហូតព្រះខ័នព្រារត្ននឹងកាប់ក្បាលសេះ ។ ខណៈនោះសេះដឹងនូវអាការនោះក៏ក្រាបទូលថា ព្រះអង្គកុំគប្បីសម្លាប់ខ្ញុំឡើយ ព្រះអង្គសម្លាប់ខ្ញុំព្រោះហេតុអ្វី ខ្ញុំនេះ អាចថ្វាយរាជសម្បត្តិដល់ព្រះអង្គបាន ។ ពោធិសត្វឮហើយតប ទៅថា ពាក្យនេះជាពាក្យពិតឬជាពាក្យកុហក សេះក៏ក្រាប ទូលថា បពិត្រក្រិសត្រ ពាក្យខ្ញុំនេះជាពាក្យសច្ចពិតប្រាកដ មែន ។ ពោធិសត្វក៏ស៊កព្រះខ័នទៅក្នុងស្រោមវិញ ទ្រង់រឭក ដល់គុណមាតាសម្រក់ទឹកព្រះនេត្រថ្វាយបង្គំអំពីចម្ងាយ ។ ព្រះពោធិសត្វនោះកាលបើសេះនាំទៅដោយលំដាប់ ក៏បាន ដល់ទៅសេតនគរ ។ ព្រះបាទសេតរាជសោយសម្បត្តិ ក្នុងសេតនគរនោះ តាំងបទុមគត្លាជាអគ្គមហេសីមានព្រះរាជ

រីតាមួយអង្គឈ្មោះនាងបីរប្បភា នាងមានរូបល្អជ្រះថ្លាគួរ
ទស្សនាប្រកបដោយធរីវណ្ណឧត្តម មានភាគគួរប្រៀបដោយ
ទេពកញ្ញា ។

មានស្រីគមម្នាក់ឈ្មោះនាងបទុមា ជាស្រីបំរើព្រះរាជធី-
តានោះ ។ បំណែកឯស្តេចទាំងឡាយនៅក្នុងជម្ពូទ្វីបប្រាថ្នា
ចង់បាននាងបីរប្បភារាល់ៗអង្គ បានបញ្ជូនគ្រឿងបណ្ណាការ
ជាច្រើនពាន់ទៅថ្វាយព្រះបាទសេតរាជដោយចង់បានព្រះរាជធី-
តា ។ ព្រះបាទសេតរាជក៏ទ្រង់ឃាត់ដោយឧង្ការថា យើងនឹង
ធ្វើធីតាយើងឲ្យជាប្រពន្ធព្រះឥន្ទ្រ ព្រះរាជធីតាយើងនេះ មាន
សភាពមិនសមគួរដល់អ្នករាល់គ្នាឡើយ ។ គ្រានោះទ្រង់ឲ្យ
នាងបីរប្បភាទៅនៅក្នុងប្រាសាទ ៧ ជាន់ ជាមួយនឹងស្រីបំរើ
ឈ្មោះបទុមា ។

ពោធិសត្តបិតហិនគរេ

ឯព្រះពោធិសត្ត ទ្រង់ដោះនូវគ្រឿងប្រដាប់សេះខាងក្រៅ
នគរហើយមានបន្ទូលនឹងមណិកក្ខអស្សតរថា ម្នាលសេះ អ្នក
ចូរទៅរកបរិភោគទឹកនឹងស្មៅ តែអ្នកកុំទៅឆ្ងាយពេកឡើយ ថា

បើយើងនឹកដល់អ្នកកាលណា ចូរអ្នកមកក្នុងកាលណោះ សេ
ក៏ចេញដើរកស៊ីស្មៅទៀបផ្លូវព្រះនគរនោះ ។

បំណែកមហាបុរសព្រះអង្គប្លែងភេទជាព្រាហ្មណ៍ ដើ
ចូលទៅកាន់នគរ ព្រាហ្មណ៍ទាំងឡាយដទៃឃើញហើយ
ស្រឡាញ់គ្រប់គ្នា ។ លុះកាលកន្លងទៅជាយូរ មនុស្សទាំង
ឡាយប្រជុំគ្នាជាពួក ៗ នៅទីទៀបផ្លោះស្ទឹងខ្លះ វាំងប្រជុំខ្លះ រ
ផ្លូវខ្លះ កណ្ដាលថ្នល់ខ្លះ ពោលសរសើរនូវរូបសម្បត្តិនៃនា
បីរប្បភារាជធីតា ។

បុច្ឆាសួរថា នាងបីរប្បភាដែលមានរូបល្អនោះតើ ដោយ
កុសលកម្មដូចម្ដេច ។ ពាក្យវិសជ្ជនាថា នាងបីរប្បភាមានរូប
មានពន្លឺកាយផ្សាយទៅអស់កាលយូរ ប្រាកដស្មើដោយព
មាស ដោយផលដែលនាងឲ្យនូវចតុបច្ច័យ ។

ពោធិសត្វបានឮពាក្យមនុស្សនិយាយគ្នា ទ្រង់គិតក្នុងព្រ
ហ្ទ័យថា "អញនឹងបានឃើញនាងបីរប្បភាដោយឧបាយដូ
ម្ដេច" ទើបទ្រង់លាបព្រះកាយដោយគន្ធវិលេបនដ៏អប់ដោយ
គន្ធជាតិ៤ប្រការ ប្រដាប់កម្រងផ្កា ទ្រង់គ្រឿងអលង្ការទាំងឡ

ស្រប លុះដល់កណ្ដាលអាធ្រាតស្ដេចនឹកដល់អស្សតរ ។

ខណៈដែលពោធិសត្វនឹកនោះ មណិកក្កុអស្សតរក៏មក ល់ឈរនៅក្នុងទីជិតព្រះអង្គមួយរំពេច ។

គ្រានោះមហាសត្វមានបន្ទូលនឹងសេះថា ម្នាលមណិកក្កុ យើងប្រាថ្នាចង់ឃើញនាងបិះប្បុភា យើងនឹងបានឃើញនូវ នាងនោះដោយឧបាយដូចម្ដេច ។ មណិកក្កុអស្សតរក្រាបទូល ថា បពិត្រមហារាជ ព្រះអង្គកុំព្រួយ ខ្ញុំនឹងនាំព្រះអង្គទៅ ។

អថមហាសត្តោគន្ធមាណាទីនិ

លំដាប់នោះមហាសត្វក៏កាន់យកនូវគ្រឿងក្រអូបនឹងកម្រង ផ្កាជាដើម ឡើងគង់លើសេះទៅដល់មាត់ទ្វារប្រាសាទនាង បិះប្បុភា ស្ដេចលបមើលតាមប្រហោងសោ បានឃើញនាង បិះប្បុភាផ្ដុំជាមួយនឹងស្រីបំរើ ទ្រង់គិតថា ស្រីនេះមានរូបល្អ ណាស់ប្រាកដបីដូចរូបធ្វើដោយមាស ទ្រង់មានបន្ទូលនឹង មណិកក្កុថា ម្នាលមណិកក្កុស្រីនេះមានឈ្មោះដូចម្ដេច ។

មណិកក្កុអស្សតរក្រាបទូលថា ស្រីនេះឈ្មោះនាងបិះប្បុ-ភា ក្នុងលំដាប់នោះពោធិសត្វបើកទ្វារសន្សឹមៗ ចូលទៅកាន់

ល្វែងជាទីបន្ទំនៃនាងបីរប្បភានោះ ទ្រង់ទតតាំងតែអំពីព្រះសិរដ
រាបដល់ផ្ចិតព្រះបាទមិនបេះផ្អែតព្រះហ្ឫទ័យ ពោធិសត្វយកគន្ធ-
ជាតិលាបព្រះកាយនាងសព្វហើយ ប្លង់នៅព្រះកេសា ស្ដេច
ទស្សនាធោមនាងមិនផ្អែតហ្ឫទ័យ ។ លំដាប់នោះព្រះពោធិសត្វ
យកគន្ធជាតិដែលសល់ គូររូបក្ងាយលើខ្នងនាងបទុមា ហើយ
ប្រដាប់ដោយកម្រងផ្កាដែលសល់ ស្ដេចឈរទតទៀត ។ គ្រា
នោះមណិកក្ខអស្សតរក៏ក្រាបទូលថា បពិត្រព្រះអង្គ មជ្ឈិម
យាមកន្លងហើយដល់វេលាបច្ឆិមយាមឥឡូវនេះហើយ ពោធិ-
សត្វក៏យាងចេញមកឡើងគង់លើសេះចេញទៅកាន់ទីលំនៅ
របស់ព្រះអង្គវិញ ហើយមានបន្ទូលនឹងសេះថា ម្នាលមណិកក្ខ
ខ្លួនអញមិនអាចនឹងនៅឆ្ងាយអំពីនាងបីរប្បភាទេ ថ្ងៃក្រោយ
ទៀតដល់កាលកណ្ដាលអាធ្រាតអ្នកមកកាន់សំណាក់យើង ម-
ណិកក្ខអស្សតរក៏ទទួលតាមព្រះបន្ទូល ។ លុះវេលារាត្រីភ្លឺឡើង
នាងបីរប្បភាតើនឡើងឃើញរូបក្ងាយលើខ្នងនាងបទុមាផង
ឃើញនូវកម្រងផ្កាគ្រឿងក្រអូបគ្រឿងលាបផង នាងសើបពោល
ចំអកថា បទុមាបានគ្រឿងក្រអូបគ្រឿងលាបអំពីទីឯណាមក

នាងបទុមាតបទៅថា បពិត្រព្រះនាងជាម្ចាស់ ព្រះនាងបានគ្រឿងក្រអូបគ្រឿងលាបអំពីទីឯណាមកលាបព្រះកាយជាអស្ចារ្យពេកៈ

សាអាទាសេគន្ធមាលាលង្កតំ

នាងចិរប្បភាក៏ឆ្ពះកញ្ចក់មើលព្រះកាយ ឃើញព្រះកាយប្រដាប់ដោយគ្រឿងគន្ធមាលា គឺតក្នុងព្រះហ្ឫទ័យថា ប្រហែលជាស្តេចទេវតាមកលាបឲ្យអញដឹង ទើបនាងប្រាប់នាងបទុមាថា ពេលាយប់នេះយើងគោងឃ្លាំមើល ។ នាងបទុមាក៏ទទួលតាមពាក្យនាងចិរប្បភា ។ ចំណែកពោធិសត្វទ្រង់ធ្វើនូវកិច្ចការដូចន័យខាងដើមក្នុងថ្ងៃជាគំរប់ពីរ នឹងគំរប់បី ហើយចេញទៅវិញក្នុងថ្ងៃជាគំរប់បួន ។ នាងចិរប្បភាមានបន្ទូលនឹងនាងបទុមាថា ម្នាលនាងបទុមា នាងចូរធ្វើឧបាយដើម្បីចាប់នូវបុរសនោះឲ្យបាន ថាបើយើងមិនអាចរកនៅចាំឃ្លាំ យើងគប្បីយកស្រទាប់ឧបលទល់ភ្នែកគង់ដេកមិនលក់ ។ ស្រីទាំងពីរនាក់ពោលថា ឧបាយនេះគួរហើយ ទើបធ្វើដោយប្រការដូច្នោះមិនបានដេកឡើយ ចាំមើលពោធិសត្វយាងមក ។ លំដាប់នោះព្រះពោធិសត្វកាន់យកនូវគ្រឿងគន្ធមាលាប្រដាប់កាយ ឡើង

គង់លើសេះក្នុងវេលាកណ្ដាលអាធ្រាត ទៅដល់ប្រាសាទនាង បើកទ្វារនឹងចូលទៅឃើញរស្មីនៃនាងបិរប្បភារុងរឿងបីដូចអណ្ដាតប្រទីប ។

ព្រះពោធិសត្វឃើញនាងបិរប្បភាហើយ មានបន្ទូលនឹងមណិកក្ខថា ម្នាលអស្សតរ អ្នកឃើញរស្មីនាងបិរប្បភាឬទេ ។ សេះក្រាបទូលថា ខ្ញុំអម្ចាស់ឃើញ ។ ចំណែកនាងបិរប្បភាកាលឃើញពោធិសត្វហើយក៏ខ្សិបនឹងនាងបទុមាថា ម្នាលនាងបទុមា ស្ដេចទេវតាមកដល់ហើយ នាងឃើញឬទេ ។

នាងបទុមាទូលតបថា ខ្ញុំម្ចាស់ឃើញ ។ ស្រីទាំងពីរនាក់ឃើញពោធិសត្វមានចិត្តត្រេកអរបដិពទ្ធ ក៏យកជាយសំពត់បិទភ្នែកសំងំដេកបីដូចជាស្រីដែលដេកលក់ស្កប់ ។ ពោធិសត្វទ្រង់យាងចូលទៅកាន់ល្វែងប្រាសាទពោលនូវពាក្យផ្សេង ៗ ទើបយកគន្ធជាតិប្រឡាប់ឲ្យស្រីទាំងពីរនាក់ ហើយឈរសម្លឹងរូបនាងបិរប្បភា ។ គ្រានោះមណិកក្ខអស្សតរក៏ក្រាបទូលទៀនពោធិសត្វឲ្យយាងចេញមក ។

## ឯវន្តនបកោសិយមានោ

ព្រះពោធិសត្វកាលបើសេះក្រាបទូលទៀនយ៉ាងនេះ ក៏ក្រោកសន្សឹម ៗ ចេញមក ខណៈនោះនាងបីរប្បភាក៏ឱបទៀបត្រចៀកនាងបទុមាថា យើងនឹងចាប់បុរសនេះ នាងបទុមាក៏ទទួលព្រមតាម ៗ នាងបីរប្បភាទេវីក្រោកអំពីម្នាស្នុះទៅឱបពាក់កណ្ដាលកាយពោធិសត្វ ដោយព្រះហស្តទាំងពីរខ្ជាប់ហើយទូលថាបូរឈប់សិនអ្នកថ្លៃ ៗ នាងបទុមាក្រោកឡើងស្នុះទៅចាប់ព្រះបាទពោធិសត្វក្រាបទូលថា ព្រះអង្គបូរឈប់សិន ៗ លំដាប់នោះពោធិសត្វមានបន្ទូលនឹងមណិកក្ខអស្សតរថា ម្នាលសំឡាញ់ខ្លួនយើងត្រូវស្រីពីរនាក់ចាប់ជាប់ហើយ ឥឡូវនេះយើងធ្វើដូចម្ដេចនឹងចេញទៅរួចបាន ៗ សេះទើបក្រាបទូលថា ព្រះអង្គបូរគង់នូវសិនចុះ សេចក្ដីអាក្រក់នឹងមិនមានដល់ព្រះអង្គឡើយ ៗ គ្រានោះពោធិសត្វតបទៅកាន់សេះថា កាលបើមានហេតុភេទកើតឡើង យើងនឹកដល់អ្នកឯងក្នុងកាលឯណា អ្នកបូរមកឲ្យឆាប់ក្នុងកាលនោះកុំខាន សេះទទួលតាមព្រះបន្ទូលហើយក៏ចេញទៅរកអាហារ ៗ សម័យនោះ

ពោធិសត្វទ្រង់ធ្វើការរួមរស់សំវាសដោយនាងបីវប្បភានោះ នាងបីវប្បភាទើទូលសួរពោធិសត្វថា "ព្រះអង្គជាស្តេចទេវតាឬមិនមែនទេ" ។

មហាសត្វឮនាងសួរដូច្នោះទ្រង់ព្រះចិន្តាថា បើអញប្រាប់ថាខ្លួនយើងជាស្តេចទេវតា ឬប្រាប់ថាសត្វដូច្នេះក្តី នាងនោះក៏គង់ជឿពិត តែថាប្រយោជន៍អ្វីដោយកិរិយាពោលពាក្យជារបស់អសប្បុរសទាំងឡាយ គួរតែយើងពោលនូវពាក្យពិត ដ្បិតពាក្យពិតជាធម៌ល្អ ពោធិសត្វមានព្រះហឫទ័យប្រាថ្នាដើម្បីពោលតាមត្រង់ទើបទ្រង់តបថា ម្នាលនាងមានភក្ត្រ យើងមិនមែនស្តេចទេវតាទេ ខ្លួនយើងនេះឈ្មោះសុធនកុមារជាបុត្រាព្រះបាទព្រហ្មទត្តក្នុងនគរពារាណសី ។ នាងបីវប្បភាបានស្តាប់ពាក្យពោធិសត្វពោលដូច្នោះ មានចិត្តត្រេកអរបីដូចជាបុគ្គលយកទឹកក្រអូប ៤៦ ក្អមមកស្រោចខ្លួនក្នុងកាលរដូវក្តៅ ក៏នៅរួមសំវាសគួរស្រឡាញ់ជាមួយនឹងពោធិសត្វក្នុងប្រាសាទនោះ ។ សព្វថ្ងៃមកនាងបទុមាមិនដែលធ្វើបាយទឹកនឹងកម្រងផ្កាគ្រឿងក្រអូបគ្រឿងលាបឲ្យលើសប្រមាណយកទៅឲ្យនាងបីវប្បភា

ឥឡូវនេះចាប់ដើមអំពីថ្ងៃពោធិសត្វទៅគង់នៅទីនោះ នាងបទុ-មាក៏កាន់យកនូវបាយទឹកជាដើមច្រើនលើសជាងអំពីដើម ។ លំដាប់នោះស្រីបំរើឯទៃឃើញវិប្បការប្លែកនៃនាងបទុមានោះ ក៏និយាយថា ម្នាលនាងបទុមា ហេតុនេះតើជាដូចម្ដេច បាន ជានាងធ្វើមិនដូចជាកាលមុន ៗ នាងបទុមាបេះតែស្ងៀម ។ ស្រីបំរើក៏សួរទៅទៀតថា បើនាងមិនប្រាប់នូវហេតុនោះទេ ជីវិតនាងឯងនឹងមិនមានឡើយ ។

គំសុត្តាបទុមាភិគតសិតា

នាងបទុមាឮពាក្យនោះភិតភ័យក៏តបទៅថា នាងទាំង ឡាយបូរវង់ចាំសិន, ហើយក៏ម្នាទៅកាន់សំណាក់នាង ចិរប្បភាទូលនូវហេតុនោះ នាងចិរប្បភាទូលនូវហេតុនោះដល់ ពោធិសត្វៗសោតមានព្រះហ្ឫទ័យត្រេកអរ មានបន្ទូលនឹងនាង បទុមាថា នាងចូរទៅវិញកុំខ្លាចឡើយ នាងបទុមាទទួល តាម ក៏បុះបាកប្រាសាទទៅជាមួយនឹងស្រីបំរើទាំងឡាយ ទៅក្រាបទូលនូវហេតុនោះដល់ស្ដេចនឹងនាងទេវីជាបិតាមាតា នាងចិរប្បភា ។

ព្រះបាទសេតរាជបានស្ដាប់ពាក្យនោះទប់ព្រះហ្ឫទ័យមិន
បានទ្រង់ខ្ញាល់នឹងពោធិសត្ត ហាក់ដូចជាពស់ដែលត្រូវវាយ
ទើបបរិតកតទៅទៀតថា អញគួរលមើលសិន កំឡាំងក្ដីតេជះក្ដី
នៃសុធនកុមារនោះនឹងមានប៉ុន្មាន ខ្លួនអញគង់ឃើញកំឡាំង
ផងតេជះផងនៃសុធនកុមារនោះ ថាបើសុធនកុមារមិនមានកំ-
ឡាំងមិនមានតេជះទេ អញនឹងកាត់ក្បាលសុធនកុមារនោះវិញ
ឲ្យខាងតែបាន ។ លំដាប់នោះព្រះបាទសេតរាជប្រាថ្នានឹងល្បង
ទើបទ្រង់ឲ្យប្រជុំស្ដេចនៅក្នុងជម្ពូទ្វីបទាំងអស់ ត្រាស់បង្គាប់
អាមាត្យទាំងឡាយថា រាប់អំពីថ្ងៃនេះទៅបំនួន ៧ ថ្ងៃយើងនឹង
ធ្វើមហោរស្រពក្នុងនគរនេះ អ្នកទាំងឡាយចូរបញ្ឈរទុកនូវក្ដា
ឈើខទុម្ពរកំរាស់ ៤ ធ្នាប់ជំរួតលើគ្នា ៧ ស្រទាប់ យកបន្ទះដែក
កំរាស់ពីរធ្នាប់ជំរួតគ្នា ៧ ស្រទាប់ បញ្ឈរទុកអំពីខាងមុខផែន
ក្ដាឈើខទុម្ពរនោះ យកបន្ទះទង់ដែង ៧ ស្រទាប់ជំរួតគ្នា
បញ្ឈរទុកអំពីខាងមុខបន្ទះដែកនោះ យកនូវរទេះ ៧ ផ្ទុកដីខ្សាច់
ឲ្យពេញបន្ទុក តែកុំឲ្យដល់បាក់កាំបាក់ភ្លៅរទេះ បញ្ឈរទុក
អំពីខាងមុខបន្ទះទង់ដែងនោះ យកដើមត្នោត ៧ ទកលុងហើយ

ប្រកដីខ្ពុប់បញ្ជរទុកអំពីខាងមុខរទេះនោះ ដំកល់ទុកនូវមិគយន្តកំពុងវិលក្នុងទីបំផុតនៃវិថីផាន់ទាំង៤មុខនោះ ។ អាមាត្យទាំងឡាយក៏ធ្វើតាមព្រះរាជឱង្ការ ស្រេចហើយក៏ចូលទៅក្រាបទូលដល់ស្តេច ។ លុំដាប់នោះព្រះបាទសេតរាជមានព្រះឱង្ការឲ្យអាមាត្យទៅប្រាប់ថា កូនអញចូរមកក្នុងទីនេះចុះ ។ អាមាត្យទៅទូលដល់ពោធិសត្វថា ស្តេចទ្រង់ត្រាស់ឲ្យហៅព្រះអង្គ ពោធិសត្វក៏ប្រដាប់កាយដោយគ្រឿងអលង្ការទាំងពួង យាងចុះចាកប្រាសាទមកជាមួយនឹងនាងបិះប្បភា បីដូចជាកេសររាជសីហចេញអំពីគុហាកែវមណីមកជាមួយនឹង នាងរាជ-សីហ ពុំនោះសោតបីដូចជាព្រះចន្ទចេញអំពីវេជយន្តប្រាសាទជាមួយនឹងនាងសុជាតា មានយានយាសលំអរដោយសិរីនឹងតេ-ជះ ព្រះអង្គស្ថិតនៅទៀបជើងជណ្ដើរមិលមើលទិសខាងណោះខាងណេះ ទិសទីដែលព្រះអង្គមិលមើលហាក់បីដូចជាកំរើក ។ គ្រានោះព្រះបាទសេតរាជក្តី នាងបទុមគព្ភាទេវីក្តី ពួកស្រីស្នំក្តីស្តេចនៅក្នុងជម្ពូទ្វីបទាំងអស់ក្តី ក្រឡេកឃើញពោធិសត្វបង្កើតចិត្តរីករាយនះពៃស្មើរញាប់ញ័រទាំងទិសធំទាំងទិសតូច ។ បំណែក

ពោធិសត្វយាងចុះបាកប្រាសាទ មកដល់ក៏ក្រាបថ្វាយបង្គំស្តេចនឹងនាងទេវី ហើយគង់នៅលើទីគួរមួយ ។

អបិសេករាជាតេនសទ្ធិ

លំដាប់នោះព្រះបាទសេតរាជទ្រង់ធ្វើនូវមង្គលសណ្ឋារមួយអន្លើរដោយពោធិសត្វមានព្រះរាជឱង្ការថា យើងទាំងឡាយមានប្រាថ្នាដើម្បីឃើញនូវកម្លាំងនៃអ្នកក្នុងថ្ងៃនេះ ។ ព្រះមហាបុរសបានស្តាប់ហើយលើកឡើងនូវអញ្ជលីថ្វាយបង្គំក្រាបទូលថា សូមព្រះអង្គចូរទតចុះ ពោធិសត្វពោលយ៉ាងនេះហើយទ្រង់នាំចេញនូវធ្នូនឹងកូនសរអំពីខាងក្នុងសំពត់សាដកសំរាប់ពន្ទៀង ព្រះអង្គបោះធ្នូនឹងបន្លោះទៅក្នុងអាកាស ហើយក៏ធ្លាក់ចុះមកក្នុងទីជិតទីប្រជុំ ។ ពោធិសត្វក៏មានបន្ទូលនឹងស្តេចដែលនៅក្នុងជម្ពូទ្វីបទាំងអស់ថា បើស្តេចអង្គណាអាច ចូរលើកនូវធ្នូនោះចុះ ។ ស្តេចទាំងឡាយនោះក៏ក្រោកឡើងទៅលើកធ្នូក្នុងខណនោះ តែមិនអាចលើកនូវធ្នូឲ្យរួច សូម្បីប៉ុនចុងសសៃសក់ ក៏វិលទៅឈរនៅកន្លែងខ្លួនវិញ ។ លំដាប់នោះពោធិសត្វកាលនឹងចាប់នូវធ្នូ ព្រះអង្គយកកូនព្រះអង្គុលីផ្ទាក់នូវបន្លោះធ្នូ

ផ្កាប់ក្បាលសរដ៏មុត មានព្រះកាយដ៏រុងរឿងដោយសិរីនឹងតេជះ បីដូចជាព្រះឥន្ទមានកាយដ៏រុងរឿងក្នុងសង្គ្រាមនៃអសុរ ទើបមានបន្ទូលនឹងព្រះបាទសេតរាជថា ព្រះអង្គឲ្យខ្ញុំបាញ់នូវវត្ថុអ្វី ព្រះបាទសេតរាជតបទៅថា អ្នកប្ដូរបាញ់នូវរបស់ ៧ ស្រទាប់ទាំង ៤ មុខនេះចុះ ។

## ពោធិសត្វសត្តខទុម្ពរផលកេហេរ

ពោធិសត្វក៏បាញ់នូវផែនក្ដារខទុម្ពរ ៧ ស្រទាប់ បន្ទាស់ដែក ៧ ស្រទាប់ បន្ទាស់ទង់ដែង ៧ ស្រទាប់ រទេះពេញដោយដីខ្សាច់ ៧ ដើមត្នោត ៧ ក៏ធ្លុះរហូតដល់ភ្នែកខាងស្ដាំនៃមិគយន្តដែលស្ថិតនៅក្នុងទីបំផុតនៃវត្ថុទាំងពួង ។ បំណែកសរដែលមុតធ្លុះវត្ថុទាំងនោះហើយត្រឡប់វិលមកធ្លាក់ចុះលើផែនដី ក្នុងទីចំពោះមុខពោធិសត្វវិញ ពួកមហាជនមានព្រះបាទសេតរាជជាប្រធាន ឃើញនូវសេចក្ដីអស្ចារ្យនោះ ក៏ធ្វើនូវសម្លេងហ៊ោបោះទៅនូវកម្រងផ្កានឹងសំពត់គ្រឿងអម្ពរ លើកឡើងនូវទង់សំពត់រាប់ដោយសែនជាគ្រឿងបូជា ។ ផែនដីធំមានកម្រាស់ពីរសែនបួនហ្មឺនយោជន៍ ក៏លាន់កក្រើកដោយតេជះនៃពោធិសត្វ បីដូចដំរី

ដ៏ប្រសើរបុះប្រែងក្នុងខណៈនោះពិត លំដាប់នោះព្រះពុទសេត-រាជព្រះអង្គក៏ក្រោកចាកអាសនាស្ទុះទៅឱបពោធិសត្វ ថើបព្រះ-សិរសាធ្វើវិវាហមង្គលក្នុងទីនោះ ។ លុះកាលកន្លងទៅដោយប្រ-ការដូច្នេះជាយូរ ក្នុងថ្ងៃមួយពោធិសត្វផ្ទំក្នុងប្រាសាទជាមួយនឹងនាងចិរប្បភា ទ្រង់រឭកព្រះមាតាក្នុងវេលាបច្ចូសម័យ មិនអាចដើម្បីទប់អស្សុជលនេត្របាន ទ្រង់ព្រះកន្សែងសោកពោលជាបទគាថា : ប្រយោជន៍ដូចម្ដេចនឹងមានដល់យើង ខ្ញនយើងកាលមិនឃើញមាតានឹងក្ស័យជីវិត តែយើងនឹងទៅកាន់សំណាក់មាតាដោយប្រការដូចម្ដេច ពោធិសត្វពោលយ៉ាងនេះហើយក៏បរិទេវនាការកើតសេចក្ដីសោកក្នុងហឫទ័យគួរស្រណោះ ។ លំដាប់នោះ នាងចិរប្បភាទេវីតើនឡើងក៏សួរពោធិសត្វថា ព្រះអង្គទ្រង់ព្រះកន្សែងអំពីហេតុអ្វីៗ ពោធិសត្វព្រះអង្គមិនប្រាប់ដល់នាងទេវី នាងទេវីទូលសួរអស់វារៈពីរដងបីដង ព្រះអង្គសម្រក់ទឹកព្រះនេត្រពោលនូវគាថា ៗ ម្នាលនាងដ៏ចំរើន បងរឭកព្រះមាតា ចាប់ដើមអំពីកាលបងចេញចាកព្រះនគរមក មណិកក្ខអស្សត្រនាំបងមកដល់ទីនេះ ដើម្បីប្រយោជន៍ឲ្យបាននាង ។

នាងបីរប្បភាបានស្ដាប់ពាក្យពោធិសត្វហើយទូលថា បើដូច្នោះព្រះអង្គនឹងធ្វើដូចម្ដេច ។ ពោធិសត្វតបថា ម្នាលនាង យើងព្រាត់មាតាមិនអាចនឹងរស់នៅបាន យើងនឹងទៅកាន់សំណាក់ព្រះមាតា ។ នាងទេវីក៏ក្រាបទូលថា បពិត្រក្សត្រថ្លៃ ខ្ញុំម្ចាស់នឹងទៅជាមួយនឹងព្រះអង្គ ស្ដេចយាងទៅទីណា ខ្ញុំម្ចាស់ក៏ទៅកាន់ទីនោះដែរ ។ ពោធិសត្វក៏ឃាត់ទៅនាងទេវីថា នាងកុំគាប់ចិត្តទៅនឹងយើងឡើយ ។ នាងទេវីមិនព្រមបេះតែអង្វរ ពោធិ-សត្វក៏ព្រមថា នាងទៅនឹងយើងក៏ល្អដែរ ។

លុះដល់រាត្រីភ្លឺឡើង ពោធិសត្វយាងទៅកាន់សំណាក់ឪពុកក្មេកម្ដាយក្មេកថ្វាយបង្គំមហាទូលថា បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំមកនៅក្នុងទីនេះយូរហើយ មិនបានឃើញមាតាឥឡូវនេះខ្ញុំនឹងទៅឲ្យឃើញមាតា ។ លំដាប់នោះស្ដេចនឹងនាងទេវីក៏ទទួលឃាត់ដោយប្រការផ្សេង ៗ តែមិនសម្រេច ទើបមានព្រះរាជឱង្ការថា ម្នាលកូន ថាបើអ្នកទៅ ចូរយកប្អូនស្រីអ្នកទៅផងចុះ ។ បិតាមាតាក្មេកអង្វរឲ្យយកនាងបីរប្បភាទៅជាមួយពោធិសត្វបេះតែឃាត់មិនព្រមយកទៅ ។ គ្រានោះព្រះបាទ

សេតរាជមានបន្ទូលនឹងពោធិសត្វថា ម្នាលកូន ធម្មតាស្ដេច ទាំងឡាយរមែងពោលវាចាតែមួយ មិនពោលវាចាពីរបី យើង ឲ្យកូនស្រីដល់អ្នកហើយអ្នកចូរនាំមប្រពន្ធអ្នកទៅចុះ ។ ពោ-ធិសត្វក៏ទទួលតាមព្រះឱង្ការ ។ លំដាប់នោះស្ដេចនឹងនាង ទេវីឲ្យធ្វើមហោរស្រពរៀបមង្គលការពោធិសត្វនឹងនាងបិរប្ប-ភាទាំងពីរអង្គ ដល់ថ្ងៃក្រោយទ្រង់ប្រដាប់ព្រះរាជធីតាហើយ ព្រះរាជទានឱវាទដល់ព្រះរាជធីតាថា នាងកុំធ្វើសេចក្ដីធ្វេស ឡើយ នាងកុំប្រមាទ នាងចូរស្ថិតនៅក្នុងអប្បមាទ នៅក្នុងសំណាក់ប្ដីគប្បីគោរពប្ដីចុះ ស្ដេចប្រទានឱវាទដល់ព្រះរាជធីតាដោយប្រការដូច្នេះ ទើបត្រាស់បង្គាប់ឲ្យតាក់តែងស្បៀងដើរផ្លូវហើយ ព្រះរាជទាននាងបិរប្បភាដល់ពោធិសត្វ ។ បំណែកពោធិសត្វក៏ថ្វាយបង្គំព្រះបាទសេតរាជនឹងនាងទេវីស្មារលាទោសស្រេចយាងចុះចាកប្រាសាទជាមួយនឹងនាងបិរប្បភា លំនាំបីដូចជាព្រះឥន្ទ្រ ទ្រង់លាមហាជនពោលជាបទគាថា ថាម្នាលអ្នកទាំងឡាយយើងលាហើយ ទោសខុះដោយវាចាឯណានីមួយនៃយើងមាន អ្នកទាំងឡាយចូរអត់នូវទោស

នោះ អ្នកទាំងអស់គ្នាទាំងក្មេងទាំងចាស់ចូរកុំធ្វើបាបឡើយ ។ លំដាប់នោះមហាជនទាំងពួងលើកអញ្ជលីប្រណម្យឈរយំសំរក់ទឹកភ្នែក មហាជនមានអាមាត្យជាដើមក៏ពោលរៀបរាប់ផ្សេងៗថា យើងធ្លាប់ឃើញនូវព្រះកាយព្រះអង្គទាំងពីរ អំពីនេះទៅយើងនឹងមិនបានឃើញព្រះអង្គអស់កាលទាំងពួង អិនបានឃើញនូវព្រះកាយមុខគួរអាល័យដ៏ប្រកបដោយសិរីនឹងអានុភាពច្រើន ឱះឱយើងទាំងឡាយមុកជាព្រាត់ប្រាសអស់កាលយូរហើយ មហាជនពោលរៀបរាប់យ៉ាងនេះឈរមើលរាល់គ្នា ។

## តគោមហាបុរិសោមណិកក្ខំ

លំដាប់នោះព្រះមហាបុរសទ្រង់ឥកដល់មណិកក្ខអស្សតរខណនោះសេះក៏មកដល់ឈរនៅក្នុងទីបំពោះព្រះភក្ត្រ ។ មហាបុរសទ្រង់ឲ្យនាងទេវីជិះខាងក្រោយ ព្រះអង្គឡើងជិះខាងមុខដោយព្រះអង្គឯង សេះក៏នាំក្សត្រីក្សត្រាទាំងពីរហោះទៅក្នុងអាកាស ហោះទៅមួយថ្ងៃបានចម្ងាយផ្លូវ ៧០០ យោជន៍រាងបីរប្បេភាទេវីមានព្រះភក្ត្រស្រពោនដោយត្រូវខ្យល់នឹងកំដៅ

ថ្ងៃ ដ្បិតសេះហោះលឿន[illegible]ប់ នាងមិនធ្លាប់លំបាកព្រះកាយ អស់កាលមកយូរហើយក៏ដល់នៅវិសញ្ញីភាន់ភាំងបាត់ស្មារតី មិនដឹងព្រះអង្គ ។ ពោធិសត្វទ្រង់ឃើញនាងទេវីមានមុខស្រពោនសរីរកាយលំបាក ព្រះអង្គកាន់យកស៊ែរមាសបោសទៅខាងមុខមានបន្ទូលនឹងសេះថា ម្នាលមណិកក្ខ អ្នកចូរឈប់សិនមណិកក្ខអស្សុតរ ពោលឃាត់ពោធិសត្វថា បពិត្រព្រះសម្មតិទេព ព្រះអង្គកុំគាប់ព្រះហឫទ័យនឹងឈប់ក្នុងទីនេះឡើយ ដ្បិតប្រទេសនេះយក្ខារយក្ខរក្សាទុក ។

បុច្ឆាសួរថា ហេតុអ្វីបានជាយក្ខារយក្ខរក្សាប្រទេសនោះ វិសជ្ជនាថា បក្ខារយក្ខនេះទៅនៅជិតទឹកបំរើព្រះវេស្សវណ្ណចំនួនបីឆ្នាំ លុះគ្រប់បីឆ្នាំហើយ យក្ខមានប្រាថ្នាដើម្បីស៊ីសាច់មនុស្សក៏អង្វរសូមពរព្រះវេស្សវណ្ណ ព្រះវេស្សវណ្ណមិនអាចឃាត់ក៏ប្រាប់ទៅយក្ខារយក្ខថា ម្នាលយក្ខ ថាបើអ្នកប្រាថ្នាចង់ស៊ីសាច់មនុស្សយ៉ាងនេះ អ្នកចូររក្សានូវប្រទេសនេះចុះ អ្នកចូរនិរមិត្តបណ្ណសាលាមួយក្នុងទីឱកាសនោះ ហើយដាក់ទុកនូវគ្រឿងបរិក្ខារសំរាប់ប្រើទាំងពួងជារបស់នៃមនុស្ស បើមនុស្ស

ណាចូលទៅនៅក្នុងបណ្ណសាលានោះ អ្នកមកហើយសួរអ្នកនោះអស់ភារបីដងថា អ្នកណាមកនៅក្នុងបណ្ណសាលានេះហេតុត្រី ក្នុងភារជាគំរប់បី មនុស្សនោះឲ្យនៅពាក្យតបដល់អ្នកថា ខ្លួនយើងនៅក្នុងបណ្ណសាលានេះ អ្នកកុំស៊ីនូវមនុស្សនោះឡើយ បើមនុស្សឯណាកាលអ្នកសួរអស់ភារបីដងហើយមិនឲ្យនូវពាក្យតបដល់អ្នកវិញ អ្នកចូរទំពាស៊ីនូវមនុស្សនោះចុះ ។

យក្ខារយក្ខបានពរអំពីសំណាក់ព្រះវេស្សវណ្ណយ៉ាងនេះហើយ ក៏ត្រឡប់មកកាន់កាប់ប្រទេសនោះ ធ្វើបណ្ណសាលាទុកល់ទុកនូវគ្រឿងដែលគួរមនុស្សបរិភោគហើយរក្សាទុក ។

នៅមាននាងយក្ខិណីម្នាក់ឈ្មោះនាងអញ្ជនវតីជាប្អូនស្រីនៃយក្ខារយក្ខនោះ យក្ខារយក្ខធ្វើនូវប្រាសាទទៀបឆ្នេរសមុទ្រហើយប្លន់យករាជធីតានៃស្តេចក្នុងជម្ពូទ្វីបទាំងអស់ ទៅទុកដើម្បីជាបរិវារនៃនាងអញ្ជនវតីនោះ នាងករេណុវតីក៏នៅក្នុងប្រាសាទនោះផង យក្ខារយក្ខសោតក៏នៅក្នុងប្រាសាទជិតនឹងប្រាសាទនាងយក្ខិណីនោះដែរ ហេតុនោះបាន

ជាមណិកក្ខអស្សុតរ ឃាត់ពោធិសត្តថា ព្រះអង្គកុំគង់នៅក្នុង ទីនេះឡើយ ដោយប្រការដូច្នេះឯង ។

## ពោធិសត្តោតត្ថបត្វាសាលំទិស្វា

ពោធិសត្តមកដល់ប្រទេសនោះ ឃើញបណ្ណសាលាទ្រង់ សួរមណិកក្ខអស្សុតរថា សាលានេះតើជារបស់អ្នកណា ។ មណិកក្ខអស្សុតរក្រាបទូលថា សាលានេះជារបស់យក្ខារ យក្ខ ពោធិសត្តសួរទៅទៀតថា ម្នាលមណិកក្ខយក្ខស៊ីម-នុស្សទាំងអស់គ្នា ឬមានមិនស៊ីមនុស្សខ្លះដែរ សេះក្រាបទូល ថា យក្ខមិនបានស៊ីមនុស្សទាំងអស់គ្នាទេ ។ ពោធិសត្តមាន បន្ទូលថា ម្នាលមណិកក្ខនាងទេវីនឿយណាស់ បើយើងនឹងទៅ ឈប់ខាងនាយ ជីវិតនាងចិរប្បភាប្រហែលជាគ្មាន ហេតុនោះ យើងទាំងឡាយគួរបុះក្នុងទីនេះសិនកសិន ។ មណិកក្ខអស្សុត រមិនអាចឃាត់ពោធិសត្ត ក៏បុះអំពីអាកាសដាក់ពោធិសត្តក្នុង ទីនោះ ឲ្យនាងទេវីងូតទឹកក្តៅដែរយក្ខដិកល់ទុកក្នុងសាលានោះ នឹងឲ្យបរិភោគអាហាររបស់យក្ខ ។ លំដាប់នោះមហាសត្តមាន

បន្ទូលនឹងសេះថា ម្នាលមណិកក្ខ យើងដេកក្នុងទីនេះផ្លាស់វេន គ្នា អ្នកចូរដេកមុនយើងៗនៅរក្សាអ្នក សេះទូលថា ព្រះអង្គ កុំរក្សាខ្ញុំឡើយខ្ញុំនឹងរក្សាព្រះអង្គ ៗ ពោធិសត្វតបទៅកាន់សេះ ដើម្បីឲ្យសេះដេកមុនថា ម្នាលមណិកក្ខខ្លួនអ្នកមកដោយភារៈធ្ងន់មានកាយលំបាកណាស់ គប្បីសំរាកខ្លួន ចូរដេកសិនចុះ យើងនឹងរក្សាអ្នកឯង ។ កាលបើព្រះពោធិសត្វពោលយ៉ាងនេះ មណិកក្ខអស្សត្រក្រាបទូលថា កុំព្រួយព្រះហឫទ័យ ខ្ញុំអាច ការពារសេចក្ដីអន្តរាយ ត្រូវនៅមើលសិន ព្រះអង្គផ្ទំចុះ ខ្ញុំ នឹងរក្សាព្រះអង ។ ពោធិសត្វបានស្ដាប់ពាក្យសេះ ក៏ទទួល ថា ម្នាលអ្នកជាសប្បុរស ពាក្យអ្នកពោលនេះពីរោះណាស់ ហើយព្រះអង្គក៏ផ្ទំមុនទៅ ។ ក្នុងវេលាបឋមយាមរាត្រីនោះ យក្ខារយក្ខមកគោះទ្វារសាលាសួរថា អ្នកណានៅក្នុងសាលា នេះ ។ មណិកក្ខអស្សត្រឲ្យពាក្យតបទៅយក្ខថាយើង យក្ខឮ ពាក្យនោះហើយថយចេញទៅ យូរបន្តិចយក្ខមកម្ដងទៀតសួរថា អ្នកណានៅក្នុងសាលានេះ មណិកក្ខអស្សត្រឲ្យនូវពាក្យតប ទៅយក្ខថា យើង យក្ខក៏ចៀសចេញទៅដោយគិតថាអ្នកនេះ

មិនទាន់ដេកលក់ទេ ។ យក្ខារយក្ខមកសួរដោយលំដាប់ដូចន័យខាងដើម ដរាបចូលមជ្ឈិមយាម លំដាប់នោះពោធិសត្វតើនឡើងមានបន្ទូលនឹងមណិកក្ខអស្សតរថា ម្នាលមណិកក្ខ អ្នកចូរដេកចុះ យើងនឹងរក្សាអ្នក សេះទទួលតាមបន្ទូលហើយក៏ដេកទៅ ។

តស្មិំ ខណេ បិយក្ខោ អាគន្ត្វា ទ្វារំ អាកោដេត្វា

ខណៈនោះយក្ខារយក្ខមកហើយគោះទ្វារសួរថា អ្នកណានៅក្នុងសាលានេះ មហាសត្វប្រាប់ទៅថា យើង យក្ខក៏ចៀសទៅយូរបន្តិចត្រឡប់មកសួរទៀតថា អ្នកណានៅក្នុងសាលានេះ ពោធិសត្វប្រាប់ទៅយក្ខវិញថាយើង យក្ខមកសួរអស់វារបីដងដូចន័យមុន ដរាបចូលបច្ឆិមយាម ព្រះពោធិសត្វក៏ឡ្យេវពាក្យតបដល់យក្ខក្នុងកាលនោះៗ រាល់ដង ។ លំដាប់អំពីនោះមកដល់វេលាបច្ឆិមយាម នាងទេវីក៏តើនឡើងក្នុងកាលជិតភ្លឺ ក៏អង្វរព្រះភស្តាឲ្យផ្ទំ ដ្បិតកាលយាងមកបានសេចក្តីនឿយលំបាកដោយខ្យល់នឹងកំដៅថ្ងៃពាល់ត្រូវ ព្រះ-ពោធិសត្វធ្វើតាមពាក្យនាងទេវីព្រះអង្គក៏ផ្ទំលក់ទៅ លំដាប់

នោះយក្ខមកគោះទ្វារសួរថាអ្នកណានៅក្នុងសាលានេះ ៗ នាងទេវីឱ្យនូវពាក្យតបដល់យក្ខដោយសំដីដ៏ទន់ភ្លន់ថាយើង យក្ខឮនូវពាក្យនោះហើយចៀសទៅ យក្ខមកសួរដូច្នោះក្នុងវារៈជាគំរប់ពីរដង នាងទេវីក៏ឱ្យនូវពាក្យតបដោយសំដីទន់តិចជាងមុន ព្រោះសេចក្ដីងងុយគ្របសង្កត់ យក្ខក៏ចៀសចេញទៅទៀត លុះដល់វារៈជាគំរប់បី យក្ខមកសួរដូចកាលមុន នាងទេវីនោះក៏ផ្ទុំលក់ស្និទក្នុងមួយរំពេច ព្រោះសេចក្ដីងងុយគ្របសង្កត់ខ្លាំង យក្ខមកដល់គោះទ្វារសួរម្ដងទៀតថា អ្នកណានៅក្នុងសាលានេះ ៗ អ្នកឯណានីមួយដែលនឹងឱ្យពាក្យតបដល់យក្ខក្នុងកាលនោះមិនមានឡើយ យក្ខក៏ដឹងថាជនទាំងឡាយនេះដេកលក់ទាំងអស់គ្នាហើយ យក្ខក៏ធ្វើនូវសម្លេងខ្លាំងបើកទ្វារអើតទៅសួរថា អ្នកនេះតើជាអ្វី ៗ មណិកក្ខអស្សុតរដេកនៅជិតទ្វារភ្ញាក់ឡើងហើយសួរថា អ្នកណាឈរនូវក្នុងទីនេះ យក្ខក៏តបទៅថា ខ្លួនយើងឈ្មោះយន្តារយក្ខ ស្ដេចនឹងនាងទេវីឮពាក្យនោះ ក៏តើនឡើង ខ្លាចយក្ខញ័របំប្រប់ទាំងព្រះកាយ ៗ លំដាប់នោះមណិកក្ខអាជានៃយតបទៅកាន់

យក្ខថា អ្នកកុំអាលចេញទៅណា យើងនឹងធ្វើយុទ្ធនាការ មួយអន្លើដោយអ្នក ។ យក្ខឮពាក្យសេះក៏តបទៅថា ម្នាលអ្នក ដ៏ចំរើន អ្នកនឹងច្បាំងដោយអ្នកណា មណិក្ខអស្សតរតបទៅ ថា យើងនឹងច្បាំងដោយអ្នកឯង ម្នាលយក្ខ អ្នកចូរច្បាំង នឹងយើងមុន យក្ខក៏តបទៅសេះថា អ្នកចូរច្បាំងមុនចុះ ។ លំដាប់នោះ សេះក៏ហោះឡើងទៅឯអាកាសសម្តែងនូវហេតុ គួរសំបើមផ្សេងៗ ហើយជាក់នូវមុខយក្ខដោយជើងមុខទាំងពីរ ឈាមក៏ហូរចេញអំពីមុខយក្ខ សេះលោតឡើងម្តងទៀតជាក់ ត្រូវទ្រូងយក្ខ ឈាមក៏ហូរចេញអំពីទ្រូងយក្ខទៀត ។

## តេសំយុជ្ឈនកាលេឧភោខត្តិយា

ក្នុងកាលដែលសេះនឹងយក្ខច្បាំងគ្នាក្សត្រិយ៍ទាំងពីរអង្គ គង់ក្នុងសាលាក៏ឮនូវសម្លេងច្បាំងគ្នា មហាសត្វស្រែកប្រាប់ ទៅមណិកក្ខអស្សតរថា ម្នាលសេះអ្នកចូររក្សានូវកំភ្លៀង ឲ្យល្អ ។ យក្ខបានឮពាក្យមហាសត្វក៏ដឹងថា ភណ្ឌ គឺ កំ-ភ្លៀងសេះនេះជាទីតំបន់ យក្ខក៏ប្រឹងចាប់កំភ្លៀងសេះខ្ជាប់មាំ

មណិកក្ខអស្សតរទំព្យាយាមដោយប្រការផ្សេង ៗ មិនអាច ដើម្បីធ្វើឲ្យផ្ទុះយក្ខបាន ខ្លួនសោតមានកំឡាំងក៏ថមថយជាង យក្ខ ។ ខណៈនោះយក្ខចាប់សេះឡើងជិះបានហើយប្រគល់ ឲ្យពលយក្ខដោយពាក្យថា អ្នកទាំងឡាយចាប់នូវសេះនេះ រក្សាទុកកុំប្រហែសឡើយ ពលយក្ខក៏ចងនូវសេះដោយ បំណងប្រើនធ្វើការរក្សាទុក ។ គ្រានោះមហាសត្តកាលបើ មិនឃើញមណិកក្ខទ្រង់ស្រែកហៅ ក៏មិនឃើញក្នុងទីឯណា នីមួយឡើយ ព្រះអង្គក្រោកឡើងយាងទៅទីជិតទ្វារទតទៅ ក៏មិនឃើញ ព្រះអង្គមិនអាចទប់ទឹកព្រះនេត្រទ្រង់ព្រះកន្សែង ជាមួយនឹងនាងទេវីថាឱខ្លួនយើងទាំងពីរនឹងវិនាសមិនខាន ឡើយ ទើបស្ដេចយាងចុះទៅខាងក្រៅឃើញឈាមដែលហូរ ធ្លាក់មកលើដី សំគាល់ក្នុងព្រះហឫទ័យថា មណិកក្ខអស្សតរ យក្ខចាប់បាន ប្រហែលជាស្លាប់ទៅហើយ ព្រះអង្គទតគ្រប់ ទិសទាំង ៤ មិនឃើញសេះ ស្ដេចក៏កៀកកណ្ដ៍នាងទេវីទ្រង់ ព្រះកន្សែងស្រណោះស្រណោក ។ លំដាប់នោះមហាសត្ត ទ្រង់ស្ទាបអង្អែលកាយនាងចិរប្បភា ពោលរៀបរាប់ជាបទគាថា

ថាឱ៎យើងទាំងឡាយសមបីវិនាសហើយ ជីវិតនៃយើងនឹងមិនមានតទៅ យើងព្រាត់ប្រាស់មណិកក្ខហើយនឹងរស់នៅដូចម្ដេចបាន យើងនឹងឲ្យអ្នកណានាំទៅក្នុងព្រៃនឹងជនបទ យើងព្រាត់ប្រាស់មណិកក្ខអស្សូតរគង់ស្លាប់ក្នុងព្រៃធំមិនខាន នាងបីរប្បភាទេវីនោះបានឮស្វាមីនាងរៀបរាប់ ក៏ក្រាបទៀបព្រះបាទពោធិសត្ត ប្រឹបាប់ព្រះបាទខ្សឹកខ្សួលពោលគាថាថា ឱះឱយើងទាំងពីរនឹងវិនាសក្នុងព្រៃមិនខាន យើងទាំងពីរមានជាតិដ៏ល្អស្មើគ្នា ត្រេបដើរលើផ្ទៃផែនដីក៏ដល់នៅសេចក្ដីទុក្ខជាទម្ងន់ក្នុងកាលឥឡូវនេះ ។ នាងទេវីខ្សឹកខ្សួលគូឲ្យស្រណោះដោយប្រការដូច្នេះ ។ ទើបមហាសត្តឃាត់នៅនាងទេវីថា អានុជបងនាងកុំខ្សឹកខ្សួលធ្ងន់ពេកឡើយ សេចក្ដីទុក្ខនេះជារបស់ទៀងរបស់សត្តលោកដោយពិត សត្តលោកតែងប្ញូលទៅជិតសេចក្ដីសុខទុក្ខ ម្នាលនាងដ៏ចំរើន នាងកុំឲ្យយើងវិនាសឡើយ ។ មហាសត្តពោលនូវពាក្យយ៉ាងនេះហើយ ស្ដេចលួងលោមនាងទេវីមានបន្ទូលថាអានុជបងនាងកុំគិត ទើបព្រះអង្គដំកល់ស្មារតីខ្ជាប់បរបាជាមួយនឹងនាងទេវីតទៅទៀតថា ម្នាល

នាង ដើមឈើទាំងឡាយក្នុងទីឯណោះ រង់រឿងដោយពណ៌ ដូចជាផ្ទៃមេឃ មហាសមុទ្រប្រហែលជានឹងមានក្នុងទីនោះយើង ទៅក្នុងទីនោះហើយ បងនៅទង់លើចុងឈើឲ្យពាណិជទាំង-ឡាយឃើញ ពាណិជទាំងឡាយ ឃើញនៅយើងហើយគង់ នឹងនាំទៅ សេចក្ដីសួស្ដីគប្បីមានដល់យើងដោយប្រការដូច្នេះ នាងទេវីក៏ទទួលតាមព្រះបន្ទូលថា ពាក្យដែលព្រះអង្គពោល ប្រពៃហើយ ក្សត្រីក្សត្រាទាំងពីរស្ដេចយាងទៅក្នុងទីនោះហើយ បងនូវទង់លើចុងឈើក៏គង់នៅទៀបដើមឈើ ។ ក្នុងកាលណោះ មានពាណិជ ៥០០ បើកសំពៅព្រមទាំងទំនិញទៅក្នុងសមុទ្រ បានឃើញពោធិសត្វនៅក្នុងទីនោះហើយសួរថា អ្នកនេះតើជាអ្វី ពោធិសត្វក្រោកឡើងដើរទៅទីជិតនាយសំពៅតបថា ម្នាលអ្នក ប្រាកដស្មើដោយយើង អ្នកចូរយកយើងទៅផង នាយសំពៅ ទាំងឡាយមានចិត្តអាសូរដល់ជនទាំងពីរក៏តបទៅថា បើដូច្នោះ អ្នកចូរឡើងមកលើសំពៅចុះ ពាណិជក៏នាំក្សត្រីក្សត្រាទៅ ដោយសំពៅ ។ លំដាប់កាលដែលពោធិសត្វនឹងនាងទេវីឡើង

ទៅនោះ សំពៅក៏លឿនទៅដោយកំឡាំងខ្យល់ តែលឿនទៅដោយអាការគាប់ក្រៃ ពកនោះអស់៧ថ្ងៃ ពាណិជមិនអាចបង្អង់សំពៅបាន ក៏ស្រែកយំថាយើងវិនាសមិនខានឡើយ សំពៅនោះសោតក៏ចូលទឹកបណ្តើរទៅ ព្រោះខ្សែក្តោងធ្លូទើបអណ្តែតទៅផ្តួសផ្តាសជិតនឹងលិចក្នុងសមុទ្រ ពាណិជឃើញនូវហេតុនោះក៏ភ័យតក់ស្លុត ទើបសំពះនូវទេវតាផ្សេងៗ ទួញយំអង្វរថាឱអស់ពួកទេវតាទាំងឡាយដ៏មានរិទ្ធីច្រើន គឺព្រះឥន្ទព្រះឥសូរព្រះបន្ទព្រះអាទិត្យនឹងទេវតារក្សាសមុទ្រប្ចូរជាទីពឹងនៃយើង នាំយើងអំពីសមុទ្រនេះឲ្យដល់ត្រើយព្រោះហេតុក្រណាស់ ។

## ពោធិសត្តោតំទិស្វាទេវិយាសទ្ធិ

បំណែកពោធិសត្តទ្រង់ឃើញអាការវិប្បរិតនោះ ព្រះអង្គសោយអាហារមានសប្បិទឹកឃ្មុំស្ករជាដើម ជាមួយនឹងនាងទេវីដរាបដល់ឆ្អែត ហើយទ្រង់យកសម្ពត់សាដកជ្រលក់ដោយប្រេងពន្លាពាត់ព្រះអង្គឡើងកាន់ដងក្តោង យកសំពត់បងពាក់កណ្តាលខ្លួននាងទេវី ហើយចងផ្ជាប់នឹងផែនក្តាយ៉ាងមាំ ឈរ

នៅលើចុងដងក្ដោង កាលបើសំពៅកំពុងតែលិចក្នុងទឹក មហាជនក៏បានជាអាហារនៃត្រីនឹងអណ្ដើក ដល់នូវសេចក្ដីវិនាសអស់ទៅ ។ បំណែកពោធិសត្វទ្រង់ឃើញនូវទឹកមហាសមុទ្រមានពណ៌ដូចលោហិតទ្រង់ព្រះចិន្ដាថា ហេតុនេះមិនដែលកើតដល់យើងឡើយ ទើបកំណត់នូវទិសទាំងឡាយព្រះហឫទ័យឆ្ពោះទៅថា នគរពារាណសីនឹងមានតាអញនៅក្នុងទិសនេះដូច្នេះ ព្រះអង្គក៏លោតអំពីដងក្ដោង រំលងត្រីនឹងអណ្ដើកទៅធ្លាក់ចុះក្នុងទីប្រមាណមួយឧសភ ដោយផលកម្មដែលក្សត្រាក្សត្រីទាំងពីរធ្វើអំពីមុន ផែនក្ដាក៏ដាច់ជាពីរ ។ ក្សត្រាក្សត្រីទាំងនោះមួយអង្គៗក៏បានក្ដាមួយកំណាត់ៗម្នាក់ហែលទឹកទៅ ឯក្សត្រាក្សត្រីដែលបានផែនក្ដាគោងហែលទៅនោះក៏អណ្ដែតទៅដោយខ្សែទឹកសោយនៅសេចក្ដីស្រែកឃ្លានដ៏ច្រើន ខ្សឹកខ្សួលគួរស្រណោះក្នុងកណ្ដាលសមុទ្រនោះ ។ បុច្ឆាសួរថាអកុសលកម្មដូចម្ដេច ដែលក្រសត្រទាំងពីរធ្វើក្នុងជាតិដ៏កន្លងហើយនោះ ។

វិសជ្ជនាថា ដូចបានឮថាក្នុងកាលកន្លងទៅយូរហើយក្សត្រីក្សត្រាទាំងពីរបានកើតជាប្រពន្ធនឹងប្ដីនៅក្នុងស្រុកមិន

ឆ្ងាយអំពីនគរពារាណសី ក្នុងថ្ងៃមួយនោះជនពីរនាក់ប្ដីប្រពន្ធទៅកាន់ជ្រោះស្ទឹងដើម្បីនឹងដួតទឹក, ក្នុងកាលនោះមានសាមណេរតូចមួយអង្គឡើងជិះទូកតូចអុមលេងក្នុងស្ទឹង, ជនពីរនាក់ប្ដីប្រពន្ធឃើញសាមណេរតូចក៏កញ្ជ្រោកទឹកឡើងកើតជាលលកដោយប្រាថ្នាលេងជាល្បែង ។ ទូកតូចនោះកាលបើលលកទឹកខ្លាំងខ្ទប់ក៏លិចលង់ទាំងសាមណេរ សេចក្ដីទុក្ខធំក៏កើតមានដល់សាមណេរដែលលិចលង់ក្នុងទឹកស្ទឹង ។ ជនប្ដីប្រពន្ធឃើញសាមណេរលង់ទឹកនាំគ្នាទៅត្រកងស្រង់ឡើង ។ អកុសលកម្មមានប្រមាណប៉ុណ្ណោះ ដែលជនពីរនាក់ប្ដីប្រពន្ធធ្វើហើយដោយប្រការដូច្នេះ ជនប្ដីប្រពន្ធទាំងពីរនោះបានទទួលផលជាទុក្ខយ៉ាងនេះចំនួន ៥០០ ជាតិ ។ ហេតុនោះព្រះពុទ្ធអង្គទ្រង់សម្ដែងថា បុគ្គលកុំគប្បីសំគាល់មាក់ងាយនូវបាប គឺកម្មលាមកថាមានបន្តិចបន្តួច មិនឲ្យផលទេ បាបតិចក៏គង់ឲ្យផលច្រើន តាមកន្លងសេចក្ដីទុក្ខធំ ពូជគ្រាប់ឈើយ៉ាងណាដែលបុគ្គលដាំ ពូជនោះគង់បេញផ្លែដូច្នោះ មានឧបមាដូចម្ដេច

កម្មជាកុសលក៏ឲ្យនូវផលល្អ កម្មលាមកក៏ឲ្យនូវផលអាក្រក់មានឧបមាដូច្នោះ ។

បីរប្បភាទេវីបរិយ្យាយមានាងកំបារំសម្បាបុណ្ណ

បំណែកនាងបីរប្បភាទេវីអណ្តែតទៅបានដល់នូវឆ្នេរសមុទ្រម្ខាង នាងក៏ឡើងចាកទីនោះដើរទៅតែម្នាក់ឯង រឭកពោធិសត្វមិនដាច់ ទប់ទឹកភ្នែកមិនបាន ទួញយំស្រែកហៅពោធិសត្វ ពោលជាបទគាថា ។ ខ្ញុំម្ចាស់មិនឃើញព្រះអង្គអ្នកជាទីពឹងរបស់ខ្ញុំ ខ្ញុំព្រាត់ចាកព្រះអង្គហើយនឹងរស់នៅដូចម្តេចបាន ខ្ញុំមិនឃើញនូវព្រះភក្ត្រព្រះអង្គហើយ ជីវិតខ្ញុំនឹងមិនមាន ផលទាំងពួងដែលមានដល់ខ្ញុំក្នុងអត្តភាពនេះ តើដោយកម្មដូចម្តេច ខ្ញុំបានទទួលនូវសេចក្តីសោកក្នុងអត្តភាពនេះ ព្រោះកម្មទាំងឡាយនោះ ឥឡូវនេះនឹងមានអ្នកណាជួយរំលត់សោកខ្ញុំ ទេវតាណាស្គាល់ផ្លូវក្នុងព្រៃសូមលោកប្រាប់ផ្លូវដល់ខ្ញុំ ទេវតាជាម្ចាស់ព្រៃនោះបើមិនឃើញខ្ញុំទេ ជីវិតខ្ញុំនឹងស្លាប់ឥឡូវនេះ ខ្ញុំព្រាត់ចាកប្តីហើយនឹងរស់នៅដូចម្តេចបាន ។ ត្រីទាំងឡាយស៊ីប្តីខ្ញុំទៅហើយឬ មួយទៀតសត្វឯណាគឺមង្គរក្រ-

តើដែលត្រូវទៅក្នុងទឹក សត្វនោះបរិភោគប្តីខ្ញុំស្លាប់ទៅហើយរ
ដឹង ។ នាងទេវីពោលរៀបរាប់យ៉ាងនេះហើយ ទើប
យកសំពត់ជ្រលក់ទឹក ដោះព្រះទម្រង់បីរង់រៀបនឹងដាយសំពត់
នាងមិនស្គាល់ទិសធំនឹងទិសតូចឡើយ ក៏ដើរទៅខាងមុខ
ឃើញផ្លូវមួយខំដើរទៅតាមផ្លូវនោះអស់ពីរបីថ្ងៃបានដល់ទៅនគរ
ឥន្ទបថ ។ នាងទេវីកាលចូលទៅកាន់នគរក៏ប្លែងខ្លួនជាស្រី
មានមុខសៅហ្មងអាក្រក់ដើរចូលទៅ ។ ក្នុងនគរនោះមាន
សេដ្ឋីធំម្នាក់មានទ្រព្យហិនហោចអស់ ទៅជាមនុស្សកំ-
សត់កាន់អម្បៀងដើរស្វែងរកភោជនចិញ្ចឹមជីវិត ។ នាងទេវី
ទៅដល់ផ្ទះសេដ្ឋីនោះនិយាយថា បពិត្រអ្នកម្ចាស់អ្នកប្តូរអ-
នុគ្រោះឲ្យឱកាសខ្ញុំនៅផង ។ សេដ្ឋីនោះតបទៅថា ម្នាល
នាង យើងជាមនុស្សកំសត់ នាងនឹងនៅក្នុងផ្ទះនេះដូចម្តេច
បាន នាងទេវីក៏ឆ្លើយថា បពិត្រអម្ចាស់ ហេតុនោះលើក
ទុកចុះ ខ្ញុំដឹងថាអ្នកជាមនុស្សកំសត់ហើយ ថាបើសេចក្តី
បង្អៀតបិត្តអ្នកមិនមានសោត ខ្ញុំគង់បានឱកាសក្នុងផ្ទះនេះ
ដោយសេចក្តីអាស្រ័យនៃអ្នក ។ សេដ្ឋីក៏តបថា ម្នាលនាង ជា

ហើយ នាងចូរនៅតាមប្រាប់នាចុះ នាងទេវីបានឱកាសហើយក៏អាស្រ័យនៅក្នុងផ្ទះនោះ ។ លុះដល់ថ្ងៃក្រោយនាងទេវីកាន់យកជញ្ជៀនមួយវង់ទៅកាន់សំណាក់មនុស្សចាស់ម្នាក់ហើយពោលថា អ្នកចូរលក់ជញ្ជៀននេះឲ្យខ្ញុំ មនុស្សចាស់នោះទទួលជញ្ជៀនហើយគន់មើលខាងក្រោម ខាងលើ ក៏គិតថាដូចជាអញគិតទៅ ជញ្ជៀននេះមានដំឡៃច្រើនស្មើដំឡៃនគរទាំងមូល ។ នាងទេវីនិយាយនឹងតាចាស់ថា បពិត្រអ្នកតាអ្នកចូលកាន់យកនូវប្រាក់ មាស កែវ ដ៏ពេញរទេះបំនួនតែបួនរទេះបុះ តាចាស់ក៏ទទួលតាមពាក្យនាងទេវីហើយក៏កាន់យកជញ្ជៀននោះទៅ ជនទាំងឡាយដ៏ស្តុកស្តម្ភមាំមួនមានក្នុងទីឯណា តាចាស់ក៏ទៅកាន់សំណាក់ជននោះក្នុងទីនោះលក់ជញ្ជៀនបានប្រាក់ មាស កែវ បំនួនបួនរទេះ នាំមកឲ្យនាងទេវី ។

## សាមហាល្អកស្បៃឯកសកជំទគ្វា

នាងទេវីនោះក៏ឲ្យនូវប្រាក់មាសកែវ ១ រទេះដល់តាចាស់ នាងកាន់យកប្រាក់មាសកែវបីរទេះដើម្បីខ្លួន។ លំដាប់នោះនាង

ទើបក៏លោះខ្ញុំស្រីខ្ញុំប្រុស នឹងទិញស្រូវឧសដោយមាសប្រាំរយដម្លឹង ជួលជាងឲ្យសងសាលានឹងគូររូបគំនូដោយមាសប្រាំរយដម្លឹងទៀត ហើយបង្គាប់ថា ម្នាលអ្នកទាំងឡាយ កាលបើសាលាអ្នកធ្វើស្រេចហើយ អ្នកប្ចូរគូគំនូយ៉ាងនេះៗ មានសភាពដូច្នេះៗ ក្នុងសាលា, ទើបឲ្យជាងទៅធ្វើសាលាធំមានរូបគំនូក្នុងទីប្រជុំជន ទៀបផ្លូវថ្នល់បួនជម្ប៉ងក្នុងកាលនោះ ៗ នាងទើបបង្គាប់ជាងឲ្យគូររូបនោះ ៗ ដោយបិត្តកម្មមានដូច្នេះជាដើមក្នុងសាលា តាំងអំពីដើមទី រឿងមុនដំបូងគឺស្តេចឡើងគង់លើខ្នងសេះហោះទៅលើអាកាសហើយទៅ មួយ, រឿងទីពីរគឺពោធិសត្វបើកទ្វារល្វែងប្រាសាទចូលទៅលបមើលនាង មួយ, ទីបីគឺពោធិសត្វផ្ទំលើក្រឡាបន្ទំដ៏មានសិរី មួយ, ទីបួនគឺពោធិសត្វគូររូបក្លាយជាដើមលើខ្នងស្រីបំរើឈ្មោះបទុមា មួយ, ទីប្រាំគឺពោធិសត្វចេញចាកនគរ មួយ, ទីប្រាំមួយ គឺពោធិសត្វធ្វើនូវកិច្ចមានចូលទៅនៅក្នុងសាលានៃយន្តយក្សជាដើម មួយ, ទីប្រាំពីរគឺសេះធ្វើចម្បាំងជាមួយនឹងយក្ស មួយ, ទីប្រាំបី គឺពោធិសត្វចេញចាកសាលានោះទៅឡើងសំពៅ

ទៅជាមួយនឹងពាណិជទាំងឡាយ មួយ, ទីប្រាំបួន គឺពោធិសត្វឈរលើចុងដងក្តោងហោតរំលងសត្វកាប ក្នុងកាលសំពៅកំពុងលិចចុះក្នុងមហាសមុទ្ទ មួយ, ស្រេចហើយនាងឲ្យដឹកល់ទុកនូវទានវត្ថុដើម្បីអ្នកដំណើរនឹងសមណព្រាហ្មណ៍ ដែលមកដល់ឈប់ក្នុងសាលានោះ, នាងបានផ្តាំអ្នកបំរើថា អ្នកដំណើរនឹងសមណព្រាហ្មណ៍ទាំងឡាយឯណា ៗ ចូលមកកាន់សាលានេះ អ្នកទាំងឡាយចូរញ៉ាំងជននោះ ៗ ឲ្យបរិភោគហើយនាំឲ្យមើលគំនូ បើគេសួរថាសាលានេះអ្នកណាសាងចូរប្រាប់ថាសាលានេះនាងបរិព្វាជិឈ្មោះឧម្មាទន្តីសាង ។ សាលានោះក៏មានឈ្មោះល្បីទៅថា ឧម្មាទន្តីបរិព្វាជិកាសាលា ចាប់ដើមអំពីកាលនោះមក ។

ឯវិសាពោធិសត្តស្សបវត្តិវិជាននក្លាយ

នាងទេវីនោះដែលឲ្យជាងធ្វើសាលាជូច្នេះដើម្បីនឹងឲ្យដឹងនូវដំណឹងនៃពោធិសត្វ ទើបនាងផ្តាំអ្នកបំរើថា អ្នកដំណើរនឹងសមណព្រាហ្មណ៍ឯណាមួយចូរមកកាន់សាលា អ្នកទាំងឡាយចូរញ៉ាំងជននោះឲ្យបរិភោគ នាំឲ្យមើលគំនូហើយកំ-

ណាត់ចាំនូវពាក្យនៃជននោះដែលពោលរៀបរាប់ហើយមកប្រាប់ដល់អញ ហេតុនោះបានជានាងទេវីដឹកលទ្ធកនូវទានវត្ថុដើម្បីជនអ្នកដំណើរជាដើមអស់កាលជានិច្ច ដោយប្រការដូច្នេះ ។

បំណែកពោធិសត្វដែលអណ្តែតទឹកសមុទ្រទៅដោយលំដាប់ ៗ ក៏បានដល់នៅកំពង់ឈ្មោះអញ្ជនវតី ស្តេចឡើងចាកកំពង់នោះភ្ញាក់រឭកដល់នាងបីវប្បភា មានព្រះនេត្រជោកជោកដោយអស្សុធារា ទ្រង់យាងចូលទៅក្នុងព្រៃបេកឡៀបកំពង់អញ្ជនវតីនោះ ។ គ្រានោះអញ្ជនវតីយក្ខិនីនិយាយនឹងនាងករណេវតីថា ម្នាលនាងករណេវតីនាងចូរទៅកាន់កំពង់ទឹកដងទឹកមកឲ្យអញងូត ។ នាងករណេវតីក៏ហៅរាជបុត្រី ១៦ នាងមកហើយ ឲ្យរាជបុត្រីដើរទៅមុន ខ្លួនឯងដើរទៅកាន់កំពង់ទឹក ដោយដំណើរយឺតពីខាងក្រោយ ។ បំណែកពោធិសត្វឃើញនាងករណេវតីក៏ស្គាល់ច្បាស់ កាលបើស្រីទាំងពួងងូតទឹកមុនហើយដងទឹកយកទៅ ព្រះអង្គក៏ចេញទៅអំពីព្រៃបេក ហៅនាងករណេវតីដែលដើរទៅអំពីខាងក្រោយស្រីទាំងពួងដោយពាក្យថា នែនាងករណេវតីដំបំ

រើន នាងករេណុវតីនោះឮពាក្យពោធិសត្វ ក៏មើលផ្ទៃងស្តាំ ឃើញពោធិសត្វហើយសួរថា អ្នកជាអ្វី នាងពោលយ៉ាងនេះ ហើយដើរទៅជិតពោធិសត្វសួរថា អ្នកឈ្មោះអ្វី ពោធិសត្វ តបទៅថា នាងឯងមិនស្គាល់ឈ្មោះយើងទេឬ នាងករេណុវតីក៏តបទៅថា បពិត្រម្ចាស់ខ្ញុំមិនស្គាល់ះទ ។ មហាសត្វក៏ប្រាប់ឈ្មោះខ្លួនដល់នាងករេណុវតីថា យើងឈ្មោះសុតធនុ ។ នាងករេណុវតីសួរតទៅថា ព្រះអង្គមកក្នុងទីនេះដោយហេតុដូចម្តេច ពោធិសត្វក៏ប្រាប់ហេតុដែលខ្លួនមកតាមលំដាប់តាំងអំពីដើមដល់នាងករេណុវតីនោះ។ នាងករេណុវតីឮហេតុនោះក៏យំអាសូរពោធិសត្វអស់កាលបន្តិច លំដាប់នោះពោធិសត្វក៏ប្រាប់ទៅថា ម្នាលនាងដ៏ចំរើន នាងប្តូរកុំប្រាប់នូវហេតុដែលយើងមកក្នុងទីនេះដល់អ្នកដទៃឲ្យសោះ ព្រះអង្គហាមហើយទ្រង់ក្រសាលនឹងរាជបុត្រីឈ្មោះករេណុវតី ដោយអាការ ១៦ យ៉ាង អាការ ១៦ នោះដូចម្តេច ។ ពោធិសត្វបានធ្វើនូវសេចក្តីស្និទស្នាលជាមួយនឹងនាងករេណុវតីនោះ ដោយអំណាចកិលេស, អាការ ១៦ នោះ គឺចាប់ភ្នងសក់ ១ ចាប់ស្លឹកត្រចៀក ១

ល្វកប្រហោងត្រចៀក ១ ស្នាបក្បាល ១ ស្នាបហ៊ាស ១ ស្នាប ចិញ្ចើម ១ ល្វកមាត់ ១ ចាប់ព្រមុះ ១ ស្នាបបង្កា ១ ស្នាប កណ្ដៅ ១ ចាប់ដស់ ១ ស្នាបផ្ចិតពោះ ១ ស្នាបពោះ ១ ស្នាប ផ្ចិត ១ ស្នាបផ្អឹងបំនី ១ ស្នាបយោនី ១ ។ នាងករណុវតីក៏ និយាយនឹងពោធិសត្វដោយអំណាបកិរិយាសើចស្រឡាញ់ឲ្យ-សប្បាយព្រះហ្ឫទ័យថា បពិត្រអម្ចាស់ ព្រះអង្គនៅក្នុងទីនេះ សិនចុះ កុំសម្ដែងខ្លួនឲ្យអ្នកដទៃឃើញឡើយ ។

សោសាធូតិសម្បដិច្ឆិត្វាតត្ថេវនិលិយិ

ពោធិសត្វនោះទទួលដោយពាក្យថាសាធុហើយក៏ពួន នៅក្នុងទីនោះឯង លំដាប់នោះនាងក៏ដងទឹកទូលដើរទៅតាម ក្រោយស្រីទាំងនោះ ក្នុងកាលដែលនាងករណុវតីចូលទៅ កាន់ប្រាសាទក្លិនមនុស្សក៏ផ្សាយទូទៅ ។ គ្រានោះនាងអញ្ជន វត្តីយក្ខិនីសួរនូវស្រីទាំងឡាយថា ក្លិនមនុស្សប្រក់មកអំពីទីឯ ណា មនុស្សឯណាមកក្នុងទីនេះ ។ ស្រីទាំងឡាយ ទូលទៅថា បពិត្រនាងជាម្ចាស់មនុស្សគ្មានទេ នាងអញ្ជនវតី ពោលតទៅថា ចុះហេតុអ្វីក្លិនមនុស្សទើបផ្សាយមកក្នុងទីនេះ

ហើយសួរទៅស្រីគំរប់ពីរគំរប់បី ស្រីទាំងឡាយនោះទូលថា មនុស្សមិនមានទេ ។ ក្នុងកាលដែលទៅដងទឹកថ្ងៃក្រោយទៀត ស្រីទាំងអស់នោះក៏ប្រជុំគ្នានិយាយនឹងនាងករេណុវតីថា ម្នាលនាងករេណុវតីដ៏ចំរើន កាលនាងដើរចូលទៅក្លិនមនុស្សសោតក៏ប្រាកដ យើងមានសង្ស័យនឹងនាង ព្រោះហេតុនោះថាបើនាងមិនប្រាប់នូវរឿងតាមពិតទេ យើងទាំងអស់គ្នាគង់ដឹងនូវហេតុភេទដែលនឹងធ្លាក់ចុះលើក្បាលនាងឯង យើងនឹងស្មើទោសនាងឯងនេះដល់នាងយក្ខិនីឈ្មោះអញ្ចនវតីជាអម្ចាស់មិនលែងឡើយ ។ នាងករេណុវតីឆ្លើយថា បើនាងទាំងអស់គ្នាមិនប្រាប់ដល់អ្នកឯណានីមួយ ហេតុឯណាដែលមានពិត យើងនឹងប្រាប់នូវហេតុនោះ ស្រីទាំងអស់ក៏ទូលថា យើងនឹងមិនប្រាប់ដល់អ្នកដទៃទេ នាងប្អូនប្រាប់យើងតាមពិតចុះ នាងករេណុវតីក៏ប្រាប់ថា បើដូច្នោះយើងនឹងប្រាប់នូវរឿងតាមពិតដល់នាងទាំងអស់គ្នា កាលបើស្រីទាំងឡាយពោលថា ម្នាលនាង ល្អហើយនាងប្អូននិយាយចុះ នាងករេណុវតីក៏ប្រាប់នូវអាការដែល

មហាសត្វមកថា បងរបស់យើងជាមនុស្សមកនៅក្នុងទីនេះ ស្រីទាំងឡាយសួរថា បងនាងឈ្មោះអ្វី ។ នាងករេណុវតី ប្រាប់ថា បងយើងឈ្មោះសុធនកុមារ ។ ស្រីទាំងពួងសួរទៅថា ម្នាលនាងខ្លួននាងពោលនូវពាក្យឯណា ពាក្យនោះជាពិតមែនឬមិនមែនទេ ។ នាងករេណុវតីតបទៅថា ម្នាលនាង ពាក្យយើងពិតប្រាកដ ។ ស្រីទាំងពួងសួរទៀតថា បងនាងឯងនោះរូបយ៉ាងណា សម្បត្តិរូបកាយរបស់បងនាងតើប្រាកដយ៉ាងណាទៅ ។

អបិសាពោធិសត្វសំវណ្ណនាអាហ

លំដាប់នោះនាងករេណុវតីពោលសរសើរពោធិសត្វប្រាប់ស្រីទាំងពួងថា ម្នាលនាងទាំងឡាយ បងយើងនេះជាបុរសដ៏ឧត្តមបរិបូណ៌ដោយយាងយាសដ៏មានសិរី គ្មានអ្នកឯណាមួយប្រាកដស្មើឡើយ បុគ្គលសូម្បីមានអណ្តាតមួយរយឬមួយពាន់ក៏មិនអាចពោលសរសើរនូវរូបកាយសម្បត្តិនឹងកំឡាំងតេជព្យាយាមរស្មីរបស់បងយើងនោះអស់ឡើយ ខ្លួនយើងនឹងអាចពោលសរសើរដោយអណ្តាតយើងតែមួយម្តេចនឹងអស់បាន ។

ស្រីទាំងពួងបានស្តាប់រូបកាយសម្បត្តិនៃពោធិសត្វនោះហើយ ក៏មានសេចក្តីប្រាថ្នាជាមួយគ្នាដោយអំណាចពុទ្ធគុណសម្បត្តិ ហើយក៏ទៅឈរជិតពោធិសត្វ ។ គ្រានោះព្រះពោធិសត្វបានធ្វើការបង្គំពន្ធមួយអន្លើដោយស្រីទាំងឡាយនោះ ស្រីទាំងនោះស្រឡាញ់រាប់អានពោធិសត្វដោយអំណាចកាយសំរេចគុណភាគ ពោលសរសើរហើយ នាំគ្នាទូលទុកដើរចេញទៅ ។ ក្នុងកាលស្រីទាំងឡាយនោះដើរចូលទៅកាន់ប្រាសាទ ក្លិនមនុស្សក៏បក់ផ្សាយពេញទួទាំងប្រាសាទ ។ លំដាប់នោះនាងអញ្ជនវតីធុំក្លិនមនុស្សហើយសួរថា ហេតុដូចម្តេចបានជាធុំក្លិនមនុស្សក្នុងកាលដែលនាងទាំងឡាយចូលមក, កាលបើហេតុនេះមាន នាងមិនប្រាប់អញតាមពិតទេ ជីវិតនាងរាល់គ្នានឹងមិនមានឡើយ នាងអញ្ជនវតីគំរាមដោយពាក្យដូច្នេះ ។ គ្រានោះនាងទាំងឡាយខ្លាចស្លាប់មិនអាចដើម្បីលាក់ អង្វរសូមទោសហើយទូលតាមត្រង់ថា បពិត្រអម្ចាស់ សុតធនុកុមារបុត្រាព្រះបាទពារាណសី ជាបងនាងករុណាវតីមកនៅក្នុងទីនេះ ។

នាងអញ្ជូនវតីបានឮពាក្យថា "សុគន្ធ" បុណ្ណោះ ហាក់បីដូចជាគេយកទឹកអម្រឹតមកស្រោចដួងចិត្តក៏មានបីតិសោមស្សកើតឡើង ហើយគិតថា បើរាជកុមារជាអ្នកប្រាជ្ញមែន គង់ដឹងអធិប្បាយអញដោយសញ្ញានេះពិត គិតហើយនាងក៏សសេរសំបុត្រដោយម្រាមដៃខ្លួនប្រគល់ឲ្យនាងករុណាវតី ផ្តាំថា បើរាជកុមារនោះជាបណ្ឌិតមែនគង់ដឹងអធិប្បាយនេះចូរយាងមកក្នុងទីនេះចុះ ថាបើមិនដឹងអធិប្បាយនេះទេ រាជកុមារនោះនឹងបានជាអាហារអញ ផ្តាំដូច្នេះហើយក៏បញ្ជូននាងករុណាវតីទៅ នាងករុណាវតីទទួលសំបុត្រហើយយំដើរទៅកាន់សំណាក់ពោធិសត្វថ្វាយបង្គំថ្វាយសំបុត្រទូលថា បពិត្ររាជបុត្រថាបើព្រះអង្គជ្រាបស្នាមក្នុងសំបុត្រនេះ ជីវិតព្រះអង្គនៅរស់តទៅបាន ថាបើមិនជ្រាបទេ ជីវិតព្រះអង្គច្បាស់ជាគ្មានហើយ ។ ពោធិសត្វឃើញស្នាមនោះក៏ជ្រាបថា នាងអញ្ជូនវតីយក្ខិនីនេះស្រឡាញ់អញដោយសេចក្តីដំរេក ទើបត្រាស់នឹងនាងករុណាវតីថា យើងដឹងនៅស្នាមក្នុងសំបុត្រនោះ ទើបទ្រង់

គូររូបព្រះអង្គប៉ីជួបជាចាប់ខុបកណ្ដាំនាងអញ្ចនវតី ហើយប្រគល់ឲ្យនាងករេណុវតីទ្រង់បញ្ជូនឲ្យទៅវិញ ។

## សាតំអាទាយតស្បាយក្ខុឥយាហាត្ថេបបេសិ

នាងករេណុវតីកាន់យករូបនោះទៅថ្វាយនាងអញ្ចនវតី ៗ ឃើញរូបក៏ព្រឺព្រួច មានខ្លួនពាល់ត្រូវដោយបីតិ៥ប្រការហើយគិតថា ហេតុនេះគួរហើយ ទើបម៉ឺម្ចាយកគ្រឿងអម្ពរសំរាប់ប្រដាប់ កម្រងផ្កានឹងគន្ធវិលេបនសំរាប់លាបខ្លួន មកហុចឲ្យនាងករេណុវតីបញ្ជូនឲ្យនាំទៅថ្វាយពោធិសត្វ នាងករេណុវតីក៏នាំយកទៅថ្វាយពោធិសត្វទូលថា បពិត្រអម្ចាស់ របស់ទាំងនេះនាងអញ្ចនវតីបញ្ជូនមកថ្វាយព្រះអង្គ ។ ពោធិសត្វឮពាក្យនោះក៏គិតថា គួរយើងទៅឥឡូវនេះ ទើបស្ដេចស្រង់ទឹកប្រដាប់កាយ មិនប្រញាប់ពេកស្ដេចយាងទៅដោយសិរីវិលាសតាមប្រក្រតីខ្លួន ឡើងកាន់ប្រាសាទនាងប៉ីជួបរាជសីហាជុំទង់មិតពត់ពុំនោះសោតប៉ីជួបគ្រឹះគន្ធ មានពួកនាងនារីហោមរោមយាងឡើងកាន់ទៅប្រាសាទ ។ បំណែកនាងអញ្ចនវតីបើកបង្អួច

ចាំមើលពោធិសត្វ ឃើញពោធិសត្វយាងមកក៏ត្រេកអរថា រាជបុត្រនោះមកហើយតើ ទើបស្រែកហៅថា មហាបុរសប្ដូរមកឆាប់ ៗ លំដាប់នោះមហាសត្វចាប់ដៃនាងអញ្ជនវតីនោះឱបអភិរម្យជាមួយគ្នា ៗ ចាប់ដើមអំពីនោះមក នាងអញ្ជនវតីក៏ស្រឡាញ់ពោធិសត្វលើសលន់គណនាមិនបាន ៗ កាលបើកាលកន្លងទៅយ៉ាងនេះ ក្នុងថ្ងៃមួយពោធិសត្វរឭកមាតាក៏គិតថា អញនឹងបានទៅឃើញមាតាដោយឧបាយដូចម្ដេចហ្ន៎ ទើបព្រះអង្គមានបន្ទូលនឹងនាងករេណុវតីថា ម្នាលនាងករេណុវតីដ៏ចំរើនដូចបានឮថា សេះក្នុងទីនេះមានដែរឬ, នាងករេណុវតីក្រាបទូលថា បពិត្រសម្មតិរាជ សេះមានក្នុងទីនេះ ពោធិសត្វសួរថា យើងនឹងបាននូវសេះនោះដោយឧបាយដូចម្ដេច ៗ នាងករេណុវតីទូលថា បពិត្រសម្មតិរាជ នាងអញ្ជនវតីនេះស្រឡាញ់ព្រះអង្គជាស្វាមី នាងឈរក្ដី អង្គុយក្ដី ដើរក្ដី ក្នុងទីឯណា ៗ រមែងពោលសរសើរគុណព្រះអង្គក្នុងទីនោះៗ ហេតុនោះព្រះអង្គអាចបាននូវសេះអំពីសំណាក់នាងដោយឧបាយឯណានីមួយមិនលែង ៗ

ពោធិសត្តថា ឧបាយនោះមានពិត ។ ក្នុងថ្ងៃមួយជាខាងក្រោយ ទ្រង់ធ្វើជារឰកព្រះមាតាទ្រង់ព្រះកន្សែងក្នុងបច្ចុសម័យ, គ្រានោះនាងអញ្ជនវតីភ្ញាក់ឡើងសួរថា ហេតុអ្វីបានជាព្រះអង្គទ្រង់ព្រះកន្សែង, ពោធិសត្តទ្រង់ស្ងៀម ។ នាងអញ្ជនវតីសួរអស់វារពីរដងបីដងដោយប្រការដូច្នេះ, ពោធិសត្តក៏តបទៅថា ម្នាលនាងដ៏ចំរើន កាលមុនយើងនៅក្នុងនគរពារាណសីធ្លាប់លេងល្បែងដោយសត្វមានដំរីសេះជាដើម ដល់មកនៅក្នុងទីនេះដោយហោចទៅ សូម្បីតែឃើញសត្វនីមួយយើងមិនដែលឃើញ ហេតុនោះបានជាយើងយំ ម្នាលនាងថាបើនាងមានសេចក្តីស្រឡាញ់យើង នាងចូរសូមសេះរបស់បងនាងឲ្យយើងថាបើយើងមិនបាននូវសេះនោះទេ ជីវិតយើងក៏នឹងមិនមាន ។ នាងអញ្ជនវតីទូលថា កាលបើហេតុយ៉ាងនេះមាន ព្រះអង្គកុំគិតឡើយ ខ្ញុំនឹងជានាឲ្យគេទៅសូមសេះនោះឲ្យបាន ។ លុះដល់ថ្ងៃក្រោយ នាងអញ្ជនវតីប្រាប់នាងករេណុវតីឲ្យទៅសូមសេះដោយពាក្យថា ម្នាលនាងករេណុវតីនាងចូរទៅសូមសេះអំពីបងអញ ។

## សាសាធុអយ្យោតិយក្ខស្សូសន្តិកំគន្ធារន្ធិតា

នាងករណេវតីទទួលថាសាធុ ហើយដើរទៅកាន់សំណាក់យក្ខសំពះហើយទូលនូវហេតុនោះ ៗ យន្ធារយក្ខបានស្តាប់នៅពាក្យនោះក៏ឆ្លើយថា នាងកុំពោលយ៉ាងនេះឡើយ ដ្បិទសេះនោះកាបណាស់ បើនាងចាប់យកទៅជីវិតនាងឯងនឹងក្ស័យ នាងចូរទៅប្រាប់ប្អូនស្រីអញ្ញវិញចុះ ។ នាងករណេវតីក៏ត្រឡប់ទៅទូលដល់នាងអញ្ជនវតីវិញ នាងអញ្ជនវតីក៏ទូលហេតុនោះដល់ពោធិសត្វ ៗ បានស្តាប់ពាក្យនោះទ្រង់ព្រះករន្សែងទៀត ។ លំដាប់នោះនាងអញ្ជនវតីអត់មិនបាននៅរឿងដែលពោធិសត្វយំក៏ប្រើនាងករណេវតីទៅទៀតថា ម្នាលករណេវតី នាងចូរទៅកុំខ្លាចឡើយ ដ្បិទសេះនេះបងអញឲ្យបងទុកមកយូរហើយ តឡូវនេះប្រហែលជាបាត់ស្រវឹងបាត់កាចហើយ នាងចូរទៅសូមទៀត ។ នាងករណេវតីទៅកាន់ដំណាក់យក្ខម្តងទៀត ទូលនូវដំណើរនោះ យក្ខសោតក៏តបទៅថា បើដូច្នោះនាងចូរចាប់យកទៅចុះ ។ លំដាប់នោះនាងករណេវតី សេះគឺយក្ខបងទុកក្នុងទីឯ-

ណាក៏ដើរទៅកាន់ទីនោះនិយាយនឹងសេះថា ម្នាលមណិកក្ខ សុតធនុរាជកុមារជាម្ចាស់អ្នកឯងមកនៅក្នុងទីនេះ សេះបានឮពាក្យនោះក៏គិតថា ម្ចាស់អញមកនៅក្នុងទីនេះទេតើ ហើយក៏សម្រក់ទឹកភ្នែកដោយរឭកម្ចាស់ នឹងត្រឡប់មានចិត្តត្រេកអរវិញដោយគិតថា អញនឹងបានឃើញម្ចាស់អញក្នុងថ្ងៃនេះ សេះក៏ស្រែកដោយសំឡេងខ្លាំង ។ គ្រានោះនាងកេរណារីតីក៏ស្រាយនៅបំណង់សេះដឹកទៅបញ្ឈរទុកខាងមុខប្រាសាទ ហើយថ្វាយបង្គំយក្ខារយក្ខ ។ យក្ខារយក្ខឃើញសេះហើយសួរនាងកេរណារីតីថា នាងចាប់សេះនេះបានដោយឧបាយដូចម្ដេច ។ នាងកេរណារីតីក្រាបទូលថា បពិត្រទេវយក្ខខ្ញុំម្ចាស់ចាប់សេះនេះបានដោយអានុភាពប្អូនស្រីព្រះអង្គ ។ យក្ខារយក្ខក៏សួរថា ប្អូនអញចេះមន្តដូចម្ដេចឬ ។ នាងកេរណារីតីទូលទៅថាបពិត្រទេវយក្ខ ប្អូនព្រះអង្គមិនចេះមន្តទេ តែថាខ្ញុំចាប់សេះបានដោយអានុភាពនៃនាង ហើយក៏នាំសេះទៅកាន់សំណាក់ពោធិសត្វថ្វាយទតព្រះនេត ។ បំណែកពោធិសត្វឃើញសេះ ទ្រង់ឈរទតសេះនោះមានព្រះនេត្ររលីមរលាម

ដោយអស្សុផលធារា ។ បំណែកឯសេះឃើញព្រះពោធិសត្វក៏បង្ហូរទឹកភ្នែកហើយសួរពោធិសត្វថា បពិត្រមហារាជនាងទេវីទៅឯណា ។ ពោធិសត្វឆ្លើយថា ម្នាលមណិកកូដ៏បំរើងយើងមិនដឹងជានាងទេវីទៅក្នុងទីឯណាទ្បើយ ។ កាលបើពោធិសត្វពោលយ៉ាងនេះ សេះក៏ទ្បូងលោមពោធិសត្វថា បពិត្រមហារាជកាលបើយ៉ាងនេះ ព្រះអង្គមិនគួរនៅក្នុងទីនេះយូរពេកទេ ។ ពោធិសត្វឆ្លើយថា ហេតុនេះលើកទុកសិនហើយព្រះអង្គក៏គង់នៅក្នុងទីនោះអស់ពីរបីថ្ងៃ ។ ក្នុងថ្ងៃមួយស្ដេចមានបន្ទូលនឹងនាងអញ្ជនវតីថា យើងទាំងទ្បាយនឹងធ្វើមហោរស្រពគឺផឹកសុរាក្នុងឱទ្យាន បានជាយើងថាយ៉ាងនេះព្រោះសេះនេះយើងក៏បានមកហើយ យើងនឹងផឹកនូវវិជយបានដ៏ប្រសើរជាកំសាន្ត ។ នាងអញ្ជនវតីក៏ធ្វើតាមពាក្យពោធិសត្វឲ្យតាក់តែងនូវសុរាដ៏ច្រើន ទើបឲ្យស្រីបំរើទាំងទ្បាយកាន់យកនូវសុរាដើរទៅកាន់ឱទ្យានហើយនាំគ្នាផឹកនូវសុរា ។

តាំងពីអញ្ជនវតីបមុខាសុរាមទត្តាអសតី

ស្រីទាំងពួងនោះមាននាងអញ្ជនវតីជាប្រធាន មិនមាន

ឈ្មោះតីមិនបានដឹងខ្លួនប្រាណព្រោះហេតុស្រវឹងសុរា ក៏ចូលទៅកាន់ប្រាសាទដេកលក់សន្ធឹកសន្ធៃ ។ លំដាប់នោះពោធិសត្វមានបន្ទូលនឹងនាងករេណុវតីថា ម្នាលនាងករេណុវតី នាងកុំគិតឡើយ ចូរនាងនៅក្នុងទីនេះសិនចុះ មិនយូរប៉ុន្មានយើងនឹងមកនាំនាងយកទៅ ។ ពោធិសត្វពោលយ៉ាងនេះហើយក៏ឡើងគង់លើសេះហោះទៅកាន់អាកាស យាងទៅដោយលំដាប់ដរាបដល់ឥន្ទបថនគរ កាលព្រះអង្គចូលទៅក្នុងនគរនោះហើយក៏ទ្រង់ប្លែងភេទខ្លួនជាព្រាហ្មណ៍ហើយមានបន្ទូលនឹងមណិកក្កថា ម្នាលមណិកក្ក អ្នកចូរនៅក្នុងទីនេះចុះ យើងនឹងដើររកនាងបីរប្ជាភក្នុងនគរនេះ ព្រះអង្គឲ្យសេះឈប់ខាងក្រៅនគរស្តេចយាងចូលទៅក្នុងនគរតែមួយអង្គឯង សួរមនុស្សទាំង-ឡាយថា សមណនឹងព្រាហ្មណ៍ជាអ្នកប្រាជ្ញគេធ្លាប់ប្រជុំគ្នាក្នុងទីឯណា ។ មនុស្សទាំងឡាយនោះតបទៅថា ម្នាលព្រាហ្មណ៍ដ៏ចំរើន មាននាងបរិព្វាជិកាម្នាក់ឲ្យជាងធ្វើនូវសាលាមួយឈ្មោះឧម្មាទន្តីក្នុងទីឈ្មោះឯណោះ គួរជាទីត្រេកអរក្រៃពេកសមណនឹងព្រាហ្មណ៍ទាំងឡាយជាអ្នកប្រាជ្ញដ៏ច្រើនតែងមក

ប្រជុំគ្នាក្នុងសាលានោះ ។ ពោធិសត្វក៏យាងទៅតាមផ្លូវដែលមនុស្សទាំងឡាយនោះបង្ហាញ លុះទៅដល់សាលានោះក៏ពោលនូវពាក្យដ៏ជាទីនាំមកនូវសេចក្ដីរឿកជាមួយនឹងសមណព្រាហ្មណ៍ដែលចូលទៅមុន ៗ ។ លំដាប់នោះនាងទាសីទាំងឡាយជាស្រីបំរើនៅក្នុងសាលានោះ កំពុងអង្គាសព្រាហ្មណ៍កំលោះដែលទើបមកប្ដីឲ្យបរិភោគខាងក្រៅសាលា ក្នុងកាលព្រាហ្មណ៍គឺពោធិសត្វនោះដើរចូលទៅ ពួកនាងទាសីក៏និយាយថា បពិត្រមហាព្រាហ្មណ៍ ធម្មតាសមណព្រាហ្មណ៍ដែលចូលមកកាន់សាលានេះគប្បីដឹងនូវវត្ត. ព្រាហ្មណ៍កំលោះក៏សួរថា វត្តដូចម្ដេចដែលព្រាហ្មណ៍គប្បីដឹង ។ នាងទាសីក៏តបទៅថា ដូចបានឮថា សមណព្រាហ្មណ៍ឯណា ៗ កាលចូលមកកាន់សាលានេះ គួរមិលមើលរូបគំនូរក្នុងសាលានេះការដែលមើលរូបគំនូរនេះឯងជាវត្តរបស់សមណព្រាហ្មណ៍អំបាលនោះ ហេតុនោះខ្លួនអ្នកត្រូវចូរមកដើរមើលរូបគំនូរនេះសិន ។ កាលបើនាងទាសីពោលយ៉ាងនេះ មហាបុរសក៏ចូលទៅកាន់សាលាទតរូបគំនូរនោះ ៗ រៀងទៅ ក៏ឃើញនូវ

រូបភាពត្រង់ដែលព្រះអង្គចូលទៅកាន់ប្រាសាទជាដំបូងក៏ទ្រង់ព្រះសិរិលម្តង ហើយយាងទតដោយលំដាប់ទៅខាងមុខទៀតឃើញគំនូរត្រង់ដែលនាងពិរប្បភាចាប់ពាក់កណ្តាលខ្លួន នាងបទុមាចាប់ជើងក៏ទ្រង់ព្រះសិរិលខ្លាំងជាងមុន ហើយយាងទតទៅខាងមុខទៀត ឃើញរូបត្រង់រឿងនោះ ៗ ចាប់ដើមអំពីព្រះអង្គចេញចាកនគរទៅដរាបដល់ព្រះអង្គចូលទៅក្នុងសាលាយន្តារយក្ខ ព្រះអង្គមានព្រះហឫទ័យអន់គិតដល់ទុក្ខ យាងទតទៅខាងមុខទៀតក៏ឃើញគំនូរត្រង់ព្រះអង្គគង់ក្រោមដើមឈើទៀបឆ្នេរសមុទ្រធំហើយបង់ទង់លើចុងឈើ ដល់មកត្រង់នេះទឹកព្រះនេត្រក៏ហៀរហូរចេញមក ទតទៅខាងមុខទៀតឃើញគំនូរត្រង់ព្រះអង្គលោតអំពីដងក្តោងក្នុងកាលសំពៅលិចចុះក្នុងមហាសមុទ្រ ហើយឃើញរូបទេវីរបស់ព្រះអង្គមានខ្សែជាប់ពាក់កណ្តាលដោយបង់ផ្ជាប់គ្នាក្នុងកាលហែលទឹកសមុទ្រ ព្រះអង្គក៏ទ្រង់ព្រះកន្សែងយ៉ាងខ្លាំង ។

អថតាបរិចារិកាតំបាសន្តញ្ញភាទន្តញ្ញទិស្វា

លំដាប់នោះស្រីបំរើទាំងឡាយនោះកាលឃើញពោធិសត្វ

សើបផងយំផងដូច្នោះ ក៏ទៅកាន់សំណាក់នាងទេវីជំរាបថា បូ-ពិត្រនាងជាម្ចាស់ មានព្រាហ្មណ៍កំលោះម្នាក់ឃើញរូបគំនូក្នុងសាលាបានធ្វើនូវកិរិយាយ៉ាងនេះផង ៗ ។ ខណនោះនាងបិ-វប្បាភានោះក៏បើកនៅបង្អួចមើលមកក៏ស្គាល់ជាមហាសត្វ នាងមិនអាចនឹងទប់ខ្លួនបាន ក៏ទ្រង់ព្រះកន្សែងយាងពុះបាកប្រា-សាទ មហាសត្វនៅក្នុងទីឯណា នាងទៅកាន់ទីនោះ លុះចូលទៅដល់ហើយក៏ក្រាបទៀបព្រះបាទពោធិសត្វពោលរៀបរាប់ផ្សេង ៗ ជាបទគាថាថា ហឫទ័យនៃខ្ញុំដែលក្តៅព្រមដោយភ្លើងគឺសេចក្តីសោកក៏ត្រឡប់បានត្រជាក់ក្នុងថ្ងៃនេះ បពិត្រសម្មតិ-រាជ ខ្ញុំឃើញព្រះអង្គជាស្វាមី ក៏មានសេចក្តីសោកប្រាសចេញ ៗ បំណែកពោធិសត្វក៏បរបាដោយពាក្យសំណេះសំ-ណាលទាំងឡាយដ៏ជាទីនាំមកនូវសេចក្តីស្រឡាញ់មានប្រការផ្សេងៗជាមួយនឹងនាងពិវប្បាភានោះ ។ គ្រានោះ មនុស្សដែលនៅក្នុងនគរក៏ផ្អើលជ្រួលជ្រើមទៅហោមរោមពោធិសត្វ និយាយគ្នាថា ដូចបានឮថាព្រាហ្មណ៍នេះឈ្មោះសុតធនុ ។ គ្រានោះព្រះបាទមហាបនាទរាជមានបន្ទូលនឹងពោធិសត្វថា ព្រះអង្គ

ប្តូរទទួលគ្រប់គ្រងនៅរាជសម្បត្តិរបស់ខ្ញុំ ហើយក៏ប្រគល់រាជសម្បត្តិថ្វាយពោធិសត្វ ដោយប្រការដូច្នេះ ។ ព្រះមហាសត្វទ្រង់ឃាត់ទៅព្រះបាទមហាបនាទរាជនោះដោយមិនប្រាថ្នារាជសម្បត្តិ ស្តេចគង់នៅក្នុងនគរនោះពីរបីថ្ងៃ ទ្រង់លាព្រះបាទមហាបនាទរាជនឹងប្រទានទរាទដល់ជនទាំងពួងហើយឡើងគង់លើសេះដោយលីលាសមានប្រការដ៏ច្រើន ជាមួយនឹងនាងទេវីយាងទៅនគរពារាណសីដោយលំដាប់ ។ ព្រះមាតានៃមហាសត្វចាប់ដើមអំពីកាលបុត្រទៅ មានព្រះនេត្រពេញដោយអស្សុជលសព្វកាលសព្វវេលា គឺវេលាថ្ងៃយប់ទ្រង់ឈរនៅទៀបទ្វារប្រាសាទទ្រង់ទន្ទឹងមើលផ្លូវពោធិសត្វអស់កាលជានិច្ច ។ បំណែកពោធិសត្វកាលយាងមកដល់ក៏ទ្រង់ចុះចាកអាកាសចូលទៅថ្វាយបង្គំព្រះបាទមាតាជាមួយនឹងនាងទេវីហើយទ្រង់ព្រះកន្សែង ។

អបិសាតំឧបគុយ្ហិត្វាសីសំចុម្ពិត្វា

លំដាប់នោះព្រះមាតាកៀកឱបព្រះរាជបុត្តថើបព្រះសិរមានព្រះសុរិណ្ណីថា កូនណើយចាប់ដើមអំពីអ្នកចេញទៅ ឱមាតា

កាលដើរក្តី ឈរក្តី អង្គុយក្តីមាននយ័ន៍នេត្រពេញដោយទឹកភ្នែក
កើតទុក្ខអស់កាលជានិច្ចដរាបនោះ ដល់វេលាអ្នកមកដល់ក្នុង
កាលឥឡូវនេះមាតាមានសោករលត់អស់ មានទឹកភ្នែកប្រាស
ចេញ មានមុខថ្លាល្អមានពណ៌រស្មី កាលនាងថ្លែងរៀបរាប់
នូវពាក្យច្រើនប្រការជាមួយនឹងពោធិសត្វនោះហើយ ក៏បញ្ជូន
ព្រះរាជបុត្តឲ្យទៅសម្រាកឯប្រាសាទ ។

គ្រានោះអ្នកនគរក៏អញ្ជើញព្រះពោធិសត្វឲ្យគង់លើគំនរ
កែវជាមួយនឹងនាងទេវីអភិសេកជាថ្មីម្តងទៀត បានប្រគំតូរិយ
តន្ត្រីទាំងពួងមានស្គរ សម្ភោ បណ្ឌវ សំខ ជាដើមមានសម្លេង
គឹកកងរំពងទូទាំងព្រះនគរ ។ លុះកាលមកខាងក្រោយអំពីវេលា
អភិសេកនោះ ព្រះមហាសត្វទ្រង់នឹករឭកដល់នាងអញ្ជនវតី
នឹងនាងករេណុវតី ទើបស្តេចឡើងគង់លើមណិកក្ខអស្សត្រ
យាងទៅដោយលំដាប់ដរាបដល់ដែនយន្តារយក្ខ ទ្រង់ស្ថិតនៅ
លើអាកាសអំពីខាងមុខប្រាសាទត្រាស់បង្គាប់ទៅយន្តារយក្ខថា
ម្នាលមហាយក្ខ អ្នកចូរឲ្យនាងអញ្ជនវតីជាភរិយាយើងមកយើង
ថាបើអ្នកមិនឲ្យមកយើងទេ អធម្មដ៏ធំនឹងបង្កើតដល់អ្នកមិន

លែងឡើយ ។ យក្ខបានឮពាក្យពោធិសត្វនោះក៏ទៅកាន់សំណាក់ប្អូនស្រីហើយសួរថា ស្តេចឈ្មោះសុតធនុជាប្តីនៃនាងពិតឬ, នាងអញ្ជនវតីក៏ទូលថា សុតធនុរាជជាប្តីខ្ញុំពិតមែនអ្នកបង ។ យក្ខក៏មានចិត្តជ្រះថ្លាក្នុងពោធិសត្វដើរទៅកាន់ទីជិតពោធិសត្វហើយទូលថា ម្នាលមហាបុរសដ៏បំពើនអ្នកចូលមកចុះ យើងនឹងឲ្យប្អូនស្រីយើងដល់អ្នកឥឡូវនេះ ។ លំដាប់នោះមហាសត្វគិតថា យក្ខនេះមានចិត្តទន់ហើយ គួរអញឲ្យស្ថិតនៅក្នុងបញ្ចសីលក្នុងកាលឥឡូវនេះ បើយក្ខនោះស្ថិតនៅក្នុងឱវាទនៃអញរក្សាបញ្ចសីលហើយនឹងបានទៅកើតក្នុងស្ថានសួគ៌ទេវលោកក្នុងកាលជាងក្រោយ ទ្រង់គិតហើយចុះចាកអាកាសចូលទៅកាន់ប្រាសាទនាងអញ្ជនវតីជាមួយនឹងបេត្តារយក្ខនោះ ។

តតោសោអត្តនោភរិយំសំសន្និបាតាបេត្វា

លំដាប់នោះយក្ខាយក្ខក៏ប្រជុំបរិសទ្យក្នុងភពនៃខ្លួន លុះបានជួបជុំហើយក៏ធ្វើគ្រឿងសក្ការៈដ៏ច្រើនដល់មហាសត្វ ហើយថ្វាយនូវប្អូនស្រីខ្លួនដល់មហាសត្វនោះ ។ ព្រះមហាសត្វក៏

ទទួលយកនាងអប្សរនារី ហើយឲ្យឱវាទយក្ខថា ម្នាលមហាយក្ខដ៏ចំរើន ខ្ញុំនឹងអ្នកក្នុងកាលមុនបានបង្កើតជាមនុស្ស ប្រព្រឹត្តនូវអំពើទុច្ចរិតដោយកាយខ្លះ ដោយវាចាខ្លះ ដោយចិត្តខ្លះ ព្រោះហេតុកម្មអាក្រក់នេះ បានជាអ្នកមកកើតក្នុងកំណើតយក្ខកាចសាហាវអាក្រក់ក្នុងកាលឥឡូវនេះ ចាប់ដើមអំពីថ្ងៃនេះទៅអ្នកចូរប្រព្រឹត្តសុចរិតបីប្រការ ចូររក្សានូវបញ្ចសីលក្នុងគ្រានេះ សីល ៥ នោះដូចម្ដេចខ្លះ គុណទាំងឡាយនេះបាននឹងចេតនាដែលលះបង់នូវបាបធម៌គឺវៀរសម្លាប់សត្វ ១ វៀរចាកកាន់យកនូវទ្រព្យអ្នកដទៃ ដែលគេមិនបានឲ្យដោយកាយនឹងវាចា ១ វៀរចាកប្រព្រឹត្តខុសក្នុងកាមគុណទាំងឡាយ ១ វៀរចាកពោលនូវពាក្យកុហក ១ វៀរចាកហេតុនៃសេចក្ដីប្រមាទគឺផឹកនូវទឹកស្រវឹងគឺសុរានឹងមេរយ ១ គុណធម៌ទាំង ៥ នេះឯងឈ្មោះថាបញ្ចសីល ។

ម្នាលយក្ខដ៏ចំរើន ដ្បិតថាបាណាតិបាតកម្មគឺបុគ្គលឯណាមួយបានសេព បានចំរើន បានធ្វើឲ្យច្រើនយ៉ាងនេះហើយ បាណាតិបាតកម្មនៃបុគ្គលនោះរមែងបណ្ដាលឲ្យមាន

ឥន្ទ្រិយ៍ជាទុក្ខមានផលជាទុក្ខ មិនជាទីប្រាថ្នា មិនជាទីត្រេកអរ តែងឲ្យបុគ្គលធ្លាក់ទៅក្នុងអបាយភូមិទាំងឡាយ ថាបើបុគ្គលនោះច្យុតចាកអត្តភាពនោះទៅហើយ ត្រឡប់មកកាន់អត្តភាពជាមនុស្សនេះវិញ ក៏នឹងមានទុក្ខច្រើន មានពៀរច្រើន មានអាពាធច្រើន មានអាយុខ្លី ។ ម្នាលយក្ខ បាណាតិបាតកម្មឯណានេះដែលបុគ្គលធ្វើហើយ បាណាតិបាតកម្មនោះប្រព្រឹត្តទៅដើម្បីអាយុខ្លី ។

ម្នាលយក្ខដ៏ចំរើន បុគ្គលកាន់យកនូវទ្រព្យដែលគេមិនឲ្យ កាលច្យុតចាកអត្តភាពនោះទៅ បើមកកាន់មនុស្សជាតិនេះវិញ ទោះកើតក្នុងទីណា ៗ រមែងមានទុក្ខច្រើន មានផលជាទុក្ខច្រើន ជាមនុស្សកំសត់ មានសម្បត្តិតិច មានបាយទឹកភោជនតិច មានអន្តរាយកើតដល់ទ្រព្យមកអំពីស្តេចខ្លះ អំពីចោរខ្លះ អំពីភ្លើងខ្លះ អំពីទឹកខ្លះ អំពីបិសាចខ្លះ អំពីសេចក្តីត្រេកអរអាក្រក់ខ្លះ ។ ម្នាលយក្ខដ៏ចំរើន អទិន្នាទានឯណានេះដែលបុគ្គលធ្វើហើយ អទិន្នាទាននោះប្រព្រឹត្តទៅ ដើម្បីសេចក្តីទាល់ក្រលំបាក ។

ម្នាលយក្ខដ៏ចំរើន កិរិយាប្រព្រឹត្តខុះក្នុងកាមទាំងឡាយ គឺបុគ្គលឯណាមួយសេពហើយ ចំរើនហើយ ធ្វើឲ្យច្រើនហើយ មិច្ឆាចារនោះរមែងបណ្តាលឲ្យមានគតិន្ទ្រិយ៍ជាទុក្ខ មានផលជាទុក្ខមិនជាទីប្រាថ្នាមិនជាទីត្រេកអរ ប្រព្រឹត្តទៅក្នុងអបាយ គប្បីមានដល់បុគ្គលនោះ ។ ម្នាលយក្ខ បើបុគ្គលនោះច្យុតចាកអត្តភាពនោះទៅហើយមកកាន់មនុស្សជាតិនេះវិញ នោះកើតក្នុងទីឯណា ៗ ជាខាងក្រោយ រមែងមានពណ៌កាយអាក្រក់ រូបអាក្រក់លាមកមិនគួរដល់ការមើល មិនគួរដល់ការឃើញ រមែងដល់នូវសភាពជាមនុស្សខ្វើយនឹងបណ្ឌកជាដើម ។ ម្នាលយក្ខ កាមេសុមិច្ឆាចារឯណានេះដែលបុគ្គលធ្វើហើយ មិច្ឆាចារនោះរមែងប្រព្រឹត្តទៅដើម្បីរូបអាក្រក់ ។

ម្នាលយក្ខ កិរិយាពោលនូវពាក្យកុហក ដែលបុគ្គលឯណាមួយសេពហើយ ចំរើនហើយ ធ្វើឲ្យច្រើនហើយយ៉ាងនេះ មុសាវាទនោះរមែងបណ្តាលឲ្យមានឥន្ទ្រិយ៍ជាទុក្ខ មានផលជាទុក្ខមិនជាទីប្រាថ្នា មិនជាទីត្រេកអរ ប្រព្រឹត្តទៅដើម្បីអបាយ ប្រព្រឹត្តទៅដើម្បីនរក គប្បីមានដល់បុគ្គលនោះដោយ

ពិត ។ ម្នាលយក្ខ ថាបើបុគ្គលនោះច្យុតចាកអត្តភាពនោះទៅ ហើយមកកាន់មនុស្សជាតិនេះវិញ កើតក្នុងទីណា ៗ ជាខាងក្រោយ កាលនិយាយពាក្យអ្វីទៅគេរមែងមិនជឿ អ្នកដទៃត្រឡប់ពោលថាប្រយោជន៍អ្វីដោយពាក្យអ្នកនេះ អ្នកនេះឯងពោលកុហកទេ ។ ម្នាលយក្ខ មុសាវាទឯណានេះដែលបុគ្គលធ្វើហើយ មុសាវាទនោះឯងប្រព្រឹត្តទៅដើម្បីទោសមានមាត់ស្អុយជាដើម ។

ម្នាលយក្ខ ហេតុនៃសេចក្តីប្រមាទគឺផឹកនូវទឹកស្រវឹងគឺសុរានឹងមេរ័យ ដែលបុគ្គលឯណាមួយសេពហើយ ចំរើនហើយ ធ្វើឲ្យច្រើនហើយ សុរាមេរ័យនោះរមែងបណ្តាលឲ្យមានឥន្ទ្រីយ៍ជាទុក្ខច្រើន មានផលជាទុក្ខច្រើន មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត ប្រព្រឹត្តទៅដើម្បីអបាយ ប្រព្រឹត្តទៅដើម្បីនរក គម្បីមានដល់បុគ្គលនោះដោយពិត ។ ម្នាលយក្ខ ថាបើបុគ្គលនោះច្យុតចាកអត្តភាពនោះទៅហើយមកកាន់មនុស្សជាតិនេះវិញ ទោះកើតក្នុងទីណា ៗ ជាខាងក្រោយ ជាមនុស្សមានបញ្ញាអាក្រក់ កើតជាមនុស្សឆ្កួត

ដល់នូវសភាពជាមនុស្សគរជាដើមក្នុងមនុស្សលោកនេះ មាន
វាចាមិនបរិបូណ៌ មានសតិភ្លេចភ្លាំង ។ សុរាមេរយមជ្ជបមា
ទដ្ឋានឯណានេះដែលបុគ្គលសេពហើយ ម្នាលយក្ខដ៏បំរើន
សុរាមេរយមជ្ជទដ្ឋាននោះ ប្រព្រឹត្តទៅដើម្បីទោសមានបញ្ញាខ្លៅ
ជាដើមដោយប្រការដូច្នេះ ។ ម្នាលយក្ខ បញ្ចវេរាទាំងឡាយ
៥ នេះមានផលមិនជាទីប្រាថ្នា មានផលជាទុក្ខមែនពិត
ដោយបំណែកមួយ ។

ផលសីល ៥ ដូចម្តេច, អានិសង្សសីល ៥ ដូចម្តេច ។
ម្នាលយក្ខដ៏បំរើនបុរសបុគ្គលចំពួកខ្លះក្នុងលោកនេះ មានសទ្ធា
មានចិត្តអាណិត មានចិត្តជាប្រយោជន៍អនុគ្រោះដល់សត្វ
លះបង់នូវបាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញា
ដាក់បង់ហើយ មានគ្រឿងសាស្ត្រាដាក់បង់ហើយមិនបៀតបៀន
សត្វទាំងពួង ។ បុរសបុគ្គលនោះជាអ្នកមានសីលបរិបូណ៌
មានសីលបានបំពេញហើយ លុះទំលាយកាយស្លាប់ទៅខាង
មុខ ក៏ទៅបង្កើតក្នុងសួគ៌ទេវលោកជាសុគតិភព ថាបើមិនទៅ
កើតក្នុងទេវលោកនោះទេ ម្នាលយក្ខ បុគ្គលនោះកាលបើ្យត

ចាកអត្តភាពនោះទៅ ត្រឡប់មកកាន់មនុស្សជាតិនេះវិញ ទោះកើតក្នុងទីឯណា ៗ ជាខាងក្រោយ រមែងមានអាយុវែង មិនមានសត្រូវ មិនមានពៀរ មានមិត្តច្រើន មានសំឡាញ់ច្រើន ជាទីស្រឡាញ់នៃទេវតានឹងមនុស្សទាំងឡាយ ម្នាលយក្ខចេតនាដែលវៀចាកបាណាតិបាតឯណានេះ ចេតនាដែរវៀចាកបាណាតិបាតនោះ មានផលប្រព្រឹត្តទៅដើម្បីសួគ៌ផង ប្រព្រឹត្តទៅដើម្បីគុណមានអាយុវែងជាដើមផង ដោយប្រការដូច្នេះ ។

## ផលកម្មទោសរោយកុសលទ្វារបុរិសបុគ្គលោ

ម្នាលយក្ខ បុរសបុគ្គលបំពួកខ្លះក្នុងលោកនេះមានសទ្ធាមិនបានកាន់យកនូវទ្រព្យដែលបុគ្គលមិនបានឲ្យដោយចំណែកបិត្តលួច ។ បុគ្គលនោះបំពេញសីលសមាទាននូវសីលប្រកបដោយសម្បត្តិគឺសីលយ៉ាងនេះ បុគ្គលនោះលុះទំលាយកាយស្លាប់ទៅខាងមុខ គប្បីទៅកើតក្នុងស្ថានសួគ៌ទេវលោកជាសុគតិភព ថាបើមិនទៅកើតក្នុងទេវលោកសោត ច្យុតចាកអត្តភាពនោះមកកាន់មនុស្សជាតិនេះវិញ ទៅកើតក្នុងទីឯណា ៗ ជាខាងក្រោយរមែងកើតក្នុងត្រកូលស្តុកស្តម្ភ ជាអ្នក

ស្តុកស្តំមានទ្រព្យច្រើន មានសម្បត្តិច្រើន ការខ្ចាត់ខ្ចាយវិនាស ទ្រព្យទាំងឡាយនៃបុគ្គលនោះរមែងមិនមានមកអំពីហេតុគឺស្តេច ឬចោរ ភ្លើង ទឹក បុគ្គលមិនជាទីស្រឡាញ់ ញាតិ ឯណានីមួយ ម្នាលយក្ខ ចេតនាដែលវៀរចាកអទិន្នាទានឯណានេះ ចេតនានោះប្រព្រឹត្តទៅដើម្បីសួគ៌ផង ប្រព្រឹត្តទៅដើម្បីប្រ យោជន៍មានសម្បត្តិច្រើនជាដើមផង ដោយប្រការដូច្នេះ ។

ម្នាលយក្ខដ៏ចំរើន បុរសបុគ្គលពួកខ្លះក្នុងលោកនេះ មានសទ្ធាដល់ព្រមហើយដោយសេចក្តីខ្មាសបាបក្តៅក្រហាយនឹងបាប ឃើញនូវទោសក្នុងកាមទាំងឡាយ លះបង់នូវកិរិយាប្រព្រឹត្តខុសក្នុងកាមគុណ វៀរចាកកាមេសុមិច្ឆាចារ បុគ្គលនោះបំពេញសីលសមាទានសីល ដោយប្រការដូច្នេះ បុគ្គលនោះលុះទំលាយកាយស្លាប់ទៅខាងមុខ គប្បីទៅកើតក្នុងឋានសួគ៌ សុគតិភព ថាបើមិនទៅកើតក្នុងឋានសួគ៌នោះទេ ច្យុតចាកអត្តភាពនោះមកកាន់មនុស្សជាតិនេះវិញ ទោះមកកើតក្នុងទីឯណា ៗ ជាខាងក្រោយ រមែងមានរូបល្អគួរដល់ការឃើញ នាំមកនូវសេចក្តីជ្រះថ្លា ប្រកបព្រមដោយពណ៌កាយដ៏ឧត្តម

ជាទីស្រឡាញ់នៃជនទាំងពួងមានឥន្ទ្រិយ៍ពេញបរិបូណ៌ ម្នាលយក្ខ ចេតនាវៀរចាកកាមេសុមិច្ឆាចារឯណានេះ ចេតនានោះប្រព្រឹត្តទៅដើម្បីសួគ៌ ប្រព្រឹត្តទៅដើម្បីគុណមានរូបល្អជាដើម ដោយប្រការដូច្នេះ ។

ឥធេកច្ចោខោភោយក្ខសទ្ធោបុរិសបុគ្គលោ

ម្នាលយក្ខដ៏ចំរើន បុរសបុគ្គលពួកខ្លះក្នុងលោកនេះ មានសទ្ធា លះបង់នៅមុសាវាទវៀរចាកមុសាវាទពោលតែពាក្យពិត មិនបានពោលពាក្យប្រាសចាកសេចក្ដីពិត មិនឲ្យសេចក្ដីប្រាថ្នារបស់ជនដទៃកំរើក មានវាចាគួរជឿ, បុគ្គលនោះបំពេញសីលសមាទាននូវសីលយ៉ាងនេះ លុះទំលាយកាយស្លាប់ទៅខាងមុខគប្បីកើតក្នុងឋានសួគ៌ជាសុគតិភព ឬបើមិនទៅកើតក្នុងឋានសួគ៌នោះទេ ច្យុតចាកអត្តភាពនោះមកកាន់មនុស្សជាតិនេះវិញ នោះកើតក្នុងទីឯណា ៗ ជាខាងក្រោយ ក្លិនផ្កាឧប្បលរមែងផ្សាយចេញអំពីមាត់នៃបុគ្គលនោះ ៗ មានសេចក្ដីប្រាថ្នាសំរេចក្នុងគន្ធជាតិ មានអណ្ដាតបរិបូណ៌ មានអញ្ចាញធ្មេញស្និទ មានសំដីផ្អែមល្ហែម ពោល

តែពាក្យដែលគួរនឹងពាក្យដែលប្រាសចាកទោស មានពាក្យគួរជនដទៃជឿបាន , កាលបើជនដទៃសួរថា ពាក្យនេះជាពាក្យអ្នកឯណា ជនដែលបានស្តាប់តមកនឹងតបទៅថា ពាក្យនេះជាពាក្យនៃបុគ្គលឈ្មោះនេះ ពាក្យនេះបុគ្គលនោះពោល អ្នកសួរនោះនឹងសរសើរថា ពាក្យឯណាជាពាក្យអ្នកនោះ ពាក្យនោះជាពាក្យពិតមែន, ម្នាលយក្ខ ចេតនាដែលវៀរចាកមុសាវាទឯណានេះ ចេតនានោះប្រព្រឹត្តទៅដើម្បីសួគ៌ផង ប្រព្រឹត្តទៅដើម្បីគុណមានមាត់ក្រអូបជាដើមផង ដោយប្រការដូច្នេះ ។

ឥធេកច្ចោខោបនភោយក្ខសទ្ធោបុរិសបុគ្គលោ

ម្នាលយក្ខដ៏ចំរើន មួយទៀត បុគ្គលបំពួកខ្លះក្នុងលោកនេះ មានសទ្ធា លះបង់នូវហេតុនៃសេចក្តីប្រមាទគឺផឹកនូវទឹកស្រវឹងគឺសុរានឹងមេរយ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន មានសតិដឹងព្រមក្នុងកាលទាំងពួង មិនបានប្រមាទ ប្រព្រឹត្តក្នុងធម៌ទាំងពួង បុគ្គលនោះរមែងទៅកាន់សំណាក់សមណនឹងព្រាហ្មណ៍ដ៏ជាបណ្ឌិតប្រកបដោយធម៌អស់កាលដ៏គួរ កាលចូលទៅអង្គុយជិតហើយសួរថា បពិតលោកដ៏ចំរើន ធម៌ដូច

ម្ដេចមានទោស ធម៌ដូចម្ដេចមិនមានទោស ធម៌ដូចម្ដេចបុគ្គល
គួរសេព ធម៌ដូចម្ដេចបុគ្គលមិនគួរសេព ដោយប្រការដូច្នេះ ៗ
បុគ្គលនោះបំពេញនូវសីលសមាទាននូវសីលយ៉ាងនេះ, កាល
ទំលាយកាយស្លាប់ទៅខាងមុខ គប្បីកើតក្នុងឋានសួគ៌ជា
សុគតិភព ថាបើមិនទៅកើតក្នុងឋានសួគ៌នោះទេ ច្យុត
ចាកអត្តភាពនោះមកកាន់មនុស្សជាតិនេះវិញ ទោះកើតក្នុងទី
ឯណា ៗ ជាខាងក្រោយបុគ្គលនោះរមែងមានបុណ្យ បរិបូណ៌
ដោយបញ្ញា ដល់ព្រមដោយបញ្ញាដ៏ប្រកបដោយអង្គ ៨ ប្រការ
មានវាចាស្រួលបួលផង ពោលនៅពាក្យគួរនឹងពាក្យដែល
ប្រាសចាកទោសផង ៗ ម្នាលយក្ខ បេតនាដែលវៀរចាក
សុរាមេរយមជ្ជបមាទដ្ឋានឯណានេះ បេតនានោះប្រព្រឹត្តទៅ
ដើម្បីសួគ៌ផង ប្រព្រឹត្តទៅដើម្បីគុណមានបញ្ញាជាដើមផង
ដោយប្រការដូច្នេះ, ម្នាលមហាយក្ខ គុណដូចសម្ដែងមកខាង
ដើមនេះ ជាអានិសង្សនៃសីលទាំង ៥ ប្រការ ។

ឯវំមហាសត្តោតស្សសីលានិសំសំកថេត្វា

ព្រះមហាសត្វសម្ដែងនូវអានិសង្សសីលដល់យត្តារយក្ខ

នោះដោយប្រការដូច្នេះ ហើយទ្រង់សរសើរនូវគុណនៃសីលនោះទៀតពោលជាបទគាថាថា សីលំអាភរណំសេដ្ឋំ សីលជាគ្រឿងប្រដាប់ប្រសើរវិសេស សីលជាស្បៀងដ៏ឧត្តម សីលជាទឹកស្រោបឲ្យត្រជាក់សប្បាយ សីលជាគោចរគឺជាអារម្មណ៍នៃព្រះពុទ្ធទាំងឡាយ ។ បំណែកយក្ខារយក្ខបានស្តាប់ធម្មកថាខមហាសត្តហើយមានចិត្តជ្រះថ្លាក្រៃលែងប្រមាណ ក៏សរសើរមហាសត្តថា ដូចយើងសរសើរ សុតធនុភាពកុមារឯណាបេះសម្តែងធម៌ទេសនាដល់យើងជាសត្វវង្វេង កិរិយាបានស្តាប់ធម៌ទេសនានោះជាលាភដ៏ប្រពៃរបស់យើងពិត យើងបានដោយល្អពិត បុគ្គលដែលឆ្លាសស្គាល់ផ្លូវប្រាប់នូវផ្លូវដល់បុគ្គលវង្វេងផ្លូវមានឧបមាដូចម្តេច ធម៌ទេសនាដែលសុតធនុភាពកុមារសម្តែងដល់យើងដោយបរិយាយដ៏ច្រើនមានឧបមែយដូច្នោះ ។ ព្រះមហាសត្តទ្រង់ទូន្មានយក្ខារយក្ខឲ្យស្ថិតនៅក្នុងបញ្ចសីលមិនឲ្យកាចតទៅទៀត បីដូចជាគោឧសភមានស្នែងបាក់ ឬមួយបីដូចជាពស់មានចង្កូមគឺបុគ្គលដកហើយដូច្នោះ ។ ស្រេចហើយព្រះអង្គក៏នាំនាងអញ្ជនវតី នាងករេណុវតី ត្រឡប់

មកនគរពារាណសីវិញ ហើយទ្រង់ដឹកលំទុកនូវនាងទាំងពីរ ក្នុងទីជាធំដោយឥស្សរិយស និងទ្រង់ធ្វើនូវគ្រឿងសក្ការដ៏ធំ ដល់មណិកក្ខអស្សតរ ដោយបំណាយនូវកហាបន ៥ សែន ។ ចាប់ដើមអំពីកាលនោះមកព្រះបាទសុតធនុរាជនោះទ្រង់សោយនូវសម្បត្តិជាសុខ សោយរាជប្រកបដោយធម៌ដ៏ស្មើ ដរាបលុះអស់ព្រះជន្មាយុក៏ទៅបង្កើតក្នុងទេវលោក ។

សត្ថាឥមំធម្មទេសនំអាហរិត្វា ជាតកំសមោធានេសិ

ព្រះសាស្តាទ្រង់នាំមកនូវព្រះធម្មទេសនានេះហើយទើបប្រជុំនូវជាតកថា ៈ ម្នាលភិក្ខុទាំងឡាយស្តេចព្រះនាមព្រហ្មទត្តក្នុងកាលនោះ បេរិលត្រឡប់ជាតិមក បានជាសុទ្ធោធនព្រះពុទ្ធបិតាក្នុងកាលឥឡូវនេះ, នាងទេវីព្រះនាមកេសិនីក្នុងកាលនោះបានជានាងមហាមាយាទេវី ជាព្រះពុទ្ធមាតាក្នុងកាលឥឡូវនេះ, ព្រះបាទសេតរាជក្នុងកាលនោះ បានជាព្រះមោគ្គល្លានថេរក្នុងកាលឥឡូវនេះ, ព្រះឥន្ទ្រាទេវរាជក្នុងកាលនោះ បានជាអនុរុទ្ធថេរក្នុងកាលឥឡូវនេះ, ព្រះបាទមហាបនាទរាជក្នុងកាលនោះ បានជាសារីបុត្តថេរក្នុងកាលឥឡូវនេះ, នាងបទុមគន្ធា

ទេវីក្នុងកាលនោះ បានជានាងគោតមីក្នុងកាលឥឡូវនេះ, នាង
ចិរប្បភាទេវីក្នុងកាលនោះ បានជានាងយសោធរាពិម្ពាក្នុង
កាលឥឡូវនេះ, នាងទាសីគមឈ្មោះបទុមាក្នុងកាលនោះ
បានជានាងឧបល្លវណ្ណាភិក្ខុនីក្នុងកាលឥឡូវនេះ មណិកក្ខអស្ស
តរក្នុងកាលនោះ បានជាកណ្ឋកអាជានេយ្យក្នុងកាលឥឡូវនេះ,
នាងអញ្ចនវតីយក្ខិនីក្នុងកាលនោះ បានជានាងបទុមវតីភិក្ខុនី
ក្នុងកាលឥឡូវនេះ នាងករេណុវតីក្នុងកាលនោះ បានជានាង
សុន្ទរីភិក្ខុនីក្នុងកាលឥឡូវនេះ, យក្ខារយក្ខក្នុងកាលនោះ បាន
ជាកាលារីយគឺមារាធិរាជក្នុងកាលឥឡូវនេះ, ព្រះបាទសុត-
ធនុរាជក្នុងកាលនោះ បេរវិលត្រឡប់ជាតិមក បានជាព្រះ
សម្មាសម្ពុទ្ធជាទីពឹងនៃសត្វលោកក្នុងកាលឥឡូវនេះ ។ អ្នក
ទាំងឡាយចូរចាំទុកនូវជាតកដោយន័យ ដែលតថាគត
ពោលហើយយ៉ាងនេះ ។៙៚—

សុតធនុជាតកំ និដ្ឋិតំ

សំដែងរឿងសុតធនុជាតក ក្នុងបាឡីគម្ពីរបញ្ញាសជាតក

ចប់សេចក្តីតែប៉ុណ្ណោះឯង

# វតនបោតជាតក

ព្រះឧត្តមមុនី អ៊ុំ ស៊ូរ អាចារ្យព្រះរាជបណ្ណាល័យកម្ពុជា

ប្រែនិងរៀបរៀង

---

បញ្ញាសជាតក

## វតនបោតជាតក

អច្ឆរិយំវត ទំ ទុក្ខំ តំ ទំ សត្ថា ជេតវនេ

វិហរន្តោ មាតុបោសកំ ភិក្ខុំ អារព្ភ កថេសិ

ប្រែជាសេចក្ដីថា សត្ថា រីសម្ដេចព្រះបរមសាស្ដាចារ្យ កាលព្រះអង្គគង់នៅក្នុងជេតវនមហាវិហារ ទ្រង់ប្រារព្ធនូវភិក្ខុ ១ រូបជាអ្នកចិញ្ចឹមមាតា ហើយទ្រង់សម្ដែងធម្មទេសនានេះ មានពាក្យថា អច្ឆរិយំវត ទំ ទុក្ខំ ដូច្នេះជាដើម រឿងនេះមានសេចក្ដីពិស្ដារប្រហែលគ្នានឹងសាមជាតក ដែលមានមកក្នុងគម្ពីរទសជាតកឯណោះ ក្នុងទីនេះមានសេចក្ដីសង្ខេបដូចនឹងពោលតទៅនេះ ។

សេចក្ដីខាងដើមរឿងនេះថា តាំងអំពីភិក្ខុនោះបានឧប្បទា

ហើយវេលាណា ក៏តែងតែស្វែងរកនូវបិណ្ឌបាតមកចិញ្ចឹមមាតារបស់ខ្លួន ទាល់តែភិក្ខុទាំងឡាយនាំគ្នាតេះដៀលលើកទោសថា ធម្មតាអ្នកបួសហើយទៅខំស្វែងរកអាហារបិណ្ឌបាតមកចិញ្ចឹមគ្រហស្ថនោះមិនសមគួរឡើយ ពាក្យទាំងនេះមិនបាត់ស្ងាត់ក៏ផ្សិតផ្សាយដល់ព្រះសោតទិព្វនៃព្រះបរមសាស្ដាចារ្យ ទើបទ្រង់មានពុទ្ធភាសិតត្រាស់ថា នែភិក្ខុទាំងឡាយកុំបៀតបៀនមើលងាយនូវភិក្ខុដែលជាអ្នកចិញ្ចឹមមាតានេះឡើយ អ្នកប្រាជ្ញទាំងឡាយអំពីបុរាណមុនឆាយ ក៏តែងទំនុកបំរុងមាតារបស់ខ្លួនដោយភេតជាអ្នកបួសដូចយ៉ាងនឹងដែរ ត្រាស់ដូច្នេះហើយព្រះអង្គក៏ទ្រង់ស្ងៀមនៅដោយតុណ្ហីភាព ទើបភិក្ខុទាំងឡាយនោះមានចេតនាប្រាថ្នាចង់ដឹងរឿងរ៉ាវនោះដោយពិស្តារ, ហើយក៏ក្រាបបង្គំទូលអារាធនាសូមឲ្យព្រះអង្គសំដែងថ្លែងធម្មទេសនាតទៅ ឯព្រះបរមគ្រូក៏ទ្រង់យឹតយោងទាញយករឿងរ៉ាវដែលកន្លងទៅហើយនោះមកសំដែងជាទីសណ្ដាប់ឲ្យភិក្ខុទាំងឡាយនោះស្ដាប់ក្នុងកាលគ្រានោះឯង ។

អតីតេភិក្ខវេ មេឃវតិនគរេមហារថោនាមរាជារជ្ជំការេសិ

សេចក្តីថា នែភិក្ខុទាំងឡាយកាលដែលកន្លងទៅហើយ នោះ មានព្រះមហាក្សត្រអង្គ ១ ទ្រង់ព្រះនាមថា មហារថរាជ សោយរាជសម្បត្តិក្នុងនគរឈ្មោះថាមេឃវតី ព្រះអគ្គមហេសី របស់ព្រះអង្គនោះ ទ្រង់ព្រះនាមថា សិរិគន្ធអាភា, គ្រានោះព្រះ បរមពោធិសត្វស្តេចផ្ចើបុត្យាការកិច្ចអំពីទេវលោកក្នុងជាន់តុ-សិត_ចុះមកកាន់យកបដិសន្ធិក្នុងគភ៌នៃព្រះអគ្គមហេសីអង្គនោះ ឯព្រះអគ្គមហេសីនោះលុះទ្រង់គភ៌បរិបូណ៌ហើយ ក៏បណ្តាលឲ្យ មានព្រះហ្ឫទ័យប្រាថ្នាចង់ចេញទៅក្រសាលលេងក្នុងព្រះរាជ ឧទ្យានពន់ពេកណាស់ ទើបទូលព្រះរាជស្វាមីឲ្យស្តេចជ្រាប ឯសម្តេចព្រះមហារថរាជជាព្រះស្វាមីស្តេចបានជ្រាបហើយ ទើបស្តេចទ្រង់ត្រាស់បង្គាប់ឲ្យហៅនូវឧយ្យានបាល គឺអ្នករក្សា ឧទ្យានឲ្យចូលមកគាល់ ហើយទ្រង់ត្រាស់បង្គាប់ថា នែនាយ ឧទ្យានចូរអ្នកទាំងឡាយចាត់ការតាក់តែងសំអាតនូវរាជឧទ្យាន នោះឲ្យល្អប្រពៃ ឯនាយឧទ្យាននោះក៏ទទួលព្រះរាជដំរះហើយ តាំងរៀបតាក់តែងតាមព្រះរាជអាជ្ញាបង្គាប់ ស្រេចហើយទើប

យកសេចក្ដីក្រាបបង្គំទូល លុះដល់ថ្ងៃដែលស្ដេចនឹងទ្រង់ព្រះរាជដំណើរទៅនោះ ព្រះមហាក្សត្រនឹងព្រះរាជទេវីព្រមទាំងសេវកាមាត្យមុខមន្ត្រីនឹងរាជបរិវារដ៏ច្រើន ស្ដេចក៏ទៅស្ថិតនៅក្នុងព្រះរាជឧទ្យានហើយទ្រង់ទតព្រះនេត្រនឹងទ្រង់ក្រសាលសំរាន្តតាមព្រះរាជហឫទ័យប្រាថ្នា តាំងអំពីវេលាព្រឹករហូតដល់ព្រះអាទិត្យអស្ដង្គតទៅ ព្រះមហាក្សត្រព្រមទាំងព្រះរាជទេវីមិនអាចនឹងស្ដេចចូលទៅក្នុងព្រះនគរបានឡើយ ព្រោះហួសវេលា ស្ដេចក៏ទ្រង់ផ្ទំនៅក្នុងឧទ្យាននោះអស់រាត្រី ១ ។

ក្នុងថ្ងៃនោះព្រះបរមរាជានឹងអគ្គមហេសី ស្ដេចក៏ផ្ទំរួមសេយ្យាសនជាមួយគ្នាទាំងពីរព្រះអង្គ លុះដល់ពេលបច្ចូសសម័យវេលាជិតព្រឹកឡើង ព្រះរាជទេពីនាងទ្រង់សុបិននិមិត្តយល់សប្ដិថាដូច្នេះ មានបុរសម្នាក់មានកាយដ៏ខ្មៅភ្នែកក្រហមសក់ក្រហម ស្លៀកសម្ពត់មានពណ៌ក្រហម ដៃកាន់នូវអាវុធមានអុខដ៏មុតថ្លា ដើរមកពីទិសបស្ចិមា ដំរង់ចូលមកកាន់ទីស្លេងដែលព្រះរាជទេវីនាងផ្ទំ ហើយក៏ចាប់នូវផ្នួងព្រះកេសានៃព្រះរាជទេវីទាញផ្ដួលផ្ដេកព្រះអង្គនាងទៅលើផែនដីភ្លៀលខ្នេះ

យកព្រះនេត្រទាំងពីរហើយកាត់ផ្ដេបនូវព្រះហស្តខាងស្ដាំ រួចពុះទំលាយនូវដើមទ្រូង ត្រូវយកនូវដំណក់លោហិតដែលហូរចេញមកទុកទើបរូងយកសាច់បេះដូងបានហើយ ក៏បែរមុខបំពោះទៅកាន់បច្ចិមទិសហើយចៀសចេញទៅ ។

ឯព្រះរាជទេវីនាងក៏មានព្រះហឫទ័យញាប់ញ័រតក់ស្លុតអំពីមរណភ័យនោះក្រៃពេកណាស់ ក៏ស្ទុះក្រោកឡើងដោយរហាស់ទើបដឹងព្រះស្មារតីច្បាស់ប្រាកដ ថាឱខ្ញុំនអញយលសបទេហះ ហើយនាងក៏ក្រោកឡើងរំពឹងគិតថា សុបិនដែលអាត្មាអញឃើញនេះជាសុបិនលាមកអាក្រក់សល់ខ្មាត សេចក្ដីអន្ដរាយនឹងមានដល់ខ្ញុំនអញ ដោយហេតុផលនៃសុបិននេះមិនខានឡើយ លុះគិតដូច្នេះហើយទើបក្រាបបង្គំទូលនូវរឿងនេះឲ្យព្រះរាជស្វាមីស្ដេចទ្រង់ជ្រាប - លុះព្រះមហាក្សត្រស្ដេចជ្រាបហើយទ្រង់ត្រាស់ប្រាប់នូវដំណើរសុបិននោះ ដល់ហោរាដែលជាអ្នកទំនាយនូវសុបិននិមិត្តថ្វាយ ឯហោរាទាំងឡាយនោះបានយលច្បាស់ក្នុងសុបិននោះហើយ ទើបយកសេចក្ដីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេពឯសុបិនដែលព្រះរាជទេវីទ្រង់

យសនេះ ទំនាយថាព្រះករុណាជាម្ចាស់ជីវិតនឹងព្រះរាជទេពី មុខជានឹងព្រាត់ព្រាកចាកគ្នាដោយផលនៃសុបិននោះ មិនខានឡើយ សូមទ្រង់ជ្រាប ។

ព្រះមហាក្សត្រនឹងព្រះអគ្គមហេសីស្តេចទ្រង់ព្រះសណ្តាប់ទំនាយនោះហើយព្រះអង្គក៏មានព្រះរាជហឫទ័យរន្ធត់ញាប់ញ័រព្រោះភ័យខ្លាចសេចក្តីព្រាត់ប្រាសចែកគ្នានោះលើសប្រមាណទើបទ្រង់សួរទៅហោរនោះថា នៃហោរាទាំងឡាយ ហេតុដែលធ្វើឲ្យយើងវិនាសបែកគ្នានោះតើដូចម្តេចខ្លះ ហោរទាំងនោះក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេវរាជក្នុងវេលារសៀលថ្ងៃនេះមហាមេឃនឹងតាំងឡើងដោរដាលជាភ្លៀងធ្លាក់ចុះមកពេញផែនដីនេះ កាលដំបូងឡើយមានទឹកប្រមាណត្រឹមករជើងបន្តិចទៅត្រឹមជង្គង់ ត្រឹមបង្កេះ ត្រឹមដោះ ត្រឹមកណ្ឋ ត្រឹមក្បាល រហូតដល់ជំរៅដើមត្នោត ១ នឹង ៣ ដើមត្នោតឡើងទៅទើបស្តេចទ្រង់សួរតទៅទៀតថា នៃអ្នកទាំងឡាយ បើមានហេតុយ៉ាងនឹងហើយ តើយើងនឹងត្រូវធ្វើដូចម្តេចទើបបានស្រួល. នេមិត្តិកាទាំងឡាយក៏ក្រាបទូលថា បពិត្រសម្តេច

ព្រះបរមមហារាជ រឿងនេះនឹងរករិត្តដទៃក្រៅពាក្យមកជាទី
ពឹងពំនាក់នោះគ្មានឡើយ គ្រានោះព្រះមហាក្សត្រស្ដេចឲ្យហៅ
នូវជាងឈើទាំងឡាយមក ហើយទ្រង់ត្រាស់បង្គាប់ថា នែ
អ្នកទាំងឡាយចូរអ្នកទាំងឡាយធ្វើនូវទូកឲ្យបានឆាប់ ហើយ
បងផ្ដាប់គ្នាស្រេចវេលាណា ចូរអ្នកទាំងឡាយប្រាប់ដល់យើង
កុំខាន នាយជាងទាំងឡាយក៏ទទួលព្រះរាជដំរះហើយក៏តាំង
ចាត់ចែងការតទូករួចស្រេចហើយទើបក្រាបទូលថ្វាយតាមព្រះ
រាជបង្គាប់ ។

លុះដល់សាយណ្ហសម័យថ្ងៃរសៀលក៏មហាមេឃតាំង
ដោរបណ្ដាលជាភ្លៀងធំធ្លាក់ចុះមកឥតមានដេបគ្រាប់ឡើយ ឯ
ទឹកភ្លៀងនោះសោតកាន់តែច្រើនកើនឡើងឥតមានអាក់ ទីដំ-
បូងឡើយមានទឹកប្រមាណត្រឹមករជើង យូរបន្តិចទៅមានជំ
រៅត្រឹមជង្គង់ ត្រឹមចង្កេះ ជំរៅដើមត្នោត ១ រហូតដល់ជំរៅ ៧
ដើមត្នោតឡើងទៅដូចទំនាយ មហាជនទាំងឡាយ បាន
ឃើញទឹកមានជំរៅប្រមាណ ៧ ដើមត្នោតដូច្នោះហើយ ក៏
មានចិត្តរន្ធត់ញាប់ញ័រខ្លាចសេចក្ដីស្លាប់តែរាល់គ្នាជាទីបំផុត

ហើយក៏ខំស្វែងរកទីពឹងអាស្រ័យ បំណែកខាងលលកធំ ៗ ក៏បោកបោះផ្ទប់នូវមហាជនទាំងនោះឡើងល់នូវសេចក្ដីវិនាស យ៉ាងធំក្នុងជាន់នោះ ឯព្រះបាទមហាបវរាជនឹងព្រះអគ្គមហេសី ក៏ស្ដេចខះខំឡើងលើទូកនោះបានហើយ លលកធំក៏បក់ផាត់ បង្ហូតនូវរាជនាវានោះឡើរអណ្ដែតត្រឡប់ត្រឡិនទៅតាមខ្សែទឹក ព្រះរាជទេវីនាងទ្រង់គភ៌បរិបូណ៌គ្រប់ខែ ហើយជាស្រីប្រកប ដោយសេចក្ដីភ័យខ្លាចប្រើន មិនអាចនឹងទប់ទល់ដំកល់ខ្លួន បាន នាងក៏ទ្រង់ព្រះកន្សែងខ្លាំង ទាំងទឹកព្រះនេត្រសោតក៏ ហូរបេញស្រោចផ្ទប់គេស្រប់ព្រះភក្ត្រា ទើបត្រាស់នូវព្រះ គាថានេះថា ៗ

អច្ចរិយំវតិទំទុក្ខំ សុខមត្តំនជាយតិ
កបំជីវាមហសេទេវ អប្បត្តំផ្គេមហណ្ណវេ
អហោអនាថាកប្បណា លភាមហសេមហោទធឹ
សលិលេអប្បត្តិដ្ឋស្មិំ កថំទីបំលភាមហសេ
នាហន្តំទេវបស្សាមិ អនាថាមរណាញ្ជមេតិ

សេចក្ដីថា បពិត្រព្រះសម្មតិទេពព្រះស្វាមី សេចក្ដីសុខ

មាត្រាថាបន្តិចបន្តួចរបស់យើងមិនមានសោះឡើយ សេចក្ដីទុក្ខក្នុងគ្រានេះហើយជាទុក្ខធំធ្ងន់សល់ខ្លាតលើសធម្មតា ជាហេតុគួរស្មើមជាទីអស្ចារ្យបំផ្លែកពេកណាស់ យើងទាំងពីរកាលបើបេះតែសាត់ទៅ ៗ ក្នុងទីជ្រៅកណ្ដាលបំណោមទឹកធំដែលរកទីជ្រកទីអាស្រ័យមិនមានហើយ ម្ដេចឡើយនឹងមានជីវិតរស់នៅតទៅទៀតបាន ឱយើងទាំងពីរអ្នកជាមនុស្សកំព្រាផុតទីពឹងត្រិមនឹងហើយ មកបានឯបំណោមទឹកធំនេះជាផ្ទះនៅកាលបើមកនៅក្នុងកណ្ដាលទឹកជ្រៅ ដែលប្រាសចាកទីពឹងហើយ ធ្វើម្ដេចទើបនឹងជួបប្រទះនូវកោះត្រើយឯណាបាន ខ្ញុំនឹងមិនបានឃើញព្រះអង្គតទៅទៀត សេចក្ដីស្លាប់របស់ខ្ញុំមុខជារកទីពឹងមិនបាន ៗ

កាលព្រះរាជទេវីពោលគាថាយ៉ាងនេះហើយ ទើបព្រះបរមក្សត្រាធិរាជលួងលោមប្រលោមព្រះរាជទេវីថា នែព្រះនាងដ៏ចំរើន ប្អូនកុំភ័យកុំខ្សឹកខ្សួលឡប្រើលពេកឡើយ ហេតុអ្វីបានជាបងពោលយ៉ាងនឹងព្រោះថាសម្បត្តិទាំងពួងដែលមានហើយ ក៏គង់ដល់នូវសេចក្ដីវិនាសពុំលែងឡើយ មានវ័យដ៏

បំរើនក្នុងកាលខាងដើមហើយ តែងនឹងចាស់ជរាគ្រាំគ្រាក្នុងកាលជាទីបំផុត មិនមានរោគាព្យាធិក្នុងកាលខាងដើមហើយតែងនឹងមានជម្ងឺឈឺចាប់ក្នុងកាលខាងក្រោយពុំខានឡើយ មានសេចក្ដីរស់នៅហើយ គង់នឹងដល់នូវសេចក្ដីស្លាប់ក្នុងទីបំផុតជាទីទៀម ព្រះមហាក្សត្រទ្រង់ប្រោសប្រទានឱវាទដល់ព្រះទេវីដូច្នេះហើយទើបព្រះអង្គត្រាស់គាថាដូច្នេះថា :

មាតាត្វំបរិទេវសិ ឯសាលោកស្សធម្មតា
អនិច្ចាវតសង្ខារា សព្វពុទ្ធេហិទេសិតា
យំកិញ្ចិកុសលំកតំ មយ្ហុរញ្ញេវតយាកតំ
សព្វកេតញ្ញុកុសលំ បិន្ធេតព្វហិសោភណោ

សេចក្ដីថា ព្រះនាងកុំខ្សឹកខ្សួលអន់ពេកឡើយធ្វើម្ដេចសេចក្ដីប្រព្រឹត្តទៅរបស់លោកតែងមានជាធម្មតាយ៉ាងនឹងហើយ សង្ខារធម៌ទាំងឡាយមិនទៀងទាត់ប្រាកដទេ ព្រះពុទ្ធគ្រប់ព្រះអង្គតែងត្រាស់សំដែងហើយយ៉ាងនឹង កុសលឯណា ១ ដែលព្រះនាងបានសាងសន្សំទុកហើយក្ដី ប្រយោជន៍ទាំង

ពួងដែលព្រះប្អូនបានធ្វើទុកដើម្បីឲ្យបងក្តី ប្អូនប្អូននឹករឭកត្រង់កុសលទាំងនោះជាចំណែកដ៏ល្អ ៗ

កាលព្រះបាទមហារបិរាជ ស្តេចបានប្រទានឱ្យភាទល្បួងលោមព្រះរាជទេវីដូច្នោះហើយ បំណែកខាងលលកទឹកធំ ៗ នោះក៏បក់បោកខ្លាំងខ្ទប់ប្ញូលមក ឯនាវានោះសោតក៏បែកបាក់ទៅជាបំណែកពីរ ព្រះទេវីក៏មានសេចក្តីភិតភ័យនឹងមរណសង្គ្រាមនោះឥតឧបមា នឹងនឹករកឧបាយណា ១ មកជួយដោះខ្លួនឲ្យរួចពីសេចក្តីគ្រោះថ្នាក់នេះមិនឃើញឡើយ នាងក៏ទ្រង់ព្រះពិលាបសោយសោក ស្រែកហៅរកព្រះរាជស្វាមីឲ្យជួយដោះនាងអំពីទុក្ខធំ ហើយត្រាស់ព្រះគាថាដូច្នេះថាៈ

ឯហិគណ្ហាហិមំទេវ ឱប្បិមោបេហិទុក្ខតោ
តយាវិនានជីវាមិ មាមំសជ្ជេបិរបេសភ

សេចក្តីថា បពិត្រព្រះសម្មតិរាជ សូមព្រះអង្គស្តេចមកជួយខ្ញុំ ចូរដោះខ្ញុំម្ចាស់ឲ្យរួចចាកគ្រោះថ្នាក់ធំក្នុងជាន់នេះឲ្យឆាប់ឡើនផង ឯខ្លួនខ្ញុំម្ចាស់សោតបើវៀរលែងព្រះអង្គហើយ នឹង

មិនមានជីវិតតទៅទៀតឡើយ ព្រះអង្គស្ដេចកុំលះបង់បោលទុំឡើយណាព្រះករុណា ។

ព្រះបាទសម្ដេចព្រះមហារបិរាជ ស្ដេចបានទ្រង់ព្រះសណ្ដាប់សព្ទសំឡេងពិលាបសោយសោកនៃព្រះរាជទេវី ព្រោះសេចក្ដីពិរាសប្រាសព្រាត់ដូច្នោះហើយ ស្ដេចក៏មានព្រះហឫទ័យស្លុតស្លុងភាន់ភាំងព្រះស្មារតីទើបយកព្រះភូសារបស់ព្រះអង្គចងពាត់ព្រះអង្គនឹងព្រះរាជទេវីផ្ដាប់គ្នាយ៉ាងមាំទុកហើយ គ្រានោះព្រះភូសាសាជិក ក៏ដាចជើចដុតចេញពីគ្នា ហាក់ដូចជាសំដែងឲ្យឃើញនូវផលនៃអកុសលកម្មរបស់ព្រះអង្គដែលបានធ្វើរួបហើយអំពីមុន ។

ព្រះមហាក្សត្រនឹងព្រះរាជទេពីទាំងពីរព្រះអង្គ ត្រូវលលកទឹកបោកបែកគ្នាទៅតែ ១ ព្រះអង្គ ៗ ។

ពាក្យសួរថា ព្រះមហាក្សត្រ នឹងព្រះរាជទេវី បានធ្វើនូវអំពើអកុសលអ្វី ទើបបានមកដល់ប្រទះលើសេចក្ដីអន្តរាយដូច្នេះនេះ ។

ពាក្យឆ្លើយថា កាលអំពីជាតិមុននោះព្រះមហាក្សត្រ នឹង

ព្រះអគ្គមហេសីទាំងពីរព្រះអង្គនេះ ជាស្ដេចសោយរាជសម្បត្តិនៅក្នុងក្រុងពារាណសី គ្រា ១ នោះព្រះអង្គទាំងពីរស្ដេចព្រះទៅស្រង់ទឹកទៀបឆ្នេរនៃគង្គា ពេលនោះមានសាមណេរ ១ អង្គអាយុបាន ៧ ឆ្នាំ អុមទូកបំរុងបតនៅត្រង់ទីនោះ ក៏ព្រះមហាក្សត្រនឹងព្រះទេពី ស្ដេចបង់ក្រសាលសប្បាយហើយទៅធ្វើទូកដែលសាមណេរជិះនោះឲ្យឃ្លេងឃ្លោងលេង_ឯសាមណេរនោះសោតក៏ហេតុតែជាមនុស្សក្មេង មានសេចក្ដីភិតភ័យនឹងទូកឃ្លេងឃ្លោងនោះក្រៃពេកណាស់ ក៏ស្រែកដោយសំឡេងឡើងខ្លាំង ហេតុតែផលនៃកម្មដែលព្រះមហាក្សត្រ នឹងព្រះនាងឲ្យសាមណេរនោះភិតភ័យនោះឯងហើយ បានជាជាប់តាមមកធ្វើឲ្យព្រះអង្គទាំងពីរព្រាត់ព្រាកប៉ាកគ្នាយ៉ាងនេះ ។

ឯអំពើអាក្រក់សូម្បីមាត្រាបាតូច ១ ក៏គួរយើងរាល់គ្នាកុំធ្វើឡើយ ព្រោះហេតុនឹងហើយបានជាសម្ដេចព្រះភគវាទ្រង់ត្រាស់ទេសនាហាមឃាត់ទុកថា:

ខុទ្ទកញ្ចមិទំកម្មំ     នតំបត្តោតិមុញ្ចតិ
ទុក្ករំសុករំកម្មំ     នភវេយ្យកុទាចនំ

សេចក្ដីថា កម្មនេះតូចតិចពេកណាស់ ចំណែកបុគ្គលអ្នកធ្វើនោះមុកជាមិនដល់នូវផលនៃកម្មនោះឡើយគង់នឹងរបូតរួចផុតទៅទេ ការងារដែលធ្វើអាក្រក់ក្ដី ល្អក្ដី មុកជាមិនមានមកអំពីទីណា ១ ឡើយ បុរសប្រុសស្រីកុំមានប្រមាទយ៉ាងនឹងឡើយ ឯការដែលធ្វើអាក្រក់ឬធ្វើល្អនោះសូម្បីបន្តិចបន្តួចក៏គង់សងផលដល់អ្នកដែលធ្វើតាមកំឡាំងមិនលែងឡើយ ដូចជាព្រះបាទមហារបិរាជ នឹងនាងសិរិរតនអារកា ដែលធ្វើលេងឲ្យសាមណេរភិតភ័យប៉ុណ្ណឹង ផលនោះក៏អាចសងវិញធ្វើឲ្យព្រាត់ព្រាកចាកគ្នាជាក់ស្ដែងយ៉ាងនេះមិនខាន ។

ឯព្រះរាជទេវីឃ្លាតចាកព្រះរាជស្វាមីហើយក៏អណ្ដែតសាត់ទៅដោយលំដាប់ ៗ ហើយបានដល់ទៅទៀបជើងភ្នំបន្ទប់ពិតនាងក៏ស្ដេចឡើងពីទឹកនោះហើយទ្រង់ទតព្រះនេត្ររកមើលទៅក្នុងទិសទាំងនេះខាងនោះក៏មិនប្រទះឃើញនូវមនុស្សម្នាឯណា ១ ឡើយ ហើយទើបទ្រង់រំសាយព្រះភូសាសាដក ហាលកំដៅពាក់កណ្ដាល នាងទ្រង់ស្លៀកបិទបាំងព្រះអង្គពាក់កណ្ដាលលុះប្រែត្រឡប់ស្ងួតទាំងអស់ហើយ ក៏ទ្រង់ស្លៀកតាមប្រក្រតី

ធម្មតា ទើបទ្រង់ស្ថិតនៅក្រោមដើមឈើ ១ ពេលនោះព្រះរាជទេវីនាងគង់នៅតែម្នាក់ឯង ជាអ្នកកំព្រាឥតមានគ្នីគ្នាមិត្តសំឡាញ់ឯណា ១ ជាទីពឹងពុំនាក់ឡើយ គួរឲ្យករុណាអាណិតពេកណាស់ នាងក៏ទ្រង់ព្រះពិលាបសោយសោក ទឹកព្រះនេត្រក៏ហូរហៀរស្រក់ស្រោចព្រះភក្ត្រ ហើយនាងមានព្រះរាជសោវនីពោលនូវព្រះគាថាដូច្នេះថា៖

វិយោគោមេកតោបុព្វេ នរស្សមិគបក្ខិនោ
តេនកម្មវិបាកេន វិយោគោបតិនាសហ
កថំបសូស្សិមំឯកំ មហារាជមហិប្បតិ
អនាថំទានិមេអជ្ជ ឯកិការព្រហារនេ

សេចក្ដីថា ការដែលបម្រាត់បម្រែះមនុស្សនឹងសត្វម្រឹគ ឬសត្វស្លាប ទំនងជាអញបានធ្វើហើយក្នុងគ្រាមុនឲ្យគេព្រាត់ព្រាកបាកគូ ឬកូនរបស់គេដឹង លុះដល់មកជាតិនេះ ទើបអញត្រូវព្រាត់ព្រាកបាកព្រះរាជស្វាមីជាទីស្រឡាញ់របស់ខ្លួន ដោយផលនៃកម្មនោះឯងជាប់តាមមកប្រែគល់ឲ្យ បពិត្រសម្ដេចមហារាជដ៏ទ្រង់នូវអំណាចគ្រប់គ្រងនូវផែនដី ធ្វើម្ដេចហើយព្រះអង្គ

នឹងបានមកជួបឃើញខ្ញុំម្ចាស់ ដែលជាស្រីកំព្រាម្នាក់ឯងក្នុងទីនេះទៀតទេ ឥឡូវនេះខ្ញុំម្ចាស់ជាស្រីអនាថាត្រមោចនៅតែម្នាក់ឯងក្នុងដង្គំព្រៃធំរកទីពឹងគ្មានឡើយ មុខជានឹងរងវេទនាដរាបដល់ស្លាប់ក្នុងថ្ងៃនេះហើយព្រះករុណា ។

ក៏ហេតុតែអំណាចតេជះបុញ្ញាធិការៈរបស់ព្រះបរមពោធិសត្វ ដែលទ្រង់អាស្រ័យនៅក្នុងគភ៌នៃព្រះរាជទេវីនោះបណ្ដាលឲ្យពិភពសម្ដេចអមរិន្ទ្រឥន្ទ្រកោសី ក្ដៅក្រហាយឡើង គ្រានោះសម្ដេចព្រះសហស្សនេត្រ ទ្រង់បានជ្រាបនូវហេតុនោះគ្រប់ប្រការទើបមានទេវឱង្ការ ត្រាស់ឲ្យហៅវិស្សុកម្មទេវបុត្រឲ្យបួលមកគាល់ លុះមកដល់ហើយទើបទ្រង់បង្គាប់ថា នែវិស្សុកម្មចូរអ្នកចុះទៅកាន់ជើងភ្នំបន្ទបពត៌ហើយនិមិត្តនូវស្រះ ១ ព្រមទាំងឈូកមានផ្កាមានពណ៌ ៥ យ៉ាង ក្នុងវនប្រទេសឲ្យជាទីសប្បាយរីករាយនឹងនិមិត្តបណ្ណសាលា ១ ព្រមទាំងគ្រឿងបរិក្ខារសម្រាប់អ្នកបួសទុកនៅក្នុងទីនោះផង រួចហើយចូរអ្នកត្រឡប់មកវិញចុះ ឯព្រះវិស្សុកម្មទេវបុត្រនោះក៏ទទួលទេវអាជ្ញា

ហើយ បុះមកនិមិត្តតាមព្រះរាជឱង្ការស្រេចហើយទើបចារិក
អក្សរទុកនៅក្លោងទ្វារនោះថា ។

យោបព្វជ្ជិតុកាមោយជាសុខំគណ្ឋតុ សេចក្តីថាអ្នកឯ
ណាត្រូវការនឹងបួស អ្នកនោះចូរកាន់យកនូវគ្រឿងបរិក្ខារនេះ
តាមសេចក្តីសប្បាយចុះ ហើយវិស្សុកម្មក៏ត្រឡប់ទៅកាន់ទីនៅ
របស់ខ្លួនវិញក្រាបបង្គំទូលសេចក្តីទាំងនោះដល់សម្តេចព្រះឥន្ទ្រា
ធិរាជស្តេចបានជ្រាបគ្រប់ប្រការ ។

ឯព្រះបាទមហារថរាជ កាលដែលអណ្តែតដោយលលក
បន្សាត់ទៅ បានរងនូវសេចក្តីទុក្ខលំបាកក្រៃលែងលើសប្រ
មាណ អណ្តែតទៅហួស ៧ ថ្ងៃ ទើបបានដល់មកនគររបស់
ព្រះអង្គដដែលវិញ ។

បំណែកខាងនាងទេវីនោះសោតនាងក៏ផ្អែតផ្អន់ទៅដោយ
សេចក្តីទោមនស្សតែរាល់ពេលឥតមានស្រាកស្រាន្តឡើយ
ក្នុងថ្ងៃ ១ នោះនាងក៏លីលាទៅតាមមគ្គមគា បានឃើញនូវ
បណ្ណសាលាព្រមទាំងអក្សរចារិកទុកនៅទីក្លោងទ្វារនោះនាងក៏
ប្រឹងទតសព្វសេចក្តីហើយ ក៏ទ្រង់ជ្រាបថាជាស្តេចទេពតាព្រះ

អង្គសាងទុកឲ្យ ទើបចូលទៅសំណាក់អាស្រ័យក្នុងបរមសា-
លានោះ ហើយនាងក៏ទ្រង់ព្រះផ្នួសបួសជាតាបសនីនៅក្នុងទី
នោះ ឯនាងទេវីជាស្រីមានគភ៌បរិបូណ៌គ្រប់ខែថ្ងៃហើយ វេលា
នោះខ្យល់កម្មជវាតបក់កំរើកឡើងបង្វិលគភ៌នាងហើយក៏ទ្រង់ប្រ
សូតនូវព្រះរាជឱរសដ៏ល្អមានពណ៌បីដូចជាពណ៌នៃមាសឆ្អិន
ក្នុងវេលាពាក់កណ្ដាលអធ្រាត្រនោះ លុះព្រឹកឡើងនាងក៏ស្រង់
ទឹកជំរះព្រះមហាសត្វហើយ ឲ្យសោយនូវក្សីរធារាប្រសើរទើប
ផ្ដេកព្រះពោធិសត្វទុកក្នុងទីនោះ ។

ឯព្រះរាជទេវីកាលដែលនឹងកំណត់ព្រះនាមថ្វាយព្រះពោធិ
សត្វនោះ គឺព្រះនាងកាន់យកនូវនិមិត្តក្នុងថ្ងៃដែលប្រសូតនោះ
ព្រោះថ្ងៃយប់នោះមានពន្លឺកែវគ្រប់យ៉ាងបណ្ដាលឲ្យភ្លឺព្រោង
ព្រាតជាសពេញក្នុងព្រៃហិមពាន្តទាំងអស់ ទើបកាន់យកហេតុ
នោះមកកំណត់ជាព្រះនាមថ្វាយថា រតនបជោត ដូច្នេះ ។ ក្នុង
គ្រា ១ នោះព្រះរាជទេវីនាងក៏ដាក់ពោធិសត្វឲ្យទ្រង់ផ្ទំនៅក្នុង
បណ្ណសាលា ហើយព្រះអង្គនាងក៏ចូលទៅក្នុងព្រៃដើម្បីស្វែង
រកមើមឈើនឹងផ្លែឈើតូចធំ លុះបានហើយក៏ត្រឡប់មកអង្គុយ

នៅក្នុងបណ្ណសាលាវិញបរិភោគនូវផលាផលទាំងនោះតាមធម្ម-តា ដែលនាងប្រព្រឹត្តធ្វើយ៉ាងនេះដរាបដល់ព្រះពោធិសត្វមានព្រះជន្មាយុបាន ៥ ឆ្នាំ ។

ក្នុងថ្ងៃ ១ នោះព្រះពោធិសត្វទ្រង់ត្រាស់សួរព្រះវររាជជននីថា បពិត្រអ្នក ម បិតារបស់ខ្ញុំនោះជាអ្វី នៅក្នុងទីណា.

ព្រះមាតាបានស្តាប់ហើយ ក៏ប្រាប់ទៅវិញថាឱកូនសំ-ឡាញ់ បិតារបស់អ្នកនោះជាស្តេចសោយរាជ មាតានេះជាព្រះរាជទេវី ហើយនាងក៏និយាយរាប់រៀបរឿងពីដើមប្រាប់ព្រះរាជបុត្រដរាបដល់ចប់. ព្រះពោធិសត្វបានទ្រង់ព្រះសណ្តាប់រឿងនោះហើយ អិនអាចនឹងទប់ទល់ខ្លួនបាន ដោយអានុភាពនៃសេចក្តីកតញ្ញូទើបទូលព្រះមាតាថា បពិត្រអ្នកមេតាំងអំពីថ្ងៃនេះទៅ សូមព្រះមាតានៅចាំសាលាចុះ ខ្ញុំនឹងទៅស្វែងរកមើមឈើផ្លែឈើមកបំរើចិញ្ចឹមអ្នក ព្រះមាតាបានស្តាប់ហើយ ទើបប្រាប់ទៅពោធិសត្វវិញដោយសេចក្តីស្នេហានឹងកូននោះថា នែកូនសំឡាញ់អ្នកកុំចូលទៅក្នុងព្រៃឡើយ កាលបើអ្នកមានជីវិតរស់នូវមាតាក៏ឈ្មោះថារស់នៅដែរ ព្រោះហេតុអ្វីក៏បានជាមាតា

ពោលយ៉ាងនឹង ព្រោះថាខ្លួនអ្នកនៅក្មេងតូចពេកណាស់ ហេតុនោះកូនកុំទៅក្នុងព្រៃឡើយ ព្រះបរមពោធិសត្វកាលមិនបានឱកាសយ៉ាងនឹងហើយ ក៏ស្ងិតនៅស្ងៀមនៅទីនោះ ៗ

វេលាថ្ងៃក្រោយព្រះរាជទេវីនាងក៏ស្ដេចចូលទៅក្នុងព្រៃស្វែងរកផលាផលតែរាល់ ៗ ថ្ងៃ ក្នុងថ្ងៃ ១ នោះព្រះពោធិសត្វក៏ចេញចាកបណ្ណសាលា ហើយទៅតាមស្នាមព្រះបាទព្រះមាតា ព្រោះបានចាំផ្លូវនឹងទិសដែលមាតាស្ដេចទៅតាំងពីដំបូងឡើយ ៗ

ថ្ងៃ ១ នោះព្រះរាជទេវីស្ដេចចេញទៅព្រៃតាំងពីព្រលឹមរកបេះផ្លែឈើបានដាក់ពេញកញ្ឆេហើយ ទើបគិតថា អញនឹងត្រឡប់មកបណ្ណសាលាវិញ ហើយនាងចូលទៅឈប់ក្រោមម្លប់ដើមជ្រៃ ១ ដើម្បីបន្ធោបង់នូវសេចក្ដីព្រួយកាយ រួចនាងប្រាថ្នាក្រោកឡើងចេញទៅទៀត ខណៈនោះមានយក្ខ ១ ឈ្មោះពលាហកអាស្រ័យនៅនឹងដើមជ្រៃ យក្ខនោះក៏ស្ទុះចូលមកចាប់ព្រះហស្ដនាងទាញទុក នាងក៏ទតព្រះនេត្រទៅឃើញរូបយក្ខនោះហើយក៏ញាប់ញ័រន្ធត់ស្លុតខ្លាចសេចក្ដីស្លាប់នោះពន់ប្រមាណ ហើយ

ក៏និកដល់ព្រះមហាសត្វថា កូនសំឡាញ់អញអើយអ្នកនៅតូចណាស់ ហើយនាងទ្រង់ពិលាបសោយសោកបោកខ្លួន ទើបពោលនូវគាថាដូច្នេះថាៈ

អនាហោទានិមេបុត្តោ  វិសត្តោឯកោអស្សមេ
ផលាផលំអលទ្ធាន  មមំទិស្វាអនាយតិ
អស្សមានិក្ខមិត្វាន  វិចរតិព្រហាវនេ
មមបុត្តំអទិស្វាន  មញ្ញោហេស្សាមិជីវិតំ
សោនូនកប្បណោបុត្តោ  បិរិវត្តាយរុច្ចតិ
អច្ឆរត្តេបរត្តេវា  ឧទីរអរិសុស្សតិ

សេចក្តីថា ឥឡូវនេះកូនអញនៅក្នុងអាស្រមតែម្នាក់ឯងរកអ្នកណា ១ ជាទីពឹងមិនមានឡើយ មុខជានឹងមិនបានបរិភោគនូវផ្លែឈើឡើយ ហើយក៏នឹងចេញចាកអាស្រមទៅស្វែងរកអញក្នុងព្រៃធំ ព្រោះហេតុតែមិនបានឃើញអញមក អញសោតក៏មិនបានឃើញកូនរបស់អញ ហើយអាត្មាអញប្រហែលជានឹងអស់ជីវិតទៅមិនខានឡើយ ឯកូនសំឡាញ់អញសោតក៏នឹងនៅកំព្រាតែម្នាក់ឯងនឹងស្រែកយំរកម្តាយទាំងយប់

កណ្ដាលអធ្រាត្រដរាបដល់ឋាតហាបបាត់សំឡេងទៅ ដូចជាទឹកក្នុងស្ទឹងដែលហូតហែងទោះឯងមិនលែងឡើយ ។

គ្រានោះព្រះបរមពោធិសត្តអង្គុយនៅចាំព្រះមាតាតាំងពីព្រឹករហូតដល់វេលាល្ងាច អិនឃើញព្រះមាតាត្រឡប់មក ទើបគឺតរំពឹងថា ពេលនេះព្រះអាទិត្យអស្ដង្គតរលត់បាត់រស្មីទៅហើយ ចុះព្រះមាតារបស់អញហេតុអ្វីក៏បាត់យូរដល់ម្ល៉េះប្រហែលជាមានអ្វី ១ បៀតបៀនមិនខានឡើយ លុះគិតដូច្នេះហើយ ក៏ក្រោកឡើងចេញចាកបណ្ណសាលា ស្រែកបង្ហករកហៅព្រះមាតាថា អ្នកមេ ៗ ដូច្នេះ ទៅក្នុងទីទៀបមាត់ស្ទឹងនឹងព្រៃញាតស្បាតរហូតដល់ជើងភ្នំធំនឹងទីដទៃ ៗ ឯព្រះពោធិសត្តប្រាស់មាតាទ្រង់សោយទុក្ខវេទនា ប្រៀបដូចកូនសុវណ្ណហង្សដែ.បប្រាសចាកមេ កាលបើពុំឃើញព្រះមាតាហើយក៏ចូលទៅកាន់ដើមជ្រៃដែលយក្ខចាប់ព្រះមាតាទុកនៅនោះ ។

ឯព្រះរាជទេវីសិរិរតនអាភា ទ្រង់ជ្រាបថា ព្រះមហាសត្តតាមមករក ទើបស្រែកប្រាប់ទៅកូនថា នែកូនសំឡាញ់ម្ដាយ ៗ នៅឯណេះហើយ ៗ ព្រះពោធិសត្តក៏ស្ទុះចូលទៅរក

មាតា ដល់ហើយក៏ឃើញមាតាអង្គុយជិតមហាយក្ខ ព្រះអង្គក៏មានព្រះហឫទ័យសោមនស្សត្រេកអរ ហាក់ដូចជាព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធក្នុងថ្ងៃស្អែក ព្រះមហាសត្វក៏ចិតចូលទៅជិតមហាយក្ខ ហើយនិយាយអង្វរយក្ខនោះថា បពិត្រមហាយក្ខ សូមអញ្ជើញអ្នកទំពារនូវសាច់ឈាមនឹងបេះដូងរបស់ខ្ញុំចុះ សូមតែអ្នកប្រោសប្រណីលែងមាតាខ្ញុំឲ្យរួចជីវិតចេញទៅជាធាប់ រួចទើបពោលនូវព្រះគាថា ដូច្នេះថា

ខាទមេមហាយក្ខអានុភាវ មាតុអត្ថាយជហាមិជីវិតំ
រុធិរមេហទយំមំសំខាទ ខាទាហិមំបតិមុញ្ចមាតរំ

សេចក្តីថា បពិត្រមហាយក្ខ អ្នកជាបុគ្គលមានអានុភាពធំខ្ញុំសូមលះបង់នូវជីវិតរបស់ខ្ញុំជំនួសព្រះមាតា សូមអ្នកបរិភោគនូវឈាមទឹងបេះដូងនឹងសាច់របស់ខ្ញុំចុះ ចូរអ្នកបរិភោគនូវរូបខ្ញុំទាំងមូលឲ្យអស់ចុះ ហើយសូមមេត្តាលែងមាតាខ្ញុំចេញទៅ ។

ព្រះពោធិសត្វនិយាយយ៉ាងនេះហើយ ទើបដើរចូលទៅជិតនៃមហាយក្ខ រួចនិយាយថា បពិត្រស្តេចយក្ខ អ្នកអា

ណិតខ្ញុំ ៗ សូមឲ្យអ្នកទំពារស៊ីនូវខ្លួនខ្ញុំទៅ សូមតែលែងមាតាខ្ញុំក្នុងវេលានេះកុំខានឡើយ ។

ទើបមហាយក្ខនោះឆ្លើយទៅកាន់ ពោធិសត្វវិញថា នែមហាបុរស បើអ្នកនិយាយយ៉ាងនឹងពិតមែន ចូរអ្នកពុះនូវទ្រូងរូងយកបេះដូងនឹងសាច់មកឲ្យយើងស៊ីនឹងឡូវនេះមើល ឯបរមពោធិសត្វ ឮដូច្នោះហើយ ទើបមកគិតក្នុងព្រះអង្គថា បុះអញនឹងបានកំបិតអំពីទីណាអេះ នឹកយ៉ាងនឹងហើយទើបងើបងើយខំសម្រឹងព្រះស្មារតីសំឡឹងមើលទៅឯអាកាស ហើយត្រាស់នូវបាទព្រះគាថាដូច្នេះថា

កតញ្ញូតាយតេជេន ពុទ្ធោហោមិអនាគតេ
ឯតេនសច្ចវជ្ជេន សត្ថិបតតុមេមុខា

សេចក្តីថា ខ្ញុំសូមប្រាថ្នាជាព្រះពុទ្ធ ១ ព្រះអង្គក្នុងកាលជាអនាគតខាងមុខ ដោយតេជានុភាពនៃចិត្តកតញ្ញូរបស់ខ្ញុំនេះ សូមកំបិតធ្លាក់ចុះមកក្នុងទីចំពោះមុខខ្ញុំកុំខានឡើយដោយពាក្យសច្ចនេះ ។

ពោលយ៉ាងនេះមិនទាន់ផុតពាក្យសច្ចវាចានោះវេលាណា

កំបិតសស្ត្រាង៍មុតធ្លាក់ចុះមកអំពីទីកណ្ដាលអាកាសមកចំពោះនៅមុខនៃព្រះពោធិសត្វ ជាលំដាប់ស្មើនៃពាក្យសច្ចវាទីនោះឯង ហើយព្រះមហាសត្វនិយាយនឹងយក្ខនោះទៀតថា បើខ្ញុំមុខជានឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខ ខ្ញុំសូមថ្វាយបង្គំលាព្រះមាតានឹងស្លាប់ សូមអ្នកឲ្យនូវជីវិតរបស់ខ្ញុំដល់ព្រះមាតាខ្ញុំកុំខានឡើយ ។ គ្រានោះព្រះមាតាក៏អង្វរឃាត់ព្រះពោធិសត្វកុំឲ្យធ្វើដូច្នោះ ឯព្រះពោធិសត្វសោតអ្នកក៏ដកលំនូវពាក្យព្រះមាតាលើត្បូងលើកទុកហើយក៏ពុះនូវទ្រូងរបស់ព្រះអង្គដោយសស្ត្រាង៍មុត ហើយចាប់យកនូវបេះដូងទាញចេញមកដកលំទុកលើព្រះហស្តខាងឆ្វេង ហើយលើកព្រះហស្តទាំងពីរដកលំលើត្បូងទើបពោលព្រះគាថាដូច្នេះថា ។

កតញ្ញុតាយតេជេន ពុទ្ធោហោមិអនាគតេ
ហទយំខាទតុមយ្ហំ មាមេយក្ខនិយតុ

សេចក្ដីថា ខ្ញុំសូមឲ្យបានត្រាស់ជាព្រះពុទ្ធ ១ ព្រះអង្គក្នុងកាលខាងមុខ ដោយអំណាចធម៌កតញ្ញូ កតវេទីរបស់ខ្ញុំនេះ បពិត្រមហាយក្ខ អញ្ជើញអ្នកពិសារនូវបេះដូងរបស់ខ្ញុំចុះ

ហើយខ្ញុំសូមជីវិតរបស់ខ្ញុំកុំអាលឲ្យរលត់អស់មុនឡើយ ព្រះបរមពោធិសត្តសំដែងនូវព្រះគាថាដូច្នេះហើយ ទ្រង់ប្រាថ្នានឹងឲ្យនូវហឫទយវត្ថុដល់យក្ខនោះដោយគោរព ទើបលើកបេះដូងនោះដំកល់លើដៃយក្ខហើយទ្រង់ប្រកាសសេចក្តីឲ្យជាក់ច្បាស់ថា នែមហាយក្ខ ខ្ញុំឯងឲ្យសាច់ដែលមានជីវិតឡើស្មើជីវិតនេះជាទានដល់អ្នក ខ្ញុំមិនប្រាថ្នាសម្បត្តិបរមចក្រពត្រាធិរាជ ឬសម្បត្តិព្រះឥន្ទ្រ សម្បត្តិព្រះព្រហ្ម នឹងព្រះបច្ចេកពុទ្ធឡើយ ឯផលដែលខ្ញុំឲ្យជីវិតនេះ ខ្ញុំសូមឲ្យបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ១ អង្គក្នុងកាលខាងមុខ នឹងបានស្រោចស្រង់សត្វនិករដែលលង់លិចទៅក្នុងសមុទ្រសាគរពោលគឺភពទាំង ៣ ប្រការ ឲ្យឡើងកាន់សុវណ្ណនាវាពោលគឺព្រះសទ្ធម្ម នឹងនាំចេញចាកសំសារភព បំឡងទៅកាន់ត្រើយគឺព្រះនិព្វាន ដែលជាស្ថានក្សេមក្សាន្តនិរាសភ័យទាំងពួង ព្រះមហាសត្វប្រកាសយ៉ាងនេះហើយ ក៏ប្រាប់ទៅមហាយក្ខឲ្យបរិភោគនូវសាច់បេះដូងនោះតាមចេតនា ឯមហាយក្ខក៏ទទួលយកសាច់នោះទៅបរិភោគទាំង

អស់មិនមានសល់ ហើយនាំយកមាតារបស់ពោធិសត្វនោះមកប្រគល់ឲ្យពោធិសត្វវិញ ។

ព្រះបរមពោធិសត្វបានជួបនឹងព្រះមាតាហើយក៏នាំទៅឲ្យគង់នៅក្រោមម្លប់ឈើ ១ ទើបក្រាបថ្វាយបង្គំទូលព្រះមាតាថា បពិត្រព្រះរាជជននីម្ចាស់ ចាប់ដើមតាំងអំពីខ្ញុំមកជ្រកនៅក្នុងព្រះឧទរអ្នកមករហូតដល់ថ្ងៃនេះ សេចក្ដីភាំងភាត់របស់ខ្ញុំដោយកាយវាចាចិត្តឯណា ១ សូមព្រះមាតាមេត្តាប្រោសប្រណីប្រទានទោសនោះដល់ខ្ញុំ ដោយសេចក្ដីការុញ្ញភាពរបស់អ្នកប៉ុះលុះពោលពាក្យប៉ុណ្ណឹងហើយក៏បាត់មាត់បាត់សំឡេងឈឹងទន់ទោព្រះអង្គក្រាបចុះទៅត្រង់ទីចំពោះព្រះភក្ត្រព្រះមាតា ។

បំណែកសម្ដេចព្រះវររាជជននីទ្រង់បានទតព្រះនេត្រឃើញព្រះមហាសត្វភាំងបាត់ព្រះស្មារតីដូច្នោះហើយ នាងក៏ក្រោកឡើងត្រកងចាប់ព្រះហស្តថ្នមព្រះអង្គពោធិសត្វមកផ្ទប់នឹងព្រះឱរាតន៍, មានព្រះហឫទ័យក្ដៅផ្សាវហាក់ដូចជានឹងបែកថ្លើមបេះជាពីរភាគ ហើយមិនអាចនឹងទប់ទល់នូវសេចក្ដីសោកនោះបានឡើយ ហើយនាងក៏យកព្រះហស្តទាំងពីរមកឱបក្រ

ស្រោបថ្នមព្រះឱរសមកដាក់ផ្ដេកផ្ដិតជិតនឹងព្រះឱរា ហើយទ្រង់ព្រះពិលាបសោយសោកជាគាថាដូច្នេះថា៖

មតិតោនូនមេបុត្តោ សុរិយោវិយមហីតលេ
បតិតោទានិមេបុត្តោ ចន្ទោវបតិតោឆមា
ឧដ្ឋេហិបុត្តមាសយេ ទយ្ហន្តេហទយំមម
តយិមតេមរិស្សាមិ កថំជីវាមិឯកិកា
អនាថាទានិហំបុត្ត បុត្តនដ្ឋាយថាមិគី
អរញ្ញេវិចរិស្សាមិ វនេហិចរិស្សាមិ
បព្វតានិវនានិច រុក្ខវិមានភុម្មដ្ឋា
អាកាសដ្ឋទេវតាច ផលបំណាបយេទេវា
ឥន្ទទេវាសព្រហ្មកា អញ្ជលីតេនមស្សាមិ
ខិប្បំបុត្តំបមុញ្ចថ ខិប្បំបុត្តំបមុញ្ចថ

សេចក្ដីថា ឱកូនអញមកដួលក្រាបនៅលើផែនដីហើយ ដូចព្រះអាទិត្យឬព្រះចន្ទដែលអស់អំណាចរស្មីហើយ ធ្លាក់ចុះមកលើផែនប្រថពី ឱកូនសំឡាញ់ម្ដាយ ចូរអ្នកក្រោកឡើង កុំដេកនៅឡើយ សាច់បេះដូងរបស់ម្ដាយភ្លើងគឺសេចក្ដីទុក្ខនឹង

នេះឥឡូវនេះហើយកាលបើកូនសំឡាញ់អ្នកស្លាប់ទៅហើយ ម្ដាយក៏នឹងស្លាប់ជា១មិនខានឡើយ ម្ដាយនឹងរស់នៅឯណាបានតែម្នាក់ឯង នែបុត្រជាទីស្រឡាញ់បំផុតរបស់ម្ដាយ ឥឡូវនេះម្ដាយរកទីពឹងពុំបាក់មិនមានឡើយ ដូចមេម្រឹគដែលព្រាត់ព្រាកបាកកូន ម្ដាយនឹងត្រាច់ទៅក្នុងព្រៃនឹងក្ស័យជីវិតដល់នូវមរណកាលក្នុងដងនៃព្រៃមិនខាន ។

១ និសោតទេវតាទាំងឡាយ ដែលលោកស្ថិតនៅក្នុងភ្នំនឹងព្រៃទាំងឡាយ នឹងដើមឈើវិមានភូមិស្ថានទាំងឡាយ ឬទេវតាដែលស្ថិតនៅលើអាកាសស្ថាននឹងជលស្ថាននឹងថលស្ថានទាំងឡាយឯណា នឹងសម្ដេចឥន្ទ្រាធិរាជ ព្រមទាំងមហាព្រហ្ម, ខ្ញុំម្ចាស់សូមប្រណម្យនមស្ការនូវទេវតាទាំងឡាយនោះសូមលោកទាំងឡាយអញ្ជើញមកជួយដោះទុក្ខកូនខ្ញុំ ឲ្យរួចផុតចាកសេចក្ដីស្លាប់ក្នុងកាលឥឡូវនេះកុំខានៗ ព្រះរាជទេវីទ្រង់ឱបនូវព្រះរាជឱរសរបស់នាងហើយទ្រង់ព្រះពិលាបដោយន័យយ៉ាងនេះ ។

គ្រានោះពិភពនៃសកទេវរាជ ក៏បណ្ដាលអាការឲ្យជា

ហេតុខុសចាកធម្មតា ដោយអំណាចនៃសេចក្តីកតញ្ញូរបស់ព្រះមហាបុរសរតន៍ សម្តេចព្រះសហស្សន័យទ្រង់រំពឹងមើលហើយទ្រង់ជ្រាបច្បាស់នូវហេតុនោះ ទើបស្តេចចុះចាកសគ្គស្ថានទេវលោក មកស្ថិតនៅលើអាកាសត្រង់ទីដែលមហាយក្ខស្ថិតនៅនោះ ហើយទ្រង់សួរទៅយក្ខនោះថា នែពលាហកយក្ខហេតុអ្វីក៏ឯងធ្វើអំពើកម្មមានកំឡាំងរហាស់យ៉ាងនេះ នែមហាយក្ខថាបើមហាបុរសនេះមិនបានរស់ឡើងឥឡូវនេះទេអញនឹងទំលាយនូវក្បាលរបស់អ្នកឲ្យបែកជា ៧ ភាគ ដោយវជិរាវុធនេះមិនខាន ពលាហកយក្ខ បានស្តាប់ដូច្នោះហើយ មានចិត្តខ្លាចស្លាប់នោះក្រៃពេក ទើបស្ទុះចូលទៅលើកព្រះបរមពោធិសត្វឡើងហើយក៏លាបស្រឡាបដោយឱសថទិព្វវិសេស ១ រំពេចព្រះពោធិសត្វក៏បានភ្ញាព្រះស្មារតីឡើង ។

ឯសម្តេចព្រះវររាជៈទេវីនាងក៏ទ្រង់អធិស្ឋានថា ៖

កតញ្ញូតាយយុត្តោសោ ពុទ្ធោហោតិអនាគតេ
មម សច្ចានុភាវេន ចិរំជីវតុឱរសោ ។

សេចក្តីថា ព្រះឱរសរបស់អញនោះជាអ្នកតាំងមាំក្នុងធម៌

កតញ្ញូ មុកជានឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាលដោយពិត សូមឲ្យឱរសរបស់ខ្ញុំរស់រួចជីវិតឡើងក្នុងកាលឥឡូវនេះ ដោយអានុភាពនៃសេចក្តីពិតរបស់ខ្ញុំម្ចាស់កុំខានឡើយ ។

កាលបើចប់ពាក្យសច្ចាធិស្ឋានហើយ ព្រះមហាបុរសក៏មានពណ៌សម្បុរដ៏ផូរផង់ ហាក់ដូចជាពណ៌ទិព្វវិសេស ដោយអំណាចនៃសេចក្តីអធិស្ឋានរបស់ព្រះរាជទេវី លុះចប់សេចក្តីអធិស្ឋានជាគំរប់ពីរព្រះបរមពោធិសត្វក៏មានដង្ហើមចេញចូលបាន ហើយប្រែព្រះអង្គត្រឡប់ទៅមកខាងឆ្វេងខាងស្តាំ លុះចប់ពាក្យសច្ចវាទីជាគំរប់ ៣ ព្រះពោធិសត្វមានព្រះស្មារតីដឹងប្រាកដហើយ ទើបក្រោកឡើងក្រាបថ្វាយបង្គំសម្តេចព្រះវររាជទេវី ព្រះជននីរបស់ព្រះអង្គក្នុងកាលគ្រានោះ ។

តមត្ថំបកាសេន្តោសត្ថាអាហ. ព្រះបរមលោកនាថសាស្តាចារ្យ ទ្រង់ប្រកាសនូវសេចក្តីទាំងនោះមកដល់ត្រឹមនេះហើយ ទើបទ្រង់សំដែងនូវព្រះគាថានេះថាៈ

និរោគោឧដ្ឋហិត្វាន វន្ទិត្វាសកមាតរំ
ឯកមន្តេនិសីទិត្វា អាវជ្ជគុណាមត្តនោ

ឯវំអាវជ្ជមានោសោ　　អកម្បិធរណីតទា
សាគរោបិសំខុព្ភិតិ　　សិនេរុតត្ថឱនមិ
ចាតុមហារាជិកាទេវា　　តាវតឹសាបយាមិកា
តុសិតាបេវយេទេវា　　និម្មានរតិយេវប
បរនិម្មិតវសវត្តី　　យេព្រហ្មាបិចទេវតា
អានន្ទិតាបមុទិតា　　ទិសាទិសំអកំសុតេ
ទិព្វមណ្ឌារវបុប្ផំ　　បទុមំបារិច្ឆត្តកំ
ទិសាទិសំឱកិរឹសុ　　នភតលេនរាមរុំ
ចម្បកំសរលំនិបំ　　នាគបុនាគកេតលំ
ទិសាទិសំឱកិរឹសុ　　ភុម្មាភុម្មដ្ឋទេវតា
សព្វេទេវាសមាគតា　　បូជយឹសុនរុត្តមំ
បូជយន្តាបយេទេវា　　តទំវិចនមព្រវិ
សាធុសាធុមហាវីរ　　កតវេទីនរុត្តម
អបិរនេវកាលេន　　ពុទ្ធោលោកេភវិស្សតិ

ប្រែជាសេចក្តីថា ព្រះមហាបុរសព្រះអង្គបានប្រាសចាក រោគាពាធហើយ ក៏ក្រោកឡើងឱនកាយថ្វាយបង្គំព្រះជននី

អង្គុយនៅក្នុងទីដ៏សមគួរមួយ ហើយទើបនឹករឭកដល់គុណ គឺសេចក្ដីល្អរបស់ខ្លួន កាលដែលទ្រង់រំពឹងយ៉ាងនឹងហើយទី នោះព្រះធរណីក៏កំរើកញាប់ញ័រ សាគរសមុទ្រក៏បន្លឺសព្ទសំ-ឡេងលាន់ឮគឹកកងរំពង ទាំងភ្នំសិនេរុរាជសោតក៏ទន់ទោឱន ទៅក្នុងទីនោះ ឯទេវតាក្នុងជាន់ចាតុមហារាជិកា នឹងតាវតឹស យាមាតុសិតនិម្មានរតីនឹងបរនិម្មិតវសវត្តី រហូតដល់ទេវតាក្នុង ជាន់មហាព្រហ្មសោតក៏មានសេចក្ដីសប្បាយរីករាយ តែរាល់ គ្នាដោយសោមនស្សចិត្ត ទាំងផ្កាទិព្វមណ្ឌារវបារិច្ឆតកបទុម ជាតិសោត ក៏ធ្លាក់ចុះរោយរាយទូទៅទាំងទិសតូចទិសធំសព្វ កន្លែង ពពួកជនទូទៅទាំងអស់ក៏រោយរាយនូវគ្រាប់ខ្សែបនឹង ផ្កាឈើផ្សេង ៗ មានផ្កាស្រល់នឹងផ្កាភាំងផ្កាខ្ទឹង នឹងផ្កាបុនាគ នឹងផ្កាចម្បាជាដើម ឲ្យផ្សាយក្លិនរហូតទៅក្នុងអាកាសនឹងទិសា នុទិស បំណែកទេវតាទាំងឡាយទាំងពួងមានភូមទេវតាជា ដើម ក៏មកប្រជុំគ្នាធ្វើសក្ការបូជា មហាបុរសជានរុត្តមក្សត្រ លុះបានបូជារួចហើយក៏ពោលសរសើរព្រមគ្នាថា នរុត្តមបពិត្រ ព្រះមហាបុរសជានរុត្តមលោក ព្រះអង្គមានភ្យាយាមធំ ទ្រង់

បានសងគុណព្រះជននី ដោយកតវេទីធម៌រូបហើយជាកិច្ចដ៏ឧត្តមប្រពៃពេកណាស់ ព្រះអង្គមុកជានឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធក្នុងលោកនេះមិនខានឡើយ ។

លំដាប់នោះ ទើបពលាហកយក្សក្រាបថ្វាយបង្គំព្រះបរមពោធិសត្វសូមខមាទោសស្រេចហើយ ក៏ទេវតាទាំងឡាយមានសម្ដេចសក្កទេវរាជជាដើម និមិត្តនូវសុវណ្ណសិរិកា (វិមាស) អញ្ជើញព្រះរាជទេវី នឹងព្រះបរមពោធិសត្វឲ្យគង់លើវិមាសនោះហើយ ជង្កើរទៅកាន់ស្រុកមេឃវតី ក្នុងវេលារាត្រីកណ្ដាលអទ្រាត្រ ហើយឲ្យគង់នូវលើរតនមញ្ចាសនពួដ៏ខាងលើប្រាសាទ ៧ ជាន់ ទើបទេវតាទាំងនោះថ្វាយបង្គំលាត្រឡប់ទៅកាន់ទីលំនៅរបស់ខ្លួន ៗ វាល់គ្នាវិញ ។

គ្រានោះសម្ដេចព្រះបាទមហាវបិរាជ ព្រះអង្គក៏បានជួបប្រទះនឹងបុត្រភរិយា ហើយទ្រង់ក៏ស្គាល់ជាក់ប្រាកដជាព្រះរាជទេវីនឹងព្រះពោធិសត្វ ស្ដេចក៏មានព្រះហឫទ័យសោមនស្សជាទីបំផុតចិត្តពេកណាស់ ហើយព្រះអង្គទ្រង់លើករាជសម្បត្តិឲ្យទៅរាជឱរសរបស់ព្រះអង្គសោយរាជជំនួស ឯព្រះបរមពោ-

ធិសត្វ ទ្រង់បានរាជាភិសេកសោយនូវបញ្ចកាមគុណតាមសមគួរហើយ ទ្រង់ក៏ឲ្យទានអស់ ១ ខែទើបលើករាជសម្បត្តិនោះបង្វែរថ្វាយព្រះអរាជបិតាវិញ ដើម្បីនឹងឲ្យព្រះបិតាមាតាទ្រង់ស្រែងតាក់តែងព្រះអង្គ នឹងសោយឡស្រួលក្នុងព្រះរាជហ្ឫទ័យ ទើបថ្វាយបង្គំសូមខមាទោសនឹងសូមព្រះរាជានុញ្ញាតដើម្បីបេញទៅទ្រង់ព្រះភ្នួស ហើយទ្រង់លាអស់រាជវង្សានុវង្សទាំងឡាយគប់គ្នា ឯមហាជនទាំងឡាយនោះ ក៏កើតសេចក្ដីសោកស្ដាយព្រះពោធិសត្វជាទីបំផុតពេក ហើយព្រះអង្គក៏ស្ដេចបេញចាកនគរទៅតែម្នាក់ឯង បែព្រះភក្ត្របំពោះទៅកាន់ភ្នំហិមពាន្តហាក់ដូចជាកូនរាជហង្សហើរចេញអំពីកំពូលភ្នំធំ ។

តមត្ថុបកាសេន្ដោសត្ថាអាហ ព្រះបរមសាស្ដាចារ្យ កាលទ្រង់ប្រកាសនូវរឿងទាំងនោះស្រេចហើយ ទើបទ្រង់ត្រាស់នូវគាថានេះថា៖

យតោរជ្ជំលភិត្វាន មាសំទានំអទាសិសោ
បិតុរជ្ជំនិយ្យាទេត្វា ហិមវន្តំនិវត្តយិ ។

សេចក្ដីថា កាលណាដែលព្រះមហាសត្វ ស្ដេចបាន

រាជសម្បត្តិរួចហើយទ្រង់ក៏បានបរិច្ចាគនូវទានប្រមាណ១ខែ ហើយ ទើបទ្រង់បង្វែររាជសម្បត្តិនោះថ្វាយដល់ព្រះរាជបិតាវិញរួចទើបព្រះអង្គក្រាបថ្វាយបង្គំសូមព្រះរាជានុញ្ញាតនឹងត្រឡប់ទៅកាន់ព្រៃហិមពាន្តវិញ ដើម្បីនឹងបួសជាឫសី ក៏ព្រះបរមពោធិសត្វទ្រង់បព្វជ្ជាជាឫសីរួចហើយវេលាណាព្រះអង្គក៏បំរើនអភិញ្ញា ៥ នឹងសមាបត្តិ ៨ ឲ្យបរិបូណ៌ឡើងក្នុងសន្តានទ្រង់ក៏រក្សាគុណវិសេសទាំងនោះមិនឲ្យសាបសូន្យឡើយ លុះអស់ព្រះជន្មាយុទៅក៏បានឡើងទៅកើតក្នុងស្ថានព្រហ្មលោក ។

ឯសម្តេចព្រះបាទមហារថរាជនឹងព្រះនាងសិរិរតនអាភានឹងមហាជនក្នុងនគរនោះ ក៏បានដឹកល់នៅក្នុងឱវាទនៃព្រះបរមពោធិសត្វនោះបានធ្វើនូវបុញ្ញរាសីទាំងឡាយ មានទានជាដើម កាលបើអស់អាយុរាល់គ្នាទៅវេលាណាហើយ ក៏បានឡើងទៅកើតក្នុងស្ថានព្រហ្មលោកគ្រប់គ្នា ។

សត្ថាឥមំធម្មទេសនំអាហរិត្វា

សច្ចានិបកាសេត្វាជាតកំសមោធានេសិ

សម្តេចព្រះបរមគ្រូទ្រង់នាំនូវធម្មទេសនារឿងនេះមក

ហើយ ទើបទ្រង់ប្រកាសនូវអរិយសច្ចទាំង ៤ ប្រការលុះចប់ហើយវេលាណា មាតុបោសក ក៏បានលុះសោតាបត្តិផលជាអរិយបុគ្គលក្នុងពុទ្ធសាសនមណ្ឌល ទើបព្រះបរមសាស្តាទ្រង់ផ្ជុំនូវជាតកមកប្រាប់ថា នាងសិរិវឌ្ឍនអាភាជាមាតាពោធិសត្វនោះបានមកជានាងមហាមាយាទេវី ព្រះបាទព្រះមហារថរាជជាបិតាពោធិសត្វនោះបានមកជាព្រះបាទសិរិសុទ្ធោទនមហារាជ ព្រះសកទេវរាជបានមកជាព្រះអនុរុទ្ធថេរ ពលាហកយក្ខបានមកជាព្រះអង្គុលិមាលថេរ ព្រះមហាសត្វរតនបជោត នោះមិនគឺអ្នកដទៃឡើយ គឺអង្គអញតថាគតជានាយកនេះឯង អស់លោកទាំងឡាយចូរទទ្រង់នូវព្រះជាតកនេះទុកដោយប្រការយ៉ាងនេះ ។ ០៚—

បប់រតនបជោតជាតក

# ខេមាខេមសរណាគមនកថា

ភិក្ខុ ឈឹម-ស៊ុំ កូនសិស្សនៅថ្នាក់ឧត្តមវិជ្ជា ឆ្នាំទី ៥ សាលាបាឡីជាន់ខ្ពស់

ប្រែនិងរៀបរៀង

ព្រះគ្រូសម្មភិរម្យ

នាយកសាលាបាឡីជាន់ខ្ពស់បានពិនិត្យផ្ទៀងផ្ទាត់

## អត្តនោមត្យាធិប្បាយ

ជនទាំងឡាយដែលកើតមកក្នុងលោក តែងស្វែងរកវត្ថុជាទីពឹងគ្រប់ ៗ រូបដូចគ្នា ព្រោះតែប្រាថ្នាចង់បានសេចក្ដីសុខតែម្យ៉ាងប៉ុណ្ណោះ តែប្លែកគ្នានឹងជនខ្លះអប្បប្រាជ្ញ ជនខ្លះមានប្រាជ្ញា ជនដែលអប្បប្រាជ្ញាមិនបានពិចារណាឲ្យឃើញច្បាស់នូវហេតុនិងផលគឺមិនដឹងថាហេតុយ៉ាងនេះ នឹងបំរើនឡើងបានជាផលយ៉ាងណា នឹងមិនដឹងថាផលនេះកើតមកអំពីហេតុដូចម្ដេចនោះឡើយ ម្លោះហើយបើមានភ័យកើតឡើង ក៏ប្រវ៉ារកវត្ថុជាទីពឹងតាមតែប្រទះ គាប់ចិត្តត្រង់ណាក៏ផ្ញើត្រង់នោះ មិនពិនិត្យត្រង់ខុសត្រូវប៉ុន្មានតាមសភាពនៃខ្លួនជាជនអប្បប្រាជ្ញា

បើមិនពិនិត្យរកខុសត្រូវសោះហើយប្រឹងតែធ្វើទៅៗ ជួនពាន លើខុស ជួនពានលើត្រូវ បើខុសត្រូវមិនដឹងដូច្នេះហើយ កាល ណាឡើយនឹងសម្រេចប្រយោជន៍បាន ។

ជនបំពូកនេះមានជាច្រើនដូចជាជនខ្លះគ្រាន់តែឃើញគេ ដល់នូវសរណគមន៍ គឺដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសំឃជាទី ពឹងគេរៀបចំគ្រឿងសក្ការមានទៀននឹងធូបជាដើមយកទៅបូជា ហើយធ្វើអភិវន្ទនាការថ្វាយបង្គំព្រះរតនត្រៃ ក៏បាំទំនងរបស់ គេបាន ដល់មានសេចក្ដីទុក្ខកើតឡើង ក៏រៀបចំគ្រឿងសក្ការ ទៀនធូបទៅអុចបូជានូវគល់ឈើហើយថ្វាយបង្គំនូវគល់ឈើ សម្គាល់ដើមឈើថាជាទីពឹងដ៏ប្រសើរ មិនតែប៉ុណ្ណោះឡើយ ជនបំពូកខ្លះទៀតបានឃើញវត្ថុអ្វីប្លែកៗគួរឲ្យសង្ស័យ ក៏បបួល គ្នាយកគ្រឿងសក្ការទៅបូជាហើយថ្វាយបង្គំសូមសេចក្ដីសុខ, ដែលធ្វើដូច្នេះ ក៏មិនព្រោះហេតុអ្វី ព្រោះតែអប្បប្រាជ្ញាហើយ ចង់បានសេចក្ដីសុខ ធ្វើទៅក៏មិនបានប្រយោជន៍អ្វីគាំឲ្យតែ នឿយពិតអំពើ ។

ប្រៀបដូចអ្នកល្ងង់ហើយចង់ស្លរប្រេង ឃើញគេអ្នកបេះ

ស្លរគេរៀបថ្មបង្ក្រាន បង្កាត់ភ្លើង ដម្កល់ឆ្នាំងខ្ទះ ហើយយក គ្រាប់ល្ហុងឬគ្រាប់ល្ហុរមកចម្រាញ់បេញបានជាប្រេងមក ខ្លះក៏ ទំរៀបថ្មបង្ក្រាន បង្កាត់ភ្លើង ដំកល់ឆ្នាំងខ្ទះហើយយកដុំគ្រួសឬ ដុំថ្មមកចម្រាញ់បម្តេចនឹងបេញបានជាប្រេង គាំឲ្យតែនឿយ ព្រួយឥតអំពើ ។

ជនខ្លះមានប្រាជ្ញាពិចារណាឃើញច្បាស់នូវហេតុនឹងផល គឺដឹងច្បាស់ថាហេតុដូច្នេះ នឹងកើតឡើងបានជាផលដូច្នេះ ផលនេះកើតមកអំពីហេតុនេះ កាលស្វែងរកវត្ថុជាទីពឹងក៏រកវត្ថុ ដ៏គួរល្មមបណ្តាលឲ្យកើតឡើងជាផលគឺសេចក្តីសុខបាន គឺ ដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងហើយមិនវិបរិតប្រែ ប្រួលយកវត្ថុអ្វីជាទីពឹងទៀត ព្រោះប្រាជ្ញាដឹងច្បាស់ថាមានតែ វត្ថុ ៣ នេះហើយជាទីពឹងដ៏ប្រសើរ កាលសទ្ធាប្រាកដមិន កម្រើកដូច្នេះហើយ សរណាគមន៍ក៏មិនកម្រើកជាសរណាគមន៍ ដ៏ប្រកបដោយមគ្គចិត្តកើតឡើងហើយបានឃើញច្បាស់នូវសច្ច ទាំង ៤ ប្រការ គឺ ទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ដោយប្រាជ្ញាដ៏មាំ ក៏កំណត់នូវទុក្ខសច្ចបានដោយ

បរិញ្ញាភិសមយ លះបង់នូវសមុទយសច្ចបានដោយបហានាភិសមយ ធ្វើឲ្យជាក់ច្បាស់នូវនិរោធសច្ចបានដោយសច្ឆិកិរិយាភិសមយ ធ្វើមគ្គសច្ចឲ្យកើតឲ្យមានឡើងបានដោយភាវនាភិសមយ ឈ្មោះថាគាស់រម្លើងនូវឫសនៃសេចក្តីទុក្ខបាន បានដល់នូវព្រះនិព្វានជាស្ថានក្សេមផុតចាកទុក្ខ ព្រោះអាស្រ័យប្រាជ្ញាហើយស្វែងរកនូវវត្ថុជាទីពឹងដ៏ប្រសើរ ។ ប្រៀបដូចបុគ្គលឆ្លាសក្នុងវិធីស្លរប្រេងបានយកគ្រាប់ល្ហុង ឬគ្រាប់ល្ហុងមកចម្រាញ់ក៏ចេញបានជាប្រេងមែន ។ ជនដែលស្វែងរកវត្ថុជាទីពឹងផ្សេងគ្នាដូចពោលរួចហើយខាងដើមនេះ សមដូចពុទ្ធភាសិតពាក្យដែលព្រះពុទ្ធជាម្ចាស់ត្រាស់ទុកមកដូចនឹងពោលតទៅនេះ:

ពុទ្ធភាសិត

ពហុំ វេ សរណំ យន្តិ  បព្វតានិ វនានិ ច
អារាមរុក្ខចេត្យានិ  មនុស្សា ភយតជ្ជិតា
នេតំ ខោ សរណំ ខេមំ  នេតំ សរណមុត្តមំ

នេតំសរណមាគម្ម សព្វទុក្ខាបមុច្ចតិ ។

ប្រែថា មនុស្សទាំងឡាយមានប្រមាណច្រើនដែលមានភ័យគម្រាមហើយ ។ មានប្រាថ្នាដើម្បីរួចចាកភ័យនោះ ( ឬមានប្រាថ្នាចង់បានវត្ថុអ្វីមានកូនជាដើម ) តែងដល់នូវភ្នំ, ព្រៃធំ, សួនច្បារនឹងរុក្ខចេតិយ គឺឈើដែលអ្នកស្រុកធ្លាប់បូជាជាទីពឹង ធម្មជាតិមានភ្នំជាដើមនេះមិនមែនជាទីពឹងដ៏ក្សេមទេ ធម្មជាតិមានភ្នំជាដើមនេះ មិនមែនជាទីពឹងដ៏ឧត្តមទេ; បុគ្គលអាស្រ័យនូវធម្មជាតិមានភ្នំជាដើមនេះជាទីពឹងហើយមិនបានរួចចាកសកលវដ្តទុក្ខ គឺសេចក្តីទុក្ខក្នុងវដ្តសំសារទាំងពួងឡើយ ។

យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ
អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ
ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ
ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ

ប្រែថា លុះតែបុគ្គលឯណា ដល់នូវព្រះពុទ្ធផង, ព្រះធម៌ផង, ព្រះសំឃផង, ជាទីពឹង ហើយឃើញច្បាស់នូវអរិយសច្ចទាំងឡាយ ៤ គឺទុក្ខអរិយសច្ច ១ សមុទយអរិយសច្ច ១ និរោធអរិយសច្ច ១ មគ្គអរិយសច្ច ១ ដោយប្រាជ្ញាដ៏មាំ, ធម្មជាតមានព្រះពុទ្ធជាដើមនេះជាទីពឹងដ៏ក្សេម, ធម្មជាតមានព្រះពុទ្ធជាដើមនេះជាទីពឹងដ៏ឧត្តម, បុគ្គលនោះអាស្រ័យនូវធម្មជាតមានព្រះពុទ្ធជាដើមនេះ ជាទីពឹងហើយទើបរួចបាកសកលវដ្តទុក្ខ គឺសេចក្តីទុក្ខក្នុងវដ្តសំសារទាំងពួងបាន ។

អត្ថនោមត្យាធិប្បាយ

ជនអ្នកស្វែងរកនូវវត្ថុជាទីពឹង ត្រូវឲ្យមានប្រាជ្ញាទើបស្វែងរកវត្ថុជាទីពឹងមិនខុស អ្នកដែលអប្បប្រាជ្ញាហើយស្វែងរកវត្ថុជាទីពឹង មានពានទៅលើខុសដោយច្រើន ទុកជាពានទៅលើត្រូវ គឺដល់នូវព្រះរតនត្រ័យជាទីពឹងហើយគង់ងមិនបានសម្រេចប្រយោជន៍ពេញទីក៏មាន ព្រោះគ្រាន់តែឮលោកអ្នកសម្តែង ៗ ថា " មានតែព្រះរតនត្រ័យជាទីពឹងដ៏ប្រសើរ " ដូច្នេះក៏យកជាទីពឹងតាមតែលោកទៅ ដែលនឹងដឹងថាប្រសើរ

នោះព្រោះហេតុអ្វី ឬដឹងថាព្រះរតនត្រ័យនោះដូចម្ដេចក៏គ្មានឡើយ ។

ជនខ្លះទៀតគ្រាន់តែឮលោកសម្ដែងថា " យកព្រះរតនត្រ័យជាទីពឹងទើបរួចចាកសេចក្ដីទុក្ខ " ក៏យកជាទីពឹងតាមពាក្យលោកទៅ ហើយនៅតែប្រព្រឹត្តទុច្ចរិតដដែលដោយគិតថា " អញបានយកព្រះរតនត្រ័យជាទីពឹងហើយ, មុខជារួចចាកសេចក្ដីទុក្ខហើយ„ បើដូច្នេះតើដូចម្ដេចនឹងសម្រេចប្រយោជន៍បាន ដូចម្ដេចនឹងរួចចាកសេចក្ដីទុក្ខបាន ។

ហេតុនេះសប្បុរសអ្នកដល់នូវសរណគមន៍ត្រូវអាស្រ័យប្រាជ្ញារបស់ខ្លួនផង អាស្រ័យនូវសេចក្ដីសុចរិតរបស់ខ្លួនផង ទើបសម្រេចកិច្ចសរណគមន៍បាន ទើបរួចចាកសេចក្ដីទុកបាន។

ប្រៀបដូចបុគ្គលទៅពឹងបុណ្យព្រះមហាក្សត្រិយ៍ គឺអ្នកផ្កាប់បុណ្យ បើខ្លួនមិនចេះបំណោះអ្វីសោះ ឲ្យព្រះអង្គតាំងឲ្យធ្វើការអ្វីកើត ពុំនោះសោតទេ អ្នកនោះចេះដឹងដែរតែមារយាទអាក្រក់ប្រព្រឹត្តទុច្ចរិតផ្សេង ៗ ឲ្យព្រះអង្គតាំងឲ្យធ្វើជាធំដូច

ម្តេចបាន, ឯអ្នកទាំងអម្បាលនេះ គឺអ្នកឥតបំណេះវិជ្ជា ឬមានបំណេះវិជ្ជាតែប្រព្រឹត្តទុច្ចរិត ផុតវិស័យព្រះមហាក្សត្រិយ៍សង្គ្រោះគឺព្រះមហាក្សត្រិយ៍សង្គ្រោះមិនបាន មានឧបមាដូចម្តេចមិញ ។

ឯបុគ្គលអ្នកដល់នូវព្រះរតនត្រ័យជាទីពឹងហើយ ល្ងង់មិនស្គាល់ទាំងព្រះរតនត្រ័យផង, ប្រព្រឹត្តទុច្ចរិតផង, ក៏មិនបានប្រយោជន៍បំណាច់អ្វីអំពីកិច្ចដែលដល់នូវព្រះរតនត្រ័យ ជាទីពឹងនោះ មានឧបមែយដូច្នោះ ។

អ្នកទៅទីពឹងបុណ្យព្រះមហាក្សត្រិយ៍ លុះតែប្រកបដោយសេចក្តីចេះដឹងផង ប្រកបដោយសេចក្តីសុច្ចរិតផង ទើបព្រះមហាក្សត្រិយ៍ប្រោសប្រាណបាន មានឧបមាដូចម្តេចមិញ ។

អ្នកដែលដល់នូវសរណគមន៍ លុះតែប្រកបដោយប្រាជ្ញានឹងសេចក្តីសុច្ចរិតទើបសម្រេចប្រយោជន៍បាន មានឧបមែយដូច្នោះ ។

ពាក្យនេះសមដូចពុទ្ធភាសិតសំខាន់ ១ កន្លែងដែលព្រះពុទ្ធជាម្ចាស់ត្រាស់ទុកមក ដូចនឹងពោលតទៅខាងមុខនេះ ។

# អត្តាហិអត្តនោនាថោ

## ខ្លួនឯងជាទីពឹងរបស់ខ្លួន

### សេចក្តីអធិប្បាយ

បុគ្គលដែលឧប័តិមកក្នុងសាកលលោកនេះនឹងនៅម្នាក់ឯងមិនបានជាដាច់ខាត ត្រូវពឹងពាក់សម្នាក់អាស្រ័យគ្នានឹងគ្នាជាធម្មតា យ៉ាងទារកដែលឧប័តិមក ក៏ត្រូវអាស្រ័យលោកដ៏ជាធំ មានបិតាមាតាជាដើមចិញ្ចឹម, បើមិនដូច្នោះនឹងរស់នៅមិនបាន, លុះចំរើនវ័យធំឡើងហើយក៏ត្រូវពឹងអ្នកដទៃទៀតជាលំដាប់ មានពឹងគ្រូអាចារ្យជួយណែនាំប្រៀនប្រដៅក្នុងផ្លូវសិល្បសាស្ត្រនិងចរិយា សេចក្តីប្រព្រឹត្តជាដើម លុះចំរើនវ័យឡើងជាមនុស្សធំពេញទី វេលាដែលនឹងស្វែងរកទ្រព្យសម្បត្តិមកចិញ្ចឹមជីវិត នឹងទំនុកបម្រុងអ្នកដែលគួរទំនុកបម្រុងក៏ត្រូវពឹងអ្នកនេះខ្លះអ្នកនោះខ្លះជាធម្មតា ដែលមិនត្រូវពឹងអ្នកណាសោះនោះគ្មាន, ដែលពោលមកនេះដើម្បីនឹងឲ្យឃើញជាគ្រប់ ៗ រូបដែលកើតមកត្រូវពឹងអ្នកដទៃជាដរាប បើដូច្នេះ

ហេតុអ្វីបានជាក្នុងធម៌នេះពោលថា "ខ្លួនឯងជាទីពឹងរបស់ខ្លួន" ពិត គ្រប់ៗរូបត្រូវពឹងអ្នកដទៃមែន តែដែលពឹងបានក៏ដោយសេចក្ដីល្អរបស់ខ្លួន អ្នកតូចប្រាកដជាត្រូវពឹងអ្នកធំ តែបើអ្នកតូចឯណាមិនមានគុណគឺសេចក្ដីល្អ ឬជាមនុស្សប្រព្រឹត្តទុច្ចរិតផ្សេងៗ អ្នកតូចនោះគង់មិនមានអ្នកធំណាជាទីពឹងទេ ប្រហែលសម្ដេចព្រះបរមសាស្ដាចារ្យ ដែលព្រះអង្គជាគារបស់លោក ជាទីពឹងរបស់សត្វទាំងឡាយ រកអ្នកដទៃក្រៃលែងជាងគ្មាន នោះក៏ជាទីពឹងចំពោះតែវេនេយ្យសត្វ គឺសត្វដែលគួរណែនាំបានប៉ុណ្ណោះ ដែលជាទីពឹងដល់ភូតបុគ្គលផងនោះគ្មានទេ, ខនេះសម្ដែងបង្ហាញសេចក្ដីឲ្យឃើញថា ខ្លួនឯងជាទីពឹងរបស់ខ្លួន អ្នកដទៃគ្រាន់តែជាបច្ច័យជួយឧបថម្ភប៉ុណ្ណោះ ព្រោះហេតុដូច្នោះ ទើបមានព្រះពុទ្ធភាសិតត្រាស់ប្រដៅថា "ខ្លួនឯងជាទីពឹងរបស់ខ្លួន" ដូច្នេះ ។

ហេតុនេះអ្នកស្វែងរកវត្ថុជាទីពឹង ត្រូវអាស្រ័យប្រាជ្ញានឹងសេចក្ដីសុចរិតរបស់ខ្លួនទើបសម្រេចកិច្ចទីពឹងបាន ។

ចំណែកខាងបិតាមាតាទំនុកបម្រុងកូន គ្រាន់តែហាម

កូនមិនឲ្យធ្វើអំពើអាក្រក់ ឲ្យកូនដំកល់នៅក្នុងកុសលកម្ម ឲ្យកូនសិក្សាសីល្បសាស្ត្រ រៀបចំឲ្យកូនមានស្វាមីភរិយា និងបែកទ្រព្យសម្បត្តិឲ្យប៉ុណ្ណោះ ដែលនឹងបែកសម្បត្តិសួគ៌សម្បត្តិព្រះនិព្វានឲ្យនោះមិនបានឡើយ ។

បិតាមាតាហាមកូនមិនឲ្យធ្វើអំពើអាក្រក់ ឲ្យធ្វើតែអំពើល្អនោះក៏មែនពិតហើយ តែថាបើកូនមិនធ្វើអំពើល្អ ក៏នៅតែមិនបានសម្បត្តិសួគ៌សម្បត្តិព្រះនិព្វានដដែល លុះតែកូនមានប្រាជ្ញាដឹងច្បាស់ថា "អំពើដូច្នេះ ប្រព្រឹត្តទៅដើម្បីឲ្យបានស្ថានសួគ៌ ឲ្យបានមគ្គ,ផល, នឹងព្រះនិព្វាន" ដូច្នេះហើយក៏ជម្កល់ប្រាជ្ញានោះឲ្យមាននៅក្នុងសន្តានជាធម្មតា ខំឧស្សាហ៍ធ្វើកុសលកម្មណា ១ ដែលគួរនឹងបានស្ថានសួគ៌ មគ្គ,ផល,នឹងព្រះនិព្វាន នោះទើបបានដោយពិត ។

ន័យនេះគប្បីសន្និដ្ឋានទូទៅដល់ជនដទៃទៀតចុះ ។

ហេតុដូច្នោះទើបសម្តេចព្រះសព្វញ្ញូបរមគ្រូជាម្ចាស់ទ្រង់ត្រាស់ថា "ខ្លួនឯងជាទីពឹងរបស់ខ្លួន" ដូច្នេះ ។

មួយ៉ាងទៀត បិតាមាតាគ្រូអាចារ្យបុត្តភរិយាស្វាមី នឹង

ទ្រព្យសម្បត្តិទាំងពួង ជួយខ្លួនបានតែការងាយៗគឺ បិតាមាតាជួយកូនបានតែត្រង់កិច្ចចិញ្ចឹមរក្សា គ្រូអាចារ្យជួយសិស្សបានតែត្រង់ការបង្ហាត់បង្រៀនចំណេះវិជ្ជា បុត្តភរិយាជួយបិតាមាតានឹងស្វាមីបានតែត្រង់កិច្ចប្រើប្រាស ស្វាមីជួយភរិយាបានតែត្រង់កិច្ចស្វែងរកទ្រព្យរបស់ឲ្យ ទ្រព្យសម្បត្តិជួយខ្លួនបានតែត្រង់ពេលដែលទាល់ក្រខ្វាស់ខាត ការទំនុកបម្រុងទាំងប៉ុណ្ណោះសុទ្ធតែជាការងាយៗទាំងអស់ ដែលនឹងជួយដល់ការក្រផងនោះមិនបានជាដាច់ខាត ។

ឯការក្រនោះគឺសេចក្ដីទុក្ខភ័យដែលកើតអំពីសេចក្ដីសៅហ្មង.

ដ្បិតឋាជនណាមួយ មានសេចក្ដីសៅហ្មង គឺធ្វើនូវបាណាតិបាតកម្មជាដើមក្នុងកាលមុន ដល់មកកាលនេះ មានទុក្ខវេទនាជាផលនៃកម្មនោះកើតឡើង បណ្ដាលឲ្យឈឺចាប់ឲ្យដល់នូវសេចក្ដីស្លាប់, ទុកជាបិតាមាតាគ្រូអាចារ្យបុត្តភរិយានឹងស្វាមី ក៏មិនអាចដើម្បីជួយដោះសេចក្ដីទុក្ខនោះបានឡើយ មិនអាចជួយអង្វរករថា "អ្នកកុំឈឺ អ្នកកុំស្លាប់" ដូច្នេះ បាន

ឡើយ ឬទុកជាមានទ្រព្យសម្បត្តិច្រើនក៏មិនអាចយកទៅពោះ ខ្លួនពីមច្ចុសេនា គឺសេចក្ដីឈឺចាប់បានឡើយ, មិនអាចយក ទៅសូកអង្វរមច្ចុរាជថាកុំស្លាប់ដូច្នេះបានឡើយ ។

អ្នកទាំងអស់មានបិតាមាតាជាដើម ជួយអង្វរករថា "អ្នក កុំឈឺ, អ្នកកុំស្លាប់" ដូច្នេះតែប៉ុណ្ណោះមិនបានទៅហើយ បំណង់ បើសម្បត្តិសួគ៌ សម្បត្តិព្រះនិព្វាន ធ្វើម្ដេចនឹងបែកឲ្យបាន បើទុកជាស្រឡាញ់ណាស់ហើយទាល់គំនិតនឹងអង្វរករមិនឲ្យ ឈឺមិនឲ្យស្លាប់មិនបានក៏ប្រាប់ថា អើអ្នក បើអ្នកស្លាប់ក៏ ស្លាប់ចុះ តែយើងសូមឲ្យពរអ្នកសូមឲ្យអ្នកទៅកើតស្ថានសួគ៌ ដូច្នេះជាដើមក៏រឹតរឹងតែមិនបានដោយក្រៃលែង.

ដ្បិតថា អ្នកដែលស្លាប់ទៅក៏មិនស្លាប់ដោយគេប្រាប់ឲ្យ ឲ្យស្លាប់ បើទុកជាបានទៅកើតស្ថានសួគ៌ជាដើមក៏មិនមែនទៅ ដោយគេយល់ព្រម គេបញ្ជូនឲ្យទៅកើត ។

ហេតុដូច្នោះបានជាអធិប្បាយថា៖ ជួយបានតែការងាយៗ ដល់ការក្រៗ ដូចសេចក្ដីទុក្ខភ័យដែលកើតអំពីសេចក្ដីសៅហ្មង របស់ខ្លួន ក៏ជួយមិនបានដូច្នេះ ។

ឯខ្លួនឯងជាទីពឹងរបស់ខ្លួន ព្រោះថាខ្លួនឯងជួយបាន ក្នុងការទាំងពួងមិនថាងាយមិនថាក្រ បើអ្នកណា ១ មានទុក្ខភ័យសេចក្ដីអន្តរាយ ឬក្ដៅក្រហាយដោយជម្ងឺឈឺចាប់ជាដើមកើតឡើងហើយ ក៏ដម្កល់ប្រាជ្ញាសេចក្ដីដឹងច្បាស់ឲ្យកើតឲ្យមានក្នុងសន្ដាន បានឃើញហេតុនៃសេចក្ដីទុក្ខភ័យថា "មិនមែនកើតមកអំពីអ្វី ពិតជាកើតមកអំពីអំពើជួអាក្រក់លាមកមានសម្លាប់សត្វជាដើម" ម្លោះហើយក៏ខ្មីឃ្មាតឧបាតខំឲ្យខានរៀនធម៌អាចិរក្សាសីល ឬចំរើនមេត្តាភាវនា ដោយចិត្តសទ្ធាជឿជាក់ច្បាស់នូវកម្មនឹងផលនៃកម្ម. អំពើទាំងនេះណា ១ ក៏អាចនាំអ្នកនោះឲ្យបានស្ថានសុខ ប្រាសចាកសេចក្ដីទុក្ខទាំងពួងបាន. គឺថាឲ្យខានរៀនធម៌អាចិរក្សាសីលជាកាមាវចរកុសល ឲ្យផលនាំបដិសន្ធិឲ្យកើតក្នុងកាមាវចរសួគ៌ទាំង ៦ ជាន់, ចំរើនមេត្តាភាវនា បានឈាននឹងអភិញ្ញា បើឈាននោះជាអារម្មណូបនិជ្ឈាន មានកសិណជាដើមជាអារមណ៍ ហៅថាលោកីយឈាន បើជារូបាវចរលោកីយឈាន មានផលនាំបដិសន្ធិឲ្យកើតក្នុងរូបាវចរសួគ៌, បើជាអរូបាវចរលោកីយឈាន

មានផលនាំបដិសន្ធិឲ្យកើតក្នុងអរូបាវចរសួគ៌. បើឈាននោះ ជាលក្ខណូបនិជ្ឈាន មានវិបស្សនាជាជើងដម្កល់ ហៅថា លោកុត្តរឈាន មានផលធ្វើជាតិឲ្យថយចុះ មិនឲ្យអន្ទោលទៅក្នុងវដ្តសំសារជាច្រើនជាតិទៀតបានឡើយ ។

ប្រាជ្ញាដឹងច្បាស់មានក្នុងសន្ដានបានធ្វើបុណ្យឲ្យទាន រៀនធម៌អាចរក្សាសីល ឬចំរើនមេត្តាភាវនា កុសលណាមួយក៏អាចដោះខ្លួនឲ្យរួចអំពីទុក្ខភ័យសេចក្ដីអន្តរាយ ឬក្ដៅក្រហាយ ដោយធម្មឺឈឺចាប់ជាដើមនោះបានដោយពិត ហេតុដូច្នោះទើប សម្ដេចព្រះបរមនាថសាស្ដាចារ្យទ្រង់សម្ដែងថា ខ្លួនឯងជាទីពឹងរបស់ខ្លួន" ដូច្នេះ ។

ខ្លួនជាទីពឹងរបស់ខ្លួន អាចជួយខ្លួនបានក្នុងការក្រ ៗ ដូច្នោះបានហើយ · ចាំបាច់ពោលថ្វីដល់ការងាយ ៗ រិតរឹងតែជួយបានឥតសេចក្ដីសង្ស័យឡើយ ។

សប្បុរសជាបណ្ឌិតជាតិ មានប្រាជ្ញាល្អ បានពិចារណាឃើញច្បាស់ថា: "ខ្លួនឯងជាទីពឹងរបស់ខ្លួន" ដូច្នេះ ហើយ គប្បីរក្សាខ្លួនឲ្យល្អ គប្បីដម្កល់ដម្កើងលើកខ្លួនឡើងប្រតិស្ឋាន

នៅក្នុងទីប្រាសចាកសេចក្ដីអន្តរាយ កុំគប្បីសប្បាយដោយអំពើឯនពាល ត្រូវត្រេកត្រអាលដោយធម៌ជារបស់សប្បុរស ទើបបានឈ្មោះថារក្សាខ្លួនដោយល្អ, ពាក្យនេះសមដូចពុទ្ធភាសិត ១ កន្លែងដែលសម្ដេចព្រះបរមគ្រូលោកាចារ្យសម្មាសម្ពុទ្ធទ្រង់សម្ដែងទុកមកដូចនឹងពោលតទៅខាងមុខនេះ ។

ពុទ្ធភាសិត

អាបទាយ ធនំ រក្ខេ ទារេ រក្ខេ ធនេនបិ
អត្តានំ សតតំ រក្ខេ ទារេហិបិ ធនេហិបិ

(ប្រែថា) បុគ្គលគប្បីរក្សានូវទ្រព្យដើម្បីការពារនូវសេចក្ដីអន្តរាយ ។

បុគ្គលគប្បីរក្សានូវប្រពន្ធទាំងឡាយ ដោយទ្រព្យដែរ, បុគ្គលគប្បីរក្សានូវខ្លួនឲ្យទៀងជាងប្រពន្ធទាំងឡាយផង ជាងទ្រព្យទាំងឡាយផង ។

សេចក្ដីអធិប្បាយ

បុគ្គលគប្បីរក្សានូវទ្រព្យសម្បត្តិ គ្រឿងឧបភោគបរិភោគទាំងពួង ប្រយោជន៍ដើម្បីការពារនូវសេចក្ដីអន្តរាយ បើមាន

សេចក្ដីអន្តរាយកើតឡើងអំពីព្រះមហាក្សត្រិយ៍រឺបជាន់ ឬចោរ ប្លន់ជាដើម អាចយកទ្រព្យសម្បត្តិនោះការពារបាន ។

បុគ្គលរក្សានូវប្រពន្ធទាំងឡាយក៏រក្សាដោយទ្រព្យនោះដែរ បើគ្មានទ្រព្យហើយនឹងរក្សាប្រពន្ធមិនបានឡើយ នឹងមានសេចក្ដីទុក្ខព្រួយកើតឡើងក្នុងកាលជាខាងក្រោយមិនខាន ដ្បិតជាតិស្រ្ដីកម្លាំងតិចសេចក្ដីប្រាថ្នាច្រើន បន្តិចត្រូវការរបស់នេះបន្តិចត្រូវការរបស់នោះ មិនចេះស្កប់ស្កល់ បើបុរសជាស្វាមីរកឲ្យមិនបាន នឹងរំខានចិត្ត កើតវិបរិតនាំឲ្យទាស់គំនិតគ្នា ឯសេចក្ដីប្រាថ្នារបស់ស្ត្រីដូច្នេះមានជាច្រើនក្នុងលោក ។

បុគ្គលគប្បីរក្សានូវខ្លួនឲ្យទៀងទាត់ប្រាកដល្អ ជាងរក្សានូវប្រពន្ធទាំងឡាយផង ជាងរក្សានូវទ្រព្យទាំងឡាយផង ដ្បិតជាប្រពន្ធក្ដី ទ្រព្យសម្បត្តិក្ដី មានប្រយោជន៍បំណាច់ដល់ខ្លួនតិច មិនអាចជួយខ្លួនក្នុងកិច្ចការដ៏ក្រ ៗ បានឡើយ ឯខ្លួនឯងទើបមានគុណបំណាច់ច្រើន អាចជួយខ្លួនក្នុងកិច្ចការដ៏ក្រ ៗ បានដូចពោលរួចមកហើយ ។

ហេតុដូច្នេះសប្បុរសអ្នកមានប្រាជ្ញាគួរស្នេហាស្រឡាញ់ខ្លួនរបស់ខ្លួន មិនត្រូវធ្វើខ្លួនឲ្យជារបស់អប្រិយ ដ្បិតសម្ដេចព្រះជិនស្រីទ្រង់សម្ដែងថា មានតែខ្លួននឹងហើយជាទីពឹងរបស់ខ្លួន បុគ្គលអ្នកស្រឡាញ់ខ្លួនត្រូវរក្សាខ្លួនឲ្យជាជាងរបស់ទាំងអស់នោះ ។

ម្យ៉ាងទៀតថា ត្រូវរក្សាខ្លួនឲ្យល្អគ្រប់វ័យទាំង ៣ គឺបឋមវ័យ, មជ្ឈិមវ័យ, បច្ឆិមវ័យ ។

វ័យទាំង ៣ នេះ បើគិតតាមអាយុមនុស្សសព្វថ្ងៃដែលខែ្វចយចុះមកនៅត្រឹម ៧៦ ឆ្នាំជាកំណត់យ៉ាងច្រើនប្រមាណអាយុ ៧៦ ឆ្នាំត្រូវបែកទៅជា ៣ បំណែក បំណែកទី ១ ពីអាយុ ១ ឆ្នាំទៅទល់នឹងអាយុ ២៥ ឆ្នាំហៅថាបឋមវ័យ, ពីអាយុ ២៦ ឆ្នាំទៅទល់នឹងអាយុ ៥០ ឆ្នាំ ហៅថាមជ្ឈិមវ័យ, ពីអាយុ ៥១ ឆ្នាំ ទៅទល់នឹងអាយុ ៧៦ ឆ្នាំ ហៅថាបច្ឆិមវ័យ, អ្នកស្រឡាញ់ខ្លួនគប្បីរក្សាខ្លួនឲ្យល្អក្នុងវ័យទាំង ៣ នេះវ័យណា ១ កុំខានឡើយ ។

ពាក្យនេះសមដូចពុទ្ធភាសិត ដែលសម្ដេចព្រះមហាក-រុណាទិគុណអនន្តញាណ មានព្រះបន្ទូលទុកមកដូចនឹងពោលតទៅនេះ ។

ពុទ្ធភាសិត

អត្តានញ្ចេ បិយំជញ្ញា រក្ខេយ្យ នំ សុរក្ខិតំ
តិណ្ណំអញ្ញតរំ យាមំ បដិជគ្គេយ្យ បណ្ឌិតោ

(ប្រែថា) បើបុគ្គលជាបណ្ឌិតដឹងថាខ្លួនជាទីស្រឡាញ់គប្បីរក្សាខ្លួននោះឲ្យល្អ បណ្ដាវ័យទាំង ៣ អស់វ័យណា ១ កុំខានឡើយ ។

សេចក្ដីអធិប្បាយ

បើបុគ្គលជាបណ្ឌិតជាតិ មានប្រាជ្ញាដឹងច្បាស់ថាមានតែខ្លួននេះហើយជាទីស្រឡាញ់ពេញចិត្តរបស់ខ្លួន ព្រោះតែខ្លួនជាទីពឹងរបស់ខ្លួនដូច្នេះហើយ ត្រូវរក្សាខ្លួននោះឲ្យល្អកុំប្រហែសធ្វេសឡើយ ឯកិច្ចរក្សានោះបើបុគ្គលគិតថាអញនឹងរក្សាខ្លួនដូច្នេះហើយចូលទៅនៅក្នុងប្រាសាទឬគុហាបិទទ្វារបិទបង្អួចតូច-ធំ ចូលសំងំក្នុងបន្ទប់ទាំងថ្ងៃទាំងយប់ថែមដាក់យាមល្បាត

ជាំរក្សា ការពារមិនឲ្យអ្នកឯណាចូលទៅបៀតបៀនបាន ដូច្នេះ ក៏មិនទាន់បានឈ្មោះថារក្សាខ្លួនដោយល្អឡើយ ។

បើគ្រហស្ថត្រូវខំរៀនធម៌អាថ៌រក្សាសីលឲ្យទាន តាមសមគួរដល់កម្លាំង បើកាលនៅក្នុងបឋមវ័យរវល់នឹងលេងគ្មានអ្នកឯណាដាស់តឿនឲ្យបំពេញកុសលទាំងនោះទេនោះត្រូវខំបំពេញក្នុងមជ្ឈិមវ័យ, បើកាលនៅក្នុងមជ្ឈិមវ័យរវល់នឹងធ្វើការចិញ្ចឹមកូនប្រពន្ធ ឆ្លៀតធ្វើកុសលមិនបានពេញលេញ ត្រូវខំបំពេញក្នុងបច្ឆិមវ័យកុំធ្វេសប្រហែសឡើយ បើធ្វើដូច្នេះ ទើបបានឈ្មោះថារក្សាខ្លួនដោយប្រពៃ ។

ចំណែកខាងអ្នកបួសវិញ កាលនៅក្នុងបឋមវ័យត្រូវខំសិក្សារៀនធម៌វិន័យ ខំធ្វើវត្តបដិបត្តិដល់គ្រូអាចារ្យខំចំរើនសមណធម៌ គឺសមថកម្មដ្ឋាន ឬវិបស្សនាកម្មដ្ឋាន បើនៅក្នុងបឋមវ័យរវល់នឹងកិច្ចសិក្សា នឹងកិច្ចធ្វើវត្តបដិបត្តិដល់គ្រូអាចារ្យ មិនបានធ្វើសមណធម៌ ត្រូវខំធ្វើក្នុងមជ្ឈិមវ័យ បើនៅក្នុងមជ្ឈិមវ័យរវល់នឹងវិនិច្ឆ័យសេចក្តីធម៌វិន័យឬអដ្ឋកថា នឹងការបង្រៀន មិនបានធ្វើសមណធម៌ទេ ត្រូវលះបង់សម្រាកកិច្ច

ទាំងនោះបញ្ចូលក្នុងបច្ចិមវ័យ ដើម្បីយកឱកាសធ្វើសមណធម៌ឲ្យពេញលេញបរិបូណ៌ ដូច្នេះទើបបានឈ្មោះថារក្សាខ្លួនដោយប្រពៃ ។

ទាំងគ្រហស្ថទាំងអ្នកបួស បើមិនធ្វើដូច្នេះហើយឈ្មោះថាមិនស្រឡាញ់ខ្លួនឡើយ មិនបានរក្សាខ្លួនដោយប្រពៃឡើយ ឈ្មោះថាធ្វើខ្លួនឲ្យមានមុខសំយុងចុះទៅកាន់អបាយ ។

ហេតុដូច្នោះសប្បុរសទាំងឡាយអ្នកស្វែងរកវត្ថុជាទីពឹង ត្រូវទីពឹងលើខ្លួនឯងឲ្យមាំ ទើបសម្រេចប្រយោជន៍បាន បើជ្រាបច្បាស់ថាខ្លួនជាទីពឹងរបស់ខ្លួនដូច្នេះហើយ ត្រូវស្រឡាញ់ខ្លួននោះឲ្យមែន បើស្រឡាញ់ខ្លួនហើយ ត្រូវរក្សាខ្លួននោះឲ្យល្អ ដូចសេចក្តីអធិប្បាយនេះចុះ ។

ខេមាខេមសរណគមនកថា ចប់

## មួយរយហាសិបមួយថ្ងៃ

# គៅមាត់ឈូងសមុទ្រសៀម

ពាក្យកាព្យរបស់ជីគិះហាក់ ក្នុងក្រសួងបុស្តិ៍ខ្សែលួស ភ្នំពេញ

---

សេចក្ដីប្រាសចាកនិរាសមិត្ត     របស់គាប់ចិត្តជិតអាត្មា
មួលហើយខ្ចាត់ទៅឆ្ងាយឱ៉ា  អ្នកណាបង់វែះបៀសពុំបាន ។
អស់ដើមព្រឹក្សរុក្ខជាតិ  ផ្លែទុំជ្រុសខ្ចាតព្រាត់ពីប្រាណ  ធ្លាក់
ដាក់ដល់ដីធរណីឋាន  មិនយូរប៉ុន្មានសត្វពាំបាត់ ។ មាតា
ប្រលោមបុត្រឆោមឆៅ  មិនឲ្យហ្មងសៅបន្តិចក្ដាត់  ដល់កូន
ធំឡើងកម្មមកកាត់  វាយផាត់ខ្ចាត់ប្រាណឆ្ងាយកាយ៉ា  ។
ដូនកាលមរណមកស្ទាក់ទាន់  កូនស្លាប់រួសរាន់ចោលមាតា
ដូនកាលឪម្ដាយក្លាយអាសារ  ស្លាប់ចោលបុត្រាវិញក៏មាន ។
ទះទកងកម្មសត្វលោក  ដាំដោកជ្រោកជ្រាកជ្រែកសន្ដាន  នាំ
សត្វទុក្ខក្ដាត់ទាំងបីឋាន  ពុំមានសម្រាន្តក្សាន្តចិត្ដា ។ ដូន
ស្លាប់ដូនឈឺព្រឹអស់ខន្ធ  រន្ធាន់ដាក់ស្បាន់ដល់សំខារ  សង្រែង
សង្រែអាល័យផ្សារ  សុខាកម្រក៏កុំយូរ ។ មិនតែរូបមនុស្ស

មានឈាមសាច់ រូបដែលសម្រេចនឹងគំនូ ឬធ្វើដោយថ្មផាង
ធ្លាក់គូ មិនយូរគង់ខូចវិនាសបង់ ។ ព្រះពុទ្ធហោមពង្សវង្ស
សាក្យ ហោមបក្រគង់មរណាជម្រង់ ញាំញីសារព្វាង្គរាងព្រះ
អង្គ យាងត្រង់ចូលកាន់និព្វានឆាយ ។ ជនជាតិបណ្ឌិត
ពិតប្រាកដ ត្រូវបេះមត់បត់កុំរាយមាយ ឧស្សាហ៍គិតស្លាប់
ខន្ធធ្លុះធ្លាយ រោយរាយសាច់ឆ្អឹងជាធរណី ។ ញើសឈាម
ប្រែភ្លាមទៅជាទឹក ព្រួឡឹកៗក្នុងដលធី កើតស្លាប់ក្រឡាប់
លើប្រថពី គ្មានទីគរអាប់រៀបពុំបាន ។ បើមានសទ្ធាមហា
មុតមាំ តោងទ្រាំទ្រែបមកមើលឋាន ទឹកក្នុងសមុទ្ទទើបស្តួត
ប្រាណ ទីនេះបំណាច់គ្មានអ្វីស្មើ ។ ដួងចិត្តនិតមូលរាងក្រ
ឡង់ មុនោពុំវៀរបង់ពុំសើរើ ពិចារណាធម៌ល្អិតប្រសើរ រិះ
រកដំណើរកាន់និព្វាន ។ ដាក់មើលឃើញផ្ទះក្បែរជើងភ្នំ គ្រឹ-
ហាទ្រនំរបស់ព្រាន ព្រៃបបាញ់សត្វបំបាត់ឃ្លាន នាំមានគិត
ភិតដល់អាត្មា ។ ឋាទខ្លួនអើយឡើយអ្វីម្លេះ មកនៅក្រអែស
ដោយអារញ្ញា ជិតជើងគិរីទីបព្វតា ឯកាឯកោជ្រិដោកាយ ។
មកខំយ៉ាងនឹងប្រឹងយ៉ាងនេះ ពុំឃើញវិសេសបានសប្បាយ

ឲ្យមានល្អលើសផងទាំងឡាយ   នឹកទៅគួរណាយស្តាយ
កម្លាំង ។  មិនគួរមកបាប់អម្រិតា  ឲ្យគ្នាវេទនាភ័យខ្លាំង
រហូតដល់ក្បៀយអង្គជីវ៉ង  បាបតាំងញាំងខ្លួនធ្លាក់នរក ។ បើក
ភ្នែកជ្រែកមើលឃើញសមុទ្រ  រន្ធត់ស្លុតពោះក្បូត្រឹកត្រក  ហ-
ទ័យាព្រឺព្រួលជ្រួលកលិយុគ  រីរក់រីរវខ្វរខ៉ា ។  ហ៊ាមើលល-
លកបោកធំ ៗ  លាន់ឮគ្រុំ ៗ ជុំអាត្មា  បង្អើលអស់ហ្វូងសត្វ
មច្ឆា  លោតឆ្លាផ្លោព្រាតពីគង្គា ។  លលកធំស្មើប៉ុនគិរី  ព្រះ
ពាយវាត់វីលោតក្រទា  បែកជាផ្កាត្រែងស្វែងមុះហិមា  បោក
បែកលើគ្នាឮពេកក្រៃ ។  ពីព្រឹកទាល់ល្ងាចក្រស្កប់ស្កល់
លោតតាមដោយខ្យល់ឥតសំបៃ  ត្រង់នេះត្រូវយើងគិតកែខៃ
វៃឆ្នៃគិតដល់អង្គរូបា ។  វាយោធៀបដូចមច្ឆរាជ  កបកើត
អំណាចស្វាបបេស្តា  គង្គាតោងលើកឡើងឧប្បមា  បីដូចសំ-
ពារយើងរាល់គ្នា ។  បើស្តេចមច្ឆរាជឃោឃៅ  ដំរូវយកសំ-
ពារជន្មា  សំពារត្រូវទៅតាមទ័យា  ឥតអ្វីរាំងពារាពុំបាន ។
ហ៊ាមើលសំពៅមានក្តោងប្តូន  ត្រូវខ្យល់រំងធ្លួនលឿនបំណាន
ទ្រោបផ្តោះរកស្រុកទំនំឋាន  កុំពង់បតហ្កានសំរានសុខ ។ សំ

ពៅប្រៀបដូចលោកអរិយ វាយោគោងដាក់ដូចជាទុក្ខ ឯ
ត្រើយប្រៀបដូចនិព្វានមុខ ទីសុខថ្កើងឋានក្សាន្តភិរម្យ ។
ឯពួកអរិយបុគ្គល មិនបង់វិលវល់ក្នុងទុក្ខធំ លោកប្រឹង
សង្វាតទីសុខ គ្មានយំគ្មានយែកគឺនិព្វាន ។ បីដូចសំពៅ
ត្រូវខ្យល់ក្តោង ខំប្រឹងចំកោងត្រែបរុករាន ទន្ទេងទន្ទាំពិតពុំ
មាន វិះធ្យានបង្អង់ត្រង់ទីណា ។ ឲ្យឆាប់បានដល់យល់
កោះត្រើយ ឲ្យទុក្ខបានស្បើយល្ហើយចិត្ត បានឈប់នែបឯប
កុំពង់រ៉ា កំសាន្តកាយាសោះនឿយហត់ ។ ហ្នុំមើលភ្នំជុំក្នុង
សមុទ្រ កំពូលខ្ពៀងផុតទឹកប្រាកដ គឺទីនោះហើយមនុស្ស
សន្មតិ កំណត់ហៅកោះតាមភាសា ។ ខ្លះធំខ្លះតូចដូចមេកូន
ដូចៈបាដីតួនជិតគ្នាវា ខាងលើជុះសុទ្ធដើមព្រឹក្សា គ្មានម-
នុស្សឯណាមួយទៅនៅ ។ យូរៗ ឮសូរម្រឹគធំ ស្រែកយំ
រងំខ្ទរក្នុងទីជ្រៅ សត្វខ្លាពុះមកជិតកោះក្បូរ ជាត់ធំស្រមូវគួរព្រឺ
ខ្លាច ។ នៅកោះស្រណោះពន់ពេកក្តាត់ ឮតែមាត់សត្វលាន់
បិញ្ចាប ឮសូរលលកហោកបាបសាប នាក់តាកាបៗច្រើន
ណាស់ព្វា ។ ព្រះយោគាវចរគប្បីណាស់ ស្វែងស្វាស់ទៅនៅ

ពិចារណា ឲ្យបានតុបតីនត្រៃយលក្ខណា ទុក្ខំអនិច្ចាអនត្តា
ពេក ៗ មើលកោះឃ្លរទៅនាំឲ្យគិត រំងរិតតែមានក្តីវិវេក
មិនបង់បានទេក្តីជំម្រែក ឃ្លានស្រែកដេកក្នុងវិត្តសង្ហារ ។
បង់ងាកភៀសប្រាណរកទីសុខ ឲ្យបានស្រណុកគ្មានកោលា
ហលផ្តល់ស្ងប់ស្ងាត់បាត់ទុក្ខា រោគាឈឺផ្សាវិនាសងាប់ ។
នេត្រាបង្អោនកោនទៅក្រោម យល់ឃើញបំណោមនៅលើ
ខ្សាប់ មានសុខ្ទសំបកខ្យងខ្មៅស្រេច លលកវាយដេចបែក
ខ្ទេចខ្ទី ។ អណ្តែតមកលើឆ្នេសាគរ កើតជាគំនរលើប្របឋពី
ច្រើនបែបច្រើនផុនច្រើនដល់ទី ពេញពាសធរណីសព្រោត
ព្រោង ។ មានលៀសងារគ្រិជស់ក្រមុំ ខ្យងស័ង្ខធំ ៗ ស
ឆ្មោង ៗ ខ្យងខ្លះមានសុខ្ទបន្លាប្រូង ច្រើនពួកច្រើនហ្វូងក្រ
ពណ៌នា ។ ជួនកាលជួបឃើញសំបកលៀស ធំក្រាសខ
ភាសធ្ងន់មុះហិមា លើកយួរដៃមួយស្ទួយរញរា លើកហើយ
ស្មើផ្កាក្រឡាប់ខ្លួន ។ មានខ្យងដូចក្រពុំម្រាមដៃ រួមជិតគ្នា
វៃល្អមាំមួន នៅក្នុងទឹកជ្រៅឆ្ងាយសំសួន បំនួនមួយពាន់
ម៉ែត្រឆ្ងាយដាក់ ។ ឃើញខ្យងនេះហើយស្រេចកាលណា នឹក

ដល់មនុស្សាបិត្តាសាម័គ្រ ឧស្សាហ៍លើកកំបង់ដៃដាក់ ស្មោះ
សាម័គ្របង្គំរតនត្រ័យ ។ ឃើញសំបកខ្ចងលៀសបៀផង
ចិត្តសែនមួហ្មងពន់ពេកក្រៃ ឋាឧជីវិតសត្វអសង្ខៃយ មកក្បួយ
ប្រលែងជន្មជីវ៉ា ។ នៅតែសំបកសកសសុទ្ធ នាំឲ្យរន្ធត់ដល់
រូបា រូបំខ្ទួនអើយវេលាណា ស្លាប់ផ្អឹងមង្សាទៅជាដី ។ ឯ
មនុស្សឯទៀតឃើញឆ្អឹងឃើង សិងរត់បាតជើងសព្រាតខ្មី
ខ្លាចលងខ្លាចលេងមិនគប្បី ស្លាប់ហើយគ្មានអ្វីប្រយោជន៍
សោះ ។ ឯសំបកខ្ចងក្នុងសមុទ្រ មនុស្សខំផ្គង់ផ្គត់ប្រឹងរឹង
អស់ ខ្លួនព្រាណបង់បានផ្ញើរបស់ ល្អស្រួលយ៉ាងស្រស់ទុក
រក្សា ។ តាំងលើតុលេងសោះអផ្សុក ដូចកុកឃើញត្រីជា
អាហារ ប្រឹងខំស្ទុះចឹកជឹកមច្ឆា លេបទាំងមូលណាគ្មានរឯង ។
ដល់សាយណ្ហោទន់ទេទៅ សូរិយាធ្លាក់ជ្រៅចូលកន្លែង ជើង
មេឃបច្ចិមទិសដាក់ស្តែង នាំឲ្យបម្លែងក្រែងណាស់ណា ។ ឲព្រះ
អាទិត្យរិទ្ធិពេកពន់ អ្នកចូលក្នុងរន្ធទៅទីណា ព្រះសូរិយាអើយ
ៗសូរិយា កាលណាអ្នកមករកយើងវិញ ។ អ្នកទៅចោល
យើងឲ្យរង់ទុក្ខ គ្មានសុខងងឹតសែនទោម្នេញ ស្ងាត់ជ្រៀប

គិតហើយសែនតឿយផ្រៀញ ពាសពេញនៅក្នុងទ្រូងខ្លោច ផ្សា ។ ងងឹតងងល់អំពល់គ្រប់ ក្នុងរាត្រីយប់សែនកោលាហលផ្តល់ផ្តេកផ្តាប់ដាប់តរុខា ឲព្រះសូរិយាម្ចាស់យើងអើយ ។ តាំងពីវេលានាទេះទៅ យើងនៅដេកធ្មេបស្មៀមកន្តើយ បើមានរាយោដាត់ស្តើយៗ ម្ចាស់អើយសែនស្រួលនិទ្រាណាស់ ។ មើលទៅទិសខាងលិចទៀងដាក់ ឃើញពន្លឺអ្នកពុំត្រចះ ប៉ែតងក្រហមលឿងពុំច្បាស់ ថៃមទាំងរហាស់ស្អាប់ស្អាបាត់ ។ ដូចជាព្រះពុទ្ធចៅចោមពង្ស កាលទ្រង់គង់ធម្មាប្រោសសត្វ សាសនារុងរឿងល្អប្រពៃ៉ត់ ពុំមានវិបត្តិត្រង់រឿងណា ។ ប្រៀប ដូចព្រះអាទិត្យកណ្តាលមេឃ រស្មីភ្លឺពេកហួសបើហា បង្កៀង ភ្លើងគប់អម្បាលណា យកមកឧបមាធ្វើម្តេចបាន ។ ដល់ព្រះអរហំអង្គសម្ពុទ្ធ សុគតបំហុតកាន់និព្វាន ធម៌និងវិន័យពុំរឹងប្តាន ពុំបានបំណានបំណាប់សោះ ។ ដូចជាសូរិយា យាត្រាត្រង់ ចូលវន្ទបាត់អង្គគួរស្រណោះ នៅតែពន្លឺភ្លឺពុំ ច្បាស់ ក្សាយរសាយអស់បាត់វិញវ៉ា ។ នេះបំដូចជាពាក្យ ប្រដៅ ព្រះពុទ្ធចោមចៅពីសាសនា ដល់ទ្រង់និព្វានទៅកាល-

ណា សាសនាកម្រល្អដូចដើម ។ គិតហើយគិតទៀតបង្អៀត
ខ្វល់ ស្មើនឹងដាច់ខ្យល់ប្រាសដង្ហើម ស្ងួតពោះវៀនទាបបេះ
ដួងថ្លើម រលួយគួរឆ្អើមវិទ្ធសង្សារ ។ ពេលយប់ឈប់លេង
ក្បែរសាគរ ខ្យល់បក់រឹករះលើជលសា បើជិះលើទូកឬភេត្រា
សែនកើតអនិច្ចាយ៉ាងមាំងខាំង ។ ទូកលោតលលកសង្បក
សល់ វាយោធាត់ដល់ឮក្តាំង ។ ព្រាយបែកជាពន្លឺភ្លឺខ្លាំង
វែងភាំងតាំងភិតគិតគណាថា ។ ឱព្រះពាយផាយផាត់អ្វីម្លេះ
យើងស្មើរបេះធ្លាក់ជលសា រលាយជីវិតបែកសំខារ ឱលោក
មេត្តាជួយយើងផង ។ ជួនមានត្រីធ្លាមដេញតាមទូក ផ្អើល
ជ្រួលស្មើរភ្ញាក់ចូលទឹកផ្គង ធ្លាមដេញប្រកិតបិត្តទ្រើសឃ្នង ទំ
ឥងយកយើងជាអាហារ ។ បើទូកធ្លាយលិចក្នុងសាគរ សម
យើងនឹងវិរម្តងនេះណា ដូចព្រះពោធិសត្វមហា ជនកអស្ចារ្យ
សាស្តាថ្លៃ ។ លោកហែលក្នុងទឹកសន្ធឹកសល់ កម្មមកតាម
ផ្តល់ច្រើនខែថ្ងៃ ប៉ុន្តែបានព្រះឥន្ទ្រកោសៃ កែខែជួយស្រង់ឲ្យ
រួចបាន ។ តែលោកអំបូរពោធិសត្វ គេរត្តនាមគ្មានបាត់
ធម៌ពីប្រាណ ឯយើងជាតិមនុស្សលោកសាម៉ាន កាលណា

នឹងបានជួបព្រះអង្គ ។ នៅក្នុងសមុទ្រគិតមុតដល់ មនុស្ស
ទាំងសាកលដែលប្រាសបង់ លិចលង់ស្លាប់បាត់ខ្លួនបុះត្រង់
ជំរង់ទៅនៅបាតសាគរ ។ តាំងពីកើតទឹកនឹងកើតដី មនុស្សក្នុង
លោកីយ៍ច្រើនគំនរ ធ្លាយទូកសំពៅនៅនាវា មរណាកុះគរក្នុង
សមុទ្រ ។ ឆ្អឹងសាច់ដាច់ដាបទៅជាដី ឈាមខ្សុសក្លាយខ្ទឹក
បំហុត នាំបម្រើនគង្គាសមុទ្រ ឲ្យរិតជ្រៅសុទ្ធផុតនាំពា ។
អស់ប្រពន្ធកូនញាតិកា ឮហាប្តីមកស្លាប់មរណា នាំកូនយំ
យែកបោកអង្គា សន្លប់ជន្មាលើត្រើយជ្រាំង ។ ទឹកភ្នែកហូរ
បែកញែកបែកបេញ ពាសពេញសមុទ្រជាទីតាំង ទទួលទឹក
នេត្រវិយោគខ្លាំង ឲ្យសែនអនិច្ចំដល់រូបា ។ កើតជាសត្វធ្វើ
ម្តេចបានសុខ ដេកដើរជាទុក្ខព្រោះសង្សារ នាំឲ្យសង្ស័យអា-
ល័យផ្សារ កាលណាបាត់សោកអាមោក្ខទេ ។ ទឹកភ្នែក
មនុស្សម្នាក់ដាក់ប្រមូល បញ្ចូលកើតបានជាទន្លេ ជាសមុទ្រ
ធំកុំគ្នាន់គ្នេ នេះហើយវាវេយើងរាល់គ្នា ។ ទុក្ខអើយទុក្ខ
តាំងអំពីកើត យោនយកកំណើត ១ ទិវា នៅក្នុងពោះម្តាយ
សោយវេទនា ច្រើនដងច្រើនគ្រាជួនកាលក្ស័យ ។ បាន

ឃើញពន្លឺព្រះអាទិត្យ ទុក្ខារំងរិតមកទៀតរៃ បៀតបៀនជានិច្ច ជាកាលនៃ គឹតហើយកើតភ័យញ័រកាយា ។ ប្ដីស្លាប់ប្រពន្ធ ទ្រន់ពេក ដូចជាសត្វសោកឥតឱល្ហ គ្មានផ្លែឈើមកជាអាហារ ក្នុងទ្រុងអួលផ្សារដោយអាល័យ ។ មាតាស្លាប់កូនស្ងួណ្យព្រលឹង គ្មានអ្វីទីពឹងឲ្យសុខសៃ យំយែកស្រែកទ្រួញគ្រួញសង្រៃ ប្រលិមទិមថ្ងៃចូលរន្ធណា ។ ប្រពន្ធស្លាប់ប្ដីសេចក្ដីក្រ ស្ទើរស្ទុះបាក់កណ្ឌាអង្គអាត្មា ឲ្យស្លាប់ទៅជាមួយសង្សារ សោះ រងទុក្ខាបែបដូច្នឹង ។ កូនស្លាប់មាតាមហាគាប់ចិត្ត ទុក្ខធំពិតឱរ៉ាតឹង អង្គុយត្រមោចស្ងាបត្រមឹង មិនដឹងរត់រកយកអ្នកណា ។ មកជួយថែថ្នួនខ្លួនឲ្យស្រួល ជំនួលសណ្ឋានដូចមាតា មិនបានម្ដងសោះទេឡើយណា ឧរិដ្ឋសង្សារលោកានេះ ។ ទុក្ខអ្វីទុក្ខម្លេះមិនបេះឈប់ ទុក្ខមានស៊ុះសព្វគ្រប់ប្រទេស គង់ពួកបណ្ឌិតមានជម្រែះ ក្របេះការពារខ្លួនឲ្យបាន ។ ហេតុនេះបុគ្គលស្រឡាញ់សុខ បង់បានស្រណុកស្រស់កល្យាណ គប្បីរិះរកទីបំណាច ធ្វើធម្មកម្មដ្ឋានឲ្យបាន

ថ្មី ។ ឯទីត្រូវត្រែបនោះណា គួរខំយាត្រារកទីព្រៃ រហោឋានស្ងាត់បាត់សំដី ស្ងួរសៀងអ្វីៗគួរណាស់ព្វា ។ ឬមួយមកនៅឆ្នេសមុទ្រ នាំឲ្យបរិត្តល្អុសុទ្ធសជ្រះថ្លា នៅជិតទឹកប្រែកើតប្រាជ្ញា ដូចបណ្ណាស្រ្តអើរុពនាយ ។ ធ្វើអស់កសិណ ១០ ប្រការ អសុភក្តីណាកើតបានងាយ ផុវកាន់និញានរិតទូលាយ សូមជនស្វាធ្យាយគិតគួអើយ ។ ៚—

ចប់តែប៉ុណ្ណេះ

# រឿងមហាភារតយុទ្ធ

ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិតនៅព្រះរាជបណ្ណាល័យ

## ប្រែចេញមកពីភាសាសៀម

(តរ-ចប់)

ភាគដប់ប្រាំមួយ

## ទៀបបំផុតនៃការសង្គ្រាម

ការសង្គ្រាមក្នុងកាលឥឡូវនេះ ជិតនឹងដល់ទីបំផុតហើយ ព្រោះទោណជាមេទ័ពធំ នឹងកណ៌ទាហ៊ានសំខាន់ដល់នៅមរណៈក្នុងវារនេះ ការសង្គ្រាមគ្រានេះធ្វើយ៉ាងសាហាវបំផុត ផលដែលកើតអំពីការសាហាវនេះ គឺក្បាលទាហ៊ានត្រូវអាវុធដាច់ធ្លាក់អំពីខ្លួន ទោរមៀលដោយដី សពទាហ៊ានដែលត្រូវអាវុធស្លាប់ក្រផេះក្រផោះ ដេកកើយគងលើគ្នាត្រៀបត្រា សពសត្វពាហនៈដែលត្រូវធ្នូ ឬលំពែងពួយនឹងត្រូវរបិកិន ក៏-ហើមបង្គ្រឹងបង្ក្រាងពាសទាំងស្នាមយុទ្ធ សំឡេងទ្រហោយំ សំឡេងថ្ងូរ មុខគួរសំវេគវេទនា សំឡេងអឹងអាស់កោលាហល

សំឡេងពោលព្យាបាទគំគួន នឹងសំឡេងសំរួលហោហាដោយមានជ័យ ។

ថ្ងៃព្រឹកឡើង តអំពីថ្ងៃមរណៈនៃព្រះរាជាទ្រុបទ ធ្ឫស្ដទ្យុម័នឱរសរបស់ព្រះអង្គបេញទៅស្វែងរកខ្លួនអ្នកសម្លាប់ព្រះបិតាតាំងចិត្តនឹងសម្លាប់ឲ្យស្លាប់ទៅតាមគ្នាទាល់តែបាន មិនជូប្រោះទេ ក៏សូលះជីវិតរបស់ខ្លួនក្នុងការព្យាយាមនោះ លុះភីមឃើញធ្ឫស្ដទ្យុម័នកំលោះតូច នឹងបេញទៅច្បាំងដោយប៉ុណាង្គជូប្រេះគេក៏ចាប់ដៃហើយនិយាយថា "ទ្រង់ះនៅក្មេងណាស់ដែលនឹងធ្វើការសងសឹកៈទោណអ្នកក្បៀវក្លា ដើម្បីកែកំហឹងរឿងមរណៈនៃព្រះរាជបិតា ឃើញពុំល្អះគួរការ ទាហ៊ានចាស់នោះជាអាហារដ៏រឹងស្វិត មិនជាគួគួរនឹងធ្មេញទន់ៗ របស់ទ្រង់ដែលនឹងគប្បីទំពារឲ្យល្អិតលេបទៅបាន ទុកឲ្យខ្ញុំវិញ ខ្ញុំនឹងច្បាំងជំនួសទ្រង់ ខ្ញុំនឹងសងសឹករឿងមរណៈនៃព្រះរាជបិតារបស់ទ្រង់ ។

ប្រានក្សត្រិយ៍កំលោះនោះថយក្រោយបេញទៅ ភីមក៏លោតចូលទៅៈកៈទោណ អ្នកបំបាំងទាំងពីរបានធ្វើការតស៊ូគ្នាយ៉ាងល្អមើល គ្មានអ្នកណាចាញ់ប្រៀបអ្នកណា លុះមរាយ

វាត់គ្នាទាំងពីរគ្មានឋិយក្រោយដល់មួយដំកោន តែភីមសូម្បី
មានកំលាំងមុះហិមាដូច្នោះក្តី ក៏នៅមិនគួគួរដល់សេចក្តីស្ទាត់
ប្រសប់របស់ព្រាហ្មណាចារ្យ

ក្រិស្ណឃើញផលប្រយោជន៍ក្នុងការច្បាំង អាស្រ័យតែ
កំលាំងសំពងគ្នាមួយយ៉ាង, ទ្រង់ទើបណែនាំយុធិស្ឋិរឲ្យប្រើវិធី
កល់យុទ្ធជំនួសកំលាំងទាហាន យុធិស្ឋិរមុនដំបូងមិនពេញ
ព្រះហទ័យនឹងប្រើវិធីឧបាយកល់ ដែលទ្រង់ជឿថាជាឧបាយ
កល់កោងយ៉ាងអាក្រក់ ព្រះហទ័យរបស់ទ្រង់ប្រកបដោយមេត្តា
មិនព្រមប្រើវិធីកលយុទ្ធ ដែលបរិយាទាហានជាន់ខ្ពស់អនុញ្ញាត
ឲ្យប្រើហើយ តែទីប្រឹក្សារបស់ទ្រង់ទូលពន្យល់ថា ត្រូវតែធ្វើ
សង្សឹកសត្រូវដោយវិធីយ៉ាងនេះទើបសមគ្នា ព្រោះសត្រូវរបស់
យើងគេអាស្រ័យតែឧបាយកោង នឹងអសច្ច ជាសរណមក
ហើយ, ហើយថា «បើទ្រង់មិនសព្វព្រះហ្ឫទ័យក្នុងការដែលគ្រាន់
តែធ្វើសង្សឹកសត្រូវក្នុងសង្គ្រាមសោត, ទ្រង់នឹងធ្វើសង្គ្រាម
សោះអី ? ម្តេចក៏មិនលើកលែងច្បាំងគ្នាចេញ, ដោយព្រមចុះ
ចាញ់ក្នុងកណ្តាប់ដៃទុរយោធន៍ទៅ ? ទ្រង់ភ្លេចសំណាមចាស់

ដែលគេធ្វើដល់ទ្រង់ហើយឬ ? រឿងលេងស្ការបង្កប់ជាតុឲ្យធ្ងន់, រឿងតិរទេស, រឿងប្រមាទមើលងាយទ្រោបទី »

កាលរឭកដល់រឿងទាស់ទែងគ្នា ក្នុងកាលមុនឡើងមកក៏ព្រឺតក្នុងព្រះហឫទ័យ ទ្រង់រំពឹងដល់រឿងឈឺចិត្តនោះ ព្រះនេត្ររលង់ដោយអស្សុជល ព្រះភក្ត្រជ្រប់ស្ញៀម ការជ្រប់ស្ញៀមនោះបានសេចក្ដីថា ទ្រង់យល់ព្រមនឹងប្រើវិធីកលយុទ្ធនោះ តែពួកបណ្ឌិតអំបាលនោះតាំងចិត្តនឹងប្រើវិធីដែលប្រាសចាកទោសមន្ទិលហ្មងហ្មង កំរ៉ាបទោណអ្នកក្លៀវក្លាខ្លាំងពូកែនោះបេញ.

គ្រានោះ ភីមបានពិឃាតយុទ្ធហស្តិនមួយ ដ៏មានឈ្មោះថា អស្វត្ថាម៉ន ប្រើឧបាយស្រែកតៗគ្នាទៅទាំងស្នាមយុទ្ធថា សឹកសម្លាប់អស្វត្ថាម៉នងាប់ទៅហើយ ពួកកុរុឮដូច្នោះក៏ចូលចិត្តថា សឹកសម្លាប់អស្វត្ថាម៉នបុត្រសំឡេញតែមួយរបស់ទោណ ( ដែលមានឈ្មោះដូចគ្នានឹងដំរីសឹក ) ដោយហេតុអឺកធឹកច្រួលច្របល់ខ្លាំងណាស់ អ្នកចាំស្ដាប់រាយការ មិនអាចនឹងស្ដាប់ឲ្យបានសេចក្ដីដោយច្បាស់លាស់ អ្នកស្ដាប់តៗមកតោងរាយសេចក្ដីផ្សំ តែផ្សំមិនត្រូវក៏តោងចូលចិត្តជ្រួសទៅ

ក្សត្រិយ៍អង្គខ្ទះក៏ទៅរកទោណ ដើម្បីសម្ដែងសេចក្ដីទោមនស្ស តូចចិត្តផង ដំណឹងនោះធ្វើឲ្យទោណធ្លាក់ចិត្ត សឹងមិនចង់ជឿត្រចៀករបស់ខ្លួន ទោណក៏មកឯបន្ទាយបាណ្ឌព ដោយដៃទទេមិនកាន់អាវុធដើម្បីនឹងដឹងសេចក្ដីពិតអំពីយុធិស្ឋិរ ដែលជាអ្នកធ្លាប់ពោលតែពាក្យពិតតែមួយយ៉ាង. បូរត្រាស់មកមើល យុធិស្ឋិរ, ទ្រង់ជាអ្នកពោលតែពាក្យពិតមកតាំងអំពីកាលណាមកហើយ, អស្វត្ថាម៉ន បុត្រដ៏ក្លារបស់ខ្ញុំត្រូវអាវុធស្លាប់ក្នុងទីចំបាំងឬ យុធិស្ឋិរបានបានឮពាក្យបុច្ឆានេះ ឲ្យទាល់គំនិតមិនដឹងបើនឹងអភិប្រាយយ៉ាងម្ដេច គឺប្រការ ១ ទ្រង់តោងពោលតែពាក្យពិតគ្រប់ប្រការ, ប្រការ ១ ទៀត ទ្រង់តោងរក្សារដ្ឋបសាសនោបាយ នឹងផ្លូវរាជការ ត្រូវបិទបាំងសេចក្ដីពិតនេះទុក ទ្រង់តោងរកឧបាយគិតដើរផ្លូវកណ្ដាលរវាងសេចក្ដីពិតនឹងសេចក្ដីកុហក មិនឲ្យខូចការរាជការ អាស្រ័យជាផ្លូវចៀសមិនបាច់ឲ្យពោលសេចក្ដីពិត ទើបត្រាស់ថា "អស្វត្ថាម៉ន ងាប់ទៅហើយ, ខ្ញុំពោលនេះសំដៅដំរីអ្នក" ពាក្យបន្ទាប់បន្សំក្លី ៗ តប្រយោគក្រោយនេះ ទ្រង់ត្រាស់ដោយព្រះ

ស្នូរសៀងស្រាលជាបំផុត ស្រាលទាល់តែមិនដឹងខ្លួន ឬមិនឮដោយត្រចៀករបស់ខ្លួន ទោណស្ដាប់បានតែពាក្យខាងដើម ព្រោះវេលានោះទោណកំពុងកង្វល់ធំ

មិនបង្អង់ជជែកតទៅឡើយសោះការ ទោណាចារ្យក៏ត្រឡប់ទៅកាន់ទីបំបាំងនៃខ្លួនវិញ មានប្រារព្ធតែក្នុងចិត្តរបស់គាត់បាត់មាត់បាត់ករស្ងាត់ស្ងៀម ចិត្តរបស់គាត់ថយកំលាំងចុះឥន្ទ្រីយ៍ទាំងឡាយមិនកំរើកហើយ បង្អង់ចាំតែមរណានឹងមកដល់ប៉ុណ្ណោះ ធ្ឫស្ដទ្យុម័នប្រុងប្រៀបជានិច្ច ចាំតែបានឱកាសនឹងសងសឹកវិញ ទ្រង់ចាំបានថា ទោណជាអ្នកសម្លាប់បិតារបស់ទ្រង់ ទោះបើភីមមិនអនុញ្ញាតឲ្យបេញតស៊ូដោយពេញមុខក្ដី ក៏នៅតែខ្វល់ខ្វាយរកឱកាសនឹងសងសឹកមរណានៃព្រះរាជបិតាវិញជានិច្ច វេលានេះជាឱកាសរបស់គេហើយ ដ្បិតទោណទ្រមអន់ ស្រពន់ស្រពោនមិនក្លាហានដូចកាលដែលកន្លងមកហើយ វេលានេះគាត់គ្រាន់តែមានកិរិយាឫកពាជាមនុស្សចាស់សំណាំសំនួនប៉ុណ្ណោះ ហេតុនោះខ្លួនគាត់វេលានេះទៅជារង់សំរាប់ឲ្យធ្ឫស្ដទ្យុម័នប្រហារបង់ដោយងាយ ៗ តអំពីនោះ

មួយស្របក់ទៅណាក៏ត្រូវសរដែលធ្លាក់ទម្លុះមិនប្លែងទៅអំពីបម្រាយ ស្លាប់កណ្ដាលសង្គ្រាមយុទ្ធ

វេលានេះកងទ័ពកុរុទាំងនេះគ្មានអ្នកនាំទ័ព ភីស្មដេកលើធនូបិដ្ឋ រង់ចាំមរណៈនឹងមកដល់ ឯទ្រោណក៏ដួលដេកខ្សល់ស្លាប់ក្នុងថ្ងៃនេះទៅហើយ. ខ្លះអ្នកធំនឹងធ្វើការដំណែងជាមេទ័ពតទៅ ហេតុដូច្នោះ ទុរយោធន៍ទើបស្ដេចប្រញាប់ទៅរកកណ៌ អ្នកសំណប់គាប់មកអំពីដើម ត្រាស់ថា "កណ៌វេលានេះអ្នកឯងបុណ្ណឹង ដែលអាចនឹងជួយកុរុទុកបាន ដោយថ្វីដៃដ៏ល្បីរបស់អ្នក ភីស្មជាអ្នកបំបាំងឯករកទីប្រៀបគ្មានជាប្រាកដ តែសេចក្ដីលំអៀងកំបាំងខាងក្នុង ក្នុងពួកបាណ្ឌពនោះ ធ្វើឲ្យដៃរបស់គេទន់ក្នុងការតស៊ូ ទ្រោណសោតក៏ជាអ្នកពូកែធ្វើតរកទីប្រៀបគ្មានដែរ តែសេចក្ដីស្រឡាញ់ក្នុងបាណ្ឌពជាកូនសិស្សសិងត្រាំនៅក្នុងសន្ដានយូរមកហើយ វាមកធ្វើសេចក្ដីក្លាហានរបស់គេឲ្យថយចុះ ។ កណ៌ ចំណែកអ្នកឯង គ្មានខ្វះកន្លះត្រង់ណាក្នុងរឿងនេះ ប្ដូរនាំទ័ពរបស់យើងចូលឯយសត្រូវឲ្យខ្ចាប

ទៅ នាមរបស់អ្នកនឹងល្បីល្បាញតទៅរហូតដល់កូនចៅជាង ក្រោយថា អ្នកជាទាហានក្មេងដ៏ក្លាបំផុត.

កណាំតបដោយសុភាពថា "ទូលបង្គំណានឹងទទួលធ្វើការមុខងារទូលបង្គំ ដោយសត្យស្មោះត្រង់ដល់ព្រះមហាក្សត្រិយ៍ និងស្រុកទេសរបស់ទូលបង្គំ

កណាំមានភក្តីដ៏ប្រប្រីមក្នុងដំណែងកិត្តិយសដែរបានទទួលថ្មី, បររបសឹកគក្រឹកចូលទៅពុះពាកណ្តាលកងទាត់ ឃាណ្ឌពដោយរួសរាន់ មរណានឹងសេចក្តីព្រឺបានចូលគ្របក្រុមយរត្តមនុស្សទាំងស្នាមយុទ្ធ សេចក្តីបំណងដ៏ធំរបស់ កណាំក៏គឺនឹងចាក់បេះដូងអរជុនដោយសរ, បំណែកឯសេចក្តី ប្រាថ្នារបស់អរជុន ក៏គឺស៊ីសាច់ប្រិបាច់ឈាមកណាំឲ្យបាន. វេលានេះ អរជុនកំពង់ជាប់ដៃធ្វើការតស៊ូនឹងកងសឹកដទៃក្នុងភាគមួយនៃស្នាមយុទ្ធ កណាំបររបសឹកស្ទុះស្វែងរកអរជុនជាយូរមិនប្រទះប៉ះសព្វាលគ្នា តែសំរាប់ការផ្លាស់ផ្តូរឲ្យកណាំឡើងយសសក្តិជាមេទាពក្មេង ជាទីត្រូវចិត្តអរជុនបំផុត អ្នកធំជា អ្នកនាំទាពក្មេងដើរល្បីនាម នាំគ្នាផុតរលត់ទៅតាមៗគ្នា អ្នក

ខ្លាំងពូកែល្បមនឹងបញ្ហាការកងទាហ៊ានក្រុបាន នៅសល់តិច ណាស់ទៅហើយ, ព្រោះហេតុនោះ បើប្រសិនជាក្រញិបកណំ មួយទៀតបានហើយ គោងរាប់ថាស្បើយទ្រូងយ៉ាងធំ, ការត ស៊ូតទៅនៃក្រុ ក៏គង់ជាគ្មានអ្នកណានឹងអាច ឬមួយយ៉ាង ទៀតល្បមនឹងឲ្យឈ្នះបានថា "មិនជាការសំខាន់ប៉ុន្មាណ"

វេលាតមកមិនយូរប៉ុន្មាណ អ្នកបំបាំងឯកទាំងពីរ ប្រាណបានមកប្រទះប៉ះគ្នាគ្រិង្គបខ្យល់កំបុតត្បូង ការតស៊ូ នៃអ្នកទាំងពីរដែលមានបំណងមកយូរហើយ ហើយមកបាន ឱកាសជួបគ្នាគ្រានេះ គេបានតយុទ្ធសំដែងមហិទ្ធិឫទ្ធិស្នារដៃ មុខគួរស្ញប់ស្ញែងមាល្បាយ, តាំងពីព្រឹកដល់ថ្ងៃត្រង់ ពីថ្ងៃត្រង់ ដល់ប្រលប់សន្សើមធ្លាក់ អ្នកទាំងពីរបណ្ដាលទោសៈប្រឡូក គ្នាក្នុងរបៀបយុទ្ធវិធីៈ ខ្ជនឹងខ្ជន, ដាវនឹងដាវ, ធ្នូនឹងធ្នូ, រាល់ ៗ ភ្លេងដាលិដាប់ទៅ ធ្វើឲ្យគេបណ្ដាលទោសៈខ្លាំង- ឡើង ៗ ជាពន្លឹក ទាល់តែអស់វេលា ត្រៃក្លក៏ធ្វើជាអាណត្តិ សញ្ញាសំរាកច្បាំងក្នុងថ្ងៃនេះ ការច្បាំងនោះក៏នៅមិនទាន់ជ្នះ បាញ់ដេបខាតទៅ ។

វេលាយប់នោះទុរយោធន៍ត្រាស់ហៅប្រជុំ ដើម្បីប្រឹក្សារាជការសង្គ្រាម. ក្នុងការប្រជុំនោះ ទ្រង់ត្រាស់ថា "ដប់ប្រាំមួយថ្ងៃពេញ យើងបានជកជង្ហើមធំ នឹងបាចសាចលោហិតរបស់យើងចោលទទេ ៗ ការសង្គ្រាមក៏នៅតែច្បាំងគគ្រឹកដោយភ្លើងកំណាច មិនស្ងប់ចុះបាន ទាហានក្លារបស់យើងរាប់ដោយចំនួនរយ នាំគ្នាស្លាប់អស់ទៅ ឯជ័យជំនះក៏នៅមើលមិនឃើញស្រមោល"

សេចក្ដីតូចព្រះហឫទ័យយ៉ាងមុន បានមកសម្ពស្សព្រះហ្ឫទ័យទ្រង់ម្ដងទៀត រហូតវេលាដប់បួនថ្ងៃនៃការសង្គ្រាមកន្លងទៅហើយ ទ្រង់គ្មានរីករាយសប្បាយព្រះហ្ឫទ័យដល់បន្តិចសោះ ស្ងួម្បីកាលទ្រង់មានជ័យបានប្រៀបក្នុងការបំបាំង ទ្រង់ក៏គ្មានផុរសប្បាយព្រះហ្ឫទ័យ ទ្រង់នឹកអស់សង្ឃឹមជានិច្ចក្នុងរឿងមានជ័យ ជួនកាលវេលាខ្លះទ្រង់នឹកសព្វ ៗ ក៏បណ្ដាលទោមនស្សតូចព្រះហ្ឫទ័យ កាលទ្រង់ទោមនស្សឡើង ច្រើនតែរករឿងកោសរូសភីស្មមុន ហើយក៏ទោណាជាទីបំផុត គឺលើកទោសថា អ្នកទាំងពីរប្រកបដោយសេចក្ដីលំអៀង តែគំនិតរបស់ទ្រង់

ក្នុងគ្រានោះៗ ក៏គឺនឹងរកហេតុតែងតាំងកណៅ មនុស្សត្តប្រុស របស់ទ្រង់ ឲ្យជាមេទាព់ធំ ទ្រង់មិនគាប់ព្រះហឫទ័យក្នុងការ សង្គ្រាមដែលលោកមេទាព់ទាំងពីរបានធ្វើមកហើយ សេចក្ដី ពិត គឺទុរយោធន៍ឯងគឺតអានមិនគាប់ដោយផ្លូវធម៌ សាហេតុ ពិតនៃសេចក្ដីមិនគាប់ព្រះហ្ឫទ័យដែលជាផ្លូវខូចខាតទាំងនោះ ក៏គឺគំនឹតសមនឹងព្រះអង្គឯងនោះឯង មិនមែនជាទៃឆ្ងាយ ដែរ ទ្រង់បានលាក់គំនួបនោះមកយូរហើយ.

កណៅដឹងថា ទុរយោធន៍ត្រូវព្រះហ្ឫទ័យនឹងខ្ជួន ធ្វើការ ដើម្បីនឹងរក្សាព្រះហ្ឫទ័យទ្រង់ឲ្យត្រជាក់ស្ងប់ៗ ប្រាសបាកភ្នាក់ ផ្អើលរន្ធត់ ទើបក្រាបទូលថា « ឲ្យថ្ងៃព្រឹកស្អែកនេះរះឡើងមក បុះ ព្រះករុណា. ព្រះអង្គនឹងឃើញបំណាច់ថ្វីដៃដែលកណៅធ្វើ នោះសំរេចលុះទៅបាន ទូលបង្គំណានឹងសម្លាប់អរជុនឲ្យស្លាប់ ក្នុងថ្ងៃស្អែកនេះ ឬបើមិនស្លាប់ ទូលបង្គំណាក៏តោងស្លាប់ ដោយដៃអរជុនវិញ

កាលបានស្ដាប់ពាក្យប្រណិធានដ៏មាំមួនដូច្នេះ ហ្ឫទ័យ ទុរយោធន៍ក៏ស្ងប់បុះម្ដងទៀត · ពាក្យប្រណិធានដ៏មាំមួននេះ

ត្រូវព្រះហ្ឫទ័យទ្រង់ជាបំផុត ព្រោះជាគ្រឿងកំសួលសោហិតរបស់ទ្រង់ និងជាគ្រឿងបំពេញហ្ឫទ័យទ្រង់ឲ្យស្ងប់ ដោយគិតថា "ជ័យជំនះនោះនៅជិតៗនេះឯង ហេតុនេះព្រះហ្ឫទ័យទ្រង់ក៏ស្ងប់ទៀតជាច្រើនម៉ោង, ស្ដេចប្រថ្ទំសិរ៉ានទិព្ទ្រារមណ៍ជាទីសប្បាយក្នុងរាត្រីកាល

ថ្ងៃព្រឹកឡើង ទុរយោធន៍ទតព្រះអាទិត្យកំពុងរះឡើងមក, មានព្រះហ្ឫទ័យរីករាយសង្ឃឹមក្នុងជ័យជំនះ ដោយប្ដីដៃកណ៍មេទាត់ថ្មីនោះជាមាំមួន របស់កកណ៍មានសល្យរាជា ជាតាយសារបីបរថ្មី លាន់ឮគឹកកងទាំងស្នាមយុទ្ធ ទង់ជ័យសោកមេទាត់ថ្មី ក៏អណ្ដែតត្រសែតបោកបក់ទៅដោយខ្យល់យ៉ាងសង្ហា ក្នុងចិត្តគេគិតតែនឹងធ្វើសង្គ្រាមនឹងអរជុន តអំពីថ្ងៃមុនដែរលើកពាក់កណ្ដាល មិនទាន់ដឹងជាខាងណាជ្នះ ខាងណាចាញ់, ភ្នែករំពៃគយគណរកតែអរជុន កាលមិនប្រទះឃើញអរជុនទាន់ចិត្ត, ក៏គិតតែក្នុងចិត្តថា "ការប្រយុទ្ធក្នុងថ្ងៃដែរហើយមក ធ្វើឲ្យសត្រូវញញើតថ្ងៃដៃ ហេតុដូច្នោះសត្រូវទើបគេប

មុខមិនមកតទល់គ្នាទៀត" ទើបនិយាយនឹងនាយសារបីថា "អរជុនគេចអំពីការតយុទ្ធគ្នានឹងខ្ញុំជាប្រាកដ"

សល្យតបថា "លោកនឹងប្រទះគ្នានឹងអរជុនក្នុងមិនយូរ, គេមិនមែនជាមនុស្សកំព្រយស្លុលស្លប់ខ្លាចអ្នកណាទេ, លោកចូរប្រយ័ត្នខ្លួនឲ្យល្អផុតអំពីភ័យវិញល្អជាជាង" កណ៌ធ្វើមុខតឹងទឹងក្រោធ កាលបានស្ដាប់ពាក្យអំបាលនេះហើយបង្គាប់ឲ្យបររថទៅដោយរហ័ស ទៅមិនឆ្ងាយប៉ុន្មាណក៏ប្រទះនឹងយុធិស្ឋិរគង់លើរថសឹកដ៏វិចិត្រ ម៉ក់ករាំងទទឹងមុខគេ មានពួកនិស័ទដ៏ក្លៀវក្លាមួយពួកលើកចូលវាយកាត់ពាក់កណ្ដាលរវាងកណ៌នឹងយុធិស្ឋិរ ព្យាយាមនឹងវាយបង្អត់កំលាំងនៃការរុកចូលមកនោះឲ្យថយចុះ តែដៃរបស់កណ៌ដ៏ទ្រង់នៅកំលាំងមុះហឹមាបានប្រហារពួកនិស័ទខ្ចាត់ទៅដោយងាយ តនោះពួកបញ្ចាលបានព្យាយាមធ្វើដូច្នោះទៀតតែក៏ត្រោងខ្ចាតទៅដូចគ្នា គ្មានអ្វីមករាំងរាទទឹងមុខកណ៌បាន. គ្មានអ្វីមកបង្អន់សេចក្ដីក្លារបស់កណ៌ឲ្យថយចុះបាន. គេសម្រុកចូលវាយយុធិស្ឋិរបីដូចជាអគ្គីដ៏រុងរឿង យុធិស្ឋិរបានទទួលទប់ទល់ការបោមវាយនោះ រឹងបឹ

ដូចជាភ្នំក្រឹប្ទ, យឹតធនូសររបស់ទ្រង់ថ្លែងចេញទៅត្រូវធិតស្មា ផ្សេងនៃកណ្ណ៍ កណ្ណ៍ថ្លែងតបមកវិញត្រូវអាវក្រុសយុធិស្ទិរជា ច្រើនអន្លើ, អាវក្រុសដែបជាបព្វាយទៅនៅតែខ្លួនទទេ យុធិ ស្ទិរក៏តស៊ូមិនលះលាភជ័យ, សេះរបស់ទ្រង់ក៏ត្រូវអាវុធងាប់ ម្តងមួយ ៗ ទង់ជ័យមហាភជក៏ត្រូវអាវុធដើបបិ៍លធ្លាក់ចុះមក ដល់ដី, រថសឹកបាក់ខ្ទេចខ្ទី, តែទោះបីដូច្នោះយុធិស្ទិរក៏ធ្វើការ តស៊ូមិនបានរាជ័យ ទាល់តែត្រូវសរមួយផ្លែដែលកណ្ណ៍ថ្លែង មក លោហិតហូរជាបមានអាការល្ងាប់ល្ងើរងធឹតមុខ ពួក ទាហានដែលតាមស្តេច បានសែងចេញទៅអំពីស្មាមយុទ្ធ ជាប្រញាប់ ។

យុធិស្ទិរនោះត្រូវសរម្ទឹងហើយ គ្មានជ័យសេចក្តីថ្លា ឬ ជ័យកំលាំងកាយតែយ៉ាងឯណានីមួយ បើមានជ័យខ្លះក៏គឺជ័យ ក្នុងរឿងដែលទ្រង់រិះគិតហេតុការនោះ ៗ ច្រើនពេកទៅ, ជ័យ ខ្លះព្រោះបិត្តធ្វើការច្រើនពេកហួសបន្ទុក សេចក្តីបមជ័យអំ បាលនេះធ្វើឲ្យទ្រង់ទោមនស្សត្អូចព្រះហ្ឫទ័យ នឹងក្រោធមួយ ស្របក់ ៗ ទ្រង់ចូលផ្ទុំក្នុងបារាំសំងំនិទ្រារមណ៍ មិនមែនព្រោះ

ឈឺចាប់រាងកាយ, តែដោយសេចក្ដីក្ដៅក្នុលព្រះហ្ឫទ័យរម្ងាប់មិនបាន ក៏ទ្រង់ផ្ចិតផ្ចេបព្រះនេត្រទំអត់សង្កត់ហាក់ដូចជាផ្ចិតស្កល់ អរជុនចូលទៅក្នុងបារាំដើម្បីនឹងមើលឲ្យដឹងថា ព្រះជេដ្ឋាមានរបួសស្លាកស្នាមធ្ងន់ប៉ុន្មាន ឃើញទ្រង់ផ្ចិតស្កល់ក៏សន្សឹមៗថយចេញទៅ យុធិស្ឋិរស្រែកសួរតាមក្រោយថា "អរជុនឬ"

"ព្រះករុណា"

"សម្លាប់អាកណ៌បានហើយឬនៅ"

អរជុនត្រឡប់ក្រូលទៅក្នុងបារាំ ក្រិស្ណក៏ចូលទៅផង, ទូលថា "នៅ, នៅព្រះករុណា មិនទាន់បានសម្លាប់វាទេ" អរជុនរៀបនឹងពោលអ្វីៗតទៅទៀត តែក្រិស្ណឃាត់បង់ ហើយអធិប្បាយឲ្យយុធិស្ឋិរទ្រង់ព្រះសណ្ដាប់ថា អរជុនបានធ្វើការតស៊ូក្នុងភាគមួយនៃស្នាមយុទ្ធ នឹងដោះដៃមកតយុទ្ធគ្នានឹងកណ៌មិនបាន តែបានតាំងបដិញ្ញាថា នឹងសម្លាប់កណ៌ឲ្យបានក្នុងថ្ងៃនេះ

យុធិស្ឋិរកាលបានស្ដាប់ដូច្នេះក៏ក្រោធ ត្រាស់ជាសេចក្ដីកោសរូសសិកសៀតឲ្យអរជុនថា" ម្ដេចអ្នកឯងតែងកាយ

យ៉ាងអ្នកចំបាំង, មានម្កុកពាក់នៅលើក្បាល, មានដៃកាន់ធនូ-សិល្ប៍ ហើយមកគេចវេះអំពីមុខកណាំងដ៏ជាសត្រូវកំណាចរបស់អ្នកឯង, ធ្វើអាការជាស្រីដូច្នេះ. ចូរប្រគល់ធនូសិល្ប៍អ្នកឯងឲ្យអ្នកដទៃកាន់នឹងគ្រាន់បើជាងខ្លួនទៅវិញ ហើយចូរពួនមុខតាមកៀនកោះងងឹត ៗ ឯណានីមួយ ក្នុងខណៈដែលសត្រូវកំណាចមកជិះជាន់យាយីមិត្រសំឡាញ់បងប្អូនអ្នកឯង ក្នុងកណ្ដាលសង្គ្រាមយុទ្ធ ហើយចាំអើតកណ្ដាលបមើលអំពីចម្ងាយ"

អរជុនញាក់ញ័រដោយទោសៈ រំងាប់មិនបាន កាលបានឮពាក្យសក់សៀតហាក់ដូចជាមិនមែនបងប្អូនដូច្នេះ, ដៃក៏ស្ទាបរកដងក្រប៊ី ដោយមនោវិញ្ញាណមិនបានបង្គាប់ឲ្យធ្វើ ហូតក្រប៊ីក្រាកអំពីស្រោម ក្នុងខណៈដែលទោសៈជុតរោលនោះ ភ្លេចគិតទៅថា អ្នកដែលនិយាយអំមិញជាព្រះជេដ្ឋារបស់ខ្លួន ក្រិស្នបើញអាកាមិនស្រួល នឹងកើតអន្តរាយធំក៏ពោលដាស់តឿនស្មារតីអរជុនឲ្យដឹងខ្លួន អរជុនដាក់ក្រប៊ីភ្លាមមានទឹកមុខស្លេកស្លាំង ដោយសេចក្ដីខ្មាសនឹងអាការដែលធ្វើផ្ដេសប្រហែលសទៅមិនគួរសម ទើបក្រាបចុះទៀបបាទមូលនៃ

ព្រះជេដ្ឋាធិរាជសុំខមាទោសដែលទោសៈនាំទៅឯងដូច្នោះ យុធិស្ឋិរក៏ប្រែទានទោសព្រះអនុជដោយស្មោះពីព្រះហ្ឫទ័យ ប្រវ៉ាឱបហើយត្រាស់ថា រៀមធ្វើឲ្យប្អូនអាក់អន់ស្រពន់ចិត្តនោះមិនមែនជាសេចក្ដីកំហុះរបស់ប្អូន បណ្ដាលហេតុមកពីរៀមមានសេចក្ដីឈឺចិត្តក្នុងរឿងផ្សេង មកទំលាយនិស្ស័យសុភាពរបស់រៀមនោះអស់ តែឥឡូវនេះសុំឲ្យលុបលាងកក្ខឡកម៌អំបាលនោះបេញដោយមេត្តាចិត្តរបស់រៀមបុះណាះប្អូន. អ្នកចូរទទួលពររបស់បងហើយចូរទៅកំរ៉ាបសត្រូវរបស់អ្នកឲ្យជ្រិះត្រឡះបេញ"

អរជុនតបទាំងអស្បុជលរលង់ក្នុងនេត្រថា " ទូលបង្គំនឹងមិនដោះអាវក្រុសនេះបេញ ទំរាំតែសម្លាប់កណ៌បាន"

ដោយពាក្យបដិញ្ញានេះ អរជុនក៏បររថសឹកទំលុះចូលទៅក្នុងកងទាព់កុរុដ៏ក្រាស កណ៌លេបឆ្លោបេញមកទទួលរះគ្នានឹងអរជុន, អ្នកចំបាំងទាំងពីរដែលធ្លាប់ផ្ទាញ់គ្នាមកជាញយ ៗ ហើយ បានចូលផ្ទាញ់គ្នាក្នុងគ្រានេះម្ដងទៀត គង់ជាមិនរាគ្នាដូចដែរហើយមកហើយអំពីមុន ៗ សរអរជុនធ្លាក់ព្រាតដូចគ្រាប់ភ្លៀង ទាល់តែដំណោះធនូដេបដោយយឺត

ខ្លាំងពេកទៅ អ្នកបំបាំងឯណាដែលនឹងធ្លាក់នៅក្នុងទីគ្រោះភាព ដូច្នេះជាគ្មាន អរជុនស្រែកសុំឲ្យបង្អង់ច្បាំងមួយរំពេចសិន ដើម្បីនឹងផ្លាស់ដំណោះធនូ តាមច្បាប់ខត្តិយបវេណី (ទំនៀម អ្នកបំបាំង) នោះលោកថា មិនឲ្យប្រទុស្តរ៉ាយសឹកដែលមិន បានកាន់អាវុធនៅដៃ, ហើយអរជុនក៏បានអាងដល់ខនេះដែរ តែកណ៌ដែលចង់តែយកជីវិតអរជុន មិនត្រូវការនឹងប្រព្រឹត្ត តាមខត្តិយបវេណីខនោះ, កាន់យកឱកាសនោះជាកំរៃក៏យឹត ធនូដ៏ធ្ងន់បំផុតបាញ់ដំរង់ទៅអរជុនខ្ជាប់ ៗ ដោយបំណងនឹង ផ្តើចជីវិតអរជុន មុនដែលគេមានឱកាសកាន់អាវុធការពារខ្លួន អជុនអន់ប្រៀបក្នុងជើងបំបាំងមួយស្របក់ ទ្រាំការប្រហារមក នៃសត្រូវពេញរបុងដែលនឹងទ្រាំបាន កាលជួសជុលដំណោះ ធនូបានដូចដើមហើយក៏បាញ់សងទៅវិញឥតបីគណនា, តែ សរអរជុនដែរបាញ់បេញទាំងអំពាលម៉ាណ មិនបានផលដូច គ្នានឹងកូនសររបស់កណ៌ ការតស៊ូនោះស្មើគ្នាជាពាក់កណ្តាល ទាំងសងខាង មើលទៅទំនងនឹងលើកលែងឬរាគ្នាទៀត ដោយ ហេតុបណ្តាលឲ្យកើតមាន កង់រថកណ៌ជាប់ផុងដីមិនរួច, កណ៌

បានស្រែកសុំឲ្យបង្អង់ញាំងសិន អាងដល់ខត្តិយបវេណី ដែរ ខ្ញុំនស្មើសអំមិញ.

វេលានេះជាឱកាសនឹងតបឲ្យដល់ចិត្ត ក្រិស្ណក៍ពោល. ស័កសៀតឲ្យកណ៌ថា "អើវេលានេះអ្នកអាងដល់ច្បាប់ទំលាប់នៃខត្តិយបវេណី ដែលអ្នកបានប្រព្រឹត្តល្មើសក្នុងអំមិញនេះឬ មនុស្សប្រយ៉ាងអ្នកនឹងមកទាក់ទិនអ្វីដោយច្បាប់នៃកិត្តិយស អ្នកបានរក្សាច្បាប់នៃកិត្តិយសទុកឬទេ កាលអ្នកព្រមដោយសកុនិបានប្លន់យកទ្រព្យស្រិង្គាររបស់យុធិស្ឋិរ, អ្នកបានរក្សាច្បាប់នៃកិត្តិយសទុកឬទេ, កាលអ្នកប្រមាទមើលងាយទ្រោបទីក្នុងទីប្រជុំរដ្ឋមន្ត្រី, អ្នកបានបដិបត្តិតាមច្បាប់នៃកិត្តិយសឬទេ កាលអ្នកគប់គិតគ្នានឹងអាទុរពលសត្តានពាលទាំងប្រាំមួយអ្នក ព្រួតវាយអភិមន្យតែម្នាក់ឯងទាល់តែស្លាប់បង់, ធ្វើអាការដូចជាចោរ,"

កណ៌នឹកខ្មាសខ្លួនប្រើន មិនអង្វររតទៅទៀត លោតបុះអំពីរថសឹកភ្លាមឮ្យាំងដោយអាការដើរជើង ខាងអរជុនវេលានេះមានប្រៀបក្នុងជើងចំបាំង យឹតធនូទិព្យរបស់គេដំរង់ក្បាល

សត្រូវហើយក៏ថ្លែងខ្ទប់ចេញទៅ ត្រូវកណ្ដៀងលខ្មោកលើផែនពសុធា, ហើយបែមទៅទៀតមិនឲ្យក្រោករួច. ។

ភាគដប់ប្រាំពីរ

## អវសាននៃសង្គ្រាម

កាលកណ្ដៀងដល់នៅមរណាទៅហើយ កងទាព់ក្រុក៏ហោលទទេ គ្មានអ្នកនាំទាព់ទៀត ទាហានរត់ខ្ចាត់ខ្ចាយទៅទីទៃៗនឹងកើតបលាបលវិះនឹងក្លាយទៅជាការអំពល់ធំ ក្រិបាបារូអ្នកមានបញ្ញានៃប្រាជ្ញក៏ទៅគាល់ទុរយោធន៍ទូលថា "កងទាព់ព្រះអង្គវេលានេះគ្មានមេទាព់នឹងបង្គាប់បញ្ជា ធម្មតាកងទាព់កាលគ្មានអ្នកបង្គាប់បញ្ជាដូច្នេះ សូម្បីជាកងទាព់ដែលល្អបំផុតក៏ស្មើដូចជាកងទាព់ហោរ ឥឡូវនេះអរជុនគ្មានអ្វីមកទទឹងទើសមុខរបស់គេ ដែលនឹងប្រាសឲ្យវិលទៅដូចយ៉ាងប្រាសស្មៅតាំងអំពីនោះមកដល់ឥឡូវនេះ បានលះសាប់ឈាមក្រៃលប្រៃហែលៗគ្នាទាំងសងខាង តែផលដែលបំណងក្នុងទីបំផុត នៅមើលមិនឃើញ សុំឲ្យពួកអ្នកដែររួចអំពីមរណាមកហើយដល់

ត្រឹមវេលានេះ ប្ដូររូបរហូតទៅចុះ កុំបោះបង់ចោលវង្សត្រកូល ដ៏ក្លារបស់ព្រះអង្គឲ្យសាបសូន្យទៅ នៅមានវេលានឹងកែខៃអ្វីតទៅទៀតបានខ្លះ សុំឲ្យធ្វើសញ្ញាស្ងប់សឹកប៉ុណ្ណឹងទៅចុះ ហ្ឫទ័យយុធិស្ឋិរសឹងប្រកបដោយមេត្តាករុណានឹងមិនបដិសេធសេចក្ដីសុំស្ងប់សឹកនេះឡើយ អាចនឹងនិយាយបានមិនថាវេលាណា"

ទុរយោធន៍តប "ក្រិបៈអើយ សំដីរបស់អ្នកគួរស្ដាប់ជាសំដីប្រាជ្ញ អ្នកធ្លាប់ជាមនុស្សកណ្ដាល និយាយបញ្ចុះបញ្ចូលទាំងសងខាងឲ្យសាសសាគ្នា តាំងអំពីដើមដែរហូតដល់ឥឡូវនេះ តែខ្ញុំក្រែងថា ពាក្យណែនាំរបស់អ្នកមិនត្រូវនឹងរបៀបលោកសព្វថ្ងៃនេះ ខ្ញុំមិននឹកឡើយថា យុធិស្ឋិរនឹងទទួលមេត្រីរបស់យើងទៀត ឬនឹកថា ភីមនឹងភ្លេចពាក្យបដិញ្ញារបស់គេឬនឹកថា អរជុននឹងឲ្យអហោសិកម្មមរណានៃអភិមន្យុ, ១ ទៀតខ្ញុំនឹងធ្វើមិនដឹងមិនឮក្នុងរឿងព្រះញាតិអ្នកធំដែលខ្ញុំនាំមកស្លាប់បង់ជាច្រើននោះដូចម្ដេចបាន. ខ្ញុំជាក្សត្រិយ៍នឹងលុតជង្គង់សំពះសុំសេចក្ដីករុណាគេម្ដេចបាន.

ខនោះជាទីអាម៉ាសមុខ ខ្ញុំបកេរតិ៍ឈ្មោះជាងការអបរាជ័យ បាញ់បាលក្នុងកណ្ដាលសង្គ្រាមយុទ្ធ សល្យព្រះរាជានៃមាទ្រនឹង ជាអ្នកនាំទាព់របស់យើងក្នុងថ្ងៃនេះ យើងនឹងមិនបន្តជំលោះ. ធនូរបស់យើង ដរ៉ាបទាល់តែយើងមានទាកោនសៅសល់តែ ម្នាក់តស៊ូនឹងគេ ទើបឈប់"

ការស្លាប់នៃកណ៌ជាទីរីករាយសប្បាយបិត្តនៃពួកបាណ្ឌព គេយលថា មេទាព់ថ្មីនោះប្រៀបដូចជារំពរទូក តែខនេះគេក៏ ដឹងខ្លួនថា កំណត់ប្រមាណកំលាំងសឹកទាបពេកទៅ អនុជ នៃយុធិស្ឋិរទាំងអស់អង្គនាំគ្នាទៅអមអង្គយុធិស្ឋិរ ដើម្បីមិនឲ្យ មេទាប់ថ្មីវាយបាន. តែយុធិស្ឋិរត្រាស់ថា ម្នាលអនុជទាំងឡាយ អ្នកទាំងឡាយបានធ្វើភាគនៃការច្បាំងជាសួនខ្លួនស្រេបហើយ ដោយសេចក្ដីក្លាហាន, ថ្ងៃនេះយើងសុំខ្លួនជាអ្នកនាំទាព់ចូល កំរ៉ាបក្បុ, បាត់សាត្យកិច្ចជាអ្នករក្សាស្លាបស្ដាំ, ធ្ឫស្ដទ្យុម៉ន ជាអ្នករក្សាស្លាបឆ្វេងរបស់យើង, ឲ្យភីមនាំទាប់ស្រេប អរជុន នាំទាព់ក្រោយ, ខ្លួនយើងនឹងកាន់កាប់កងទាព់ធំកណ្ដាល

ដោយចាត់របៀបក្បួនទាព់ដូច្នេះ យើងសង្ឃឹមថា “ នឹងយកជ័យជំនះបានដោយការចូលវាយក្នុងម្ដង”

យុធិស្ឋិររក្សាវិធារបស់ព្រះអង្គទុកតាមន័យដែលពោលមកហើយ បានស្ដេចនាំទ័ពចូលតស៊ូដោយក្លាហានជាសូស្ដីជ័យសិទ្ធិ សំរាប់ពួកបាណ្ឌពដែលបានព្រះរាជារបស់គេជាមេទាព់ធំ ក្នុងថ្ងៃបំផុតនៃការចំបាំង ការច្បាំងថ្ងៃនេះច្បាំងយ៉ាងផ្ដេសផ្ដាសបំផុត មិនទៅតាមរបៀប ច្បាំងបានតែមួយស្របក់ៗរកកល់ជ្រួលនឹងបែកកង. ជុំវិញលោកមេទ័ពទាំងពីរខ្វលខ្វាញ់ត្រឡប់ដូចពាយុ ឮតែសូរសន្ធឹកតស៊ូគ្នា សល្យតស៊ូរទ្រាក ៗ យ៉ាងអស់សង្ឃឹម យុធិស្ឋិរស្ដេចសឹកទ្រង់នៅធម្មានុភាព បានតស៊ូដោយក្លាហាន កូនសរដែលថ្លែងចេញទៅព្រួស ៗ ញឹកដូចគ្រាប់ភ្លៀងទៅធ្លាក់លើសល្យអ្នកដល់ព្រហ្មលិក្ខិតក្នុងថ្ងៃនោះ ទង់ជ័យកំពូលពល់របស់កុរុត្រូវសរដេចបិត ៗ ហើរប្រុយដូចស្លឹកឈើទំជ្រុះ ពួកកុរុត្រូវវាយបែកខ្ចាកចេញ ហើយត្រឡប់រួមជាកងវិញ តែដូច្នេះជាច្រើនគ្រា មិនយូរប៉ុន្មាណសល្យមេទាព់ធំខាងកុរុត្រូវអារុធរលើងគ្រែងទៅទៀត

ពួកបាណ្ឌពសង្កុញប្ចូលកាប់កាត់វាយវាត់ផ្ទេងត្តាំ ធ្វើឲ្យកង ទាត់ក្បួរអបរាជ័យវិនាសវាល សហទេពប្ចូលប្រហារអ្នកលេង ស្ការដោយកលកោង គឺសកុនិ ដែរមានជីវិតរស់នៅដល់ថ្ងៃ នោះ, ភីមវាយទុហសាសនស្លាប់ ដោយគទាវុធដ៏ធំរបស់គេ ហើយក៏កាត់កណ្ឋហុតឈាម តាមពាក្យបដិញ្ញាដែលគេប្រណិ ធានទុក "អើ, អើ, យើងមិនដែលផឹកអ្វីផ្អែមដល់ម្លេះ បំណែក ឯទុរយោធន៍បានស្តេចរត់ចេញអំពីស្នាមយុទ្ធទៅតែមួយអង្គឯង អស្វត្ថាម៉ន បុត្រទោណដែលស្ម៊ីថាស្លាប់ទៅហើយ, និង ព្រាហ្មណក្រិបាចារ្យ, ព្រាហ្មណខាន់ធនូឈ្មោះ កិត្តិវរម៉ន ទាំង ៣ នេះត្រូវបាប់ខ្លួនបានជាឈ្លើយសឹក ។

ព្រះចៅទុរយោធន៍ ក្រុងហស្តិនបុរ ស្តេចរត់យកតែជីវិត ខណដែលទ្រង់រត់ទៅអំពីទីបំបាំង គិតថាគួរយកដំបងកាយ សិទ្ធិសំរាប់អង្គទៅផង ព្រោះក្រែងថាសត្រូវនឹងដិតដោយតាម ទៅធ្វើអន្តរាយ នឹងបានជាគ្រឿងការពារខ្លួន, ទៅមិនឆ្ងាយ ប៉ុន្មានអំពីស្នាមយុទ្ធ មានត្រពាំងទឹកមួយជ្រៅ ទុរយោធន៍ បានចុះទៅអាស្រ័យពឹងពួនលាក់ខ្លួនក្នុងទីនោះសំរាករកឱកាស

នឹងរត់តទៅ ទ្រង់បេះវិជ្ជាមុចទឹកបានយូរៗ សំកាំងសឹកកនៅក្នុង ទឹកបានច្រើនៗថ្ងៃដូចត្រី ហេតុដូច្នោះកាលទ្រង់ចុះទៅក្នុងត្រ-ពាំងនោះ បានមុចទៅនៅក្រោមទឹក ដើម្បីលាក់ខ្លួនពួនភ័យ·

គ្រានោះមានការគគ្រឹកគគ្រេងលេងសប្បាយរីករាយក្នុង បន្ទាយបាណ្ឌព តែព្រះបាទ័យយុធិស្ថិរវេលានោះគ្មានរីករាយ សប្បាយនឹងគេសោះ មានតែស្រងូតស្រង៉ាតព្រួយព្រះកមល ដោយស្តាយស្រណោះដល់ពួកព្រះញាតិដែលត្រូវពិឃាត ស្លាប់បង់ទៅទាំងនោះ ព្រោះអ្នកដែលស្លាប់ទៅទាំងសងខាង សុទ្ធតែជាព្រះញាតិរបស់ព្រះអង្គទាំងអស់ ទ្រង់បដិព័ទ្ធដោយ បំណងនៃលោហិត, ដោយបំណងនៃប្រទេស, ដោយបំណង នៃសេចក្តីស្នេហា ព្រោះមូលហេតុទាំងនេះ ខណកាលអ្នក ដទៃគេរីករាយខ្សៀវខ្សាល់ ព្រះបាទយុធិស្ឋិរបេះតែសៅព្រះហ្ឫទ័យ ទ្រង់កាន់ទុក្ខឲ្យពួកព្រះញាតិវង្សទាំងសងខាងដែលបែកឋាន ទៅ ទ្រង់សំដែងទុក្ខក្នុងព្រះហ្ឫទ័យឲ្យប្រាកដថា " មើលចុះ ណា យើងជាក្សត្រិយ៍ក្នុងពពួកអ្នកស្លាប់ ។

គ្រានោះមានអ្នកក្រាបទូលថា ប្រទះទុរយោធន៍នៅក្នុង

ទឹកត្រពាំង, ដំណឹងនោះនាំសេចក្ដីបន្ទោបង់នៅទុក្ខមកកាន់ព្រះហ្វទ័យទ្រង់ដែលស្ងួតសៅ មិនមែននាំមកនៅបំណងនឹងចាប់រាជសត្រូវដ៏ធំនោះឡើយ ព្រោះទ្រង់យល់ថាជាហេតុឲ្យឱកាសដល់ទ្រង់ នឹងបានធ្វើការសំរួបសំរួមស្ងប់សឹក ដើម្បីទទួលយកអាណាចក្រឥន្ទ្របថរបស់ព្រះអង្គដែលបង់ទៅ មកវិញដោយស្រួល, នឹងប្រគល់រាជអាណាចក្រហស្តិនបុរដែលវាយបានឲ្យទុរយោធន៍វិញ ព្រះហ្វទ័យទ្រង់ប្រកបដោយមេត្តាគ្មានគិតនឹកព្យាបាទសងសឹកតែក្នុងវេលានេះទេ ពីដើមមកក៏ដូច្នេះ របស់ដែលទ្រង់ត្រូវការ ក៏គឺនឹងសុំយករាជអាណាចក្ររបស់ទ្រង់ ដោយសិទ្ធិនៃសាលោហិតមកវិញប៉ុណ្ណោះ ទ្រង់មិបានត្រេកអរនឹងរបស់ដែលវាយបាន, ហើយព្រះហ្វទ័យទ្រង់គង់នឹងសប្បាយ កាលឃើញទុរយោធន៍គ្រប់គ្រងព្រះនគរជាសុខ ហេតុនោះកាលទ្រង់ជ្រាបទីសំណាក់ទុរយោធន៍ហើយក៏ស្ដេចប្រញាប់ទៅឯត្រពាំងទឹកនោះ ស្រែកហៅបេញព្រះនាមទុរយោធន៍ពេញព្រះសូរសៀង ទុរយោធន៍ក្នុងជាន់ដីបូងមិនឆ្លើយតប កាលយុធិស្ឋិរពោលបបួលឲ្យឡើងមកច្បាំងគ្នាតត្ដ

ទើបឆ្លើយតបថា "ចូរយករាជអាណាចក្ររបស់ខ្ញុំចុះ, ចូរសោយរាជសម្បត្តិជាសុខចុះ, ចូរលែងខ្ញុំឲ្យនៅតាមអំពើចិត្តខ្ញុំ, ខ្ញុំនឹងទៅនៅព្រៃត្រង់វ័យដែលសល់ក្នុងអាយុកាលរបស់ខ្ញុំ ដោយការភាវនានឹងបំពេញតបៈ"

យុធិស្ឋិរតប "ខ្ញុំនឹងមិនយករបស់ដែរខ្ញុំមិនមានជ័យក្នុងទីបំបាំងបានមក ខ្ញុំទទួលយករបស់អំណោយនោះមិនបាន"

ទុរយោធន៍តប បើទ្រង់សណ្ឋានឹងប្រាំងតទល់ខ្ញុំនឹងឡើងទៅ.

យុធិស្ឋិរទទួលនឹងធ្វើតាមសញ្ញានោះ តែទុរយោធន៍ក៏នៅឈរស្ងាក់ស្ទើរមិនចង់ឡើងមក ភីមបណ្ដាលទោសៈដោយហេតុឃើញយូរមិនចង់ឡើងមក ក៏ស្រែកគំរាមទៅថា «បើទ្រង់មិនឡើងមកអំពីទឹកឥឡូវនេះ ក៏នឹង....អ្នកក្រពើបួម, យើងនឹងលោតចុះទៅអូសយកខ្លួនឡើងមកឥឡូវនេះ,

ទុរយោធន៍ ក៏ម្ដងទៀងឡើងមកលើគោក ភីមសើចហាះហាយ ៗ កាលឃើញព្រះភ័ក្ត្រទុរយោធន៍ប្រឡាក់ភក់នឹងទឹកប្រ

ណោក. ហាះហៃ យើងនឹងថ្លែងការអស់សំណើចរបស់យើងឡើងទៅជាការយំ

ពាក្យបដិញ្ញារបស់ភីមធ្វើទុករហូតអាយុកាល គឺនឹងសម្លាប់ទុរយោធន៍ឲ្យបាន ហេតុនោះការតស៊ូគ្រានោះ ទើបបណ្តោយឲ្យភីមជាដំបូងចូលប្រយុទ្ធនឹងទុរយោធន៍ អ្នកបំបាំងទាំងពីរប្រសប់ស្ទាត់ក្នុងការប្រើអាវុធសឹងល្បីតាមទាំងគូ អ្នកទាំងពីរជាសត្រូវនឹងគ្នា ដែលបានបដិញ្ញាទុកនឹងយកជីវិតគ្នាទៅវិញទៅមក គ្រានោះអ្នកបំបាំងទាំងពីរប្រាណបានចូលប្រយុទ្ធគ្នាដណ្តើបជ័យយ៉ាងក្រៃពេក មុខអ្នកទាំងពីរមានដំណក់ឈាមប្រឡាក់ដុំ ៗ ភ្នែកក្រហមដូចភ្នែកអាអូត សំឡេងសំឡក់ហាក់ដូចជានឹងស្ទុះទៅស៊ីសាប់គ្នា លោហោតវាយវាត់គ្នានឹងគេបកែប្រែខ្លួន បែកពពុះមាត់ស្កុល ខណៈមួយនោះ ទុរយោធន៍ហៀបនឹងកាប់ភីមបាន គឺទ្រង់វាយញាំងទៅត្រូវក្បាលជ្រុលទ្រេតទ្រោតទៀបដួល តែមិនយូរក៏ទប់ខ្លួនឡើងវិញបាន ក៏វាយសងទៅវិញត្រូវក្បាលជង្គង់ទុរយោធន៍ គ្រាប់អង្គញ់បែកល្អិតទៅ ទុរយោធន៍ដួលផ្កាប់មុខស្រប៉ូប ។

សេចក្ដីបដិញ្ញារបស់ភីម ក៏បានសំរេចតាមដែលគេប្រណិធានទុក, គេក៏ញាក់អុខញាក់មាត់រាំរេជុំវិញទុរយោធន៍ហើយពោលថា "នេះឈ្មោះថា បានធ្វើសង្សឹកដ៏ខ្ពស់ទ្រាបទី ក្នុងទីបំផុត"

យុធិស្ឋិរ ខ្វល់នឹងភីមដែរពោលផ្ដាំគ្នាសត្រូវដែរដួលហើយត្រាស់ឲ្យនាំខ្លួនចេញចាកទីនោះ ដើម្បីកុំឲ្យធ្វើរឹករវរជាហេតុបង្អៀតបង្អល់ចិត្តទុរយោធន៍ កាលភីមទៅហើយយុធិស្ឋិរក៏លុតជង្គង់ខាងអង្គទុរយោធន៍ ត្រាស់ថា "ទ្រង់នៅជាក្សត្រិយ៍ និងជាម្ចាស់របស់ខ្ញុំ."

តែវេលានោះ ព្រះនេត្រទុរយោធន៍ធ្មេចទៅហើយ, វិញ្ញាណចេញចាករាងកាយទៅហើយ, ទ្រង់មិនដឹង មិនឮ, មិនឃើញការលុតជង្គង់សំដែងសេចក្ដីគោរពអំពីបាណ្ឌវរាជនេះទេ អ្នកដែលធ្វើដូច្នេះ នឹងមិនបានទទួលពាក្យតប ឬពាក្យអំណរគុណអំពីទ្រង់ កាលដល់ប្រលប់ ពួកមេទាព់នាយកងនៃកងទាព់កុរុដែលមានជីវិតរស់នៅ បាននាំគ្នាមកគំនាប់ព្រះបរមសពក្សត្រិយ៍ម្ចាស់ជីវិតរបស់គេជាច្រើន

សពអ្នកចំបាំងដែលត្រូវអាវុធស្លាប់ក្នុងទីចំបាំងដេករដ្ឋិក ពាសពេញទាំងយុទ្ធភូមិបានប្រមូលរួបរួមមកទុកនៅទីមួយ កន្លែងសិន នឹងលើកឡើងកាន់ជើងថ្ករាល់ៗ សពទាំងអំបាល នោះ សពដែលថ្វាយព្រះភ្លើងជាដំបូង គឺព្រះបរមសពព្រះបាទ ទុយោធន៍ បាណ្ឌវក្សត្រិយ៍ទាំងឡាយបានកាន់ទុក្ខថ្វាយតាម ពួកគោរព ព្រោះហេតុថា ដេបមេត្រីគ្នាដោយធ្វើសង្គ្រាមក៏ពិត តែទាំងសងខាងកើតអំពីផៅរួមគ្នា នឹងបដិពទ្ធគ្នាដោយបំណង នៃខត្តិយសភាព ទើបកាន់ទុក្ខរាល់គ្នាក្នុងពពួកហឹន្ទូ ។

ធ្មតរាស្ត្រវេលានេះ មុខគួរអាសូរជាទីបំផុត ព្រះរាជបុត្រ របស់ព្រះអង្គត្រូវអាវុធក្នុងសង្គ្រាស្លាប់អស់ រាស្ត្រនិករក៏ស្លាប់ រលោះអស់ពីព្រះនគរ ទ្រង់សោយភារទុក្ខសៅស្លុតជាបំផុត បិត្ត ទាំងព្រះនេត្រខ្វាក់ពពេមពពើមដួច្នេះ បានស្តេចឧស្សាហ ខំយាងទៅកាន់ទីចំបាំង ដើម្បីស្តេចទៅសំដែងសេចក្តីអាលោះ អាល័យដល់ព្រះរាជបុត្រដែលសុគតទៅទាំងនោះ ដល់ ទីកន្លែងថ្វាយព្រះភ្លើង នាងខត្តិយានីទាំងឡាយក្នុងព្រះរាជសំ ណាក់នោះ បានស្តេចទៅឯទីថ្វាយព្រះភ្លើងសពអ្នកចំបាំងអំ

បាលនោះ[១] ខត្តិយនារីអំបាលនោះ នាំគ្នាឱ្យកឱ្យលបរិទេវនាការពិលាបទៅទីទៃ ៗ រាជនារីទាំងឡាយមិនដែលស្តេចយាងចេញទៅក្រៅវាំង គ្រានេះតោងស្តេចយាងដោយព្រះបាទគ្មានសំពត់បិទបាំងព្រះភក្ត្រ · ព្រះនេត្រដែលទន់ដូចបទុមជាតិឥឡូវនេះក្រហមដូចជាតិហិង្គុលនឹងដាំដាំដោយទ្រង់ព្រះកន្សែងអភិរូបនារីដូចទេពធីតា ក្នុងកាលឥឡូវនេះមកបំពាសនទៀលដោយដី ប្រឡាក់ប្រឡូកអាប់អស់រាសី សក់ភ្នួងដែលតែងតែសិតសំអាងរាល់វេលា គ្រានេះរំសាយចោលឲ្យជំពាក់ស្មុកស្មាញ នឹងមិនបានសិតសំអាងតទៅ នាងក្សត្រិយ៍រាប់ចំនួន

---

(១) លោកអ្នកសាងប្រាសាទនគរវត្ត (កម្ពុជា) បានឲ្យឆ្លាក់រូបភាពរឿងចំបាំងមហាភារតនេះត្រង់ភាវៈទីបំផុតនៃការសង្គ្រាម នៅប្រាសាទនគរវត្ត នាព្រះរបៀងទី ១ ជាន់ខាងឡិចភាគខាងត្បូង គឺធ្វើឲ្យឃើញរូបភាពកំពុងច្បាំងគ្នា ៈ កងទាព់កោរពនៅខាងជើង កងទាព់បណ្ឌពនៅខាងត្បូង ក្នុងកងទាព់កុរុធ្វើរូបក្សត្រិយ៍ ១ អង្គត្រូវអាវុធសុគតក្នុងសង្គ្រាម គេយកទៅដំកល់នៅក្នុងភាគទី ១ ហើយតាំងគ្រឿងខ្ពស់សំរាប់ក្សត្រិយ៍ ហើយធ្វើមានរូបក្សត្រិយ៍ប្រុសស្រីទៅប្រជុំក្នុងទីនោះជាច្រើន

យើងយល់ថា រូបនោះជារូបព្រះបាទទុរយោធន៍ ដែលត្រូវអាវុធសុគតហើយ គេយកទៅដំកល់ទុកនៅទី ១ ដ៏សមគួរ ហើយតាំងគ្រឿងខ្ពស់សំរាប់ក្សត្រិយ៍ មានព្រះក្ងស់ ឆ្មិតចាំម៉ែរបាយមន្តជាដើម ដើម្បីនឹងថ្វាយព្រះភ្លើងនៅវេលាក្រោយ អ្នកប្រាជ្ញចង់ឃើញ សូមអញ្ជើញទៅមើលនៅទីនោះ ,

ដោយរយជាមេម៉ាយគ្មានភស្តា ដោយហេតុមហាសង្គ្រាមគ្រានេះ, នារីឯទៀតជាច្រើនរយអង្គ បានបង់បុត្រ ឬបងប្អូន ឬបិតាទៅ. នឹងអ្នកឯទៀតជាច្រើនឥតបីបើគណនាបានខូបខាតទៅ ១ ភាគក្នុង ៤ ភាគនេះ មិនអាចនឹងពោលបានថា ការខូបខាតរបស់អ្នកណាធ្ងន់បំផុត រាល់ៗ នារីនោះបានសំដែងការសោកសៅជាទម្ងន់ ហាក់ដូចជានាងបង់ខាតលោកិយទ្រព្យអស់គេងរលីងអំពីខ្លួន នាងដាលដំគក់ឱរា បោចរាចកេសាបំរាសនទៀលដោយធូលី.

ព្រះបាទធូតរាស្ត្រទ្រង់ឈរកណ្ដាលពពួកនាងក្សត្រិយ៍អំបាលនោះ ព្រះនេត្រងងឹតមើលអ្វីមិនឃើញ ទ្រង់ឈរស្ងៀមមិនត្រាស់ព្រះវាចាបេញមក តែក្នុងព្រះហ្ឫទ័យពេញទៅដោយទុក្ខសោកដ៏មហិមា ទើបឯព្រះនាងគន្ធារី (ទេពីព្រះបាទធូតរាស្ត្រ) ជាទីអាណោចអាធម្មបំផុត ព្រះនាងបួលឱបព្រះរាជបុត្រមួយអង្គម្ដងៗ បបោសអង្អែលដោយសេចក្ដីស្រឡាញ់ពេញចិត្ត នឹងត្រាស់សណ្ដាវាចាប្រកត្របៀកព្រះរាជបុត្រដែលមានវិញ្ញាណទៅព្រួសហើយ នាងប្រព្រឹត្តកិរិយាហាក់ដូចជាព្រះ

រាជបុត្ររាល់អង្គមានព្រះជន្មរស់នៅ ហាក់ដូចជានាងមកទទួល
ព្រះរាជបុត្រត្រឡប់ចូលព្រះនគរ ក្នុងជាន់ដំបូងព្រះនាងមិន
ព្រមមានសោរនីចេញមកជាសំដីសំដែងទុក្ខរបស់មាតា ក្នុងទី
បំផុតសេចក្ដីសោកចូលគ្របហ្ឫទ័យខ្លាំង កើតអាក់អួលឡើង
មក ទើបត្រាស់ជាភ្លេងពិលាបដូចតទៅនេះ

នេះទុរយោធន៍ឱរសយើងឬ? ដំបូងគេចេញចាកនិវេស
ស្ថានមានចិត្តរីករាយលោតកន្ទ្រង ដូចអាជានៃយសិន្ធពជាតិ
គ្មានចិត្តព្រួញព្រីក្នុងរឿងសង្គ្រាម កាលគេនឹងចេញទៅធ្វើ
សង្គ្រាមបានសុំពរម្ដាយថា "ព្រះមេម្ចាស់ចូរប្រទានពរសួស្ដី
នឹងជ័យមង្គលឲ្យកូនផង" ម្ដាយតបថា កូនម៉្ដាយ សុំទេពតា
ចូលពិភក្សរក្សាអ្នក ឲ្យរួចអំពីភ័យអន្តរាយ កូនម្ដាយកុំព្រួយ
ធម្មមាននៅទីណា ជ័យជំនះមាននៅទីនោះ អនិច្ចា នរណា
នឹងដឹងបានថា ពាក្យដែលម្ដាយនិយាយនឹងអ្នកគ្រានោះជា
បច្ឆិមវាចា តែខ្លួនអ្នកមុខជានឹងបានសោយសុខក្នុងទិព្យលោក
ហើយ ម្ដាយមិនសូវជាអាណិត ដូចព្រះរាជស្វាមីរបស់ម្ដាយ
ព្រះអង្គនឹងទ្រង់ព្រះវរកាយដូចម្ដេចបាន ក្នុងគ្រាជរាបៀតបៀយកំ

លាំងដូច្នេះ? អើ កូនម្ដាយក្លា មានតេជានុភាពដ៏មុះហឹមា រកអ្នកណាប្រៀបគ្នាក្នុងសង្គ្រាម ជាទីស្រប់ស្ញែងនៃអរិរាជសត្រូវរបស់អ្នក ជាក្សត្រិយ៍ដ៏ខ្ពស់សក្ដិ ជាបុរសអាជានៃយក្នុងយុគអនិច្ចា ឥឡូវនេះចូលនិទ្រាអ្នកបំបាំងក្នុងកណ្ដាលស្នាមយុទ្ធ មិនបង់ជាតិកំណើតដែលកើតមកជាអង្គកូនប្រុស យកលោហិតខ្លួនលាបផែនដីជាបំណាច់ក្នុងលោក វេលានេះអ្នកចូលកាន់ឋានសួគ៌នៃអ្នកបំបាំង គ្រាដែលគេមានរាងកាយប្រឡាក់ដោយលោហិតក្រស់ក្រាំងដេកនៅកណ្ដាលស្នាមយុទ្ធ វិញ្ញាណរបស់គេបានឡើងទៅនិទ្រាក្នុងដួងហឫទ័យនៃព្រះអ្នកសាង ។

ទេវីរបស់ទុរយោធន៍គ្រានោះ ព្រះនាងដើរចេញអំពីសពវីរបុរសម្នាក់ទៅរកម្នាក់ទៀត. នាងឱបព្រះរាជស្វាមីរបស់នាងហើយ ក៏ឱបលក្ខណាម័នអ្នកជាឱរស បីដូចជាមិនច្បាស់ក្នុងចិត្តថា អ្នកណាមានបណ្ដាសក្ដិខ្ពស់ជាង អ្នកណាជាទីស្នេហាច្រើនជាងក្នុងពីរអ្នកនោះ ហើយនាងថ្លែងរៀបរាប់ថា “ទុរ-យោធន៍ព្រះរាជស្វាមីយើងអ្នកគ្រប់គ្រងកុរុរាណាចក្របាន ១៣ ឆ្នាំនេះហើយ ជាក្សត្រិយ៍ជាន់ខ្ពស់មានសង្ហារាសីហ៊ោងក្រៃពេក

ពួកបាណ្ឌពឬស្បាសេចក្ដីលំអរនៃព្រះរាជអាណាចក្រ នឹងសេចក្ដីសុខសម្បូណ៌ក្នុងព្រះរាជអាណាចក្ររបស់អ្នក អ្នកស្ងួប្ស៊ប្រាំងទាល់ផុតជង្ហើមក្នុងទីបំបាំង មើលចុះណេកក្ដើយនេះហៅអ្នកញ្ញា អនិច្ចា កុរុអាណាចក្រវេលានេះគ្មានអ្នកគ្រងហើយទុរយោធន៍ព្រះរាជស្វាមីរបស់យើងអ្នកលះសិរីរាជសម្បត្តិក្នុងលោកកណ្ដាលនេះ ទៅនៅក្នុងមណ្ឌីរស្ថានក្នុងលោកដទៃលោកដទៃគឺឋានសួគ៌ជាន់ខ្ពស់ជាប្រាកដ បើគម្ពីរវេទនោះពិតមែន បើទេវតាមិនបេះនិយាយមុសាវាទ"

ពិធីឈាបនកិច្ចអស់វេលាជាយូរ មិនតែព្រោះសពច្រើនប៉ុណ្ណោះ ពីព្រោះកុលស្ត្រីទាំងនោះបេះតែបរិទេវនាការមិនបេះអស់មិនបេះហើយ, មិនអាចនឹងបំរាត់យកសពចេញពីទ្រូងអ្នកដែលសោកអំបាលនោះ, ក្នុងទីបំផុតសពទាំងនោះក៏ត្រូវបំរាត់យកទៅបូជា ទាំងកំពុងអ្នកអំបាលនោះក្ដុកក្ដួលក្នុងឱរាលុះស្រេចការបូជាហើយ, បណ្ដាអ្នកកាន់ទុក្ខទាំងប៉ុន្មាន ក៏នាំគ្នាដើរទៅឯឆ្នេរព្រះគង្គា ដើម្បីនឹងជីរះកាយក្នុងទឹកដ៏សក្ដិសិទ្ធិ, នឹងដើម្បីឧទ្ទិស្សមតកភត្តទៅឲ្យវិញ្ញាណដែលស្លាប់ទៅ

ក្នុងកាលដែលកំពុងធ្វើបុណ្យនោះ ព្រះនាងប្រិឋាដើរចូលទៅរកឱរសទាំងប្រាំ (បាណ្ឌវកុមារ) បញ្ចេញសេចក្ដីសម្ងាត់រឿងសម្ភពជាតិរបស់មេទាព់ (កណ៌) ដែលជាសត្រូវនឹងអរជុនយ៉ាងសំខាន់នោះ ឥឡូវនេះមកប្រាកដក្លាយទៅជាបងប្អូនរបស់គេ, កណ៌ទើបបានដឹងរឿងនេះអំពីភីស្មក្នុងវេលាដែលទៀបនឹងស្លាប់ហើយ តែគ្មានអ្នកណាដឹងទៀតទាល់តែនាងប្រិឋាបាននាំសេចក្ដីសំវេគស្លុតចិត្ត មកបញ្ចេញក្នុងវេលានេះ ហើយសុំឲ្យឧទ្ទិស្សប្រំណែកកុសលឲ្យគេដែលជាបងច្បង

ស្រេចឈាបនកិច្ច ក៏ប្រកាសការរាជាភិសេកយុធិស្ឋិរជាមហារាជានៃអាណាចក្រហស្តិនបុរ រួមទាំងអាណាចក្រឥន្ទ្របបមកផងដូចអំពីដើម តែទ្រង់គ្មានត្រេកត្រអាលឬធ្វើឫកឡើតយសស័ក្ដិតែយ៉ាងឯណានីមួយ មកជារង្វាន់ជំនួសសេចក្ដីលំបាកតោកយ៉ាក ដែលទ្រង់បានត្រាំត្រែងរងវេទនាជាយូរក្នុងគ្រាត្រូវនិរទេស, ឬជំនួសការខូចខាត, ដែលទ្រង់បានខូចបង់ទៅក្នុងវេលាធ្វើសង្គ្រាម ព្រះហឫទ័យទ្រង់ក្រៀមទៅដោយសម្បត្តិសម្បូណ៌និងការសំដែងសេចក្ដីភក្ដីទាំងនេះ មិនធ្វើឲ្យ

យុធិស្ឋិតត្រេកត្រអាល មានតែបន្ថែមទុក្ខឡើងរិតណាស់ឡើង មួយយ៉ាង រាល់ទិវារាត្រី ទ្រង់មានព្រះហ្ឬទ័យក្តុកក្តួលរំជួល គឹតដល់រឿងកាប់សម្លាប់ញាតិបងប្អូន ដ៏ជាបាបកម្ម ក្នុងទីបំផុត លោកឫសី „វិយាស„ ចូលទៅគាល់ហើយទូលណែនាំទ្រង់ ឲ្យធ្វើ "អស្វមេធយ័ញ្ញ" ពិធីសម្លាប់សេះបូជាយិជដែលគេ ពោលថា អាចលុបលាងបាបកម្មរបស់ទ្រង់បាន.

ទើបឲ្យជ្រើសជ្រាវរកសេះសន្ធួន សំបូរដូចពន្លឺព្រះចន្ទ មានត្រចៀកខ្មៅម្ខាង លុះបានសេះដូចថានេះមកហើយ ក៏ឲ្យធ្វើផែនមាសហើយចារឹកព្រះនាមយុធិស្ឋិរនៅផែនមាសនោះ ស្រេចហើយយកទៅចងនឹងមុខសេះនោះ ហើយលែងសេះនោះ ឲ្យវាដើរទៅតាមចិត្តវា មានកងទាព់មួយទាព់ក្នុងបង្គាប់បញ្ជា អរជុនលើកតាមទៅ ការសម្លាប់សេះបូជាយិជនោះ ជាការប្រកាសឥស្សរភាពជាស្តេចធំលើរដ្ឋសីមាទាំងឡាយជិតខាងជុំវិញ. ។

ប្រវេណីដូច្នេះ បើក្សត្រិយ៍អង្គឯណានីមួយក្នុងប្រទេស ជិតខាងបង្ក្រាបចាប់សេះនោះទុក ក៏ជាទីចូលចិត្តបានថាជា

អាណត្តិសញ្ញា និងប្រកាសសង្គ្រាមតទល់ ក្សត្រិយ៍នោះតោង
លើកទាព់ចេញមកច្បាំងនឹងកងទាព់ដែលតាមសេះទៅនោះ
បើក្សត្រិយ៍អ្នកម្ចាស់នគរនោះចាញ់ តោងប្រគល់កងទាព់របស់
ខ្លួនឲ្យកងទាព់សេះ ថែមកំឡាំងទាព់ឲ្យច្រើនឡើង ហើយ
លើកតទៅទៀត បើគ្មានក្សត្រិយ៍ឯណានិមួយបង្អាបចាប់សេះ
នោះទុកទេ បណ្តោយឲ្យដើរជាន់ព្រះនគរ ក៏ជាគ្រឿងសំគាល់
ថាក្សត្រិយ៍ក្នុងព្រះនគរនោះៗ ខ្លបខ្លាច ពេញចិត្តទទួលគោរព
រាប់អានក្សត្រិយ៍ម្ចាស់សេះនោះថាជាចៅហ្វាយនាយធំរបស់ខ្លួន
លុះសេះនោះត្រេចទៅសុះសព្វព្រះនគរជិតខាងហើយត្រឡប់
មកវិញ គេក៏សម្លាប់វាបូជាយិជ្ញជាពិធីដ៏សក្តិសិទ្ធ៍.

គ្រានោះជារាត្រីកាលនៃថ្ងៃពេញបូណ៌មីខែចេត្រ (គឺខែ
ចេត្រ) ដែរយុធិស្ឋិរលែងសេះសឲ្យរង្គាត់ទៅ ជាគ្រឿងសំ-
ដែងព្រះរាជបំណងរបស់ព្រះអង្គនឹងធ្វើពិធីអស្វមេធ អរជុនអ្នក
ជិតដោយពាជីទៅគ្រានោះ បានប្រទះប៉ះនឹងភ័យជាច្រើន
លើក គ្រាដំបូងបានតស៊ូគ្នានឹងព្រះរាជានៃមាលវ ដែលឃាត់
ឃុំសេះនោះទុក តែអរជុនជ្នះ ព្រះរាជាអង្គនោះក៏ជិតដោយ

តាមអរជុនទៅជាសម្ពន្ធមិត្រ កាលរង្គាត់តទៅទៀត ក៏បាន ប្រទះតស៊ូដោយអន្លើ ៗ គ្រាមួយនោះពាជីដើរចូលដាស់រាជអាណាចក្រមណីបុរ ព្រះរាជាប្រទេសនោះមិនទទួលស្គាល់ថាជាក្សត្រិយ៍ចំបង អរជុនគោងផ្ចាញ់ក្សត្រិយ៍នោះឡើតឡប់បិត្តរាប់អានជារាជសម្ពន្ធមិត្រ សេះសត្រេចចេញចាកព្រះនគរទៅត្រឡប់ដល់ព្រះនគរវិញ អស់វេលាមួយឆ្នាំពេញ រវាងនោះយុធិស្ឋិរបំពេញតបួះយ៉ាងតឹងរឹងខ្ជាប់ខ្ជួន ដូចយ៉ាងព្រះឫសីក្នុងព្រៃក្នុងមួយថ្ងៃទ្រង់សោយតែមួយពេល វៀរចាករបស់ស្រស់បំអាប និងទ្រង់ផ្ទំលើផែនដីជាប្រក្រតី

ដល់ចុងឆ្នាំ អរជុនបានត្រឡប់មកព្រះនគរវិញព្រមទាំងពាជី មានការទទួលជាឱឡារិករីករាយទូទាំងក្រុង កងទាព់មានជ័យត្រឡប់ចូលក្រុងវិញបានទទួលបដិសន្ថារៈនឹងបំណាច់រង្វាន់យ៉ាងពេញចិត្ត ក៏ស្រែកហោយកជ័យគឹកកងរំពងទាំងក្រុង

ថ្ងៃពេញបូណ៌មីខែមាឃ ជាថ្ងៃកំណត់ធ្វើពិធីអស្វមេធនៅទីដ៏សក្តិសិទ្ធមួយកន្លែង ដែលបានត្រៀមទុកអំពីមុនសំរាប់

ការនេះ បានអញ្ជើញក្សត្រិយ៍តាងប្រទេសជិតខាងមកប្រជុំក្នុងពិធីសម័យនេះ សង់ព្រះបន្លាប់ទមាសប្រាលរន្ទាលជាឧទ្យានិកសំរាប់ទទួលក្សត្រិយ៍តាងប្រទេសទាំងឡាយដែរមកកាន់ព្រះរាជសំណាក់ បារាំទាប ៗ សំរាប់ទទួលអ្នកមានបន្ទាសក្តិតូច ៗ ចុះមក ពួកជីព្រាហ្មណ៍ឲ្យនៅបារាំផ្សេង ១ តែឯង ៗ

សង់សុវណ្ណមណ្ឌបមួយខ្នង ក្នុងព្រះមហារាជវាំង រៀបទីអង្គុយទុកជុំវិញមណ្ឌបនោះ, ជីព្រាហ្មណ៍អ្នកធំអង្គុយក្បែររាជបល្ល័ង្ក, អ្នកតូចជាថានានុក្រមចុះមក អង្គុយឃ្លាតបេញទៅជាជាន់ ៗ រៀងរាយវែងបេញទៅ លើថ្នាក់ខ្ពស់ក្រាលដោយសុវណ្ណភូសា តាំងបល្ល័ង្កមាសពីរយ៉ាងធំខ្ពស់បល្ល័ង្កមួយសំរាប់មហារាជធូតរាស្ត្រ បល្ល័ង្កមួយទៀតសំរាប់ព្រះរាជាយុធិស្ឋិរ ខត្តិយនារីទាំងឡាយអង្គុយរៀងរាយតាមកន្លែងដែលកំណត់ទុកខាង ៗ រាជបល្ល័ង្ក.

កាលពួកភ្ញៀវចូលអង្គុយតាមអណ្តាប់តាមទីកន្លែងរៀបរយហើយ ក៏ផ្តើមធ្វើពិធីនោះ យុធិស្ឋិរនឹងទ្រោបទីបងបុងដោយសំពត់ផ្ទាប់គ្នាតាមបែបដែលធ្លាប់ប្រើក្នុងការរាជាភិសេក, ទ្រង់

ចុះស្រង់ទឹកព្រះគង្គាជាទឹកដ៏មានសព្វគុណស័ក្តិសិទ្ធិ៍ ហើយស្តេចចេញច្រត់ព្រះនង្គ័លដោយព្រះនង្គ័លមាសទឹមគោឈ្មោលសំបុរសមួយគូ ឯទ្រោបទីក៏យាត្រាតាមព្រះនង្គ័លព្រួសសាបបុត្តណ្ណជាតិ និងអបរណ្ណជាតិ គឺពូជធារគ្រប់ចំពូកដែលជារបរក្នុងព្រះរាជអាណាចក្រ ពួកព្រាហ្មណ៍ក៏ស្វាធ្យាយស្លោកជ័យមន្តតាមក្នុងគម្ពីរវេទ, ពួកស្រី ៗ ដែលមកក្នុងពិធីនោះក៏ច្រៀងជាបទភ្លេងទៀត.

នាកណ្តាលផ្ទៃទីបួនជ្រុងចតុរសនោះ សាងព្រះវិហារមួយខ្ពស់អំពីដីមួយហត្ថ, លើព្រះវិហារនោះមានរូបសំដែងដ៏ណែងនឹងការបរទៅនៃតារាករនឹងព្រះអាទិត្យព្រះចន្ទ្រលើផ្ទៃមេឃកណ្តាលព្រះវិហារ មានតុបួនជ្រុងតួបដាក់រំកាប់ខ្លឹមចន្ទន៍មួយគំនរ មានក្លស់មាសបើកបាំងពីលើ. គេក៏ដុតខ្លឹមចន្ទន៍នោះហើយយកប្រេងនឹងស្រូវសាលី នឹងរបស់ឯទៃ ៗ ដែលសក្តិសិទ្ធិ៍មកបង់ចុះក្នុងគំនរភ្លើងនោះ ភ្លើងក៏ឆេះរុងរោចន៍ឡើងផ្សែងហុយត្រឡប់អប់អស់ទាំងមណ្ឌលដ៏សក្តិសិទ្ធិ៍នោះ មានក្លិនក្រអូបឈ្ងុយឈ្ងប់.

ទើបព្រះមហាក្សត្រិយ៍ ព្រមដោយព្រះរាជវង្សានុវង្សដែលមកប្រជុំព្រមនៅទីនោះហុកសិបបួនអង្គ នាំគ្នាយាងជាក្បួនទៅដងទឹកអំពីស្ទឹងព្រះគង្គាមកព្រិប្រស់ព្រះសិរយុធិស្ឋិរ តាមបទភ្លេងនឹងបទសូត្រមន្ត.

ស្រេចកិច្ចនេះ ក៏ប្រគេនទេយធម៌ទក្ខិណាដល់ពួកព្រាហ្មណ៍ នឹងចែករបស់ដល់ក្សត្រិយ៍តាងប្រទេសដែលជាស្រុកបំណុះទាំងប៉ុន្មាន ជាច្រើនអង្គបានទទួលព្រះរាជទានរំយោលគ្រឿងយសរោមសត្វប្រដាប់ពេជ្របុត នឹងគ្រឿងប្រដាប់យ៉ាងដទៃ ៗ ឯអ្នកក្រៅអំពីនេះ បានទទួលព្រះរាជទានដំរីសេះឬសំពត់អាវគ្រឿងយស,

តពីនោះ ទើបយកសេះសដែលអំរុងនឹងសម្លាប់បូជាយិជនោះទៅលាងទឹកដ៏ស័ក្តិសិទ្ធ៍ហើយនាំយកមកសម្លាប់ ភីមកាន់ដាវធំចុងងរឈរបង់ដំទែងកាប់ករសេះនោះខ្ទាប់ដាច់ច្ចិល, ន័យថា ក្បាលសេះនោះអន្តរធានបាត់ទៅយ៉ាងមុកគួរអស្ចារ្យ ហើយក៏សំលេះយកសេចដ៏បរិសុទ្ធ៍បូជាភ្លើងពិធីនោះ

នៅមានពិធីយ៉ាងដទៃ ៗ តទៅទៀតដែលមិនបានពោល

ទុកដោយល្អិតក្នុងទីនេះសុំសង្ខេបសេចក្ដី ប្រាប់ទុកតែត្រឹមថា បានបដិប័ទតាមរាយល្អិតក្នុងពិធីនោះ ៗ ដែលមានប្រាកដក្នុងគម្ពីរវេទ បានធ្វើសព្វគ្រប់ទាំងអស់ជាការបង្កើតសេចក្ដីលំអរ ឬសេចក្ដីសំខាន់ដល់ពិធីនោះ ទំរាំតែរៀបចំសព្វគ្រប់ អស់វេលាជាងមួយសប្ដាហ (គឺជាងមួយអាទិត្យ) រហូតដល់ការលៀងព្រាហ្មណ៍ជាទីបំផុត កិច្ចអំបាលនេះបើវៀរបង់មិនធ្វើក៏ខូចពិធី ភីមជាភ្នាក់ងារត្រួតត្រា មីរៈប៉ែកនេះ ដែលជាការកង្វល់ធំ ច្រើនខាងឯការសួរដណ្ដាំលៀងភ្ញៀវរាប់ដោយពាន់ ៗ ដែលអង្គុយទទួលទានអាហារក្នុងមួយពេល ៗ កាលស្រេចការលៀងហើយ, ក៏ចែកប្រាក់ទក្ខិណាដល់ព្រាហ្មណ៍ទាំងឡាយរៀងខ្លួន ស្រេចភត្តកិច្ចនឹងការទទួលបច្ច័យហើយ ពួកព្រាហ្មណ៍ក៏អនុមោទនា ពួកភ្ញៀវរាប់ដោយចំនួនម៉ឺនក៏ថ្វាយសព្ទសាធុការពរទ្រហឹងអឺងកង ផ្សំគ្នាជាសំឡេងគឹកកងដូចសំឡេងលលកក្នុងមហាសមុទ្រ.

រាជអាណាចក្រហស្តិនបុរបានត្រឡប់ចំរើនរុងរឿងដោយរដ្ឋប្រសាសនោបាយកោសល្យរបស់មហារាជយុធិស្ឋិរ, សេចក្ដី

សុខ, មេត្តា, សេចក្ដីសត្យសុចរិតនឹងយុត្តិធម៌ បានត្រឡប់មានមកក្នុងព្រះរាជអាណាចក្ររបស់ព្រះអង្គ រាជមណ្ឌីរស្ថាននៅក្រុងឥន្ទ្របថដែលទ្រុតទ្រោមបាក់បែកទៅក្នុងវេលាដែលទ្រង់ត្រូវនិរទេសនោះ ក៏បានផ្លាស់ផុលករសាងឡើងវិញជាថ្មីនឹងទ្រង់សាងព្រះរាជមណ្ឌីរស្ថានបែមឡើងទៀតក្នុងទីផ្សេង ៗ

ឯព្រះបាទធ្ឫតរាស្ត្រ គ្មានវេលាស្រាកស្រាន សោករឿងមរណនៃទុរយោធន៍ដ៏ជាបិយោរសរបស់ព្រះអង្គ ទោះបីខ្លួបកាបមានសេចក្ដីខុះជាប់ខ្លួនក្ដី ក៏ជាឱរសរបស់ព្រះអង្គ យុធិស្ឋិរបានបដិបត្តិមហារាជចាស់នេះ ដោយថ្នឹតថ្នមយ៉ាងល្អដោយឋានៈជាបុត្រ នឹងដោយសេចក្ដីឧស្សាហ៍យ៉ាងទាសា, នឹងមិនធ្វើការអ្វីដោយអំពើចិត្ត ដោយមិនបានទទួលព្រះរាជានុញ្ញាតអំពីទ្រង់ជាមុនឡើយ ដើម្បីឲ្យទ្រង់អ្នកមានបុត្រព្រាត់ព្រាកបាកទៅបានសេចក្ដីសុខកាយសប្បាយចិត្តផង តែគ្មានអ្វីមកប្រែឲ្យទ្រង់បានសេចក្ដីរីករាយ ក្នុងវេលាទុក្ខដ៏ធំនេះ គ្មានអ្វីជារង្វាន់ផ្លួសសេចក្ដីខូបខាតដ៏ធំដែលទ្រង់បានទទួលក្នុងបច្ឆិមវ័យនេះបាន គ្មានអ្វីមកលើកសំរាលទុក្ខដ៏ធ្ងន់ទ្រូងនេះ

បាន ទ្រង់ឡើយណាយក្នុងលោក គ្រឿងរាជកកុធភណ្ឌ, របស់អំបាលនេះប្រាកដដូចជាស្រមោលដ៏រកខ្លឹមសារគ្មាន ព្រះហឫទ័យទ្រង់ចង់បានសេចក្ដីសុខដែលលើសលប់របស់មនុស្ស ព្រោះហេតុនោះក្នុងទីបំផុតទ្រង់ក៏ចេញចាកអំពីពពួកមនុស្ស ស្ដេចទៅនៅព្រៃជាមួយនឹងព្រះនាងគន្ធារីទេវី នឹងវិទូរអ្នកប្រាជ្ញក៏តាមស្ដេចទៅផង យុធិស្ឋិរនឹងខ្ញុំរាជការអ្នកធំជូនស្ដេចព្រះរាជដំណើរទៅដល់ចុងព្រៃធំ ហើយមហារាជក៏ត្រាស់បញ្ជូនឲ្យអ្នកទាំងនោះត្រឡប់ឋាននិវេសស្ថានវិញ នឹងត្រាស់លាដោយសុន្ទរកថាដ៏ពីរោះតទៅនេះ ។

ម្នាលកូនសំលេញអាពុក អ្នករាល់គ្នាក៏ដឹងថា អាពុកនេះដោះខ្លួនចេញអំពីទុក្ខនៃក្សត្រិយ៍ មកជាយូរឆ្នាំហើយ ដោយវៀរចាកភារៈជាព្រះរាជា ប្រគល់ឲ្យបុត្រយើងដែលចែកឋានទៅ គឺទុរយោធន៍, ឥឡូវនេះគេក៏ស្លាប់បង់ រាប់ថាផុតទុក្ខមួយលើកហើយ, វេលានេះយើងមានសេចក្ដីត្រេកអរក្នុងការនៅព្រៃវៀរចាករាជសម្បត្តិបានទុកដាក់ឲ្យនៅក្នុងអារក្ខានៃព្រះរាជនត្តា គឺយុធិស្ឋិរដែលប៉ីដូចជាបុត្ររបស់យើងម្នាក់ ខ្លួនយើងចាស់

ជាប្រៀបគណនាដូចព្រឹក្សាជាតិនៅជិតច្រាំង រមែងទ្រុត
ទ្រោមបុះដោយកាល លំបាកនឹងគ្រងកាយដ៏គ្រាំគ្រាដែល
ទៀបនឹងចូលកាន់មាត់នៃមច្ចុរាជ ប្រការ ១ ទៀតព្រះជាម្ចាស់
ហាក់មកបណ្ដាលឲ្យខូចបក្ខមកអំពីក្មេង ហេតុនោះអំពីដើម
មកយើងមានតែភ្នែកខាងក្នុងបុណ្ណោះ ជាមហាបុណ្យលាភ
ឲ្យយើងមើលឃើញសន្ដោសធម៌ជារឿយ ៗ ព្រោះហេតុនោះ
យើងឃើញគួរហើយ ដែរយើងនឹងគ្រងអាយុដែលសល់នៅ
តិចតួចនោះដោយសេចក្ដីសន្ដោស រវាងកាលដែលយើងកាន់
កាប់ព្រះនគរ បានឆ្លងដំរង់ទៅកាន់សេចក្ដីសុចរិតយុត្តិធម៌តាម
សតិបញ្ញា មានកេរ្តិ៍ឈ្មោះតិចតួចខ្លះដែរ តែមកប្រែខូច
កេរ្តិ៍ឈ្មោះទៅវិញ ព្រោះគ្រប់គ្រងផ្ដេសផ្ដាសខាងចុងក្រោយ
កូនអើយអាពុកក្រែងថាសេចក្ដីខុសនោះមានច្រើន មិនបង់ឲ្យអំ-
ពល់ដល់ចិត្តអ្នក នឹងចិត្តអាពុកតទៅ ដូចយ៉ាងក្នុងបច្ចុប្បន្ននេះ
តែហេតុការណ៍អំពាលនោះជាអតីតភាគកន្លងទៅហើយ ម្នាល
សុភាពបុរសទាំងឡាយ កិច្ចការក្នុងក្រុងអាណាចក្រវេលានេះ
យើងផ្ញើទុកក្នុងអារក្ខារបស់អ្នក ជាធុរៈរបស់អ្នកនឹងរក្សាឬនឹង

ទំលាយបេញ តែបូរបាំទុកណា ជាមរតកដ៏ប្រើនទាំងម្លេះ ដែលយើងលើកប្រគល់ឲ្យអ្នកនេះ ជាបរម្បរសម្បត្តិដ៏ត្រកាល សំរាប់ព្រះនគរដ៏ឧត្តមស័ក្តិនេះ ជាបុព្វកិច្ចខាងដើមដែលអ្នកត្រូវរក្សាទុកដោយសេចក្តីហ្មត់ហ្មែន នឹងការពារទុកដោយសេចក្តីប្រយ៉ាតប្រយែង យើងសុំពោលដាស់តឿនអ្នកក្នុងទីបំផុត គឺដរាបណា អ្នកជាម្ចាស់ផែនដីទ្រង់នៅធម៌ នឹងមានមេត្តាដល់ពពួកមនុស្សផងគ្នា ដរាបនោះ សឹកសូម្បីមានកំលាំងដូចមេ្តចក្តីក៏មិនអាចនឹងធ្វើអន្តរាយដល់សសៃសក់នៃអ្នកបាន "

យុធិស្ឋិរក្រាបបង្គំទៀបយុគលបាទនៃមហារាជដោយគោរព ទទួលពរដ៏កល់លើត្បូងហើយក៏ស្តេចត្រឡប់មកក្រុងហស្តិនបុរវិញ.

តអំពីនោះ យុធិស្ឋិរបានគ្រងរាជសម្បត្តិដំណាលសន្តតិវង្សជាសុខក្សេមក្សាន្ត នឹងល្បីល្បាយឮព្រះកិត្តិយស សំដែងព្រះអង្គត្រង់ដែតត្រដឹមឲ្យលោកឃើញជាប្រាកដ ថាជាអ្នកគ្រងរាជ្យដោយយុត្តិធម៌ នឹងប្រកបដោយមេត្តាជាបុរេចារិក អ្នកនគរនាំគ្នាជ្រះថ្លាស្រឡាញ់អស់អញ្ញភក្តិ នឹងគោរពកោតក្រែង

ព្រះបេស្កាជាអាចិណ្ណ, រាជសត្រូវស្ងប់ស្ងៀងក្រែងព្រះតេជានុ-ភាព, អ្នកប្រទេសជិតខាងនាំគ្នារាប់អាន ព្រះឥរិយាបថខាងក្រៅប្រព្រឹត្តទៅតាមយសសក្តិ និងដំណែងនៃក្សត្រិយ៍ក៏ពិត តែខាងក្នុងព្រះហឫទ័យយុធិស្ឋិរបំណាង់សេចក្តីសង្វេស សព្វព្រះហឫទ័យតែក្នុងការនៅព្រៃ ទ្រង់គិតហើយគិតទៀតដល់កាល ១៣ ឆ្នាំ ដែលទ្រង់បានបដិប័ទឲ្យកន្លងទៅ ដោយឋានៈជាអ្នកត្រូវនិរទេសគ្មានទីសំណាក់អាស្រ័យ អារញ្ញប្រទេសដែនដងព្រៃម្លប់ត្រឈៃត្រជាក់សាយសព្វឥន្ទ្រីយ៍មានអាកាសធាតុបរិសុទ្ធ ជាទីឲ្យល្ហែល្ហើយស្បើយស្រួលក្នុងឧរា, ចិញ្ចឹមជីវិតដោយផ្លែឈើមើមឈើយ៉ាងអារញ្ញិកសត្វ សេចក្តីសុខ និងសេចក្តីស្ងាត់ គ្មានអ្នកណាមករំអុកបិត្តឲ្យបង្អៀតបង្អល់ ដែលទ្រង់បានសេពក្នុងរវាង ១៣ ឆ្នាំនោះទ្រង់នាំយកមកផ្ទៀបក្នុងបច្ចុប្បន្ននេះជាញយៗ ទ្រង់ព្រះចិន្តាឃើញថា ជាវេលាសុខសប្បាយជាបំផុតក្នុងអាយុកាល, មិនមែនជាទ្រង់នឹងភ្លេចរឿងទុក្ខសោកដល់ពពួកព្រះញាតិដែលត្រូវពិឃាតស្លាប់ក្នុងសង្គ្រាមនោះក៏ទេ, ទ្រង់សោកគ្មានល្ហែរដល់វិញ្ញាណដែលព្រាត់ព្រាក

ទៅទាំងកំពុងស្រឡាញ់ពេញចិត្តនោះដល់មួយវេលា បើប្រ-
សិនជាមិនកើតបំបាំងរាំងដល់គង់ជានឹងបានឃើញមុខព្រះញាតិ
នៅរហង់ជុំវិញព្រះអង្គត្រៀបត្រា ធ្វើឲ្យអាគារស្ថាននឹងអាណា
ចក្រអធិកអាធំឈ្មោះធរជាទីសប្បាយរីករាយ ទុក្ខថ្មីសោតក៏ផ្ទុក
ផ្ទួនធ្ងនត្រួតមកទៀតផុតវិស័យនឹងធ្លាក់ធ្លៀតឲ្យស្រស់ស្រាល
ដោយក្រោយព្រះបាទធ្ឫតរាស្ត្រចាកទៅពីរឆ្នាំ នារទអ្នកប្រាជ្ញ
នាំពណ៌ដំមានមកក្រាបទូលថាភ្លើងឆេះព្រៃ, ព្រះបាទធ្ឫតរាស្ត្រ
ទ្រង់ព្រះជរាព្រះនេត្រអន្ធការ នឹងព្រះនាងគន្ធារី ព្រមដោយ
អ្នកនៅជាមួយស្ដេច ត្រូវភ្លើងព្រៃរោលស្លាប់អស់, មុខគូអនិច្ចា
អីម្លេះ អ្នកធ្វើសង្គ្រាមក៏ស្លាប់ក្នុងសង្គ្រាម អ្នកមិនធ្វើសង្គ្រាម
ក៏ស្លាប់ក្រៅសង្គ្រាម.

តពីពណ៌ដំមាននេះ នៅមានពណ៌ដំមានថ្មីមកទៀត
គឺមានរាជទូតនាំពណ៌ដំមានមកអំពីក្រុងទ្វារកៈមកក្រាបទូល
ថា ក្រិស្ណឲ្យអញ្ជើញអរជុនទៅឯក្រុងទ្វារកៈជាធាប់ អរជុន
ក៏ប្រញាប់ប្រញាល់ទៅឯក្រុងទ្វារកៈតែមុននឹងទៅដល់ ក្រិស្ណ
ក៏ទទួលទិវង្គតបង់ អរជុនទៅដល់នឹងត្រឡប់មកវិញភ្លាមមិន

បាន តោងនៅមើលចាត់ការឈាបនកិច្ចសពព្រះរាជសម្ពន្ធមិត្រដ៏ស្និទ្ធរបស់ទ្រង់ឡស្រែបសិន ព្រះពរបរាមជាព្រះអនុជនៃក្រិស្ណ ក៏សុគតទៅតាមក្រិស្ណប្រទាន់ៗគ្នា, ព្រះបាទវាសុទេពព្រះរាជបិតាក្រិស្ណ ក៏សុគតក្រោយនោះតៗគ្នាទៅ មិនតែបុណ្ណោះក្នុងកាលអិនយូរប៉ុន្មាន អំពីវេលាដែលអរជុនត្រឡប់អំពីក្រុងទ្វារកៈមកហើយ ទឹកសមុទ្រជោជន់ឡើងមកលិចក្រុងនោះ ស្រុកមាត់កំពង់មានទឹកពាត់ជុំវិញ របស់វង្សយាទវក៏លិចអន្តរធានអស់ទៅ,

កាលអរជុនតាំពណាំដមានមរណៈនៃក្រិស្ណ និងសេចក្ដីវិនាសសាប់សូណ្យនៃយាទវអាណាប់ក្រ មកក្រាបទូលនោះ, សេចក្ដីសោកសៅរបស់យុធិស្ឋិរតទ្វេយ៉ាងធ្ងន់រកទីបំផុតគ្មាន; វិតរូតព្រះហ្វទ័យងឹតឈឹង គ្មានអ្វីមកកំចាត់ឲ្យប្រាសចាកទៅបាន ទ្រង់នឿយណាយដល់សេចស្បែករាងកាយ ដ៏ជាភារៈដ៏ទម្ងន់, មានព្រះរាជបំណងតែនឹងលះគ្រឿងវិតរូតទាំងនេះនឹងលះជីវិតដែលជាគ្រឿងកង្វល់ធំនេះចេញ ទ្រង់មានព្រះហ្វទ័យមមៃនឹកគ្មានដេបមួយវេលា ទ្រង់នឹកសង្ស័មព្រះអនុជ

ទាំងបួនអង្គ នឹងទុកដាក់ឲ្យជាអ្នកជំណាងព្រះអង្គតទៅ ហើយនឹងបានអនុម័តិអំពីព្រះអនុជទៅនៅព្រៃយាងបព្វជិតប្រព្រឹត្តវត្ត, ហ្វាំងកាលឲ្យកន្លងទៅដោយការបំរើនភាវនា ព្រះអនុជទាំងបួនក៏អនុម័តិអនុមោទនាតាមព្រះរាជប្រារព្ធ តែព្រះអនុជទាំងបួនក៏មានបំណងដូចគ្នានឹងទ្រង់, កើតធ្ងើយណាយក្នុងរាងកាយនឹងសេចក្តីលំបាកនៃជីវិត ចង់ស្វែងរកតែសេចក្តីសុខសំរាកកាយឲ្យសប្បាយ ទើបត្រៀមខ្លួនព្រមនឹងតាមស្តេចទៅនៅព្រៃ ដោយគ្មានអាលោះអាល័យនឹងសម្បត្តិសម្បូណ៌ធូបាយទាំងនោះឡើយ,

យុធិស្ឋិរ ក៏បែងរាជអាណាចក្រហស្តិនបុរជាពីរភាគ មួយភាគទ្រង់លើកឲ្យបរិក្សិតបុត្រអភិមន្យុប្រសូតក្រោយមរណៈនៃអភិមន្យុ, ទ្រង់អភិសេកឲ្យជាក្សត្រគ្រងពិភពហស្តិនបុរ មួយភាគទៀតប្រទានឲ្យយុយុត្សុ ជាបុត្របួនទុរយោធន៍ ទ្រង់អភិ-សេកឲ្យជាព្រះរាជាគ្រងក្រុងឥន្ទ្របថនឹងទ្រង់ប្រទានឱវាទផ្តាំប្រ-ដៅក្សត្រិយ៍ទាំងពីរអង្គឲ្យរក្សាសន្តិភាព នឹងសម្ពន្ធមេត្រី.

គ្រានោះក្សត្រិយ៍បាណ្ឌវក៏ដោះគ្រឿងសម្រាប់ក្សត្រិយ៍

បេញបាកអង្គ លះគ្រឿងមាសពេជ្រនឹងអាវុធយុទ្ធភណ្ឌ ទ្រង់ភោគបព្វជិតតាមសម័យ នាំយកទាំងព្រះនាងទ្រោបទីទៅផង បេញដើរឆ្ពោះទៅកាន់ព្រៃ មានទាំងសុវានសត្វ (ឆ្កែ) ស្មោះត្រង់នឹងម្ចាស់មួយតាមទៅផង ដែរវាមិនព្រមឲ្យបោលវានៅក្នុងព្រះរាជវាំង ទ្រង់យាងឆ្ពោះទៅទិសបូពា. មួយថ្ងៃហើយមួយថ្ងៃទៀត មួយអាទិត្យហើយមួយអាទិត្យទៀត ស្ដេចព្រះរាជដំណើរទៅក្នុងព្រៃធំងងឹត ជួនកាលក៏ត្រូវដើរកាត់វាលត្រូវកំដៅថ្ងៃរហេមរហាម ដូចអណ្ដើកចូលភ្លើង ជួនកាល ត្រូវធ្លងស្ទឹងដែរមានមកទទឹងមុខក្នុងរវាង ៗ ទ្រង់បោលសំបុកសម្បត្តិទៅដោយតាំងចិត្តថានឹងមិនត្រឡប់វិលវិញ នាំគ្នារត់បោលគ្រឿងកង្វល់នឹងសេចក្ដីនឿយណាយនៃជីវិត ការលំបាកតោកយ៉ាកៈទៅតាមផ្លូវ ការក្រវីល់ក្រវាយដោយសេចក្ដីស្រេកឃ្លានមុខគួរជាទីកើតទុក្ខវេទនា គាតោះទ្រង់ទទួលទុក្ខវេទនានោះដោយតុណ្ហីភាព គឺតរុញ្ញា ធ្វើទៅទាំងនេះដោយបំណងដើម្បីនឹងឲ្យផុតគ្រឿងរួតរឹតជីវិត

កាលកន្លងទៅមិនយូរប៉ុន្មានថ្ងៃ នាងទ្រោបទីជាអ្នកកំ-

ឈាំងតិចជាងគេក្នុងពួកនោះ ក៏ដួលតាមផ្លូវ ដេចខ្យល់ស្លាប់ដោយមហាទុក្ខដួចពោលហើយ គ្មានការយំយែកជាការសំដែងសេចក្ដីអាលោះអាល័យឡើយនាង សំរាប់ខ្លួននាងរាប់ថា អស់ទុក្ខសោក អស់ភិតភ័យមួយពេលហើយ, ឈ្មោះថាផុតចាកសេចក្ដីជាទំនែជីវិត អស់កង្វល់មួយគ្រាហើយ, កាលទ្រាបទីស្លាប់ទៅភីមទូលសួរយុធិស្ឋិរថា "ហេតុអ្វីទ្រាបទីទើបស្លាប់? ហេតុម្ដេចនាងមិនឡើងឋានសួគ៌ទាំងរស់, នាងបានប្រព្រឹត្តអកុសលកម្មអ្វីទើបមកទទួលមរណកម្មកណ្ដាលផ្លូវព្រៃដូច្នេះ.

បណ្ហាអំបាលនេះ មិនបានពោលក្នុងទំនងនៃអ្នកសោយទុក្ខវេទនា, ពោលក្នុងទំនងនៃផ្លូវធម្មបណ្ហា យុធិស្ឋិរតបថា "ហ្ឫទ័យរបស់នាង នឹងជីវិតរបស់នាង រួមជាមួយគ្នានឹងអរជុន, កាលអជុនប្រព្រឹត្តកន្លងអកុសលកម៌ហើយ, នាងក៏បានកន្លងអកុសលកម៌ផងដែរ នាងទើបបានទទួលផលនៃអកុសលកម៌ដូច្នេះ.

ក្រោយនោះមក បងប្អូនភ្លោះ ១ គូគឺនកុល នឹងសហទេពដួលដេចខ្យល់ស្លាប់តាមផ្លូវ អ្នកដែលសល់នៅក៏នាំគ្នាដើរផ្លូវត

ហាក់បីដូចជាមិនដឹងជាមានហេតុអ្វីកើតឡើង, បីដូចជាបាន កំណត់ការទុកជាស្រេចមកអំពីដើមហើយ,

តមកអរជុនក៏ស្លាប់ទៅទៀត ភីមឲ្យមានសេចក្ដីរន្ធត់នឹង ស្រៀវក្នុងហឫទ័យឡើងខ្លះបន្តិចបន្តួច ទើបទូលសួរយុធិស្ឋិរថា ហេតុម្ដេចអរជុនអ្នកគ្មានខុះ ក៏មកបានទទួលវិបាកនៃបាប គឺ មរណ,

យុធិស្ឋិរតបថា "ព្រោះហេតុគ្រាមួយនោះ អរជុនបាន អួតប៉ំដៃហួសប្រមាណថា ខ្លួននឹងប្រហារសឹករបស់ខ្លួនឲ្យរាប អបរាជ័យទៅ ដោយការវាយតែម្ដង រឿងនេះអរជុនមិនអាច នឹងធ្វើឲ្យសំរេចបាន សំដីដែលអួតនោះក្លាយទៅជាមុសា វាទ មុសាវាទនោះជាបាបផលនៃបាបក៏គឺមរណ,

ភីមនឹងយុធិស្ឋិរតែពីរអង្គប៉ុណ្ណោះ ដែររស់នៅក្នុងវេលា នេះ ទ្រង់នាំគ្នាដើរផ្លូវតទៅ ដើរស្ងាត់ស្ងៀមគ្មាននិយាយសន្ទនា គ្នា, សុវានសត្វនោះក៏ជិតដោយតាមទៅដូចអំពីដើម ថ្ងៃមួយ នោះ ភីមទ្រាំសេចក្ដីនឿយលំបាកមិនបាន ក៏ដួលដេចខ្យល់ ស្លាប់ទៅទៀត តែវេលាហាបហោប ៗ នោះបានទូលសួរយុធិ

ស្អិរថា " ទ្រង់ជ្រាបបានឬទេថា ព្រោះអកុសលកម៌អ្វី ទូលបង្គំណាទើបមកប្រសព្វមរណភ្នុងវេលានេះ"

យុធិស្ឋិរតបថា "អ្នកបានធ្វើអំពើបាបក្នុងផ្លូវកាយទ្វារ និងក្នុងផ្លូវវចីទ្វារ. អ្នកប្រឡាក់ប្រឡូសទៅដោយនិស្ស័យជាអ្នកត្រេកអរស្ងួរោះដេរពោលអ្នកដទៃ. លោភអាហារនិងពោលអួតខ្លួន"

ក្នុងវេលានេះសល់នៅតែយុធិស្ឋិរមួយអង្គ ស្ដេចយាងសន្សឹម ៗ តទៅ គ្មានគ្នីគ្នានិងសន្ធាជាពីរ មានតែសុន័ខ ១ ជាភឿនតាមទៅក្នុងដែនដងព្រៃ យូរថ្ងៃទើបស្ដេចដល់មេរុបរពតខណៈទៅដល់ឮសំឡេងព្រះឥន្ទ្រស្រែកប្រាប់ថា "ឡើងកាន់ឋានសួគ៌. ក្សត្រិយ៍ទ្រង់ធម៌ តែយុធិស្ឋិរតបថា "មិនបាន, ខ្ញុំទៅតែម្នាក់ឯងមិនបាន, ប្អូនឲ្យប្អូនខ្ញុំនិងនាងទ្រោបទី ដែរខ្ញុំបោះបង់បោលតាមផ្លូវនោះទៅផង, គេទាំងនោះជាអ្នកមានសប្ធូ និងមានយសសក្ដិខ្ពស់ក្នុងជីវិតរបស់គេដូចគ្នានិងខ្ញុំ, ប្អូនស្ដាប់ខ្ញុំព្រះឥន្ទ្រអើយ, ប្អូនឲ្យសំរេចតាមពាក្យអង្វររបស់ខ្ញុំ"

ព្រះឥន្ទ្រតបពីលើមកថា "បងប្អូននិងរាជិនីរបស់ទ្រង់

ឡើងមកមុនទ្រង់ហើយ" យុធិស្ធិរតសេចក្ដីថា "បើដូច្នោះ សោត សុំអនុញ្ញាតឲ្យសុន័ខកំសត់របស់ខ្ញុំឡើងទៅកាន់ឋានសួគ៌ផង ព្រោះវាបានដើតដោយតាមខ្ញុំមក រហូតជីវិតរបស់វា" ព្រះឥន្ទ្រមានទេវឱង្ការថា ឋានសួគ៌មិនមែនជាឋានសំរាប់សត្វលាមកនឹងឡើងបាន យុធិស្ធិរអង្វរថា ទ្រង់នឹងសប្បាយក្រៃយ មិនបាន ដោយសុន័ខនោះឡើងទៅផងមិនបាន ព្រោះហេតុអ្វី ព្រោះហេតុថាវាជាសត្វស្លូតត្រង់ហើយភក្ដីនឹងខ្ញុំជាបំផុត បានតាមមកជាភឿនកំសត់រហូតជីវិតរបស់វា.

ព្រះឥន្ទតប "ទ្រង់បានលះព្រះអនុជនឹងមហេសីរបស់ទ្រង់ក្នុងគ្រាដើរផ្លូវ អស់ដើងស្លាប់កណ្ដាលផ្លូវមួយម្ដង ៗ នោះ ដោយគ្មានអាលោះអាល័យដល់គេ ហេតុម្ដេចក៏លះសុន័ខលាមកនេះមិនបានហ្ន៎ះ .

យុធិស្ធិរ អធិប្បាយថា "ខ្ញុំគ្មានប្រាថ្នានឹងលះបង់អ្នកដែលស្លាប់ទៅទាំងនោះសោះ តែអ្នកអំបាលនោះ នឹងត្រឡប់រស់មកវិញមិនបាន ក៏តោងលះបង់គេដើរហោលមក ដោយវាល់ប្រាជ្ញានឹងគិតកែខែតទៅ ទើបឯសត្វនេះវាកំពង់មានជីវិត

រស់នៅឡើយ សឹងដេកនៅខាងខ្ញុំនេះ ហេតុនោះខ្ញុំនឹងកាត់ចិត្តលះបង់ចោលវាម្ដេចបាន"

ត្រាស់ដូច្នោះហើយ យុធិស្ឋិរក៏ងាកទៅមើលសុនខនោះ តែវាបាត់ទៅហើយ. ព្រះធម្មទេព (ទេវតាអ្នករក្សានោយុត្តិធម៌) គឺព្រះឥន្ទ្រទៅឈរត្រង់កន្លែងសុនខនោះហើយត្រាស់នឹងយុធិស្ឋិរថា យុធិស្ឋិរ អ្នកជាបុត្ររបស់យើង, អ្នកជាបុត្ររបស់យើងជាអ្នកមានសច្ចរហូតដ៏វិតរបស់អ្នក ទៀងទាត់មិនដែលឃ្លៀងឃ្លាត អ្នកមិនព្រមលះបង់ចោលយើងដែលជាសុនខរបស់អ្នក ដោយព្រោះថាយើងជាអ្នកមានសត្យសុចរិតស្ម័គ្រត្រង់នឹងអ្នក, អ្នកឯងរកទីប្រៀបគ្មានក្នុងសកលលោក.

គ្រានោះព្រះចោមអមរិន្ទ្រក៏នាំយុធិស្ឋិរឡើងកាន់ឋានសួគ៌ទាំងរស់ កាលទ្រង់ទៅដល់ឃើញទុរយោធន៍គង់លើរាជបល្ល័ង្ករុងរឿងប្រាលរន្ទាល មានពួកក្សត្រិយ៍ក្សអ្នកធំ ៗ ដែលត្រូវអាវុធស្លាប់ក្នុងសង្គ្រាមគ្រានោះ ឈរអមជុំវិញរាជបល្ល័ង្ក ទ្រង់ទតរូបនោះដោយសេចក្ដីអស្ចារ្យ ហើយទតរៀង ៗ តទៅទៀតមិនប្រទះឃើញព្រះអនុជ នឹងនាងទ្រោបទីរបស់ព្រះអង្គនៅក្នុង

កំឡុងនោះ ទ្រង់នឹកពិពិលធ្ងល់ចិត្ត ព្រះឥន្ទ្រទ្រង់ជ្រាបភារៈចិត្តយុធិស្ឋិរហើយត្រាស់ថា អ្នកធ្ងល់ឬថា ហេតុម្តេចទើបមិនបានប្រទះឃើញព្រះអនុជនឹងមហេសីក្នុងទេវលោកនេះ ល្អហើយ យើងនឹងប្រាប់អ្នកឯងឲ្យភ្លឺថា គេជាសត្វបាប កាលបើដូច្នោះគេនឹងឡើងមកក្នុងទីនេះមិនបានជាដេបខាត វេលានេះនៅក្នុងទីដទៃនៅឡើយ អ្នកតោងនៅឆ្ងាយអំពីគេ, តោងសោយសុខនៅស្ថានសួគ៌សំរាប់ខ្លួនអ្នកតែម្នាក់ឯង, ចោលអ្នកអំបាលនោះឲ្យនៅរងកម៌ទ្រាំទុក្ខវេទនាដែលគេនឹងគប្បីទទួលតាមយថាកម៌របស់គេចុះ.

តែយុធិស្ឋិរមិនបានអើរងនឹងនៅឆ្ងាយអំពីព្រះរាជភាតានឹងមហេសី ក្នុងសំណាក់នៃព្រះឥន្ទ្រដ៏ជាស្ថានបរមសុខនេះ ទើបទូលទាស់ថា "ខ្ញុំនឹងទៅជាមួយពួកកោរពក្នុងឋានសួគ៌នេះមិនបាន" ខ្ញុំចង់នៅរួមបងប្អូននឹងមហេសីរបស់ខ្ញុំជាង គេនឹងនៅឯណាក៏តាម ខ្ញុំនឹងចោលគេអ្នកមានក្តីស្នេហាចងជាប់ជានិច្ចដោយបើញសុខចំពោះខ្លួននោះមិនបាន"

ព្រះឥន្ទ្រមានទេវឱង្ការសួរដោយក្រោធថា អ្នកឯងត្រៀមខ្លួនស្រេចហើយឬ ដែលនឹងទៅនៅរងទុក្ខក្នុងនិរយាបាយ ព្រោះក្ដីស្នេហាដល់គេទាំងឡាយ យុធិស្ឋិរតបថា "សេចក្ដីស្រឡាញ់នេះឯងនឹងបណ្ដាលសហាសកម៉អំបាលនោះដែលគេកំពុងសោយ ឲ្យត្រឡប់ជាបរមសុខ សុំឲ្យខ្ញុំទៅឯទីដែលបងប្អូនខ្ញុំនៅ ដែលទ្រោបទីនៅ ខ្ញុំនឹងលះគេម្ដេចបាន"

គ្រានោះព្រះឥន្ទ្រត្រាស់បញ្ជាឲ្យទេពបរិវារមួយអង្គ នាំយុធិស្ឋិរទៅកាន់ទីសំណាក់វិញ្ញាណនៃក្សត្រិយ៍បាណ្ឌវ ទេវទូតនោះនាំយុធិស្ឋិរទៅកាន់ស្រុកក្រោមព្រះធរណី ដ៏ឆ្ងាយសែនឆ្ងាយ ដ៏ជ្រៅនឹងជ្រៅចុះទៅតាមលំដាប់ ទីនោះអាកាសងងឹតសូន្យសុង អាកាសពេញទៅដោយផ្សែងផ្សារ សត្វដែលមានខ្យល់ប្រាណ នឹងដកដង្ហើមចេញចូលមិនស្រួលបេះតែឈ្លក់ផ្លូវធ្លាក្រាលរាយទៅដោយរងើកភ្លើង មានរលាក្បាលខ្មោចរៀបរៀងរាយជាកំពែងខេត្តខ័ណ្ឌ រលាក្បាលខ្មោចប្រែតអំបាលនោះ ស្រែកថ្ងូរហឺតាមសព្វជាតិនៃប្រែតវិស័យ នៅទីកណ្ដាលភូមិមានរណ្ដៅធំមុះហិមា ឆេះសន្ធោ ហើយក្នុងរណ្ដៅភ្លើងនោះ

ក្សត្រិយ៍បាណ្ឌុវភាតានឹងទ្រោបទីកំពុងសោយវិបាក បំរាសន-
គៀលរន្ធះរន្ធែងស្រែកទ្រហោទ្រហឹងដោយសេចក្ដីឈឺចាប់ពោល
វាល ដោយអំណាចនៃភ្លើងអវិចីដែលឆេះមិនបេះរលត់នោះ

យុធិស្ឋិរឃើញអាការដូច្នោះ ក៏ភ្ញាក់ព្រឺតហើយថយ
ក្រោយឃ្លាតចេញទៅ ដោយភិតភ័យ ខណៈនោះទ្រង់បាន
ឮសំឡេងព្រះអនុជនឹងទ្រោបទីស្រែកអង្វរ សុំឲ្យទ្រង់ឈប់
មួយស្របក់សិន ព្រោះថាដែលទ្រង់មកនៅ ៗ ទីនោះធ្វើឲ្យ
គេបានសេចក្ដីសុខ ស្បើយទុក្ខស្រាកស្រាន់គ្រាន់បើ យុធិស្ឋិរ
ស្ដាប់មានសេចក្ដីខ្លាចភ្លើងនរកនោះជាពន្លឹក ក្រែងទ្រង់នឹងត្រូវ
ទទួលយ៉ាងគេដែលទ្រង់ឃើញក្នុងវេលានោះ តែដោយអំណាច
មេត្តាចិត្តទ្រង់នឹងចៀសចោលគេអំបាលនោះមិនបាន ត្រាស់
ស្ដេចទៅកំដរសត្វនរកអំបាលនោះ ឲ្យបានស្រាន់ស្រាលទុក្ខ
មួយគ្រាសិន, ហើយទ្រង់ក៏បណ្ដាញទេវទូតអ្នកនាំផ្លូវនោះថា
អ្នកចៀសអំពីខ្ញុំបានហើយក្នុងកាលឥឡូវនេះខ្ញុំនឹងនៅក្នុងទីនេះ
សិន ដើម្បីនឹងរំងាប់ទុក្ខផ្សារខ្លោចបងប្អូននឹងប្រពន្ធខ្ញុំ"

ក្នុងមួយរំពេចនោះ ការផ្លាស់ប្រែយ៉ាងអស្ចារ្យបានកើតឡើង ប្រែរូបដើមចេញបាត់អស់ មនុស្សទាំងលោកបើបានឃើញហើយ ស្ទើនឹងមិនជឿភ្នែករបស់ខ្លួនៈ ទីដែលងងឹតស្ងួតស្ងុង នឹងទីដែលសត្វលោភយមបាលរិបាក ក៏ត្រឡប់ជាភ្លឺស្វាងរងរឿង នឹងជាទីសុខស្រណុកសប្បាយពន់ប្រមាណ.

ឯភូមិនរកដែលយុធិស្ឋិរឃើញដោយព្រះនេត្ររបស់ទ្រង់ក្នុងមួយរំពេចនោះ គ្រាន់តែជាស្រមោលដែលព្រះឥន្ទ្រនិរមិត្របណ្តាលឲ្យឃើញ ដើម្បីពិសោធ្យសេចក្តីសត្យ នឹងសេចក្តីមេត្តាស្រឡាញ់របស់ទ្រង់ កាលសេចក្តីសត្យនឹងមេត្តារបស់ទ្រង់ផ្ទះការពិសោធ្យយ៉ាងពន្លឹកនោះហើយទេវតាក៏នាំទ្រង់ទៅឯទឹកព្រះគង្គា សិងហ្សូរដោយដងស្ទឹងនៅលើឋានសួគ៌ ជាទឹកមានអានុភាពដ៏សក្តិសិទ្ធ ឲ្យទ្រង់ស្រង់ទឹកនោះ ដោយអានុភាពនៃទឹកព្រះគង្គាដ៏សក្តិសិទ្ធផុតឆាប់នេះ ព្រះវរកាយនៃយុធិស្ឋិរក៏ក្លាយទៅជាទេវសភាពទិព្យរូប កាលក្លាយទៅជាទេវតាហើយទ្រង់បានអនុញ្ញាតឲ្យនៅក្នុងឋានសួគ៌ជាន់ខ្ពស់ ព្រះក្រិស្ណជា

ព្រះរាជសម្ពន្ធមិត្តរបស់ទ្រង់សឹងឡើងទៅឧបត្តិមុន ក៏ធ្វើបដិ. សន្ថារះទទាក់ទទូលទ្រង់ដោយរីករាយ.

ព្រះក្រិស្ណនោះ មានរស្មីភ្លឺផ្លេករុងរឿងជាបំផុតគ្របលើរបស់ទាំងពួង ដែលរុងរឿងក្នុងលោក សឹងភ្នែករបស់មនុស្សមិនដែលឃើញអំពីកាលណាមក គ្រានោះយុធិស្ឋិរបានឃើញព្រះអនុជទាំង ៤ អង្គព្រមទាំងទ្រោបទីរបស់ទ្រង់ នឹងបណ្តាអ្នកដែលទ្រង់ស្រឡាញ់រាប់អានកាលនៅក្នុងមនុស្សលោកនេះផង ។៚

សិទ្ធិរស្តុ (ចប់)

ÉCOLE FRANÇAISE
BIBLIOTHÈQUE